ធម្ម្ជលសុទិយា

ក្រុមបិត្តំគំនៀមធម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា គឹងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែមករា លេខ ១

ព.ស. ២៤៩៣ – គ.ស. ១៩៤៤

LIBRARY
HIST INSTITUTE



ភ្នាម្ពាសទិយា

ទស្សនាវិដ្ឋី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ
ប្រោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

	មាត្ថីរៀង	**ទំព័រ**
ផ្នែកសាសនា		
— សង្ខិតន័យពីប្រវត្តិព្រះពុទ្ធសាសនា នៅ ប្រទេសកម្ពុជា នាអតីតកាល	ក្រុមដំនុំទំនៀមទម្លាប់ខ្មែរ	៨
— សីលធម៌	ឃុនបណ្ណានុវ៉ក្ស ប៊ូ - ប៊ូ	៦៦
— បញ្ញាសជាតក ភាគទី ៣ (តមក)	ប ណ្ឌិតមហា ឈឹម -ស៊ុម	៨៦
ផ្នែកអក្សរសាស្ត្រ		
— រឿងសៅរសោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង—ប៉ម ...	៥៨
— រឿងសាមកុក (តមក)	ឧកញ៉ា ឆូ- កន	៥៩
— ដំណឹងតាមឧ្យល់ក្នុងកន្ទារ: (តមក) ...	លោក ផេង - ជ្រីវ	៦៣
— រឿងបល្ស៍ង្គទិព្យ (តមក)	លោកវ៉ាយ- ប៊ុក	៣៣
កំណត់ទឹងប្រវត្តិការណ៍		
— បញ្ជីរាយនាមបៅអធិការដែលតាំងថ្មី ...	(តមក) ក្រសួងធម្មការ	៣៩

មួយឆ្នាំមាន ១៦ ស្យែវិភៅ — ដំឡៃជាវិ ៦១០រ.០០

KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: Page

— Aperçu sur l'histoire du Boud-
dhisme au cambodge . . . . Commission des Moeurs et coutumes 8

— Siladharma . . . . . M. BOU-PO 22

— Pannasajataka- vol. 3 (suite) . M. CHHIM-SOUM 42

PARTIE LITTERAIRE:

— Le «SAU SOY» ou l'influence
saturnienne (suite) . . . . . vén. PEUNG-PAM 54

— Histoire de samkok (suite) . . oknha NOU-KAN 59

— Le souffle du désert (suite) . . M. PHENG-CHRIV 67

— des trente deux récits du trone
(suite) . . . . . M. RAY-BUC 73

NOTES ET CHRONIQUES:

— Nomination des nouveaux chau-
Adhikar (suite) . . . . . Ministère des Cultes . . . 79

Prix d'abonnement annuel (comprenant 12 numéros) 210$00

វិចារណាកថា

នយោបាយ ជាគុណជាតសម្រាប់ពិភពលោកខាងផ្លូវសម្ការៈ, សាសនា ជាគុណជាតិសម្រាប់ពិភពលោកខាងផ្លូវចិត្ត ។ នយោបាយ ជាកង់ម្ខាងសម្រាប់រៀបចំប្រទេស ហៅថា អាណាចក្រ, សាសនា ជាកង់ម្ខាងសម្រាប់អប់រំចិត្តប្រជាជន ហៅថា សាសនចក្រ ឬធម្មចក្រ ។ ធម្មតារថ ឬរទេះ លុះតែកង់ទាំងធ្វេងស្តាំរិលស្មើគ្នា មិនរអាក់រអួលទើបលឿនទៅបាន, ប្រទេសនីមួយៗក៏ដូចគ្នា លុះតែអាណាចក្រ នឹងធម្មចក្រ ដែលទុកដូចកង់ទាំងពីរិលស្មើគ្នា មិនងាស់ មិនតាំងម្ខាងៗ ទើបលឿនទៅរកសេចក្តីសុខសេចក្តីចម្រើន ដោយសន្តិភាពបាន ។

ហេតុដូច្នេះ, បានជាប្រទេសទាំងពួងក្នុងសាកលលោក តែងបង្កើតវិជ្ជាហានខាងអាណាចក្រសម្រាប់បង្រៀនខាងផ្លូវនយោបាយរៀបចំប្រទេស, ខាងធម្មចក្រសម្រាប់បង្រៀនអប់រំប្រជាជនខាងផ្លូវចិត្ត ដើម្បីឲ្យបានហានៈជាអារ្យជន អារ្យប្រទេស ។

រាជរដ្ឋាភិបាលយើង បានជ្រាបការណ៍នេះ ទើបបានបង្កើតវិជ្ជាហានពុទ្ធសាសនបណ្ឌិត្យឡើង ប្រតិស្ឋានកណ្ណាលព្រះរាជធានី ភ្នំពេញ ។ វិជ្ជាហាននេះ បានចាត់ការរៀបរៀងនឹងរៀបចំបោះពុម្ពផ្សាយ នូវសៀវភៅធម៌អាថិក្សួនច្បាប់ផ្សេងៗ ដែលទាក់ទងដោយវិជ្ជាខាងព្រះពុទ្ធសាសនានឹងខាងអក្សរសាស្ត្រ ព្រមទាំងបានផ្សាយចេញនូវទស្សនាវដ្ឋីមួយ

មាននាមថា ទស្សនាវដ្ឋីកម្ពុជសុរិយា ដែលលោក - អ្នកកំពុង អាននេះ ។

យើងសូមផ្ទើបទពិចារណាចំពោះទស្សនាវដ្ឋីនេះ ដូចតទៅ :

ក)- ទស្សនាវដ្ឋីកម្ពុជសុរិយា ប្រែថា "សៀវភៅបេញរាយ សម្រាប់អានវិលវង់តាមកាលកំណត់ ដូចព្រះអាទិត្យវិលបំភ្លឺ ប្រជាជនកម្ពុជា" ។ ធម្មតាសៀវភៅដែលហៅថាទស្សនាវដ្ឋី គ តែងតែចុះអត្ថបទលាយចម្រុះ សម្រាប់អានតឿ្យតសេចក្ដីគ្នាជាហូរហែ តាមលំដាប់ថ្ងៃ-ខែ-ឆ្នាំ ដែលគេកំណត់ទុកហើយ សេដៀងគ្នានឹង សាព័ត៌មាន, អត្ថបទខ្ទីៗ ដែលល្មមចុះមួយសៀវភៅចប់ក៏ចុះចម្រុះគ្នាឲ្យ ចប់ៗទៅ, អត្ថបទវែងៗ ចុះមួយសៀវភៅមិនចប់ ដោយលៃទំព័រទុកចុះ អត្ថបទឯទៀតផង ក៏ចុះតៗ ទៅជាប្រើនសៀវភៅ ត្រាតែចប់; បើមិន ចុះចម្រុះអត្ថបទឡរឿងទេ ចុះតែអត្ថបទមួយ មួយសៀវភៅ នឹងក្លាយ ទៅជាសៀវភៅធម្មតា មិនមែនជាទស្សនាវដ្ឋី ។ ហេតុនេះ, បានជា ទស្សនាវដ្ឋីកម្ពុជសុរិយានេះ មានចុះចម្រុះអត្ថបទ ចម្រុះរឿង ដូចរឿង សាមកុកជាដើម បន្តិចម្តងៗ ដរាបដល់ចប់ទើបឈប់ ។

ខ)- កំណើតទស្សនាវដ្ឋីកម្ពុជសុរិយា ទស្សនាវដ្ឋីនេះកើតពី ព.ស. ២៤៧០ (ត.ស. ១៩២៨) មកដល់ ព ស. ២៤៩៧ (ត.ស. ១៩៥៤)

ចាន ២៧ ឆ្នាំហើយ មិនដែលរលត់ដូចទស្សនាវដ្តីទាំងពួងក្នុងកម្ពុជរដ្ឋ ដែលកើតឡើងហើយ ច្រើនតែធាប់រលត់នោះឡើយ, ដោយសារពុទ្ធបរិសទ្យដែលជាប់ចាន់ក្រែបអត្ថរសទស្សនាវដ្តីនេះ បេះតែនិយមអាន ជាហូរហែមិនដាច់ ទើបទស្សនាវដ្តីនេះរស់កនមានជីវិតដរាបមកចាន ។

គ)- វិត្តបំណងនៃទស្សនាវដ្តីកម្ពុជសុរិយា យើងត្រូវការផ្សាយនូវអត្ថបទដែលទាក់ទងដោយពុទ្ធវចនៈឬដោយរឿងជាពុទ្ធសាសនា ទោះបីត្រូវផ្សាយនូវសារស្តារល្បែង (រឿងប្រលោមលោក) ដែលទាក់ទងដោយអក្សរសាស្ត្រផង ក៏ផ្សាយចានតែរឿងដែលមិនខំនាស់នឹងព្រះពុទ្ធសាសនា ហើយជារឿងចានគតិខាងផ្លូវធម្មនិមួយកំលេសប៉ុណ្ណោះ, ពីព្រោះទស្សនាវដ្តីនេះ ជារបស់ពុទ្ធសាសនបណ្ឌិត្យ (ក្រសួងផ្សាយពុទ្ធសាសនា) ដែលត្រូវការណែនាំពុទ្ធជនឲ្យដើរតាមសម័យព្រះធម្មិគ្រប់គ្រងលោក, មិនត្រូវការណែនាំពុទ្ធជនឲ្យរត់តាមសម័យកំលេសគ្រប់គ្រងលោកទេ ។

ឃ)- ក្របមុខនឹងសណ្ឋានទស្សនាវដ្តីកម្ពុជសុរិយា យើងគិតផ្លាស់ប្តូរខ្លះដែរ តែដោយខើបនឹងផ្លាស់ថ្មីៗផង ដោយឃើញថាការផ្លាស់ប្តូរមិនជាប្រយោជន៍ប៉ុន្មានផង ក៏ផ្អាកសិនទៅ. ប៉ុន្តែបើតាមការពិតក្របមុខទស្សនាវដ្តី បើចានជាធ្លាប់ចណាទៅហើយគួរតែចុកចប់នោះជាយើហោទៅស្រួលជាង, ឬនាយាបើជាក់ក្នុងចំណោមសៀវភៅច្រើនមុខ

ឲ្យអ្នកផងក្រឡេកឃើញធាប់ស្គាល់ ជាទស្សនាវដ្តីនេះ ទស្សនាវដ្តីនោះបានភ្ជាម ។ ទោះបីក្របខាងក្រៅមិនស្ងរស្អក៏ដោយ ឲ្យតែសេចក្តីខាងក្នុងស្អក៏ទុកជាបានការ, ដូចផ្ទៃខ្នុរណាំងដែលសម្បកក្រៅត្រាតត្រាតតែក្រៃបខាងក្នុងផ្អែមធ្ងាញ់ពីសាជាងផ្ទៃល្ងា ដែលសម្បកក្រៅរលោងស្រិល ។ បើចង់ពិសោធន៍ការនេះ សូមធ្វៀបគ្នាមើល សៀវភៅរបស់បណ្ណាគារផ្សេង ។ ដែលក្របមុខមានពណ៌និងក្បាច់ក្សូរស្អ ។ ហើយនឹងសៀវភៅតិហិបដិបត្តិជាដើម របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យដែលមានក្របមុខខាងក្រៅលាត ឥតពណ៌ ឥតក្បាច់ តែសាច់ធមិខាងក្នុងស្អ មានប្រយោជន៍ចំពោះពុទ្ធបរិសទ្យ ដែលមួយមុខ ។ បោះពុម្ពមួយលើក ។ ច្រើនម៉ឺនក្បាល ច្រើនលើក ច្រើនលានក្បាលទៅហើយ នៅតែមិនទាន់ផ្អែតផ្អន់ផង តើខាងណាមានអ្នកនិយមអានច្រើនជាងខាងណា ?

ង)– ជំឡៃទស្សនាវដ្តីកម្ពុជសុរិយា យើងចង់បន្ថែមទំព័រនឹងចង់ឲ្យថោក តែផ្ទើទៅពុំកើតដោយរោងពុម្ពចេះតែជំឡើងថ្ងៃបោះពុម្ពរាល់ធ្នាំ យើងក៏ត្រូវតែជំឡើងថ្ងៃតាមខ្ងះ, ប៉ុន្តែដោយអនុគ្រោះប្រជាជន យើងក៏គិតឲ្យតែត្រប់ត្រាន់ជំឡៃបោះពុម្ពនឹងជំឡៃចាត់ចែងការផ្សាយប៉ុណ្ណោះ ។ បើយកជំឡៃសៀវភៅរបស់បណ្ណាគារផ្សេង ។ ហើយនឹងជំឡៃសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ មានតិហិបដិបត្តិជាដើម មកប្រៀបផ្ទឹមគ្នាមើលនឹងឃើញថាខាងក្រសួងនេះថោកជាង ។

ក្រៅពីទស្សនាវដ្ត៌កម្ពុជសុរិយា, សព្វថ្ងៃនេះ យើងមិនមែនឈរ ទ្រឹងស្ទៀមព្រងើយទេ យើងបានបោះពុម្ពសៀវភៅតំងចាស់តំងថ្មី, សៀវភៅចាស់ៗ ជូចតិហ៌បដិបត្តិជាដើម, ថ្មីៗ ជូចព្រះត្រៃបិដកជាដើម ដែលចេញផ្សាយតាមលេខរៀងតៗ ត្នាទៅមុខៗ ប្រែកៗ ឈ្មោះ, ហើយ ការបោះពុម្ពនោះទៀត យើងបោះតាមតែសេចក្ត៌ត្រូវការប្រជាជនទឹងតាម ចំនួនប្រាក់ថវិកាជាតិ ដែលយើងធ្វើជូច្នេះ មិនមែនដោយខ្វះអ្នកនិពន្ធទេ គឺ ខ្វះប្រាក់ចំណាយ; ចាំពេលណាសប្សូរប្រាក់ យើងនឹងបំពេញចិត្ត លោកអ្នកអាន ដោយចេញសៀវភៅថ្មីៗ ចម្រែកៗ ដែលជាស្នាដៃ អ្នកនិពន្ធជំនាញៗ តទៅ ។

និគមវចន:

ទស្សនាវដ្ត៌កម្ពុជសុរិយា ពិរោះពិសាធ្វាញ់ឈ្ងុយឈ្ងិត
សម្រាប់តែពុទ្ធជនពិត ដែលមានគំនិតធ្ងន់ខាងធមិ ។
មិនមែនសម្រាប់លោកជន ដែលធ្ងន់ខាងកាមាវចរ
ពីព្រោះមានគោលដ៏បវរ ត្រូវផ្សាយតែធមិនៃព្រះពុទ្ធ ។
ទោះបីផ្សាយរឿងអក្សរសាស្ត្រ ក៏មានឧកាសចេញផ្សាយសុទ្ធ
តែរឿងមិនទាស់មិនពិរុទ្ធ នឹងគោលព្រះពុទ្ធសាសនា ។

ពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

សង្ខិតន័យពីប្រវត្តិព្រះពុទ្ធសាសនា
នៅប្រទេសកម្ពុជានាអតីតកាល

របស់

លោក ហ្សង់-ប៊ស្សឺលីយេរ

ប្រតិភូសាលាបារាំងសែសនៅបុងបូពាប្រទេស

អភិរក្សសារមន្ទីរអាល់ប៊ែរសារ៉ូត៍

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរប្រែសម្រួល

ផ្ទុបឆ្នៅនេះ :

ឯកសារដ៏ចាស់ជាងគេបំផុត ដែលដំណាលពីប្រវត្តិប្រទេសកម្ពុជាជំនាន់ដើមនោះ គឺសិលាចារិកនៅ យ៉-ចាញ់ (Vo-Canh) ។ សិលាចារិកនេះពិតមែនតែគេរកឃើញនៅភូមិភាគញ៉ាត្រាំង (Nha-Trang) តែគេអាបស្គាល់បានថាជារបស់ហ្ជូណន ។ សិលាចារិកនេះចាប់កំណើតឡើងក្នុងសតវត្សរ៍ទី ៣ នៃគ្រិស្តសករាជ ជាអត្ថបទលិខិតដំបូងបង្អស់មួយនៃប្រទេសហ្ជូណនផង ជាភស្តុតាងនៃការឧបត្ថម្ភព្រះពុទ្ធសាសនារបស់ព្រះរាជាសម័យនោះផង ។ សូ្យ៉ាតេចារិកភាសាសំស្ក្រឹតក្នុងផែនសិលានោះជាផ្ទូរការក៏ដោយ, តែព្រះពុទ្ធសាសនាសម័យនោះប្រាកដជាព្រះពុទ្ធសាសនា

ទក្ខិណនិកាយដោយពិត, ឯលទ្ធិឧត្តរនិកាយគេប្រតិបត្តិក្នុងកាលមកជា
ក្រោយទេ មិនមែនមុនសតវត្សរ៍ទី ៧ នៃគ្រិស្តសកាជឡើយ ។ ចំណែក
កាសាបាលីប្រហែលគេចាប់ផ្តើមប្រើមុនដំបូងនៅពុទ្ធសកាជ ១.៨៥៦
គ្រិស្តសកាជ ១.៣០៩ ។

សម័យហ្ជូណានមកដល់រដ្ឋកាលព្រះបាទជយវ្មន ទី ២

ក្នុងចិរកាលនៃសតវត្សរ៍ទី ៤ នៃគ្រិស្តសកាជ យើងខ្ជះខាតសេចក្តី
ឲ្យការណ៍ទាំងស្រុង ។ សេចក្តីរាយការណ៍ជាប្រកពចិនដែលមាន
ដំណាលពីជីវកាពប្រទេសហ្ជូណាន ក៏មានពិស្តារណាស់ដែរ តែមិនសូវ
យើញមានដំណាលពីសាសនា ដែលគេគោរពក្នុងសម័យនោះឡើយ ។

រវាងពុទ្ធសកាជ ១.០៦៣ គ្រិស្តសកាជ ៤៨០ ប្រវត្តិរាជវង្សត្សុ
(T'si) ប៉ែកខាងត្ស្យងមានសេចក្តីរាយការណ៍ច្រើន ផ្ទុយនឹងសេចក្តីខាងដើម
ស្រឡះ សេចក្តីថា: "ការគោរពព្រះឥសូរ នឹងព្រះវិស្ណុក្នុងសម័យនោះ
ជាកិច្ចសំខាន់ណាស់ តែទោះជាយ៉ាងណាក្តីព្រះពុទ្ធសាសនាក៏ចាក់ឫស
ចាក់គល់ទូលំទូលាយណាស់ដែរ" ។ ក្នុងពុទ្ធសកាជ ១.០៦៧
គ្រិស្តសកាជ ៤៨៦ ព្រះបាទកោណ្ឌិន្យជយវ្មន៍ទបានបញ្ជូនកិក្ខុជាតិហិណ្ឌូ
មួយអង្ត នាម នាគសេន: ជាបេសកសមណ:ទៅកាន់ព្រះរាជសំណាក់
ព្រះអធិរាជចិន ។ នៅក្នុងរជ្ជកាលនេះកិក្ខុជាតិហ្ជូណានពីរអង្គគឺព្រះថេរ:
នាម សង្ឆបាល: នឹងព្រះថេរ:នាម មន្ត្រសេន: បានតាំងជាវត្តអារាម

នៅប្រទេសចិនហើយ ព្រមទាំងបានប្រែព្រះត្រៃបិដកផង, ឯសេចក្តីប្រែនោះឃើញមានច្បាកដនៅក្នុងបិដកចិនជាបន្ទាល់ស្រាប់ ។

ក្នុងរជ្ជកាលព្រះចាន្ទ្រគុប្តវ័ន ជាព្រះរាជាចុងក្រោយបង្អស់នៃប្រទេសហ្គូណាន ព្រះពុទ្ធសាសនាក៏មានដំហរបន្ទាប់បន្សំនៅឡើយ ដូចជាសេចក្តីក្នុងសិលាចារឹកនៅច្បាសរគាត្រហ្ម (ស្រុកចាទី) បានចែងពុកថា "ការគោរពព្រះបរមសារីរិកធាតុតាមសណ្ឋាប់ថែរក្សាតែម្យ៉ាងដែលគេប្រតិបត្តិក្នុងសម័យនោះ" ។ ព្រះចាន្ទ្រគុប្តវ័ន្តព្រះអង្គលោកមិនជាពុទ្ធសាសនិកពិតមែនទេ តែទ្រង់បានសំដែងព្រះអង្គឲ្យព្រះអធិរាជប្រទេសចិនឃើញថាទ្រង់គោរពព្រះបរមសារីរិកធាតុ ដ៏មានតម្លៃបំផុតគឺព្រះកេស ១ សរសៃនៃព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ។

ក្នុងកាលខាងក្រោយអំពីរជ្ជកាលព្រះចាន្ទ្រគុប្តវ័ន្តមក ស្រាប់តែបាត់ដំណឹងសូន្យឈឹង ស្ទើរតែអស់មួយសតវត្សរ៍ទៀត, សព្វថ្ងៃនេះយើងពុំទាន់បានដឹងនៅឡើយថា មានហេតុកេតព្រះពុទ្ធសាសនាដូចម្តេចខ្វះអំពីការរួបរួមប្រទេសចិនឡានេះ ។ កាលពីពុទ្ធសករាជ ១.១៧០ គ្រិស្តសករាជ៦២៧ មានសិលាចារឹកនៅវិទ្យាវិសេសមួយទៀត គេពុកជាឯកសារមួយដែលស្តីពីព្រះពុទ្ធសាសនានៅក្នុងសម័យនោះ, តមកក៏បាត់ដំណឹងសូន្យឈឹងទៀត រហូតមកដល់ទីបំផុតនៃសតវត្សរ៍ទី ៧ នៃគ្រិស្តសករាជ ។ ប៉ុន្តែយើងសង្កេតឃើញមានបព្វជិតឈ្មោះ យ៉ី-ត្សីង

(Yi-Tsing) ដែលធ្វើដំណើរផ្ទងកាត់ទ្វីបអាស៊ីកាតអគ្នេយ៍ នៅរវាងពុទ្ធសករាជ ១.២១៤ ទៅ ១.២៣៨ គ្រិស្តសករាជ ៦៧១ ទៅ ៦៩៥ បានសរសេរទុកថា: "ព្រះពុទ្ធវចនៈចំរើនរុងរឿងហើយផ្សាយទូទៅ, ប៉ុន្តែសព្វថ្ងៃនេះ មានព្រះរាជាមួយព្រះអង្គកាចឃោរឃៅបានបំផ្ទិចបំផ្ទាញ ព្រះពុទ្ធវចនៈចោលអស់ ឥតមានភិក្ខុសង្ឆសោះទ្បើយ . . ." ។ មិនសមបើមានអំពើយង់ឃ្នងដែលកម្រមានណាស់ នៅប្រទេសកម្ពុជាជួចជាបព្ទជិត យី-ត្សឹង បានពោលថាកាចកំរាលនោះសោះ ព្រោះមានសិលាចារិកខ្ទះនិយាយថា មានកសាងវត្តក៉អារាមនៅទ្បើយរវាងជំនាន់ជដែលនេះ ។ ទោះជាម្តេចម្តាក៏ដោយប្រហែលជាមានប្រតិកម្មយ៉ាងនេះ ជាផ្ទូវការពិតមែនក៏មិនដឹង បានជាលទ្ធិព្រះពុទ្ធសាសនាថេរវាទសាបរលាបសូន្យទៅ ពីព្រះរាជអាណាចក្រខ្មែរអស់កាលជាច្រើនសតវត្សរ៍ ។ កាលនោះ ព្រះពុទ្ធសាសនាលទ្ធិមហាយានចាប់ផ្តើមចំរើនតក់ ។ ទ្បើងវិញ ។ ឯសិលាចារិកដែល៍មានស្តីពីលទ្ធិមហាយាននេះ គឺសិលាចារិកនៅពុទ្ធសករាជ ១.៣២៤ គ្រិស្តសករាជ ៧៨១ ប៉ុន្តែបើយកទេវរូបដែលចាស់ជាងគេមកប្រៀបធៀបវិញឃើញថា ទេវរូបទាំងនេះកើតទ្បើងតាំងពីកាលសតវត្សរ៍ទី ៧ នៃគ្រិស្តសករាជម្ទើះ ។ មួយទៀត, យើងត្រូវកំណត់ចាំថាប្រទេសដែលបានទទួលអារ្យធមិពីប្រទេសឥណ្ឌៀ មិនដែលឃើញប្រទូសក៉យចំពោះ ព្រះពុទ្ធសាសនាលទ្ធិមហាយានទ្បើយ កាល

ពីមុន ជាន់សតវត្សទី ៧ នៃគ្រិស្តសករាជ (សុម៉ាត្រាប្រទេសជ្វា) ប៉ើយើងយកការរចនាលង្ការនៃទេវរូបមកជាគ្រឿងសំគាល់វិញ យើញថាទើបតែកើតមានច្រើននៅក្នុងរយកាលនៃសតវត្សរ៍ទី ៨ នៃគ្រិស្តសករាជទេ ។ ឯទេវរូបទាំងនោះច្រើនតែកសាងឡើងតំណាងលោកកេស្ទរៈជាពោធិសត្ទប្រកបដោយមេត្តា ។

ក្នុងរយកាលនៃសតវត្សរ៍ទី ៩ នៃគ្រិស្តសករាជ ក្រោយដែលគេលែងគោរពពោធិសត្ទលោកេស្ទរៈជាលំដាប់មក ទេវរូបនឹងសិលាចារិកខាង ព្រះពុទ្ធសាសនាលទ្ធិមហាយាន ក៏ហាក់ដូចជាអន្តរធានសាបសូន្យអស់ទៅ ។ ការអន្តរធាននេះប្រហែលជាកើតឡើងអាស្រ័យដោយការបង្កើតការគោរពព្រះឥសូរ នៃ ព្រះបាទជយវ្ម៉ានទី ៦ (ព.ស. ១.៣៦៥-១.៣៩៣ គ.ស. ៨០៦-៨៥០) ឡើងវិញ ។ ព្រះរាជាទ្រង់មានព្រះរាជបំណងនឹងស្ថាបនា ព្រះរាជានុកាពដោយយកសាសនាជាបាទ ពឹងផ្អែកទៅលើពួកព្រាហ្មណ៍ ហើយទ្រង់មិនបានទទួលសេចក្តីយល់ព្រមការពារជាផ្លូវការជល់ ព្រះពុទ្ធសាសនាឡើយ, ត្រង់នេះ យើងត្រូវចាំមើលក្នុងរជ្ជកាលនៃ ព្រះរាជាជាតំណវង្សទីពីរ គឺ ព្រះបាទឥន្ទ្រវ្ម៉ានតទៅ ដើម្បីនឹងដកស្រង់យកអត្ថបទដែលនិយាយជល់ការស្ទ្រាមស្ទាត់ចំពោះព្រះពុទ្ធ-សាសនា គឺសំលាចារិកនៅបាន-បុង-កែ (Ban-Bong Kè) ។

ការកសាងក្រុងអង្គរវហ្ចតដល់បាមវាយយកអង្គរបាន

ក្នុងរជ្ជកាលព្រះបាទយសោវ្ម៉ន ជាព្រះរាជាកសាងក្រុងយសោ-ធរ:បុរ: ជាក្រុងអង្គរជាន់ដើម យើងបានឃើញគេទទួលស្គាល់ព្រះពុទ្ធសាសនាជាផ្លូវការ, នេះហើយជាប្រវត្តិមុនដំបូងនៅប្រទេសខ្មែរ ។ សិលាបាវិកចែងថាព្រះរាជាទ្រង់បានកសាងវត្តអារាមជាច្រើន ជាវត្តសម្រាប់ព្រះឥសូរខ្លះ សម្រាប់ព្រះវិស្ណុខ្លះ សម្រាប់ព្រះពុទ្ធសាសនាខ្លះ សាសនាទាំងនេះបានទទួលសិទ្ធិនឹងបុព្ធសិទ្ធិយ៉ាងម៉ឺងម៉ាត់ដូចគ្នា ។ ប៉ើទុកជាសិលាបាវិកចែងថា ព្រះរាជាទ្រង់អនុញ្ញាតឲ្យកាន់សាសនាតាមចិត្តដ៏ទូលាយយ៉ាងនេះក៏ដោយ គេក៏គង់សំដែងឲ្យយើញច្បាស់ថាព្រះពុទ្ធ-សាសនាមានការអើពើជាងការគ្រប់គ្រង ដោយសមភាពចំពោះសាសនាឥណ្ឌូដែរ ។

ក្រោយរជ្ជកាលរុងរឿងនៃព្រះបាទយសោវ្ម៉ន, ព្រះពុទ្ធសាសនាជាផ្លូវការធ្លាក់ចុះមកកាន់ការស្លប់ស្ងៀមម្ហយលើកទៀត, ប៉ុន្តែការកសាងវត្តរ៉ាអារាមជាអនេកនៅមានប្រាកដក្បែរព្រះរាជធានីនៅឡើយ ដោយច្រើនចំពោះភាគទីពីរនៃសតវត្សរ៍ទី ១០ នៃគ្រិស្តសករាជ ។ ទេវស្ថាន ៣ កន្លែងនៅបាតដុំ ជាទេវស្ថាននៃព្រះរាជាគណ:មួយអង្គក្នុងបណ្តាព្រះរាជាគណ:ទាំងឡាយដែលមានកេរ្តឹ៍ឈ្មោះល្បីល្បាញជាងគេ គឺមួយ១ទ្ធិសដោយគោរពចំពោះព្រះពុទ្ធ មួយទៀតចំពោះនាងវជ្របាណី

មួយតទៅទៀតចំពោះនាងប្រាជ្ញាបារមីតា ។ ផែនស៊ីលានៅវត្តស្រីសុន្ទរ
មុនការកសាងទេវស្ថាននេះមិនយូរប៉ុន្មានមានចែងសារៈសំខាន់ថា "លទ្ធិ
ព្រះពុទ្ធសាសនាមានតេប្រតិបត្តិរហូតដល់ទៅក្សែរ ។ ព្រះរាជវង្សានុវង្ស
ផង" ។ លទ្ធិព្រះពុទ្ធសាសនានេះសសៀរទៅរកខាងនិកាយយោតាចារៈ
ដែលជាសារៈសំខាន់មួយខាងការគោរពពោធិសត្វលោកេស្វរៈ ។

ក្នុងរជ្ជកាលនៃព្រះបាទសូរ្យវ្មន្ទីទី ១ (ព.ស. ១.៥៤៥-១៥៩៣
ត.ស. ១០០២-១០៥០) ព្រះពុទ្ធសាសនាមិនមែនគ្រាន់តែព្រះរាជា
ទទួលស្គាល់ជាផ្លូវការប៉ុណ្ណោះទេ គឺព្រះរាជាទ្រង់ថ្វាយការអើពើហើយ
ទ្រង់គោរពប្រតិបត្តិថែមទៀតផង ។ ព្រះរាជាអង្គនេះទ្រង់ជាសាវ័កពិត
ប្រាកដរបស់ព្រះពុទ្ធសាសនា កាលទ្រង់ទីវង្គតទៅ គេថ្វាយព្រះមរណ-
នាមព្រះអង្គថាព្រះបាទនិរ៉ានបទ សឲ្យឃើញច្បាស់ប្រាកដ, ប៉ុន្តែទោះបី
មានការសាងទេវស្ថានចំរើនឡើង ប្រកបដោយរូបចម្លាក់ខាងព្រះពុទ្ធ-
សាសនាព្រមទាំងព្រះពុទ្ធរូបទាំងនេះ ដូចព្រះពុទ្ធរូបប្រក់នាតមុច្ចលិន្ទជា
ដើមក្តី ក៏ការគោរពរបស់ព្រះរាជាមិនមែនត្មានការផ្លាស់ប្តូរទេ ។ សិលា-
ចារិកនៅស្តុកកោះធំបានពោលបញ្ជាក់ពីប្រវត្តិតកូលព្រាហ្មណ៍ជាន់ខ្ពស់
ម្នាក់ ស្តីចំពោះការផ្លាស់ប្តូរនេះថា: "នៅក្នុងរជ្ជកាលព្រះបាទនិរ៉ានបទ
ព្រះរាជវង្សានុវង្សទាំងអស់គោរពបូជាទេវរាជតាមព្រះរាជទង្ការ" ។

ក្រោយរជ្ជកាលព្រះបាទសូរ្យវ្មន្ទីទី ១ មានការកសាងទេវស្ថាន
នឹងសិលាចារិកជាកស្តុតាងដរាប សំដែងឲ្យឃើញថាការគោរពព្រះពុទ្ធ-

សាសនាជាប់តំណវង្សតគ្នារដឹកវៀងរាបជាលំដាប់មក ។ តាមសេចក្ត
ក្នុងព្រះមរណនាម, ព្រះរាជាទាំងឡាយគង់នៅតាមទំនៀមហិណ្ឌូសម័យ-
បុរាណ តែនាមឺនមុខមន្ត្រីនៅរឹងប្រតិបត្តិតាមព្រះពុទ្ធសាសានា ឥត
សង្ស័យឡើយ ។ ឯព្រះពុទ្ធសាសនាលទ្ធិមហាយានទំនងជាចូលដៃនឹង
ពួកអ្នកប្រាជ្ញសាសនាពួកខ្ទះ បានជាក្នុងមជ្ឈដ្ឋាននាមឺនមុខមន្ត្រីទាំងនោះ
មានត្រកូលមួយកូលក្នុងវង់ការយ៉ាងសំខាន់ក្នុងប្រវត្តិ គឺរាជវង្សមហីធារ-
ចុរៈឡើងកាន់អំណាចក្នុងពុទ្ធសករាជ ១.៦២៣ ត្រិស្តសករាជ ១.០៨០ ។

ទោះបីព្រះបាទសូរ្យវ្មន្ទី ២ ជាព្រះរាជាមានព្រះកេរ្តិ៍ដ៏សម្បើម
ក្នុងព្រះរាជវង្សនោះ ទ្រង់គោរពព្រះវិស្ណុហើយទ្រង់បានកសាងប្រាសាទ
នគរវត្តល្បីល្បាញក៏ដោយ, តែព្រះរាជាជាតំណវង្សមកត្រឡប់ទៅជាកាន់
ព្រះពុទ្ធសាសនាយ៉ាងស្មោះស្ម័ត្រទៅវិញ ដោយទ្រង់សព្ទព្រះទំយកេប
វិមុត្តិរសនៃព្រះសាសនាព្រះសក្យមុនី តែប៉ុណ្ណោះ, តែទ្រង់មិនបានតាំង
នៅក្នុងព្រះរាជសទ្ធាមុតមាំប៉ុន្មានទេ, លុះដល់ព្រះរាជបុត្រព្រះអង្គគឺព្រះ
បាទជយវ្មន្ទី ៧ ទ្រង់មានជ័យជំនះទ្រង់បានដេញចាមដែលលុកលុយ
បណ្ណាលឲ្យចលាចលពាសពេញប្រទេសក្នុងសតវត្សរ៍ទី ១២ នៃត្រិស្ត-
សករាជ នោះបានសាន្តត្រាណហើយទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាតាម
របៀបច្ចីឲ្យរឹងបឺង មានរបៀបរៀបរយចំរើនលូតលាស់ជូចដើមឡើងវិញ ។

ព្រះបាទជយវ្ម៉ន្ទ៉ទី ៧

ព្រះបាទជយវ្ម៉ន្ទ៉ទី ៧ ទ្រង់មានការកិច្ចសម្បើមអស្ចារ្យណាស់គឺត្រូវដណ្តើមប្រទេសឲ្យបានផុតចេញពីអ្នកលុកលុយ, ត្រូវរៀបចំឲ្យប្រទេសសាន្តត្រាណ, ត្រូវជួសជុលព្រះរាជានុភាពឡើងវិញ..., ទាំងអស់នេះទ្រង់ត្រូវតែបំពេញដោយព្រះរាជធន្ទៈដ៏មុតមាំ ជាសេចក្តីអង់អាចរបស់ព្រះអង្គ ដែលប្រជារាស្ត្រប្រកបដោយសេចក្តីស្នេហាជ្រាលជ្រៅជកចិត្តចេញពុំបាន បានទាំងជួយព្រះអង្គដោយជំនឿដ៏ខ្ជាំងក្លាផង ។ ទ្រង់មានព្រះរាជបំណងវាតពង្រីកព្រះតេជានុភាព តាមតន្ទងឧត្តមតតិមហាករុណាទិគុណទ្រង់ប្រកបព្រះរាជជីវភាពព្រះអង្គ តាមចរិយាព្រះពោធិសត្ទអវលោកិតេស្ទរ: ជូចសិលាចារិកតំកើងព្រះអង្គថា: "ទ្រង់រងទុក្ខវេទនាចំពោះជម្ងឺប្រជារាស្ត្រព្រះអង្គ ជាងព្រះអាពាធចំពោះព្រះកាយព្រះអង្គ ព្រោះទុក្ខវេទនាសាធារណជនជាទុក្ខវេទនានៃព្រះរាជា មិនមែនជាសេចក្តីទុក្ខចំពោះព្រះអង្គទេ". (ផែនសិលាមន្ទីរពេទ្យ) ទ្រង់គោរពសេចក្តីថា "មតិាដ៏ប្រសើរបំផុតដែលនាំទៅកាន់សម្មាសម្ពោធិញ្ញាណគឺលទ្ធិឯកឥតមានមន្ទិលសៅហ្មង ដើម្បីការយល់ច្បាស់នូវសេចក្តីពិត (យថាភូតទស្សនញ្ញាណ) ព្រះធម៌នោះអមតបុគ្គលក្នុងត្រៃលោកត្រូវគោរពបូជា ទុកជាព្រះខ័នបំផ្ទាញបង់នូវគុម្ពឈើ គឺកិលេសាសវ:" (សិលាចារិកនៅតាព្រហ្ម) ។

ក្នុងនាមព្រះរាជសន្ធាព្រះអង្គ, ព្រះបាទជយវ្មន្ទី ៧ ទ្រង់កសាង
ទេវស្ថានច្រើនជាអនេកពាសពេញប្រទេស មានទេវស្ថានខ្ទះធំអស្ចារ្ស
មានមន្ទីរពេទ្យ អាស្រម នឹងសាលាសំណាក់ច្រើនកន្ទែង ។ សាសនា
ដែលគេគោរពនោះ គឺលទ្ធិមហាយានដែលរួមចុះនៅក្នុងគុណ ព្រះពុទ្ធ,
ពោធិសត្វលោកេស្វរ:, នាងប្រាជ្ញាបារមីតា ព្រមទាំងពោធិសត្វជទៃទ្រៃត
ដែលមានគុណានុភាពបន្ទាប់បន្សំចុះមក ។ ប៉ើទុកជាក្នុងរជ្ជកាលនេះ
មានសេចក្តីរុងរឿងជូចសេចក្តីក្នុងសិលាចារិកចែងថា មានកសាងវត្តរ៉ាអា-
រាមខាងព្រះពុទ្ធសាសនាក៏ដោយ, ឯពួកព្រាហ្មណ៍គេក៏មិនលះបង់ចោល
ចេញពីក្នុងព្រះរាជការណ៉ីយកិច្ចទេ, ជូចជានៅបច្ចុប្ប្ធន្នកាលនេះ ពួក
ព្រាហ្មណ៍នៅតែប្រកបពិធីក្នុងព្រះរាជពិធីផ្សេង ៗ នៅទ្យើយ គឺគេនៅ
គោរពតាមទំនៀមដែលមានជាច្រើនសតវត្ស៍រមកហើយ តាំងពីព្រះបាទ
ជយវ្មន្ទី ៦ ម្ទ៉ៃ: ។

បណ្តាព្រះរាជបុត្រនៃព្រះបាទជយវ្មន្ទី ៧ មានព្រះរាជបុត្រមួយ
ព្រះអង្គដែលទ្រង់ស្តេចចេញទៅបំពេញការសិក្សានៅកោះលង្កា ហើយ
ទ្រង់បានបព្វជានៅប្រទេសនោះ (តាមទំនៀមកិក្ខុសង្ឆគណ:មហា
វិហារ) ។ នេះជាកិច្ចការយ៉ាងសំខាន់មួយនៃព្រះពុទ្ធសាសនាលទ្ធិថេរ-
រាទដែលមានចារិកនៅប្រទេសកម្ពុជា ហើយហាក់ជូចជាបានពន្ធឺមួយ
ទ្យយល់សេចក្តីពិតថា ព្រះពុទ្ធសាសនាលទ្ធិថេរវាទចំរើនលូតលាស់

ដុះដាលឡើងជាមួយគ្នា មួយអន្លើដោយព្រះពុទ្ធសាសនាលទ្ធិមហាយាន ដែលគេតុកជាផ្លូវការ ដោយហេតុណាស់សេចក្តីនេះអាចអុជគ្រាលបំភ្លឺនូវការសិក្សាវិជ្ជារូបសាស្ត្រ (Iconographie) សម័យជាមួយគ្នាបានកាលណាបើមិនមានសិលាចារឹកជាកស្តុតាង ។ ការដែលនាំឲ្យវិលត្រឡប់មករកអាន ព្រះពុទ្ធសាសនាដែលធ្លាប់ប្រតិបត្តិមកហើយ កាលពីប្រថមសតវត្សរ៍យ៉ាងនេះវិញ ទំនងជាដោយការខាត់ខន់នឹងការចំរើនផ្លូវគមនាគមន៍ខាងដើងគោកជាមួយនឹងជ្រោយគោះខាងលិច ព្រោះនៅទីនោះ ព្រះពុទ្ធសាសនាលទ្ធិថេរវាទតំពូងដុះលូតលាស់រស់រវើកនៅឡើយ ។

ព្រះរាជសន្ធតិវង្ស នៃព្រះបាទជ័យវរ្ម័នទី ៧ រហូតដល់ប្រតិស្ឋានព្រះរាជធានីក្រុងភ្នំពេញ

ការគោរព ព្រះពុទ្ធសាសនាតាមតម្រាយ ព្រះបាទជ័យវរ្ម័នទី ៧ ដែលទ្រង់បានខិតខំដោយ ព្រះរាជសទ្ធា នឹងដោយ ព្រះឋាមពលដ៏មុតមាំយ៉ាងនេះ មិនបានបិតថេរវេរាលនៅយូរលង់ៗទៅបានទេ តែងតែកាលជាខាងក្រោយពីកាលដែលទ្រង់ចាត់បង់ទៅហើយ ។ ដោយពិតចាប់តាំងពីរាជសន្ធតិវង្សទីពីរមក ប្រវត្តិប្រទេសខ្មែរមានប្រតិកម្មដ៏សាហាវប្លែកអស្ចារ្យណាស់ គឺព្រះរាជាអង្គក្រោយមិនតេញ ព្រះទ័យកន្លែងការគោរពនូវទេវរូប ហើយព្យាយាមបំផ្លិចបំផ្លាញលុបបាតម្រាយ ព្រះពុទ្ធសាសនា

តាមដែលគ្រង់ស្តប់ខ្លឹមនោះដោយអំពើតាចដូចមនុស្សដែរ ។ នៅក្នុង-
សាទពាដស្តានខ្លះ ឃើញមានស្នាមគោសលុបការរចនាទឹងទេវរូបផ្សេង ។
ជាស្នាដៃនៃពួកអ្នកបំផ្លិចបំផ្លាញ ដែលពេញចិត្តនឹងសាសនាព្រះឥស្សរ,
ដោយពិត ប្រហែលជារួមដៃជាមួយនឹងពួកអ្នកនាំខាងសាសនាព្រាហ្មណ៍
ផង គឺពួកអ្នកដែលអស់អំណាចកាលដែល ព្រះពុទ្ធសាសនាឡើង ៧ ធ្លើ
បដិវត្តន៍ខាង ព្រះពុទ្ធសាសនាឡើង. ពួកនេះប្រាថ្នាចង់ដណ្តើមយក
អំណាចបុព្វសិទ្ធិពីដើមរបស់ខ្លួនដែលបាត់បង់ទៅមកកាន់វិញ, មួយទៀត
ព្រះពាជាអគ្គីថ្មីដែលឡើងគ្រងរាជបល្ល័ង្កឡើង ទំនងជាអ្នកដែលផ្តល់ឲ្យ
នូវកាសដែលខ្លួនរង់ចាំមកយូរហើយផង ។

លុះដល់ ព្រះពុទ្ធសាសនាលទ្ធិមហាយានដែលផ្ញើសំណាងនៅលើ
របៀបពាជាធិបតេយ្យ ហើយអាប់នុនស្មើទៅកងតាលជាមួយនេះផង,
ឯព្រះពុទ្ធសាសនាលទ្ធិថេរវាទនៅមានសារតែមិនតិចប៉ុន្មានដែរ ក៏លូត
លាស់ដុះដាលឡើងវិញ យ៉ាងធាប់រហ័សកងរាងខាងចុងសតវត្សទី ១៣
នៃគ្រិស្តសកាជ ។ ត្រង់នេះ យើងត្រូវយកច្បាសាទអគ្គរដំនាន់ក្រោយ។
ដែលកសាងដោយសម្ភារៈមាំ ។ មកជាបន្ទាល់លទ្ធិថេរវាទនេះ ។
លោកចៀវ-តាកួន ពាដទូតចិន ដែលមកកាន់ប្រទេសខ្មែរ កាលពុទ្ធសក-
ពាដ ១.៨៣៩ គ្រិស្តសកាជ ១.២៩៦ បានចែងពុកបញ្ជាក់ពីសាសនា
ដែលគេនិយមប្រតិបត្តិកងសម័យនោះ ព្រមទាំងចុះសេចក្តីពិយការណ៍

សំខាន់ ៗ ដែលស្តីពីច្បាប់ព្រះពុទ្ធសាសនា នឹងសេចក្តីរាយការណ៍ខ្ទះ ទៀតមិនសូវជាត្រប់ត្រាន់ទេ តែជាសេចក្តីបញ្ជាក់ដ៏មានតម្លៃទុកសម្រាប់ អ្នកប្រវត្តិទាំងឡាយផង ។

លោក ចៀវ-តាកួន ឃុនឃើញសិលាចារិកជាភាសាឃុលីដែលចាស់ជាងគេពីកាលជំនាន់ក្សត្រសោយរាជ្យបន្ទាប់តមក ។ សិលាចារិកនេះមានតាំងពីពុទ្ធសករាជ ១.៨៥៦ ត្រិស្តសករាជ ១.៣០៩ ជាអនុស្សាវរីយ៍នៃការកសាងព្រះវិហារព្រមទាំងដំកល់ព្រះពុទ្ធរូបផង ។ ទោះបីព្រះពុទ្ធសាសនាលទ្ធិថេរវាទចំរើនរុងរឿង មានភស្ពុតាងប្រាកដយ៉ាងនេះក៏ដោយ មិនមែនប្រែថាសសនាព្រាហ្មណ៍សាបសូន្យទៅទេ ការគោរពសាសនាព្រាហ្មណ៍ក៏ចំរើនរុងរឿងខ្លាំងណាស់ដែរ នៅក្នុងផ្ទៃព្រះរាជវាំងក្នុងដើមសតវត្សរ៍ទី ១៤ នៃត្រិស្តសករាជ, ឯពិធីព្រាហ្មណ៍ក្នុងបច្ចុប្បន្នកាលនេះទុកជាភស្ពុតាង នៃការអាប់ឧនទៅរបស់សាសនាព្រាហ្មណ៍ក្នុងកាលនោះ ។

ចាប់តាំងពីនិរាសអង្គរ គឺក្នុងរវាងខាងចុងសតវត្សរ៍ទី ១៥ នៃត្រិស្តសករាជមក មិនមានសិលាចារិកស្តីពីហេតុការណ៍អ្វីសោះ មានតែប្រវត្តិតែប៉ុណ្ណោះទេដែលមានរៀបរាប់ហេតុការណ៍ផ្សេង ៗ ក្នុងសម័យកាន់ប្រែ ៗ តាមទំនងប្រហែលជាព្រះពុទ្ធសាសនាលទ្ធិថេរវាទចេះតែចំរើនត ៗ មកដោយរហ័ស ព្រោះព្រះឃុនពញ្ញាយ៉ាតក្រោយដែលទ្រង់ទៅប្រថាប់នៅ

ក្រុងស្រីសុន្ធរមិនយូរប៉ុន្មាន ទ្រង់ប្តេជ្ញាថានឹងមកកសាងព្រះពុទ្ធជានីនៅក្រុងភ្នំពេញក្នុងឆប្បញ្ចកាលនេះ គឺនៅដុំវិញចេតិយធំមានកែ្ពរឈ្មោះនេះហើយ ដែលជាទីតាំងព្រះពុទ្ធជានីថ្មី ។ ភ្នំនេះជាមជ្ឈដ្ឋាននៃព្រះពុទ្ធជានីថ្មីជាទេវល័យដម្កល់ព្រះទេវពុទ្ធជាប់ជាទំនៀមតមកដូចសតវត្សរ៍ដែលកន្លងមកយូរលង់ហើយ ។ វត្តអារាមទាំងប៉ុន្មានដែលទ្រង់កសាងសុទ្ធតែជាវត្តព្រះពុទ្ធសាសនា មានវត្តអារាមខ្លះដែលទ្រង់គោរពគេបានជួសជុលបំតែរហូតមកដល់សព្វថ្ងៃនេះ ។

ចាប់ពីទាងដើមសតវត្សរ៍ទី ១៥ នៃគ្រិស្តសករាជមក ព្រះពុទ្ធសាសនាចាក់ឫសគល់មាំជាស្ថាពរនៅក្នុងកម្ពុជវដ្ត, លុះក្រោយមកជិត ១២ សតវត្សរ៍ ទើបត្រឡប់មកកាន់ព្រះពុទ្ធសាសនាទក្ខិណនិកាយ ដូចសេចក្តីរៀបរាប់ក្នុងសិលាចារឹកនៅយ៉ៃ-ចាញ់ វិញ (Vo-Canh) មួយទៀត, ដល់មកសតវត្សរ៍ទី ១៦ នៃគ្រិស្តសករាជ ទោះបីជាតិពរុយគេស៍ មានបំណងចង់បំផ្លាញព្រះពុទ្ធសាសនាយ៉ាងណាក៏ដោយ ក៏មិនអាចញុំាងព្រះពុទ្ធសាសនាឲ្យកន្ត្រើកញាប់ញ័ររលំឫសគល់បានឡើយ ។

សង្ខិត្តន័យពីប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសកម្ពុជានាអតីតកាលចប់ត្រឹមប៉ុណ្ណេះ ។

ឃុនបណ្ណានុរ៉ក្ស ប៊ូ-ប៉ូ ជ្រៀបជ្រៀង

សីលធម៌(1) ពាក្យនេះកាត់ជា ២ បទគឺសីល ១ ធម៌ ១ ។ ការរក្សាកាយវាចាឲ្យរៀបរយល្អ ឲ្យប្រាសចាកទោស ហៅថា សីល ចានដល់សីល ៥ សីល ៨ សីល ១០ សីល ២២៧ ។ សការៈដែលទ្រទ្រង់ ហៅថា ធម៌ ។

ពាក្យថា "ធម៌" នេះជារបស់កណ្ណាល គឺទ្រទ្រង់ទាំងខាងល្អ ទ្រទ្រង់ទាំងខាងអាក្រក់; បើខាងល្អ គឺទ្រទ្រង់អ្នកប្រព្រឹត្តល្អមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ហៅថា ធម៌ល្អ (កុសលធម៌), បើខាងអាក្រក់ គឺទ្រទ្រង់អ្នកប្រព្រឹត្តអាក្រក់ឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ហៅថា ធម៌អាក្រក់ (អកុសលធម៌) ។ ធម៌ក្នុងពាក្យថា សីលធម៌នេះ សំដៅយកធម៌ខាងល្អ ។

ក្នុងទីនេះ មិនបានអធិប្បាយអំពីសីលទេ ព្រោះមានសេចក្តីពិស្តារដូចលោក-អ្នកធ្លាប់ជ្រាបស្រាប់ហើយ សូមអធិប្បាយតែត្រង់ពាក្យថា ធម៌ឲ្យពិស្តារបន្តិច ។

មនុស្សអ្នកមានធម៌នៅប្រចាំក្នុងចិត្ត ឬថាអ្នកប្រព្រឹត្តធម៌ជាប់ជានិច្ច ធម៌នោះតែងរក្សាអ្នកនោះមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់បាន ព្រោះសេចក្តី

---

1 ច្បាប់ធម្មចក្ស ទ្រៃ ២២ ទំព័រ ៩៩៧ ។

អាក្រក់ត្មានផ្ទូរនឹងកើតឡើងបាន មានតែសេចក្តីល្អឲ្យបានសេចក្តីសុខ
ម្យ៉ាងប៉ុណ្ណោះ ។ ធម៌នេះ មានលក្ខណៈនឹងកិច្ចផ្សងអំពីសីល, សីលមាន
ការរៀបរយកាយវាចាជាលក្ខណៈ មានការកំចាត់បង់សេចក្តីអាក្រក់
ដែលនឹងគប្បីប្រព្រឹត្តកន្ទងដោយកាយវាចាជានិច្ច រមែងសម្រេចជាសីល
បានដោយការលះវៀរ គឺលះវៀរតាមសិក្ខាបទនោះ ។ ចំណែកធម៌នោះ
មានសភាពទ្រទ្រង់អ្នកប្រព្រឹត្តទុកមិនឲ្យធ្ទាក់ទៅក្នុងទីអាក្រក់, មានកិរិយា
ធ្វើអធ្យាស្រ័យរបស់មនុស្សអ្នកប្រព្រឹត្តឲ្យរឹតតែល្អិតសុខុមរិក្រលែង ជាង
ភាពដើមជាលក្ខណៈ, មានការកំចាត់បង់សេចក្តីអាក្រក់ ដែលនឹងគប្បី
កើតឡើងក្នុងចិត្តជាកិច្ច រមែងសម្រេចប្រយោជន៍ដល់អ្នកប្រតិបត្តិបាន
ដោយការធ្វើតាមសីលនឹងធម៌ មានលក្ខណៈនឹងកិច្ចផ្សងគ្នាជូច្នេះ ហេតុ
នោះ ទើបចាត់ថាជាខប្រតិបត្តិដែលបុគ្គលនឹងត្រូវបំពេញឲ្យប្រព្រឹត្តទៅ
ទាំង ២ យ៉ាង នឹងបំពេញតែមួយ ។ មិនបានទេ ។ ក៏បុគ្គលអ្នករក្សាសីល
ឈ្មោះថា ជាអ្នកវៀរចាកសេចក្តីអាក្រក់បានមែនហើយ ប៉ុន្តែសេចក្តី
អាក្រក់ដែលលះវៀរបានដោយសីលនោះ ជាសេចក្តីអាក្រក់យ៉ាងត្រោត
ត្រាតដែលឃើញបានងាយ ចំណែកសេចក្តីអាក្រក់យ៉ាងល្អិតនៅមាន
ក្នុងចិត្តទៀត ឬនឹងគប្បីកើតឡើងផ្ទូវចិត្តផុតវិស័យរបស់សីលដែលនឹង
កំចាត់បាន ។ គប្បីឃើញជូចបុគ្គលអ្នករក្សាសីលតែម្យ៉ាង ត្មានធម៌ជា
ត្រឿងតាំពារ ហើទៅជួបប្រទះនឹងមនុស្សមានទុក្ខ ជូចឃើញគេធ្ទាក់ទឹក

ឬអត់ឧាយ ហើយដើរហួសទៅមិនឧានជួយគេឲ្យផុតពីអន្តរាយផង យ៉ាង
នេះសីលមិនដាច់ទេ ប៉ុន្តែជាហេតុឲ្យគេតិះដៀលឧានថាជាអ្នកឲ្យាស
ចាកមេត្តាករុណាដល់មនុស្សមានទុក្ខវេទនា ព្រោះហេតុនេះ បុគ្គលអ្នក
រក្សាសីលតែម្យ៉ាងមិនទាន់ឧានឈ្មោះថាល្អមែនទែនទេ ឬថាមានធមិមិន
ទាន់ឧានទេ ត្រូវតែជាអ្នកប្រតិបត្តិធមិផង ទើបចាត់ថាល្អមែនទែន ឬមាន
ធមិឧាន ហើយឧានឈ្មោះថាជាអ្នកមានសីលមានធមិ ។

មួយទៀត អ្នករក្សាសីលដែលនឹងរក្សាឲ្យបរិសុទ្ធឧាន ត្រូវតែ
អាស្រ័យការប្រព្រឹត្តិធមិឲ្យជាគូគ្នា ។ សីលកាលមានធមិជាគ្រឿង
អប់រំហើយ នឹងដាច់ផ្ទុះធ្ទាយដោយកម្រណាស់ រមែងរឹងបុឹងមាំមួន ។
សីលដែលនឹងដាច់ផ្ទុះធ្ទាយទៅឧាន ក៏ព្រោះអាស្រ័យចិត្តមានអធ្យាស្រ័យ
ទៅត្រាតត្រាត ។ កាលចិត្តឧានអាស្រ័យធមិជាគ្រឿងអប់រំហើយ
រមែងមានអធ្យាស្រ័យល្អិតសុខុម ។ កាលបើចិត្តមានអធ្យាស្រ័យល្អិត
សុខុមល្អហើយ សីលនឹងមិនដាច់ទៅដោយងាយ។ ទេ ហេតុនេះ
អ្នករក្សាសីលលោកទើបប្រដៅឲ្យប្រព្រឹត្តធមិជាគូគ្នា ។ ធមិក្នុងទីនេះ
សំដៅយក កល្យាណធមិ ប្រែថា "ធមិដ៏ល្អ" ជាខប្រតិបត្តិដ៏
ពិសេស ត្រូវរក្សាឲ្យជាគូនឹងសីលឲ្យាំ ។ អ្នកដែលមានកល្យាណធមិ
ទៅក្នុងចិត្ត លោកហៅថា កល្យាណជន ប្រែថា "ជនល្អ"
កល្យាណធមិនោះលោកចែកទុកជា ៥ ប្រការ ជាគូគ្នានឹងសីល ៥ គឺ

១-	មេត្តានឹងករុណា	ត្ថនឹងសីលសិក្ខាបទទី	១
២-	សម្មាអាជីវ:	,,	២
៣-	សេចក្តីសង្រួមក្នុងកាម	,,	៣
៤-	ការមានសត្យ	,,	៤
៥-	ការមានសតិជុំវិញ	,,	៥

អធិប្បាយ

១.— មេត្តា ជានដល់ការផ្សាយមេត្រីចិត្ត គិតប្រាថ្នាឲ្យគេជានសុខ ។ ការផ្សាយមេត្តានេះប្រព្រឹត្តទៅដោយអាការ ២ យ៉ាង គឺផ្សាយទៅដោយចំពោះពួកគណៈរបស់ខ្លួន ឬបុគ្គលដែលខ្លួនជ្ជាប់ស្គាល់ ហៅថា ឧទ្ទិស្សផរណា ១, ការផ្សាយទៅក្នុងសត្វមិនមានប្រមាណ មិនចំពោះអ្នកណា ទោះបីជាសត្វឬបុគ្គល មិនកំណត់ពួកនោះពួកនេះ ហៅថា អនោទ្ទិស្សផរណា ១ ។

គុណធមិនេះជារបស់សំខាន់ក្រៃលែងរបស់ពួកមនុស្ស ជាហេតុឲ្យមានសេចក្តីគោរពរាប់អានគ្នា មានសេចក្តីអើពើជួយគ្នាទៅវិញទៅមកផ្សាយមេត្តាទៅដោយចំពោះ ជាហេតុឲ្យមនុស្សដែលខ្លួនផ្សាយមេត្តាទៅដល់នោះមានសេចក្តីស្រឡាញ់គោរពរាប់អាន គប្បីឃើញជូចយ៉ាងមាតាបិតាមានសេចក្តីមេត្តាក្នុងបុត្រធីតា ឈ្សាហ៍ទំនុកបម្រុងឲ្យជានទទួលសេចក្តីសុខជាយ៉ាងក្រៃលែង បុត្រធីតាក៏មានសេចក្តីស្រឡាញ់គោរព

មាតាបិតានោះយ៉ាងខ្ចាំងក្លា បើមាតាបិតាគ្មានមេត្តាក្នុងបុត្រធីតាទេ គ្រាន់
តែចិញ្ចឹមកុំឲ្យគេតិះដៀលប៉ុណ្ណោះ បុត្រធីតាក៏មិនសូវមានចិត្តស្រឡាញ់
គោរពមាតាបិតាណាស់ដែរ ។

ការផ្សាយមេត្តាដោយមិនចំពោះ ជាហេតុឲ្យមនុស្សទាំងឡាយ
មានសេចក្តីស្រឡាញ់គោរពរាប់អាន គប្បីឃើញជូចយ៉ាងបុគ្គលដែល
មិនធ្លាប់ស្គាល់គ្នាមកពីមុន ប៉ុន្តែលុះបានទទួលសេចក្តីអើពើផ្សាយមេត្តា
រកគ្នាទៅវិញទៅមកហើយ ត្រឡប់ជាមានសេចក្តីស្រឡាញ់គោរពរាប់
អានគ្នា នេះក៏ព្រោះមេត្តា ។ បើអ្នកទាំង ៦ ខាងចេះតែមានចិត្តបុស្យា
ឈ្នានីសគ្នា ធ្វើម្តេចនឹងស្រឡាញ់គ្នាកើត កុំថាតែមនុស្ស សូម្បីសត្ត
តិរច្ឆាន កាលបើបានទទួលសេចក្តីរាក់ទាក់ទំនុកបំរុងអំពីអ្នកណា ក៏គង់
តែចេះសំដែងអាការស្រឡាញ់ពេញចិត្តនឹងអ្នកដែលមានមេត្តាជល់រានោះ
ដែរ ព្រោះជូច្នោះ បានជាលោកប្រដៅឲ្យបំពេញទាន ។ នេះក៏ដើម្បីឲ្យ
ជាការសំដែងមេត្រីចិត្ត ។ មេត្តានេះជាគ្រឿងទំនុកបំរុងសីលសិក្ខាបទ
ទី ១ ឲ្យមាំមួនក្រៃលែងឡើង បើក្នុងកាលខ្លះកើតចិត្តព្យាបាទឈ្លោះ
ប្រកែកគ្នា កាលតាំងចិត្តផ្សាយមេត្តាទៅហើយ គឺតាំងចិត្តឲ្យគិតឃើញថា
យើងជាអ្នកស្រឡាញ់សុខ ស្អប់ខ្ពើមទុក្ខ រូបគេក៏ជូចជាយើងដែរ កាល
បើយើងធ្វើឲ្យគេមានសេចក្តីក្តៅក្រហាយ គេក៏មុខជាខានបានសុខ យើង
មិនគួរនឹងធ្វើឲ្យគេបានទុក្ខទេ លំដាប់នោះក៏នឹងធ្វើចិត្តបុស្យាឈ្នានីសព្យា-
បាទ ឲ្យស្រាកស្រាន្តថយចុះបានរហូតដល់លែងព្យាបាទគេជាទីបំផុត ។

ករុណា ជានដល់សេចក្តីអាណិតអាសូរ ជ្រាថ្នានឹងឲ្យគេផុតទុក្ខ ក្នុងវេលាអ្នកដទៃជានទទួលទុក្ខ ។ គុណធមិនេះចាត់ថាជាធមិដ៏សំខាន់, ប្រការមួយទៀត សឹងជាហេតុដែលនឹងធ្វើឲ្យមនុស្សគ្រប់ៗ រូបមានសេចក្តីជួយជ្រោមជ្រែងក្នុងរឿងទុក្ខកំយនៃគ្នានឹងគ្នា មិនអង្ពុយស្ស្ងមមើលបំណាំគ្នា ។ កាលបើគ្មានករុណាដល់គ្នាទេ គង់តែមានចិត្តអាក់អន់នឹងគ្នាខ្ទះមិនខាន, ករុណាជាគ្រឿងជាស់គ្រឿនចិត្តឲ្យគិតដល់សេចក្តីសុខទុក្ខរបស់អ្នកដែលខ្ជូនមិនពេញចិត្ត លំដាប់ពីនោះ ក៏នឹងកើតសេចក្តីអាណិតអាសូរមិនអាចបៀតបៀនគេជាន, ការមិនចូលចិត្ត មិនពេញចិត្ត ក៏អន់ថយតិចទៅ ដរាបដល់អស់រលីង ។

មេត្តានឹងករុណាទាំង ៦ នេះ ជាគ្រឿងកំចាត់វិហិង្សាវិតក្ក គឺគិតបៀតបៀនអ្នកដទៃ ។ កាលបើមនុស្សយើងចេះតែមានមេត្តាករុណាដល់គ្នានឹងគ្នាដូច្នេះគ្រប់ៗ រូបហើយ ការបៀនបៀនប្រទូសរ៉ាយគ្នាក៏លែងកើតមាន, ដូច្នេះ សីលសិក្ខាបទទី ១ ក៏នឹងរឹតតែតាំងមាំមួនខ្ចាំងឡើងលើសដើម ។

មេត្តានឹងករុណានេះ មានគុណប្រើនដូចពោលមកហើយ ប៉ុន្តែត្រូវប្រើក្នុងផ្ទូវដែលត្រូវ បើប្រើក្នុងផ្ទូវខុស ដូចជួយអ្នកត្រូវទោសព្រោះប្រពឹត្តខុសជាដើម មិនចាត់ជាមេត្តាករុណាទេ ហើយជានឈ្មោះថាទំនុកបម្រុងអ្នកធ្វើខុស, ផ្ទូវដែលល្អគួរតែពិចារណាថា ជាកម្មរបស់គេ

ដែលគេបានធ្វើខុសមកហើយ រួចត្រូវតាំងចិត្តឲ្យនៅជាកណ្តាល; មេត្តា
ធិ៍តុណាកាលបើប្រែខុសផ្លូវដូច្នេះ រមែងមានទោសច្រើនដូចគ្នា; នេះ
ចាត់ជាកល្យាណធម្មគួធិ៍សីលសិក្ខាបទទី ១ ។

២— សម្មាអាជីវៈ: បានដល់សេចក្តីព្យាយាមស្វែងរកគ្រឿង
ចិញ្ចឹមជីវិតក្នុងផ្លូវដែលត្រូវ; គុណធម៌នេះចាត់ថាជាធម៌សំខាន់ប្រការមួយ
របស់បុគ្គលអ្នករក្សាសីល ធិ៍ចាត់ថាជាគ្រឿងផ្គត់ផ្គង់សីលសិក្ខាបទទី ២
ឲ្យតែតែមាំមួនគ្រែវែងឡើង ។ បុគ្គលអ្នករក្សាសីលហើយ បានឈ្មោះ
ថាជាអ្នកលះវៀរចោកការស្វែងរកគ្រឿងចិញ្ចឹមជីវិតក្នុងផ្លូវដែលខុស សូម្បី
វៀរចោកការស្វែងរកក្នុងផ្លូវដែលខុសដូច្នោះហើយ ក៏ត្រូវតែទំស្វែងរកក្នុង
ផ្លូវដែលត្រូវផង (១) បើមិនទំស្វែងរកទេ គ្រឿងចិញ្ចឹមជីវិតរបស់ខ្លួនក៏ធិ៍ធិ
ខ្វះខាត កាលបើខ្វះគ្រឿងចិញ្ចឹមជីវិតហើយ កាយក៏គង់ធិ៍ឲ្យនៅ
មិនបាន ត្រូវតែស្លាប់ ឬមានអ្នកខ្វះបានអាស្រ័យបរិភោគទ្រព្យសម្បត្តិ
ចាស់ដែលមានស្រាប់ ប៉ុន្តែបើគ្មានទ្រព្យថ្មីបូលសោះ ទ្រព្យចាស់មុខ

---

១ ល្បួនប្បាប់ក្នុងព្រះពុទ្ធសាសនា សុទ្ធតែប្រដៅមនុស្ស ឲ្យមានព្យាយាមប្រឹងប្រែងទាំង
អស់ មិនដែលប្រដៅឲ្យខ្ជិលច្រអូសទេ គឺប្រដៅថា បើជាគ្រហស្ថត្រូវទំធ្វើការចិញ្ចឹមជីវិត ឬទំ
ប្រព្រឹត្តធម៌ឲ្យមែនទែន កុំខ្ជិល កុំធ្វេសប្រហែសឡើយ បើជាភេទបព្វជិតវិញ ត្រូវតែទំប្រឹង
ប្រព្រឹត្តធម៌ឲ្យខ្ជាំងក្លាលើសគ្រហស្ថទៅទៀត ។ ប៉ុន្តែរឿងនេះ មានអ្នកខ្វះដែលមិនយល់ច្បាស់
ក្នុងផ្លូវវិធីរបស់ព្រះពុទ្ធសាសនាសោះ ត្រឡប់ជាតិះដៀលថា ព្រះពុទ្ធសាសនាប្រដៅឲ្យមនុស្ស
ខ្ជិលច្រអូស អ្នកកាន់ពុទ្ធសាសនាសុទ្ធតែជាមនុស្សទម្រន់ ពួកអ្នកបួសជាមនុស្សខ្ជិលណាស់
តែបានការអ្វីសោះ ។ អ្នកមានគំនិតបែបនេះខុសស្រឡះ ព្រោះតែខ្លួនល្ងង់ខ្លៅ ឬខ្លួនមិនធ្លាប់
ហែល ជានដាហ៊ានថាស្មុគស្មាញបំពានផ្លូវប្លែ ។

ជារលស់អស់ទៅរាល់ថ្ងៃរហូតដល់ផុតអស់រលីងឥតសល់អ្វី, បើទ្រព្យ
ចាស់អស់រលីងហើយ សេចក្តីតាល់ក្រចូលមកសង្កត់កយ៉ាងធ្ងន់ តាល់
តែត្រាំរក្សាសីលតទៅទៀតមិនបាន នឹងត្រូវបែរក្សាលចុះទៅកាន់កាពជា
មនុស្សថោកតាបម្ពងទៀត ព្រោះហេតុនោះ លោកទើបប្រដៅឲ្យអ្នក
ដែលតាំងនៅក្នុងសីល ឲ្យមានព្យាយាមខំប្រឹងប្រែងស្វែងរកគ្រឿងចិញ្ចឹម
ជីវិតកុំឲ្យខ្ជិលច្រអូស ប៉ុន្តែឲ្យស្វែងរកតែក្នុងផ្លូវដែលត្រូវធម៌ជូចយ៉ាងដែល
ហៅថា សម្មាអាជីវ: ។ ការស្វែងរកក្នុងផ្លូវត្រូវតាមគន្ធងធម៌ក្នុងទីនេះ
មិនមែនសំដៅយកតែត្រឹមថា ឲ្យវៀរចាកមិច្ឆាជីវ:ប៉ុណ្ណោះទេ កាលបើ
វៀរចាកមិច្ឆាជីវ:ហើយ ត្រូវប្រកបដោយសេចក្តីប្រព្រឹត្តិជាធម៌ក្នុងការ
ស្វែងរកគ្រឿងចិញ្ចឹមជីវិតផង រឿងនេះគប្បីយើញសេចក្តីប្រព្រឹត្តិជាធម៌
ក្នុងកិច្ចការ ក្នុងបុគ្គល ក្នុងវត្ថុ ដូចតទៅនេះ ៖

សេចក្តីប្រព្រឹត្តិជាធម៌ក្នុងកិច្ចការ: ការងារគ្រប់យ៉ាងដែលខ្លួន
ត្រូវធ្វើហើយនឹងបានទទួលផលប្រយោជន៍អំពីគេ ត្រូវតែតាំងចិត្តធ្វើឲ្យ
មែនទែន សំដៅយកផលជាធំ កុំគិតតែចង់បានមួយចំណែក ដូចជាខ្ញុំ
រាជការបានទទួលផលប្រយោជន៍អំពីរដ្ឋបាល ត្រូវតែតាំងចិត្តធ្វើការឲ្យ
រដ្ឋបាលមែនទែនរក្សាកិច្ចការជាមុខក្រសួងរបស់ខ្លួនកុំឲ្យខ្ជះខាត ធ្វើកិច្ច
ការនោះ។ ឲ្យសម្រេចទៅដោយល្អ មិនបិទបាំងមុខក្រសួង ធ្វើឲ្យ
ពេញលេញតាមកំណត់កាលវេលា កាលមកធ្វើការ ក៏មកឲ្យត្រឹមត្រូវ

តាមពេល កាលនឹងត្រឡប់ទៅផ្ទះវិញ ក៏ត្រឡប់ឲ្យត្រឹមត្រូវតាមពេល រួមសេចក្តីថា កុំធ្វើដោយឃើញតែបាន ។ សូម្បីកិច្ចការយ៉ាងដទៃ ។ ដែលខ្លួនត្រូវបានទទួលផលប្រយោជន៍អំពីគេ ក៏ត្រូវធ្វើដោយស្មោះត្រង់ កុំយកចំណេញយកប្រៀបគេ ធ្វើឲ្យសមគួរដល់ការដែលនឹងបានទទួលប្រយោជន៍អំពីគេ នេះឈ្មោះថាសេចក្តីប្រព្រឹត្តិជាធម្មិកឯកិច្ចការ ។

សេចក្តីប្រព្រឹត្តិជាធម្មិកក្នុងបុគ្គល: ការងារដែលត្រូវធ្វើ សុទ្ធតែជាប់ជំពាក់នឹងមនុស្សទូទៅ ក៏ត្រូវធ្វើឲ្យស្មើ មិនយល់មុខថាអ្នកនោះអ្នកនេះ ដូចជាឈ្មួញ កាលយករបស់មកលក់ត្រូវតំណាត់ថា យើងនឹងលក់យកចំណេញប៉ុន្មាន ហើយទើបបានលក់ កាលលក់ក៏ត្រូវលក់ឲ្យស្មើមុខគ្នា ដូចជាលក់ឲ្យអ្នកនេះ ថ្លៃប៉ុណ្ណេះ កាលលក់ឲ្យអ្នកដទៃក៏ឲ្យដំឡៃស្មើគ្នាដែរ កុងរបស់ដូចគ្នា ទោះអ្នកទិញជាមនុស្សជាន់ណាក៏ដោយ ត្រូវលក់ឲ្យដំឡៃស្មើគ្នាជាដរាប មិនត្រូវលក់ឲ្យខុសដំឡៃគ្នាដូច្នេះជាដើម នេះឈ្មោះថាប្រព្រឹត្តជាធម្មិកឯបុគ្គល ។

សេចក្តីប្រព្រឹត្តិជាធម្មិកក្នុងវត្តុនោះ: ដូចបុគ្គលដែលជាអ្នកជំនួញនោះ កាលនាំយកទំនិញមកលក់តែងដឹងថា របស់នោះល្អ របស់នោះមិនល្អ កាលលក់ក៏ប្រាប់អ្នកទិញតាមពិត ដូចរបស់សុទ្ធក៏ប្រាប់ថាសុទ្ធ របស់កៃងក្លាយក៏ប្រាប់ថាកៃងក្លាយ របស់ល្អក៏ប្រាប់ថាល្អ

មិនល្អក៏ប្រាប់ថាមិនល្អ ប្រាប់តាមការពិតនៃវត្ថុនោះ។ មិនកុហកបញ្ឆោត ជូចរបស់មិនល្អប្រាប់ថាល្អ របស់ក្លែងក្លាយប្រាប់ថារបស់សុទ្ធជាដើម. នេះឈ្មោះថាសេចក្ដីប្រព្រឹត្ដិជាធម្មិក្នុងវត្ថុ ។

មួយទៀត អ្នកមានសីល សូម្បីវៀរចាកការងារដែលជាទោស ដោយត្រង់ជូច្នោះហើយ ក៏នៅតែត្រូវលះវៀរការងារបែបខ្លះទៀត ដែលជាផ្លូវខូចខាតចាកទ្រព្យសម្បត្ដិ ជូចជាស្វែងរកទ្រព្យក្នុងការក្នាល់ ។ ល្បែងក្នាល់ជាការនាំឲ្យខូចកេរ្ដ៍ឈ្មោះ ជួនកាលដេកកើតទុក្ខ ជួនកាលខូចខាតទ្រព្យ ។ ឯទ្រព្យដែលបានមកអំពីការក្នាល់នោះ មិនគង់ទ្រង់អង្វែងដោយហេតុ ៦ យ៉ាង គឺ ១ បានមកងាយប្រើនតែមិនសូវស្ដាយ ចាយវាយងាយ ទុកមិនគង់, ៦ ការចង់បានគ្មានទីបំផុត ទោះបីបានប៉ុន្មានក៏នៅតែមិនគ្រប់គ្រាន់ដែរ ចេះតែខំលេងតទៅទៀត គង់តែមានពេលក្លាត់ចាញ់គេមួយគ្រា ។ ទ្រព្យដែលបានមកដោយងាយជូច្នេះ មានសេចក្ដីស្រឡាញ់មិនជូចទ្រព្យដែលបានមកដោយត្រូវចេញដើមទុន ចេញកំ-ឡាំងទេ ។ ទ្រព្យដែលរកបានមកហើយ ត្រូវចេះរក្សានឹងចាយវាយប្រើប្រាស់ឲ្យជាប្រយោជន៍ គឺទំនុកបម្រុងខ្លួនឯងខ្លះ ទំនុកបម្រុងអ្នកដែលគួរទំនុកបំរុងខ្លះ កាលមានហេតុគួរប្រើទើបប្រើ មិនចេះតែចាយវាយខ្ជះខ្ជាយទាល់តែហួសប្រមាណ នឹងមិនត្បិតត្បៀតខ្លាំងពេក ។

មនុស្សគ្រប់រូប កាលបើនាំគ្នាប្រកបការងារដ៏ប្រាសចាកទោស

ប្រកបតែក្នុងផ្ទូវត្រូវជូចពោលមកនេះហើយ រមែងបានទទួលសេចក្តីសុខ
សប្បាយ មិនត្រូវមានភ័យមានពៀរនឹងអ្នកណាឡើយ ។

សម្រាប់អ្នករក្សាសីល កាលតាំងនៅក្នុងសម្ងាអាជីវៈជូច្នេះហើយ
រមែងជាផ្ទូវដែលនឹងឲ្យរក្សាសីលសិក្ខាបទទី ២ បានបរិសុទ្ធ សីលរបស់
ខ្លួនក៏នឹងមិនពពាលមិនពព្រុះ ព្រោះហេតុនោះ គុណធមិនេះលោក
ទើបចាត់ថាជាកល្យាណធម៌ប្រការមួយ សម្រាប់បំពេញឲ្យជាគូគ្នាទៅ
នឹងសិក្ខាបទទី ២ ។

៣.— សេចក្តីសង្រួមក្នុងកាម បានដល់កិរិយាដែលមិនប្រ-
ព្រឹត្តល្មោភក្នុងកាម ធ្វើសេចក្តីត្រេកអរក្នុងកាមតាមប្រមាណដែលមាន;
គុណធមិនេះចាត់ថា ជារបស់សំខាន់ក្នុងកិរិយានឹងតាំពារសីលសិក្ខាបទ
ទី ៣ ឲ្យគង់ស្ថិតស្ថេរ នឹងជាគ្រឹងចង្អុលបង្ហាញសេចក្តីបរិសុទ្ធិរបស់
បុរសស្ត្រីឲ្យឃើញច្បាស់ ។ អ្នកដែលលះវៀរចាកកាមហើយ ប៉ុន្តែ
នៅប្រព្រឹត្តខ្លួនឲ្យជាមនុស្សរិលវល់ឈ្ងក់នៅក្នុងកាម ក៏ត្រូវចាត់ថាជាអ្នក
មានមន្ទិល មិនមែនជាអ្នកបរិសុទ្ធស្អាត ។

សម្រាប់បុរស កាលមានភរិយាហើយ ក៏ត្រេកអរពេញចិត្តនៅ
តែក្នុងភរិយារបស់ខ្លួន មិនគួរនឹងទៅស្ទ្រីគ្រស្មោះលបស្រឡាញ់ស្រីដទៃ
ឡើយ កាលបើខ្លួនមានប្រពន្ធហើយយ៉ាងណា ក៏គប្បីតាំងសេចក្តី
ស្សាហ៍ចិញ្ចឹមរក្សាគ្នាទៅ បើទុកជាក្រលំបាកយ៉ាងណាក៏មិនត្រូវលះ

បង់ចោលគ្នាដែរ នេះឈ្មោះថាជាអ្នកតាំងនៅក្នុង សទារសត្ថោស ប្រែថា "ត្រេកអរតែក្នុងកិយារបស់ខ្ជូន," អ្នកប្រតិបត្តិខ្ជូនបានជូច្នេះ រមែងជាទីគ្ជូរសរសើរ ទាំងជាទីស្រឡាញ់ទុកចិត្តរបស់អ្នកជិតផង ។

សម្រាប់ស្ត្រី កាលមានស្វាមីហើយ ក៏ត្រេកអរនៅតែក្នុងស្វាមីរបស់ខ្ជូន តាំងចិត្តទំនុកបម្រុងបំរើស្វាមីរបស់ខ្ជូនមិនទៅស្ម៉ីគ្រស្មោះរួមរក្សស្រឡាញ់ប្រុសជិត សូម្បីស្វាមីរបស់ខ្ជូនមានសេចក្តីទាល់ក្រលំបាកយ៉ាងណាក៏ដោយ មិនសំដែងអាការព្រងើយកន្តើយសោះអង្គើយនឿយណាយរសាយចិត្តចេញពីស្វាមីរបស់ខ្ជូនដែរ ស្ត្រីជូច្នេះ បានឈ្មោះថាមានសេចក្តីប្រព្រឹត្តិធមិដ៏ល្អប្រពៃក្នុងស្វាមីរបស់ខ្ជូន រមែងជាទីទុកចិត្តរបស់ស្វាមី នឹងជាទីសរសើររបស់ជនទូទៅ ។

មួយទៀត ប្រុសដែលមានកិយារួចហើយ ឬក៏នៅលីវមិនទាន់មានប្រពន្ធទេ ដែលទៅកពប្រសពនឹងស្រីជិតមានស្រីពេស្យាជាដើម សូម្បីមិនចាត់ថាជាកាមេសុមិច្ឆាចារ ក៏នៅតែជាហេតុឲ្យបានទទួលសេចក្តីវិនាសច្រើនប្រការ គឺ ៖

ក)- ត្រូវបង់ទ្រព្យ ព្រោះការទំនុកបម្រុងស្រីនោះ តាំងពីត្រូវចាយវាយក្នុងការបណ្តើរគ្នាលេង នឹងបរិភោគដេកអង្គុយរហូតទៅដែលជាការមិនគ្ជូរឲ្យខូចខាតទ្រព្យ ។

ខ)- ជាអណ្ឌូងកើតនៃរោគ, បណ្តារោគទាំងអស់ រោគដែល

តើតអំពីស្រីពេស្យា ដែលហៅថា "តាមភេត" នេះតាប់ថាជាភេតយ៉ាងតាច អាក្រក់ម្យ៉ាង អាចធ្វើឲ្យអាយុវែងតាយពិតលពិតារខ្លាច ក្នុងទីបំផុតក៏ដល់ស្លាប់ បើមិនស្លាប់ទេ ភេតនេះក៏អាចជាប់ធ្ងន់ខ្លាចដល់ការយានឹងបុត្រារបស់ខ្លួន ធ្វើឲ្យការយានឹងបុត្រារបស់ខ្លួនបានខូចខ្លួលខ្ទុកជាមួយផង ។

ក)_ ជីតជីតធំឯអង្គរាយណាស់, ធម្មតាស្រីពេស្យាតែងតែស្នេហ៍ស្និទ្ធស្រឡាញ់ប្រុសច្រើននាក់ តាលបើប្រុសតើតមានសេចក្តីហិង្សាប្រដែងគ្នាហើយ ក៏នឹងតើតឈ្លោះវាទគ្នាខ្លះ ប្រខូសរ៉ាយកាយគ្នាខ្លះ ។

សម្រាប់ស្ត្រីគ្មានស្វាមី ក៏មិនគួរខ្លាចនឹងស្រឡាញ់បុរស សូម្បីជាប្រុសដែលមិនត្រូវហាមប្រាមក៏មិនគួរដែរ ព្រោះជាខ្លួចក្តើរឈ្លោះនឹងអាចឲ្យខូចទាតទ្រព្យសម្បត្តិព្រោះការចិញ្ចឹមប្រុស ។

ទោសដែលពោលមកនេះ អាស្រ័យសេចក្តីមិនស្ងប់ក្នុងកាមជាហេតុ ព្រោះដូច្នោះ លោកទើបប្រដៅឲ្យសង្រួមក្នុងកាម; កាលបើមានសេចក្តីសង្រួមក្នុងកាមហើយ ការរក្សាសីលក្នុងសិក្ខាបទទី ៣ ក៏នឹងតាំងនៅបានដោយមាំមួន ហេតុនេះ សត្ថាសន្តោស លោកទើបចាត់ជាកល្យាណធម្មប្រការមួយ ឲ្យបំពេញជាគូគ្នានឹងសីលសិក្ខាបទទី ៣ ។

ង_ សេចក្តីមានសត្យ: ការប្រព្រឹត្តិខ្លួនជាមនុស្សត្រង់ ហៅថាមានសត្យ ចាត់ជាគុណធម៌ដ៏សំខាន់ប្រការមួយ ដែលជាគ្រឿងផ្គត់ផ្គង់

សីលសិក្ខាបទទី ៤ ឲ្យមាំមួនស្ថិតស្ថេរ មានប្រភេទដែលនឹងគប្បីវិភាគ ជាដូចតទៅនេះ ៖

ក)- សេចក្តីទៀងក្នុងធម៌ ជាដល់សេចក្តីប្រតិត្តិខ្លួនជាធម្ម ក្នុងកិច្ចការដ៏ជានាទីរបស់ខ្លួន កាលនឹងធ្វើអ្វីមិនធ្វើឲ្យខុសដោយអំណាច អគតិ ៤ គឺ ឆន្ទាគតិ សេចក្តីលំអៀងព្រោះស្រឡាញ់ ទោសាគតិ សេចក្តីលំអៀងព្រោះមិនត្រូវគ្នាស្អប់គ្នា មោហាគតិ សេចក្តីលំអៀងព្រោះល្ងង់ខ្លៅ ភយាគតិ សេចក្តីលំអៀងព្រោះខ្លាច ។

គប្បីឃើញដូចអ្នកវិនិច្ឆ័យកាត់ក្តី ជាក់ខ្លួនជាកណ្តាល កាត់សេចក្តីទៅដោយធម៌ មិនទន់ទៅបក្សខាងពួកដែលខ្លួនស្រឡាញ់ មិនសង្កត់សង្កិនខាងពួកដែលខ្លួនស្អប់ ជាដឹងហេតុផលល្អហើយទើបកាត់សេចក្តី ឥឡូវមិនខ្លាចផ្លូវខាងនោះខាងនេះ ឬសូម្បីមនុស្សដទៃ ។ ក៏ប្រកាន់យកតែសេចក្តីត្រឹមត្រូវជាធំ ។

ខ)- សេចក្តីស្មោះត្រង់ ជាដល់សេចក្តីប្រតិត្តិត្រង់ចំពោះបុគ្គលជាមិត្ត ឬសូម្បីដល់អ្នកដទៃ ។ គប្បីឃើញតួយ៉ាងក្នុងមិត្តអ្នកវៀរចាកគោល ៤ ស្ថាន គឺមនុស្សគិតតែប្រយោជន៍ខ្លួន, មនុស្សល្អតែមាត់, មនុស្សប្រចុប, មនុស្សដើរនាំក្នុងផ្លូវវិនាស, ហើយជាអ្នកប្រកបដោយភាពជាមនុស្សមានឧបការ, មនុស្សរួមសុខរួមទុក្ខ, មនុស្សប្រាប់ប្រយោជន៍មិត្ត ដូច្នេះជានេះឈ្មោះថាស្មោះត្រង់ចំពោះមិត្ត ។

គ)- សូមីភ៉ាត្ថិ បានដល់សេចក្តីស្រឡាញ់ភក្តីក្នុងចៅហ្វាយ
នាយរបស់ខ្លួន កាលបើខ្លួនព្រមលើកឲ្យអ្នកណាធ្វើជាចៅហ្វាយនាយ
របស់ខ្លួនហើយ ខ្លួនក៏តាំងចិត្តប្រព្រឹត្តស្មោះត្រង់សុចរិត មិនគិតឧយិស
ចំពោះបុគ្គលនោះ ចាំជួយមើលនឹងជាកំឡាំងក្នុងកិច្ចតូចធំតាំងពួង រហូត
ដល់ជួយការពារវាងសេចក្តីអាក្រក់វិនាស មិនឲ្យកើតឡើងដល់ចៅហ្វាយ
នាយរបស់ខ្លួន ក្នុងទីបំផុត សូម្បីជីវិតក៏អាចលះបង់ជួសបាន មានចិត្ត
ស្រឡាញ់ភក្តីជានិច្ចមិនបែកចិត្ត នេះបានឈ្មោះថាជាអ្នកស្វាមីភក្តិ ។

ឃ)- សេចក្តីកតញ្ញូ បានដល់សេចក្តីដឹងឧបការៈដែលលោក
បានធ្វើហើយដល់ខ្លួន ជាគូគ្នានឹងកតវេទី ដែលប្រែថា អ្នកដឹងឧបការៈ
ដែលលោកធ្វើហើយ នឹងធ្វើតបវិញ តែក្នុងទីនេះមិនបានប្រាថ្នាយ៉ាង
នោះ ប្រាថ្នាតែត្រឹមមិនភ្លេចគុណរបស់លោក ដូចខ្លួនបានទទួលឧបការ
គុណអំពីលោកអ្នកដទៃដូចមាតាបិតាជាដើម ក៏មិនភ្លេចគុណរបស់លោក
ដែលបានធ្វើឧបការៈឲ្យខ្លួនដំកល់លោកទុកក្នុងហានៈដែលជាអ្នកមានគុណ
មានសេចក្តីគោរពរាប់អានលោក មិនជាមនុស្សលុបគុណរបស់លោក ។

ព្រោះដូច្នោះ សេចក្តីមានសត្យ ទើបចាត់ថាជាគុណធមិដ៏សំខាន់
ក្រៃលែងក្នុងការដែលនឹងទំនុកបម្រុងសីលសិក្ខាបទទី ៤ ឲ្យមាំមួនឡើង ។
កាលបើមិនមានសេចក្តីសត្យសុចរិតទេ សីលនេះក៏នឹងបែកធ្លាយទៅបាន

ដោយងាយ ហេតុនោះ សេចក្តីមានសត្យ លោកគេបចាត់ជាកល្យាណ-ធម៌ប្រការមួយ សម្រាប់ប៉ាពេញជាគួគ្នានឹងសីលសិក្ខាបទទី ៤ ។

៥– សេចក្តីមានសតិជុំវិញ ចានដល់សេចក្តីមិនកយមាយ មិនភ្ជាចស្ងារតី កាលនឹងធ្វើកិច្ចការអ្វីៗ ក៏ឲ្យមានសតិសម្ឆជញ្ញៈចាំត្រួតត្រា រវាំងប្រយ័ត្នមិនឲ្យខុសភ្ជាត់ ។ គុណធម៌នេះ ពប់ថាជាកិច្ចសំខាន់ប្រការមួយ ដែលនឹងផ្គត់ផ្គង់សីលទុកឲ្យមាំមួន ។ សីលគ្រប់ខដែលនឹងជាប់ធ្ជុះធ្ជាយទៅចាន ក៏ព្រោះភាពជាអ្នកមិនមានសតិសម្ឆជញ្ញៈចាំពិនិត្យពិចារណា ។ អ្នកដែលប្រើសតិសម្ឆជញ្ញៈប្រចាំការ នឹងធ្វើអ្វីក៏មិនខុសមិនភ្ជាំងភ្ជាត់ ព្រោះជូច្នោះ ភាពជាអ្នកមានសតិជុំវិញ លោកគេបចាត់ថាជាធម៌ផ្គត់ផ្គង់សីលឲ្យមាំមួន មានប្រភេទដែលនឹងលើកឡើងពោលក្នុងទីនេះ ៤ ប្រការ ៖

(ក– សេចក្តីស្គាល់ប្រមាណក្នុងអាហារដែលនឹងបរិភោគ: អាហារនោះតាមធម្មតាក៏មានប្រយោជន៍ដល់ពងកាយ ធ្វើឲ្យពងកាយគង់ទ្រង់នៅចាន បើមនុស្សយើងមិនចានអាស៊ីយអាហារទេ ជីវិតពងកាយក៏គង់ទ្រង់នៅមិនចាន តាមធម្មតាជាយ៉ាងនេះក៏មែនហើយ ប៉ុន្តែសូម្ឆីជូច្នោះក៏ត្រូវតែអាស៊ីយភាពជាអ្នកដឹងប្រមាណ បរិភោគតែល្មមសមគួរ បើមិនជូច្នោះទេ អាហារនោះឯងនឹងភ្ជាយទៅជាទោសវិញ ហេតុនេះគប្ឆីវៀរចាករបស់ដែលជូរប្អូម ដែលនឹងកឲ្យកើតទោស មិនបរិភោគឲ្យ

ប្រើនពេកឬឲ្យតិចពេក ឲ្យពិចារណាមើលថា អាហារណាជាទោសដល់រាងកាយ អាហារណាជាប្រយោជន៍ ត្រូវចាកអាហារដែលជាទោស បរិភោគតែអាហារដែលមានប្រយោជន៍ ។ បើមិនមានសេចក្តីដឹងស្គាល់ប្រមាណទេឲ្យតែយើញអាហារក៏ចេះតែបរិភោគទៅដូច្នេះ រមែងជាទោសកឲ្យកើតសេចក្តីទុក្ខលំបាកដល់រាងកាយបានក្នុងពេលខ្លះ ព្រោះដូច្នោះលោកទើបប្រដៅឲ្យដឹងស្គាល់ប្រមាណក្នុងអាហារ ។

៧)– សេចក្តីមិនធ្វេសប្រហែសក្នុងការងារ: បានដល់កិរិយាដែលមិនព្រងើយកន្តើយ បណ្តែតបណ្តោយលះចោលធុរៈក្នុងកិច្ចការងារដែលខ្លួនត្រូវធ្វើឲ្យខូចខាត ប្រញាប់ចាត់ចែងប្រញាប់ធ្វើឲ្យរួចស្រេច នឹងធ្វើឲ្យត្រូវតាមកាលៈទេសៈ គប្បីយើញដូចយ៉ាងធ្វើស្រែចម្ការ នឹងត្រូវតែប្រញាប់ចាត់ចែងធ្វើឲ្យត្រូវតាមរដូវកាល បើបង្អង់ទុកទៅធ្វើក្នុងវេលាមិនមែនរដូវកាល ក៏ឥតបានផល ។ សូម្បីការលក់ដូរជួញប្រែក៏ត្រូវតែពិចារណាឲ្យសមគួរតាមកាល ត្រូវគិតទុកជាមុនថារបស់លក់វេលានោះវេលានេះនឹងបានថ្ងៃប្រើនឬតិច - របស់ណាមានមនុស្សត្រូវការប្រើន របស់ណាមិនសូវមានគេត្រូវការចង់បាន, បើជាកិច្ចការរឹតតែស្អិតសំខាន់ឡើង ក៏ត្រូវតែខំពិចារណាឲ្យប្រើនដែរដូចធ្វើរាជការ ត្រូវតែជាអ្នកចេះដឹងយល់ច្បាស់ក្នុងវិធីដំណើរការ ប្រុងប្រយ័ត្នឲ្យប្រើនណាស់ នឹងត្រូវតែរក្សារបៀបទុកមិនឲ្យភ្ជាំងភ្ជាត់; អ្នកដែលមានសេចក្តីប្រយ័ត្នដូច្នេះ ឈ្មោះថាមិនធ្វេសប្រហែសក្នុងកិច្ចការ ។

គ)- សេចក្តីមានសម្បជញ្ញៈក្នុងការប្រព្រឹត្តិខ្លួន: ចានដល់
កិរិយាដែលដឹងជុំវិញ ក្នុងការដែលខ្លួននឹងធ្វើ នឹងនិយាយ នឹងគិត
ប្រុងប្រយ័ត្នមិនឲ្យក្ខាំងក្ខាត់ នឹងធ្វើ នឹងនិយាយ នឹងគិត ក៏ទាំងគិតពិចា-
រណាមើលមុខមើលក្រោយ ផ្ទូវចានផ្ទូវបង់ឲ្យរៀបរយសព្ទត្រប់ កាល
បើដឹងថាយ៉ាងណានឹងជាត្រឿងវិនាសជាផ្ទូវឲ្យកើតទោស ក៏រៀរចេញ
ប្រកបតែផ្ទូវដែលមានគុណ ដូច្នេះ រមែងជាបច្ច័យឲ្យធ្វើការអ្វីៗ មិនក្ខាត់
ខុស នេះឈ្មោះថាសេចក្តីមានសម្បជញ្ញៈក្នុងការប្រព្រឹត្តិខ្លួន ។

ឃ)- សេចក្តីមិនប្រមាទក្នុងធម៌: ចានដល់សេចក្តីញ្ញាំងបញ្ញា
ចុះពិចារណាឲ្យយើញតាមសភាពសេចក្តីកើតពិតរបស់សង្ខារថា មនុស្ស
យើងដែលកើតមកក្នុងលោកនេះ រមែងត្រូវមានសេចក្តីចាស់ឈឺស្ទាប់ជា
ធម្មតា ជាយ៉ាងនេះស្មើគ្នាទាំងអស់ ផ្សេងគ្នាតែត្រង់ធាប់ឬយូរប៉ុណ្ណោះ
ទេ ។ កាលបើយើញតាមកើតពិតហើយ មិនធ្វើខ្លួនឲ្យជាមនុស្សម្លមៅ
ស្រឹងជាប់នៅក្នុងសេចក្តីសុខដែលមានប្រមាណតិច ប្រញាប់ប្រញាល់
ធ្វើសេចក្តីល្អប្រឹត ធ្វើខ្លួនឲ្យជាប្រយ៉ាជន៍ដល់ខ្លួនដល់អ្នកដទៃ ឲ្យសម
គ្នានឹងភាពជាអ្នកដែលរស់នៅអាស្រ័យលោក កាលយល់យើញថាកិច្ច
ឯណាធ្វើមិនទាន់ចានសម្រេច ឬមិនទាន់ធ្វើនៅឲ្យើយ ក៏ខំប្រញាប់ចាត់
ចែងធ្វើកិច្ចនោះឲ្យរួចស្រេចទៅ កាលវេលាសេចក្តីស្ទាប់នឹងមានមក
ដល់ ក៏នឹងមិនចានន៏កស្តាយក្រោយថា ការយ៉ាងនោះយ៉ាងនេះយើង

មិនពាន់ជានធ្វើ បើជានធ្វើរួចស្រេចហើយ សូម្បីនឹការលឹកឃើញក្នុង
រៀលាណា ក៏រមែងជានទទួលសេចក្តីរីករាយក្នុងកិច្ចការដែលខ្លួនជានចាត់
ចែងធ្វើឲ្យស្រេចហើយនោះ ។

មួយទៀត សេចក្តីល្អនឹងសេចក្តីអាក្រក់ ជារបស់ដែលមនុស្សគ្រប់
រូបមិនគួរប្រមាទ ព្រោះធម៌ទាំង ៤ នេះឲ្យផលមិនស្មើគ្នាទេ សេចក្តីល្អឲ្យ
ផលជាសុខ សេចក្តីអាក្រក់ឲ្យផលជាទុក្ខ សេចក្តីល្អជារបស់ដែលមនុស្ស
គ្រប់រូបគួរប្រញាប់បំពេញ សេចក្តីអាក្រក់ជារបស់ដែលគួរវៀរដោយ
ជាច់ខាត, សូម្បីសេចក្តីអាក្រក់ ខ្លួននឹងធ្វើតែត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ក៏
មិនគួរធ្វើដែរ ការធ្វើបន្តិចម្តង ៗ នោះឯង នឹងជាហេតុឲ្យច្រើនឡើងជាន ។
សេចក្តីល្អនោះឯងគួរតែព្យាយាមធ្វើឲ្យច្រើនឡើង ប៉ុន្តែ បណ្តាសេចក្តី
ល្អនឹងសេចក្តីអាក្រក់ទាំង ៤ នេះ សេចក្តីល្អច្រើនតែធ្វើជានក្រជាងសេចក្តី
អាក្រក់ ត្រូវតែអាស្រ័យសេចក្តីព្យាយាមខំប្រឹងធ្វើ សូម្បីខាងដើមមិន
ចូលចិត្តចង់ធ្វើសោះ ក៏ត្រូវតែខំប្រឹងទង់ទាញចិត្តឲ្យទាល់តែមានអធ្យា-
ស្រ័យថ្នឹកប្ដជាប់ស្ទិទ្ធ ឯសេចក្តីល្អដែលជានធ្វើឲ្យកើតមានឡើងក្នុងខ្លួន
ហើយ សេចក្តីល្អនោះរមែងនឹងជាទិពឹងរបស់ខ្លួនជាន ទាំងក្នុងបច្ចុប្បន្ន
នឹងភពមុខ; កាលបុគ្គលជានប្រតិបត្តិខ្លួនឲ្យដំណើរទៅតាមធម៌ ដែល
ពោលមកនេះហើយ ឈ្មោះថាជាអ្នកមិនប្រមាទក្នុងធម៌ ។

ការមានសតិជុំវិញនេះ កាលមាននៅក្នុងខ្លួនហើយ រមែងនឹងជា
បច្ច័យឲ្យតាំងខ្លួនទុកក្នុងគុណធម៌ដែលល្អ នឹងធ្វើ នឹងនិយាយ នឹងគិត

មិនឧស មិនភ្លាត់ ចាត់ថាជាគ្រឿងប្រដាប់របស់អ្នកមានសីល ធ្វើឲ្យ
សីលដែលឲ្ជនរក្សារឹតតែមាំមួនៃក្រលែងឡើង លោកគើបចាត់សតិថាជា
កល្យាណធម៌ប្រការមួយ សម្រាប់បំពេញជាគូនឹងសីលសិក្ខាបទទី ៥ ។

កល្យាណធម៌ ៥ ប្រការដូចពោលមកនេះ សូម្បីតែ ១ ប្រការក៏រមែង
ជាគ្រឿងទំនុកបម្រុងសីលឲ្យមាំមួនបានដែរ ប្រៀបដូចស្នូលដែកដែល
នៅក្នុងសសរស៊ីម៉ង៍ត៍ រមែងធ្វើឲ្យសសរនោះរឹងប៉ឹងមាំទាំឲ្យាំងឡើងទៀត
ហេតុនោះ មនុស្សគ្រប់រូបគួរតែបំពេញធម៌ទាំង ៥ ប្រការនេះឲ្យជាគូគ្នា
នៅនឹងសីលជាប់ជានិច្ចចុះ ។

គោលដែលត្រូវចាំក្នុងសីលដឹងធម៌		
សីលសិក្ខាបទ ៥		កល្យាណធម៌ ៥
១ - បាណាតិបាត	ជាគូនឹង	មេត្តា, ករុណា
២ - អទិន្នាទាន	- ជ -	សម្មាអាជីវៈ
៣ - កាមេសុមិច្ឆាចារ	- ជ -	សទារសន្តោស
៤ - មុសាវាទ	- ជ -	សច្ច
៥ - សុរាមេរយ	- ជ -	សតិ

បញ្ញាសជាតក

កាតដី ៣

បណ្ឌិតមហា ឈឹម - សុំម សាស្ត្រាចារ្ស

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រៃហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្ជនឯង

កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៩៦, ត.ស. ១៩៤៣

(តមក)

ឧលកបណ្ឌិតដី ១១

លោកអាចារ្ស ឈឹម - ណាក ក្រុមជំនុំព្រះត្រៃបិដក

ប្រៃពីបាលី

(ត - ចប់)

ហៃកូនជាទីស្រឡាញ់ពេញចិត្តម្តាយ! ហៃកូនជាទីស្រឡាញ់ស្នើហ្ហុទ័យម្តាយ! ហៃកូនជាទីស្រឡាញ់ស្នើជីវិតមាសម្តាយ! តាំងពីដើមរហូតមកទល់នឹងកាលឥឡូវនេះ កូនមិនដែលបានសេចក្តីលំបាកវេទនាសោះ ម្តេចឡើយក៏កូនប្រុសមកស្លាប់អសារឥតការយ៉ាងនេះ? បើតែដូច្នេះ សមម្តាយនឹងបែកទ្រូងស្លាប់ពុំខាន, ចូរកូនកល្យាណអ្នកត្រឡប់ទៅវិញឲ្យធាប់ ។ ។

ពោធិសត្វជម្រាបមាតាវិញថា បពិត្រព្រះមេមានគុណធ្ងន់! សូមលោកកុំមានប្រសាសន៍យ៉ាងនេះឡើយ, ជ្យិតឯុំបាទ លះជីវិតចំពោះព្រះ

ពុទ្ធ ព្រះធម៌ ព្រះសង្ឃ, សូមលោកកុំហាមឃាត់ខ្ញុំបានឡើយ; បានជាខ្ញុំនិយាយយ៉ាងនេះ ព្រោះថា

ពុទ្ធោ តិលោកទីបោវ៎ ពុទ្ធោ សុរិយោ តមោនុទោ
យេ យទ្ធិ សរណំ ពុទ្ធំ ឆត្តិ តេសំ ភយំ សទា ។
ធម្មោ តិលោកទីបោវ៎ ធម្មោ សុរិយោ តមោនុទោ
យេ យទ្ធិ សរណំ ធម្មំ ឆត្តិ តេសំ ភយំ សទា ។
សង្ឃោ តិលោកទីបោវ៎ សង្ឃោ សុរិយោ តមោនុទោ
បេរ យទ្ធិ សរណំ សង្ឃំ ឆត្តិ តេសំ ភយំ សទា ។
យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
អបទីបោ ឆ ភវៃយ្យ អធិគច្ឆេយ្យ បទំ សុខំ ។

ព្រះសម្មាសម្ពុទ្ធជាប្រទីបក្នុងលោក ព្រះអង្គដូចជាព្រះអាទិត្យអាចកំចាត់បង់នូវងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណាបានដល់ព្រះពុទ្ធជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសូម្បីកាលណា ។ ព្រះសទ្ធម្មជាប្រទីបក្នុងលោក, ព្រះសទ្ធម្មនោះឯង ជាព្រះអាទិត្យអាចកំចាត់បង់នូវសេចក្តីងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណា បានដល់នូវព្រះសទ្ធម្មជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំង-

ឡាយនោះសព្វ ៗ កាល ។ ព្រះសង្ឆជាប្រទីបក្នុងត្រៃលោក
ព្រះសង្ឆនោះឯងជាព្រះអាទិត្យ អាចកំចាត់បង់នូវងងឹតគឺអវិជ្ជា,
ជនទាំងឡាយឯណា បានដល់នូវព្រះសង្ឆជាទីពឹងទីរលឹក,
ភ័យមិនមានដល់ជនទាំងឡាយនោះសព្វ ៗ កាល ។ បើនរ
ណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ព្រះសង្ឆជាទីពឹង
ទីរលឹកហើយ, នរជននោះ ឈ្មោះថាជាអ្នកមានប្រទីបគឺបញ្ញា
ហើយបានន្ទូវព្រះនិព្វានជាបរមសុខដ៏ក្រៃលែង ។

ដោយហេតុនេះហើយ សូមអ្នកម្ពាយកុំយាត់ខ្ចុំបាទឡើយ ។

លំដាប់នោះ មាតារបស់ទុលកបណ្ឌិត កាលបើមិនអាចឲ្យកូនត្រ-
ឡប់ទៅវិញបាន ក៏វិលទៅកាន់គេហដ្ឋានវិញទៅ ។ ទើបទុលកបណ្ឌិត
ស្ទាបអង្អែលឈើអណ្ណាតនិយាយថា ម្នាលឈើអណ្ណាតអើយ, ឈើ
ដទៃខ្ទះគេយកទៅធ្វើជាព្រះវិហារ ឈើខ្ទះគេយកទៅរចនាជាព្រះពុទ្ធរូប
ឈើខ្ទះគេយកទៅធ្វើជាទីចង្ក្រម ឈើខ្ទះគេយកទៅធ្វើជាទីអាវាស, ចុះ
ប្រៃកអ្វីតែអ្នកឯងក៏ប្រឡាក់ប្រឡូសមិនស្អាតសោះដូច្នេះ ។ ខណៈនោះឯង
ទេវតាបានព្ទពាក្យពោធិសត្វហើយ ក៏ចុះមកប្រជុំគ្នា ។ ឈើអណ្ណាត
ក៏ដួលចុះទៅ ដោយអានុភាពនៃទេវតា ។ ពួកអ្នកនគរទាំងអស់ក៏
ផ្អើលធោឡោឡើង ។

ថ្ងៃនោះ បិតាព្រះពោធិសត្វឈ្មោះសុជាតព្រាហ្មណ៍ បានផ្ទុកមាស
ពេញសំពៅមកអំពីក្រុងបាតលិបុត្ត បានមកដល់ចិននគរហើយ ពួក

មហាជនទាំងអស់ ក៏នាំគ្នាទៅជំរាបគាត់ថា បពិត្រលោកសុជាតដ៏ចំរើន, លោកជ្រាបដែរឬ? លោកឃើញដែរឬ? ឪលកបណ្ដែតជាបុត្រចស់លោក ស៊ូលះបង់ជីវិតចំពោះព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ឥឡូវនេះពួកពេជ្ឈឃាតឲ្យឡើងលើឈើអណ្ដែតទៅហើយ ។ សុជាតព្រាហ្មណ៍ បានឮពាក្យនោះហើយ ក៏មានដួងចិត្តទំយញាប់ញ័រ ស្ទួតកក្តៅគ្រហាយ សព្វសព្វាង្គកាយហើយមកប្រញាប់ប្រញាល់ តំរង់ទៅកន្លែងស្មសាន; លុះទៅដល់ហើយឃើញកូនដូច្នោះ ក៏និយាយទៅកាន់ពួកពេជ្ឈឃាតថា "ម្នាលពួកពេជ្ឈឃាត, អ្នកកុំធ្វើកូនខ្ញុំឲ្យវិនាសឡើយ ខ្ញុំនឹងលោះយកវិញ" ហើយគាត់ទៅកាន់ព្រះលានស្ដេច ក្រាបបង្គំទូលព្រះពជាថា "បពិត្រព្រះសម្មតិទេព, សូមទ្រង់ព្រះមេត្តាប្រោសសង្គ្រោះទូលព្រះបង្គំជាខ្ញុំ, សូមព្រះអង្គកុំឲ្យបុត្រទូលព្រះបង្គំជាខ្ញុំវិនាសឡើយ, ទូលព្រះបង្គំជាខ្ញុំនឹងលោះយកកូននេះវិញ" ។ ព្រះពជា បានទ្រង់ព្រះសវនាការពាក្យព្រាហ្មណ៍ក្រាបបង្គំទូលដូចនោះហើយត្រាស់ថា "ម្នាលព្រាហ្មណ៍ លុះតែអ្នកឯងឲ្យមាសប៊ុនសរីរៈកូនអ្នកឯងមកយើងឯង ទើបយើងឲ្យកូននោះរួចបាន" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំស៊ូតែថ្វាយ ពុំឲ្យខ្លះតន្ទុះឡើយ" ហើយទៅបើកសំពៅយកមាសមកដំកល់ទុកប៊ុនសរីរៈកូនលោះយកកូន នាំយកទៅផ្ទះវិញ ។

គ្រានោះ ព្រះសង្ឃត្រេះ ឋានច្រាប់ដល់កិក្កីងាំងឮយថា ម្នាលលោកដ៏មានអាយុងាំងឮយ, យើងងាំងឮយដែលរួចពីកុក្កុត្រព្រោះតែ

ទុលកបណ្ឌិតនេះ, ឥឡូវនេះ យើងអង្គុយក្នុងទីនុ៉ះ ដើម្បីនឹងសរសើរ
កិត្តិគុណនៃសេចក្តីជ្រះថ្លារបស់ទុលកបណ្ឌិត ហើយទំចំរើនកម្មដ្ឋាន ប្រឹង-
ប្រែងព្យាយាម ដើម្បីតបទុបការគុណរបស់គាត់ទើបគួរ ។ លំដាប់នោះ
កិក្ខុទាំងអស់ក៏ទទួលប្រតិបត្តិតាមពាក្យមហាថេរ ។ ព្រះថេរ គង
ក្នុងទីនោះដាមួយនឹងកិក្ខុទាំងឡាយ ហើយចំរើនកម្មដ្ឋាន ប្រឹងប្រែង
ព្យាយាមក៏ចាន សម្រេចព្រះអរហត្តបដិសម្ភិទាញាណ ព្រមគ្នាទាំង ៣៣
រូប ។ ទើបព្រះនាគទីបកត្ថេរដ៏មានអាយុ គិតថា "ស្តេចនេះ ប្រកប
ដោយមិច្ឆាទិដ្ឋិ" ទើបលោកប្រឹក្សាគ្នាថា បើដូច្នោះគួរតែយើងទាំងឡាយ
ទៅសង្រ្គោះដល់ទុលកបណ្ឌិត ។ កិក្ខុទាំងអស់នោះ ក៏មានសេចក្តីប៉ុនប៉ង
តែបែបមួយ ក្រោកចាកអាសនៈ ឃ្ជុំចីវរ កាន់យកចាត្រហោះឡើងទៅ
កាន់អាកាសវេហាស៍ដូចជារាជហង្សប្ចដូចជាព្រះអាទិត្យ ដែលត្រេចទៅ
តាមផ្លូវអាកាសដូច្នោះ ។ កិក្ខុខ្លះអង្គុយ កិក្ខុខ្លះចង្ក្រម កិក្ខុខ្លះសឹង កិក្ខុ
ខ្លះស្ទាបអង្អែលមណ្ឌលព្រះចន្ទព្រះអាទិត្យ កិក្ខុខ្លះឈរលើកំពូលភ្នំ ។
កិក្ខុទាំងនោះចានសំដែងឥទ្ធិបុទ្ធិអស្ចារ្យជាអនេកប្រការ ។ ត្រានោះ ព្រះ
រាជាទតព្រះនេត្រឃើញហេតុជាទីអស្ចារ្យ ដែលមិនធ្លាប់មានយ៉ាងនេះ
ហើយ ក៏មានសេចក្តីតក់ស្ទុត ព្រឺព្រះលោមាព្រឺព្រះចម្មា មានព្រះភក្ត្រា
សំយុងចុះ ហើយត្រាស់ហៅពួកអាមាត្យថា ម្នាលអាមាត្យដ៏ចំរើនទាំង-
ឡាយ, ពួកចោរនុ៉ះហ្នឹហោះមកតាមអាកាស មានប្រាថ្នានឹងសម្ចាប់យើង,
បើយ៉ាងហ្នឹង តើយើងគិតធ្វើដូចម្តេច? ត្រានោះ អាមាត្យទាំងឡាយ

ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, សូមព្រះអង្គត្រាស់ហៅ
ទុលកបណ្ឌិតមកស្លូរ ។ ព្រះរាជាក៏ត្រាស់ហៅទុលកបណ្ឌិតមក ។ ទុលក-
បណ្ឌិតមកដល់ក្រាបថ្វាយបង្គំព្រះរាជា ហ៊ីយអង្គុយក្នុងទីដ៏សមគ្លូរ ។ ព្រះ
រាជាត្រាស់ស្លូរទុលកបណ្ឌិតថា ម្នាលអ្នក, ពួកចោរទាំង ៣៣ រូបដែល
អ្នកឯងដោះលែង, ឥឡូវហោះមកតាមអាកាស បម្រុងនឹងសម្ងាប់យើង,
បើជូច្នោះចូរអ្នកឯងជួយដោះទុក្ខផុរៈយើងផង ។ ព្រះពោធិសត្វបានស្តាប់
ព្រះរាជឧង្ការៈហ៊ីយមានសេចក្តីរីករាយ ដូចជាព្រះចន្ទពេញវង់ ក្រាបបង្គំ
ទូលទទួលការថា "បពិត្រមហារាជ, សូមព្រះអង្គកុំកិតក័យបារម្ភឡើយ"
ហ៊ីយក្រាបបង្គំទូលថា "ទូលព្រះបង្គំជាឱ្ចុំនិមន្តលោកទាំងនោះក្នុងថ្ងៃនេះ"
លុះទុលកបណ្ឌិតលួងលោមព្រះរាជាឲ្យបានស្លូលព្រះទ័យហ៊ីយ ទើប
ឲ្យគេចាត់ចែងក្រាលអាសនៈបម្រុងទុក ។ លំដាប់នោះព្រះរាជាកាន់យក
ត្រឿងក្រអូបនឹងផ្កាកម្រងជាដើមឈរចាំក្នុងទីនោះ ។ ទុលកបណ្ឌិត
ដើបមើលអាកាស ហ៊ីយផ្គងអញ្ជលីផ្គុកតុំម្រាមដៃទាំង ១០ នមស្សការ
ចំពោះព្រះអរហន្ត ពោលពាក្យយ៉ាងនេះថា :

ព្រះសង្ឆជាប្រទីបក្នុងត្រៃលោក ព្រះសង្ឆជាព្រះអាទិត្ស
អាចកំចាត់បង់នូវងងឹតគឺអវិជ្ជា ជនទាំងឡាយឯណាបានដល់
នូវព្រះសង្ឆជាទីពឹងទីរលឹក ក័យមិនមានដល់ជនទាំងឡាយ
នោះសព្វ ។ កាល ។

ពុទ្ធសាវកទាំងនោះក៏ចុះចាកអាកាសមកត្រប់អង្ក ។ ទុលកបណ្ឌិត
និយាយថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន, ខ្ញុំព្រះករុណាឈ្មោះ
ទុលកបណ្ឌិត សូមក្រាបថ្វាយបង្គំនិមន្តលោកម្ចាស់ ។ លំដាប់នោះ ភិក្ខុ
ទាំង ៣៣ រូបបានស្តាប់ពាក្យទុលកបណ្ឌិតហើយ ក៏មកតង់លើអាសន:
ដែលព្រះរាជាឲ្យក្រាលទុកបម្រុងក្នុងព្រះរាជនិវេសន៍ ។ ទុលកបណ្ឌិត
អង្គុយរំលឹកគុណភិក្ខុទាំងនោះ ។ ព្រះរាជាថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន
ហើយធ្វើសក្ការបូជា ។ លំដាប់នោះ ព្រះនាគទីបកត្ថេរ សំដែងធម៌
ចំពោះព្រះរាជាជាបទព្រះគាថាថា

សកិទេវ មហារាជ សព្ពិ ហោតិ សមាគមោ
សោ ឆំ សង្គមោ បាលេតិ ឆាសព្ពិ ពហុសង្គមោ ។
សព្ពិវេ សមាសេថ សព្ពិ កុព្វេថ សន្ថវ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ឆ បាបិយោ ។

បពិត្រមហារាជ, ការនៅរួបរួមជាមួយនឹងពួកសប្បុរស សូម្បី
តែម្តងប៉ុណ្ណោះ ក៏ការនៅរួមនោះ អាចរក្សានូវអ្នកនោះមិន
ឲ្យមានអន្តរាយបាន, ឯការនៅរួមជាមួយនឹងអសប្បុរសទុក
ជាច្រើនដងយ៉ាងណា ក៏មិនអាចរក្សានូវអ្នកនោះបានឡើយ ។
បុគ្គលគប្បីរាប់រកនូវពួកសប្បុរសតែម្យ៉ាង, គប្បីធ្វើសេចក្តី
ស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលដែលបានដឹងនូវព្រះ

សទ្ធម្មរបស់ពួកសប្ប្យុរសហើយ នឹងបានជាអ្នកវិសេសថ្ថូថ្ថា មិនមែនជាថោកទាបឡើយ ។ រាជរថដែលនាយជាងបានធ្វើវិចិត្ររចនាដោយល្អ រមែងចាស់ត្រាំត្រាឡេ, មួយវិញទៀត សូម្បីតែសរីរៈរាងកាយរបស់មនុស្សសត្វទាំងឡាយ ក៏រមែងចាស់ត្រាំត្រាដែរ, មានតែធម៌របស់សប្ប្យុរសទើបមិនចាស់ត្រាំត្រាឡើយ; សប្ប្យុរសទាំងឡាយ រមែងញ្ញាំងពួកសប្ប្យុរសផងគ្នា ឲ្យដឹងប្រាកដដូច្នេះ ។

មេយនឹងដីជារបស់ធ្វាយជាច់សែយាលពីគ្នា, ត្រើយសមុទ្រទាងអាយនឹងត្រើយសមុទ្រទាងនាយ ក៏ធ្វាយជាច់សែយាលពីគ្នាដោយពិត, ចំណែកទាងធម៌របស់សប្ប្យុរសនឹងអសប្ប្យុរសប្រាកដជាធ្វាយជាងនោះឡេទៀត ។

ត្រហស្ថអ្នកបរិកោគនូវកាមគុណ ជាមនុស្សឆ្ងឹលច្រអូសមិនប្រពៃឡើយ, អ្នកបួសតែមិនសង្រួមឥន្ទ្រិយដោយប្រពៃ ក៏មិនល្អដែរ, ស្តេចធ្វើការឥតពិចារណា មិនល្អសោះឡើយ, អ្នកប្រាជ្ញមានសេចក្តីក្រោធ ក៏មិនល្អដូច្នោះដែរ ។

បុគ្គលឯណាវង្វេងជានិច្ច ហើយសាកសួរចំពោះបុគ្គលវង្វេងផងគ្នា បុគ្គលនោះឈ្មោះថារឹតតែវង្វេងដោយក្រៃលែង, បុគ្គលនោះមិនបានដល់នូវសួស្តីឡើយ រមែងដល់នូវសេចក្តី

ឆូចចិត្តជាប្រក្រតី ។ មពិត្រមហ្ការាជ, ការសេពគប់នឹងជន
ពាលបែបនោះ ក៏ជូប្ចោះដែរ ។

បុគ្គលឯណាចង់ដើរក្នុងផ្ទូវទេ ប៉ុន្តែត្រឡប់ជាទៅរកឯក្នុ
ទិញ បុគ្គលនោះ រមែងមិនបានន្ទូវសួស្តីឡើយ តែងតែធ្លាក់
ទៅក្នុងជ្រោះក្នុំជាប្រក្រតី ។

នរជនណាមួយ ខ្ជប់ប្រហុកដោយសូវក្ខាំង, សម្ស៊ីតែស្ស្ទូ
ក្ខាំងក៏តែងផ្សាយក្ខិនស្អុយចេញមកដែរ យ៉ាងណាមិញ ការ
សេពគប់បុគ្គលពាល ក៏យ៉ាងនោះដែរ ។ នរជនឯណាមួយ
ខ្ជប់ក្រិស្នាខ្ទឹមចន្ទន៍ ដោយស្ទឹកឈើ, សម្ស៊ីតែស្ទឹកឈើ ក៏
មានក្ខិនក្រអូបផ្សាយចេញមកដែរ យ៉ាងណាមិញ, ក៏ការ
សេពគប់ជាមួយបណ្ឌិតក៏យ៉ាងនោះដែរ ។ បុគ្គលឯណា
ចូលទៅអាស្រ័យនឹងបុគ្គលពាល ស្មិទ្ធស្នាលជាមិត្តសំឡាញ់
បុគ្គលនោះ តែងលិចចុះក្នុងសេចក្តីទុក្ខ ដូចជាពូជដែលគេ
បណ្តុះហើយ ។ ជនឯណា បានធ្វើនូវអំពើអាក្រក់ ជន
នោះតែងបានន្ទូវអំពើអាក្រក់ទិញដែរ, ជនឯណា បានធ្វើ
អំពើល្អ ជននោះតែងបានសេចក្តីសុខដែរ ។ ជនទាំងអស់
រមែងខ្ទាចសេចក្តីទុក្ខ, ជនពាលរមែងខ្ទាចសេចក្តីស្ទាប់,
ជនពាលរមែងជួបប្រសព្ទនឹងហានរក, អ្នកប្រាជ្ញតែងជួប
ប្រសព្ទនឹងព្រះនិញ្ទាន ។ ជនពាលមិនស្តាប់ពាក្យមាតាបិតា,

ជនជាអ្នកប្រាជ្ញតែងស្តាប់ពាក្យមាតាបិតា, ជនពាលមិនធ្វើតាមពាក្យគ្រូអាចារ្យ, ជនជាអ្នកប្រុងប្រាជ្ញតែងធ្វើតាមពាក្យគ្រូអាចារ្យ ។ នរជនទាំងឡាយឯណា ចូលទៅសេពប្រកបការចំពោះបាបកម្ម, នរជនទាំងនោះ តែងទៅកាន់នរកធ្លាក់ចុះទៅក្នុងទីមិនសមគួរ ។ នរជនទាំងឡាយឯណាជាអ្នកត្រូវការនឹងបុណ្យ វៀរចាកបាបកម្ម, នរជននោះតែងទៅកាន់ឋានសួគ៌ តែងបានទទួលសម្បត្តិសមតាមសេចក្តីប្រាថ្នា ។

លុះចប់ធម៌ទេស្នាហើយ ព្រះពាជាអង្គនោះ ក៏មានសេចក្តីជ្រះថ្លាចំពោះព្រះរតនត្រ័យ ។ ព្រះអង្គ បានប្រគល់កាយថ្វាយខ្លួនចំពោះព្រះរតនត្រ័យ ហើយឲ្យពាំងពួកមហាជនឲ្យខ្ចងស្គរប្រាប់អ្នកនគរទាំងអស់ហើយទ្រង់ត្រាស់ព្រះពាជបញ្ជាថា នរណា ។ ដែលនៅក្នុងខេត្តដែនរបស់យើង, អ្នកនោះកុំមានសេចក្តីប្រមាទចំពោះព្រះរតនត្រ័យឡើយ ។

ចាប់ដើមតាំងពីថ្ងៃនោះមក មនុស្សទាំងឡាយ អ្នកនៅក្នុងចំនួនកោដិសន្ថានមិនបានឡើយ បានតាំងក្នុងសម្មាទិដ្ឋិ ជាប់ជាបមកដល់សព្វថ្ងៃនេះ ។ លំដាប់នោះ ព្រះពាជាទូលព្រះថេរៈយ៉ាងនេះថា "បពិត្រលោកម្ចាស់ដ៏ចំរើន ទោសគឺសេចក្តីភ្លាំងភ្លាត់ជាកាយកម្ម វចីកម្ម មនោកម្ម ដែលកន្លងទៅហើយ ដោយការនៅរួបរួមជាមួយនឹងបាបមិត្រ សូមលោកម្ចាស់អត់ទ្រាំទោសទាំងអស់នោះដល់ខ្ញុំព្រះករុណា" ។ ហើយត្រាស់ព្រះពាជនុដ្ឋារវចនៈតទៅទៀតថា

ក្នុងកាឡបក្ខ (ចំណែកខាងរនោច) ព្រះចន្ទ្រតែងតែសាបសូន្យទៅមួយថ្ងៃបន្តិចៗ យ៉ាងណាមិញ, បពិត្រលោកម្ចាស់ដ៏ចំរើន ការនៅច្បូកច្បឺងជាមួយនឹងពួកអសប្បុរសក៏មានឧបម័យដូចជាព្រះចន្ទ្រក្នុងកាឡបក្ខយ៉ាងនោះដែរ, ខ្ញុំព្រះករុណា នៅរួបរួមជាមួយនឹងព្រាហ្មណ៍ដ៏លាមកថោកទាបក៏មានឧបម័យដូចព្រះចន្ទ្រខាងរនោចដូច្នោះ, ខ្ញុំព្រះករុណាទៅកាន់ទុគ្គតិដោយហេតុឯណា ហេតុនោះគឺបាបកម្មដែលខ្ញុំព្រះករុណាបានធ្វើហើយ ។

ព្រះចន្ទ្រក្នុងសុក្កបក្ខ (ខាងខ្នើត) តែងចំរើនឡើងមួយថ្ងៃបន្តិចៗ យ៉ាងណាមិញ, បពិត្រលោកម្ចាស់ដ៏ចំរើន, ការនៅរួបរួមនឹងពួកសប្បុរស ក៏មានឧបម័យដូចព្រះចន្ទ្រខាងខ្នើតយ៉ាងនោះដែរ, ការនៅរួបរួមជាមួយនឹងលោកម្ចាស់ ក៏ឧបម័យដូចជាព្រះចន្ទ្រខាងខ្នើតដូច្នោះដែរ ។ បពិត្រលោកម្ចាស់ជាអ្នកប្រាជ្ញ, សូមលោកម្ចាស់ជ្រាបនូវខ្ញុំយ៉ាងនេះចុះ ខ្ញុំព្រះករុណាទៅកាន់សុគតិ ដោយហេតុឯណា ហេតុនោះគឺកុសលដែលខ្ញុំបានធ្វើហើយហ្នឹងឯង ។

ព្រះពាហ្មទ្ធ័ត្រាស់ដូច្នេះស្រេចហើយ ក៏បញ្ជូនព្រះវេរៈចាំងនោះឲ្យត្រឡប់ទៅវិញ ទ្រង់តាំងទុលកបណ្ឌិត ក្នុងដំណែងជាសេនាបតី ហើយទ្រង់បណ្តេញព្រាហ្មណ៍កំចាបអាក្រក់ បំបរបង់ចេញចាកនគរ ។

ពួកអ្នកនគរទាំងអស់ ក៏នាំគ្នាធ្វើបុណ្យមានឲ្យទានជាដើម ហើយទំនុក
បំរុងព្រះសង្ឆដោយចតុប្ឆច្ចយ ។

ព្រះរាជា មួយអន្ធើដោយទុលកបណ្ឌិត. ក៏ទំប្រឹងប្រែងធ្វើបុណ្យ
មានឲ្យទានជាដើម រៀងរាបជរាបជល់ទីបំផុតព្រះជន្មាយុ ទ្រង់សោយ
ព្រះទិវង្គតទៅ បានទៅកើតក្នុងទេវលោក ។ ឯពួកអ្នកនគរទាំងអស់
ទំប្រឹងប្រែងធ្វើបុណ្យមានឲ្យទានជាដើម រៀងរាបជរាបជល់ទីបំផុតអាយុ
ក៏បានទៅកើតក្នុងទេវលោករាល់ៗ គ្នា ។

សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំធម៌ទេស្នានេះមកហើយ ទ្រង់
ប្រជុំជាតក ទ្រង់ត្រាស់ព្រះពុទ្ធដីកាជាទីបំផុតថា ព្រាហ្មណ៍មិច្ឆាទិដ្ឋិ
គឺជាទេវទត្ត. ព្រះរាជាដែលប្រទូសរ៉ាយព្រះសង្ឆនោះហើយបានស្ថិត
នៅក្នុងឧរាទតថាគត គឺជាអានន្ទ, ព្រះមាតាគឺជាព្រះនាងមហាមាយាជា
ពុទ្ធមាតា, ព្រះបិតា គឺជាព្រះបាទសុទ្ធោទន, ភរិយា គឺជានាងយសោ-
ធរាពិម្ពា, កូន គឺជារាហុល, បរិសទ្យដ៏សេស ជាអ្នកធ្វើបុណ្យ គឺជា
ពុទ្ធបរិសទ្យ. ទុលកបណ្ឌិត គឺអង្គតថាគត ដែលជាទីពឹងនៃសត្វលោក ។
អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ទុលកបណ្ឌិតជាតក ទី ១១ តែប៉ុណ្ណោះ ។

ផ្នែកអក្សរសាស្ត្រ

រឿងសៅរ៍សោយ

(សិសោរដាតក)

ព្រះមហាឧត្តមរិដ្ឋា ផលញ្ញាណោ ប៊ឹង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រាស្លឹកវិត

(តមក)

ក្សិណនោះសាមណេរ ញ្ចហើយដើយបែរ ឃើញឯសិសៅរ៍ មានចិត្តប៉ែតី មេត្រីព្រះចៅ ទើបស្ទុះចៅរៀ ដោយនូវសាទរ ។ នាំស្តេចត្រាច់ឆ្ពោះ ចេញពីទីនោះ ដោយស្មោះត្រេកអរ ហើយឲ្យស្តេចឈប់ ក្រោមម្ចប់បវរ សាកស្ទរសាទរ ទៅវិញទៅមក ។ ឯព្រះរាជា រឹងតែវេទនា ឈឺឆ្ទុរពុរពក ដែលត្រូវដំណំ ជាំក្រំរបក ឈាមជ័រហូរមក ពេញវង់អង្ក្ត ។ ណាមួយខ្សោយអង្ក ពុំអាចផ្ទិតផ្ទង់ទ្រទ្រង់ទុក្ខា ក៏ទ្រតព្រះអង្ក ដួលតូងនៅនា ជិតខ្សឹនសីមា ល្ហិតៗនិត្យនៅ ។

សាមណេរតូចនោះ យល់ហេតុកេទច្ចោះ រន្ធត់រត់ទៅ ប្រាប់ភិក្ខុត្រប់អង្ក ដែលតង់វង់នៅ ថា"សូមទានទៅ ដ្ឋិតមានមនុស្សមក ។

ឲ្ជនមនុស្សនោះហោង មានស្នាមដំបង រាយថងពងពក ដើរម្នាក់ឯង
ក្ងូវ ឥឡូវមកជ្រក មិនដឹងជាមក ពីស្រុកឯណា" ។

ភិក្ខុផងទាំងនោះ ញ្ចនេនពោលឆ្ពោះ ថាមនុស្សពិក នាំគ្នាមកដល់
បានយល់រាជា សង្វេគគ្រប់គ្នា រវទនាឥតបី ។ មានចិត្តមេត្តា អា-
ស្សរករុណា ដល់មហាចក្រី លុះឃើញក្សត្រក្សាន្ត ទ្រង់មានស្នាវតី
ទើបចូលជិតឲ្ងី ស្ពីថា "ញោមអើយ ។ មកពីស្រុកណា មកមាន
កាយា ទុក្ខាឥតស្ឆើយ ?" ទើបក្សត្រទត្តម ប្រណម្យទើបដើយ
សំពះធ្ងាស់ធ្ងើយ ទូលតបទៅថា ។ "ឧ! ព្រះគុណម្ចាស់ ព្រះគុណ
ផ្ងន់ណាស់ ខ្ញុំព្រះករុណា ជាតិជាមហាក្សត្រ ប្រាសព្រាត់ឃ្ងាតឃ្ងា
ពីនគរ រវទនាស្ទើរក្ស័យ ។ ខ្ញុំនេះព្រះគុណ ពីដើមធ្នើមបុណ្យ ថ្ពំថ្ពើង
ណាស់នៃ ជាស្តេចសោយរាជ្យ អំណាចពេកក្រៃ តែកម្មចង្រៃ តាម
ទាន់នេម្ពង ។ ហាក់ជូចធ្ជតពិត រង្វេងទ្វៃងចិត្ត ចេញចាកមកហោង
នឹងសេះអាជានេយ្យ ប្រាំពកន្ងង ព្រះខាន់ ១ ផង នឹងមកុដកែវថ្ងៃ ។
ជាប់មកនឹងឲ្ជន តែកម្មចាំផ្ជន ចំនួនក្រាស់ក្រៃ ទ្រព្យខ្ញុំបីហ្នឹង សុទ្ធ
សឹងទ្រព្យថ្ងៃ មានអាចង្រៃ មកវៃ(1) យកទៅ ។ រាវាយរាថង បែក
ក្ឈាលបែកឲ្ងង ឈាមផងប្រាលឆ្ពៅ ខ្ញុំមកដល់នេះ មិនអាចដើរទៅ
ទើបសូមស្នាក់នៅ តទៅលុះជា" ។

• ពាក្យត្រឹមត្រូវ "រាយ" ។

អស់ពាំងភិក្ខុផង បានដឹងទំនង ជាអង្គរាជា មានចិត្តអាស្សរ អំបូរពុត្ថា ទើបនាំគ្នីគ្នា រកថ្នាំដំបៅ ។ ខ្ញុះក៏ចាត់ចែង ឲ្យនេនានោះឯង រកជាំទឹកក្តៅ យកមកស្រោចលាង អស់ពាំងដំបៅ ជាក់ថ្នាំក្នុងក្រៅ គឺលាបផឹកផង ។ ខ្ញុះក៏បោសស្អំ ដំណាំជាំកៃ ពីមុខពីខ្នង ស្តេចបានស្រាន្តឈឺ ជម្ងឺនោះហោង អស់ពាំងភិក្ខុផង ថ្វាយភោជន៍ភោក្តា ។ នាំគ្នារឹកវរ ខ្ញុះបានបបរ ខ្ញុះក៏បាយណា ខ្ញុះបានងៀតរ៉ស់ ខ្ញុះបានងៀតប្រា ថ្វាយស្តេចភោក្តា នាគ្រានោះហោង ។

សម្តេចសិសៅរ៍ ប្រកបចួបនៅ នឹងគុណសង្ឃផង មើលថែ ក្សត្រក្សាន្ត សព្វហានគ្មានហ្មង ពីរបីថ្ងៃហោង សះជាអាពាធ ។ បានសុខសប្បាយ អស់អង្គាកាយ ក្សត្រថ្ងៃភូវនាថ ប្រកបចួបត្រង់ គុណសង្ឃជាអាទ៏ ផ្ចិតផ្ចង់សង្ឆាត ដោះទុក្ខសព្វសត្ត ។

សំនួរស្ងរថា "សង្ឃត្រប់អាត្មា នាំគ្នាប្រតិបត្តិ ថែពាំរោគានៃមហាក្រសត្រ(*) ឲ្យបាត់ឈឺច្ការត់ តើព្រោះហេតុអ្វី?" ។

ចំឡើយធ្វើយថា "ព្រោះមហាក្សត្រា កាលសាងបារមី ស្តេចត្រាច់ទិលវង់ ទៅក្នុងភពបី ពេលមួយចក្រី បានកើតជាតិជា ។ រុរស ១ នាក់ ឈ្មោះកុលក: ជាអ្នកប្រាជ្ញថ្ថា លោកបានឲ្យទាន ជីវិតអាត្មា ជល់សង្ឃត្រប់គ្នា នោះជាហេតុផល ។ ដូច្នោះបានជា ភិក្ខុសព្វ

---

* ពាក្យត្រឹមត្រូវ "ក្សត្រ" ឬ "ក្សត្រិយ៍" ។

គ្រប់គ្នា លីលាមកយល់ ព្រះបាទចមចក្រ ទុក្ខភ្ជាក់មកដល់ នាំគ្នារចល់ វែចាំគ្រប់អង្គ" ។

ស្តេចនៅនឹងវត្ត ហើយក៏ប្រយ័ត្ន ប្រតិបត្តិសត្យសង្ឃ បន្តិច ស្តេចយឹក រញកនឹកចង់ បួសធ្វើជាសង្ឃ ក្នុងពុទ្ធសាសនា ។ រៀបទ្ធូរ ចូលដំនតិតទូល ដល់សង្ឃផងថា "បពិត្រអម្ចាស់ ខ្ញុំព្រះជ្រះថ្លា ចង់ព្រាថ្នា បួសជាសង្ឃកៃ្រ ។ សូមមានមេត្តា បំបួសផងវ៉ា យកជានិស្ស័យ" ពេលនោះអស់សង្ឃ គ្រប់អង្គអរកៃ្រ ពោលថា "ក្សត្រថ្លៃ ល្អកៃ្រណាស់ហោង ។ គ្រឿងបរិក្ខារ មានគ្រប់ប្រការ ឃើញថា គ្មានហ្មង ខ្វះតែចីវរ ដែលក្រែកមួង តុំដឹងទាក់ទង រកបានពីណា" ។

ព្រះមហាក្សត្រក្រាន្ត ទូលថា "សូមមាន ខ្ញុំមានកូសា សម្រាប់ជណ្តប់ នេះជាប់មកណា សូមមានមេត្តា ចាត់ការឲ្យមាន" ។

កិកុផងគ្នាន់គ្នេរ នាំគ្នាកាត់ដេរ ស្រែចគ្រប់សព្វហាន ទើបនាំមកចាត់ ថ្វាយថ្វាត់ក្សត្រក្រាន្ត ស្រេចស្រួលទូលថ្លាន "សូមមាននរនាថ ។ សូមព្រះកូរ ទ្រង់យកចីវរ ទៅគង់សំអាត ហើយតាំងក្រាក់ខ្នរ ជាក់ស្តែរតុហាត ផ្ចិតផ្ចង់សង្វាត ជ្រលក់ទៅហោង" ។

ក្សត្រថ្លៃពន្ធក ទទួលយកមក រៀបចំផ្គុំផ្គង តែទ្រង់ចិន្តា ថា "ការនេះហោង បើធ្វើតែម្តង ក្នុងវត្តនេះណា ។ ផ្សែងផងគង់បក់ ឲ្យសង្ឃផងឈ្លក់ វ៉ៃក់ទុក្ខា ចេះតួរអញទៅ ស្មោះត្រៃសីមា" គិតហើយក្សត្រា

លីលាចរចុះ ។ ដល់ស្រែចស្តេចទ្រង់ តុំគង់ចង្អដ់ ទើបទ្រង់ពុះទុស
ដុតស្មៅក្រាក់ខ្ចី លុះដល់វាពុះ រំងាស់ទៅលុះ ល្មមបានដែលក់ ។
ជង់ទឹកនោះមក ដាក់ស្មកប្លុចយក ចីវរដែលគក់ ដុះស្អាតម៉ត់ចត់
សង្កត់ដែលក់ ឈ្លួចឈ្លីញីញាក់ ពាក់ហាលលើខ្សែ ។ យកទឹកសល់
នៅ រម្ងាស់ទៀតទៅ ដុតកើងបន្តែ សង្វាតដែលក់ គ្មានតក់គ្មានល្លែ
ហាលហើយទៅប្រែ ដោយក្តីច្រើយ័ត្ន ។ ថ្ងៃនោះជៀងជាក់ មានជន ៤
នាក់ សុះស្រែងខ្វែងខ្វាត់ ដើរតាមរកគោ ដ្បិតគោវាចាត់ ដ្រៀតដ្រក
រកស្មាត់ តុំឃើញឡើយណា ។ ទៅ។ តាមផ្លូវ ក្បែរនោះឯងក៏ឮ
ឯងទៅឃើញថា មានផ្សែងភ្លៅខ្លួ បបួលគ្នីគា ចូលទៅមើមា ដល់
មហាក្សត្រថ្លៃ ។ បុរស ៥ នាក់ មើលទល់យល់ជាក់ ចីវរនោះនៃ
ឃើញជាស្បែកគោ ពិតឥតសង្ស័យ វត្តពន្ធប្រែវៃ ជាពោះវៀនពិត ។
ឯចំណាំងក្រាក់ ប្រែខ្វែបែរជាក់ ទៅជាចំណិត នៃដុំសាច់គោ ទឹង
គ្រឿងក្នុងពិត ទឹកក្រាក់ល័ក្ខដិត ជាឈាមគោណា ។ រឯស់ច្រើ
ក្លាយប្លែកចំណាំ ព្រោះកម្មក្សត្រា បុរស ៥ នាក់ យល់ជាក់នេត្រា
សំគាល់ស្តេចថា ជាក់ជាចោរហោង ។ បង្កើតចិត្តក្រោធ ទឹងយោវ-
ច្រឡោត លោចាប់ដំបង វាយព្រះទ្រង់យស បែកអស់ទាំងខ្លួន
ខ្លះធាក់ទាត់ផង លុះដួលដល់ដី ។

(មានត)

កណ្ឌទី ២០

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែរៀបរៀង

(តមក)

ឃឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ឡៅពីលុះឃើញកងទ័ពលើកមកពីបម្ចាយ ក្រឡេកឃើញទង់ជ័យសម្រាប់ទ័ពបូធូ ក៏សំគាល់ថាបូធូលើកមកខ្ជូនឯង ។ បំរើសេះល្បាតមកប្រាប់ឡៅពីថា កងទ័ពអ្ជនសៀរប្រឹក្សាមិនបុរុះគ្នា នៅរាវង់មិនបានបេញប្បាំងនឹងបូធូទេ ១ ទៀតកងទ័ពបូធូនោះ នឹងបានឃើញទង់ជ័យសម្រាប់ទ័ពបូធូក៏ឥតអង្គឺមាន កាលទ្ចុំបាទត្រឡប់មក ប្រទះនឹងកងទ័ពលើកមកជិតស្រុកនេះហើយ ឃើញទង់ជ័យសម្រាប់ទ័ពបូធូដោតពីមុខតែខ្ជូនបូធូនឹងនៅក្នុងកងទ័ពនេះឬកងទ័ពខាងណោះមិនប្បាស់ប្រាកដ ។

ឡៅពីបានស្តាប់ដូច្នោះ ក៏ប្រឹក្សានឹងតាន់តេងតាមពាក្យបំរើសេះហើយថា ឃើងមានសេចក្តីសង្ស័យមិនដឹងជាបូធូនៅខាងកងទ័ពណា ។

តាន់តែងធ្វើយថា កលៗបាយចូតួនោះមានច្រើនច្រកណាស់ កម្រមនុស្សណាទីងដឹងដល់ ដែលកងខ្មែរនៅការដ៏បុរាំងនឹងចាំងអួនសៀវនោះ គ្មានខន់ដ័យសម្រាប់ខ្មែរចូតួសោះ ខ្ញុំបានយល់ថា ចូតួមុខជានៅកងកងខ្មែរនោះជាច្រកង ឯកងខ្មែរដែលលើកមកខាងស្រុកយើងនេះតាហានកំតិច តែខន់ដ័យសម្រាប់ចូតួមកផង ដែលចូតួគិតធ្វើការគ្នានេះច្បាថ្នាទីងឲ្យលោកបារម្ភក្រែងថា ខ្លួនចូតួមកកងកងខ្មែរនេះ ។

ក្រៅពីបានស្តាប់ដូច្នោះកំងាកនៅសួរគួនអ៊ូគៀវហុយថា ប្អូនចាំង ២ នាក់ តើនរណាទីងយកអាសាចេញទៅធ្វើការ ឲ្យដឹងច្បាស់ហេតុផលជាចូតួមកឬមិនមក? ។ គៀវហ៊ុយធ្វើយឆ្លើយថា ខ្ញុំបានសុំយកអាសាចេញទៅធ្វើការឲ្យដឹងហេតុ. បើដូចនឹងចូតួហើយខ្ញុំបានទីងចាប់ខ្លួនចូតួមកឲ្យបាន ។ ក្រៅពីនិយាយតបទៅគៀវហ៊ុយវិញថា ប្អូនឯងនៅក្មេងសេចក្តីខ្វីគំនិតណាស់ ចាំងចិត្តថ្លើមក័រួសរហ័ស ទីងឲ្យទៅមិនបានទេ ។ គួនអ៊ូថាខ្ញុំបានសុំយកអាសាចេញទៅធ្វើការ ។ ក្រៅពីថា បើគួនអ៊ូចេញទៅយើងល្មមទុកចិត្តបាន ។ គួនអ៊ូក៏លាក្រៅពីលើកតាហានសេះ ៣ ពាន់ចេញទៅ ពេលនោះទេសកាលជារដូវរងាទឹកសន្សើមចុះខ្លាំងណាស់ តាហានចាំងតួងក័រងាត្រជាក់ពន់ពេក គួនអ៊ូទស្សាហ៍នាំតាហានចូលទៅដល់មុខបន្ទាយអងតុង ហើយគួនអ៊ូបរសេះចេញទៅឈរមុខតាហានស្រែកថា នរណាជាមេទ័ព ចូរប្រញាប់ចេញមកយើងនឹងសាកសួរ ។

អង្គុងបានឮគួនអ៊ូស្រែកស្សរដូច្នោះ ក៏ដិះសេះចេញមកឈរនៅមុខ
បន្ទាយហើយស្រែកប្រាប់ថា មហាឧបាជលើកមកដល់ទីនេះហើយ ហេតុ
ម្តេចខ្ជូនទើបមិនចូលមកគំនាប់ ។ គួនអ៊ូតបថា បើមហាឧបាជមកមែន
ឲ្យអញ្ជើញចេញមក យើងនឹងថ្វៃងសេចក្តីជំរាបលោក ។ អង្គុងតបថា
ខ្ជូនជាអ្នកតូចទាបគួរប្ដនឹងឲ្យមហាឧបាជចេញមកជួប ។ គួនអ៊ូខឹងណាស់
ក៏បរសេះរាំជាវចូលទៅ ។ អង្គុងក៏បរសេះរាំលំពែងចេញមកតច្បាំង
នឹងគួនអ៊ូបាន ៥ ក្រូង ។ គួនអ៊ូធ្វើជាញាក់សេះថយរត់ទៅក្រោយ ។
អង្គុងមិនដឹងកលក៏ដេញបណ្តោយតាមដល់ជើងភ្នំ គួនអ៊ូរាមកតទល់
ដល់ជិតគ្នា ទើបលើកជាវឡើងកាប់ឲ្យអង្គុងគេចចុះ ហើយគួនអ៊ូក៏ស្ទុះ
ទៅរួបចាប់យកខ្ជូនអង្គុងបាន ជាក់លើសេះពីក្រោយនាំចូលទៅឲ្យឡៅពី
ហើយពណ៌នាឲ្យឡៅពីស្តាប់គ្រប់ប្រការ ។ ឡៅពីក៏មានចិត្តសោមនស្ស
ប្រីតា តែមិនបានស្គាល់កិរិយាអង្គុងច្បាស់ក៏សាកស្សរថា អ្នកឯងជា
នាហ្ន៉ានចូធូតំណែងអ្វី? ហេតុម្តេចមកធ្វើកលឧបាយក្រូងថា ចូធូមកនៅ
ក្នុងកង៉ទ័ពនេះ? ។ អង្គុងធ្វើយថា ខ្ញុំបាទឈ្មោះអង្គុងជាទីសេនា
ទោរបស់ចូធូ ឯខ្ជូនចូធូមិនបានមកក្នុងកង៉ទ័ពនេះទេ ឲ្យខ្ញុំបាទនឹងឡៅ-
តាយលើកទ័ពមក គំនិតខ្ញុំបាទនឹងបានគិតធ្វើកលសឹកខ្ជូនឯងក៏ទេ ដែល
យកទង់ជ័យសម្រាប់ទ័ពចូធូលើកមកក្នុងកង៉ទ័ពនេះ ព្រោះចូធូបង្គាប់ប្រើ,
ខ្ញុំបាទខ្ជាចអាជ្ញាក៏ធ្វើតាមបង្គាប់ចូធូ ។ ឡៅពីបានស្តាប់ ក៏យកគ្រឿង

សម្លៀកបំពាក់ ១ ប្រដាប់មកឲ្យអង្គតុង ហើយរៀបតុលៀងគោជនាហារ
ឲ្យអង្គតុងបរិភោគ រួចឲ្យគាហានយកខ្លួនអង្គតុងទៅឃុំទុក បើចាប់
ឡៅតាយឫទ្ធិនវៀលាណាទើបបានគិតការតទៅទៀត ។

គួនអ៊ូនិយោយទើឡៅពីថា ខ្ញុំបាទប្រមាណចិត្តលោកឃើញថា
លោកនៅឫម្តងទាចចិត្តចូរ ឫនជាមិនសម្លាប់អង្គតុងចេញ បើដឹងដូច្នេះ
ខ្ញុំបាទមិនចាប់តាំងរស់មកជូនលោកទេ ។ ឡៅតីតបថា ដែលយើង
មិនប្រើតៀវហ៊ុយឲ្យចេញទៅនោះ ព្រោះគិតឃើញថាចិត្តតៀវហ៊ុយរួស
រហ័សណាស់ បើចាប់មេទ័ពបានមុខជានឹងសម្លាប់មិនខាន ដែលយើង
បានខ្លួនអង្គតុងមកទុកដូច្នេះ នោះចូរួទើងថាប្រការម្តេចក៏មានផ្លូវនឹងដោះ
ស្រាយតែម្តងទៅបានដោយងាយ ។

តៀវហ៊ុយក៏ដំរាបឡៅតីថា គួនអ៊ូទៅចាប់ខ្លួនអង្គតុងបានមកហើយ
ខ្ញុំបាទនឹងសុំយកអាសាចេញទៅចាប់ខ្លួនឡៅតាយមកជូនលោកទៀត ។
ឡៅតីតបថា ឯឡៅតាយនោះជាចៅហ្វាយស្រុកគុយជីវ កាល
ចៅហ្វាយខែត្តទាំង ១៨ មណ្ឌល លើកទៅកំចាត់តាំងតុតីគ្រាមុននោះ
ឡៅតាយក៏លើកពលទៅធ្វើការជាមួយផង គ្រានោះចូរួយើញឡៅតាយ
មានដំរែចាជ្រា បានជាប្រើឲ្យធ្វើមេទ័ពលើកមក ដែលឫនឯងនឹងលើក
លើកទាហានចេញទៅចាប់ខ្លួនឡៅតាយនោះ បងយល់ឃើញថាមិន
មែនបានតាមបំណងគិតទេ ។ តៀវហ៊ុយធ្វើយតបថា នឹងចាប់ពុកជា

ពូកែជូចម្តេចថ្ងៃដែឡៅតាយប៉ុណ្ណេះ ខ្ញុំបាទនឹងចាប់យកមកឲ្យបាន ។ ឡៅពីថា បងក្រែងប្អូនឯងចេញទៅច្បាំងនឹងផ្ទើឲ្យអន្តរាយជល់ជីវត ឡៅតាយតែម្តង មិនបានខ្ជូនទាំងរស់មកជូចជាគួនអ៊ូ ។ តៀវហ៊ុយថា ទនេះលោកកុំបីវតក្តឡើយ បើខ្ញុំបាទសម្ងាប់ឡៅតាយក្តី ឬចាប់ខ្ជូនមិន បានមកទាំងរស់ក្តី ឲ្យលោកកាត់ក្បាលខ្ញុំបាទចេញ ។ ឡៅពីបាន ញ្ជូច្នោះក៏ពេញចិត្តណាស់ ទើបចាត់ទាហានសេះ ៣ ពាន់ឲ្យតៀវហ៊ុយ ៗ ក៏លាឡៅពីលើកចេញទៅ ។

ឯឡៅតាយកាលដឹងថា គួនអ៊ូចាប់ខ្ជូនអងតុងទៅបាន រួចឃើញ តៀវហ៊ុយលើកទ័ពមកទៀត ឡៅតាយក៏នឹកញញើតដែតៀវហ៊ុយមិន បានចេញច្បាំងប្រុងតែរក្សាបន្ទាយរាយកងទ័ពយាមល្បាតពីក្នុងបន្ទាយ ។ ឯតៀវហ៊ុយនោះលុះមិនឃើញឡៅតាយចេញមកច្បាំងសោះ ក៏លើក ទាហានចូលទៅដល់មុខបន្ទាយឡៅតាយ ហើយឲ្យទាហានស្រែកដេរ ជាពាក្យអាស្រូវកាសផ្សេង ៗ ឡៅតាយក៏សម្ងំស្ងៀមមិនបានលើកទ័ព ចេញច្បាំង ដែលរាវង់ជូច្នេះគ្រប់ ៥ ថ្ងៃ ។ តៀវហ៊ុយក៏គិតកលឧបាយ បង្ហាប់ទាហានទាំងពួងថា កណ្តាលយប់ស្ងាត់ក្នុងថ្ងៃនេះ ពេលយាម ៣ ជ្ងាយ យើងនឹងលើកចូលទៅប្ងន់យកបន្ទាយឡៅតាបរឲ្យបាន ឲ្យទាហាន ទាំងអស់ត្រៀមខ្ជូនឲ្យស្រេច ។ តៀវហ៊ុយផឹកស្រាហើយផ្ទើកិរិយា បែបស្រវឹងមិនដឹងខ្ជូន ក៏រកវៀងយកទោស់ទាហានម្នាក់ ឲ្យរាយ

ប្រហែល ៣០ រំពាត់ ហើយនិយាយនឹងតាហានដែលមានគោសនេះថា ពេលយាម ៣ ផ្ទាយក្នុងយប់នេះ យើងនឹងកាត់ក្បាលឯងសែនទង់ជ័យ ហើយលើកពលចូលទៅវាយបន្ទាយឡៅតាយ ។ គៀវហ៊ុយបង្គាប់ឲ្យចងតាហាននោះទុក ។ លុះពេលយាម ១ ថ្ងាយ គៀវហ៊ុយក៏លបប្រើមនុស្សឲ្យចូលទៅស្រាយចំណងតាហានមានគោសនោះចេញ តាហាននោះក៏លបរត់ទៅដោយមានចិត្តខឹងក្តៅនឹងខ្ទាចសេចក្តីស្ទាប់ ក៏គេចចូលទៅក្នុងបន្ទាយឡៅតាយ ហើយនាំយករឿងដែលគៀវហ៊ុយគិតនោះ ជ្រាប់ឡៅតាយគ្រប់ប្រការ ។ ឡៅតាយបានស្តាប់ហើយយើញរបួសស្ទាកស្នាមតាហាននោះជាបន្ទាល់ ក៏គ្មានពិកាល់សង្ស័យសំគាល់ថាពិតទើបកេណ្ឌតាហានឲ្យចេញទៅពួនបង្កប់ក្រៅបន្ទាយជា ២ កង ក្នុងបន្ទាយនោះគ្មានមនុស្សនៅសោះ ។

គៀវហ៊ុយដឹងថាតាហានដែលមានគោសត្រូវវាយនោះ រត់ទៅហើយ ក៏គិតថា ហេតុល្អអាក្រក់តាហាននេះរាគង់រត់ទៅជ្រាប់ឲ្យឡៅតាយដឹងមុខជាឡៅតាយនឹងចោលបន្ទាយ ឲ្យតាហានចេញពួនបង្កប់មិនខានអញនឹងរិះគិតអានត្រួតកលចាប់ខ្លួនឡៅតាយឲ្យបាន ។ លុះដល់ពេលយាម ៣ ថ្ងាយ គៀវហ៊ុយក៏លើកតាហានញ៉ែកគ្នាទៅពួនបង្កប់ជា ២ កង ហើយបង្គាប់ថា បើយើញពន្ធឺក្ងើងធេះបន្ទាយឡៅតាយ ត្រូវឲ្យលើកគ្នាវាយប្រសព្វខ្ទប់តំងសងខាង ខ្លួនគៀវហ៊ុយជាកងកណ្តាលប្រចាំ

ជូន ហើយបង្ហាប់ទាហាន ៣០ នាក់ជាកងមុខឲ្យចូលទៅប្ចន់អុជក្ងើង
ឲ្យធេះបន្ទាយឲ្យបាន ។ ទាហាន ៣០ នាក់ក៏លើកចូលទៅប្ចន់បន្ទាយ
ហើយជុតក្ងើងធេះឡើង ។

ឯទាហានឡៅតាយដែលពួនបង្ហប់ទាំង ៦ កង លុះឃើញជូច្នោះ
ក៏លើកវាយខ្ទប់ទាំងសងខាង ។ ទាហានតៀវហ៊ុយដែលបង្ហប់នៅពី
ខាងក្រៅ នឹងខ្ជួនតៀវហ៊ុយ លុះឃើញពន្ធឺក្ងើងធេះឡើងក្នុងបន្ទាយនៃ
ឡៅតាយ ក៏លើកសម្រុកចូលទៅវាយខ្ទប់ជា ៣ ជ្ជូវ ។ ចំណែកទាហាន
ឡៅតាយដែលបានឃើញទាហានតៀវហ៊ុយវាយខ្ទប់ពីក្រោយ ហើយ
ចាក់កាប់សម្ចាប់ខ្ចះរបួសពីការខ្ចះ ទាហានទាំងនោះក៏បែកខ្ចាត់ខ្ចាយទៅ
ខ្ចះ ។ តៀវហ៊ុយក៏បរពលចូលប្រយុទ្ធនឹងឡៅតាយបានមួយស្រចក់
តៀវហ៊ុយក៏ចាប់ខ្ជួនឡៅតាយបានហើយឲ្យទាហានចងទុក ។ បណ្ណា
ទាហានដែលបែកខ្ចែកទៅនោះ ក៏ត្រឡប់ចូលមកចំណុះចុះចូលតៀវហ៊ុយ
ជាច្រើន តៀវហ៊ុយក៏ឲ្យទាហានស្រូតទៅជំរាបឡៅពី ។ បានស្តាប់ក៏មាន
សេចក្តីត្រេកអរ ហើយនិយាយនឹងគ្ជនអ៊ូថា តៀវហ៊ុយជាមនុស្សចិត្ត
ស្រាលរហ័សកាចសាហាវណាស់ ត្រានេះគិតកលឧបាយចាប់ខ្ជួន
ឡៅតាយបាន ដែលតៀវហ៊ុយមានសតិបញ្ញាគិតឃើញបានការជូច្នេះ
ដោយបុណ្យសំណាងរបស់យើង ។ មានសេចក្តីសប្បាយចិត្តណាស់ ។

លុះវេលាព្រឹកឡើង ឡៅពីក៏នាំគ្ជនអ្ចិចេញទៅទទ្ជល់ដល់ក្រៅកំពែងស្រុក ត្រៀវហ៊ុយយើញឡៅពី, ឆ្ជនអ្ចិទៅដល់ក៏ចូលមកគំនាប់ ហើយនិយាយថា បងតិះដៀលថា ខ្ញុំបាទជាមនុស្សចិត្តស្រាលរហ័ស ឥឡូវខ្ញុំបាទចេះរិះគិតឧបាយកលចាប់ខ្ជនឡៅតាយបាន បងបានយើញដំរេះប្រាជ្ញាខ្ញុំបាទហើយឬ? ។ ឡៅពីតបថា ប៉ើបងមិនសង្កត់សង្កិនប្ជូនឯងយ៉ាងនេះទេប្ជូនឯងក៏ក្វើនចិត្ត ណាឡើយនឹងរិះគិតចាប់ខ្ជនឡៅតាយបាន ។ ត្រៀវហ៊ុយក៏អស់សំណើច ទើបឡៅពីចុះពីលើសេះចូលទៅស្រាយចំណងឡៅតាយចេញ ហើយនិយាយថា "ដែលប្ជូនយើងបានទៅធ្វើអ្នកដល់ទីនេះ អ្នកចូរអភ័យទោសចុះកុំបីប្រកាន់ឡើយ" និយាយហើយឡៅពីក៏នាំឡៅតាយចូលទៅក្នុងស្រុក ហើយឲ្យរៀបតុលៀងភោជនាហារ ប្រើបំរើឲ្យទៅនាំខ្ជនអងតុងពីក្នុងយុំនាំមកបរិភោគជាមួយនឹងឡៅតាយ ។

(មានត)

ត្រៀវជាពន្លឺនៃម្ចាស់ផ្ទះ

ជនជាសំឡាញ់មកកាន់ផ្ទះនៃជនណា ដើម្បីកិច្ចការណាមួយ ជននោះឈ្មោះថា ជាអ្នកមានបុណ្យ ជាអ្នកមានកល្យាណធម៌ ជាអ្នកគ្ជរគេសរសើរ នៅនាលោកនេះ ។

ដំណឹងតាមទ្យល់ក្នុងកាន្តារ:

លោកជេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីកាសាបារាំងមកជាកាសាខ្មែរ

(តមក)

លោកមាន៉ិយោរំពឹងថា "ប៉ើវិលទៅវាលទ្យាច់ពេលនេះ គឺប្រយោជន៍នឹងចាប់យកស្រីក្រមុំ ម្ហ៉ះហើយមុខជាបង្ហាញទ្ធនអញទៅរកទោសហើយស័ក្តិយសរបស់អញនឹងរះបះចញជាប្រាកដ" លុះគិតដូច្នោះហើយទើបគិតតទៅទៀតថា "ណ្ហើយកុំចុះ, អំពាម្ជយមកដល់មាត់ល្មមហើយ" ។ ក៏ផ្ទើយថា:

– "អញត្រឡប់ទៅវាលទ្យាច់មិនបានទេ . . . ។ រាហ្ជសហើយ។ ណាដិតយប់ផង ។ អញត្រូវទៅឲ្យដល់ក្រុងកាសិ - កាវាប្ចីលីឲ្យស្មើពេលគ្នានឹងលោកនាយរបស់អញ" ។

នាងឡីឡាស្រដីទៀតថា : "ទ្ចុំម្ចាស់ សូមអង្ហរលោកម្ពង !" ។ នាយទាហានរងញឹម។ ហើយយកដើងសុទ្ធតែរោមស្រមូវមកកៀសដៃនាងដែលកំពុងលើកប្រណម្យអង្ហរ ។

ទណ:នោះ លោកតាមាន៉ាព្រុកអែលតាឌ៉ ដែលចេះតែសំគាល់ចាំស្តាប់ការណ៍អ្ហីមិនមានទ្ធះត្រង់ណា ក៏ដើរចូលមករកលោកព្រិនូបាលឌនតំនាប់ដោយសេចក្តីគោរព ហើយនិយាយថា :

– "នាងនេះជានារីក្នុងកុលសម្ពន្ធរបស់ខ្ញុំ បើប្រសិនជាលោក
បើកច្បាប់ឲ្យខ្ញុំប្រើមនុស្សខ្ញុំម្នាក់ឲ្យទៅរកបងរបស់វាក៏បាន" ។

លោកម៉ារិយោបើកត្នោកចំលោកតាម៉ាត្រុក ហើយតាំងសំឡក់ចង់
ស៊ីសាច់ដោយបញ្ជាញសំដីថា :

– "អាឯងមានការអីមកលាយឡំជាមួយនឹងគេដែរ? អាឆ្កែ!
អាឯងដឹងឬទេត្រង់ទីនេះ ធំស្រេចលើអញ" ហើយតាត់ដាកទៅបង្គាប់
ទាហានម្នាក់ថា : "ចាប់ក្មេងនេះដាក់លើសេះឡើង ។ នាងនេះត្រូវ
ចិត្តអញ ។ យកវារក្សាទុកសម្រាប់ខ្លួនអញ!" ។

ទាហាននោះផ្ទើតាមភ្លាម ។ នាងឡើឡាបន្រះផង ស្រែកផង តែ
ឥតអំពើ ។ គេលើកនាងឡើងជូចស្ទឹកកណ្តាបដាក់លើខ្នងសេះ ។
នាងមមើរឃើញបងស្រីរបស់ខ្លួន គេបោះបង់ចោលកណ្តាលវាលខ្សាច់
ស្ទាប់តែម្នាក់ឯង ។ ខណៈនោះ ការអស់កំឡាំងនឹងសេចក្តីទុក្ខព្រួយញ្ចាំ
ញ្ចីនាងពន់ពេក ម្ហ៉ះហើយនាងក៏បណ្តាយខ្លួនឲ្យប្រព្រឹត្តទៅតាមយថា-
កម្មក្នុងកណ្តាប់ដៃទាហាន ហើយនាងសន្ទប់បាត់មាត់ឈឹង ។

លោកព្រិន្ទបាលទោម៉ារិយោ ញញឹមពេញចិត្ត គាត់ចាប់លើកកំប៉ុង
ស្រាផឹក ហើយផ្ទើសញ្ញាដល់ពួកទាហានឲ្យផ្ទើដំណើរតទៅទៀត ។

*

* *

ព្រះអាទិត្យទើបនឹងលិចបាត់ពន្ធឹរស្មី ។ ដីសើម ។ ត្រជាក់ចំណែក
សូរស័ព្ទផ្សង ។ ហាក់ដូចជាលាន់ព្ទឡើងក្នុងខ្សាច់ ។ ពួករតិសុខុមសត្ត

ពួកនិសាចរបក្សី ពួកឧរគ្គសត្វទាំងឡាយ ក៏តែងរកសត្វទាំងនេះ ដូចជា
បានចេញរួចពីការរងទុក្ខវេទនា គឺកំដៅថ្ងៃក្នុងពេលរសៀល ទឹងពន្លឺព្រះ
អាទិត្យ ។

នាងអាឥស្សាងងឹតងងុល ចេះតែវារកកេរសកក្សាសទាំងថ្ងូរហ៊ុះ
លើដីឡាច់ ។

នាងឡឺឡា តាំងពីចេញទៅ មិនដឹងជាប៉ុន្មានម៉ោងហើយទេ?

តឡូវនេះ ដៃនាងអាឥស្សាដែលធ្លាប់តែក្តៅ ពុះប៉ះដីឡាច់
ស្រាប់តែដឹងថាត្រជាក់គួរសម ហើយអាកាសក៏អន់ក្តៅ ។ នាងចូលចិត្ត
ថាយប់ហើយ យប់ឲ្យឃើញអន្ធការគោសៈតញ្ញលើកលឡាច់ទាំងមូល ។

ពេលនេះ គឺប៉ុន្មានពេលដែលចាស់ ។ តែនឹងនិយាយថាមានបិសាច
ចេញពីក្នុងដីឡាច់ ហើយធ្វើបាបដល់អ្នកដំណើរច្រៃហែស រំឭងជ្រួលនា
រាល់ភន្លារៈ ។ ខណៈនោះ អាឥស្សាតំពុងតែគ្រុន ក៏ស្រាប់តែភ័យ
ខ្លាចបែកញើសត្រជាក់អស់ទាំងខ្លួនឯណា ។ នាងកំសត់យល់ថា
ព្រះអាឡឹសបោះបង់នាងចោលជាទៀងជ្រាកដ ។ នាងស្រែកហៅ
ដោយសំឡេងខ្សោយ។ កណ្តាលរាល់ឡាច់ស្ងាត់ត្រឈឹងថា: "ម៉ែ!
ឡឺឡា!" ។

សំដីទាំងពីរម៉ាត់ចេញពីមាត់នាងនេះ គឺជាសំដីចុងបំផុត ជាសំដី
ជាទីគោរពដែលនាងថ្លាយចំពោះខ្លួនក្នុងរាល់ឡាច់ ហើយសំដីនេះគ្មាន
ឮសូរព័ងសោះ ក្នុងភក្តីស្ងាត់នោះ ។

នៅឯណោះ ឆ្វាយបន្តិច គេឃ្វសូរឆ្កែព្រៃមួយលូតឯង ព្រោះ លោកខែទើបនឹងរះចេញ ។ ពេលវេលាចេះតែកន្ធងទៅ កណ្តាលយប់ស្ងាត់ឃ្វសូរតែនារីវង្វេងផ្ទូវស្រែកហៅថា: "ម៉ែ! ឡើឡា!" ។

នាងនឹកភ័យខ្លាចជានិច្ច ។ នាងនឹកម្យ៉ាងទៀតថា បើប្អូននាងមិនឃើញត្រឡប់មកវិញតាមពាក្យសន្យា ដើម្បីជួយស្រង់ជីវិតនាងទេ នោះប្អូននាងប្រាកដជាត្រូវប៉ះលើត្រោះថ្នាក់ក្នុងកណ្តាលរាលខ្យាច់ដូចរូបនាងដែរ ។

នាងនឹកស្តាយណាស់ អំពីការស៊ូប្តូរជីវិតនេះដែលខ្លួននាងអង្វរទទូចសុំឲ្យប្អូនស្រីនាងនាំមក គឺជាយោបល់ខុសស្រឡះ រួចទឹកភ្នែកស្រាប់តែហូររហាមពេញលើថ្ពាល់ ។ នាងខំប្រឹងរារប្រវាលើដីខ្យាច់ល្បងមើលទៀត ហើយស្រែកហៅថា: "ម៉ែ! ឡើឡា!" ។

រួចនាងកំសត់លោត្រញែងខ្លួនដោយសេចក្តីភិតភ័យមួយរំពេច នាងស្ទុះថយក្រោយក្រាក ហើយប្រឹងដើបឈរ ព្រោះដៃនាងទើបនឹងជាក់ទៅលើខ្យមួយស្អិតៗ ត្រជាក់ៗ នាងស្រែកថា: "យី! ពស់!" ។

រួចនាងស្រែកហៅតាមធម្មតាវិស័យ មិនបានជាគិតថា:

– "លោកអើយ ជួយផង!" ។

នៅក្នុងក្រហែងថ្ម មានពស់វែកមួយអាស្រ័យនៅនោះ ។ នាងអន្ធចក្ខុកំសត់ដើបខ្លួនឡើង ពស់នោះរាផ្អើល ហើយរារមកជិតខ្លួននាង ។ កាលណារាធំក្លឹនមនុស្ស ក្នែករាទាំងពីរយ៉ាងខៀវស្រងាត់បើកឡើងភ្លឺធ្ទុះ,

ក់ក់រឡើងតាមសំពត់ដែលរុំជុំវិញពោះនាង ។ សត្វនេះក់រកកំដៅអ៊ុនៗ
ត្រង់ដោះនាង រួចក់រឡើងដល់ត្រង់កនាង ទៅជាចង្វាះដុំត្រសាលក្តុក
ពាំងពីរ ។ នាងភ័យពេក ស្ទើរបាត់ស្មារតី នាងចាប់ឥសប់ណាងទឹង
គ្រវាត់ចេញឲ្យឆ្ងាយពីខ្លួន ប៉ុន្តែគ្រវាត់មិនចាន់យឺតពេក ។

នាងបានដឹងថា ហាក់ដូចជាដែកស្លែចពីរមុតសាច់ក្រោមដោះខាង
ឆ្វេង ។ ឥឡូវត្រង់មុខរបួសឡើងក្តៅដូចគេដុត ។ ពិសពស់តំចូល
ពេញខ្លួននាងហើយជាស្រេច ។ ខណៈនោះ នាងចូលចិត្តថាសេចក្តី
ស្លាប់ទឹងមានដល់ខ្លួននាង មិនយូរឡើយ ។ នាងស្រមៃស្រមៃហាក់ដូច
ជាខ្មោច ម្ជូតៗទៅតំខ្លួនវិញខ្លួន ។ ម្ល៉ោះហើយ ទឹកភ្នែកអ៊ុនៗហៀរហូរ
ចេញច្រោក ។ ពីភ្នែកខ្លាក់ទាំងពីរ ។

កាលនោះនាងកំព្រាទឹកឃើញដល់ភូមិកំណើតមានផ្ទះកំពូល មាន
ផ្ទះច្នៃស ។ មានវត្តអារាមប្រកបដោយផលព្រឹក្សមែកសាខាច្រឈឹងច្រៃឈើ
រួចទឹកដល់កាលដែលនាងគ្រាប់ចរ ក្នុងស្រុកស្រែជាមួយនាងឡឺឡា
ហើយនឹងកិច្ចការអាដ៏រិះរបស់នាងទាំងពីរ ។ តទៅទៀត នាងហាក់ដូច
ជាភ្ញាក់ដឹម្តាយនិយាយ ឃើញមុខគាត់ញញឹមជាក់ដែលនាងស្រឡាញ់
រកអ៊ីប្រៀបគ្មាន ។ អនុស្សាវរីយ៍ជាអនេកលេចមានឡើងច្របូកច្របល់
គ្នាពេញទាំងសន្ដានចិត្ត គឺដូចជានំគ្រៀបដែលនាងចូលចិត្តបរិភោគ ដូច
ជាអង្កាំតូងតែវប្រ័នៗ ស៊ុតព្រាបដែលនាងចូលចិត្តពាក់ទៅក ដូចជាទំនុក-
ធម៌ ដូចជាទំនុកចម្រៀង ដូចជាសំឡេងកូនចៀម កូនពពែ . . . ។

ការឈឺចាប់ក្នុងទ្រូងត្រង់មុខរបួសអន់បន្តិចហើយ ប៉ុន្តែមានការ
ឈឺចាប់ផ្សងមួយទៀតចូលមកជល់ ។ ខ្លួននាងត្រជាក់អស់ហើយ ។
សេចក្តីស្លាប់មុខជាទៀងប្រាកដ ។ ទឹកភ្នែកក៏ឈប់ហូរ ។ សន្តិសុខ
យ៉ាងធរកទីបំផុតគ្មាន ចូលសណ្ឋិតនៅក្នុងដួងហ្ឫទ័យនៃនាង ។

នាងពោលខ្សឹប ៗ ថា:

– "សូមឲ្យបំណងរបស់ព្រះអាទ្យសសម្រេចចុះ!

ទោះបីការសុខចំត្តរបស់នាងដូចម្តេចក៏ដោយចុះ ប៉ុន្តែចំណែក
កំឡាំងយុវភាពនៅតែតយុទ្ធមិនយល់ព្រមនឹងមច្ចុរាជយង់ឃ្នង ដែលផ្តាច់
ជីវតិន្ទ្រិយនាងដែលទើបនឹងបានអាយុ ៦០ ឆ្នាំ ។ ម្រ៉ោះហើយទឹកភ្នែក
ក៏ចាប់ជោរជន់ហូរចេញមកជាច្ចីម្ពងទៀត ។ នាងឃើញហាក់ដូចជាមុខ
ប្អូនស្រីនឹងមុខម្តាយរបស់នាងញ៉ាញ៉ឹមស្លូតនៅពីមុខនាង ដោយសេចក្តី
ព្រួយ ។ នាងចូលចិត្តថាពេលនាងដល់ហើយ ៗ នាងតាំងសង្ឆ្មស្មារតី
ដើម្បីទទួលសេចក្តីស្លាប់ ។ នាងដេកសណ្តូកដើងយ៉ាងស្ងៀលលើដីខ្សាច់
ហែរមុខមើលមេឃដើម្បីឲ្យព្រះអាទិត្យចាំងរស្មីមកត្រូវ ។

ឥឡូវនេះរហសភាពដ៏អស្ចារ្យ យាងចុះពេញក្នុងសរីរកាយនាង
ហើយជាស្រេច ។ កាលព្រះអរុណ: ចាងចោលរស្មីបំព្រាងលើផ្នូក
ខ្សាច់បំភ្លឺព្រះធរណី ចិត្តអាឥស្សាតាក៏ចាកចេញផុតពីរាងកាយក្នុង
រវលានោះ ។

(មានត)

រឿងបល័ង្ពុទិត្យ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ចុត្យ៉ងជម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ដល់ពេលយប់ ព្រះរាជាទ្រង់បានចាត់ឲ្យរៀបចំសុរានឹងមេរ៉យជាច្រើន យ៉ាង សាច់, ត្រី, រតុផ្សេងៗ, នំបាំង, បាយចំអិនលាយទឹកឃ្មុំនឹងស្ករ, គោជនាហារ, សម្ងរ, ទឹកដោះគោខាប់, ទឹកដោះគោរាវ, ខ្ទាញ់គោចំរាញ់ឲ្យស្អាត, ទឹកខ្ទាញ់ ដល់ពេលយប់គោ. កំញាន. កម្រងផ្កា, ប្រុជ្ជា, ត្រឿងក្រអូបផ្សេងៗ . . . ល . . . សម្រាប់បូជាចំពោះវតាលៈអគ្គី; ព្រះអង្គទ្រង់បានចាត់ឲ្យយកវត្ថុទាំងអស់នោះ ទោងកល់នោព្រះរាជរាងហើយព្រះអង្គទ្រង់គង់ចាំនោក្រឡាព្រះបន្ទំ ។

វតាលៈអគ្គី បានចូលទៅក្នុងព្រះរាជរាង លើកព្រះខិនឡើងបំណងនឹងពិយាជព្រះបាទរក្រមទិត្យ ៗ មានព្រះឆន្ទារទៅកាន់វតាលៈអគ្គិថា: "ម្នាលវតាលៈអគ្គី! ចូរអ្នកស្តាប់យើង! ដោយហេតុថាអ្នកឯងមកទីនេះ បំណងនឹងសម្ងាប់យើង ៗ តតមានសង្ស័យថា ត្រង់បំណងអ្នកឯងមុខជានឹងមិនបានសម្រេចនោះឡើយ វតគោជគាហារទាំងនេះយើងឲ្យគេប្រមូលយកមកដំកល់ទុកនៅទីនេះដើម្បីអ្នក; ចូរអ្នកបរិភោត

អាហារទាំងអស់នេះសិន រួចសឹមអ្នកសម្ចាប់យើងជាក្រោយ" ។ រៀតាល:
អគ្គី កាលបានស្តាប់ព្រះរាជឧត្តារព្រះបាទវិក្រមទិត្យហើយ ក៏អាស្រ័យ
អាហារទាំងនោះ មានសេចក្តីពេញចិត្តនឹងព្រះអង្គក្រៃពេក ក៏ទូលថា
"ទូលបង្គំសប្បាយចិត្តនឹងព្រះអង្គពន់ពេក ទូលបង្គំសូមថ្វាយប្រទេស
អវន្តីនេះដល់ព្រះអង្គ; ទូលបង្គំសូមទុកទ្រង់ជាព្រះមហាក្សត្រិយ៍ទីមួយ
ហើយសូមឲ្យទ្រង់សោយរាជសម្បត្តិជាសុខសប្បាយចុះ ។ តែសូមទ្រង់
ចាត់ឲ្យផ្ទើម្ហូបអាហារមានឧជារសបែបនេះ ទុកឲ្យទូលបង្គំបរិភោគរាល់ថ្ងៃ
កុំខាន" ។ ដល់រៀតាល:អគ្គីក្រាបទូលព្រះបាទវិក្រមទិត្យហើយ
ក៏វិលត្រឡប់ទៅគេហដ្ឋានវិញ ។

ព្រិកឡើង ព្រះមហាក្សត្រិយ៍ទ្រង់បានបំពេញព្រះរាជករណីយកិច្ច
ទ្រង់បានចូលទៅក្នុងព្រះរាជមុន្ទីរប្រឹក្សា ។ ពួកទីប្រឹក្សានឹងអ្នកឯទៀត
បានឃើញព្រះមហាក្សត្រិយ៍ ក៏គិតក្នុងចិត្តថា: "បើព្រះមហាក្សត្រិយ៍
អង្គនេះរួចពីកណ្តាប់ដៃរៀតាល:អគ្គី យើងយល់ថាព្រះអង្គជាបុគ្គលដ៏
ឧត្តម" ។ កាលពិចារណាយ៉ាងនេះហើយ ពួកទីប្រឹក្សានឹងអ្នកឯ
ទៀត ក៏សំដែងសេចក្តីគារវ:ចំពោះព្រះអង្គ, បានយកចិត្តទុកដាក់បម្រើ
ព្រះអង្គឥតប្រមាទសោះឡើយ ហើយបំពេញករណីយកិច្ចសព្វ ៗ ខ្លួន ។

ព្រះបាទវិក្រមទិត្យ ទ្រង់បានផ្ទើឲ្យពួករដ្ឋមន្ត្រីនឹងអ្នកឯទៀតស្តាប់
ព្រះរាជឧត្តារ ដោយសេចក្តីកោតខ្ចាចផង, ករុណាផង, ព្រះអង្គបាន
បំពេញនូវរាជធម៌ត្រប់យ៉ាង តាមច្បាប់នយោបាយនឹងបទបញ្ញត្តិក្រម

ព្រហ្មទណ្ឌ ។ រាល់ថ្ងៃ, ព្រះអង្គបានចាត់ឲ្យរៀបចំហ្ហូបអាហារដូចមុនទុក
សម្រាប់រាតាលៈអគ្គី ។ តែតមក, ព្រះអង្គទ្រង់បានធ្វើឲ្យរាតាលៈអគ្គី នៅ
ក្រោមព្រះរាជបញ្ជារបស់ព្រះអង្គ ដោយប្រើមធ្យោបាយដូចខាងក្រោម ។

មានសម័យថ្ងៃមួយ ក្នុងពេលអភិទេសកាល, រាតាលៈអគ្គី កាល
បានបរិភោគអាហារទាំងនោះ មានសេចក្តីរីករាយសប្បាយចិត្តហើយមិន
បានរិលត្រឡប់ទៅតេហដ្ឋានវិញ ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះ
បន្ទូលសួរទៅរាតាលៈអគ្គីថា: "ឆរាតាលៈ តើអ្នកឯងមានសមត្ថភាព
ធ្វើអ្វីបានខ្ទះ? មានវិជ្ជាអ្វីខ្ទះ?" ។ រាតាលៈអគ្គីទូលតបវិញថា. "អ្វី
ដែលនៅក្នុងដួងវិញ្ញាណរបស់ទូលបង្គំ ។ បង្គាប់បានទាំងអស់, ទូលបង្គំ
ដឹងទាំងអស់" ។ ព្រះអង្គទ្រង់ត្រាស់តបថា: "ចូរអ្នកឯងប្រាប់យើង,
មើលចំមកយើង តើជីវិតយើងមានចិរវេលាត្រឹមណា?" ។ រាតាលៈ-
អគ្គីក្រាបទូលថា: "ព្រះជន្មាយុព្រះអង្គមានមួយរយព្រះវស្សា" ។ ព្រះ
បាទវិក្រមទិត្យមានព្រះឆន្ទារតបថា: "ក្នុងជីវិតយើងមានអកុសលពីរយ៉ាង
ជាកិច្ចមិនល្អសោះឡើយ; យើងប្រាថ្នាឲ្យអ្នកឯងធ្វើអាយុយើងឲ្យបាន
កើនចំនួនមួយឆ្នាំ ក្នុង ១០០ ឆ្នាំ, ឬបន្ថយមួយឆ្នាំក្នុង ១០០ ឆ្នាំចេញ បាន
ឬទេ? ។ រាតាលៈអគ្គី ក្រាបទូលថា: "ព្រះអង្គប្រកបដោយសុក្រិតភាព
នូវព្រះរាជចរិយា សោភ័ណ, សប្បុរស, អាណិតអាសូរអ្នកដទៃ,
សុចរិត ឈ្នះរាគាទិកិលេស, ពួកអាទិទេព នឹងព្រាហ្មណ៍តែងគោរព
ព្រះអង្គ; ជីវិតរបស់ព្រះអង្គពេញទៅដោយសេចក្តីសុខ, ទូលបង្គំមិន

អាចបង្កើន ឬបន្ថយបានឡើយ" ។ ព្រះបាទវិក្រមទិត្យកាលទ្រង់
សរនាវាចាវេតាលៈអត្តី ក៏មានព្រះទីយសោមនស្សពន់ពេក; វេតាលៈ-
អត្តី ក៏ត្រឡប់ទៅគេហដ្ឋានវិញ ។

តាំងពីថ្ងៃនោះមក ព្រះមហាក្សត្រិយ៍ មិនបានចាត់ឲ្យរៀបចំអាហារ
ក្នុងពេលរាត្រី សម្រាប់វេតាលៈអត្តីទេ, តែព្រះអង្គប្រុងប្រៀបតស្ងួនឹង
វេតាលៈនេះ ។ បន្ទិចទៀត វេតាលៈមកដល់មិនឃើញមានអាហារដំកល់
ទុកនៅទីនោះ ឃើញតែព្រះរាជអាកប្បកិរយាប្រុងប្រៀបនឹងធ្វើសង្ត្រាម
ទៅវិញ, ក៏មានចិត្តក្រោធជាខ្លាំងហើយពោលថា: "ស្តេចពាល,
ឥឡូវនេះ ម្តេចក៏អ្នកឯងមិនរៀបចំអាហាឲ្យខ្ញុំបរិភោគ?" ។ ព្រះបាទ-
វិក្រមទិត្យមានព្រះឧង្ការតបទៅវេតាលៈវិញថា: "ប្រើអ្នកឯងមិនអាច
បន្ទន្ទូវចិរវេលានៃជីវភាពយើង ឬបន្ថយជំវិតយើងបានទេ តើឲ្យយើង
រៀបម្ហូបអាហារជានិរន្ទរកាលឲ្យអ្នកឯងបរិភោគ មានផលប្រយោជន៍
អ្វី?" ។ វេតាលៈតបថា: "ម្តេចក៏អ្នកឯងពោលដូចនេះ? អ្នកឯង
មកតស្ងួតាក្នុងកាលឥឡូវនេះ គឺក្នុងថ្ងៃនេះហើយដែលអញបរិភោគអ្នក
ឯង" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ឌាបន្ទូវវាចាវេតាលៈនេះហើយ
ទ្រង់ព្រះក្រោធជាខ្លាំង ព្រះអង្គទ្រង់ក្រោកឡើង ដើម្បីតយុទ្ធតាម
ក្សន្ទរណារិជ្ជាជាច្រើនយាងនឹងវេតាល ក្នុងរយៈវេលាជាច្រើនាទី ។
វេតាលៈបានពិសោធន៍ស្តេចនេះដឹងច្បាស់ថា "ព្រះអង្គទ្រង់មានព្រះរាជ-
ពលភាពនឹងព្រះវីរិយភាពដ៏អស្ចារ្យក្នុងការតយុទ្ធនេះ" ។ វេតាលៈមាន

សេចក្តីពេញចិត្តក៏ពោលថា "នែព្រះមហាក្សត្រិយ៍ ព្រះអង្គមានព្រះពរជ័យសិរីសួស្តីវ្រឹទ្ធាអស្ចារ្យ ខ្ញុំសូមក្រាបទូលបង្គំជាខ្ញុំមានសេចក្តីពេញចិត្តនឹងព្រះវិរិយភាពរបស់ព្រះអង្គ ចំពោះការតយុទ្ធនេះណាស់, សូមព្រះអង្គទ្រង់មានព្រះពរតែង្ហាវ តើព្រះអង្គមានព្រះពរជំណងចង់បានអ្វីពីខ្ញុំសូមក្រាបទូលបង្គំជាខ្ញុំ" ។ ព្រះមហាក្សត្រិយ៍មានព្រះបន្ទូលថា: "បើអ្នកឯងស្រុះស្រួលនឹងយើងត្រូវអ្នកយល់ព្រមថា ក្នុងកាលអនាគតបើយើងនឹកដល់អ្នកឯង ឲ្យអ្នកឯងមកជិតយើងភ្លាម" ។ រៀងលះ ក៏យល់ព្រមតាមព្រះពរជំណងរួចក៏លាត្រឡប់ទៅគេហដ្ឋានវិញ ។

ដល់ព្រឹកស្អែក ព្រះពរជវិប្រក្សាបានដឹងរឿងក៏រៀបនេះ ពីព្រះឧស្ដព្រះមហាក្សត្រិយ៍. ហើយបានយល់ជាក់ច្បាស់នូវសន្តតិវង្សនៃព្រះអង្គ ក៏ចាត់ឲ្យធ្វើមហាសន្និបាតជាខ្លាំងក្លា ដើម្បីនឹងអភិសេកព្រះអង្គឲ្យសោយរាជ្យ ជាស្តេចនៅប្រទេសនោះ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានទទួលព្រះរាជាភិសេកហើយ ក៏បានសោយរាជសម្បត្តិជាសុខ មិនបានទ្រង់ព្រះចិន្តាថារាជសម្បត្តិនោះមានបន្ទាគឺទុក្ខភ័យឬលំបាកផ្សេងៗឡើយ ។

ក្នុងសេលានោះ មានយោគីម្នាក់មកដល់ ហើយក្រាបទូលថា: "ខុមហារាជ! កិច្ចការដែលខ្ញុំសូមទាំងប៉ុន្មាន សូមព្រះអង្គយល់ព្រមតាមទូលបង្គំៗ នឹងថ្វាយពាក្យមួយដល់ព្រះអង្គ" ។ ព្រះមហាក្សត្រិយ៍មានព្រះបន្ទូលថា: "នែយោគី, អ្នកចង់បានព្រះរាជទ្រព្យ របស់យើងទាំងប៉ុន្មាន ឬជីវិតយើង យើងនឹងប្រគល់ជូនអ្នកដូចបំណង,

យើងនឹងធ្វើតាមបង្គាប់អ្នកទាំងអស់" ។ យោគីនោះក្រាបទូលថា: "ទូលបង្គំមានកិច្ចត្រូវធ្វើពិធីបូជាសព; សូមព្រះអង្គយាងទៅជួយទូលបង្គំកុំខាន" ។ ព្រះមហាក្សត្រិយ៍ទ្រង់យល់ព្រម, យោគីនោះក៏នាំព្រះអង្គទៅកាន់អាឡាហនដ្ឋាន ។ លុះស្តេចទ្រង់យាងទៅដល់ទីនោះ យោគីក៏បង្គាប់ព្រះអង្គថា: ព្រះអង្គ, ចម្ងាយពីទីនេះចំនួនពីរក្រុស:, មានរុក្ខជាតិមួយដើមឈ្មោះសំសប: គេបានយកសាកសពមួយទៅចង; សូមព្រះអង្គយាងទៅយកសាកសពនោះក្នុងកាលឥឡូវនេះ" ។ យោគីនោះលុះបង្គាប់ព្រះមហាក្សត្រិយ៍ហើយ ក៏ទៅស្ថិតនៅខាងទិសបូពាិនៃប៉ាធាដែលតាំងនៅមាត់ស្ទឹង យយាិ ហើយសូត្រនូវមន្ត្រ(១) ត្រង់បូជនិយដ្ឋាននាងអាទិទេវីកាលិកា ។ ព្រះមហាក្សត្រិយ៍ទ្រង់ហាងទៅដល់ព្រឹក្សជាតិ សំសប: ទ្រង់ឡើង ទៅលើដើមឈើនោះហើយយកព្រះខ័ន កាត់ផ្តាច់ចំណង ដែលចងសាកសព ។ ធ្លាក់ជ្រុះមកដល់ដី ។ តែដល់ព្រះមហាក្សត្រយ៍ទ្រង់ចុះពីលើរុក្ខជាតិមកដល់ដី សាកសពនោះឡើងទៅលើរុក្ខជាតិនោះវិញ ហើយធ្វើឲ្យមានសភាពចងព្យួរដូចកាលពីមុន ។

(មានត)

---

១ មន្ត្រ (Mantras) វាចាអាចិកចាំងហើយមានឥទ្ធានុភាពឲ្យសម្រេចទៅតាមបំណង ដូចជាគាថាកាំភ្លើងជាដើម, យើងហៅថា មន្តអាគម ។

កំណាត់ឯកប្រវត្តិការណ៍

បញ្ជីឈ្មោះនាមចៅអធិការដែលតាំងថ្មី

របស់គ្រែសួងធម្មការ

(តទៅ)

សញ្ញាប័ត្រលេខ ៤២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហង់-ជួប នាមឆាយា ជោតន្តេរ កើតឆ្នាំវក អាយុ ៥៤.វស្សា ៣៣ ជាចៅអធិការ វត្តអង្គព្រះស្តេច ឃុំបឹងក្រាញ់ ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៤២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អាំង-អ៊ូច នាមឆាយា សុធម្មបញ្ញា កើតឆ្នាំច អាយុ ៥២ វស្សា ៣០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៤២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន-សៀន នាមឆាយា ជោតន្តេរ កើតឆ្នាំមមី អាយុ ៤៩ វស្សា ២២ ជាគ្រូសូត្រឆ្វេង-វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៤២៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប្ចាក់-ឱត នាមឆាយា សុវណ្ណជោត កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៦ ជាគ្រូសូត្រឆ្វេង វត្តអង្គគោល ឃុំ-ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៤២៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ

ប៉ែន - ឧម នាមធាយា នន្ធត្ថេរ កើតឆ្នាំមមែ អាយុ ៥៥ វស្សា ៣២ ជាចៅអធិការ វត្ត - ឃុំ - ស្រុក - ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកត្រូ ហ្ជ - ឃ្ជយ នាមធាយា នន្ធជោត កើតឆ្នាំកុរ អាយុ ៥១ វស្សា ២៧ ជាត្រូសូត្រស្ពាំ វត្ត ឃុំ - ស្រុក ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩២៨ ចុះកាលបរិច្ឆេទដដែល តាំងលោកត្រូ ព្រាប - ម៉ម នាមធាយា បញ្ញាកេសរ កើតឆ្នាំថោះ អាយុ ៥៩ វស្សា ៣៩ ជាចៅអធិការ វត្តប្រាង្ឌណ៍អណ្ណែត ឃុំ - ស្រុក - ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩២៩ ចុះកាលបរិច្ឆេទដដែល តាំងលោកត្រូ ម្ជន - សុខ នាមធាយា ព្រហ្ជជោត កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាត្រូសូត្រធ្ជេង វត្ត - ឃុំ - ស្រុក - ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកត្រូ ក្ជូច - ឡុង នាមធាយា សុវណ្ណបញ្ញា កើតឆ្នាំថោះ អាយុ ២៣ វស្សា ៣ ជាត្រូស្រូត្រស្ពាំ វត្ត - ឃុំ ស្រុក ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកត្រូ សុខ - ស្រី នាមធាយា ជោតបញ្ញា កើតឆ្នាំច អាយុ ៥២ វស្សា ៣២ ជាចៅអធិការ វត្តអង្ឌកូរ ឃុំ - ស្រុក - ខេត្រដដែល ។ (មានត)



ដំណើរទស្សនានៃឯកឧត្តម អ៊ូ-ន

នៅថ្ងៃទី ១៣ ធ្នូ ១៩៥៤ ម៉ោង ១៥ នឹង ៣០ នាទី ដាច្ចៃសុភមង្គល ដោយវិដ្ឋាហានពុទ្ធសាសនបណ្ឌិត្យ បានទទួលភ្ញៀវពិសេស គឺ ឯ. ឧ. អ៊ូ-ន្ធ រដ្ឋមន្ត្រីទី ១ នៃសហភាពភូមាព្រ៉ឹមទាំងលោកចំទាវ នឹងសហការី រួមដា ៩ រូប ដែលអញ្ជើញមកទស្សនាវិដ្ឋាហាននេះ ។

រៀលនោះ, យើងបានយើញតិស្សរដន គឺ ឯ. ឧ. ប៉ាល់-ដួន រដ្ឋលេខាធិការ ក្រសួងធម្មការ, លោក យឹន-ចឹម អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ, លោកឈុន-យឹន នាយកមន្ទីរនឹងបុគ្គលិកក្រសួងធម្មការ ព្រមទាំងក្រសួងពុទ្ធសាសនបណ្ឌិត្យ ដែលយើងសូមអភ័យទោស ដោយចេញនាមពុំសព្វគ្រប់ បានមករង់ចាំទទួល ឯ. ឧ. អ៊ូ-ន្ធ នៅកើយខាងមុខវិដ្ឋាហាន ហើយបានតាំចូលទៅទស្សនាគ្រប់កន្ទៃងដ៏គួរ ។

យើងសំគាល់ឃើញ ឯ. ឧ. អ៊ូ-ន្ធ ស្ទ្យៀកសំពត់អន្ទូញសំឡុយព័ណ៌ខ្យៀវប្រផេះ ពាក់អាវិស កមូលឡេវកុំ ពាក់ឈ្នូតក្បាលស, លោកចំទាវស្ទ្យៀកសំពត់អន្ទូញសំឡុយព័ណ៌ខ្ទាញ់ក្តាម ពាក់អាវិបំពង់ខ្ទី ដៃវៃងព័ណ៌ស ដាសំលៀកបំពាក់នឹងសាច់សំពត់របស់ជាតិភូមា ។

ការចូលទស្សនាវិដ្ឋាហានពុទ្ធសាសនបណ្ឌិត្យ ឯ. ឧ. អ៊ូ-ន្ធ បានចាប់អារម្មណ៌ជាច្រើន ដោយឃើញ ឯ. ឧ. ពិនិត្យមើលទីទាំងឡាយ ជាដើមគឺ ប្រកាសអក្សរខ្មែរដែលនៅលើទូដាក់ស្នាកប្រាប់ឈ្មោះតម្លីរ បានឲ្យអ្នកប្រែភាសាអានអក្សរនោះជាសំឡេងខ្មែរនឹងភូមាដូនស្តាប់មួយស្របក់ធំ, ហើយទើបទៅទស្សនាទីដំកល់សាស្ត្រាស្ទឹកវិត ដែលនៅជុំវិញការិយាល័យនៃអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ។

បន្ទាប់ពីនេះ, បានតាំទៅទស្សនាកន្ទៃងក្រុមដំនុំព្រៃរ៉ៃត្រៃបិដក, ហើយហួសទៅទស្សនាសាលាបាលីជាន់ខ្ពស់, លុះចូលទៅដល់យ៉ាងមុខ ដោយ ឯ. ឧ. អ៊ូ-ន្ធ ព្រមទាំងសហការីជាពុទ្ធដនកំបានគោរពព្រះសង្ឆជាបាងហ្ទាងនឹងសាស្ត្រាចារ្យ ដោយកាយវិការដ៏សមរម្យ ។ យើងចាំបានថាមុននឹងចូលទៅ, ឯ. ឧ. អ៊ូ-ន្ធ ឃើញព្រះសង្ឆព្រះបាទទទេ ក៏ងាករកទីទាបឈរសុំទោស ហើយទើបឧនកាយថ្ទាយបង្គំ ។ ចំណែកសភាពស្ត្រី ៣ រូបមានលោកចំទាវ អ៊ូ-ន្ធ ជាដើម ឃើញដោះស្ឆៃកដើងលុតជង្គង់ទាំងពីរឧនក្បាលដិតដល់ដីលើកដៃថ្ទាយបង្គំដោយទន់ភ្ទន់ ។ លុះគោរពហើយទើបចូលទៅទស្សនាសមណសិស្សដែលកំពុងរៀនត្រៀបត្រា, រួចថ្ទាយបង្គំលាត្រឡប់ទៅវិញដោយរីករាយ ។

អវសាននៃការទស្សនានេះ, អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បានផ្ទូន ឯ. ឧ. អ៊ូ-ន្ធ នូវព្រះពុទ្ធរូបសម្រិទ្ធឹគ្រាផ្ទាញ់មារ ១ ព្រះអង្គដែលរកបានដោយក្រ ជារចនាខ្មែរបុរាណដែលមានក្នុងវិដ្ឋាហានពុទ្ធសាសនបណ្ឌិត្យ ដើម្បីជាអនុស្សាវរីយ៍ ។ យើងសំគាល់ឃើញ ឯ. ឧ. អ៊ូ-ន្ធ មានអំណរចំពោះអំណោយនេះណាស់ដោយលោកចេះតែលើកបិទទូលលើស៊ីរសារឿយ ៦ ។

ពុទ្ធសាសនបណ្ឌិត្យ

ភម្ពុជសុទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៣ – គ.ស. ១៩៤៤



ភម្ពមសនិយា

ទស្សនាវដ្ដី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ
ហ្មោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

	បញ្ជីរឿង	**ទំព័រ**
ផ្នែកសាសនា		
— វិចារណកថា	ពុទ្ធសាសនបណ្ឌិត្យ	៨៣
— អភយទានពិសេស	ព្រះឧបាលិវង្ស សូរ - ហាយ ...	៨៧
— បញ្ញាសជាតក ភាគទី ៣ (តមក)	បណ្ឌិតមហា ឈឹម -ស៊ុម	១០២
ផ្នែកអក្សរសាស្ត្រ		
— រឿងសាមកុក (តមក)	ឧកញ៉ា នូ- កន	១១៨
— រឿងបល្ស៉ង្គទិព្យ (តមក)	ណេកវ៉ាយ- ប៊ុក	១២២
— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីចំរៀងនឹងប្រយោជន៍ចំរៀង ..	ណេកចាប - ពិន	១៣១
កំណត់នឹងប្រវត្តិការណ៍		
— អនុសំវិច្ជរមហាសន្និបាតទី ១១ នៃមន្ត្រីសង្ឆ សម្រាប់ឆ្នាំ ១៩៥៥	ពុទ្ធសាសនបណ្ឌិត្យ	១៤៦
— ពិធីបុណ្យទក្ខិណានុប្បទានរបស់ព្រះសាសនមុនី មាស-កង ចៅអធិការវត្តពិភទ្ធរង្សី	ព្រះវិន៍យធរអនុគណ ឯក- ញឹម .	១៥១

ម្ចូយឆ្នាំមាន ១២ ស្យៀវភៅ — ដំឡៃជាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE: Page

— Editorial . . . . . *Institut Bouddhique* 83

— Abhayadanapisès . . . . . *vén. SO-HAY* 87

— Pannasajataka- vol 3 (suite) . *M. CHHIM-SOUM* 102

PARTIE LITTERAIRE:

— Histoire de samkok (suite . . *oknha NOU-KAN* 118

— Les trente deux récits du Trône (suite) *M. RAY-BUC* 122

— Activité de la Commission des Mœurs et Coutumes Les Chansons) . . . . . *M. CHAP-PIN* 131

NOTES ET CHRONIQUES:

— Réunion annuelle des digitaires religeux . . . . . *Institut Bouddhique* 146

— Transmission de mérites célébrée par le vén Brah Sasanamuni Meas-Kang . . . . . *vén. EK-NHIM* 151

Prix d'abonnement annuel (comprenant 12 numéros) 210$00

ធៀបពីពោះភ្លេងនឹងពីពោះធម៌

ភ្លេងជាគ្រឿងធ្វើចិត្តនៃមនុស្សលោកឲ្យរំភើបរីករាយ, ភ្លេងនេះបើអ្នកចេះលេងដំនាញ រមែងជាទីពេញនៃអ្នកបានស្តាប់ ។ តែភ្លេងរបស់ជនជាតិណា ជនជាតិនោះស្តាប់ពីពោះ គឺថាខ្មែរស្តាប់ភ្លេងខ្មែរពីពោះ ខ្មែរស្តាប់ភ្លេងបារាំងមិនពីពោះ ។ ពាក្យនេះបានសេចក្តីថ្វីមកថា អ្នកស្តាប់ភ្លេងពីពោះ មកពីស្តាប់បាន មិនពីពោះមកពីស្តាប់មិនបាន ។ ហេតុនេះសូម្បីខ្មែរស្តាប់ភ្លេងខ្មែរ បើខ្លួនមិនចេះលេងភ្លេងនោះទេ ក៏ស្តាប់ភ្លេងខ្មែរមិនពីពោះ ទោះបីខ្លួនជាជាតិខ្មែរ តែបើចេះលេងភ្លេងបារាំង ក៏អាចស្តាប់ភ្លេងបារាំងពីពោះ ។ ដូច្នេះ ការពីពោះនឹងមិនពីពោះគង់តែស្តាប់ភ្លេងមកតែពីអ្នកស្តាប់ ចេះនឹងមិនចេះគង់តែស្តាប់ភ្លេងនោះឯង ។

សេចក្តីនេះ សឲ្យឃើញច្បាស់ថា មនុស្សយើងបើបានអប់រំខ្លួនខ្លះគង់ផ្លូវណា បានចេះចាំស្តាត់ដំនាញហើយ គង់ពេលក្រោយមក កាលបើបានស្តាប់ឮឬបានឃើញរបស់នោះ រមែងពីពោះឬពេញចិត្តចង់ស្តាប់ចង់ធ្វើ ។ ឧទាហរណ៍យ៉ាងអ្នកចេះច្រៀង ឮគេច្រៀង ក៏ចង់ច្រៀង, អ្នកចេះជាល់ ឃើញគេជាល់ ក៏ចង់ប្រជាល់, អ្នកចេះលេងចត្តង្គ, ឃើញគេលេងចត្តង្គ ក៏ចង់លេង, ចំណែកអ្នកមិនចេះវិញ សូម្បីស្តាប់ឮហើយមើលឃើញហើយ ក៏គ្មានចិត្តស្រើបស្រាល ចង់ច្រៀង ចង់ជាល់ ចង់

លេងទេ ។ រឿងនេះ បំភ្ងឲ្យយល់បានថា អ្នកដែលមានចិត្តចំណូលក្នុង
ល្បែងតាំងនោះ មកពីគេពីរោះ បានជាគេពីរោះ មកពីគេបានអប់រំពីមុន ។

ការស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏មានទំនង
យ៉ាងនេះដែរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាក្នុងទីខ្ងះ មានពុទ្ធបរិស័ទ
ស្តាប់រាប់ពាន់រាប់ម៉ឺននាក់ តែចំពោះអ្នកដែលស្តាប់ទៅហើយពីរោះ
សម្រេចជល់គុណវិសេស មានសោតៈជាដើម មានតែម្នាក់ ឬពីរនាក់
ប៉ុណ្ណោះ ដូចកាលព្រះបរមត្រូនៃយើងទ្រង់ស្តេចទៅសំដែងធម្មកថាអំពី
មរណស្សតិ ក្នុងអគ្គាឲ្យវវិហារ នាដែនអាឲ្យវី ក្នុងទីប្រជុំនៃបរិស័ទច្រើន
ពាន់ ។ ក្នុងពេលចប់ធម្មទេសនានោះ មានតែនាងបេសការធីតា (កូនស្រី
ជាងតំបាញ) ម្នាក់ឯងទេ ដែលបានសម្រេចសោតាបត្តិផល ដោយហេតុ
មុនស្តាប់ធម្មកថានេះ នាងបានការនាតាំងថ្ងៃតាំងយប់ នូវមរណស្សតិ
អស់រវាង ៣ ឆ្នាំមកហើយ ។ រឿងនេះធ្ងុះឲ្យយល់ច្បាស់ថា អរិយសាវ័ក
តាំងឲ្យាយ ដែលបានសម្រេចមគ្គផលក្នុងពេលដែលស្តាប់ធម៌ព្រះសម្ពុទ្ធ
ព្រោះអាស្រ័យកម្ចាំងនៃអភិនិហារ កសាងទុកមកអំពីអតីតផង ។

វត្ថុនំទាន (រឿងក៉ូ) ដែលមានចែងក្នុងគម្ពីរធម្មបទដ្ឋកថា, ក្នុង
រឿងមួយ ។ លោកចែកពីរោះជា ៣ ជាន់ គឺ ១– ពីរោះបទដើម ដោយ
ផ្ងើឲ្យអ្នកស្តាប់ចង់ដឹងរឿងក៉ូ តើជាយ៉ាងណាទៅ ។ ២– ពីរោះបទ
កណ្ណាល ដោយការសំដែងធម៌ (គាថា) តភ្ជាប់ពីរឿងនោះមក ។
៣– ពីរោះបទចុង ដោយការសំដែងញ្រកបំបែកធម៌នោះ (អដ្ឋកថា)
ឲ្យល្មិតល្អន់ ផ្ងើឲ្យអ្នកស្តាប់កាន់តែចូលចិត្តជ្រៅទៅ ។ ។ តែរឿងនោះ

មានជនខ្ទះបានស្តាប់ប្ដបានអានហើយ ត្រង់បទដើមក៏មិនពីរោះ បទ
កណ្ណាលក៏មិនពីរោះ បទចុងក៏មិនពីរោះ; ជនខ្ទះពីរោះតែបទដើម បទ
កណ្ណាលនឹងបទចុង មិនពីរោះ, ជនខ្ទះទៀត ពីរោះតែបទកណ្ណាលនឹង
បទចុង ត្រង់បទដើមមិនពីរោះ ។

ជនដែលមិនពីរោះទាំង ៣ ជាន់ គឺជនគ្មានបានអប់រំក្នុងផ្លូវវិជ្ជាមក
សោះ ជាមនុស្សល្ងិតដូចយប់ ។ ជនដែលពីរោះតែបទដើម គឺជនដែល
បានអប់រំ សិក្សាវិជ្ជាបានចេះដឹងយ៉ាងបន្ណូ ។ ជនដែលពីរោះតែបទ
កណ្ណាលនឹងបទចុង គឺជនចេះដឹងជាន់ខ្ពស់ ត្រូវការចង់ស្តាប់តែសាច់ធមិ
មិនត្រូវការចង់ដឹងរឿងរ៉ាវ ។

ទស្សនាវដ្ដីកម្ពុជសុរិយាយើង ក៏មានសេចក្ដីពីរោះទំនងនឹងរឿងទាង
លើនេះដែរ គឺពីរោះទី ១ ដោយអត្ថបទជាធមិអាចិផ្នែកសាសនា, ពីរោះ
ទី ២ ដោយអត្ថបទផ្នែកអក្សរសាស្ត្រ, ពីរោះទី ៣ ដោយអត្ថបទជាកំណត់
នឹងប្រវត្តិការណ៍ ។ តែយើងក៏អាចដឹងទាន់ថា អ្នកអានទស្សនាវដ្ដីយើង
មិនមែនចេះតែពីរោះត្រប់គ្នា ត្រប់ទាំង ៣ ជាន់ទេ អ្នកអានខ្ទះពីរោះត្រង់
អត្ថបទនេះ ខ្ទះពីរោះត្រង់អត្ថបទនោះ, អ្នកអានខ្ទះទៀត ក៏មិនពីរោះត្រង់
ណាសោះ ។ ព្រោះហេតុនោះ ការធ្វើឲ្យពីរោះត្រូវត្រប់ថានៈនៃមនុស្ស
ជាការណ៍ផុតវិស័យយើង មិនអាចធ្វើទៅបានទេ ស្រេចហើយតែអ្នក
អានដែលបានអប់រំវិជ្ជាទុក ឬមិនបានអប់រំវិជ្ជាទុកពីមុន ដែលជាកាជន៍
សម្រាប់ត្រង់អត្ថរសនៃទស្សនាវដ្ដីនេះ ដូចជាអ្នកស្តាប់ក្ងេងពីរោះនឹងមិន
ពីរោះដូច្នោះឯង ។

ពីរោះតាមបាន:នៃមនុស្ស

កុមារសឹងពីរោះដោយសំដី លួងលោមស្តីថាឲ្យនំផ្អែមពីសា,
ប្រុសកំឡោះស្រីក្រមុំធ្លាញ់ពាក្យថា តែងកាយដោយគ្រឿងនេះឆើតឆាយ ។
អ្នកជាប់គុកសឹងពីរោះពាក្យថារួច ពីទោសលួចដែលពាជការធ្វើពេញទី,
អ្នកមានពេគុកពានសព្វកាយិន្ទ្រិយ តែងសំតីពីរោះពាក្យជ្រាប់ទុសថ ។
ពួកជនតាលសឹងពីរោះពាក្យខុច្ចរិត, ពួកបណ្ឌិតពិតពីរោះពាក្យល្អផុត
ជាវាចាមានទឹមសារយ៉ាងចំហុត, សូមលំអុតបញ្ចប់រឿងពីរោះអើយ ។

ពុទ្ធសាសនបណ្ឌិត្យ

សភាពល្អ ៤ ពួក

១— ព្រះរាជាល្អ ព្រោះទ្រង់ទសពិធរាជធម៌,
២— ឥរជនល្អ ព្រោះមានប្រាជ្ញា,
៣— មិត្តភក្តិល្អ ព្រោះមិនប្រទុស្តមិត្ត,
៤— សេបក្តីសុខមាន ព្រោះមិនធ្វើបាប ។

ផ្នែកសាសនា

អភយទានពិសេស

ព្រះឧបាលិវង្ស សូរ-ហាយ វត្តឧណ្ណាលោម

ក្រុមដំនុំព្រះត្រៃបិដក

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះសង្ឆ ដោយសេចក្តីគោរព) ។

លំដាប់នេះ សូមសំដែងអំពី អភយទានពិសេស ដូចដំណើរសេចក្តីដែលនឹងអធិប្បាយ បរិយាយតាមហេតុផល ទុកជាសណ្ឋាប់នៃពុទ្ធបរិស័ទតទៅ ។

ពាក្យថា អភយទាន នេះ បានសេចក្តីថា ការឲ្យទកាសដល់មនុស្សសត្ត មិនឲ្យមានភ័យ គឺថាទុកជាក់ខ្ជួនយើងមិនឲ្យជាសត្រូវដល់មនុស្សនឹងតិរច្ឆាន ដោយការធ្វើខ្ជួនយើងមិនឲ្យមនុស្សនឹងពួកសត្ចមានសេចក្តីភិតភ័យព្រោះហេតុតែយើង ។

ពាក្យថា ពិសេស បានសេចក្តីថា ដោយឡែក, គុណដែលគួរសរសេរី, ដែលប្ចែកលើសលន់ ។ រួមសេចក្តី: ពាក្យដែលហៅថា "អភយទានពិសេស" នេះ សំដៅយកការឲ្យអភ័យចំពោះពួកសត្ច ៣

ប្រភេទ ដែលជាបសុសត្វមានឧបការៈច្រើនមានគោជាដើម ដូចសេចក្ដីពណ៌នាតទៅនេះ ៖

បសុសត្វ (សត្វចិញ្ចឹម) មានច្រើនប្រភេទគឺ គោ, ក្រប៉ី, សេះ ជាដើម ។ គោ ក្រប៉ី សេះ ជាពាហនៈរបស់មនុស្សគ្រប់ប្រទេស ។ មនុស្សទាំងអស់ សុទ្ធតែបានអាហារអំពីកម្ចាំងគោក្រប៉ី ដែលជាសត្វបម្រើរបស់អ្នកផ្ទៃស្រែចំការ ។ កម្ចាំងរបស់គោក្រប៉ីបណ្ណាលឲ្យកើតបានស្រូវ អង្ករ ល្ង សណ្ណែក ពោតជាដើម សម្រាប់ចិញ្ចឹមមនុស្សក្នុងលោក ។ ផលិតផល ដែលកើតអំពីធរណីទាំងប៉ុន្មាន ក៏សុទ្ធតែកើតមកអំពីកម្ចាំងគោក្រប៉ី ។ អ្នកផ្ទៃស្រែចំការត្រូវមានគោក្រប៉ីនេះឯងជាដើមទ្រព្យ, គោក្រប៉ីនេះ ជាដើមសេដ្ឋកិច្ចរបស់មនុស្សគ្រប់ប្រទេស, ជាបសុសត្វមានឧបការគុណយ៉ាងធំលើមនុស្ស ត្បូរណាស់តែបសុសត្វពួកនេះបានទទួលអភយទានអំពីមនុស្ស ។

គោក្រប៉ីជាសត្វបម្រើ ក្នុងការទ៍មរទេះបរដឹកនាំអីរ៉ាន់គ្រប់មុខ, ក្នុងការភ្ជួររាស់ដីស្រែចំការ, ក្នុងការជិះចម្ងងកាត់ទឹកភក់ ដែលយើងមិនអាចដើរទៅដោយជើងបាន ។ គោក្រប៉ីជាសត្វមានម្រយោជន៍ធំបំផុតដែលអាចជួយជីវិតមនុស្សយើងឲ្យរស់នៅសព្វថ្ងៃនេះ ត្បូរតែគោក្រប៉ីបានទទួលអភយទានអំពីមនុស្សដោយពិត ។ ប៉ុន្តែបណ្ណាមនុស្សទាំងអស់មិនសូវដែលពុអ្នកណាមួយនិយាយសរសើរថា "គោក្រប៉ីនេះមានឧបការគុណសោះ ។ ជនជាតិខ្មែរអ្នកមានធមិសប្ឋុរសនៅខែត្រក្រៅ ក្នុងកាលពីដើមមិនសូវមានអ្នកចេះបរិភោគសាច់គោក្រប៉ីទេ, អ្នកខ្លះដែលមាន

គោក្របីស្លាប់ ទឹមន្តព្រៃសង្ឃឹបង្ក្រូល ទុំសកុសលបញ្ជូនទៅឲ្យគោក្របីដែលស្លាប់នោះ រួចហើយក៏យកទៅកប់ ។ អ្នកខ្លះដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌ ឈប់ក្បរកាស់អស់ ២ ថ្ងៃក៏មាន ៣ ថ្ងៃក៏មាន, គេលាងទឹកគោក្របីឲ្យជ្រះស្អាតល្អ ហើយយកប្រែងមៀលាបក្បាលនឹងស្នែង រួចវមាគោសចំពោះមុខគោក្របីនោះ ដោយពាក្យដ៏ខន់ក្ងន់ថា "យើងបានយកឯងមកជាពាហនៈទឹមប្រើ ក្បរកាស់ដីកន្លះ ឥឡូវនេះដល់ថ្ងៃខែបុណ្យភ្ជុំបិណ្ឌ, យើងលាងទឹកលាបប្រែងមៀឲ្យឯងពាល់គ្នា ដែលយើងបានប្រើប្រាស់ដោះស្តីវាយប្រដៅបន្តិចបន្តួច, សុំឲ្យឯងពាល់គ្នា កុំចងកម្មពៀរនឹងយើង តាំងយើងក៏សុំកុំឲ្យមានកម្មពៀរនឹងឯងពាល់គ្នាហ្នា ! " ។

មនុស្សជាន់ពីដើម បើតាមសង្កេតទៅឃើញថា មានឧត្តមគតិបរិសុទ្ធណាស់ មិនសូវមានអ្នកពិឃាតគោក្របីទេ តាំងអ្នកដែលចេះបរិភោគសាច់គោក្របីក្នុងឃុំនីមួយ ។ ក៏មិនសូវមានឡើយ ។ មនុស្សជាន់មុន ប្រើគោក្របីប្រកបដោយចិត្តមេត្តាករុណា ដោយបានឃើញគេបំប៉ននិងទឹកឲ្យឆ្អែតស្កប់ស្កល់ល្អណាស់ ។ អ្នកខ្លះច្រូតស្រូវសំទូងដែលឲ្យគោក្របីបរិភោគឲ្យបានឆ្ងាញ់ពីរដងមួយកាល ។

សេះជាពាហនៈសម្រាប់បម្រើមនុស្សដែលត្រូវការដឹកក៏បាន ទឹមរទេះក៏បាន ។ សេះជាសត្វមានកម្លាំងអត់ធ្មត់មានល្បឿនលឿនជាងសត្វទាំងអស់ មិនធាប់ហត់នឿយសន្ធាបញ្ជើសដូចគោក្របីទេ ។ សេះពាប់ថាជាសត្វមានប្រយោជន៍ក្នុងការដឹកដោយមានការប្រញាប់ ។ សង្គ្រាមដើមគោកគាំងពីសម័យព្រៃនាយរហូតដល់បច្ចុប្បន្ននេះ, គេតែងប្រើសេះជា

ពាហនៈក្នុងសង្ត្រាម ឬាលីហៅថា "អស្សានីក" ប្រែថា "កងទ័ព
សេះ" ឬថា "ពួកទាហានសេះ", សេះក៏រាប់ថាជាបសុសត្វមានឧបការ:
ដល់មនុស្សបន្ទាប់បន្សំនឹងគោក្របីដែរ ។ អ្នកប្រើសេះក៏គួរតែថ្នាក់ថ្នម
ដោយមេត្តាករុណា ហើយគួរតែឲ្យអភ័យដល់ជីវិតបសុសត្វនេះកុំខាន ។

ប្រជាជនឥណ្ឌៀមិនបរិភោគសាច់គោក្របី

ប្រជាជនភាគច្រើននៅប្រទេសឥណ្ឌៀដែលកាន់សាសនាព្រាហ្មណ៍
នឹងសាសនាព្រះពុទ្ធ រ៉ៀរលែងតែពួកអ្នកកាន់សាសនាឥស្លាម មិនបរិ-
ភោគសាច់គោក្របីទេ គេទុកជាសត្វមានឧបការគុណជាទីបំផុត, សូម្បី
កាលនៅក្រោមអំណាចរដ្ឋាភិបាលអង់គ្លេស អ្នកដែលធ្វើការរាជការជា
មួយនឹងអង់គ្លេស ទោះបីអង់គ្លេសនិយាយដឹកនាំយ៉ាងណា ក៏មិនព្រម
បរិភោគសាច់គោដោយជាច់ខាត ។ ឥឡូវនេះ រដ្ឋាភិបាលបណ្ឌិតនេហ្រុ
ប្រទេសឥណ្ឌៀ ឲ្យានបញ្ញត្តទូទៅក្នុងអាណាចក្រទាំងមូល តាមផ្លូវការ
ហាមផ្តាច់មិនឲ្យពិឃាតគោក្របី ។ បើអ្នកណោលបពិឃាតនឹងត្រូវទោស
ជាទម្ងន់ ប្រហែលគ្នានឹងទោសពិឃាតមនុស្សដែរ ។ អ្នកប្រទេសឥណ្ឌៀ
ភាគច្រើនមិនបរិភោគសាច់សត្វ សូម្បីសាច់មាន់ទាជ្រូកក៏គេមិនបរិភោគ
ដើម្បីរក្សារាងកាយឲ្យប្រកបដោយអនាម័យ ឲ្យរាងកាយមានសុខភាពល្អ
ដោយគេយល់ឃើញថា សាច់ជាហេតុនាំឲ្យកើតរោគច្រើនយ៉ាង មាន
លោហិតរោគជាដើម ។ លោហិតរោគ (រោគឈាមលើស) ដែល
នាំឲ្យខ្លួនយើងមានរោគជាច់សរសៃ ក៏ព្រោះទោសល្មោភបរិភោគសាច់

បណ្តាលហេតុឲ្យមនុស្សមានស្លាប់ជាច្រើន ។ គេតមសាច់គោក្របី តឹងរឹងបំផុតដូចពួកចាមជាតមសាច់ជ្រូកដែរ ។ មួយទៀត ជនជាតិឥណ្ឌៀដែលកាន់សាសនាព្រាហ្មណ៍ ឬកាន់សាសនាព្រះពុទ្ធសព្វថ្ងៃនេះ ដែលតមត្រីសាច់ កាន់តែច្រើនណាស់ហើយ ដោយគេយល់ឃើញហេតុ ៥ យ៉ាង គឺ

១ - ការមិនបរិភោគត្រីសាច់នេះ ឈ្មោះថាជាជីវិតទានដល់ពួកសត្វតិរច្ឆានគ្រប់ប្រភេទ ។

២ - អហឹសាលទ្ធិ (លទ្ធិមិនបៀតបៀនមនុស្សសត្វ) ជាលទ្ធិរបស់រដ្ឋបុរសមួយរូបឈ្មោះ មហត្មគន្ធី ដែលជាលទ្ធិល្អគួរគោរព គួរជឿ ។

៣ - សាសនាព្រាហ្មណ៍ មានបវត្តិការណ៍តាំងអំពីព្រឹទ្ធាយុយូរលង់ណាស់ហើយថា បើអ្នកណាបរិភោគសាច់គោក្របី, គេកាត់កាល់លែងកប់អានអ្នកនោះថាជាអារ្យមនុស្សហើយ, គេទុកជាក់អ្នកបរិភោគសាច់គោក្របីថាជាអនារ្យមនុស្ស ជាន់ដល់មនុស្សចណ្ឌាលឬមនុស្សមិលក្ខជាតិ គឺជាតិមនុស្សថោកទាប, មនុស្សមានជាតិអាក្រក់, មនុស្សព្រៃផ្សៃ ។

៤ - គោក្របីជាសត្វមានឧបការៈដល់មនុស្សដែលអាចជួយជីវិតមនុស្សដោយកម្លាំងកាយច្រើនណាស់ ទាំងជាសត្វស្លូតបូត ។

៥ - គោជាបសុសត្វដែលមនុស្សគួរដឹងគុណបំណាច់ ព្រោះថាក្នុងសាសនាព្រាហ្មណ៍មានដំណាលរឿងថា "គោជាឈ្មោះទេវបុត្រមួយអង្គ ជាពាហនៈ គឺជាយានដំនិះរបស់ព្រះសិវៈ (ព្រះឥស្សរ) ដែលឋិតនៅ

ក្នុងហានសួគិទេវលោក" ។ គោទេវបុត្រនេះឈ្មោះ នន្ទិ ដែលគេហៅ
ថា "គោនន្ទិទេវបុត្រ" ។ ទេវបុត្រនោះតែងតំណែងខ្ជួនធ្វើជាគោ
ដើម្បីជាយានជំនិះថ្វាយព្រះសិវ: ដែលត្រូវការជិះទៅកាន់ទីណាមួយ ។
គោនន្ទិទេវបុត្រនេះ ជាអ្នកបំរើយ៉ាងសំណប់របស់ព្រះសិវ:ដែលឥណ្ឌា
ឲ្យនាមថា "គោឧសភរាជ" គឺស្តេចគោឈ្មោល ។ ខ្មែរយើងជ្ជាប់
កាន់សាសនាព្រាហ្មណ៍ដែរ ចុានជាមានពាក្យថា "ព្រះគោ" ដោយ
ការជាប់ចិត្តគោរពគោនោះទេដឹង? មានទាំងពាក្យហៅថា "ព្រះគោ
ព្រះកែវ" ។ ពាក្យថា "ព្រះគោព្រះកែវ" នេះ ប្រហែលជារូបគោ
ដែលគេកសាងទុកជាតំណាងនៃគោនន្ទិទេវបុត្រ, ទាំងរូបគោនោះគេធ្វើ
អំពីកែវ ឬក៏សំដៅព្រះពុទ្ធរូបកែវមរកតទេដឹង?

អាស្រ័យហេតុ ៥ យ៉ាងនេះហើយ ចុានជាពួកអ្នកកាន់សាសនា
ព្រាហ្មណ៍ប្រទេសឥណ្ឌាគោរពគោ មិនបរិភោគសាច់គោជរាបមក ។

ហេតុ ៥ យ៉ាងដូចពោលមកខាងលើនេះ អាចបញ្ញាត្តរាវាំងជនជាតិ
អ្នកកាន់សាសនាព្រាហ្មណ៍មិនឲ្យបរិភោគត្រីសាច់ ។ ប្រជាជនជាតិ
ខ្មែរយើងក៏ត្លរពិចារណាតាមហេតុ ៥ យ៉ាងនេះដែរ ប៉ុន្តែត្រង់ហេតុទី ៥
នោះ មានគម្ពីរជាតកក្នុងពុទ្ធសាសនារបស់យើងថា "ព្រះសម្មាសម្ពុទ្ធ
កាលនៅជាពោធិសត្ត ដែលកំពុងត្រាច់រង្គាត់ក្នុងភពវដ្ពសង្សារនៅឡើយ
ព្រះអង្គក៏ធ្ជាប់យកជាតិជាគោដែរ" ។

គម្ពីរជាតកក្នុងពុទ្ធសាសនា មានអតីតនិទានដំណាលថា កាលព្រះ
សម្មាសម្ពុទ្ធបរមត្រូរបស់យើង កំពុងអន្ទោលយោនយកកំណើតនៅក្នុង

ហានៈជាព្រះពោធិសត្ត ដែលនៅត្រាប់ឆ្ពាត់ក្នុងរាលវដ្តសង្សារនៅឡើយ, ព្រះអង្គធ្លាប់ចាប់ជាតិកំណើតជាគោ ដែលមានក្នុងជាតកហៅថា "កណ្ហ-ទសកជាតក" នឹង "ទន្ធិវិសាលជាតក" ។ ជាតកនៃព្រះពោធិសត្ត ដែលធ្លាប់ចាប់ជាតិជាគោពីរជាតិនេះ សឹងមានប្រាកដនៅក្នុងគម្ពីរជាតកឯណោះស្រាប់ហើយ ។ យើងអ្នកកាន់ព្រះពុទ្ធសាសនា កាលបើពិចារណាដល់រឿងជាតករបស់ព្រះពោធិសត្ត ដែលទ្រង់ធ្លាប់យកជាតិជាគោនេះ. យើងគ្លរមានចិត្តមេត្តាករុណាដល់គោ. មិនគ្លរនឹងហ៉ានពិឃាតគោ ឬបរិភោគសាច់គោសោះឡើយ ។ កាលព្រះអង្គបានត្រាស់ដឹងគង់ក្រោមម្លប់ពោធិព្រឹក្ស, យើងជាពុទ្ធបរិស័ទ តែងមានសេចក្តីគោរពចំពោះពោធិព្រឹក្ស មិនហ៉ានកាប់ដើមពោធិព្រឹក្សទេ សូម្បីពាក់ម្លកឬបុំងធ្វីតដើរក្រោមដើមពោធិព្រឹក្ស ក៏យើងមិនហ៉ាន ។ ចំណែកខាងពោធិព្រឹក្សដែលយើងគោរពយ៉ាងណា. គោក៏យើងគ្លរគោរពយ៉ាងនោះដែរ ។ ករណីនេះកាលបើយើងពិចារណាដោយហ្មត់ចត់ មិនគ្លរហ៉ានបរិភោគសាច់គោឡើយ ។

ពួកតិរច្ឆានក្រៅពីគោ ដូចយ៉ាងដំរី, ត្រីរ៉ស់, ចាបជាដើមក៏មានជាតកដែលនិយាយអំពីព្រះសម្មាសម្ពុទ្ធធ្លាប់ចាប់ជាតិដែរ ប៉ុន្តែជារឿងជាតកកន្ធងទៅជាយូរអង្វែងណាស់ហើយ, មួយទៀតដូចយ៉ាងដំរី ជាសត្វចតុប្បាទមានខ្លួនធំណាស់ ប៉ុន្តែជាសត្វមិនសូវមានប្រយោជន៍ច្រើនដូចគោក្របីទេ ចំណែកខាងត្រីរ៉ស់នឹងចាបជាដើម ជាតិរច្ឆានតូចតាចមិនរាប់ថាជាបសុសត្ត (សត្វចិញ្ចឹម) ទេ តែបើពុទ្ធបរិស័ទមានសេចក្តី

គោរពដោយការមិនបៀតបៀន មិនបរិភោគសត្វតាំងនេះបាន ក៏រឹតតែ ប្រសើរណាស់ទៅទៀត ។

គោព្រះរាជទ្រព្យក្នុងពិធីប្រត់ព្រះនង្គ័ល

នៅប្រទេសកម្ពុជាយើងមានទំនៀមព្រះរាជពិធីប្រត់ព្រះនង្គ័ល ។ ពិធីនេះជារបស់ព្រះមហាក្សត្រ ដែលតែងធ្វើមករៀងរាល់ឆ្នាំមិនដែលដាច់, ព្រះរាជពិធីនេះយកគោមកទឹមនង្គ័លរួចថ្វាយព្រះមហាក្សត្រដើម្បីប្រត់ក្ឆូរជាកិច្ចមង្គលនាំមុខបណ្ណារាស្ត្រ ដើម្បីពិសោធន៍សម្បូងសង្រូងឲ្យប្រជាជនធ្វើស្រែក្នុងឆ្នាំនេះបានផលបរិបូណិ បានសុខសប្បាយក្នុងការធ្វើស្រែ ។ គោមួយនឹមដែលយកមកទឹមក្នុងព្រះរាជពិធីប្រត់ព្រះនង្គ័លនោះ ជាគោព្រះរាជទ្រព្យហៅថា គោឈសករាជ ដែលចិញ្ចឹមទុកជាទីប្រោសប្រាណដោយមេត្តាករុណាដ៏ល្អបំផុត ។ គោមួយនឹមរបស់ព្រះរាជទ្រព្យនោះ ជាសត្វមានក័ព្វសំណាងល្អណាស់ ដែលរួចខ្ជូនអំពីការពិឃាត ដោយការទទួលអកយទានអំពីព្រះមហាក្សត្រិយ៍, ឯគោក្រៅពីនេះមិនទាន់ដែលបានទទួលអកយទានសោះ ។

ប្រទេសភូមាបញ្ញត្តមិនឲ្យពិឃាតគោក្របី

ប្រទេសភូមាដែលទើបរួចអំពីអាណានិគមអង់គ្លេសថ្មីៗ បានទទួលឯករាជ្យបរិបូណិ, ឥឡូវនេះព្ធថារដ្ឋាភិបាលភូមា បានបញ្ញត្តដាច់ខាតមិនឲ្យពិឃាតគោក្របីដូចប្រទេសឥណ្ឌៀដែរ លុបបំបាត់មិនឲ្យមានសមាគម (ក្នុងស៊ុ) ពិឃាតគោក្របីទ្បើយ ទុកឲ្យនៅមានតែសមាគមពិឃាតជ្រូក

ពពែមាន់ទាប៉ុណ្ណោះ ដោយគេយល់ឃើញថា គោក្របីនេះជាសត្វមានគុណូបការៈ ជាប្រយោជន៍ដួយបំពេញការណីយកិច្ចរបស់មនុស្សយ៉ាងធំណាស់ ត្រូវតែឲ្យអភ័យដល់សត្វពួកនេះ មិនត្រូវពិឃាតឡើយ, គោក្របីនេះ យើងត្រូវចិញ្ចឹមគ្រាន់តែខុកទឹមប្រើ ឬរួតយកទឹកដោះប៉ុណ្ណោះ មិនត្រូវពិឃាតយកសាច់មកធ្វើជាអាហារឡើយ គេបានតាំងបង្កើតសមាគម សម្រាប់ទទួលយកគោក្របីចាស់ៗ ចិញ្ចឹមខុកឲ្យតាល់តែស្រួតថែមទៀត ព្រោះហេតុនោះត្រូវតែយើងមានមេត្តាករុណាខំខុកបំរុងតាមសមគួរដល់សត្វដែលមានឧបការៈដូចយ៉ាងគោក្របីសេះ ។

ប្រទេសកម្ពុជាយើង ជាប្រទេសកាន់ព្រះពុទ្ធសាសនាដូចប្រទេសឥណ្ឌា កូមាដែរ តាំងឯកពជ្រក៏មានកេតនកណ្ហកាន់តែក្តីថ្លាបរិបូណ៌ហើយ គួរតែចែកសិទ្ធិឯកពជ្រដល់គោក្របីឲ្យគ្មានរួចអំពីការពិឃាតផង ។ យើងអ្នកកាន់ព្រះពុទ្ធសាសនា ស្គាល់សិក្ខាបទទី ១ របស់និច្ចសីល ជាពុទ្ធប្បញ្ញត្តិដែលព្រះអង្គហាមមិនឲ្យសម្លាប់សត្វនោះស្រាប់ហើយ សូម្បីសត្វល្អិត ។ មានសង្កើចចៃជាដើមក៏ត្រូវហាមតាំងអស់ ។ ចំណែកខាងសត្វមាន់ទាជ្រកជាបសុសត្វដែរ ប៉ុន្តែគេមិនពាក់ថាជាពាហនៈទេ ឯគោក្របី ជាសត្វបម្រើមានឧបការៈដួយកម្លាំងមនុស្សបានធំណាស់, គួរតែយើងអ្នកកាន់ព្រះពុទ្ធសាសនាឲ្យអភ័យ, ឲ្យសិទ្ធិដល់គោក្របីឲ្យគ្មានរួចខ្លួនស្រឡះអំពីការពិឃាត ទើបឈ្មោះថាយើងអ្នកមានមនុស្សធម៌ឬយុត្តិធម៌ដ៏ប្រសើរ របស់មនុស្សអ្នកមានធម៌និយ័តក្នុងព្រះពុទ្ធសាសនាដោយពិតផង ឈ្មោះថាយើងបានរក្សាវិតិសីលពិសេសផង ។

គោក្របីជាសត្វមានកម្លាំងច្រើនប្រើប្រាស់ ជាប្រយោជន៍ដល់មនុស្ស, គួរយើងជាមនុស្សប្រើប្រាស់ដោយសេចក្តីកតញ្ញូអាណិតអាសូរ, យើងជាមនុស្សត្រឡាំងមិនសមបើធ្វើចិត្តទុច្ចរិតអាក្រក់ឥតមេត្តាករុណា, ឥតនឹកឃើញឧបការៈរបស់គោក្របី ដែលយកគ្នាមកប្រើជួយកម្លាំងដើម្បីបានប្រយោជន៍ បានសុខមកខ្លួនជាច្រើនណាស់, បើតាមសង្កេតដោយយុត្តិធម៌ដ៏បរិសុទ្ធ ឃើញថាមិនគួរហាន ប្រមាថពាធដន្ទ, ហាន ពិឃាត, ហាន បរិភោគសាច់គោក្របីសោះឡើយ ។ ការពិឃាតគោក្របីនេះជាអកតញ្ញូតា ជាអំពើបាបឬជាអំពើទុច្ចរិតអយុត្តិធម៌មួយដែលគួរឲ្យស្បថស្បែងយ៉ាងធំរៃលែងរបស់មនុស្សអ្នកកាន់ធម៌ ក្នុងពុទ្ធសាសនា ។ សូម្បីកងគម្ពីរក៏មានសំដែងថា សម្រាប់សត្វមានគុណធំ មានទោសធំដែរ ។

យើងអ្នកកាន់ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា កាលបើឮដំណឹងថា ប្រទេសឥណ្ឌានឹងប្រទេសភូមាឲ្យអភ័យដល់គោក្របី ដោយការរៀបរៀងអំពីការពិឃាតគោក្របីដូច្នោះហើយ ប្រហែលជាលោកអ្នកសប្បុរសខ្លះ ដែលធ្លាប់មានព្រហ្មវិហារធម៌នឹកក្នុងចិត្តដោយរសោមនស្សត្រេកអរអនុមោទនាចំពោះប្រទេសនោះពុំខាន ព្រោះគោលបំណងរបស់យើងអ្នកកាន់ព្រះពុទ្ធសាសនា ដែលយើងធ្លាប់រៀបចាកជាតិជាតមកក៏មានស្រាប់ហើយ ។ ត្រីសាច់ទាំងអស់គេធ្លាប់ពាប់អានថាជាអាហារក៏ពិតមែនហើយ ប៉ុន្តែយើងអ្នកកាន់ព្រះពុទ្ធសាសនា គួរពិចារណាអាហារផង ដូចយ៉ាងសាច់គោក្របី មិនគួរយកមកធ្វើជាអាហារសម្រាប់

មនុស្សអ្នកមានសីលធម៌សោះ, អ្នកល្មោភស៊ីសាច់ ច្រើនតែស្រូតទៅរក
សុរាមកជឹកក្លៃមថែមទៀតក៏មាន នាំបណ្តាលឲ្យស្រវឹងទូចប្រាជ្ញាស្មារតី
នាំបង្កជម្លោះទាស់ទែងរាយកាប់ត្នាក៏មាន ។

គោក្របីដែលយើងពុំគួរសំឡាប់នោះដោយហេតុ ៦ យ៉ាង :

១ - ព្រោះហេតុថា បសុសត្វមានឧបការៈគុណច្រើនដល់មនុស្ស

២ - ព្រោះហេតុថា អ្នកសំឡាប់សត្វដែលមានរាងកាយធំ ត្រូវ
មានទោស ជាមហាសាវជ្ជ: (ទោសច្រើន)

៣ - ព្រោះហេតុថា គោជាតិរច្ចានដែលព្រះបរមពោធិសត្វធ្លាប់
ចាប់ជាតិដែរ

៤ - ព្រោះហេតុថា សាច់គោក្របីកាលបើអ្នកល្មោភបរិភោគអាច
បណ្តាលឲ្យកើតរោគច្រើនយ៉ាងមានលោហិតរោគ (រោគឈាមលើស)
ជាដើម ដែលជាហេតុនាំឲ្យជាប់សរសៃស្លាប់ដោយងាយ

៥ ព្រោះហេតុថា យើងជាមនុស្សត្រឡាំងពុំគួរទុកជាក់ខ្លួនជា
មនុស្សអកតញ្ញូចំពោះគោក្របីសោះ

៦ - ព្រោះហេតុថា [ប្រទេសឥណ្ឌា] - ភូមាដែលជាពុទ្ធសាសនិក
ជួចយើងដែរ គេតមជាច់ខាតក្នុងការពិយាតគោក្របី ។

គោក្របីនេះ ជាសត្វជួយស្រោចស្រង់ជីវិតមនុស្ស ឲ្យរស់នៅឲ្យ
ប្រយោជន៍ធំណាស់ ។ យើងជាមនុស្សនៅក្នុងសង្គមមនុស្ស ទាំងគោ
ក្របីដែលជាបសុសត្វ ក៏យើងយកមកប្រើប្រាស់ជួយជាកម្លាំង នៅក្នុង

សង្គមជាមួយនឹងយើងជាមនុស្សដែរ ។ យើងគួរចិញ្ចឹមទុកដើម្បីគ្រាន់តែ
ប្រើប្រាស់ដោយការទឹមរទេះដឹកនាំ, ទឹមនង្គ្គ៍លក្ជូររាស់ដោយចិត្តដ៏ត្រជាក់
ប្រកបដោយមេត្តាករុណាប៉ុណ្ណោះបានហើយ, មិនគួរយើងសម្ចាប់ជីវិត
យកសាច់បរិភោគ ឬលក់ទៅឲ្យឈ្មួញដែលទិញយកទៅឲ្យសមាគម
ពិឃាតសោះទ្បើយ, គួរឲ្យអាណិតអាណោចខ្ចោចផ្សាចំពោះគោក្របីពន់
ពេកណាស់ ។ បើយើងមិនបានផ្ទើកិច្ចតបគុណណាមួយដល់គោក្របី
ក៏ហើយទៅចុះ, យើងកុំតែពិឃាតឬកុំលក់ទៅឲ្យអ្នកពិឃាតក៏ឈ្មោះថា
យើងមានសប្បុរិសធម៌ក្នុងសន្តាន សមគួរដល់មនុស្សធម៌ណាស់ហើយ ។

ប្រជាជនប្រទេសឥណ្ឌា ទាំងអ្នកកាន់សាសនាព្រះពុទ្ធ ទាំងអ្នក
កាន់សាសនាព្រាហ្មណ៍ តែងពោលពាក្យរិះគន់ពេបជ្រាយចំពោះអ្នក
ដែលបរិភោគសាច់គោក្របី ថាជាមិលក្ខជាតិ គឺជាតិនៃមនុស្សអាក្រក់
ថោកទាបជាទីបំផុត ។ មួយទៀត ជនដែលគេហៅថាមិលក្ខជាតិ
នោះ ដោយគេសំគាល់មនុស្ស ៣ ពួក ៖

១– គោមំសភក្ខកោ ជនអ្នកស៊ីសាច់គោ

២– លោកវាក្យញ្ច ភាសតេ អ្នកនិយាយពាក្យ តែខាងផ្ទូរលោក

៣– សញ្ចាបារវិហីគោ ជាអ្នកប្រាសបាកមារយាទំគ្រប់យ៉ាង ។

ប្រជាជនឥណ្ឌាយល់ថា គោទុកជាម្តាយរបស់មនុស្ស ព្រោះថា
ទារក ទារិកាដែលកើតអំពីម្តាយ ជួនកាលម្តាយមានជម្ងឺតំកាត់ណាមួយ

មិនមានទឹកដោះបំបៅកូនក៏មាន ម្តាយស្ងាប់ចោលកូនទៅក៏មាន ។ គាវកគាវិកា ទាំងនោះ ក៏ត្រូវគេចិញ្ចឹមឲ្យរស់នៅបាន ដោយទឹកដោះគោ, ព្រោះហេតុនោះ កាលបើអ្នកណាមួយហាមពាំយាតគោឬស៊ីសាច់គោ, អ្នកនោះឈ្មោះដូចជាអ្នកពាំយាតម្តាយ ឬស៊ីសាច់ម្តាយរបស់ខ្លួន ។

ពាក្យឬរឿងការដែលត្រូវនិយាយ មានច្រើនយ៉ាងពិតមែន ប៉ុន្តែបើបំប្រួញដោយខ្លឹមានតែ ២ យ៉ាងគឺ លោកវោហារ: ពាក្យដែលនិយាយក្នុងរឿងផ្លូវលោក ១, ធម្មវោហារ: ពាក្យដែលនិយាយក្នុងរឿងផ្លូវធម៌ឬប្រកបដោយធម៌ ១ ។ ពួកជនណាច្រើនចូលចិត្តនិយាយតែខាងផ្លូវលោកម្យ៉ាង មិននិយាយផ្លូវធម៌ផង, ពួកជននោះគេតែងរិះគន់ថាជាមនុស្សថោកទាប ។

ពាក្យថា "ច្បាស់ចាកមារយាទគ្រប់យ៉ាង" បានដល់បុគ្គលអ្នកប្រព្រឹត្តក្នុងផ្លូវអបាយមុខ មានការលេងល្បែងស៊ីសង ទំនាក់ផឹកសុរាជាដើម ។ ពួកជនណា ជាអ្នកប្រកបដោយមារយាទថោកទាប មានការប្រព្រឹត្តក្នុងផ្លូវអបាយមុខជាដើម ពួកជននោះគេតែងហៅថា អនារ្យមនុស្ស គឺមនុស្សពុំប្រសើរឡើយ ។ សមដូចបាលីលោកនីតិរបស់ប្រទេសឥណ្ឌាថា:

គោមំសភក្ខកោ យោ តុ លោកវោហារញ្ញូ ភាសតេ
សព្ភាហរិហីនោយំ មិលក្ខូតិ វុច្ចតេ ។
យេ ច ខាទន្តិ គោមំសំ មាតុមំសំវ ខាទយេ
មតេសុ តេសុ គិជ្ឈានំ ទទេ សោតេ ច វិហយេ. ។

ប្រែថា "ជនណាជាអ្នកស៊ីសាច់គោ ១ និយាយតែរឿងផ្ទូរលោក ១ ជាអ្នកប្រាសចាកមារយាទគ្រប់យ៉ាង ១ ជនទោះគេតែងហៅថាមិលក្ខជាតិ ។

ពួកជនណាស៊ីសាច់គោ ពួកជនទោះ ទុកដូចជាស៊ីសាច់ម្តាយរបស់ខ្លួន កាលបើគោក្របីស្លាប់ . យើងគួរឲ្យទានដល់ត្មាតទាំងឡាយ ឬយកទៅបន្សាត់ចោលក្នុងទ្បែទឹក" ។

សេចក្តីនេះ ជាបរេណីធមិរបស់ប្រជាជនឥណ្ឌាដែលជាអ្នកកាន់សាសនាដ៏ទក្រិដ្ឋ ។

ដំណើរសេចក្តីអធិប្បាយអត្ថបទ អំពីការឲ្យអភ័យដល់គោក្របី ដូចហេតុផលដែលអាងមកនេះ ដើម្បីឲ្យពុទ្ធបរិស័ទក្នុងប្រទេសកម្ពុជាយើងពិចារណាតទៅ ។ បទបញ្ញត្តិអំពីការពិឃាតគោក្របីនេះ ជាភារៈនៅលើយើងទាំងឡាយជាអ្នកកាន់ព្រះពុទ្ធសាសនា, បើយើងពិចារណាឃើញជាក់ច្បាស់ហើយ ព្រមព្រៀងគ្នាមិនបរិភោគសាច់គោក្របី អ្នកសម្លាប់គោក្របីក៏មិនសូវមាន. យើងទាំងឡាយក៏ឈ្មោះថា ឲ្យអភ័យដល់ជីវិតគោក្របី ។ បើទុកជានៅមានអ្នកសម្លាប់ក៏មានចំនួនតិចដែរប៉ុន្តែដំណើរការពិឃាតគោក្របីនេះ បើជារាជរដ្ឋាភិបាល ពិចារណាឃើញថា ការបិទសមាគមពិឃាតគោមិនខាតផលសេដ្ឋកិច្ចប៉ុន្មានទេអាចចេញច្បាប់បញ្ញត្តជាផ្ទូវការទួទៅ ក្នុងព្រះរាជអាណាចក្រទាងមូលហាមផ្តាច់មិនឲ្យពិឃាតគោក្របី ដូចប្រទេសឥណ្ឌា - ភូមាបានទោះ

ជាការប្រសើរណាស់ ។ ឯសមាគម (កុងស៊ី) ពិយាតគោដែលជ្ជាប់
មានពីមុនមក ក៏ត្រូវបំបាត់ចោលឲ្យអស់កុំឲ្យពិយាតគោជាជាច់ខាត ។
ប៉ើជារាជរដ្ឋាភិបាលអាចបញ្ញត្តជូច្នេះបាន ប្រហែលជាប្រជាជនអ្នកកាន់
ពុទ្ធសាសនា ដោយភាគច្រើន មានសេចក្តីត្រេកអរសាទរជាអនេក
បរិយាយ ។ ឯការបញ្ញត្តិដ៏ប្រៃកក្នុងការឲ្យអភ័យដល់ជីវិតគោក្របីនេះ
ឈ្នោះថាជាឧត្តមគតិដ៏ខ្ពស់បំផុត របស់រាជរដ្ឋាភិបាល ដែលគួរអ្នក
ប្រវត្តិសាស្ត្រចារឹកកត់ត្រាទុក ក្នុងប្រវត្តិនៃប្រទេសកម្ពុជាតទៅ ។

ពណ្ឌិនាអំពីអភយទានពិសេស សូមសន្មតថាចប់តែប៉ុណ្ណោះ ។

ឧក្ការបស់អ្នកក្រីក្រ

មុនបង្អស់ ការកើតមកជាទុក្ខក្រៃលែងទៅហើយ, តពីកើតមកមានតែទុក្ខកើតពីក្រីក្រ ទុគ្គិតគ្រប់កាលទាំងពួង, តមកប្រព្រឹត្តចិញ្ចឹមជីវិតដោយការធ្វើជាខ្ញុំបំរើគេ ក៏ទុក្ខទៀត, ឧហ្ម៉ជីវិតនេះ មានតែទុក្ខត្រួតលើទុក្ខត ។ ត្នាយ៉ាងនេះទេតើ!

បញ្ញាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

អាធិត្តរាជជាតក ទី ១២

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមដំណុំព្រះត្រៃបិដក

ប្រែពីបាលី

សទ្ធាយ ទានំ ទទោតិ ឥទំ សត្ថា ជេតវនេ, វិហរន្តោ ទានបារមឹ អារព្ភ កថេសិ ។

សត្ថា រីអង្គសម្តេចព្រះបរមសពៅជ្ញសាស្តាចារ្យ កាលទ្រង់សម្ថានព្រះវិយោបថនៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវទានបារមី ទ្រង់សំដែងធម៌ទេសនាមានបទព្រះបាលីថា សទ្ធាយ ទានំ ទទោតោ ដូច្នេះជាដើម ។

សេចក្តីដំណាលថា មានកាលសម័យថ្ងៃមួយ កិកុពាំងឡាយអង្គុយប្រជុំគ្នាក្នុងសាលាធម្មសភា ពោលពណ៌នាសរសើរទានបារមីនៃសម្តេចព្រះបរមសាស្តាថា ឧបា្ហ ! អាវុសោពាំងឡាយ, ព្រះសាស្តាមិនឆ្អែតក្នុងការឲ្យទានសោះ ។ កាលនោះ ព្រះសាស្តាទ្រង់ព្រះសវនាការឮសំដីកិកុពាំងនោះដោយទិព្វស្រោត ក៏ទ្រង់ចេញចាកគន្ធកុដីមកកាន់

សៈលាធម្មសភា ទ្រង់គង់លើព្រះពុទ្ធាសនៈដ៏បវរ ហើយសួរភិក្ខុតាំងនោះថា ម្នាលភិក្ខុតាំងឡាយ, ឥឡូវនេះអ្នកតាំងឡាយអង្គុយប្រជុំគ្នានិយាយអំពីរឿងអ្វី? ។ ភិក្ខុតាំងនោះក្រាបបង្គំទូលសព្វសេចក្តី, ព្រះជិន-ស្រីក៏ទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុតាំងឡាយ តថាគតជាបុគ្គលមិនឆ្អែតក្នុងការឲ្យទានក្នុងកាលឥឡូវនេះមិនជាការអស្ចារ្យទេ, បើកាលពីដើម ទើបអស្ចារ្យខ្លាំង;" ទ្រង់ត្រាស់ប៉ុណ្ណោះហើយ ក៏គង់ស្ងៀមព្រងើយកន្ទើយ ដរាបតែភិក្ខុតាំងនោះអារាធនា ទើបសម្តេចព្រះភគវា ទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា

អតីតេ ភិក្ខវេ ជេតុត្ថរនគរេ អាទិត្ថរាជា នាម រជ្ជំ ការេសិ

ម្នាលភិក្ខុតាំងឡាយ កាលកន្ធងរំលងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទអាទិត្ថរាជ សោយរាជសម្បត្តិក្នុងនគរជេតុត្ថរ មានព្រះអគ្គមហេសីព្រះនាមនាងសង្ខទេវី ។ ព្រះរាជាអង្គនោះ ទ្រង់សោយរាជ្យប្រកបដោយធម៌ ទ្រង់ឲ្យជាងកសាងសាលាទាន ៦ ខ្នង គឺនៅក្បែរទ្វារនគរ ៤ ខ្នង នៅទីពាក់កណ្តាលនគរ ១ ខ្នង ទៀបទ្វារព្រះរាជនិវេសន៍ ១ ខ្នង ហើយទ្រង់ចំណាយព្រះរាជទ្រព្យមួយសែនកហាបណៈ ព្រះរាជទានដល់ស្ថុមយាចក អ្នកកំសត់ទុគិតរាល់ ៗ ថ្ងៃ; ទ្រង់ធ្វើនូវអ្នកជម្ពូទ្វីបតាំងអស់ ឲ្យក្សូរនង្គ៉ីលទុកមិនបាច់ក្ជូរាស់, ទ្រង់បង្អុរចុះនូវភ្លៀងគឺទាន ដូចជាមហាមេឃបង្អុរចុះនូវទឹកភ្លៀងក្នុងកាលនៃកត្តិកបុក្ស ទ្រង់រក្សាសីលមិនដែលឲ្យអ្នកណាមួយសម្ទាប់សត្វ សូម្បីតែមួយឡើយ ។ ក្នុងកាលបច្ចូសសមំយថ្ងៃមួយ ព្រះរាជាទ្រង់ព្រះសុបិននិមិត្ត

ឃើញថា មានព្រាហ្មណ៍ចាស់ម្នាក់ មកសូមកោជន; លុះទ្រង់តើន
ចាកក្រឡាបន្ទំឡើង ទ្រង់ជ្រាបថា ថ្ងៃនេះមុខជាមានស្ងូមយាចកមក
ពីព្រឹកមិនខាន, ទើបទ្រង់ព្រះចិន្តនាការគិតថា បើមាននរណាមួយមក
សូមបេះដូង, អាត្មាអញគួរតែទំលាយទ្រូងយកបេះដូងមកឲ្យ; បើសូម
ក្បាល, អាត្មាអញគួរតែកាត់ក្បាលឲ្យ; បើសូមក្នែកក្តី សាច់ក្តី ឈាមក្តី
សរីរ:ពាក់កណ្តាលក្តី, សរីរ:ទាំងមូលក្តី, អាត្មាអញគួរតែឲ្យអវយវ:
ទាំងនោះ មិនត្រូវរា, ពុំនោះសោតទេ, បើនរណាមួយ សូមកវិយាក្តី
ព្រះរាជបុត្រក្តី រាជសម្បត្តិក្តី, អាត្មាអញក៏គួរតែឲ្យ, ឬក៏ស្ងូមយាចក
ណាមួយមកនិយាយថា "បពិត្រព្រះបាទអាទិត្តរាជ, ចូរព្រះអង្គមកជា
ទាស:ខ្ញុំចុះ" ដូច្នេះក្តី. ក៏អាត្មាអញសូលួងលោមអាត្មាអញទៅផ្ទើខ្ញុំ
បំរើអ្នកនោះជាប្រាកដ ។ កាលព្រះបាទអាទិត្តរាជកំពុងទ្រង់ព្រះ
ចិន្តនាការដូច្នេះ ក៏ផែនក្រឡាមហាប្រឹបពី ដែលមានកម្រាស់ ២ សែន ៤
ម៉ឺនយោជន៍ កក្រើករំពើកខ្ទរខ្ទីរញាប់ញ័រយ្ងេងយ្ងោង ដូចជាដំរីចុះប្រេង
ស្រែកកង្ពួចបញ្ចេញសម្ងេងខ្ទរខ្ទារ, ទាំងស្តេចក្នំសិនេរុបពិតរាជ ក៏ពុំ
អាចតាំងនៅនឹងបាន មានអាការទន់ល្ងន់ល្ងាសឡនលំទោនមកកាន់នគរ
ដេតុត្តរដូចជាចុងដំបងទង៌ផ្តៅ ដែលបុគ្គលរោលក្ងើង, ទាំងសមុទ្ទសាគរ
ក៏កើតរលកបោកបែកផ្ការត្រែង. ផ្ទេកបន្ទោរក៏បញ្ចេញសូរ្យសែងផ្ទៀល
ធ្ងាត់ច្រវាត់សព្ងទិសទី, ទាំងស្តេចទេពកោសិយក៏ទះដៃឲ្យសព្ទសាធុការ
ជាមួយនឹងទេវតាទាំងពួង, ទាំងមហាព្រហ្មក៏ផ្ទើសាធុការដែរ, កោលា-

ហលកើតមានរហូតដល់ព្រហ្មលោក ។ ព្រោះហេតុនោះ បាន
ជាព្រះសាស្តាទ្រង់ត្រាស់ថា

យទាហំ ទារកោ ហោមិ ជាតិយា អដ្ឋវស្សិកោ
តទា ឆិសដ្ឋ បាសាទេ ទាឆំ ទាតុំ វិបិឆ្ឌយឹ
ហទយំ បក្ខ ទទេយ្យំ មំសំ បិ រុបិរំ បិ ប
ទទេយ្យំ យទិវា កោបិ យាចេយ្យ អឌ្ឍសរីរំ
ឯវំ មេ បិឆ្ឌយឆ្ឌស្ស អកម្ឃិ មហាបឋវីតិ ។

កាលដែលតថាគតនៅជាកុមារ មានអាយុ ៨ ឆ្នាំតាំងពី
កំណើត តថាគតអង្គុយលើប្រាសាទរំពឹងគិតនឹងឲ្យទានថា
អញគួរតែឲ្យបេះដូង ឲ្យក្នែក ឲ្យសាច់ ឲ្យឈាមទៅជាទាន,
ប្រុបើមាននរណាមួយ សូមសរិរពាក់កណ្តាលក្តី, ក៏អាត្មាអញ
គួរតែឲ្យ; កាលតថាគតកំពុងគិតយ៉ាងនេះ ក៏មហាប្រឹបពី
កក្រើករំពើកញាប់ញ័រឡើង ។

ខណៈនោះឯង ពិភពសក្តទេវរាជ ក៏សំដែងឧណ្ហាការក្តៅកាយ ។
ឡើង ។ ព្រះឥន្ទទ្រង់អាវដ្ឋនាការពិចារណាជ្រាបហេតុនោះហើយ ក៏
ទ្រង់ព្រះបិន្ទនាការគិតថា ' ឆហ្នា ! នាថបុគ្គលជាទីពឹងរបស់សត្វលោកកើត
ឡើងក្នុងលោកហើយតើ, ហានរកមុខជានឹងសូន្យ, ទេវលោកមុខជានឹង
ពេញមិនខាន, ព្រោះព្រះបាទអាទិត្តរាជជាពន្ធកពុទ្ធង្ក្ទុរបណ្ឌូលពោធិសត្វ
កំពុងតែចង់បំពេញព្រះរាជទាន, ឥឡូវនេះ គួរតែអាត្មាអញជួយបំពេញ

ព្រះបារមីព្រះអង្គ, កាលពីដើមអាត្មាអញសូមវត្ថុដទៃ ។, ឥឡូវនេះ
អាត្មាអញសូមភោជនចុះ" លុះទ្រង់រំពឹងគិតដូច្នោះ ក៏មានសេចក្តីត្រេក
អរវិកវាយជាសោមនស្ស ហោះចុះចាកហានស្ងគិមកនិម្មិតខ្លួនជាព្រាហ្មណ៍
ចាស់ មានសរីរៈស្គម សក់ស្ការ កាន់ឈើច្រត់ដើរវញិលវញ៉ា ចូលមក
កាន់ព្រះរាជធានីហើយបង្ហាញខ្លួនដល់ព្រះបាទអាទិត្តរាជ ឲ្យទ្រង់ទត
ឃើញនោក្នុងទីព្រះរាជលាន បានពោលនូវជយសព្ទ ៣ ជង៌ថា ជយតុ ភវំ
ជយតុ ភវំ មហារាជ ! បពិត្រព្រះរាជសម្ភារ, សូមព្រះករុណាទ្រង់មាន
ជយជំនះ ! សូមព្រះករុណាទ្រង់មានជ័យជំនះ ! ។ ត្រានោះ ព្រះរាជា
ទ្រង់មានព្រះរាជឧង្ការត្រាស់ស្ងរថា ម្នាលព្រាហ្មណ៍ អ្នកមកដើម្បីអ្វី ? ។
ព្រាហ្មណ៍ក៏ក្រាបបង្គំទូលព្រះចក្រីថា បពិត្រព្រះរាជសម្ភារ, ទូលព្រះ
បង្គំជាខ្ញុំចាស់ជរាគ្រំត្រាជាទុព្វលភាព ទ័លក្រជុនជាប ឥតមានវត្ថុអ្វី
ត្រាន់ទទួលព្រះរាជទាន ឲ្យមានជីវិតតទៅទៀតសោះ, មិនតែប៉ុណ្ណោះ
ថែមទាំងមានរោគឈឺពោះ ចុះរុះចុកសៀតព្យាធិបៀតបៀនជាច្រើនប្រការ
ទៀតផង, ទូលព្រះបង្គំជាខ្ញុំមកដោយបំណងចង់សូមភោជន ត្រាន់ជា
ស្បៀងលៀងជីវិត សូមព្រះបពិត្រទ្រង់ព្រះរាជទាន ដល់ទូលព្រះបង្គំ
ជាខ្ញុំក្រោមល្អងធូលីព្រះបាទ ។ ព្រះរាជាទ្រង់ព្រះសវនាការហើយ
ទ្រង់មានសេចក្តីសោមនស្ស ដូចជាបុរសកំសត់ពីកំណើត បាននូវធ្នាំង
កំណប់, ទើបព្រះចមភពទ្រង់ក្រោកឡើងម្ទីម្ទា ព្រះហត្ថាកាន់ភោជន
ដោយភាជនមាស ត្រាស់ថា "ម្នាលព្រាហ្មណ៍ដ៏ចំរើន, ឃើងឲ្យទាន
ដល់អ្នកនេះ មិនមែនប្រាថ្នាសម្បត្តិស្តេចចក្រពត្តិ មិនប្រាថ្នាសម្បត្តិ

ព្រះឥន្ទ្រ សម្បត្តិព្រះព្រហ្ម សម្បត្តិព្រះបច្ចេកពុទ្ធឡើយ, ទាននេះ
សូមឲ្យបានជាបច្ច័យនៃការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ" ហើយទ្រង់
ទូលនូវកោជនដូចជាទិព្វលើព្រះសីរៈរបស់ព្រះអង្គ ទើបទ្រង់ព្រះរាជទាន
ដល់ព្រាហ្មណ៍ ។ គ្រានោះ ព្រាហ្មណ៍ក៏ត្រេកអរកោជនចោល ហើយ
ពោលពាក្យទ្រគោះថា "យើអើ ព្រះបាទអាទិត្តរាជម្តេចក៏ឲ្យកោជនសៅ
ហ្មងដល់យើងយ៉ាងនេះ!" ហើយក៏ធ្វើដូចជាខឹងណាស់ បោកបាស់
ប្រទេចផ្តាសា ចៀសចេញទៅ ។ ព្រះមហាក្សត្រទុកជាឮសំដីដូច្នោះ
ក៏ទ្រង់ឥតមានព្រះពិរោធត្រេកអរក្រោធដល់បន្តិចសោះ មានព្រះកត្តិស្រស់
បស់ញញឹមប្រឹមប្រិយ ដូចសុវណ្ណបទុមកំពុងរីកស្គុះស្គាយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលព្រះសាស្តាទ្រង់ប្រកាស
សេចក្តីនោះ ទ្រង់ត្រាស់ជាបទព្រះគាថា ដូច្នេះថា

សទ្ធាយ ទានំ ទទតោ ភោជនំ ទិព្វសម្បត្តិំ
ព្រាហ្មណស្ស អទា ទានំ ពោធិយាយេវ ការណា
ទទាមិ ភោជនំ ទានំ ព្រាហ្មណោ កោធមានសោ
បហាយ ភោជនញ្ចេវ រាជា អកោធមានសោ
រាជា បសន្នចិត្តោវ សម្ពោធិកាមកោ ភវេ
ព្រាហ្មណស្ស អទា ទានំ សម្ពោធិ បាបុណិស្សតិ ។

កាលដែលតថាគតឲ្យទានដោយសទ្ធា តថាគតបានឲ្យកោជន
ដូចជាទិព្វ ជាទានដល់ព្រាហ្មណ៍ ព្រោះហេតុតែចង់បាននូវ

ពោធិញ្ញាណ, ព្រាហ្មណ៍ក៏ត្រឡប់ជាមានចិត្តខឹងក្រោធ លះ
បង់ចោលនូវកោជននោះទៅវិញ, តថាគតជាស្តេចឥតមាន
សេចក្តីក្រោធ មានចិត្តជ្រះថ្លាហើយ ជាអ្នកប្រាថ្នានូវ
ពោធិញ្ញាណ ចានឲ្យទានដល់ព្រាហ្មណ៍ ទើបដល់នូវ
សម្មាសម្ពោធិញ្ញាណពិតមែន ។

ត្រានោះ ព្រះមហាក្សត្រទ្រង់រំពឹងគិតដោយកម្ចាំងព្រះបីតិសោ-
មនស្សថា "ឧហ្នុ ផ្ទើម្ពេចអេះនឹងមានស្ងួមយាចកមកដល់ទៀត!"
ហើយទ្រង់គង់ចាំមើលផ្ទូវ ដោយព្រះរាជហ្ឫទ័យចង់ព្រះរាជទានណាស់
ដូចជាអ្នកប្រមឹកស្រាកំពុងស្រេកខ្ទាំងដូច្នោះ ។ ខណៈនោះ សក្កទេវរាជ
ក៏លះបង់គេទព្រាហ្មណ៍ចាស់ ប្រែក្រឡះជាព្រាហ្មណ៍កំឡោះវិញ,
ព្រាហ្មណ៍នោះមិញមានរូបល្អ មានសម្ឡរស្រស់ ត្រឡប់ចូលមកជិត
ព្រះរាជា ផ្ទើអាការរាក់ទាក់ ក្រាបបង្គំទូលស្តូវព្រះរាជាថា

កច្ចិ នុ ភោតោ កុសលំ កច្ចិ នុ ភោតោ អនាមយំ
កច្ចិ ជិតោ ជនបទោ កច្ចិ វុដ្ឋិ ន ធិជ្ជតិ

បពិត្រព្រះរាជសម្ការ ដ៏ទ្រង់នូវព្រះចេស្តា, ព្រះករុណា
ទ្រង់ប្រកបដោយព្រះបរមសុខស្ថួលក្នុងព្រះអង្គទេឬ? ព្រះ
ករុណាពុំមានរោគអាពាធព្យាធិអ្ទី មកប្រៀតប្រៀនព្រះអង្គ-
កាយទេឬ? ព្រះករុណាទ្រង់ចាត់ការរៀបចំជនបទវៀតត្រ
ដែន ចានសេចក្តីស្ងប់ស្ថួលទេឬ? ក្ទៀងរលឹមធ្លាក់មក

ពុំដាច់ ល្មមសម្រេចផលក្សេត្រកម្មនៃអ្នកជនបទបានទេប្ត ។
ព្រះរាជាទ្រង់ត្រាស់ថា

កុសលញ្ចេវ មេ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ
អថោ ជិតោ ជនបទោ អថោ វុដ្ឋិ ន ធិជ្ជតិ

"ម្នាលព្រាហ្មណ៍, យើងមានសេចក្តីសុខស្ស្រួលក្នុងកាយទេ, ពុំមានរោគអាពាធព្យាធិអ្វីបៀតបៀនទេ, ទាំងជនបទ ក៏យើងបាត់ការរៀបចំបានសេចក្តីស្ងប់ស្ស្រួលដែរ, ម្យ៉ាងទៀតក្នៀងរលឹមជ្ងាក់មកពុំដាច់ ល្មមសម្រេចផលក្សេត្រកម្មនៃអ្នកជនបទបាន" ហើយទ្រង់ត្រាស់តទៅទៀតថា

ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ
អន្តោ បវិស ភទន្តេ បាទេ បក្ខាលយស្សុ តេ

ម្នាលមហាព្រាហ្មណ៍, អ្នកអញ្ជើញមកប្រៃពៃហើយ! ម្យ៉ាងទៀត អ្នកទើបនឹងមកដល់ថ្មីៗ អម្ហាញ់មិញនេះ បើដូច្នេះចូរអ្នកដ៏ចំរើន ចូលមកយកទឹកលាងជើងឲ្យស្ស្រួលបួលសិនចុះ ។

លុះព្រះមហាសត្វទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ព្រះចិន្តនាការតិតថា "ព្រាហ្មណ៍នេះមិនមែនជាមកដោយតតការណ៍ទេ, គួរតែអាត្មាអញស្ងរឲ្យដឹងដើមទង" ទើបទ្រង់ត្រាស់ព្រះរាជឧត្ការស្ងរថា

អ្នកឯងមានការណ៍ដូចម្តេច មានហេតុយ៉ាងណា បានជាមក

ដល់ដែនយើង? យើងសួរអ្នក ត្រូវតែអ្នកប្រាប់យើងតាមត្រង់កុំខាន ។

ព្រាហ្មណ៍បានស្តាប់ព្រះតុង្ការនោះ ហើយក្រាបបង្គំទូលតបថា បពិត្រព្រះរាជសម្ភារ ខ្ញុំព្រះអង្គមកដើម្បីសូមព្រះនាងសង្ខទេវីជាព្រះរាជទេពីរបស់ព្រះអង្គ; សូមព្រះអង្គព្រះរាជទាន ព្រះនាងដល់ទូលព្រះបង្គំជាខ្ញុំកុំខាន ហើយក្រាបបង្គំទូលដូច្នេះទៀតថា

ធម្មតាពែកស្ទឹងចិនទន្លេមេខកវារី ជាទីពេញប្រៀបដោយទឹកថ្លា អស់ពួកមហាជនមនុស្សម្នា ព្រមទាំងសត្វទ្វេជាទេចតុប្បាទ តែងស្វាតចូលមកទទួលព្រះរាជទាន ប៉ុន្តែជម្រះច្រាណកំសាន្តបំបាត់សេចក្តីស្រេកឃ្លានគ្រប់ៗគ្នា ក៏ដល់ធារពុំដែលស្រេកស្រុតរីងសូតឡើយ ដូចម្តេចមិញ; ឯព្រះរាជហឫទ័យរបស់ព្រះអង្គ ក៏ពេញដោយសេចក្តីមេត្តាអាសូរករុណាដូច្នោះ; ទូលព្រះបង្គំជាខ្ញុំមកសូមហើយ, សូមទ្រង់ព្រះរាជទានព្រះអគ្គមហេសី ដល់ទូលព្រះបង្គំជាខ្ញុំកុំខាន ។

ព្រះមហាសត្វទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ មានព្រះសោមនស្សរីករាយឥតក្រៃពេកពន់ពាក្យព្រាហ្មណ៍នោះឡើយ ហើយមានព្រះរាជហឫទ័យមិនរួញរាក្នុងការបរិច្ចាគទាន ទ្រង់បន្ទូលព្រះវាចាត្រាស់ដូច្នេះថា

ម្នាលព្រាហ្មណ៍ អ្នកឯងសូមរបស់អ្វីនឹងយើង យើងឲ្យរបស់

នោះ, យើងមិនធុញគ្រាន់ទេ, យើងមិនឈឺរបស់ដែលមានទេ, ព្រោះចិត្តយើងតែងរីករាយចំពោះការឲ្យជូនច្នោះស្រាប់ ។

ទ្រង់ត្រាស់ដូច្នេះហើយទ្រង់ងាកទតព្រះរាជទេពីត្រាស់ថា ម្នៃបួនពុំងា, បងចង់បានសម្ងាសម្ពោធិញ្ញាណណាស់ ។ ព្រះរាជទេពីទ្រង់ព្រះសវនាការស្តាប់ព្រះរាជឧង្ការនោះហើយ ទ្រង់មិនមានសេចក្តីភ័យកិតត្រាស់ព្រះរាជសារីយថា បពិត្រព្រះរាជសម្ភារ, ខ្ញុំម្ចាស់ជាទាសីរបស់ព្រះអង្គស្រាប់, ព្រះអង្គជាព្រះរាជស្វាមីជាធំលើខ្ញុំម្ចាស់ហើយ, បើព្រះអង្គសព្វព្រះរាជហឫទ័យចង់ព្រះរាជទានរបស់អ្វី សូមទ្រង់ព្រះរាជទានកុំខើសទាល់, ខ្ញុំម្ចាស់ឥតភ័យឆ្ងាម្តងឡើយ, បពិត្រព្រះសម្មតិទេព, សូមព្រះអង្គអនុគ្រោះ សូមទ្រង់អត់ទោសកំហុសដល់ខ្ញុំម្ចាស់, ខ្ញុំម្ចាស់សូមថ្វាយបង្គំចំពោះព្រះបាទ, ការថ្វាយបង្គំរបស់ខ្ញុំម្ចាស់នេះ ជាទីបំផុតហើយ ។ ព្រះមហាសត្វក៏ទ្រង់កាន់យកទឹកកុណ្ឌីជ្រួចប្រទានទាងទៅដល់ព្រាហ្មណ៍មួយរំពេចថា "ម្នាលព្រាហ្មណ៍, នាងសង្ឃទៅជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើង, ប៉ុន្តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់ពេញចិត្តជាងនាងសង្ឃទៅ ១ រយគុណ ១ ពាន់គុណទៅទៀត" ត្រាស់ដូច្នេះហើយ ក៏ប្រទានទាងទៅព្រាហ្មណ៍នោះ ។ ខណៈនោះ ផែនប្រឹថពីកក្រើករំពើកញាប់ញ័រ ទាំងមហាសមុទ្រក៏កើតព្យុះលេកចោកបែកផ្លាត្រែង, ទាំងស្តេចកុំសិនេរុ ក៏នុនលំទោនមក, ទៅតានឹងមហាព្រហ្មទាំងឡាយ ឲ្យសំពូសាធុការទ្រហឹងអឺងកង កើតជាកោលាហលដកបដល់ព្រហ្មលោក ។

គេន រុត្តំ ព្រោះហេតុនោះបានជា សម្តេចព្រះបរមពិជិតមារ ទ្រង់ត្រាស់សំដែងថា

កាលដែលតថាគតកើតជាព្រះបាទអាទិត្តរាជនោះ បានចាប់ ដៃនាងទេវី កាន់គុណ្ឌីទឹកផ្ទួចឲ្យទៅជាទានជល់ព្រាហ្មណ៍ ព្រោះបង់បានត្រាស់ពោធិញ្ញាណ, កាលតថាគតលះបង់ នាងទេវីត្រានោះ ក៏កើតសេចក្តីអស្ចារ្យគួរខ្ទាច គួរព្រឺរោម ព្រឺស្បែក ទាំងផែនដីក៏កក្រើករំពើកញាប់ញ័រ ។

ត្រានោះ ព្រះតន្ទ្ធិចាប់សក់នាងទេវីកើចកន្ត្រាក់នាំបេញទៅ ។ ព្រះនាងទេវីក៏ទ្រង់ព្រះកន្សែង សោកវិយោគខ្សឹកខ្សួលអួលអន់ក្នុងព្រះ ឧរា ។ មហាសត្តោ តំ ទិស្វា ព្រះមហាសត្វទ្រង់ទតឃើញដូច្នោះ ទ្រង់មានព្រះរាជឧង្ការលួងលោមថា ហៃប្អូនមាសពុំងា, សូមប្អូនស្ងួនត្ងា នាងកុំខ្សឹកខ្សួលឡើយ, បងសូមសម្មាសម្ពោធិញ្ញាណនឹងនាងឯងហើយ សូមប្អូនអាណិតបងចុះ ។ ព្រះនាងទេវីទ្រង់ព្រះសណ្ឌាប់ព្រះរាជឧង្ការ ហើយមានព្រះរាជសវនីយថា បពិត្រមហារាជបរមកស្តា, ខ្ញុំម្ចាស់សូម ថ្វាយសព្វញ្ញុតញ្ញាណចំពោះព្រះអង្ត, សូមទ្រង់កុំព្រួយព្រះរាជហ្ឫទ័យ ឡើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្តេចព្រះបរមសាស្តាចារ្យ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា

នាកាលព្រះបរមពោធិសត្ថ ទ្រង់ព្រះរាជទានព្រះទេពីសេច ព្រាហ្មណ៍កំណាចមានចិត្តក្រៃវក្រោធ គើចអូសយកទៅ

ឯព្រះរាជាព្រះអង្គមានព្រះរាជហ្ឫទ័យមិនក្រេវក្រោធ ប្រកប
ដោយសេចក្តីទ្រៀងទាត់ ព្រោះព្រះទ័យប្រាថ្នាតែព្រះ
សម្ពោធិញ្ញាណ ។

ត្រានោះ ព្រះឥន្ទ្ធបានជ្រាបអធ្យាស្រ័យនៃក្សត្រទាំងពីរព្រះអង្គ
ក៏ទ្រង់ពោលសរសើរសព្វត្រប់ប្រការដល់ព្រះអង្គ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្ពេចព្រះបរមសាស្តាចារ្យ
កាលទ្រង់ប្រកាសនូវសេចក្តីនោះ ទ្រង់ត្រាស់ថា

សម្ពេចព្រះសក្កទេវិន្ទ ទ្រង់ជ្រាបនូវតំរិះនៃក្សត្រទាំង ២
ព្រះអង្គនោះហើយ ទ្រង់ពោលសរសើរថា សត្រូវទាំងឡាយ
ទាំងពួង ទោះបីជាទិព្វក្តី ជាមនុស្សក្តី, ក៏ព្រះអង្គមាន
ជ័យជំនះឈ្នះសព្វត្រប់ប្រការ ទាំងមហាប្រឹថពីព្រះអង្គ
បានធ្វើឲ្យញាប់ញ័រ កិត្តិស័ព្ទសេចក្តីសរសើរចំពោះព្រះអង្គ
ផ្សព្វផ្សាយទៅរហូតដល់ឋានតាវត្តឹង្ស ទាំងផ្ទេកបន្ទោរក៏ដួច
ដាលធ្វៀលច្រវាត់ ទៅជុំវិញសព្វទិសប្រាកដដល់ក្នុំទាំង
ឡាយ, ក្នុំនារទបពិតទាំងពីរ ក៏អនុមោទនាចំពោះព្រះអង្គ,
ពួកទេវតាទាំងអស់ ទោះទាំងព្រះឥន្ទទាំងព្រះព្រហ្មទាំងស្តេច
បជាបតិ ទាំងព្រះចន្ទ្ធ ទាំងព្រះយម ទាំងស្តេចវេស្ស-
រណក្តី តែងអនុមោទនាសរសើរថា ព្រះបាទអាទិត្តរាជ
អង្គនោះ ទ្រង់ធ្វើនូវអំពើដែលអ្នកផងធ្វើបានដោយកម្រ,
សប្ឋុរសឲ្យទានដែលគេឲ្យផងបានដោយកម្រ, ធ្វើនូវអំពើល្អ

ដែលគេក្រែងធ្វើផងកើត, អសប្បុរសទាំងឡាយ ធ្វើតាមផង
ពុំបានទេ, ធម៌របស់សប្បុរស ពួកអសប្បុរសប្រព្រឹត្ត
បានដោយកម្រ, ព្រោះហេតុនោះ បានជាដំណើរចេញអំពី
លោកនេះទៅកាន់លោកខាងមុខ នៃសប្បុរសនឹងអសប្បុរស
ទាំងឡាយជាគតិផ្សេងគ្នា គឺពួកអសប្បុរសតែងទៅកាន់នរក
ពួកសប្បុរសតែងទៅកាន់ឋានសួគ៌ ។

គ្រានោះ មហាសត្វទ្រង់មានព្រះរាជហប្ញទ័យពេញដោយបីតិ
ដោយព្រះតម្រិះយល់ថា ទានដែលអាត្មាអញឲ្យនេះជាទានប្រពៃពេក
ណាស់ ។ លំដាប់តពីនោះមក ព្រះឥន្ទ្រាបបង្គំទូលថា បពិត្រ
មហារាជ, ទ្រង់ទាំងពីរព្រះអង្គមានព្រះទ័យដូចគ្នាតែមួយបែប, តទៅ
ក្នុងកាលជាខាងក្រោយ ទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធពុំខាន; បពិត្រ
ព្រះសម្មតិទេព, ខ្ញុំជាសក្កទេវរាជ មកដោយសេចក្តីសុចរិតចំពោះ
ព្រះអង្គ ។ ព្រះឥន្ទ្រាធិរាជពោលដូច្នេះហើយ ក៏សូមឲ្យព្រះរាជា
ទ្រង់ព្រះរាជទានអភ័យទោស ទើបថ្វាយព្រះនាងសង្ខទេវីចំពោះព្រះ
រាជាវិញថា

ខ្ញុំព្រះអង្គសូមថ្វាយព្រះនាងទេវី ដ៏ល្អល្អះសព្វគ្រប់ចំពោះ
ព្រះអង្គវិញ, សូមព្រះអង្គតាំងព្រះរាជហប្ញទ័យស្រឡាញ់ព្រះ
នាងទេវី តាំងព្រះនាងទេវីក៏សូមតាំងព្រះរាជហប្ញទ័យស្រ-
ឡាញ់ព្រះចក្រីកុំបីមានអាក់ ។ ធម្មតាទឹកដោះនឹងសង្ខ វត្ថុ
ទាំងពីរមុខនេះ មានពណ៌ស្មើគ្នាយ៉ាងណា, ក៏សូមឲ្យព្រះ

ករុណាទឹងព្រះទាន់ទេវី មានព្រះពរជ្ឈាស័យស្តីគាយ៉ាងនោះ
ចុះ, ខ្ញុំព្រះអង្គជាសក្កទេវរាជ្ញ មកកន់សំណាក់ព្រះអង្គ សូម
ផ្តាំអញ្ជើចំពោះព្រះអង្គ, បពិត្រព្រះអង្គជាស្តេចប្រសើរ
ខ្ញុំព្រះអង្គសូមថ្វាយបង្គំ, បពិត្រព្រះអង្គមានព្យាយាមធំ, ល្អ
ហើយ! ប្រពៃហើយ! ព្រះអង្គពិតជាទឹងបានត្រាស់ជា
សម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ក្នុងកាលជាអនាគតពុំ
ខាន ។

ព្រះឥន្ទ្រាធិរាជពោលដូច្នេះហើយ ទ្រង់ពោលទូន្មានតទៅទៀតថា
បពិត្រមហារាជ, សូមព្រះអង្គប្រតិបត្តិធម៌គោរពចំពោះព្រះ
វេរាជមាតាបិតា; បពិត្រព្រះរាជា, ព្រះអង្គប្រតិបត្តិធម៌ក្នុង
លោកនេះហើយ ទឹងបានទៅកាន់ស្ថានសួគ៌; បពិត្រព្រះ
មហារាជ, សូមព្រះអង្គប្រតិបត្តិធម៌ គឺសេចក្តីមេត្តាប្រោស
ប្រណីចំពោះពួកសត្វពាហនៈ ទឹងពួកពលគ្រប់គ្នា; បពិត្រ
ព្រះរាជា, ព្រះអង្គប្រតិបត្តិធម៌ក្នុងលោកនេះហើយទឹងបាន
ទៅកាន់ឋានសួគ៌, បពិត្រមហារាជ, សូមព្រះអង្គប្រតិបត្តិ
ធម៌ ចំពោះម្រឹគបក្សីសត្វសត្វ, បពិត្រព្រះរាជា ព្រះ
អង្គប្រតិបត្តិធម៌ក្នុងលោកនេះហើយ ទ្រង់ទឹងបានទៅកាន់
ឋានសួគ៌, បពិត្រមហារាជ សូមព្រះអង្គប្រតិបត្តិធម៌ព្រោះ
ថា ធម៌ដែលព្រះអង្គសន្សំហើយ រមែងនាំមកនូវសេចក្តី
សុខ; បពិត្រព្រះរាជា ព្រះអង្គប្រតិបត្តិធម៌ក្នុងលោក

នេះហើយ ខ្ញុំនឹងបានទៅកាន់ឋានសួគ៌, បពិត្រព្រះមហាភជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះព្រះឥន្ទនឹងទេវតានឹងព្រហ្មទាំងឡាយ. ជនទាំងឡាយដល់នូវឋានដ៏ត្រឹមត្រូវដោយការសន្សំធម៌, ព្រោះហេតុនោះ សូមព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ ។

ព្រះឥន្ទ្រាធិរាជ ទ្រង់ប្រៀនប្រដៅទេសតាធិរាជធម៌យ៉ាងនេះហើយ ទ្រង់ទូន្មានតទៅទៀតថា "បពិត្រមហាភជ, សូមព្រះអង្គកុំប្រហែសធ្វេស, សូមទ្រង់ឲ្យទាន, សូមទ្រង់រក្សាសីលកុំបោះបង់ឡើយ" ពោលទូន្មានដូច្នេះហើយ ក៏ត្រឡប់ទៅកាន់ទីលំនៅរបស់ព្រះអង្គវិញហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្ដេចបរមសាស្ដាចារ្យ ទ្រង់ប្រកាសនូវសេចក្ដីនោះទ្រង់ត្រាស់ថា

សម្ដេចព្រះមឃវាទេវរាជ ជាព្រះស្វាមីនៃនាងសុជាតា លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ពោលសរសើរព្រះបរមពោធិសត្វរួចស្រេចស្ដេចហោះទៅកាន់ឋានទេវលោកវិញហោង ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់នាំធម៌ទេសនានេះមកហើយ ទ្រង់ត្រាស់ព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ តថាគតបានឲ្យទានក្នុងកាលដែលនៅជាពោធិសត្វយ៉ាងនេះឯង" ហើយទ្រង់សំដែងប្រកាសសច្ចធម៌, លុះចប់សច្ចធម៌ ទ្រង់ប្រជុំជាតកថា

ព្រះវរោជមាតានៃព្រះបាទអាទិត្តរាជ ទ្រង់ចេរិលវិមានមក ប្រាន់មកកើតជាព្រះនាងមហាមាយា, ព្រះវរោជបិតា ប្រាន់ជាព្រះបាទសុទ្ធោទន, ព្រះឥន្ទ្រ ប្រាន់ជាព្រះអនុរុទ្ធ, នាងសង្ឃទេវីប្រាន់ជានាងយសោធរា, បរិសទ្យក្រៅពីនោះប្រាន់ជាពុទ្ធបរិសទ្យទាំងអស់. ឯព្រះបាទអាទិត្តរាជគឺជាតួអគ្គតថាគតជាលោកនាថហ្នឹងឯង; អ្នកទាំងឡាយចូរទ្រទ្រង់ចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ អាទិត្តរាជជាតកទី ១៤ តែប៉ុណ្ណោះ ។

ខ្ញុំសេចក្តីសំគាល

ឱការៈ! ប្រាន់ឮរឿង ។ មកថា បុគ្គលឈ្មោះថាស្លាប់មាន ៥ ប្រការ សូម្បីរស់នៅក៏ឈ្មោះថាស្លាប់ដែរ គឺបុគ្គលក្រីក្រ ១ បុគ្គលឈឺច្រើន ១ បុគ្គលល្ងង់ ១ បុគ្គលដែលគេនិរទេស ១ បុគ្គលដែលធ្វើជាខ្ញុំបំរើគេ ១ ។

ដោយភក្តី ខ្ញុំបំរើគេមិនហ៊ានស៊ីតាមចិត្តឯងទេ នៅតែចាំបែរក្សាឥតប្រាន់ដើកតូន មិនដែលនិយាយពាក្យណាម្តងដែលឥតខ្លាចក្រែងសោះ បើតែយ៉ាងនេះតើខ្ញុំបំរើគេនៅតែរស់ប្រាន់ទៀតហ្ន៎?

សេរីធម៌ (ធម៌ជាខ្ញុំបំរើគេ) លោកពោលទុកថាជាការប្រព្រឹត្តនៃឆ្កែ នេះបើយើងនិយាយដោយមិច្ឆាទិដ្ឋិ, តែក្នុងករណីនេះ សត្វឆ្កែតែងប្រព្រឹត្តធ្វើតាមជន្មនៃខ្លួន, ឯអ្នកបំរើគេ ធ្វើតាមបង្គាប់នៃដនដែរជាម្ចាស់ ។

ផ្នែកអក្សរសាស្ត្រ

រឿងសាមកុក

កណ្ឌទី ២០

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ឡៅពីនិយាយនឹងឡៅតាយ, អងតុងថា កាលដែលយើងលើកទ័ពមកនោះ នឹងបានតិតប្រទូសរ៉ាយដល់មហាឧបរាជក៏ទេ ប្រយោជន៍ធ្វើការតបស្នងសងគុណមហាឧបរាជតែត្រប់រវលាមិនជាច់ ក្រោយនោះ គីម៉ៅចិត្តអាក្រក់តិតប្រទូសរ៉ាយដល់យើងឲ្យអស់ជីវិត បានជាយើងសម្ចាប់ជីវិតគីម៉ៅវិញ មហាឧបរាជមិនដឹងថា គីម៉ៅប្រទូសរ៉ាយនឹងយើងមុន បានជាឲ្យអ្នកឯងទាំង ២ នេះលើកកងទ័ពមកចាប់យើង ធម្មតាកើតមកជាមនុស្សក្តី សត្វក្តី រមែងស្រឡាញ់ជីវិតជូចគ្នាទាំងអស់ បើមានគេមកបៀតបៀនរវលាណា តែងតែការពារអន្តរាយដោយសេចក្តីស្រឡាញ់ខ្ជួនដែលគ្ជនអ៊ូ, គៀវហ៊ុយ បានធ្វើទុក្ខដល់អ្នកទាំង ២ នោះកុំបីមាន

អាយាតញ្ញាបាទតទៅឡើយ ឥឡូវយើងអនុគ្រោះដោះឲ្យអ្នកទាំង ២ រួច
អាយុជីវិត ឲ្យអ្នកនិះគិតវិលត្រឡប់ទៅវិញចុះ ដើម្បីនឹងឲ្យដំណឹងដល់
មហាឧបាជដ្រាបសេចក្តី ហើយអ្នកត្រូវដួយនិយាយឲ្យឃើញសេចក្តី
ពិតសុចរិតរបស់យើង ។ ក៏សុំចងមេត្រីដល់អ្នកទាំង ២ តទៅ ។

ឡៅតាយនឹងអងតុងបានស្តាប់ឡៅពីអធិប្បាយដូច្នោះ ក៏មានសេចក្តី
គ្រេកអរណាស់ធ្វើយតបថា ដែលលោកប្រោសករុណាទុកអាយុជីវិតខ្ញុំ
បាទ ព្រះតេជ:ព្រះគុណធ្ងន់នឹងរកអ្វីប្រៀបផ្ទឹមពុំស្មើដល់ ខ្ញុំបាទនឹងវិល
ត្រឡប់ទៅប្តឹងផ្តល់ពីឧកជការដល់មហាឧបាជថា លោកមានចិត្តសត្យ
ទៀងត្រង់ មិនបានគិតប្រទូសព៉យដល់មហាឧបាជឡើយ ដែលបាន
ជាធ្វើការហួសទៅហើយទាំងម្ចុ៉ះ ពីព្រោះសេចក្តីទាល់លើទាល់ បើ
មហាឧបាជមិនជឿខ្ញុំបាទនឹងយកបុត្រកវិយាទុកជាចំណាំ បើអំណើះត
ទៅមុខ លោកប្រែចិត្តគិតប្រទូសព៉យប្រការម្តេច សុំឲ្យសម្ងាប់បុត្រ
កវិយា ខ្ញុំបាទទាំងអស់ចុះ ។ ឡៅពីបានស្តាប់ដូច្នោះក៏អស់សង្ស័យ
គំនាប់ឡៅតាយនឹងអងតុងតាមគួរសមហើយថា "ដែលអ្នកទទួលធុរ:
យើងដូច្នេះ យើងអរគុណណាស់" ហើយឡៅពីក៏ប្រមូលទាហានដែល
ត្រៀវហ៊ុយបានមកនោះ បង្ខិលឲ្យឡៅតាយ, អងតុងវិញ ។ ឡៅតាយ
អងតុងក៏គំនាប់លាឡៅពី នាំទាហានទាំងពួងចេញពីស្រុកឈើជីវ ចេញ
ទៅប្រហែលចម្ងាយ ៥០០ សិន (២០ ត.ម.) ។

ខណ:កាលឡៅពីនិយាយលើកទោសឡៅតាយនឹងអងតុងនោះ,
ត្រៀវហ៊ុយក៏ក្តៅក្តួលធួលក្នុងចិត្ត គិតលើកទាហានលបចេញទៅស្ទាក់

កណ្តាលផ្លូវ ។ គួនអ៊ូឃើញតៀវហ៊ុយលើកតាហានទៅកំសត់រួយ ទើបឡើងសេះនាំតាហាន ៤ ៥ នាក់ តាមស្នាមដើងតៀវហ៊ុយទៅ ។ ឯតៀវហ៊ុយកាលត្រឡែកឃើញឡៅតាយ អង្គតុងលើកតាហានមក, តៀវហ៊ុយក៏កំពួនទៅឈរស្ងាក់ពីមុខ ហើយស្រែកគំហកដោយសំឡេងខ្លាំងថា ឯងនិយាយកូតកុហក់បញ្ឆោតបងអញដូចម្តេចខ្លះ? បានជាបងអញលែងឯងតាំង ២ នាក់មក? ។ ឡៅតាយ, អង្គតុងបានឮតៀវហ៊ុយស្រែកគំហកដូច្នោះ ក៏ភ័យស្លុតចិត្តញ័រពន្តត់អស់តាំងខ្លួន មិនបានតបថាប្រការម្តេចសោះ ខលួលគួនអ៊ូតាមទៅទាន់ឃើញតៀវហ៊ុយទៅស្ងាក់ពីមុខដូច្នោះ ក៏ស្រែកថា តៀវហ៊ុយកុំអាលធ្វើវីវរ បងយើងលែងគេឲ្យទៅហើយ ។ តៀវហ៊ុយឆ្លើយថា បើលែងអា ២ នាក់នេះទៅហើយ គង់តែវានឹងត្រឡប់មកធ្វើអន្តរាយដល់យើងវិញជាប្រាកដ ។ គួនអ៊ូតបថា បើគេមិនដឹងគុណយើងនឹងត្រឡប់មកប្រទូសរ៉ាយយើងវិញ សឹមយើងចាប់សម្លាប់ចេញ គ្មានសេចក្តីនិន្ទាទេ ។

ឡៅតាយ, អង្គតុងបានស្តាប់ដូច្នោះក៏ឆ្លើយថា ពេលនេះឡៅតីមានគុណដល់យើងជាទម្ងន់ណាស់ ប្រសិនបើមហាឧបរាជប្រើយើងឲ្យលើកទ័ពមកទៀត យើងក៏មិនមកជាដាច់ខាត សូម្បីមហាឧបរាជនឹងសម្លាប់បុត្រភរិយាយើងតាំងអស់ក៏តាមចិត្តចុះ សូមអ្នកតាំង ២ បើកលែងយើងទៅតាមស្រួលកុំបីបៀតបៀនយើងឡើយ ។ តៀវហ៊ុយថា ក្បាលឯងតាំង ២ នាក់នេះ អញលើកទុកឲ្យនៅជាប់នឹងខ្លួនហើយ បើប្រសិនឯងទៅញុះញង់ចូរួប្រការម្តេច ចូរួនឹងលើកទ័ពមក អញនឹងកាប់ឯង

ព្រមទាំងទាហានឯងមិនឲ្យសល់ម្នាក់ ។ ឡៅតាយនឹងអងតុងបានស្តាប់ទាំងខ្ចាចទាំងមានចិត្តត្រេកអរ ក៏បង្ខំបរសេះនាំទាហានស្រូតរូតទៅ ។

ឆ្លងអ៊ូ, ត្រៀវហ៊ុយក៏វិលត្រឡប់ទៅក្រុងឈីជីវវិញ ហើយជំរាបឡៅពីថា ដែលលោកបើកលែងឡៅតាយនឹងអងតុងទៅនោះ ខ្ញុំបាទយល់ឃើញថា ចូធូនឹងលើកកងទ័ពមកផ្ទើអន្តរាយលោកវិញពុំខាន ។ ស៊ុនខៀនបានព្ទឆ្លងអ៊ូ, ត្រៀវហ៊ុយថាដូច្នោះ ក៏និយាយនឹងឡៅពីថា ដែលប្អូនលោកថានេះក៏ត្រូវមែនហើយ បើចូធូលើកទ័ពមក លោកនឹងតាំងទ័ពនៅតែក្នុងស្រុកឈីជីវនេះ ឆង់នឹងថ្ងៃការព្រោះចូធូជាប្រាកដសូមឲ្យលោកវំលែកពលទាហាន ទៅតាំងនៅក្នុងស្រុកសៀរផាយ ១ ក្នុងស្រុកហេហ្ទី ១ កង នឹងបានជួយច្បាំងជាទ័ពសន្ទប់ពីក្រៅ ។ ឡៅពីបានស្តាប់យល់ឃើញត្រូវ ទើបប្រើឆ្លងអ៊ូ ឲ្យលើកពលនាំនាងកាំហ៊ូយិននឹងនាងបុីហ៊ូយិន ដែលជាកវិយាឡៅពីទៅរក្សាទុកឯស្រុកហេហ្ទឹ ប្រើស៊ុនខៀននឹងតាន់យ៉ុង, ប៊ុតុក, ប៊ុហង ៤ នាក់នេះទៅរក្សាស្រុកឈីជីវ ឯឡៅពីនឹងត្រៀវហ៊ុយក៏លើកពលទាហានទៅរក្សាស្រុកសៀវផាយ ។

កាលឡៅតាយនឹងអងតុងទៅដល់ក្រុងហ៊ូតោ ក៏ចូលទៅជំរាបចូធូតាមរឿងដែលបានទៅផ្ទើសត្រាមនឹងឆ្លងអ៊ូ ត្រៀវហ៊ុយនោះគ្រប់ប្រការហើយថា ឡៅពីមានចិត្តសុចរិតគិតដល់គុណូបការមហាឧបរាជមិនដែលដាច់ មិនបានក្សត់ចិត្តគិតប្រទូសរ៉ាយដល់មហាឧបរាជក៏ទេ ដែលឲ្យឆ្លងអ៊ូ ត្រៀវហ៊ុយចេញមកច្បាំងនឹងខ្ញុំបាទនោះ ជាធម្មតាការពារជីវិតទេ

ឥឡូវឡៅពីបើកលែងខ្ជូនខ្ញុំបាទតាំង ៦ នាក់ ឲ្យចូលមកសារពិតក្តិដល់.
មហាឧបរាជតាមផ្ទូវរាជការជាសុចរិត ។

ចូធូបានស្តាប់ដូច្នោះក៏ខឹងណាស់ថា "អាតាហានដើបពីស្ទាប់យ"ង
នេះនឹងចិញ្ចឹមរក្សាទុកមិនបានទេ," ថាហើយក៏បង្គាប់ពេជ្ឈឃាតឲ្យចាប់
ខ្ជូនឡៅតាយនឹងអងតុងប្រុងនឹងឲ្យនាំឡៅសម្ទាប់ ។ ខុងយ"ុងឃើញ
ដូច្នោះក៏ចូលឡៅហាមឃាត់ចូធូថា ឯថ្ងៃដែឡៅតាយនឹងអងតុងនោះ នឹង
ឡៅតទល់នឹងថ្ងៃដែសេចក្តីរិះគិតរបស់ឡៅពីនោះមិនបានទេ ដែលលោក
មឹងឲ្យយកខ្ជូនអ្នកតាំង ៦ ឡៅប្រហារជីវិតចេញនោះ តាហានតាំងឡាយ
នឹងធ្វើការតឡៅក៏មានតែសេចក្តីតូចចិត្ត ។ ចូធូបានស្តាប់ក៏យល់ឃើញ
ត្រូវដូចពាក្យខុងយ"ុងថា, ទើបបង្គាប់ពេជ្ឈឃាតថាកុំឲ្យសម្ទាប់រាចុះ តែ
ត្រូវឲ្យដកហូតសារចេញពីនាយតាហាន យកខ្ជូនឡៅទុកប្រើជារាស្ត
សុទ្ធសាធ ។ រួចចូធូក៏កេណ្ឌប្រមូលសេនាតាហាននឹងលើកឡៅត-
តាំងច្បាំងនឹងឡៅពី, ខុងយ"ុងនិយាយថា "ដែលមហាឧបរាជនឹងលើក
ទ័ពឡៅនោះ រវលានេះជាទេសកាលរងាពន់ពេក តាហានតាំងពួង
នឹងបានសេចក្តីលំបាកតោកយ"ក សុំឲ្យលោកចាត់ប្រើប៉ំរើដែលមាន
សតិបញ្ញា ឡៅនិយាយបញ្ចុះបញ្ចូលឡៅពៀវនឹងតៀវស៊ីវឲ្យឡើងមក
ស្តាប់បង្គាប់លោកសិន ទោះបីលោកនឹងលើកទ័ពឡៅធ្វើការទីណា
ក៏មិនមានកង្ខល់ក្រោយ ឯស្រុកឈីជីវនោះបីដូចជានៅក្នុងកណ្តាប់ដៃ
លោកៗ នឹងតិតយកពេលណា ក៏គង់នឹងបានដោយងាយ ។

(មានត)

រឿងបល់ផ្ពាធិព្យ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ចាត្យ៉ងជម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ព្រះមហាក្សត្រិយ៍ទ្រង់វិចិកិច្ឆាពន់ពេក ទ្រង់ក៏ឡើងទៅលើព្រឹក្សជាតិ
នោះដោះយកសាកសព ដោយព្រះអង្គឯងរួចព្រះអង្គទ្រង់ចុះមក ។

ក្នុងពេលនោះ, រៃតាល:អគ្គីយល់ថាព្រះមហាក្សត្រីយ៍ មានសេចក្តី
វិតក្កជាខ្ចាំង ក៏ប្រតិស្ឋានរូបចំពោះព្រះភ័ក្ត្រព្រះអង្គហើយ ក៏និទានរឿង
ក៉វទាំងអស់ម្តៃប្រាំយ៉ាង ដើម្បីបំបាត់នូវសេចក្តីហត់នឿយរបស់ព្រះអង្គ
(រឿងក៉វទាំងម្តៃប្រាំនោះ មានពណិនាដោយពិស្តារនៅក្នុងសៀវភៅ
រៃតាលបញ្ចវីសតិ) ។ រួចតមករៃតាល: ក្រាបទូលព្រះមហាក្សត្រិយ៍
ថា: "បពិត្រព្រះមហាក្សត្រ សូមទ្រង់ជ្រាបថា យោគីនេះ ជាមេធ្មប់
យ៉ាងចំណាន; គាត់នាំព្រះអង្គមកទីនេះ ព្រោះគាត់យល់ថា ព្រះ
អង្គជាឧត្តមបុគ្គល, ហើយមានសង្ឃឹមថា នឹងយកទ្រង់បូជាយ័ញ
ដើម្បីនឹងឲ្យខ្ជូនគាត់បានកើតជាមនុស្សសុវ៉ណ្ណ សូមព្រះអង្គកុំប្រមាទត្រូវ
ប្រុងប្រយ័ត្នជាដរាប, បើយោគីនោះមានបង្គាប់ឲ្យព្រះអង្គធ្វើការអ្វីក៏ដោយ
ត្រូវព្រះអង្គយល់ថា បើព្រះអង្គឧបត្ថម្ភពួកពាលទុច្ចរិត, កិច្ចទាំងនេះមិន
ជាការប្រសើរឡើយ" ។

សេចក្តីថ្លែងនៃវេតាលៈនេះធ្វើឲ្យព្រះរាជាមានវិចិកិច្ចាជាខ្ទាំង ហើយ
ព្រះអង្គទ្រង់ព្រះតំរិះដូច្នេះថា "យោគីនេះ បានលះបង់កវិយា, បុត្រ,
... ល ... ហើយមកធ្វើជាឥសី; អញជាស្តេចសោយរាជ្យនៅ
ប្រទេសនេះ, ខ្លួនអញជារាជូបត្ថម្ភនៃបុគ្គលម្នាក់ៗ ក្នុងប្រទេសនេះ;
អ្នកនេះ មានបំណងចង់យកខ្លួនអញទោបូជាយ័ញ្ញ ដើម្បីឲ្យខ្លួនប្រែភាព
ទៅជាមនុស្សសុវ័ណ្ណ ។ ភោគទ្រព្យជាវត្ថុបំណងជាយ៉ាងកៃលែងនៃ
បុគ្គលនេះ; ក្រៅពីភោគទ្រព្យនេះ គាត់យល់ថាគ្មានអ្វីប្រសើរជាង ។
ដើម្បីនឹងឲ្យបានសុខស្ថួលចំពោះខ្លួនឯង យោគីកំណាចនេះ មាន
បំណងនឹងធ្វើឲ្យកើតទុក្ខទោស ជាអនេកប្បការចំពោះជនដទៃឯទៀត
ជាច្រើន ហើយមិនមានចិត្តរួញរាត្រង់ការប្រព្រឹត្តិនូវបាបអកុសលនោះ
ឡើយ ។ ព្រោះហេតុដូចនេះ, បានជាមនុស្សធ្លួត ដោយហេតុមក
ពីលោក អាចប្រព្រឹត្តអកុសលដើម្បីប្រាថ្នានូវប្រយោជន៍ផ្សេងៗ ចំពោះ
ខ្លួន, រួចតមក ត្រូវទៅសោយផលទុច្ចរិតនោះ ហើយត្រូវវិលកើត
ស្ទាប់ម្ជុយពាន់ដង ហើយនឹងរងទុក្ខជាច្រើនយ៉ាង ។ ពួកពាលសា-
មាន្យ បើទុកជាគេយកទៅជ្រមុជក្នុងមហាសាគរ ដែលមានទឹកបរិសុទ្ធ
ស្អាត ក៏មិនអាចលះបង់នូវអំពើទុច្ចរិតអកុសលសោះឡើយ; ដូចជាពស់
ដែលផឹកទឹកដោះនៅសមុទ្រខ្សីរ មិនអាចក្អួតមកវិញនូវទឹកអម្ចុត តែង
តែព្រួសសុទ្ធតែពិស ។ តែពិសរបស់សត្វពស់ គេអាចការពារបាន
ដោយសូត្រមន្ត្រ ហើយនឹងឲ្យផឹកនូវឧសថវិសេស ដោយប្រព្រឹត្ត
ទៅតាមឧរាទ ដែលសំដែងក្នុងសៀវភៅសីលធម៌ (នីតិសាស្ត្រ) ដូច

ពួកពាលអាចបន្ទូរបន្ទយបានន្ទូវអំពើទុច្ចរិត ដែលខ្ជូនប្រព្រឹត្តនេះមាន
សភាពកាចអស្ចារ្យ; ការណិយកិច្ចនៃព្រះមហាក្សត្រិយ៍ ត្រូវតែពិយាជ
មនុស្សមានសភាពបែបនេះ" ។ លុះដល់ព្រះអង្គទ្រង់វិនិច្ឆ័យក្នុងព្រះទ័យ
ស្រេច ព្រះអង្គក៏លើកព្រះខ័នកាប់ក្បាលយោតីនោះភ្ជាម ។ ស្រាប់
តែមនុស្សសុវ័ណ្ណាចេញមក សរសើរព្រះតេជានុភាពហើយ ក៏ចូល
ខ្ជូនមកបំរើព្រះអង្គដោយសេចក្តីគោរពមិនធ្នាំធ្គង តាំងពីពេលនោះមក ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះហសនភាពជាយ៉ាងកៃលែង,
ទ្រង់កាន់មនុស្សសុវ័ណ្ណានោះ ហើយយាងមកព្រះរាជនិវេសនដ្ឋាន, ដោយ
អនុគ្រោះនៃមនុស្សសុវ័ណ្ណានោះ ព្រះអង្គសម្ស្យណិណដោយភោតទ្រព្យ
ជាងព្រះបាទកុវេរៈទៅទៀត ហើយព្រះអង្គសព្ធព្រះរាជហ្ចុទ័យនឹង
កាមរាគគ្រប់យ៉ាង ព្រមទាំងជម្រៃកផ្សង ។ ។

ក្នុងពេលនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះសិទ្ធសេន មកពីប្រទេស
ភ័ន្យៈកុប្ជរ ចូលមកក្នុងមន្ទីរក្រុមព្រះរាជប្រឹក្សាព្រះមហាក្សត្រិយ៍ បាន
ថ្វាយបង្គំព្រះអង្គហើយថ្វៃងថា: "បពិត្រព្រះសម្មតិទេព! ដោតរាសនា
ប្រៀបដូចស្ត្រី បើដោតរាសនាដ៏ទត្តមរបស់ព្រះអង្គ បានមកពីព្រះអង្គ
ពិតប្រៀបដូចព្រះរាជបុត្រី; បើដោតរាសនាដ៏ទត្តមនេះ បានមកពីព្រះ
បរមរាជបិតា ប្រៀបដូចព្រះភគិនី; បើដោតរាសនានេះ បានមកពីអ្នកណា
ក្រៅពីអ្នកខាងលើនេះ ប្រៀបដូចភរិយាអ្នកជទៃ; សូមព្រះអង្គទ្រង់
ពិចារណាឲ្យច្បាស់ថា: និស្ស័យដ៏ទត្តម មិនដែលចុះសំរុងគ្នានឹងកាមរាគ
ឡើយ; ព្រោះហេតុដូចនេះ បានជាលោកអ្នកសប្បុរស បើកាលណា

ជានផលតាមនិស្សយដល់ថ្នាក់ឧត្តមហើយ ប្រើនបរិច្ចាគទ្រព្យសម្បត្តិ
ទៅជាទាន, ព្រះអង្គជាសប្បុរសបុគ្គល ត្បូរតែធ្វើទាន" ។ ព្រះ
មហាក្សត្រិយ៍ទ្រង់ព្រះសណ្ឋាប់នូវវាចារបស់ព្រាហ្មណ៍ហើយ ទ្រង់មាន
ព្រះតំរិះថា: "គង់នៅក្នុងមហាប្រាសាទ, ទ្បើងគង់លើព្រះរាជទីនាំង
អស្សតរដ៏រិសេសនឹងអាជាន័យដ៏ត្រកាល, ត្រេកត្រអាលសប្បាយនឹងនារី
ស្អាតផូរផង់, បើទុកជាត្មានអ្នកណាបានឃើញ ក៏មិនមែនជាលក្ខណ:
នៃមហាបុរសទេ ។ អ្នកណាដែលប្រៀបភោគទ្រព្យរបស់ខ្លួនថាមិនមែន
របស់ខ្លួនទៅវិញ អ្នកនោះគឺបានលះបង់នូវអត្តទត្តភាព (égoisme) ហើយ
មានចិត្តសទ្ធាបរិច្ចាគនូវភោគទ្រព្យនោះទៅជាទានបាន, អ្នកនោះហើយគេ
ទុកជាមហាបុរស អ្នកនោះតែងបានទទ្ធួលសេចក្តីសរសើរ" ។ ព្រះបាទ
វិក្រមទិត្យកាលទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏តាំងបរិច្ចាគព្រះរាជទ្រព្យទៅ
ជាទាន; នៅត្រប់ប្រទេស ក្នុងលោកសន្ទិវាស ត្មានអ្នកក្រទុរ្ភិក្សអត់ឃ្ងាន
សោះទ្បើយ, ព្រះរាជកិត្តិសព្ទក៏ល្បីល្បាញទៅដល់ស្ថានទេវលោក ។

សក្កទេវរាជបានយាងទៅក្នុងទេវសភា បានព្ទព្ធកទេវតាពោលសរ-
សើរព្រះរាជកិត្តិគុណនៃព្រះមហាក្សត្រិយ៍វិក្រមទិត្យ ។ ព្រះឥន្ទ្ធទ្រង់
មានព្រះហ្ឫទ័យសោមនស្សពន់ពេក ហើយទ្រង់មានទេវឡង្ការថា "ក្នុង
ពិភពលោកនេះ ព្រះមហាក្សត្រិយ៍វិក្រមទិត្យ ជាអភិរាជលើមហាក្សត្រិយ៍
ទាំងពួង ដូចជាខ្លួនខ្ញុំដែលជាធំជាងទេវតាទាំងអស់ ។ ព្រោះហេតុនេះ
យើងជ្រះថ្ងាពន់ពេកចំពោះព្រះមហាក្សត្រិយ៍វិក្រមទិត្យនេះ យើងនឹង
ធ្វើអំណោយនូវព្រះបល្ងង្កទិព្យ ដែលចរនាដ៏វិចិត្រដោយកែវពិទូសូរ្យកាន

ត្រប់យ៉ាង ហើយមានរូបតំនូរជារូបទេពនិម្មិត ៣២ រូប ធ្វាក់ជាក្បាច់សិល្ប ជាប់នៅលើនោះ ។ ឧព្រះពាយ! ចូរអ្នកយកព្រះបល្ង្ហង្ក្ទិព្យនេះជាប្រញ្ជាប់ហើយហោះយ៉ាងលឿនតាមនភាល័យ យកទៅដំកល់កណ្ណាលមហាសន្ទិបាតក្នុងព្រះរាជមន្ទីរ នៃព្រះបរមរាជវាំង ហើយថ្វាយទៅមហារាជវិក្រមទិត្យ ចំពោះព្រះភ័ក្ត្រ" ។ អភិរាជវិក្រមទិត្យទ្រង់បានទទួលព្រះបល្ង្ហង្ក្ទិព្យនេះហើយ ទ្រង់ក៏បានចាត់ឲ្យប្រជុំនូវនាហ្មឹនសព្វមុខមន្ត្រី ផ្ទើព្រះរាជពិធីរាជាភិសេកគង់នៅលើព្រះរាជបល្ង្ហង្ក្ទនេះ ។ កាលណាព្រះអង្គគង់នៅលើព្រះរាជបល្ង្ហង្ក្ទនោះ ព្រះកេតនភណ្ឌព្រះឥន្ទ្ធាធិរាជ គឺវីរភាព (héroisme), ហាមភាព, ពលភាពនៃសីលធម៌, បរមត្ថបញ្ញា, តេជានុភាព, កម្មិកភាព, ប្រាជ្ញា, វិទ្យា ទាំងប៉ុន្មាននេះទៅជាព្រះរាជចរិយានៃព្រះមហាក្សត្រិយ៍វិក្រមទិត្យនេះទៅវិញ ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះចិន្តាថា: "មកអំពីអញបរិច្ចាគទាន ដោយសេចក្តីណែនាំនៃព្រាហ្មណ៍សិទ្ធសេន បានជាអញបានមកជួបប្រទះនឹងលាភប្រសើរជាយ៉ាងវិក្រឹលេង គឺព្រះបល្ង្ហង្ក្ទិព្យដ៏ថ្ងៃថ្ងានេះ" ។ ព្រះអង្គទ្រង់ព្រះជំរិះជូចេ្នះហើយ កាលក៏មានព្រះទ័យទន់ទោរទៅរកព្រាហ្មណ៍សិទ្ធសេន ហើយទ្រង់បានតែងតាំងព្រាហ្មណ៍សិទ្ធសេន ជាសមាជិកនៃព្រះរាជក្រុមប្រឹក្សារបស់ព្រះអង្គ ជានាយកលើបណ្ឌិតទាំងអស់ ។

ព្រះមហាក្សត្រិយ៍ កាលទ្រង់យាងមកកាន់ទីប្រជុំនៃក្រុមប្រឹក្សាក្នុងព្រះបរមរាជវាំង ក្នុងមួយថ្ងៃ ៗ តែងមានមនុស្សទាំងរយនាក់មកបង្គំតាល់ខ្ងះចេះខាងគម្ពីរវេទមិមាំស:, តរក្ស, ពួកបណ្ឌិតខាងលទ្ធិសំខ្យ, បតំជលិ,

វយសេសិក:, ពួកសិនិទ្ធ: ខាងវិទ្យា កល្យ៉ាលណ:, និរុក្ត:, ជ្យូតិស:, សម្ចុតិ, ព្រមទាំងពួកវាទក: នឹងនាងវាទិកា តែងប្រាណមានវិវណ្ណស្រស់បំព្រង មានបុរសជាបណ្ឌិតខាងសាស្ត្រ ខាងច្បាប់នយោបាយ ច្បាប់ព្រហ្មទ័ណ្ឌ សៀវភៅវេទ្យវិទ្យា, . . . ល . . . ឯតទគ្គបុគ្គល គឺ កលិទស:, វ៉ិរុសិ ភវភូទិ, សបនក:; អមរសិម្ភ.; សំកុ: វេតាលភត:, ឃតកបូរិ, វរាហ:, ម្ហិរ: ធំវំតិរ: . . . ល . . ដោយមានពួកបណ្ឌិតជាបរិវារ, ព្រះមហាក្សត្រិយ៍ ក៏បានទ្រង់ព្រះសណ្តាប់នូវកាព្យនិទានផ្សងៗ ដែលបាននិពន្ធទៅតាមសាស្ត្រ ហើយទ្រង់គង់នៅសោយរាជសម្បត្តិ ប្រកបដោយសុវត្ថិភាពតទៅ" ។

រូបទេពនិម្មិតទីមួយពោលថា: "ឧអភិរាជភោជ:! ព្រះអង្គឥតមានវិចិកិច្ចាអ្វីទេឬ? ផែនដីដែលសម្បូណិដោយគ្រឿងអលង្ការគ្រប់យ៉ាងមិនជាការលំបាកនៃអ្នកដែលចង់បាន ដោយប្រើពលភាពនៃច្បាប់ គឺ សមាធិកម្មដ្ឋាន, ធមិសូត្រ, ទាន, វិទ្យា ។ ពាក្យនិទានអំពីព្រះរាជ កិត្តិគុណ ឬព្រះរិទ្ធានុភាពនៃអភិរាជវិក្រមទិត្យ នោះមានជាប្រើនបែបគេមិនអាចនឹងដឹងនូវចំនួនបានឡើយ ។ ព្រះជន្មាយុ ១០០ ឆ្នាំ គេមិនអាចបន្ទយចំនួនបាន, តើអវសានជាតិនៃព្រះអង្គមានសភាពយ៉ាងណាទៅ?

ព្រះបាទវិក្រមទិត្យ ដោយទ្រង់បានចាំព្យាករណ៍នៃវេតាលៈអគ្គីថាទ្រង់មានព្រះជន្ម ១០០ ឆ្នាំ, លុះដល់ទ្រង់បានជ្រាបថា ព្រះអង្គជិតដល់ពេលសោយព្រះទិវង្គតហើយ ទើបទ្រង់ព្រះតម្រិះថា "ការណ៍ដែល

ព្រះរាជសម្ភពមកជាវស្សក្សត្រិយ៍ ត្រូវមរណៈក្នុងទីសមរភូមិ! "ហើយ ជល់ទ្រង់ព្រះទិវង្គតទៅ មុខជាទ្រង់ទៅបដិសន្ធិនៅស្ថានសួគ៌" ។ កាល ព្រះអង្គទ្រង់ព្រះចិន្តាយ៉ាងនេះហើយ ទ្រីបទ្រង់មានព្រះរាជបំណងចង់ធ្វើ សង្គ្រាម នឹងមហាក្សត្រិយ៍មួយអង្គ ទ្រង់ព្រះនាមសាលិរាហនៈគង់នៅ ទីក្រុងប្រតិស្ថថាន ។

ព្រះមំហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលសូរសិហនាទ ទៅកាន់ព្រះ រាជទីប្រឹក្សាឲ្យរៀបចំកងទ័ពមួយ ។ ព្រះរាជទីប្រឹក្សាទទួលព្រះរាជឧត្តារ ក៏បានប្រមូលព្រះរាជយានមួយពាន់, ព្រះរាជគជេន្ទូមួយម៉ឺន ព្រះរាជ-ពាជីមួយម៉ឺន, អូដ្ឋមួយលាន, អស្សតរជប់លាន, ពួកយោធាសរជ័យ មួយរយលាននាក់, ពួកកាន់ធ្នូជាច្រើននាក់, ត្រឿងយុទ្ធោបករបេញ ក្ងើងជាច្រើន, ពួកយោធាកាន់ជាវនឹងពាក់អាវដែកចំនួន ១០០ កោដិនាក់, រំពាត់ជាងមួយរយ, ព្រមទាំងប្រជាប់ជាក់ព្រួញ, ព្រួញ, ធ្នូ, ខែល, ជាវ, លំពែង, បហរណរត្ត (ត្រឿងប្រហារ), កាំបិតស្នៀត, ពូថៅ, កាំក្ងើងប្រធេះ, កាំក្ងើងធំនឹងត្រឿងអាវុធយុទ្ធកណ្ឌឯទ្រៃតជាច្រើន ។ ក្រៅពីនេះ ព្រះរាជទីប្រឹក្សានោះ បានប្រមូលខ្សែ, ជំបង, សំពត់ជង្រំ (គេនត៍) សំពត់ក្រាស់, ព្រះរាជាសនៈ, ភួយ, បង្គោល, ទង់ជ័យ, ហើយបានរួបរួម ស្គរធំ, ស្គរជ័យ, ស្គរសុម្ភោ, ស្គរ, ខ្ទុយ, ត្រែធំ, ត្រែតូច, ស្នែងផ្ទុំសង្គ្រាម, ស្នែងផ្ទុំជ័យ, ស្គរតូច, ធាបនឹងឧស្សវកណ្ឌ ផ្សេងៗ ។ ព្រះរាជទីប្រឹក្សា បានចាត់ចែងតាមព្រះរាជឧត្តាររួចជាស្រេច ក៏យកសេចក្តីទៅក្រាបបង្គំទូលឲ្យទ្រង់ជ្រាប ។

មហ្ការាជវិក្រមទិត្យ ស្តេចទ្រង់គង់លើព្រះរាជរថដែលរចនាជាំ ដោយត្សូងពិទូរ្យនឹងកែវផ្សេង ។ ហើយទឹមដោយរាជពាជី ដែលព័ទ្ធ ជុំវិញព្រះអង្គ មានកងទ័ពញ្ញែកជាបួនកងអង្គទ័ព ចោមរោមជាបរវារ ទ្រង់ចេញចាកព្រះរាជនិរេសនដ្ឋាន ដើម្បីទៅផ្ទើសង្ត្រាមនឹងស្តេចសាលិ-រាហន: ។ ព្រះបាទវិក្រមទិត្យ លុះដល់ស្តេចយាងទៅដល់រណស្ថាន, ទ្រង់ចូលទៅតស៊ូយ៉ាងសម្បើមអស្ចារ្យ ហើយក្នុងខណៈដែលតទល់នឹង ស្តេចសាលិរាហន: ចំពោះព្រឹះក័ក្ត្រ ទ្រង់ក៏ចូលកាន់ព្រះទិរង្គតក្នុងពេលនេះ ហើយទ្រង់យាងទៅសោយទិព្ទសម្បត្តិឯស្ថានសួគិ ។ ប្រទេសអវន្ត្តី ត្រឡប់ទៅជាគ្មានព្រះមហាក្សត្រីយ៍; រាជសម្បត្តិគ្មានអ្នកណាគ្រប់គ្រងតទៅទៀត ។

ព្រះអគ្គមហេសីទីមួយ កាលទ្រង់បានជ្រាបថាព្រះមហារាជវិក្រម-ទិត្យ:ទ្រង់ទិរង្គត ព្រះនាងទ្រង់មានព្រះសវនីយ៍ទៅកាន់ព្រះរាជទីប្រឹក្សា ដោយព្រះរាចាទន់ផ្អែមថា: "លោកកុំបារម្ភអ្វី, ខ្ញុំទ្រង់គភិ, ខ្ញុំមុខជាប្រសូតព្រះរាជបុត្រមួយព្រះអង្គ ដែលជាព្រះរាជទាយាទសោយរាជ្យស្នង ព្រះបាទវិក្រមទិត្យនៅប្រទេសនេះ; ព្រះរាជបុត្រនេះ មុខជាទុកលោកឲ្យផ្ទើការនៅទីនេះ តទៅទៀតមិនខាន" ។

(មានត)

សកម្មភាពនៃក្រុមជំនុំនៀមទម្ងាប់ខ្មែរ
បរិយាយពីចម្រៀងនឹងប្រយោជន៍ចម្រៀង
របស់លោក ចាប-ពិន

តាងនាមក្រុមជំនុំទំនៀមទម្ងាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូម បរិយាយអំពីកំណើតចម្រៀង និងប្រយោជន៍របស់ចម្រៀងដូចតទៅនេះ៖

ស្លរ: ការច្រៀងកើតពីតឹមណាមក ?

ឆ្លើយ: ការច្រៀងកើតតាំងពីមនុស្សចេះប្រើពាក្យសំដីមក ។

ស្លរ: ហេតុម្តេចបានជាប្រជាជនចូលចិត្តច្រៀង? ព្រោះត្រូវការអ្វី ?

ឆ្លើយ: បានជាប្រជាជនចូលចិត្តច្រៀង ព្រោះត្រូវការរស់នៅក្នុងសង្គម, ត្រូវការចិញ្ចឹមបុត្រ, ត្រូវការគូសង្សារ, ត្រូវការអាពាហ៍ពិពាហ៍ ជាដើម ។

ស្លរ: ការច្រៀងជាការសំដែងអ្វី ?

ឆ្លើយ: ការច្រៀងជាការសំដែងសាវតារជាតិ-ទឹកចិត្តអធ្យាស្រ័យ និងបំណងរបស់ប្រជាជន គឺថាប្រជាជនមានបំណងយ៉ាងណាក៏បណ្ណាលឲ្យច្រៀងតាមទំនងបំណងនោះ; រួមសេចក្តីថា: ចម្រៀងជាសំឡេងឬជាសម្រែកចិត្តរបស់មនុស្សជាតិពិតៗ ទោះបីអ្នកមិនចេះតែងទំនុកខ្លួនឯងក៏រមែងជ្រើសរើសយកទំនុកចាស់ៗ របស់គេ ដែលអ្នកផងតែងច្រៀងមកច្រៀងតម្រូវតាមសេចក្តីត្រូវការរបស់ខ្លួន ។ មិនតែមនុស្សទេ, សម្ឃី

តែសត្វស្វាបន្តិច ដូចសេកសារិកាជាដើម ក៏ជម្នួតាបណ្ដាលឱ្យរៀនច្រៀងជាសម្រែកចិត្តរបស់វា ចំពោះគូសង្សាររបស់វាជាដើមដែរ ព្រោះគេតែងឃើញវានៅក្បែរគ្នាឥតមុខមាត់ផ្លែងផ្ដង្គន់ផ្ដោះផ្ដងរកគ្នា ដោយសម្ងេងដ៏ពីរោះគ្រលួចគួរឱ្យស្រេងេះស្រេងោច ។

ប្រជាជនគ្រប់ជាតិគ្រប់ភាសាគ្រប់ប្រទេស ក្នុងសាកលលោកទាំងសម័យបុរាណ ទាំងសម័យបច្ចុប្បន្ន ទាំងប្រទេសចម្រើនហើយ ទាំងប្រទេសមិនទាន់ចម្រើន សុទ្ធតែត្រូវការរាប់អានការច្រៀងទាំងអស់សូម្បីទៅសម័យអនាគតក៏ដូចគ្នា ប្រទេសដែលចម្រើនណាស់ គេតែងតែត្រូវការណាស់ទៅទៀត ។ ដោយហេតុប្រជាជនក្នុងសាកលលោកត្រូវការរាប់អានចម្រៀងគ្រប់រូប ទានជាគេហៅចម្រៀងគ្រប់បែបថា "ចម្រៀងប្រជាមានិត" វិញថា "ចម្រៀងជារបស់ដែលប្រជាជនពាប់អាន" ភាសាបារាំងហៅថា (chant populaire) ។

ទំនុកច្រៀងប្រជាមានិត មានសភាពផ្សេងៗគ្នា ប្រព្រឹត្តទៅតាមស្ថានភាពនៃសញ្ជាតិនៃប្រទេសនិងសង្គមរបស់ប្រជាជន ប្រៀបហាក់គ្នានឹងជីវភាពរបស់ប្រជាជាតិក្នុងសាកលលោក ដែលប្លែកៗគ្នាដោយបែបៗតែរួមចុះក្នុងបទជាសំឡេងឬសម្រែកចិត្ត របស់ប្រជាជនប្រចាំជាតិនីមួយៗ ដូចគ្នា ។

ចម្រៀងជាគូគ្នានិងភ្លេង ជាសិល្បៈមួយផ្នែក ហៅថា "តន្ត្រីសិល្បៈ" ជាអារម្មណ៍ឬជាគ្រឹះស្ថានដ៏សំខាន់ប្រចាំសញ្ជាតិ ហើយជា

ជំហររបស់ប្រជាជាតិទីមួយ។ អាចញុំាងជាតិឲ្យតន់ដាវផ្សុជួចភាសា ទឹង អក្សរសាស្ត្រដែលអាចធ្វើជាតិឲ្យបិតថេរថេរកាលនៅកន្លែង ។

តាមពិតភាសាក្តី អក្សរក្តី ចម្រៀងក្តី ក្វែងក្តីរបស់ជាតិណា ជាគ្រឿងសំគាល់ដ៏សំខាន់សម្រាប់ជាតិនោះ តើគេគ្រាន់តែឃើញអក្សរ ឬភាសាចម្រៀងបុក្វែងរបស់ជាតិណា គេអាចស្គាល់ជាន់ក្លាមថាជាអក្សរ-ភាសា ចម្រៀង-ក្វែង របស់ជាតិនោះបានជាប្រាកដមិនចាំបាច់ឃើញរូបមនុស្សជាម្ចាស់របស់ឡើយ ។

ចម្រៀងខ្មែរ ជាអារម្មណ៍ជាគ្រឹះស្ថានហើយជាតីតសិល្បៈដ៏សំខាន់មួយផ្នែករបស់ខ្មែរ សម្រាប់ឧបត្ថម្ភជាតិខ្មែរឲ្យចាក់ឫសជាប់បិតថេរប្រាកដប្រជានៅកន្លែង គឺថា ចម្រៀងខ្មែរមាននៅកន្លែងជាភាពណា ជាតិខ្មែរក៏មាននៅកន្លែងជាភាពនោះ, បើចម្រៀងខ្មែរលាយសូន្យបាត់ទៅវេលាណា ខ្មែរក៏បាត់ទៅវេលានោះជាប្រាកដ ។ ហេតុនេះខ្មែរយើងគួរសន្ធឹងរក្សាកត់ត្រាទុកនូវចម្រៀងខ្មែរដែលមានបែបបទ ទឹងទំនុកផ្សេង។ ឲ្យតន់ទៅតទៅកុំឲ្យបាត់បង់ ។

តាមពិត ចម្រៀងប្រជាមានតិតខ្មែរ មានតាំងពីមានខ្មែរនៅកន្លែងលោកនេះមក, ប៉ុន្តែការផ្លាស់ប្តូរសម័យរបស់ប្រទេសខ្មែរ ដូចជាផ្លាស់ពីសម័យ-ដ្ឋរមកជាសម័យកុំពេញជាដើម តែងធ្វើចម្រៀងខ្មែរឲ្យផ្លាស់ប្តូរពាក្យពេចន៍ក្នុងទំនុកចាស់ខ្លះ ឲ្យបង្កើតជាទំនុកថ្មីខ្លះ សម្រួលទៅតាមសម័យរបស់ខ្លួនជាធម្មតា ដើម្បីឲ្យប្រជាជនខ្មែរកន្លងសម័យខ្លួនស្តាប់បានដឹង ។

រៀលានេះ ខ្ញុំសូមស្រង់យកដោយសង្ខេបតាមដែលចាំបានខ្ទះនូវ ទំនុកច្រៀងចាស់របស់ខ្មែរ ដែលមិនដឹងជាតែងក្នុងសម័យណា នឹងមិន ដឹងជាឈ្មោះណាតែងប្ដូ ធ្លីមច្រៀងមុនគេនោះ មកត្រាទុកជាឧទាហរណ៍ ក្នុងទីនេះតាមបទនឹងទំនុកច្រៀងមានប្រការឡេងៗ ដែលជាសំឡេង ប្ដូ សម្រែកចិត្តរបស់ប្រជាជនជាតំខ្មែរសុទ្ធៗ ដើម្បីរក្សាទុកនូវទំនុកច្រៀង ប្រជាមានិតខ្មែរសម័យបុរាណឲ្យបានបំភ្លេចរតង់រង្សតទៅ នឹងដើម្បីជា បទពិចារណាជូនអស់លោកបង់ប្អូនរួមជាតំពិចារណា ដូចតទៅនេះ ៖

ទំនុកសំដែងសេចក្ដីខ្មាស

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលចង់បានស្ត្រី ណាម្នាក់ តែមានគេមកដែងកាត់មុខយកបានទៅ ក៏បណ្តាលឲ្យច្រៀង សំដែងទឹកចិត្តអៀនខ្មាស មានដើមថា:

ស្រីអើយ! បង់ប៉ង់ មានគេដែងបង់
បង់មិនចង់នៅស្រុក ស្លាប់ទៅជាខ្មោច
ដេកដីស្រណុក បង់មិនចង់នៅស្រុក
ខ្មាសមុខប្អូនស្រី ។

ទំនុកសំដែងសេចក្ដីស្តាយ

ទំនុកច្រៀងមួយបែបទៀត ជាសម្រែកចិត្តរបស់បុរសដែលខ្លួនបាន ចំណាំស្ត្រីណាម្នាក់ទុកតាំងពីក្មេងមក តែដល់ធំឡើងមានគេមកយកស្ត្រី

នោះកាត់មុខបានទៅ ក៏បណ្ណាលឲ្យប្រៀងសំដែងទឹកចិត្តសោកស្តាយ មានដើមថា:

ស្តាយអើយ សែនស្តាយ! ដូចចេកនួនក្ខាយ
ស្រគាលទុំដើម ។ បងខំស្រាចទឹក តាំងពីតូចនៅ
ដល់ធំឡើងទៅ នរណាបេះបាត់ ។

ទំនុកសំដែងសេចក្ដីអាណិត នឹងសេចក្ដីរ៉ាប់រង

ទំនុកប្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលស្រឡាញ់ស្ត្រីណាហើយ ឃើញស្ត្រីនោះធ្វើការនឿយហត់ មានចិត្តអាណិត ក៏បណ្ណាលឲ្យប្រៀងសំដែងសេចក្ដីអាណិត នឹងសេចក្ដីរ៉ាប់រងមានដើមថា:

ស្រីឆ្មៅដើរទន! ដាក់មុខស្រពោន
ឆ្មៅបងនឿយណាស់ បើជិតទៅរ៉ា
បងទៅជួយផ្ទាស់ ឆ្មៅបងនឿយណាស់
ជកផងស្ទូងផង ។

ទំនុកសំដែងបំណងល្អបំពោះកូន

ទំនុកប្រៀងមួយបែប ជាសម្រែកធន្ទះរបស់ម្តាយឪពុកដែលប៉ងឲ្យកូនស្រីរបស់ខ្លួនបានសម្រេចប្រយោជន៍ល្អ ក៏បណ្ណាលឲ្យប្រៀងមានដើមថា:

សក្រវាទ៏ផ្ការកំពីងពួយ កូនស្រីតែមួយ
ទុកឲ្យចិនឆៅ បង្ឆាប់ជួះក្សឿង

ត្រើងឈើស្រឡៅ ទុកឲ្យចិនធៅ
ធ្វើដង្ហាធំ ។

ទំនុកសំដៃងបំណងបំពោះគ្ងសង្ហារ

ទំនុកច្រៀងមួយបែប ជាសម្រែកធន្ធរបស់បុរសអ្នកប៉ង់ចង់បានស្ត្រីឯណានីមួយដែលខ្លួនត្រូវចិត្ត ក៏បណ្តាលឲ្យច្រៀង មានដើមថា:

អាំអើយ ស្រីអាំ! ពោះពុទ្ធលោកផ្តាំ
ឲ្យអាំដោយបង បងដាំពោធ៏មួយ
ពុំទាន់បានធ្ងង ឲ្យអាំដោយបង
ធ្ងងពោធ៏ពីរនាក់ ។

ទំនុកសំដៃងសំនួររបស់បុរស

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តសំដែងសំនួររបស់បុរសអ្នកចង់បានស្ត្រីណាម្នាក់ដែលខ្លួនស្រឡាញ់ ក៏បណ្តាលឲ្យច្រៀងជាពាក្យដណ្តឹងស្ត្រីនោះ មានដើមថា:

ស្រីសទ្រលុក មុខមាត់ប្រឹមប្រិយ
ប៉ើបងចូលស្ត្រី ស្រីព្រមឬទេ?

តាមសង្កេតក្នុងទំនុកច្រៀងសម្រាប់បុរស និងសម្រាប់ស្ត្រីវិញ្ញរយើងសម័យបុរាណយើញវិញ្ជកគ្នា, ខាងបុរសច្រើនប្រើទំនុកសំដែងសេចក្តីល្ងងលោមស្ត្រី ដូចស្រង់ទំនុកខ្ងះមកពោលហើយក្នុងខាងលើ, ចំណែក

ខាងស្ត្រីវិញ ប្រើនតែប្រើទំនុកសំដែងសេចក្តីបន្ទុះបង្អាប់បុរសជាដរាប មានឧទាហរណ៍ ដូចស្រង់មកពោលដោយសង្ខេបតទៅនេះ ៖

ទំនុកសំដែងសេចក្តីបង្អាប់

ទំនុកប្រៀងមួយបែប ជាសម្រែកចិត្តរបស់ស្ត្រីដែលដឹងថាបុរសណាត្រូវការនឹងខ្ជូន តែខ្ជូនមិនត្រូវការនឹងបុរសនោះ ក៏បណ្តាលឲ្យប្រៀងសំដែងសេចក្តីបន្ទុះបង្អាប់មានដើមថា :

ប្រុសអើយ ប្រុសបាណ! ឃើញស្រីចង់បានមិនមើលមាឧ
គន់មើលទៅមុខដូចកញ្ចប់ជាតុ គន់មើលទៅមារយាទ
ដូចផ្តែក្រោមផ្ទះ ។

ទំនុកសំដែងសេចក្តីរិះគន់

ទំនុកប្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសឬស្ត្រីដែលប្រកបដោយសេចក្តីរិះគន់ មានដើមថា

ក) កញ្ចាញ់ចេកអើយ! លោតទំចុងក្តាត
មេម៉ាយរាប់បាត្រ លោកគ្រូចង់សឹក ។
បាសកទៅយាត់ លោកគ្រូថាទេ
ចង់បានកូនគេ ទៅខាងដើងក្តី ។

ខ) លោកគ្រូចង់សឹកប្រញឹកណាស់
ប្ជូសយូរខ្ជាចចាស់ ខានបានប្រពន្ធ ។

ឥ) ឲលុកៗអើយ! កុំធ្វើបាបលោក
កុំឡោះឥរតោក ទុកលោកធ្វើបុណ្យ ។

ទំនុកសំដែងសេចក្ដីលោភជាការបម្អក

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោលផ្តោះ ផ្តងនឹងស្ត្រីដោយសេចក្ដីលោភជាការបម្អក មានដើមថា:

ស្រីអើយបងនឹក ស៊ីបាយស្ងូបទឹក ប្រាំតោមកន្ទះ
ប្រាំពីរធ្នាំងដិ ប្រាំបីធ្នាំងខ្ទះ ប្រាំតោមកន្ទះ ស៊ីសោះរមូល ។

ទំនុកសំដែងសេចក្ដីត្រេកត្រអាល

ទំនុកច្រៀងមួយបែប ជាសម្រែកចិត្តរបស់បុរសដែលពោលផ្តោះ ផ្តងនឹងស្ត្រីដោយតម្រេក មានដើមថា:

ឧ! ម្ទប់ជូងអើយ! ដែលបងអង្គុយ បងអត់ងងុយ
ចាំស្រីរៃ, រៃរួចហើយ បំពេញសណ្តាង់ ទម្រាំខែត្រង់
នាំអូនចូលគេង ។

ទំនុកសំដែងសេចក្ដីសរសើរ

ទំនុកច្រៀងមួយបែប ជាទំនុកសំដែងសេចក្ដីសរសើរនឹងប្រៀបធៀប ឲ្យអ្នកស្តាប់កើតតំនិតគំតជល់ហាន:ទាបខ្ពស់របស់ខ្លួន ថាមិនមែនមានតែ ខ្លួនម្នាក់ឯងគ្រាន់បើជាងគេទេ មានគេឯទៀតគ្រាន់បើដែរ មានដើមថា:

អញថាភ្នំស្ងូប ស្ងូបអីតែឯង
មានភ្នំកម្រែង រៃងហើយស្ងូបផង ។

ទំនុកសំដែងបំណងនឹងជំនឿ

ទំនុកប្រែងមួយបែប ជាទំនុកសំដែងបំណងនឹងជំនឿក្នុងអំណោយ
ទាន មានដើមថា:

ឧ! សត្វមហោរី យំសុីផ្ទៃដ្រៃ ធ្វើបុណ្យទានអ្វី
ឲ្យដ្រៃផ្ទៃទ្រៃត ដ្រៃផ្ទៃពីមុន ផ្ទៃចាលបង់សៀត
ឲ្យដ្រៃផ្ទៃទ្រៃត ជាក់ទានសព្វសត្វ ។ល។

ទាំងបទទាំងទំនុកចម្រៀងមហោរី ត្លូរចាត់ទុកជាចម្រៀងថ្នាក់ខ្ពស់
មួយបែបរបស់ខ្មែរឥតនរណាកែប្រែបាន ដែលតាមកាសាបារាំងហៅថា
ចម្រៀងក្លាសុិករបស់ខ្មែរ ។

*

* *

ទំនុកប្រៀងនៅពេលធ្វើមង្គលការ

បណ្ណាចម្រៀងប្រជាមានិតខ្មែរទាំងអស់ ចម្រៀងដែលមានទំនុក
ច្រើនជាងគេ គឺចម្រៀងក្នុងមង្គលការ, បន្ទាប់មកចម្រៀងលៀង
ឈារក្សនឹងឡើងអ្នកតា; ចម្រៀងក្រៅពីនេះមានទំនុកបន្ទាប់បន្សំ ។

រប្រៀបវារៈមង្គលការដែលមានច្រើនថ្នាក់ គឺថ្នាក់ចូលរោងកាត់សក់,
ឡើងអ្នកតា, លើកជំនូន, រៀងផ្ទៃឈើ, ក្រុងពាលី, សំពះរោង, ចំ-
រើនបរិត្ត, រាំខ្សែរបុកលីក្ត, ធ្វើផ្ទេញ, ដោតផ្កាស្លា, សំពះរានពេលា,
ហូតផ្កាស្លា, សុំកូនចេញផ្ទឹម, បើកបាយខុន (ឲ្យពរចងដៃ) តោង
ស្សែចូលក្នុង, សាកនេួល (ក្រោយផ្ទឹមរួច) រៀបស្ពកលើកស្ពក សំពះ

អាចារ្យមហា នឹងផ្សំដំណេក (បញ្ចុកចេកនំ) សុទ្ធតែត្រូវប្រើងត្រប់ថ្នាក់ទាំងអស់ ហើយមានទំនុកនឹងបទជាប្រើនសម្រាប់ប្រើងក្នុងថ្នាក់ទាំងនោះ តាមលំដាប់ គឺបទសាវោមេ, ហ្ចុំវោង, សំពោង, ជាត់ជាយ អង្គរវាជស្តេចផ្ទំ, លោមនាង, ថ្នមនាង, ព្រាថោង, នាងនាត, នាតព័ន្ធ, កន្ទ្រាំត្រែប្ចុជុំត្រៃ, កន្ទង់រ័ត្ន, កាត់ត្រើយ, សារាយអណ្តែត, កន្សែងក្រហម, កន្សែងស្ងត្រ, ជំរ័ស, ក្ទោងប្ចក្ទោងបណ្តែត, រ៉ៀងផ្ទៃឈើ, បំពេរ អុំទូក, កាត់សក់, បុកល័ក្ត, ដោតផ្ការស្ទាប្ចជាវផ្ការស្ទា, សំពះពេលា, បៃកបាយខុន, សាកន្ទេល, ត្រាំងដោះក្រាល, ស្តេចដើរ, លលេរ, ម្ទប់ដូង, អន្ទក់រាំង, ចន្ទោ, សំពៅថយ នឹងកងសោយ ។

ចម្រើងក្នុងមង្គលការដែលមានប្រើនទំនុកប្រើបទដូចពោលមកនេះ តាមសង្កេតសព្ទត្រប់ទៅឃើញទំនុកខ្ទះ ជាទំនុកសំដែងសេចក្តីសប្បាយ, ខ្ទះសំដែងសេចក្តីតោរព, ខ្ទះសំដែងសេចក្តីទូន្មាន ។ល។ ហើយខ្ទះមានប្រយោជន៍ប្រើន ខ្ទះមានប្រយោជន៍តិច ដែលមិនអាចស្រង់យកមកពោលឲ្យសព្ទត្រប់ក្នុងទីនេះបានព្រោះពេលខ្ទី ប៉ុន្តែទោះបីមានប្រើនបែបដូច្នេះ ក៏រ្ជមចុះក្នុងសេចក្តីសំដែងសម្រែកចិត្តរបស់ជនជាមេបាត្ត្រសារដែលប្រាថ្នាឲ្យសាមីខ្ជួនកូនចៅជាអ្នកការថ្មី បានសេចក្តីសុខសេចក្តីចម្រើនទាំងអស់ ។

សូមស្រង់ទំនុកខ្ទះក្នុងបណ្តាទំនុកប្រើងមង្គលការ មកពោលក្នុងទីនេះដោយសង្ខេប ដូចតទៅនេះ ៖

ទំនុកហ៊ុំរោងឬបើករោង

ទំនុកប្រៀងមួយបែបជាទំនុកសំដែងសេចក្តីគោរព សេចក្តីសូមពរ ចំពោះវត្ថុសក្តិសិទ្ធិនៅពេលចូលរោងការ ហៅថា "ទំនុកហ៊ុំរោងឬបើករោង" មានដើមថា:

យើងខ្ញុំសុំនមស្ការ លើកហត្ថាលើសិរសី
បង្គំកែវទាំងបី សូមសេរីជ័យជំនះ ។
ហើយលេងក្ងេងហ៊ុំរោង តាមទំនងទំនៀមចាស់
ក្ងេងធ្នើមជាដើមអាសន៍ បើកប្រកាសជាស់ទេវតា ។
ថ្ងៃនេះថ្ងៃជោគជ័យ ញាតិប្រុសស្រីក្ងុំមេបា
នឹងរៀបមង្គលការ លៀងអាហារពិសាតុ ។
ហេតុនេះសូមទេវតា ភៅអ្នកតាបាចាស់ស្រុក
ការពារឲ្យបានសុខ ចាកក្តីទុក្ខក័យទាំងឡាយ ។
អញ្ជើញព្រាយកុមារ ព្រៃបព្ងតាទីជិតឆ្ងាយ
ចូលមកយកស្រាបាយ ហើយប្រែកាយឲ្យពរជ័យ ។
ជល់លោកអ្នកទាំងឡាយ សុខសប្បាយទាំងប្រុសស្រី
ព្រមទាំងតួសាមី ទើបការថ្នីកុំបីហ្នង ។
ហ៊ុំរោងប្រាំពីរបទ ចប់កំណត់ត្រឹមនេះហោង
សូមឲ្យអស់ញាតិផង ជួយគឹកកងហ៊ោយកជ័យ ។
ជ័យហោងហៅជយោ យើងស្រែកហ៊ោគំរប់បី
កក្រើកបើករោងថ្នី ជោគសួស្តីជោយជាក់ច្បាស់ ។

ទំនុកបើកបាយខុន

មានទំនុកប្រៀនមួយបែប ជាទំនុកសំដែងសេចក្តីគោរពចំពោះ
ត្រកូលរៀមច្បងសូមកូនស្រីមកផ្ទឹម សម្រាប់ប្រៀនក្នុងមង្គលការនៅ
ពេលមុនផ្ទឹម គឺពេលដែលកូនប្រុសមកអង្គុយលើអាសនៈកណ្ណាលហ្ចូន
មេបាប្រុងចាំកូនស្រីមកផ្ទឹម មានដើមថា:

បាយខុនចងដៃ អំបោះ ១ សរសៃ ថ្ងៃស្នើនឹងមាស
ទឹកផ្ទៃលសម្រឹទ្ធ៍ ប្រសិទ្ធ៍ឧកាស លើកទ្បើងត្រាស
ត្រដួចគួចហត្ត ។

ថ្ងៃនេះជាថ្ងៃជា ថ្ងៃបានពេលា យកពារយាមសត្ត
ពេលសំពូអក្សរ អរុណសុវត្ត៍ ពារពពកផាត់ ពន្ធឺពេញវង់ ។

ញ្ចសូរគងហើយ អ្នកគ្រាបលើទ្នើយ
ប្រុងលុតជួញជង់ ដៃចាប់ស្ទាពរ
លើកទ្រទម្រង់ ហត្ថារាតវង់
ហូតជាក់ប៉ីជង ។

ច្បងជូនឪពុក ហើយទើបគ្រាបទុក
ជូនទៅម្ចាយផង ទោជូនមាស្រី
ទីបីជូនបង រៀបតាមរៀមច្បង
ទំនៀមបុរាណ ។

ស្ទាពរទាំងបី ជូនមេបាស្រី
ជាស្រេចត្រប់ប្រាណ កូនប្រុសគោរព

គ្រប់ញាតិសន្ថាន ចាំស្រីកល្យាណ
ចេញប្រាណមកផ្ទឹម ។

អនអើយ ! ស្រីអន ! សុំបើកភ្ជងនន
ឲ្យអនអមទឹម ដឹកដៃកូនស្រី
ប្រឹមប្រិយញញឹម ក្រាបម៉ីបអបផ្ទឹម
នៃបនឹមលោកប្រុស ។

ទំនុកបើកភ្ជងនន

អនអើយ ! ស្រីអន ! សុំបើកភ្ជងនន
សុំអនមកផ្ទឹម ផ្សិតពេលថ្មើរនេះ
ទាន់នៅព្រលឹម សុំអនមកផ្ទឹម
គូព្រេងដល់ហើយ ។

ទំនុកបំពេរ

ទំនុកប្រៀងមួយរបៃប ជាទំនុកសំដៃងដំបូន្មាន ដៃលម្តាយ ទូន្មានកូនស្រី សម្រាប់ប្រៀងក្នុងមង្គលការនៅពេលចងរៃដ ហៅថា "ទុកបំពេរ" មានដើមថា:

កូនអើយ ! ចាំផ្ទៀង ម្តាយប្រៀងបំពេរ ពាក្យជកប្ទែកគេ ជាមេប្យាប់ចាស់ ចូរចាំជាក្រឹត្យ ព្រោះផ្សិតក្រណាស់ ធម្មតា មេផ្ទះ ប្រះគេងឈ្ទេងតិត ។

កើតមកជាមនុស្ស ត្រើសនៅតំនិត

ត្រូវរៀនវិះគិត មើលព្រឹត្តិស្វាមី ។
កុំដើរបង់សៀត ឃ្លាតផ្ទះរាត្រី
បើមានការអ្វី ប្រាប់ប្ចីឲ្យដឹង ។
ចូលគេងកូនឯង កុំថ្ងៃងរៀងខឹង
កុំត្អកវឹងត្អឹង ក្រញ៉ឹងក្រញូវ
យប់យន់យូរហើយ នាងអើយ ! គេងទៅ
ព្រោះពេលយប់ជ្រៅ ប្តីញៅបំពេរ ។
នាងនៀយពីថ្ងៃ ត្នានដៃទំនេរ
បម្រើរត់រេ ដោយគេការបើង ។
នាងគេងកាលណា កុំផ្ទារដៃឡើង
មួយទៀតកុំទើង គេងទឹមក្យាលប្តី ។
បើជួនជាពាល់ កាន់ជល់កេស៊ី
ត្រូវមានសំដី សុំទោសតាមការ ។

*
* *

ចម្រៀងប្រជាមានិតថ្មៃរយើង មានប្រើនទំនុកប្រើនបទជាអនេក លើសតណនា ពុំអាចពណិនាឲ្យចប់សព្វគ្រប់ក្នុងទីនេះបាន; ប៉ុន្តែ ទោះជាប្រើនជូច្នោះ ក៏សង្កេតសព្វគ្រប់ទៅយើញថា ចម្រៀងប្រជា-មានិតថ្មៃរទាំងប៉ុន្មាន ទោះជាយ៉ាងណា ក៏សុទ្ធតែទុកជាសម្រែកចិត្ត របស់ប្រជាជនខេមរជាតិទាំងអស់ ហើយជារបស់មានប្រយោជន៍ដោយ

យ៉ាងទៅតាមទំនុកតាមបទ, ប្រែកតែខ្ទះតិចខ្ទះប្រើន, ដែលស្រងំទំនុកខ្ទះ
មកពោលខាងដើមនេះ សង្ខេបណាស់គ្រាន់តែជាឧទាហរណ៍ នឹងជា
បទពិចារណាជូនបងប្អូនរួមជាតិពិចារណាប៉ុណ្ណោះ; សូមបញ្ចប់ត្រឹម
ប៉ុណ្ណោះ ។

និគមវិបន:

ចម្រៀងខ្មែរបាត់, ជាតិខ្មែរបង់ មិនបិតនៅតង់យូរប៉ុន្មាន
ចម្រៀងខ្មែរស់, ខ្មែរស់បាន ជនខ្មែរគួរមានកក្តីកាព ។
រក្សាចម្រៀងខ្មែរឲ្យនៅ ចម្រើនតទៅជារៀងរាប
ឲ្យរិតតែខ្ពស់កុំឲ្យទាប កុំសាបរលាបជល់ឥសាន ។

បាប - ពិន

កំណត់ទឹងប្រវត្តិការណ៍

អនុសំវច្ឆរមហាសន្និបាតទី ១១ នៃមន្ត្រីសង្ឃ
សម្រាប់ឆ្នាំ ១៩៥៥

កាលពីថ្ងៃទី ៨ ទឹងទី ៩ ខែមករា ឆ្នាំ ១៩៥៥ មន្ត្រីសង្ឃទាំងឡាយ ក្នុងទីក្រុងទឹងខែត្រក្រៅ នៃព្រះរាជអាណាចក្រកម្ពុជា បានធ្វើការប្រជុំ អនុសំវច្ឆរមហាសន្និបាតទី ១១ នៅវត្តបទុមវតី, វត្តឧណ្ណាលោម ទឹងវត្តព្រះកែវមកិត ។

សន្និបាតនៅវត្តបទុមវតី

ថ្ងៃសៅរ៍ទី ៨ មករា ពេលម៉ោង ១៥, ៣០ នៅក្នុងព្រះវិហារ វត្តបទុមវតី មានការជួបជុំមន្ត្រីសង្ឃទឹងចៅអធិការ ខាងគណៈធម្មយុត្តិ ក្នុងព្រះរាជធានី ដែលមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក ព្រះ ព្រហ្មមុនី អ៊ូ ជាចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ ទឹងព្រះអរិយកស្សប អ៊ូច ជាដើម ដោយមានឧបាសក ឧបាសិកាជាច្រើននាក់អញ្ជើញមក ជួបជុំផង ។ ការសន្និបាតនៅវត្តនេះ ធ្វើឡើងក្រោមអធិបតីភាពនៃ ឯកឧត្តម ប៉ាល់ ផួន រដ្ឋលេខាធិការក្រសួងធម្មការ ទឹងសម្តេចព្រះ សុធម្មាធិបតីសង្ឃនាយក ។

កាលមន្ត្រីសង្ឃនិមន្តមកជួបជុំហើយ ឯកឧត្តម ប៉ាល់ ផួន ដែល មានលោកឈុន-យ្យើន នាយកការិយាល័យអមធង កឹបានអញ្ជើញ

មកដល់ហើយចូលទៅថ្វាយបង្គំព្រះសង្ឆខាងក្នុងព្រះវិហារ ។ រួចហើយ ឯកឧត្តមបានសន្ទនាជាមួយនឹងមន្ត្រីសង្ឆ ខាងផ្នែកសាសន សិក្សាដែលប្រទេសយើងក្នុងសម័យនេះ កំពុងត្រូវការអ្នកចេះដឹងត្រប់ផ្នែកទាំងផ្លូវលោក ទាំងផ្លូវធម៌ ដើម្បីតាំទ្រដ្ឋឲ្យសមតាមកិត្តិយស ។ ការប្រស៊ីយរវាងឯកឧត្តម ប៉ាល់-ជួន នឹងមន្ត្រីសង្ឆ នៅវត្តបទុមវតីនេះ អស់ពេល ២៥ នាទី ។ បន្ទាប់ពីនោះមក ឯកឧត្តមអញ្ជើញទៅវត្តឧណ្ណាលោម ។

សន្ទិបាតនៅវត្តឧណ្ណាលោម

នៅថ្ងៃដដែល វេលាម៉ោង ១៦ មន្ត្រីសង្ឆគណ:មហានិកាយមានសម្តេចព្រះមហាសុមេធាធិបតី សង្ឆនាយក, សម្តេចព្រធម្មលិខិតឧត្តម-ប្រឹក្សាវត្តលង្កា, ព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ នឹងរាជាគណ: ហានានុត្រិម ក្នុងទីក្រុង ព្រមទាំងមេគណ, អនុគណ ចៅអធិការជាដើមក្នុងព្រះរាជអាណាចក្រទាំងមូល បាននិមន្តទៅជួបជុំនៅជាន់ខាងក្រោមនៃមហាកុដិ ។ ការសន្ទិបាតនេះ ធ្វើឡើងក្រោមអធិបតីកាពនៃឯកឧត្តម ប៉ាល់-ជួន រដ្ឋលេខាធិការក្រសួងធម្មការ នឹងសម្តេចព្រះមហាសុមេធាធិបតី សង្ឆនាយក ។

ឯកឧត្តម ប៉ាល់-ជួន កាលអញ្ជើញចេញពីវត្តបទុមវតី ចូលទៅកាន់ទីសន្ទិបាតសង្ឆវត្តឧណ្ណាលោមហើយ ក៏ថ្វាយបង្គំសម្តេច នឹងព្រះសង្ឆ រួចមានប្រសាសន៍ប្រស៊ីយចំពោះព្រះថេរានុត្តេរជាកិច្ចបដិសណ្ឋារ, បន្ទាប់មក ក៏ចាប់ផ្តើមបើកឧកាសប្រជុំ ដោយថ្ងៃងទទួល

អំណរចំពោះការនិមន្តមកនៃព្រះសង្ឆត្រប់អង្ត ក្នុងព្រះរាជអាណាចក្រ ដែលទំយកព្រះទ័យទុកដាក់ដល់ទីប្រជុំ ដើម្បីរិះរកមធ្យោបាយ ឲ្យកើត មានវិវឌ្ឍន៍ក្នុងផ្នែកសិក្សា ចំពោះព្រះពុទ្ធសាសនា ។

បន្ទាប់ពីឯកទត្តមមក, សម្តេចព្រះមហាសុមេធាធិបតី សង្ឆនាយក បានមានថេរដីកាពន្យល់ដល់ទីប្រជុំអស់ពេលយ៉ាងយូរ អំពីពាក្យពេចន៍ ទូះដែលមេគណ, អនុគណ បានធ្វើមកដោយឃ្វៀងឃ្វាត ពុំត្រូវតាម រាជស័ព្ទ តាមដើមកំណើតស័ព្ទ អំពីកិច្ចសិក្សាខាងធម្មវិន័យ; នៅទី បំផុត សម្តេចបានរិះរកមធ្យោបាយ ឲ្យបានស្ថូលដល់សិស្សសមណ: ដែលប្រឲ្យងប្រដែងខាងធម្មវិន័យ ។ មុននឹងបញ្ចប់ សម្តេចបានមាន ថេរដីកាសុំឲ្យព្រះសង្ឆដែលនិមន្តមកពីគ្រប់វត្តក្នុងព្រះរាជធានី នឹងគ្រប់ ខេត្ត រួមព្រះទ័យជាមួយនឹងលោកទ្ធិសព្រះរាជកុសលថ្វាយចំពោះ ព្រះប្រិយមហាក្សត្ត ដោយស្វាធ្យាយធមិ ប្រសិទ្ធិពរថ្វាយដោគជ័យ ជាដើម ។ ការធ្វើអនុសំវច្ឆរសន្និបាត នៅវត្តទណ្ណាលោម បានបញ្ចប់ នៅម៉ោង ១៨ គឺម៉ោង ៦ រសៀល ។

មហាសន្និបាតនៅវត្តព្រះកែវមក៉ត

នៅថ្ងៃអាទិត្យទី ៩ មករា ឆ្នាំ ១៩៥៥ មន្ត្រីសង្ឆ នឹងចៅអធិការ ព្រមទាំងកិត្ទុសាមណេរ ទាំងក្នុងក្រុង ទាំងខេត្ត៖ក្រៅ ទាំងគណ:ធម្ម-យុត្តិ ទាំងគណ:មហានិកាយ បានប្រជុំមួយលើកទៀត ជាប្រជុំធំនៅវត្ត ព្រះកែវមក៉ត ក្រោមព្រះរាជាធិបតីកាពនៃព្រះករុណាជាអម្ចាស់ជីវិតលើ

ត្សង ។ មុនពេលដែលព្រះមហាវីរក្សត្រសេ្ពចយាងដល់, ព្រះសង្ឆ
ទាំងពីរគណ: បានចំរើនសត្តប្បករណ៍ ទទ្ធិសថ្វាយព្រះរាជកុសលចំពោះ
ព្រះបិតរ គឺបុព្វរាជាដែលសោយព្រះទីរង្គតហើយ ដែលដំកល់ព្រះអដ្ឋិ
ធាតុទុកនៅព្រះចេតិយក្នុងវត្តព្រះកែវមកិត ។

នៅម៉ោង ៩ នឹង ១៥ នាទី សមាជិកព្រ រាជរដ្ឋាភិបាល ដែលមាន
ឯកឧត្តម ប៉ែន-នុត ជានាយក, ឯកឧត្តម យិត-ស្រុន ប្រធានក្រុម
ប្រឹក្សាជាតិ, សមាជិកក្រុមប្រឹក្សាជាតិ ឯកឧត្តមញ្ញឹក-នូវ ចាងហ្វាង
ពិធិការក្នុងព្រះបរមរាជវាំង នឹងមន្ត្រីក្រសួងធម្មការ សុទ្ធសឹងស្ត្រីកពាក់
សំពត់តាមប្រវិតណីជាតិ បានអញ្ជើញទៅឈរតំរៀបជាជួរនៅមាត់ទ្វារ
ព្រះកែវមកិតរង់ចាំថ្វាយបង្គំទទួលព្រះមហាវីរក្សត្រ ។

ម៉ោង ៩ នឹង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្សង បាន
សេ្ពចយាងដោយព្រះទីនាំងរថយន្ត ដល់មាត់ទ្វារព្រះកែវមកិត ដោយ
មានឯកឧត្តម អ៊ុំ-ឈាង-ស៊ុន ក្រុមប្រឹក្សាឯកជនអមព្រះអង្គ, លោក
ឌ៉ សាត លេខាធិការផ្ទាល់ព្រះអង្គ នឹងលោកវរសេនីយត្រី មាស-ហ៊ុល
នាយទាហានបង្គាប់ការផ្ទាល់ព្រះអង្គ បានអញ្ជើញហែធង ។ ក្នុង
ខណ:នោះ គណ:រដ្ឋមន្ត្រីក៏បានថ្វាយបង្គំ ហើយដង្ហែព្រះអង្គជាមួយនឹង
ក្រុមតម្ងួតបន្ទមកទៀត ។ ក្រោយដែលក្រុមភ្ងេង នឹងក្រុមទាហានរក្សា
ព្រះអង្គ ប្រគំបទភ្ងេងនគរាជធ្វើគារវកិច្ចរួចហើយ, ព្រះរាជាបានសេ្ពច
យាងចូលទៅក្នុងមន្ទីរព្រះសទ្ធម្ម ដោយដោះទ្រនាប់ព្រះបាទ គង់ប្រថាប់
ផ្ទាល់កម្រាលព្រះរាជាសន: ហើយព្រះមហាក្សត្រថ្វាយបង្គំព្រះសង្ឆ

ដែលមានសម្តេចតំាងជីព្រះអគ្គជាប្រធាន ។ ដើម្បីជាកិច្ចប្រែស្រួយចំពោះ
ព្រះសង្ឃ ដែលបានមិមន្តមកប្រជុំអនុសំវច្ឆរមហាសន្និបាតទី ១១ នេះ
ព្រះនរបតីបានរៀនព្រះពាជនុច្ចារន្ទូវព្រះបន្ទូលសូរសីហនាទ យ៉ាងវែង
ហើយយ៉ាងជាក់ច្បាស់ទៅកាន់ព្រះសង្ឃទំងឹគហស្ថ នូវស្ថានការណ៍កង
ប្រទេសនឹងក្រៅប្រទេស ។ ក្នុងទីបំផុត ព្រះមហាវីរក្សត្របានមាន
ព្រះពាជនុច្ចារន្ទូបបញ្ជាក់ថា អនាគតនៃប្រទេសយើងមានស្ថានភាពគួរ
ឲ្យព្រួយបារម្ភ ការបើអ្នកនយោបាយចេះតែឱ្យរឿយៗនាំកាន់
ភស្តុឲ្យឃល់ឃ្លាងពីស្ថានការណ៍ពិត ។ ព្រះពាជនុច្ចារន្ទូវព្រះបន្ទូល
សូរសីហនាទយ៉ាងវែងនេះ បានបញ្ចប់នៅម៉ោង ១១ នឹង ២១ នាទី
ព្រះសង្ឃបានស្តាប្យាយទំព្ញមន្តដយន្តោ ប្រសិទ្ធីពរជ័យ ចំពោះព្រះ
កូមិន្ទូជាទីបញ្ចប់កិច្ច ។ ព្រះពាជាបានស្តេចយាងត្រឡប់ទៅកាន់ព្រះ
បរមពាជវាំងវិញ ដោយមានឥស្សរជនដដែលដង្ហែអមព្រះអង្គផង ។

មន្ត្រីសង្ឃដែលមិមន្តមកប្រជុំអនុសំវច្ឆរៈមហាសន្និបាតនេះ បាន
ទៅទទួលភត្តាហារថ្ងៃត្រង់នៅកង់មហាកុដិវត្តឧណ្ណាលោម កង់ព្រះបរម-
នាមនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង នឹងកង់នាមនៃឯកឧត្តមរដ្ឋ-
លេខាធិការក្រសួងធម្មការ ។

ពុទ្ធសាសនបណ្ឌិត្យ

តំណើរបុណ្យទក្ខិណានុប្បទាន

របស់ព្រះសាសនមុនី មាស-កឹង ចៅអធិការវត្តពិកទូរង្សី

ព្រះវិនយធរអង្គុគណ ឯក-ញឹម

រៀបរៀង

កាលពីថ្ងៃសៅរ៍ - អាទិត្យ ១២-១៣ កើតខែអស្សុជ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃ ១០-១១ ខែតុលា ឆ្នាំ ១៩៥៤ ព្រះសាសនមុនី មាស-កឹង ភជាគណៈជាន់ទោ ចៅអធិការវត្តពិកទូរង្សី សង្កាត់លេខ ២ ក្រុងកំពតពេញ បានធ្វើបុណ្យទក្ខិណានុប្បទានជាឧទ្ទិសកុសលដល់វត្តពិកទូរង្សី ដើម្បីឧទ្ទិសផលប្រគេន-ជូនចំពោះគ្រូឧបជ្ឈាយាចារ្យ ទាំងមាតាបិតា របស់លោក ដែលទទួលអនិច្ចធម្ម-អនិច្ចកម្មទៅយូរឆ្នាំហើយ ។

លើកទី ១ ថ្ងៃសៅរ៍ ១២ កើតឆ្នាំមមី ពេលព្រឹកមានរៀបពិធីតាំងគ្រឿងសក្ការៈដោតទង់ជ័យជាក់ផ្កាថ្វាយត្រៃរតនត្ត័យ ដើម្បីអភិសេកព្រះពុទ្ធរូបថ្មពណ៌សខ្ពង់ឈរបិណ្ឌបាត ២ ព្រះអង្គដែលទើបទទឹងសាងថ្មី ព្រមទាំងរៀបក្រងផ្កាពណ៌ឆ្មេង ។ មានផ្កាចំប៉ាជាដើម ធ្វើជាស៊ុមចងព័ទ្ធជុំវិញ ។ ឆាយារូបទាំង ៤ គឺរូបព្រះសេតព្រះពោធិរង្សី ទេព ១ រូបព្រះសេតញ្ជិក ១ រូបព្រះសង្ឃនាយកសង្ឃ ហាស់-មាស ១ រូបឧបាសិកា សួរ-យ៉ុន ១ ដែលដាក់តាំងជាប់ជួរលំដាប់ពីខាងឆ្វេង ទៅខាងស្តាំអមពុទ្ធាសនៈ នៅកន្លែងឧបដ្ឋានសាលាធ្វើបុណ្យ បើយើញគួរឱ្យជ្រះថ្លា ។ ការក្រងផ្កានេះជាស្នាដៃយាយ ។ នៅរៀនធម៌ជួយឧបត្ថម្ភ ។

លុះដល់ម៉ោង ២០ ពួកឧបាសក ឧបាសិកា ជួបជុំនមស្សការ។ រួចហើយព្រះវិន័យធរអនុគណ ឯក ញិម ចៅអធិការវត្តធម្មិស្សរារាម ខែត្រសៀមរាប ក្រោកឈរឡើងថ្វែងសុន្ទរកថា តាងនាមព្រះសាសនមុនីមហាថេរជាដើមបុណ្យ, ក្នុងផ្ទៃនៃសុន្ទរកថានោះ មានរៀបរាប់ប្រវត្តិត្រៃបុគ្គល នឹងឧទ្ទិសផលជូនទៅបុព្វការីនៃលោកនឹងថ្វាយព្រះរាជកុសលចំពោះព្រះករុណាព្រមទាំងព្រះរាជវង្សានុវង្ស នឹងជូនភាគឧត្តមផលដល់លោកអ្នករាជការគ្រប់ក្រសួងគ្រប់ដំណែង ព្រមទាំងសហការីជាភ្នាក់ងារនៃរាជការនោះ។ លុះចប់ហើយក៏ឡើងត្រែទេសនារំលឹកស្មារតីលោកអ្នកមកជួយផ្ទើបុណ្យនឹងកតញ្ញូកតវេទិតាធម៌ ចំនួន ១ ម៉ោង ។ លុះដល់ម៉ោង ២២ និមន្តព្រះបាឡាត់ ឆិម វត្តមហាមន្ត្រី ភ្នំពេញ ទេសនាតទៅទៀតចំនួន ១ ម៉ោង ។ ហើយឈប់សម្រាកម្តងក្នុងរាត្រីនោះ លុះដល់ម៉ោង ៥ · ៣០ និមន្តព្រះមហាថេរដែលមកពីវត្តក្រៅក្រុង ២០ អង្ត សូត្រថ្វាយពុទ្ធជយមង្គល ដល់ព្រះពុទ្ធរូបដែលសាងថ្មីនោះ ។

សុន្ទរកាថា

សូមថ្វាយបង្គំ ចំពោះសម្តេច ដោយគោរព,
សូមថ្វាយបង្គំ ដល់ព្រះថេរានុត្តេរ. ទាំងឡាយ,
សូមជំរាប ឯកឧត្តម ព្រះតេជព្រះគុណនឹងលោកអ្នកទាំងឡាយ!

សូមទានជ្រាប, សូមជ្រាប ។

ខ្ញុំព្រះករុណា អាត្មាភាព សូមឧកាសថ្វែងសុន្ទរកថា តាងនាមព្រះតេជព្រះគុណ ព្រះសាសនមុនី នឹងជាដំណាងនាមពុទ្ធបរិស័ទទាំងឡាយ

ជាចំណុះវត្តពិតទូរនឹងនេះដែលធ្វើបុណ្យទុទ្ទិសផលដល់ព្រៃបុគ្គល, ហេតុនេះ សូមសំគាល់ភ្ញាក់ថា ជាភ្ញាក់ចារបស់លោកថ្ងៃនេះដោយព្រះអង្គឯង ។

សម្តេច - ឯកឧត្តម - អស់លោកអ្នកគាំង ឡាយ !

បុណ្យនេះជាបុណ្យរំលឹកឧបការគុណមាតា-បិតាគ្រូឧបជ្ឈាយាចារ្យផង, ជាបុណ្យធ្ងន់អាយុសង្ខារបស់ខ្លួនដែលកន្លងទៅហើយបាន ៦៣ ឆ្នាំ នឹងឆ្នាំនេះផង ទើបធ្វើឲ្យមានចីវរទាន, បិណ្ឌបាតទាន, សេនាសនទាន, ភេសជ្ជទាន, ជាអាមិសទាន នឹង ធម្មទាន ដោយធនធានរបស់ខ្លួនខ្លះ, ដោយសេចក្តីឧបត្ថម្ភរបស់សិស្សានុសិស្ស នឹងលោកអ្នកដែលជាឧបាសក ឧបាសិកា ព្រមទាំងកល្យាណមិត្តទាំងឡាយខ្លះ, ដែលបានជួញចិត្តចូលខ្លួនមកជួយឧបត្ថម្ភដោយកម្លាំងកាយនឹងធនធាន, ខ្ញុំព្រះករុណាអាត្មាភាព មានមនោសញ្ចេតនាសោមនស្សត្រេកអរក្រៃពេកដែលឆ្លងកន្លងដំណើរសម្តេច, ព្រះករុណា គ្រប់អង្គ ឯកឧត្តមនឹងអស់លោកទាំងឡាយដែលបានទិមន្តនឹងអញ្ជើញមកជាកិត្តិយសដ៏ប្រសើរក្នុងបុណ្យនេះ, មិនមែនតែខ្ញុំព្រះករុណាអាត្មាភាពម្នាក់ឯងទេត្រេកអរនេះ ទាំងលោកជាក្រុមពុទ្ធបរិស័ទក្នុងវត្តនេះទាំងមូលក៏ត្រេកអរដូចគ្នា, សូម្បីតែសាលាបុណ្យដែលជាវត្ថុមិនមានវិញ្ញាណ ក៏ប្រដាប់ខ្លួនដោយថ្មីជាដើម ទទួលអំណរលោកក្នុងពេលនេះដែរ ។ ខ្ញុំព្រះករុណាអាត្មាភាពបានឃើញធម្មជាតមនុស្សសត្វក្នុងលោកនេះតែងជ្រកនៅក្រោមម្លប់ ៤ ប្រការ គឺ: ១ – រុក្ខជាតិ ម្លប់ឈើនានាដែលមានមែកត្រសុំត្រសាយសាខា នៅវេលាក្តៅមនុស្សសត្វដើរចូលទៅជ្រក ក៏ឈើនោះឲ្យជ្រកបានខ្លួទៅផត

រើសមុខ, ហើយអាចបាំងកំដៅថ្ងៃឲ្យអ្នកជ្រក បានសុខកាយសប្បាយ
ចិត្តឥតមានប្រៃប្រួល; ៦– មាតាញាតិធាយា មួប់មាតាបិតាជីដូន
ជីតាញាតិសាលោហិត អាចបាំងបិទកំដៅឲ្យជ្រកនៅបានតែត្រឹមកូនចៅ
ផៅពង្សវង្សត្រកូលរបស់ខ្លួន, ៣– អាចរិយធាយា មួប់ត្រូអាចារ្ស
ក៏អាចការពារបិទបាំងបានតែត្រឹមសិស្សានុសិស្សរបស់ខ្លួនប៉ុណ្ណោះ មិន
ទូទៅដល់សិស្សត្រូដ៏ទៃឡើយ, ៤– ពុទ្ធធាយា មួប់ព្រះពុទ្ធសាសនា
ជាមួប់ធំទូលាយក្រៃលែង តាមតែមនុស្សបែបណាជាតិណា ស្វែងមក
ពីទិសណាទីណាក៏ដោយ តែចូលមកជ្រកហើយ មួប់ព្រះពុទ្ធសាសនា
ក៏អាចបិទបាំងការពារកំដៅគឺក្ងើងទុក្ខក្ងើងកិលេស ដែលធាបធេះសព្ទ
សត្ទចូលជ្រកឲ្យត្រជាក់បានត្រប់ៗ ត្នា ។

មួប់ទាំង ៤ ប្រការដូចថាមកនេះឈ្មោះថាបានធ្វើឧបក្ការគុណមុន
លើមនុស្សអ្នកចូលជ្រក, ហេតុនេះអ្នកជ្រកត្រូវដឹងគុណ ត្រូវធ្វើតប
ឧបការគុណវិញ; បើជ្រកនៅក្រោមដើមឈើណា បុរាណថាមិនត្រូ
ស្ទោះសម្បកកាប់មែកហែកបណ្ត្ចូលឈើនោះឡើយ; បើមួប់មាតាបិតា
ជីដូនជីតាញាតិសាលោហិតវិញ ក៏កូនចៅអ្នកជ្រក ត្រូវគោរពកោតខ្ជាច
លោក ហើយប្រតិបត្តិលោកដោយជូនអាហារបាយទឹកនំចំណីនឹងគ្រឿង
ស្ងៀកពាក់ជាដើម; បើមួប់ត្រូអាចារ្ស សិស្សអ្នកជ្រក ត្រូវគោរពកោត
ខ្ជាច ត្រូវប្រតិបត្តិលោក ដោយធ្វើកិច្ចវត្តផ្សេងៗ មានអាចារិយវត្តជា
ដើម, បើមួប់ព្រះពុទ្ធសាសនាវិញ ពួកពុទ្ធបរិស័ទត្រូវគោរពកោតខ្ជាច
ប្រតិបត្តិឲ្យត្រូវតាមគារវធម៌ ៧ ប្រការ មានពុទ្ធគារវតាជាដើម ។

ដោយហេតុនេះខ្ញុំព្រះករុណា សូមឧកាសរៀបចាប់ប្រវត្តិឧបការគុណនៃព្រៃបុគ្គលរបស់ខ្ញុំខ្ញី ។ ប្រគេន - ជូនស្តាប់ឲ្យឃើញជាក់ស្តែងតាងតៅ

១ - លោកស៊ូ-យិន ជាមាតាគឺញោមស្រីខ្ញុំ លោកមានចិត្តអាណិតអាសូរចិញ្ចឹមបីបាច់ថែរក្សាស្នេហាស្រឡាញ់ថ្នុតថ្នមខ្ញុំ ក្នុងក្រមគ្រួសានេះជាងគេទាំងអស់ ចាប់តាំងពីខ្ញុំជ្រកនៅក្រោមម្លប់លោកគឺតាំងពីខ្ញុំជ្រកនៅក្នុងផ្ទៃលោកដរាបរៀងមក ។

២ - លោកព្រះសម្ពាងសារពេជ្រ ហាស់-មាស ជាបិតា គឺជាញោមប្រសខ្ញុំ លោកបានចិញ្ចឹមបីបាច់ថែរក្សាខ្ញុំដោយថ្នុតថ្នមលោកបានទាំងបង្រៀនវិជ្ជាអក្សរសាស្ត្រ ទឹងលេខដល់ខ្ញុំដោយទឹកចិត្តអាណិតអាសូរប្រកបដោយព្រហ្មវិហារ ដរាបដល់ខ្ញុំបានចេះដឹងវិជ្ជាជ្រើការធ្វើជាស្មៀនតត់ត្រាដោយលេខនឹងក្យបាន លោកឥតដែលមានជេរស្តីប្តាយទេតប់ ប្តូកបន្តុះបង្អាប់ដល់ខ្ញុំម្តងឡើយ; លោកមាតាលោកទាំងបិតាទាំងពីរនេះ ចាប់តាំងពីខ្ញុំមកជ្រកនៅក្រោមម្លប់លោក ។ ឲ្យសេចក្តីសុខដល់ខ្ញុំរៀងមកដរាបដល់ថ្ងៃលោកទទួលមរណភាពតៅ ។

ឯខ្លួនខ្ញុំជាកូនវិញ ចាប់តាំងពីថ្ងៃដឹងក្តីរហូតមក មិនដែលធ្វើឲ្យឃើញសយ្យងហ្មងគ្មងដល់ចិត្តលោក តែងតែជួយធ្វើការងារ ទឹងចិញ្ចឹមបីបាច់ថែរក្សាតបឧបការគុណលោកទាំងពីរវិញ ដរាបដល់លោកចាស់ដរាបនៅវេលាមានជម្ងឺម្តង។ ខ្ញុំបានរកថ្នាំទឹងគ្រូពេទ្យមកជួយព្យាបាលភេតលោកលុះដល់លោកទទួលមរណៈតៅ ។ ញោមស្រីជន្មាយុ ៨៥ ឆ្នាំ អនិច្ចកម្មក្នុងឆ្នាំជូតទោស័ក ព.ស. ២៤៩១ បើកប់មកដល់ ព.ស. ២៤៩៧

នេះលោកអនិច្ចកម្ម ៧ ឆ្នាំហើយ; ញោមប្រុសជន្មាយុ ៨២ ឆ្នាំ អនិច្ចកម្ម ក្នុងឆ្នាំថោះបញ្ចស័ក ៣ ស. ២៤៨១ ហើរាប់មកដល់ ៣.ស. ២៤៩៧ នេះលោកទទួលអនិច្ចកម្មទៅ ១៦ ឆ្នាំហើយ; កាលលោកទាំងពីររស់នៅ ទ្បើយ ខ្ញុំបានទបត្ថម្ភលោក ឲ្យលោកស្ថិតនៅក្នុងសីលធមិនឹងសមាធិ ដ៏មាំមួន លោកបានធ្វើខ្ជួនលោកឲ្យជាទីពឹងខ្ជួនបានក្នុងសីលសមាធិធមិ ។

ខ្ញុំតងទំនុកបំរុងផ្គត់ផ្គង់លោកដោយកិច្ចត្រប់យ៉ាង មានជួនបាយទឹក នំចំណីជាដើម លុះដល់លោកមរណភាពទៅ ខ្ញុំបានរៀបចំធ្វើបុណ្យ រំលាយសពលោកទាំងពីរជាទឡាវិក ដ៏សមគួរតាមហានៈរបស់លោក ដែលខ្ញុំជាកូនត្រូវធ្វើដោយសេចក្តីគោរព ក្នុងទីបំផុតជីវិតរបស់លោក ទាំងពីរនោះ ។ ខ្ញុំបានកសាងចេតិយយកអដ្ឋិធាតុរបស់លោកមកធ្វើបុណ្យ ហើយបញ្ចុះទុកជាអនុស្សាវរីយ៍ក្នុងទីវត្តនេះ ខ្ញុំតងនាំក្រុមញាតិធ្វើបុណ្យ ទក្ខិណានុប្បទាន ទទ្ធិសផលជូនរៀយ ។ រាល់ ។ ឆ្នាំ ។

៣ - ឯព្រះតេជព្រះគុណ ព្រះសពព្រះពោធិវង្ស ទេព លោក ជាត្រូទបជ្ឈាយ៍របស់ខ្ញុំ ជាប់តាំងពីសាមណេរមក ដរាបដល់ទបសម្បទា ជាភិក្ខុ, ហើយព្រះអង្គលោកជាត្រូកម្មដ្ឋានាចារ្យធំមួយក្នុងកម្ពុជប្រទេស នេះ, ខ្ញុំបានរៀនសមថកម្មដ្ឋានអំពីលោក ។ បានបង្រៀនខ្ញុំឲ្យបានចេះ ដឹងដរាបដល់ធ្វើជាត្រូបង្រៀនគេទៀតបាន លោកតែងរំលឹកជាស់តឿន ខ្ញុំឲ្យធ្វើល្អ ឲ្យបានត្រឹមត្រូវតាមផ្ជូវសីលធមិ ដោយទឹកព្រះទ័យប្រកប ដោយមេត្តា ឥតដែលមានជេរស្តីបន្ទោសថាអ្វីដល់ខ្ញុំទ្បើយ, មិនតែ

ប៉ុណ្ណោះបានតាំងឲ្យខ្ញុំម នសមណស័ក្តិ ជាទីព្រះសមុហ៍ពោធិបញ្ញា ក្លាប់
តាមដំណែងសមណស័ក្តិរបស់លោក ។

ខ្ជូនខ្ញុំជាសិស្សតែងតែធ្វើកិច្ចវត្តនានាជល់លោក មានគក់ច្របាច់ជា
ប្រក្រតី នឹងកិច្ចវត្តជទៃ ។ ខ្ញុំគោរពប្រតិបត្តិលោក ឥតដែលមានឲ្យ
ឃ្នើសឃ្នងព្រះទ័យឡើយ ខ្ញុំជាសទ្ធិវិហារិករបស់លោកជាសិស្សផ្ទាល់
ព្រះអង្គបម្រើលោក គ្រប់កិច្ចការជរាបជល់លោកចាស់ជរាជន្មាយុ ៩៥
ឆ្នាំ ក៏ចាប់មានអាពាធជាទម្ងន់ ខ្ញុំបានចាត់ការរកថ្នាំ រកគ្រូពេទ្យខ្ចៃ-
បាកំងមកព្យាបាលរោគ តែព្រះអង្គលោកពុំព្រមឲ្យពេទ្យមើលសោះ
ឡើយ ឧសថក៏លោកមិនព្រមធាន់ផង, ក្នុងរវាង ១០ ថ្ងៃប៉ុណ្ណោះ ក៏
លោកទទួលអនិច្ចធម្មទៅ ដោយរោគជរា ក្នុងជន្មាយុ ៩៥ ឆ្នាំ លោក
អនិច្ចធម្មក្នុងឆ្នាំមមី ឯកស័ក ព.ស. ២៤៦២ បើរាប់ពីត្រឹមនោះមកជល់
ព.ស. ២៤៩៧ នេះ ៣៥ ឆ្នាំហើយ; ខ្ញុំក៏ទំចាត់ការធ្វើបុណ្យបូជាសព
លោកជាបួយនឹងសិស្សានុសិស្ស តាំងគ្រហស្ថតាំងបព្ចជិតយ៉ាងធំអស្ចារ្ស
ជាទឡ្ឆារិក ឲ្យបានសមតាមហានៈរបស់លោក រួចហើយរើសអដ្ឋិធាតុ
កសាងព្រះចេតិយធ្វើបុណ្យអភិសេកព្រះពុទ្ធរូប បញ្ចុះអដ្ឋិធាតុទុកជា
អនុស្សាវរីយ៍ ក្នុងទីចេតិយនៅព្រះលានមុខព្រះវិហារវត្តពិកទួរង្សីនេះ
ជរាបជល់សព្វថ្ងៃ; ខ្ញុំមានចិត្តចាំឧបការគុណលោកជាបុព្ចបុរសតាំងបីឥត
ភ្លេច បីជួចជាគេធ្វាក់ក្លាប់ទុកក្នុងហ្ហ្ហ៍ទ័យ ទើបផ្តើមធ្វើបុណ្យរំលឹកគុណ
លោក ក្នុងគ្រានេះជាទឡ្ឆារិក; ក្នុងពេលនេះ ខ្ញុំសូមរំលឹកអស់លោក
ជាពុទ្ធបរិស័ទតាំងឡាយសូមតាំងព្រះទ័យ សូមតាំងចិត្តប្រតបដោយ

មេត្តាការុញ្ញភាព ហ៊ីយសម្ងឹងមើលទៅធាយារូបទាំង ៤ ដែលតាំងទុក
ពីមុខនោះ សម្រឹងជញ្ជឹងព្រះនៃត្រលក្ខណ៍ សម្រាកស្ងៀមចំនួន ១ នាទី
តាំងចិត្តផ្សាយទត្តមផលដល់លោកដោយមនោសម្ជស្សជា ត្រប់ៗត្នា ។
(ឈប់សម្រាក ១ នាទី ហ៊ែរមុខចំទៅធាយារូបទាំង ៤) ។

ញោមទាំងពីរ! ព្រះតេជព្រះគុណព្រះសព! ខ្ញុំព្រះករុណា
អាត្មាភាព ជាកូនមានដួងចិត្តមមៃនឹកឃើញច្ឆាស់នូវទបការគុណលោក
ថ្នីៗ ជាប់នៅក្នុងចិត្តជានិច្ច ឥតបាត់សោះឡើយ ។

ពិតមែនតែរូបញោម រូបព្រះតេជព្រះគុណរលាយបាត់ទៅ តែ
អំពើល្អដែលបានកសាងហ៊ីយនោះ នៅជាប់ហ៊ីដូចជាគេធ្លាក់ទុកក្នុង
ដួងហ្ឫទ័យនៃខ្ញុំព្រះករុណា អាត្មាភាព ឥតបាត់បន្ទិចបន្ទួចឡើយ ។

សូមញោម សូមព្រះតេជព្រះគុណជ្រាបថាក្នុងថ្ងៃ ១៦-១៧ កើត
ខែអស្សុជនេះកូនបានធ្វើបុណ្យ ទទ្ធិសផលជូន-ប្រគេនទៅ សូម
អញ្ជើញ សូមនិមន្តមកទទួលយកភាគទត្តមផលនេះ សោយសេចក្តី
សោមនសស្សតាមសមគួរដល់សេចក្តីប្រាថ្នាកុំបីខានឡើយ ។

ម្យ៉ាងទៀត ក្រុមពុទ្ធបរិស័ទទាំងឡាយក្នុងទីវត្តពិភទូរង្សីនេះ
សូមទទ្ធិសកុសលក្នុងបុណ្យនេះអំពីចម្ងាយថ្ងាយព្រះករុណា ជាព្រះ
ប្រិយមហាក្សត្រិយ៍ ព្រមទាំងព្រះវររាជបិតា ព្រះវររាជជនន៊ីនាថ នឹង
ព្រះរាជវង្សានុវង្ស នឹងឯកទត្តមរដ្ឋមន្ត្រីត្រប់ក្រសួង ព្រមទាំងលោកអ្នក
រាជការត្រប់ដំណែង ព្រមទាំងសហការីនៃអស់លោកនោះៗផង សូម
ឲ្យបានស្ថិតនៅក្នុងសេចក្តីសុខដែលកើតពីសុចរិតយុត្តិធម៌ ហ៊ីយឲ្យបាន

ប្រកបដោយយសស័ក្តិសិទ្ធិវិទ្ធិតេជ: ឈ្នះអស់ពួកសត្រូវដែលស្ថិតនៅគ្រប់ទិសជាស្ថាពរតទៅ ។

នៅទីបំផុតនេះ ទ្ធិព្រះករុណាអាត្មាភាពសូមអរគុណ សូមប្រគេនសូមជូនបុណ្យ ដល់អស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ដែលបានជួយទ្ទល់ទ្ទាយដោយកម្ចាំងកាយនឹងកម្ចាំងធនធាន ឲ្យបុណ្យនេះបានរុងរឿងឡើងដល់ប៉ុណ្ណេះ, សូមកុសលនេះជួយទ្រទ្រង់អស់លោកគ្រប់គ្នាឲ្យបានជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចំរើន តាំងពីពេលនេះតទៅដរាបដល់បានសម្រេចមគ្គផលព្រះនិព្វានជាអវសានជាតិកុំបីឃ្ចាតឡើយ ។

ពាក្យនេះបើអស់លោកយល់ព្រមជាសច្ចានុម័តិហើយ ក៏ចូរឲ្យសទូសញ្ញាថាសាធុ ៗ ព្រម ៗ គ្នាមកហោង ។

លើកទី ២ - ថ្ងៃអាទិត្យ ១៣ កើតខែឆ្នាំដដែល ពេលម៉ោង ៧-៣០ ព្រឹក ក្រុមនាក់ឧបត្ថម្ភក៍ជាប្រើនគ្នា បានរៀបចាត់ចែងយាគូគឹបបរប្រគេនព្រះសង្ឆបំនួន ៨៦ អង្គធាន់ នឹងពួកអ្នកមកជួយបុណ្យទាំងអម្បាលម៉ានចំនួន ១៥០ នាក់ ពីសាត់តទ្ទះទាតឡើយ ហើយដល់ទៅម្ហូបអាហារបិណ្ឌបាតក្នុងពេលថ្ងៃក៏មានលោកយាយ ៗតា ៗជាកម្មដ្ឋានសិស្សានុសិស្សនឹងក្រុមចំណុះដើងវត្តទាំងខ្មែរ, ចិន, យួន, ជួយផ្គត់ផ្គង់ជាប្រើនគ្នាទៀត, ឯទាងភេសជ្ជ: ក៏មានលោកអ្នកចាត់ចែងប្រគេនលោកគ្រប់ទាំងពីរថ្ងៃគឺថ្ងៃ ១២-១៣ កើត ។

លុះដល់ម៉ោង ១១ ព្រឹក ព្រះសង្ឆដែលនិមន្តមកពីវត្តក្រៅ ២៧ វត្តនឹងព្រះសង្ឆនៅក្នុងវត្តពិភទ្ធរង្សីរួមជា ៨០ អង្គ មានសម្តេចព្រះធម្មលិទិត

ទត្តមប្រឹក្សា ល្ងឹ-ឯម ចៅអធិការវត្តលង្ការក្រុងភ្នំពេញជាប្រធាន, ចូលទៅតង់ក្នុងទបជ្ជានសាលា ជាសាលាធ្វើបុណ្យនោះសូត្រសត្តប្យករ-ណាភិធម្មចប់ហើយ បង្សុកូលរួចស្រេចពួកទបាសកទបាសិកាលើកចង្ហាន់មកវេរភត្តប្រគេនព្រះសង្ឆ ៗ ធ្វើភត្តានុមោទនាចប់ ក៏ទទួសផ្សាយទត្តមផលប្រគេន-ជូនទៅបុព្វការីបុគ្គល គឺជួងវិញ្ញាណក្ខន្ធនៃសពជូចបានរាប់នាមក្នុងសុន្ទរកថាខាងលើស្រាប់ លុះលោកធ្វើភត្តកិច្ចរួចស្រេចហើយ ប្រគេនទេយ្យទានមានចីវរជាដើម នឹងជូនដំណើរលោកដោយរថយន្តខ្ទះ ដោយបរាវណាថ្ងៃយានជំនិះខ្ទះ រួចកិច្ចមួយលើក លុះដល់ម៉ោង ១៥ ពួកទបាសកទបាសិកាមកជួបជុំនមស្សការហើយ ក៏និមន្តព្រះសង្ឆរួចូលទៅក្នុងទបជ្ជានសាលាជាសាលាបុណ្យ ហើយនិមន្តព្រះគ្រូមង្គលរង្សីអនុគណ ឯល ចៅអធិការវត្តរកាកោងក្នុង ស្រុកមុខកំពូល ទៃត្រកណ្ណាល នឹងលោកព្រះគ្រូសង្ឆសុមេធ ធង-ភ្ងឹន វត្តទណ្ណាលោមក្រុងភ្នំពេញ ទេសនាសង្គាយនា ព្រះសង្ឆក្រៅពីនេះចំនួន ៥០ អង្គគង់ហត្ថបាស; លុះចប់ទេសនាហើយ ប្រគេនទេយ្យទានមានចីវរជាដើមដល់ព្រះសង្ឆគ្រប់ ៗ អង្គ ។

ឯទបាសកទបាសិកា នឹងក្រុមទបត្ថម្ភវត្ត មានលោកអាចារ្យជាដើមក៏នាំគ្នាទទួសផលរួចហើយ ទើបក្រុមរថយន្តជូនដំណើរ ក៏ចាត់ការជូនដំណើរលោកគ្រប់វត្ត ទៅជាក់តាមទីកន្ទែងវត្តដែលលោកនៅ, សម្រេចកិច្ចបុណ្យត្រឹមប៉ុណ្ណេះ ។

ឥន្ទ្រសទ្ទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមីនា លេខ ៣

ព.ស. ២៤៩៣ _ គ.ស. ១៩៤៤



ភម្ពសន្ទិយា

ទស្សនាវដ្ដី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ហ្វោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

	បញ្ជីរឿង	**ទំព័រ**
ផ្នែកសាសនា		
— វិចារណកថា	លោក ចាប-ពិន	១៦៣
— ភដវសតីកថា	ព្រះអាចារ្យ ហេន . ធឿង	១៦៩
— វិរុទ្ធវត្ថុកថា	ព្រះវិភទ្ធញ្ញាណ សោម-ឡុច ..	១៧៩
— បញ្ញាសជាតក ភាគទី ៣ (តមក)	បណ្ឌិតមហា ឈឹម -សុិម	១៨៥
ផ្នែកអក្សរសាស្ត្រ		
— រឿងសៅរសោយ (តមក)	ព្រះមហាឌត្តមវិជ្ជា ប៉ុង—ប៉ម ...	២០៣
— អនុស្សាវរីយ៍ ចំពោះ ព្រះបាទសម្តេច ព្រះនរោត្តម-សីហនុ រ៉ូវ្ឌន	លោក អ៊ុង-សុិមន៍	២១២
— រឿងសាមកុក (តមក)	ឈកញ៉ា នូ- កន	២១៦
— ដំណឹងតាមឲ្យល់ក្នុងកន្ទារៈ (តមក) ...	លោក ផេង-ជ្រីវ	២២២
— រឿងបល្ស៍ង្គទិព្យ (តមក)	លោក ភ៉យ- ប៊ុក	២២៩
កំណត់ទឹងប្រវត្តិការណ៍		
— ពិធីបុណ្យស្រោចទឹកចំរើន ព្រះជន្មសម្តេច ព្រះសុធម្មាធិបតី អ៊ុង-ស្រី សង្ឆនាយក គណៈធម្មយុត្តិ	អាចារ្យវត្តបទុមវតី	២៣៥
— បញ្ជីភាយនាមចៅអធិការដែលតាំងថ្មី (តមក)	ក្រសួងធម្មការ	២៣៩

មួយឆ្នាំមាន ១២ ស្យៀវភៅ — ដំឡៃដាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
Editorial	M. CHAP-PIN.	163
— Rajavasatikâtha.	Vén. HEN-THŒUNG	169
— Viruddhavatthukatha	Vén. SOM-LOCH	179
— Pannasajataka- vol.3 (suite) .	M. CHHIM-SOUM	185

PARTIE LITTERAIRE:

— Le «SAU SOY» ou l'influence saturnienne (suite)	Vén. PEUNG-PAM	203
— Souvenirs du Roi Norodom Sihanouk	M. OUNG-SOUM	212
— Histoire de samkok (suite). .	Oknha NCU-KAN	216
— Le souffle du désert (suite) . .	M. PHENG-CHRIV.	222
— Les trente deux récits du Trône (suite)	M. RAY-BUC	229

NOTES ET CHRONIQUES:

— Cérémonie du bain religieux de S. E le Chef de la secte Dammayutti	Achar vat Botoum-vaddey . .	235
— Nomination des nouveaux Chau-Adhikars (suite)	Ministère des Cultes . . .	239

Prix d'abonnement annuel (comprenant 12 numéros) 210$00

ជីវភាពពលរដ្ឋឯករាជ្យ

ឧបាសក ចាប - ពិន រៀបរៀង

សម័យនេះ ប្រទេសខ្មែរបានផ្ទាស់ស្ថានភាពជាប្រទេសឯករាជ្យ បរិបូណ៌ រួចរដោះចាកនឹមអាណានិគមហើយ, តែប្រជាជនខ្មែរមិនទាន់ផ្ទាស់ជីវភាពរបស់ខ្លួន ឲ្យសមជាពលរដ្ឋប្រទេសឯករាជ្យពេញទីនៅឡើយ ។

កាលប្រទេសខ្មែរនៅក្នុងនឹមអាណានិគម, ខ្មែរយើងបណ្តែតជីវភាពរបស់ខ្លួនទៅតាមតែគេជាអាណាព្យាបាល, ដល់ចុងឯករាជ្យពេញលេញដូចសព្វថ្ងៃ, ខ្មែរយើងមិនគប្បីបណ្តែតជីវភាពដូច្នោះទៀតទេ គប្បីតែរង្កើនខ្លួនរើខ្លួនឲ្យផុតចាកជីវភាពសម័យអាណានិគម; គួរនាដូចជនជាបាវគេឬកូនចៅនោះបន្តបន្តាយដូច្នេះ តែងតែបណ្តែតខ្លួនទៅតាមសេចក្តីដឹកនាំរបស់ចៅហ្វាយនាយឬមេបាគ្រួសារ, ប៉ុន្តែលុះគេបានរួចខ្លួនជាអ្នកជាឬជាអ្នកមានកិរិយាស្វាមី ជាមេបាគ្រួសារ តាំងខ្លួនផ្ទាល់ខ្លួនឯងគ្រាលណា គេមិនត្រូវបណ្តែតបណ្តោយខ្លួនដូច្នោះទៀតទេ, គេត្រូវតែពឹងខ្លួនគេជាជាប ហើយគេត្រូវតែផ្ទាស់ជីវភាពរបស់ខ្លួន ទៅតាមហានៈជាអ្នកជា ជាមេបាគ្រួសារ តាំងខ្លួនឲ្យមានដំហររឹងប៉ឹងឡើង ។

ពួកទេសចរ (អ្នកដើរពិនិត្យមើលប្រទេស) កាលគេចូលប្រទេសណា គេឃើញតែផ្ទះសម្បែងរបស់ប្រជាជន ដែលទុកជាស្រែមខាងស្រែ

របស់រដ្ឋ ហើយនឹងយើញតែសម្លៀកបំពាក់ឬកពាអាកប្បកិរិយារបស់ប្រជាជន ដែលទុកជាស្រោមខាងក្រៅរបស់ពលរដ្ឋ ក្នុងប្រទេសនោះ គេអាចទាយបានភ្លាមថាជាប្រទេសចំរើន ឬមិនចំរើន ដោយសារសំបកក្រៅរបស់ប្រទេសនោះឯងសំដែងប្រាប់ឲ្យគេស្គាល់បាន ។

ដូច្នេះ, នៅរៀលាដែលប្រទេសខ្មែរបានឯករាជ្យពេញទី អាចត្រប់ត្រងខ្លួនដោយខ្លួនឯងដូចសព្វថ្ងៃនេះ, ប្រជាជនខ្មែរត្រូវតែប្រយ័ត្នរឿងសំបកក្រៅឲ្យមែនទែន ហើយត្រូវតែប្រញាប់អប់រំខ្លួនឲ្យបានជាអារ្យជន ដោយស្រុះគ្នារៀបចំសម្លៀកបំពាក់ ព្រមទាំងឬកពានឹងការចេះដឹងរបស់ខ្លួន ដែលជាស្រោមរបស់ឯករាជ្យឲ្យល្អ ឲ្យរៀបរយ ឲ្យសមរម្យតាមអារ្យធម៌របស់ប្រទេសឯករាជ្យ ដូចំបរិយាយគោលៗ តទៅនេះ :

សំលៀកបំពាក់ចាត់ជា ៣ សម្រាប់ គឺ

១- សម្រាប់នៅផ្ទះ;

២- សម្រាប់ចេញក្រៅ;

៣- សម្រាប់ចូលកាន់ទីប្រជុំ ។

រៀលានៅក្នុងផ្ទះ ឬនៅក្នុងភូមិរបស់ខ្លួន ជាធម្មតា ទោះបីស្លៀកពាក់យ៉ាងណាក៏បាន តាមចូលចិត្ត តាមមានតាមបាន ឲ្យតែសមរម្យកុំឲ្យតែថោកទាបពេក, តែបើម្ចាស់ផ្ទះជាសុភាពបុរសកំពុងធ្វើការអ្វីនៅផ្ទះ ដោយស្លៀកតែខោ ឬសារុងមិនពាក់អាវ ហើយបើមានភ្ញៀវមករកត្រូវយកអាវទ្រនាប់មកពាក់សិន សឹមអង្គុយសំណេះសំណាលនឹងភ្ញៀវទើបថ្ងៃថ្នូរពេញជាម្ចាស់ផ្ទះដ៏មានសេរី ។

សម្ងៀកបំពាក់មិនល្អ នាំអ្នកស្ងៀកពាក់ឲ្យថោកទាបឲ្យអ្នកផង មើលងាយ, សម្ងៀកបំពាក់ល្អឲ្យថ្ងៃថ្នូរ ឲ្យគេញញើត, បើស្ងៀកពាក់ល្អ ហើយអ្នកស្ងៀកពាក់ចេះរៀបបូកពាអាកប្បកិរិយាឲ្យថ្ងៃថ្នូរផងទៀតក៏រិតតែនាំឲ្យគេសំគាល់ថាជាមនុស្សចំណាប់ចំនួនថែមទ្បើង សមជាពលរដ្ឋទ្វៃរឯករាជ្យមានអាវ្យធមិត្ពង់ត្ពស់មែន ។

ការស្ងៀកពាក់ល្អនឹងមិនល្អឲ្យលទ្ធផលជ្ជុយគ្នាស្រឡះ ដូចមានទាហរណ៍តទៅនេះ :

ថ្ងៃមួយ, នៅក្រុងភ្នំពេញមានអ្នកមានមុខមានមាត់ម្នាក់ស្ងៀកក្រមាពញ្ជាក់ហស់ពពួក់ មិនពាក់អាវ មិនសិតសក់ នៅធ្វើការក្នុងភូមិរបស់ខ្ជួន ។ ចួនជាពេលនោះ មានបុរសម្នាក់ដើរមករកការធ្វើ, ដោយសំគាល់ថាជាគូលីផ្ទះនោះ, បុរសនោះ ក៏ស្ងរថា "ពូ! ម្ចាស់ផ្ទះនេះត្រូវការគូលីម្នាក់ទៀតទេ?" ។ អ្នកនោះប្រាប់ថា "ចាំស្ងរលោកឲ្យ, ១ ម៉ោងទៀតទើបដឹងការ" ។ ក្រោយបុរសនោះចេញទៅ, អ្នកនោះងូតទឹកសិតសក់ស្ងៀកពាក់ស្អាតបាត រៀបចំបូកពាស្ងួលបួល ។ បុរសនោះមកវិញ ឃើញរូបដដែលស្ងៀកពាក់ល្អ ក៏ត្រឡប់ជាហៅថា "ព្រះតេជព្រះគុណ!" . . . ។

នេះជាលទ្ធផលនៃការស្ងៀកពាក់អាក្រក់ - ល្អ ដែលជាគ្រឹងធ្វើហានៈមនុស្សឲ្យទាបត្ពស់ខុសគ្នា, ត្រូវតាមសុកាសិត ១ បទថា "មាន់ល្អព្រោះរោម, រូបធោមល្អព្រោះតែង", ដែលបានសេចក្តីថា: ប្រទេស

ថ្លើងរុងរឿងពីព្រោះពលរដ្ឋមានសម្លៀកបំពាក់ល្អទឹងប្រកាថ្លៃថ្នូរ សុភាព
កបសារ ប្រាជ្ញាឈ្លាសវៃ ។

លោចេញក្រៅភូមិ, គប្បីប្រើសម្លៀកបំពាក់ដែលប្រាកដអ៊ីតមានផ្នត់ល្អ កុំចេញទៅឆ្ងាយតាំងសម្លៀកសារុង ឬតាំងស្លៀកតែខោដតាក់អាវ ព្រោះជាការស៊ើសពន្លូសសៀបប្រៀបណាស់ នាំឲ្យថោកគាបជាតិ ឲ្យជនបរទេសមាក់ងាយ ។

នៅទីក្រុងធំៗ ក្នុងប្រទេសយើង មានក្រុងភ្នំពេញជារដ្ឋធានី តែងតែមានការប្រជុំធំៗរឿយៗ. នៅពេលប្រជុំម្តងៗ តែងតែមានមនុស្សច្រើនហើយច្រើនជាតិផងដែលកាត់មកពីទីផ្សេងៗ; ពួនកាលមានទេសចរដែលមិនធ្លាប់ស្គាល់ប្រទេសខ្មែរសោះមកក្នុងទីនោះផងខ្លះ ។ ដូច្នេះ, ដើម្បីឲ្យរុងរឿងប្រទេសខ្មែរ ប្រជាជនជាតិខ្មែរទាំងបុរសទាំងស្ត្រី គប្បីប្រើសម្លៀកបំពាក់ប្រកបដោយឥណ្ឌាផ្សេងៗ មានឥណ្ឌាសជារដ្ឋធានី ទាំងអស់គ្នា, យ៉ាងហោចណាស់ត្រឹមខោខ្មៅ ឬសំពត់ខ្មៅ អាវស កុំគប្បីប្រើសម្លៀកបំពាក់ខ្មៅសុទ្ធដែលមើលទៅឃើញខ្មៅងងឹតដូចយប់ ឬដូចហ្វូងក្អែក; នាំឲ្យស្រអាប់ឯកពណ៌ខ្មែរ ។ មួយទៀត បើមានកិច្ចទៅហែអ្វី ឬទៅមើលពិធីអ្វី កុំគប្បីស្លៀកក្រមាពាក់លៃដ៏ខ្លួនវនលឈរតុបដៃ ឬអង្គុយត្រចោមក្បាលដង្គង់នៅចិញ្ចើមថ្នល់ នាំឲ្យថោកគាបអារ្យធម៌ខ្មែរក្រៃពេក, ប៉ុន្តែ ទោះបីស្លៀកពាក់ល្អត្រឹមត្រូវហើយ បើមិនរៀបប្រកាឲ្យថ្លៃថ្នូរផងទេ ក៏នៅតែមិនរុងរឿងទៀត; ព្រោះហេតុនេះ សូមបញ្ជាក់ថា

លក្ខណៈដែលប្រជាជនខ្មែរត្រូវរៀបចំខ្លួន ឲ្យសមជាពលរដ្ឋខ្មែរឯករាជ្យ
នោះ និយាយដោយបំព្រួញមាន ៣ យ៉ាង គឺ

១ - ត្រូវរៀបចំសម្លៀកបំពាក់ឲ្យល្អតាមថ្នាក់ តាមពេល ដូច
ពណិនាមកហើយ;

២ - ត្រូវរៀបចំអាកប្បកិរិយាបុកពាឲ្យថ្លៃថ្នូរ ស្ងាហាប់ សណ្តាប់-
ធ្នាប់ ចំណាប់ចំនួន, កុំធ្វើគ្រុយ ៗ ត្រុន ៗ ដែលនាំឲ្យជនបរទេសមើល
ងាយ, ប៉ុន្តែកុំឲ្យក្លាយទៅជាព្រហើនកោងកាច ហើយនឹងកុំបរិកោត
សុរា ឬទឹកត្នោតជូរ និយាយប៉ប៉ាច់ប៉ាញ ឡូឡា សើយលាត់ តាម
តៀមស្រា តាមផ្សារផ្សា ឬតាមចិញ្ចើមថ្នល់ ដែលនាំឲ្យជនប៉រទេស
ថ្កោលមារយាទខ្មែរ;

៣ - ត្រូវចំស្វែងរកការចេះដឹងនឹងរៀបចំចិត្តគំនិតឲ្យក្លៀវក្លា ក្លាហាន
រឹងប៉ុង ម៉ុងម៉ាត់ ដោយសំដែងអាការរីករាយ ទស្សាហ៍ ស្រវាស្រទេញ
រហ័សរហួន ចង់មានចង់បាន កុំចំអៀក ទម្រន់ ទន់ខ្សោយ ។

កាលបើប្រទេសខ្មែរផ្ទាស់ស្ថានភាព ជាប្រទេសឯករាជ្យពេញទី
ហើយ, ប្រជាជនខ្មែរត្រូវតែប្រញាប់ប្រញាល់ផ្ទាស់ជីវភាពរបស់ខ្លួនរៀង
ខ្លួនឲ្យបានជាអារ្យជន ដោយប្រកបតាមលក្ខណៈ ៣ យ៉ាងដូចពោលមក
ដោយសង្ខេបខាងលើនេះ ទើបសមជាពលរដ្ឋឯករាជ្យពេញទី ។

ឯករាជ្យពេញទីនៃប្រទេសកម្ពុជា ជាកម្ចាំងដ៏ធំមួយចំពោះព្រះ
ពុទ្ធសាសនា ជាសាសនាសម្រាប់ទេមរជាតិក្នុងកម្ពុរដ្ឋ ដែលរដ្ឋធម្មនុញ
ប្រទេសកម្ពុជាបានធានាអះអាងថា ជាសាសនារបស់រដ្ឋ ។

យើងសូមប្រសិទ្ធីពរឲ្យកម្ចាំងនេះ បានចំរើនឡើង នឹងរឹងប៉ុងមាំមួនតទៅ ដើម្បីឧបត្ថម្ភិត្រសរណដ្ឋាន គឺជាតិ សាសនា មហាក្សត្រ ឲ្យបានថ្កើងរុងរឿងជាកិយ្យោភាព រហូតកល្បាវសាន !



និគមវិបន:

ត្រឹះស្ថានស្រោមរដ្ឋប្រាកដជាក់ សម្ថៀកបំពាក់ស្រោមពលរដ្ឋ
ជនខ្មែរគួរកែឲ្យហ្មត់ចត់ ដើម្បីឲ្យរដ្ឋបានថ្កំថ្កើង ។
ឲ្យសមតាមភាពរដ្ឋឯករាជ្យ ឲ្យមានអំណាចប្រសើរឡើង
កសាងប្រទេសជាតិខ្មែរយើង ឲ្យល្អឲ្យថ្កើងតាន់សម័យ !

បាប - ពិន



ផ្នែកសាសនា

រាជវសតីកថា

ព្រះអាចារ្យ ហេង - ធឿង វត្តមហាមន្ត្រី

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឆ ដោយសេចក្តីគោរព) ។

ក្នុងឧកាសនេះ អាត្មាភាពសូមសំដែងអំពី "រាជវសតីកថា" ជាឧរាទរបស់សម្តេចព្រះបរមសាស្តា ដើម្បីជាផ្លូវចំរើនក្នុងការសិក្សានៃពុទ្ធសាសនិកជន តាមគោលនៃព្រះពុទ្ធភាសិតដែលមានក្នុងមហានិបាត-ជាតក ឧទ្ធកនិកាយ ដូចបទនិពន្ធគាថាយាំងនេះថា:

ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិចក្ខណោ
សុសំវិហិតកម្មន្តា ស រាជវសតឹ វសេ

ប្រែថា: បុគ្គលអ្នកប្រឹងប្រែងក្នុងការងារ ជាអ្នកមិនប្រមាទ មានបញ្ញាឃើញប្រចក្ស ចាត់ចែងការងារបានរៀបរយ បុគ្គលនោះគប្បីតាំងនៅក្នុងរាជការបាន" ។

ព្រះពុទ្ធភាសិតនេះសរសើរថា អ្នកដែលអាចតាំងនៅក្នុងវង្ស រាជការបាន ដោយគុណធម៌ ៤ ប្រការ ដែលហៅថា រាជវសតី:

๑ - ជាអ្នកប្រឹងប្រែងតស៊ូក្នុងការងារ;

๒ - ជាអ្នកមិនប្រមាទធ្វេសប្រហែស ចុះសចាកសេចក្តីខ្ជិលច្រអូសក្នុងមុខត្រួស;

៣ - ជាអ្នកមានបញ្ញាពិចារណា គិតគូរមើលសេចក្តីចំរើនវិនាសក្នុងការងារ;

៤ - ជាអ្នកចាត់ចែងការងារឲ្យមានរៀបរៀបរយ មិនច្របូកច្របល់ ។

ដូចអធិប្បាយតទៅនេះ ៖

ការប្រឹងប្រែងតស៊ូព្យាយាមក្នុងករណីយកិច្ចគ្រប់ប្រការ ចាត់ថាជាគុណសម្បត្តិសំខាន់យ៉ាងក្រៃលែង អាចធ្វើឲ្យអ្នកប្រកបដល់នូវសន្តិវរសុខនឹងបរមសុខបាន ។ ការងារទាំងឡាយមានការរកស៊ីចិញ្ចឹមជីវិតដោយប្រក្រតី ដូចជាកសិកម្ម, វណិជកម្ម, វេជ្ជកម្ម, ទស្សាហកម្ម, ហត្ថកម្ម, និងការសិក្សាអក្សរសាស្ត្រ, លេខសាស្ត្រ, ប្រវត្តិសាស្ត្រ, សាសនសាស្ត្រ, វិទ្យាសាស្ត្រ, តក្កសាស្ត្រជាដើម រហូតដល់កិច្ចការជាមុខត្រួសួនរបស់ខ្លួន ដែលចាត់ថាជាករណីយកិច្ចត្រឹមត្រូវ ក៏សុទ្ធតែត្រូវអាស្រ័យសេចក្តីព្យាយាមជួយដឹកនាំគាំទ្រផង, សមដោយនិពន្ធពុទ្ធភាសិតថា: ឧដ្ឋានា វិន្ទតេ ធនំ "អ្នកមានសេចក្តីព្យាយាមមាំ រមែងបានទ្រព្យសម្បត្តិ" ។ មនុស្សដែលមានទ្រព្យសម្បត្តិសុកសប្តម្ភ តែងបានសេចក្តីសុខ ។ ការដែលមានភោគសម្បទ ក៏ដោយអាស្រ័យសេចក្តីព្យាយាមលះកាត់សេចក្តីសុខបន្តិចបន្តួចបន្តុចបន្តួចបន្តុចបន្តួចបន្តុ

ឱ្ជិលប្រអូស ព្រោះសេចក្តីឱ្ជិលប្រអូស រមែងធ្វើអាការដូចមិត្តឲ្យសេចក្តី
សុខក្នុងខាងដើម ល្ងងលោមបុគ្គលល្ងង់ឲ្យលង់លិច ពេលមកខាង
ក្រោយផ្តល់សេចក្តីទុក្ខឲ្យមិនមានទីបំផុត; ឯសេចក្តីព្យាយាមនោះ រមែង
ធ្វើអាការដូចជាសត្រូវ ឲ្យសេចក្តីលំបាកក្នុងខាងដើម តែពេលខាង
ក្រោយត្រឡប់ទៅជាមហាមិត្ត អាចជូនសេចក្តីសុខយ៉ាងធំរកទីបំផុតគ្មាន
ហេតុនេះសេចក្តីឱ្ជិលប្រអូសជាគ្រឿងកសាងសេចក្តីទុក្ខ ការព្យាយាមជា
គ្រឿងផ្សាំបណ្តុះសេចក្តីសុខ ។ បុគ្គលដែលធ្ងងសេចក្តីទុក្ខបាន ក៏ព្រោះ
ការព្យាយាម, បើគេធុញទ្រាន់នឹងការព្យាយាមដោយឃើញតែសេចក្តី
លំបាកក្នុងករណីយកិច្ចមុនហើយ គេនឹងធ្ងងសេចក្តីទុក្ខក៏ពុំបាន ដូចជា
បុគ្គលចូលលត់ភ្លើងក្នុងពេលដែលធេះផ្ទះ បើខ្ជាចក្តៅក៏លត់ពុំបាន ។ ពិត
ណាស់ សេចក្តីលំបាករមែងកើតជាមួយនឹងការព្យាយាម ព្រោះមនុស្ស
ដែលមានឧបស័គ្គក្នុងវេលាធ្វើ បើចុះចាញ់ឧបស័គ្គនោះក៏ត្រូវរងទុក្ខវេទនា
ជាដរាប តែបើយកជ័យជំនះឧបស័គ្គនោះបាន សេចក្តីទុក្ខព្រួយក៏ឃ្ងាត
ចេញពីខ្លួនឯង ។ ការដែលមិនខ្ជាចនឿយហត់នេះឯងឈ្មោះថា "វិរិយ:" ។
ពោលដោយមូលហេតុមាន ២ យ៉ាង គឺកាយនឹងចិត្ត ។ ដែលប្រព្រឹត្តទៅ
តាមផ្លូវកាយ ហៅថា "កាយិក:" តាមផ្លូវចិត្ត ហៅថា "ចេតសិក:" ។
ដូច្នេះ វីរិយ:មិនមែនមានក្នុងទីដទៃគឺមានក្នុងកាយនឹងចិត្ត កាយនឹងចិត្តនេះ
ឯងជាទីតាំងនៃការព្យាយាម កាលបើបុគ្គលឃើញច្បាស់យ៉ាងនេះហើយ
ត្លូរប្រកបការប្រឹងប្រែងអង់អាចខាងផ្លូវកាយនឹងផ្លូវចិត្ត ដែលធម្មតាតាក់
តែងឲ្យមក មិនគ្លូរទុកកាយនឹងចិត្តឲ្យនៅទំនេរឥតប្រយោជន៍ទេ ។

ចំណែកករណីយកិច្ចដែលត្រូវធ្វើដោយផ្លូវកាយនឹងចិត្ត ទាំងផ្នែកគតិ-
លោកនឹងគតិធម្មិ តាំងពីជាន់ទាបរហូតដល់ជាន់ខ្ពស់ សុទ្ធតែត្រូវអាស្រ័យ
ការតស៊ូប្រឹងប្រែងជាគ្រឿងទំនុកបំរុង ទើបអាចសំរេចសមតាមបំណង
ចាន ។ សេចក្តីព្យាយាមមានកម្លាំង តែងដឹកនាំបុគ្គលអ្នកប្រកបឲ្យ
ប្រសព្ធសន្ធិសុខទាន់ពេលសម័យ ប្រៀបដូចគ្រឿងចំក្រដែលបង្វិល
រថយន្ត, អាកាសយាន, កប៉ាល់នឹងកាណូតឲ្យទៅកាន់មាតាំដឹធ្វាយ
ចានដោយសុវត្ថិភាព ។ កាលបើបុគ្គលមានព្យាយាមមាំជាគ្រឿងទំនុក
បំរុងហើយ នឹងចានជាដើមទុនកកើតផលគឺវរសុខនឹងសេរីធម្មិ ។ តែ
ករណីយកិច្ចដែលត្រូវធ្វើ នឹងដើរលឿនទៅដោយសេចក្តីរៀបរយល្អចាន
ដោយអាស្រ័យសេចក្តីមិនប្រមាទ ប្រាសចាកការធ្វេសប្រហែសក្នុងមុខ
ការងាវរបស់ខ្លួន ទើបរួចចាកវិបត្តិកាត់ចូលទៅរកស្ថស្តី ហេតុនេះព្រះ
ទសពលញ្ញាណប្រទានអប្បមាទធម្មិជាគុណសម្បត្តិចាត់ទុកក្នុងបទទី ២ ។

សេចក្តីមិនប្រមាទនេះ ចានដល់សេចក្តីប្រយ័ត្នមិនធ្វេសប្រហែស
មិនភ្លេចភ្លាំង មិនភាន់ភាំងទៅក្នុងអារម្មណ៍, បើពោលដោយសេចក្តី
ចានដល់ការមិនវង្វេងភ្លេចស្មារតី មិនបណ្តោយចិត្តឲ្យដើរទៅតាមសេចក្តី
សេរឹងជ្រុលជ្រប់ ។ សេចក្តីមិនប្រមាទនេះជាទីតាំងនៃគុណប្រយោជន៍
ដ៏ធំទូលាយទាំងគតិលោកនឹងគតិធម្មិ ត្លយ៉ាងដូចអ្នករកស៊ីល្ជ្ជូលទទ្ជូល
រក្សាចិញ្ចឹមគោក្របីឲ្យគេ កាលបើធ្វេសប្រហែសមិនយកចិត្តទុកដាក់ក្នុង
ការថែទាំរក្សាសត្វដែលខ្លួនចិញ្ចឹមទេ ហ្ជូងសត្វនោះក៏នឹងអន្តរាយ ព្រោះ
រោគវិបត្តិខ្លះ ព្រោះចោរភ័យខ្លះ រកផលល្អគ្មាន; កាលបើប្រុងប្រយ័ត្ន

មិនបណ្តែតបណ្តោយ អន្តរាយបែបនោះក៏មិនមាន បើទុកជាមានខ្ទះ
ក៏តិចជាងមិនប្រយ័ត្ន ។ ឯអ្នកត្រប់ត្រងផ្ទះ បើមិនអើពើក្នុងការរវាំង
មើលគេហស្ថាន មិនរវាំងទ្រព្យសម្បត្តិបណ្តោយឲ្យការងារច្របូកច្របល់
ត្នា អោតសម្បីទដែលមិនទាន់កើតក៏មិនកើត ដែលកើតហើយក៏វិនាស
ឋាត់ទៅ នឹងទៅជាចន្ទោះបើកឲ្យចោរចូលលុកលុយយកសម្បត្តិទ្រព្យ
ឋានទ្រៀត ។ ចំណែករាជបុរសអ្នកបដិបត្តិរាជការ បើធ្វេសប្រហែសមិន
ប្រយ័ត្នក្នុងមុខការរបស់ខ្លួន ក៏រមែងមិនរួចពីកំហុស ។ កាលបើមាន
ចិត្តស្វាមីភ័ក្តិក្នុងការណីយកិច្ចរបស់ខ្លួន មិនមានសេចក្តីប្រមាទ ទើបឋាន
ជាអ្នកចំរើនក្នុងកិច្ចការទៅតាមលំដាប់ ។ ឯអ្នកជាប្រធានរបស់គណៈវង្ស
ត្រកូល បើមិនប្រយ័ត្នថែទាំយកចិត្តទុកជាក់ក្នុងនាទីរបស់ខ្លួន មិនបីឋាច់
រក្សាទំនុកបំរុងនូវអន្តោជននឹងពាហិរជនដោយធម្មិកោឋាយទេ អន្តរាយ
នឹងកើតឡើងដល់គណៈត្រកូលវង្ស មិនឋានចំរើនមាំមួនទៅតាមផ្លូវ
ល្អ ពួកជនពាលនឹងឋានឧកាសបង្កសេចក្តីវិនាន ហេដ្ឋិមជនក៏នឹង
ឋានសេចក្តីទុក្ខក្តៅក្រហាយ មិនមានសេចក្តីស្ងប់ដាសុខ; កាលបើតាំង
ចិត្តថែទាំរក្សាទំនុកបំរុងដោយសេចក្តីមិនប្រមាទ ទើបអាចកំចាត់ទោស
ភ័យ-វិបត្តិ ឋានសម្រេចសេចក្តីសុខ-សួស្តីដ៏ធំទូលាយ ។ ចំណែកអ្នក
ត្រូវការខាងផ្លូវធម៌ បំពេញកុសលចរិយាវត្ត រក្សាក្រៀកទុកនូវសតិ
មិនឲ្យសេចក្តីប្រមាទលុកលុយ ទើបអាចហាមឃាត់អកុសលដែលមិន
ទាន់កើតមិនឲ្យកើតឡើង ធ្វើកុសលដែលកើតឡើងហើយ ឲ្យរឹងរិត
តែចំរើនឡើងជាភិយ្យោភាព ជាគោលនៃសន្តិសុខក្នុងព្រះពុទ្ធសាសនា

សមដោយទេសនាន័យ ដែលសម្តែចព្រះសម្ពុទ្ធជាម្ចាស់ត្រាស់សរសើរ
សេចក្តីមិនប្រមាទក្នុងធម្មបទ ទ្រង់ភនិកាយថា: "បណ្តាកុសលធម៌ទាំង
អស់ សេចក្តីមិនប្រមាទជាធំជាង ដូចស្នាមដើងសត្វទ្វេបាទ បតុប្បាទ
ដែលសញ្ជរលើប្រថពី ស្នាមដើងដំរី ធំជាងស្នាមដើងទាំងអស់" ។ កាល
បើបុគ្គលមិនប្រមាទហើយ កុសលធម៌ដែលមិនទាន់កើតនឹងកើតឡើង,
ដែលកើតឡើងហើយ ក៏នឹងតែតចំរើនឡើង អ្នកមិនប្រមាទរមែងតាញ
យកនូវប្រយោជន៍ទាំងពីរផ្លូវបាន គឺ ប្រយោជន៍ក្នុងបច្ចុប្បន្នដែលឃើញ
ជាក់នឹងភ្នែក បានដល់ប្រយោជន៍កុងតតិលោក, ប្រយោជន៍ក្នុងសម្ប-
រាយិកតលោកនាយ បានដល់ប្រយោជន៍តតិធម៌ ឈ្មោះថាអ្នកមាន
ជ័យដ៏នេះទាំងពីរផ្លូវ ឬពោលដោយរ៉ៅហារថា បានសំរេចសម្បត្តិទាំង
ពីរយ៉ាងគឺ ភោគសម្បត្តិ បានដល់មាស, ប្រាក់, កែវ, កង ដែលជា
គ្រឿងទំនុកបំរុងដល់សាមិសុខ និងគុណសម្បត្តិ បានដល់កុសលធម៌
នឹងសេចក្តីបរិសុទ្ធិកាយ · វាចា - ចិត្ត ដែលជាឧបការដល់និរាមិសសុខ ។
តែសេចក្តីមិនប្រមាទនេះដែលអាចកើតឡើងដល់បុគ្គល ក៏ដោយសារការ
ដួបប្រទះនូវវត្ថុអស់ទៅនឹងសូន្យទៅជាសាក្សី តពីនេះ ទើបអប្បមាទធម៌
កើតចំរើនឡើង ដូចបុគ្គលអ្នកឃើញការវិនាសទៅនឹងសូន្យទៅនៃ
ភោគសម្បត្តិ រមែងជាមូលហេតុមិនឲ្យប្រមាទក្នុងការស្វែងរកភោគទ្រព្យ
មិនឲ្យប្រមាទក្នុងការបរិហារក្សាទ្រព្យ មិនប្រមាទក្នុងការចាយវាយ
ទ្រព្យ ។ កាលបើឃើញការសាបសូន្យចាកយស ជាមូលហេតុឲ្យប្រយ័ត្ន
រក្សាក្នុងការណ៍យ៍ផ្សេង។ ហេតុនេះ អប្បមាទធម៌ជាគុណសម្បត្តិ របស់

បុគ្គលអ្នកត្រូវការចំរើនក្នុងរាជវសតី ត្រូវអប់រំឲ្យកើតមានក្នុងសន្ធានរបស់ខ្លួន ជាថ្នាក់ទី ២ ។ តែថាបើខ្ជះបញ្ញាជាគ្រឿងពិចារណាលៃលកមើលសេចក្តីវិនាសទៅនឹងសូន្យទៅនៃកិច្ចការ ក៏ជាហេតុឲ្យការងារដែលខ្លួនធ្វើឲ្យប្រព្រឹត្តទៅដោយលំបាក មិនមានរបៀបរៀបរយ បើមានបញ្ញាជាគុណជាតិខ្ពង់ខ្ពស់ចូលអែបនៃបផង នឹងត្រិះរិះប្ដពិចារណា ប្ដក៏នឹងធ្វើអ្វីៗ បានមិនទើសទាក់ ហេតុនេះទើបទ្រង់ត្រាស់ថា បញ្ញា ជាគុណ-សម្បត្តិថ្នាក់ ៣ ។

ប្រើជាដែលស្គាល់ច្បាស់ហេតុផល ឈ្មោះថា បញ្ញា ។ គុណសម្បត្តិនេះល្អទាំងគតិលោកនឹងគតិធម៌ ព្រោះថាសព្វវត្ថុទាំងចំណែកល្អប្ដអាក្រក់ រមែងជាហេតុឲ្យផលគូគ្នា ហេតុល្អឲ្យសម្រេចផលល្អ ហេតុអាក្រក់ឲ្យសម្រេចផលក៏អាក្រក់ ហេតុនៃសេចក្តីសុខឲ្យសម្រេចផលក៏ជាសុខ ហេតុនៃសេចក្តីទុក្ខឲ្យសម្រេចផលក៏ជាទុក្ខ ធម្មជាតិទាំងអស់សុទ្ធតែមានហេតុផលជាគូៗ គ្នា មិនផ្ទាស់ប្ដូរទៅរកធម្មជាតិដទៃទ្បើយ ហេតុនៅមានត្រឹមណាផលក៏នៅមានត្រឹមនោះ កាលបើអស់ហេតុទើបផលរលត់ ។ អ្នកមានបញ្ញាដឹងច្បាស់ហេតុផល តាមគន្ធងវឌ្ឍនធម៌ បានឈ្មោះថា អ្នកស្គាល់ហេតុស្គាល់ផល, និស្សយចិត្តគំនិតរបស់បុគ្គលនោះ រមែងក្ខឺស្ងាងព្រោះពន្ធឹតឹបញ្ញា បណ្តោញចោលនូវងងឹតគឺអវិជ្ជា មិនឲ្យមានឧកាសរួបរិតចូលមកព័ទ្ធព័ន្ធបាន ។ ព្រះអាទិត្យព្រះចន្ទមានដួងប្រទីបបញ្ចេញពន្ធឹច្បាស់ដល់ចក្ខុរបស់សត្វយ៉ាងណា បញ្ញាក៏បញ្ចាំងពន្ធឹឲ្យធ្ងុះចេញក្ខឺពីចិត្តគំនិតបានដូច្នោះ, លោកនឹងរុងរឿងធូរទូលាយបាន ក៏ព្រោះតែអាស្រ័យ

បុគ្គលអ្នកមានប្រាជ្ញាដឹងផ្ទូវហាយនធម៌ វឌ្ឍនធម៌ច្បាស់ ប្រកបទុបាយជា
គ្រឿងលុបលាងសេចក្តីវិនាសចោលចេញ ដើរទៅតាមបដិបទានៃសេចក្តី
ចំរើន ។ ផ្ទូវធម៌ក៏ជូចគ្នា បើចិត្តប្រាសចាកបញ្ញា អវិជ្ជាក៏រួបរិតឲ្យងងឹត
ចិត្តសន្ធានមានតែពេលដែលកករល្អក់មិនមានពេលថ្ងា ប្រសិនបើបញ្ញា
ចូលទៅទំនុកបំរុងផង ក៏ជួយបង្ហាញផ្ទូវឲ្យស្គាល់ច្បាស់ធម្មតារបស់ទុប-
ស័ត្តបាន កាលបើចិត្តដើរទៅកាន់ផ្ទូវត្រូវជូចនេះហើយ អាចទទួលពន្ធឹតឹ
បញ្ញាមកអំពីផលដែលធ្វើខ្ជួនឲ្យរួចចាកងងឹតបាន ។ ឯពន្ធឹព្រះអាទិត្យ
ព្រះចន្ទមានជួងអាចបញ្ចេញពន្ធឹបាន តែកន្ទុងដែលមិនមានវត្ថុអ្ទីបិទបាំង
បើមានវត្ថុអ្ទីបិទបាំងក៏ផ្សាយពន្ធឹទៅមិនដល់ ចំណែកពន្ធឹតឹបញ្ញាទុកណា
ជាវត្ថុជាទុបស័ត្តយ៉ាងណាក៏ដោយ ក៏អាចក្ងឹធ្ទុះទៅរហូតបាន ថែមទាំងជា
គុណជាតិមាំមួនផង រាប់ថាជាពន្ធឹយ៉ាងកំពូល សមដោយពុទ្ធនិពន្ធដែល
ទ្រង់ត្រាស់ទុកថា ឌត្ថិ បញ្ញា សមា អាភា "ពន្ធឹស្មើ
ដោយបញ្ញាមិនមាន" ។ បញ្ញាអាចសង្កេតពិចារណារកហេតុដ៏សុខុម
ល្អិតដែលកំបាំង ឲ្យក្ងឹច្បាស់ប្រាកដទ្បើង មិនមានពន្ធឹដទៃស្មើ
នឹងជាគ្រឿងជាស់គ្រឿនឲ្យដើរទៅរកផ្ទូវត្រូវជាផ្នែកសុចរិត ។ បុគ្គល
មានអាជីពប្រកបដោយបញ្ញា រមែងធ្វើការណីយកិច្ចប្រាសចាកទោស
ដើម្បីជាសាធារណប្រយោជន៍ដល់សាធារណជន មិនប្រព្រឹត្តលបក្សត់
ព្រោះតែយើញប្រយោជន៍ផ្ទាល់ខ្ជួនតែម្យ៉ាង តែងចែករំលែកផ្សព្ទផ្សាយ
ជាសាធារណ៍ដល់ជនដទៃ ដោយទឹកមេត្តាចិត្តអាណិតត្រាប្រណី ទាំងនេះ

ក៏ព្រោះអាស៊ីយបញ្ញាជាគ្រឿងទំនុកបំរុង ។ លោកអ្នកដែលគ្រប់គ្រងប្រជុំជនឲ្យជាពួកគណៈប្ដក្រុមគ្រួសារទៅបាន រាប់តាំងពីត្រកូលមួយ ប្ដកូមិភាគទ្បើងទៅ ក៏ព្រោះមានបញ្ញា ស្គាល់ហេតុផល ដឹងជាក់នូវទបាយជាគ្រឿងការពារសត្រូវ មិនឲ្យមានឧកាសញ្ចាំញ៉ីបៀតបៀនបាន, មួយទៀតពួកអ្នករាជការនឹងបីបាច់ថែរក្សាមាតុកូមិឲ្យដើរទៅដោយសន្ធិវិធី ក៏ត្រូវមានបញ្ញាស្គាល់ហេតុ ផល ពិចារណាគិតគូរ រំពឹងមើលឲ្យធ្ងន់មានគំនិតយ៉ាងសុខុមជុំវិញមិនខ្ជះកន្ជះ ចេះរកទបាយជាគ្រឿងកែខៃទបស៊ីគ្គផ្សេងៗបាន ហេតុនេះ បញ្ញាទើបចាត់ជាគុណសម្បត្ដិ ដែលបុគ្គលអ្នកប្រាថ្នាការចំរើនក្នុងវស្សរាជការគួរអប់រំក្នុងថ្នាក់ទី ៣ ។

ទុកណាជាបរិបូណ៌ដោយគុណសម្បត្ដិគ្រប់ទាំង ៣ ប្រការនេះហើយតែកិច្ចការងារនៅច្រងេងច្រងាងប្រទាំងប្រទើសមិនរៀបរយ ក៏រាប់ថាជាអ្នកមានសមត្ថភាពក្នុងការងារមិនទាន់បាន លុះត្រាតែចាត់ចែងការងារឲ្យមានរបៀបរៀបរយ មិនច្របូកច្របល់ ទើបនឹងជួបផ្ទូវនៃវឌ្ឍនធម៌ទៅតាមវស្សរាជការ ហេតុនេះទើបសម្ដេចព្រះមហាមុនីត្រាស់នូវភាពនៃបុគ្គលអ្នកចាត់ការមានរបៀបរៀបរយទុកក្នុងគុណសម្បត្ដិថ្នាក់ទី ៤ ។

ឋម្ចតាបុគ្គលអ្នកមានករណីយកិច្ច ដែលនឹងត្រូវធ្វើយ៉ាងណានីមួយកាលមិនធ្វើតាមកាលសម៉យ បណ្ណោយការងារឲ្យសល់ទុកនៅ ប្ដមិនចាត់ចែងការងារនោះឲ្យមានរបៀបរៀបរយល្អ ការងារនោះហៅថា ច្របូកច្របល់ លោកតិះដៀលថាជាអពមង្គល មិនជាហេតុនាំមកនូវសេចក្ដីចំរើន ។ ចំណែកការងារដែលចាត់ចែងឲ្យមានរបៀបសមតាមកាលសម៉យ

មិនបណ្តោយឲ្យសល់ទុកខាល់តែលើសប្រមាណ កាលបើមានការងារ
យ៉ាងណាលេចឡើង ត្រូវធ្វើឆាប់តស៊ូការងារនោះឲ្យសម្រេចដោយ
សួស្តី មិនបង្អង់ពេលវេលា មិនបណ្តោយការថ្ងៃនេះឲ្យអាត់ខានទៅ
ដល់ថ្ងៃស្អែក ដែលជាហេតុនាំឲ្យខឿយណាយក្នុងវេលាត្រូវធ្វើ លោក
ហៅថាការងារមិនច្របូកច្របល់ ដាក់សរសើរបស់បណ្ឌិតជន សម
នឹងពុទ្ធភាសិតថា: អនាកុលា ឯ កម្មន្តា ឯតម្ពុ ំលសម្ពុទ្ធំ
"ការទាំងឡាយដែលមិនច្របូកច្របល់ ចាត់ជាមង្គលខ្ពស់បំផុត" ។

ហេតុនេះ សាធុជនអ្នកប្រាថ្នាផលគឺសន្តិសុខ-វឌ្ឍនធម៌ សេរីធម៌
អារ្យធម៌ គួរអប់រំឲ្យនៅក្នុងត្រកូមន៍សម្ងាបតិបត្តិប្រព្រឹត្តតាមគោលនៃឧប-
យោវត្រៃ សេចក្តីបដិបត្តិរបស់ពាជសេវក: នាមថា "ពាជវិសតី" គឺសេចក្តីប្រឹង
ប្រែង តស៊ូព្យាយាមគ្រងមុខត្រួសួនៃការងារមិនរួញរា, មិនបណ្តោយឲ្យ
សេចក្តីប្រមាទចូលគ្របសង្កត់ខាល់តែខូចខាតការងារ, មានបញ្ញាដាក្រឡឹង
ពិចារណាការអស់ទៅនឹងសូន្យទៅរបស់ការងារ, ចាត់ចែងការងារឲ្យមាន
របៀបរៀបរយមិនច្របាំងច្របើសច្របូកច្របឡំគ្នា ទើបនឹងប្រសព្វផ្លូវនៃ
សន្តិសុខយ៉ាងត្រៃលែង ជាកូមិភាគនៃសេចក្តីរីកចម្រើនក្នុងវង្សនៃពាជការ
បាន សមនឹងទេសនាជាឧត្តមពុទ្ធសាសនី ដែលព្រះបរមលោកនាថត្រាស់
ទុកថា: "អ្នកប្រឹងប្រែងក្នុងការងារ, មិនប្រមាទ, មានបញ្ញាឃើញច្បាស់,
ចាត់ចែងការងារឲ្យរៀបរយ អ្នកនោះតប៉ាំងនៅក្នុងពាជការបាន" ។

អធិប្បាយមកប៉ុណ្ណេះ គឺសមគួរដល់ពេលវេលានឹងបញ្ចប់ឯវំ ដោយ
ន្ទូវបការយ៉ាងនេះឯង ។

វិរុទ្ធវត្ថុកាថា

សំដែងពីវត្ថុដែលប្លែកគ្នាក្នុងត្រៃលោក (១)

ព្រះវិភទ្ធញ្ញាណ លោម-ឡុប រៀបរៀងកាលពីតង់ព្រះដន្ធនៅ

ត្រៃលោកតែងទ្រទ្រង់វត្ថុមានវិញ្ញាណនឹងវត្ថុគ្មានវិញ្ញាណ; វត្ថុមានវិញ្ញាណបានខាងមនុស្ស អមនុស្ស (២) នឹងសត្វតិរច្ឆាន, វត្ថុគ្មានវិញ្ញាណបានខាង ដី ទឹក ក្លើង ខ្យល់ ដើមឈើ ស្មៅនឹងវល្ជិជាដើម, វត្ថុទាំងអស់នេះកើតឡើងតែងប្លែក ៗ គ្នា ។

វត្ថុមានវិញ្ញាណ ដូចពួកមនុស្ស តែងប្លែកគ្នាដោយសម្បុរខ្ទះ ប្លែកគ្នាដោយក្ជិនខ្ទះ ប្លែកគ្នាដោយទ្រង់ទ្រាយខ្ទះ ប្លែកគ្នាដោយឥរិយាបថខ្ទះ ប្លែកគ្នាដោយសំឡេងខ្ទះ ។

ចំណែកវត្ថុដែលគ្មានវិញ្ញាណ ដូចដើមឈើ ស្មៅ វល្ជិ ដី ទឹក ក្លើង ខ្យល់ ខ្យាច់ ក្រួសនឹងថ្ម ទាំងនេះ ក៏ប្លែក ៗ គ្នាមិនដូចគ្នាឡើយ អស់-លោកអ្នកទាំងឡាយបានយើញច្បាស់នឹងក្នែកតប់គ្នាហើយ ខ្ញំមិនបាច់ថ្ងែងរៀបរាប់ឲ្យពិស្តារឡើយ ចូរអស់លោក អ្នកទាំងឡាយពិចារណាមើលចុះ រៀរលែងតែស្ថានព្រះនិព្វានចេញ ក្រៅពីស្ថានព្រះនិព្វានហើយ របស់អ្វី ៗ តែងមិនទៀងទាំងអស់ ឥតលោកអ្នកណានឹងតិតត្រូវបាន ព្រោះហេតុនោះ បានជាមានពុទ្ធភាសិតថា "របស់ដែលមិន

---

១ ប្រៃថា: លោកទាំងបី គឺ: កាមលោក ១, រូបលោក ១, អរូបលោក ១ ។ ២ សំដៅយក ឆ្មាច ប្រេត យ៉ក្ស អសុរកាយនឹងទេវតា ។

ត្រូវគិត មាន ៤ យ៉ាងគឺ វិស័យព្រះពុទ្ធ ១, វិស័យឈាន ១, ផលកម្ម ១, គិតពីរឿងលោក ១ ” ។

១— វិស័យព្រះពុទ្ធ: ព្រះសម្ពុទ្ធព្រះអង្គមានព្រះកាយកំពស់ ១៨ ហត្ថ ព្រះអង្គអាចយាងចូលទៅគង់នៅក្នុងត្រាប់ស្ពបាន បើយ៉ាងនេះយើងនឹងគិតថា ព្រះអង្គនិម្មិតព្រះកាយឲ្យតូច ហើយធ្វើត្រាប់ស្ពឲ្យធំទ្បើងប្ដយ៉ាងណា ក៏គិតមិនត្រូវ ព្រោះព្រះកាយព្រះអង្គទំហំប៉ុន្មាន ក៏នៅប៉ុណ្ណោះដដែល ត្រាប់ស្ពទំហំប៉ុន្មាន ក៏នៅប៉ុណ្ណោះដដែល នេះគឺដោយអំណាចបុណ្យបារមីរបស់ព្រះអង្គ ត្មានអ្នកណានឹងគិតត្រូវ តែទំគិតហើយមុខជានឹងត្រឡប់ទៅជាមនុស្សឆ្កួតមិនខានឡើយ ។ មានរឿងដំណាលពីបុរសម្នាក់ ទំរិះគិតពីវិស័យរបស់ព្រះពុទ្ធ ក៏មិនសម្រេចដូចប្រាថ្នា ស្ទើរនឹងត្រឡប់ទៅជាឆ្កួត ។ រីលានោះមានអ្នកមានប្រាជ្ញម្នាក់ មានចិត្តមេត្តាបានយកកញ្ចក់ ១ ទៅឆ្ទុះតួព្រះចតិយកំពស់ ១ រយ ៦០ ហត្ថ ទំហំ ៣ រយ ៦០ ហត្ថ ហើយប្រាប់ថា: អ្នកឯងចូរមើលស្រមោលព្រះចតិយក្នុងកញ្ចក់នេះ ។ ឯបុរសនោះក៏ទៅមើលឃើញមែន ។ ទើបអ្នកមានប្រាជ្ញាសួរថា: តួព្រះចតិយធំម្ទ៉ះ អាចចូលមកជាប់នៅក្នុងផ្ទៃកញ្ចក់នេះបាន បើដូច្នេះតើអ្នកយល់ថា ព្រះចតិយនេះតូចទៅហើយកញ្ចក់រីកធំឡើងប្ដដូចម្តេច? ។ អ្នកនោះតបថា: មិនមែនដូច្នោះទេ តួព្រះចេតិយនឹងតួកញ្ចក់នេះ មានទំហំប៉ុន្មាន ក៏នៅប៉ុណ្ណោះដដែល ។ អ្នកមានប្រាជ្ញក៏ប្រាប់ថា: អើវិស័យរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ អ្នកគិតមិន

ត្រូវទេ តែទំគិតហើយមុខជានឹងធ្ពួតមិនខាន ។ ឯបុរសនោះក៏ជឿចូលចិត្ត
ឥតសង្ស័យតទៅទៀតឡើយ ។

២_ វិស័យឈាន: លោកអ្នកដែលបានសម្រេចឈាន ប្រកប
ដោយអភិញ្ញាហើយ តែងមានបុទ្ធិមានអំណាច អាចនឹងទៅចាប់យក
ព្រះអាទិត្យព្រះចន្ទ មកធ្វើជាតាំងសម្រាប់ទ្រដើងក៏បាន ឬនឹងចង់និម្មិត
ខ្លួនឲ្យជាវត្ថុអ្វីៗ ក៏សម្រេចបានត្រប់យ៉ាងឥតមានទើសទាស់ឡើយ ។

៣_ ផលកម្ម: មនុស្សដែលបានធ្វើកុសលកម្ម ឬអកុសលកម្ម
ហើយ តែងសោយសេចក្តីសុខទុក្ខតិចប្រើន តាមផលកម្មដែលខ្លួនបាន
ធ្វើមកនោះ, ប្រើចំណែកខាងកុសលកម្ម ផលកម្មនោះនាំទៅកើតជាទេវតា
ឬនាំទៅកើតជាមនុស្ស ក៏មិនដូចគ្នា ខ្លះកើតក្នុងត្រកូលខ្ពង់ខ្ពស់ ខ្លះកើត
ក្នុងត្រកូលថោកទាប ខ្លះមាន ខ្លះក្រ ខ្លះល្អ ខ្លះអាក្រក់ជាដើម ។

ប្រើចំណែកខាងអកុសលកម្មវិញ ផលកម្មនោះនាំទៅកើតក្នុងអ-
បាយភូមិ ទាំង ៤ គឺ នរក ប្រេត តិរច្ឆាន នឹងអសុរកាយ រងទុក្ខវេទនា
ផ្សេងៗ គ្នា មិនដូចគ្នាឡើយ ។

៤_ ការគិតពីធ្វើងលោក: បុគ្គលណាមួយគិតថា កាលដើម
បង្អស់តើនរណាបង្កើតព្រះអាទិត្យព្រះចន្ទ ដី ទឹក ក្ងើង ឲ្យល់ ព្រមទាំង
ដើមស្វាយ ដើមដូង នឹងដើមស្វាជាដើមនេះមក បានជាមានជាប់មក
ដល់សព្វថ្ងៃនេះ ក៏រិះគិតមិនឃើញឡើយ ព្រោះវត្ថុទាំងនោះតែងកើត
មកជាធម្មតា នឹងមានលោកអ្នកណា មានបុទ្ធិ មានអំណាចអាចនឹង

ឋានដ្ឋិតខុកមកកំណេ គឺមានតាំងពីកដី ទឹក រហូតដល់មកសព្វថ្ងៃនេះឯង ហេតុនោះបានជារកលោកអ្នកនិងគិតមិនត្រូវ ។

សូមថ្លែងពីរបស់ដែលដូចគ្នាវិញ ឯរបស់ដែលដូចគ្នាអត់មានដូចមិនបាននោះ និយមយកតែនិងសេចក្តីស្លាប់តែម្យ៉ាង ព្រោះរូបយើងកាល់-គ្នាតែកើតឡើងហើយតែងស្លាប់ទៅវិញជាធម្មតា ខុសគ្នាតែខ្លះស្លាប់មុនខ្លះស្លាប់ក្រោយប៉ុណ្ណោះ ទើរៀងតែបង្ហែតពីសេចក្តីស្លាប់ពុំបាន ប្រុសក៏ស្លាប់ ស្រីក៏ស្លាប់ ក្មេងក៏ស្លាប់ ចាស់ក៏ស្លាប់ អ្នកធំក៏ស្លាប់ អ្នកតូចក៏ស្លាប់ អ្នកមានក៏ស្លាប់ អ្នកក្រក៏ស្លាប់ អ្នកជ្រាបក៏ស្លាប់ អ្នកខ្លៅក៏ស្លាប់ អ្នកល្អក៏ស្លាប់ អ្នកអាក្រក់ក៏ស្លាប់ អ្នកអាយុវែងក៏ស្លាប់ អ្នកអាយុខ្លីក៏ស្លាប់ សេចក្តីស្លាប់នេះឯងតែងមានយល់មុខថា អ្នកនេះធំអ្នកនេះតូចឡើយ ។

ក្នុងទីនេះ ខ្ញុំសូមលើករឿងព្រៃង ១ មកថ្លែង ឲ្យឃើញច្បាស់ក្នុងសេចក្តីស្លាប់នេះទៀត ក្នុងរឿងព្រៃងនោះលោកបានដំណាលតៗមកថា: មានមនុស្សម្នាក់ក្រទ្រព្យសម្បត្តិពន់ពេកណាស់ ហើយដំពាក់ពាក់-ព័ន្ធទ្រព្យគេក៏ច្រើន ក្នុងមួយថ្ងៃៗ គេមកតឹងតាទ្រព្យរបស់ជាច្រើនដូច, ប៉ុន្តែកំសត់នោះដល់ពាល់គំនិតគិតរកវត្ថុអ្វីសង់គេពុំបាន ក៏កាន់តែព្រួយចិត្តឡើងៗ គិតចង់ស្លាប់ធាប់ មិនចង់រស់នៅជាមនុស្សតទៅ ក៏ស្រែកហៅរកព្រះកាល (១) ថា: "ព្រះកាលអើយមកយកខ្ញុំធាប់ទៅ កុំឲ្យខ្ញុំរស់នៅយូរ ពិបាកចិត្តខ្ញុំពេកណាស់" ស្រែកហៅយ៉ាងនេះគ្រប់ជាដង ។

---

១ ប្រែថា សេចក្តីស្លាប់ ។

គ្រានោះ ព្រះកាលក៏មកតាមពាក្យដែលបុរសនោះស្រែកហ្វៅមែន ប្រៃដ៏ខ្លួនជាតាចាស់ម្នាក់ដើរមកដល់ហើយស្ងរថា "ចុះហេតុដូចម្តេច បានជាអ្នកឯងស្រែកហ្វៅយើងជាព្រះកាលអីដល់ម្ទ៉ះ អ្នកឯងកើតទុក្ខមិនសុខចិត្តពីរឿងអ្វីខ្ទះ? ចូរប្រាប់យើងឲ្យធាប់" ។ ចៅកំសត់នោះតបថា "ឆ! លោកអើយ សព្វថ្ងៃនេះខ្ញុំទាល់ក្រពេកណាស់ កើតព្ជួយចិត្តជ្សិតជំពាក់ទ្រព្យគេក៏ច្រើន គេមកតឹងទាររឿយ ។ រកវត្ថុអ្វីសងគេពុំបានសោះ ព្រោះហេតុនោះបានជាខ្ញុំស្រែកហ្វៅលោក ឲ្យលោកយកខ្ញុំឲ្យធាប់ទៅ កុំឲ្យវេទនាយូរពេក" ។ ព្រះកាលប្រាប់វិញថា: "ហើដូច្នោះអ្នកឯងថប់ថ្ងីពេលនេះយើងមិនទាន់យកអ្នកឯងនៅទ្បើយទេ យើងជួយអ្នកឯងឲ្យមានទ្រព្យសម្បត្តិមានអាយុវែង បានសប្បាយចិត្តទៅខាងមុខសិនតែត្រូវអ្នកឯងរៀនមន្តអាគមតាថាថ្នាំសង្ក្ទូវពីយើង រួចអ្នកយកទៅរកមើលជម្ងឺគេចុះ នឹងបានមានទ្រព្យសម្បត្តិច្រើនទៅខាងមុខមិនខាន" ។ ចៅកំសត់នោះមានចិត្តត្រេកអរ ក៏បានទទួលរៀនតាមពាក្យព្រះកាលប្រាប់ដោយសព្វគ្រប់ ហើយព្រះកាលនោះក៏បាត់ខ្លួនពីទីនោះមួយរំពេចទៅ ។ គ្រាខាងក្រោយមក ចៅកំសត់នោះបានដើរមើលជម្ងឺអ្នកស្រុកដែលឈឺទាំងប៉ុន្មាន ក៏បានសះជាដូចសេចក្តីប្រាថ្នា ហើយគេបូជារង្វាន់ខាន់ខាវជាច្រើន យូរ ៗ ទៅត្រឡប់ជាអ្នកមានទ្រព្យសម្បត្តិយ៉ាងធំស្តុកស្តម្ភមាំមួនឡើង ។ គ្រាខាងក្រោយមកទៀត ព្រះកាលនោះមកប្រាប់វិញថា: "អ្នកឯងរៀបចំខ្លួនប្រាណចុះ ប្រាំពីរថ្ងៃទៀត យើងមកយក

អ្នកឯងហើយ" ។ អ្នកនោះក៏កើតសេចក្តីទោមនស្សតូចចិត្តគិតថា "កាលពីដើមអញកំពុងទាល់ក្រលំបាកវេទនា បានខំស្រែកហៅព្រះកាលឲ្យមកយកឲ្យធាប់ ពេលនោះព្រះកាលមិនព្រមយក ក៏ជួយទំនុកបំរុងអញឲ្យមានទ្រព្យសម្បត្តិឡើង ឥឡូវអញមានទ្រព្យសម្បត្តិស្មើលបួលហើយ ត្រឡប់ជាមកយកអញទៅវិញ នរណាសុខចិត្តទៅ បើជូច្នេះគួរអញនឹងគិតវេះគេចរត់ឲ្យផុតពីព្រះកាល កុំឲ្យតាមរកអញឃើញឡើយ" គិតជូច្នេះហើយក៏ប្រាប់ប្រពន្ធកូនតាមរឿងនោះដោយសព្វត្រប់ ដល់វេលាយប់ក៏ជញ្ជូនទ្រព្យសម្បត្តិទាំងអស់ នាំទាំងប្រពន្ធកូនចុះសំពៅបើកផ្ទងសំដៅទៅសមុទ្រក្រៅ ដោយគិតថា: មុខជានឹងផុតពីកណ្តាប់ដៃព្រះកាលហើយ ។ លុះបើកសំពៅត្រប់ ៧ ថ្ងៃ ដល់ទៅមហាសមុទ្រ ពេលនោះ កើតមានខ្យល់ព្យុះបក់ប្រាករលកមកផ្ទប់សំពៅលិចទៅក្នុងទឹកមហាសមុទ្រ ជនទាំងនោះក៏ស្លាប់ទាំងអស់គ្នាឥតមានសល់ម្នាក់ឡើយ ត្រូវជូចពាក្យព្រះកាលថា ប្រាំពីរថ្ងៃទ្រតនឹងមកយកនោះឯង ។

រឿងនេះផ្ទុះឲ្យយល់ច្បាស់ថា មនុស្សសត្វគេចពីស្លាប់មិនផុតព្រោះជារបស់ត្រូវមានស្មើគ្នា ជូច្នេះ យើងកុំក្រេចថាខ្លួនយើងមិនស្លាប់ហើយកុំក្រេចថាខ្លួនយើងត្រូវចាប់ជាតិជាថ្មីទ្រតៃ តាមយថាកម្មដែលខ្លួនបានសាងមក ។

សំដែងមកក្នុងវិរុទ្ធកថា សូមបញ្ចប់ត្រឹមប៉ុណ្ណោះ ឯវំ ។

ឧញ្ញាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម-សុិម សាស្ត្រាចារ្ស

នៅសាលាបាលីដាន់ទ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្ជួនឯង

កាលដែលនៅដាភេទបញ្ចដិតពី ព.ស. ២៤៨៦, ត.ស. ១៩៤៣

(តមក)

ឧក្ក្ហម្មានិកាជាតក ទី ១៣

លោកអាចារ្ស ឈឹម-សុិម ក្រុមដំនុំព្រះត្រៃបិដក

ប្រែពីបាលី

យោ បុគ្គលោ ទោសជនោតិ ឥទំ សត្ថា ជេតវនេ វិហ-
រន្តោ អត្ថនោ ទុក្ខំ អារព្ភ កថេសិ ។ សត្ថា រីអង្គសម្តេចព្រះបរម
សាស្ត្រាចារ្ស កាលទ្រង់សម្រាន្តព្រះឥរិយាបថនៅវត្តជេតពន ទ្រង់ប្រា-
រព្ធនូវសេចក្តីទុក្ខរបស់ព្រះអង្គ ទ្រង់សម្តែងធម៌ទេសនា មានបទព្រះ
បាលីថា យោ បុគ្គលោ ទោសជនោ ជូច្ចេះជាដើម ។

កិរ បានព្ធថា ភិក្ខុទាំងឡាយ ប្រជុំគ្នានិយាយក្នុងសាលាធម្មសភាថា
ឆ ហ្នាំ! ព្រះសាស្ត្រាជាម្ចាស់យើង ទ្រង់អត់សង្កត់នូវទុក្ខវេទនា ដែល
ប្រព្រឹត្តទៅក្នុងកាយនឹងក្នុងព្រះទ័យ ជរាបតែបានត្រាស់សម្មាសម្ពោ-
ធិញ្ញាណទ្បើង ។ តំ សុត្ថា សម្តេចព្រះបរមសាស្ត្រា ទ្រង់ព្រះសវនា-
ការព្ធពាក្យនោះហើយ ទ្រង់ចេញចាកគន្ធកុដី មកគង់លើព្រះបវរពុទ្ធា-
សនៈ ដែលគេរៀបចំសម្រាប់ព្រះអង្គ ហើយទ្រង់មានព្រះពុទ្ធដីកា

សួរថា. ម្នាលភិក្ខុតំងឡាយ, ឥឡូវនេះអ្នកតំងឡាយអង្គុយប្រជុំគ្នានិយាយពីរឿងអ្វី? ។ ភិក្ខុតំងនោះក្រាបបង្គំទូលតាមដំណើរសេចក្តីទើបព្រះជិនស្រីទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុតំងឡាយ, មិនត្រឹមតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, កាលពីដើម ក៏តថាគតធ្វាប់អត់ត្រាំនូវទុក្ខវេទនាដែរ គឺកាលដែលតថាគតកើតក្នុងត្រកូលកុដុម្ពិក: តថាគតបានដោះខ្ជូនរួចអំពីការសម្ងាប់នៃស្តេចមិនប្រកបដោយធម៌ ហើយបានរស់រួចជីវិតឡើងវិញ ដោយឧបាយធ្វៀសវៃ" សម្តេចព្រះជិនស្រីទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់គង់នៅដោយតុណ្ហីភាព ដរាបតែភិក្ខុតំងនោះអារាធនា ទើបព្រះសាស្តាទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា

អតីតេ កាលេ ក្នុងកាលដ៏កន្ធងរំលងទៅហើយ មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណស៊ី ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ព្រនាម ធុតធរ បានសោយរាជសម្បត្តិប្រកបដោយធម៌ តពីព្រះរាជបិតាមក; ព្រះបាទធុតធរនោះមានព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាម អជិត បានសោយ-រាជសម្បត្តិតមកទៀត ។ ត្រានោះ មានកុដុម្ពិក:ម្នាក់នៅក្នុងជនបទ ។ ព្រះពោធិសត្វទ្រង់បានមកកើតជាកូនកុដុម្ពិក:នោះ ឈ្មោះ ទុក្កម្មានិក ។ កុដុម្ពីជាបិតា បានប្រៀនប្រដៅទុក្កម្មានិកនោះ ក្នុងកាលដែលខ្ជូនរៀបទទួលអនិច្ចកម្មថា "ហៃបា អ្នកឯងកុំយកស្រីមេម៉ាយបីដងជាប្រពន្ធ, កុំយកបុរសបួសបីដងជាសំឡាញ់ កុំសេពតប់នឹងស្តេចឥតពិចារណាឡើយ" ។ កុដុម្ពិក:ផ្តាំពាក្យបីមាត់ដូច្នេះហើយ ក៏ទទួលអនិច្ចកម្មទៅ ។

ពោធិសត្វជាបុប្រតិតថា "បិតាអញបានផ្តាំយ៉ាងនេះ, តើពាក្យនេះនឹង
មានផលឬត្មានអេះ" កំពុងតែតិតជូច្មេះ ក៏ជួនជាមានស្រីម្នាក់មេម៉ាយបី
ជង មកសំដែងអាការស្និទ្ធស្នាល ត្លូរឲ្យចាប់ចិត្ត, ពោធិសត្វក៏គិតថា
"អាត្មាអញត្លូរល្ឋងពាក្យបិតាក្នុងត្រានេះចុះ" តិតតែប៉ុណ្ណោះហើយ
ក៏យកស្រីនោះមកធ្វើជាកិយារបស់ខ្លួន ។ តមកទ្រៃត មានបុរសម្នាក់
ប្លូសបីជង សឹកបីជង មកសំដែងសេចក្តីស្និទ្ធស្នាល ក៏ពោធិសត្វរាប់
រកយកបុរសនោះជាសំឡាញ់ទ្រៃត ។ ក្នុងកាលខាងក្រោយមក ទុក្ពម្មានិក
ពោធិសត្វចង់ល្ឋងចិត្តកិយា ក៏ទៅចាប់សុវណ្ណហង្សរបស់ព្រះរាជា ដែល
កំពុងត្រាច់ទៅក្សែរមាត់ស្ទឹង យកមកជីករណ្តៅមួយហើយជាក់ហង្សក្នុង
រណ្តៅនោះ ត្របជាលពពោកកក់ទុកប្រហោងតូចៗ កុំឲ្យហង្សនោះជាច់
ជង្ហើមស្ទាប់ ហើយត្រឲ្យប់មកផ្ទះវិញ សម្ទាប់ហង្សមួយជទៃទ្រៃត
ចិញ្ចាំស្ទជាស្រេចដំកល់ទុក ក្នុងកាលដែលកិយានោះទៅផ្សារបាត់ ។
កាលបើកិយាមកជល់, ក៏និយាយកុហកថា ខ្ញុំចាប់សុវណ្ណហង្សរបស់
ព្រះរាជាមកសម្ទាប់ចិញ្ចាំស្ទស្រេចទៅហើយ ។ កិយាគឺបន្ទោសថា
អ្នកប្តីអើយ, អ្នកឯងមិនជឹងទេឬ? អំពើនេះមានទោសធ្ងន់ណាស់! ។
កាលនោះ ក៏កើតសេចក្តីជ្ឌលជ្រើមឡើងក្នុងទីក្រុងទាំងអស់ ដោយ
ហេតុដែលបាត់សុវណ្ណហង្សរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ចាត់ឲ្យ
ចំណាយមាស ១ ពាន់ដំឡឹង ឲ្យអាមាត្យដើរប្រទក្សិណផ្សារ ឃោសនា
ផ្សាយដំណឹងថា ប៉ើអ្នកណាជឹងថាសុវណ្ណហង្សបាត់ដោយហេតុជូចម្តេច
នោះទ្រង់នឹងព្រះរាជទាន មាសមួយពាន់ដំឡឹងនេះ ។ ត្រានោះ កិយា

ទុក្កម្មានិក កំពុងចង់បានប្តីដទៃទៀតផង កំពុងចង់បានមាសនោះផង ក៏ធ្វើយធ្ងងទៅនឹងអាមាត្យអ្នកឃោសនាថា នែអ្នកទាំងឡាយអើយ, អ្នកវាល់ត្នាយកមាសមកឲ្យខ្ញុំចុះ ខ្ញុំដឹង ។ អាមាត្យស្សរថា ន្រណាចាប់សុវណ្ណហង្ស? ។ ស្រីនោះធ្វើយថា ប្តីខ្ញុំ ។ – ពិតមែនឬអ្វី? – ពិតមែន បានជាខ្ញុំថា ។ ទើបអាមាត្យទាំងឡាយនាំសេចក្តីនោះទៅក្រាបបង្គំទូលព្រះរាជា, ព្រះរាជាទ្រង់បង្គាប់ឲ្យចាប់ទុក្កម្មានិកបុរសនោះមក ។ អាមាត្យទាំងឡាយ ចាប់ទុក្កម្មានិកបុរសចងដោយចំណង ៥ ប្រការរាយដំប្រំនាំមកបង្ហាញព្រះរាជា ។ ចំណែកខាងបុរសឃួស ៣ ដងសឹក ៣ ដងដែលជាសំឡាញ់នោះ បានឃើញគេចាប់ទុក្កម្មានិកបុរសទៅហើយ ក៏ឥតមានសេចក្តីឈឺធ្មាល ឬដួយដោះសាអ្វីសោះ, ប្រែរជានិយាយដូច្នេះវិញថា អ្នកឯងឲ្យសំពត់មួយនោះមកខ្ញុំ, អ្នកឯងមើលចុះសំពត់របស់ខ្ញុំរហែកដូចគេជ្រៀក, អ្នកឯងជាប់ទោសទៅហើយ ចាំបាច់ប្រើប្រាស់សំពត់ធ្វើអ្វី ។ ទុក្កម្មានិកបុរសនោះ ក៏ឲ្យសំពត់ស្ងៀកសំពត់ដណ្តប់របស់ខ្លួនទៅ ។

ត្រានោះ ព្រះរាជាទ្រង់បង្គាប់ថា អ្នកទាំងឡាយ ចូរនាំរាទៅសម្ងាប់ខាងក្រៅនគរក្នុងថ្ងៃនេះកុំខាន ។ ទុក្កម្មានិកបុរសនោះ ក៏ទន្ទេញទន្ទូរថា "បើខ្ញុំស្ងាប់, ហង្សក៏ស្ងាប់; បើខ្ញុំមិនស្ងាប់, ហង្សក៏មិនស្ងាប់ដែរ" ។ អាមាត្យទាំងឡាយគម្រាមថា "ហង្សអ្នកឯងស្ងស៊ីអស់ទៅហើយ មានហង្សពីណារស់ឡើងវិញ!" គម្រាមដូច្នេះហើយក៏នាំទៅដើម្បីសម្ងាប់ ។ ថ្ងៃនោះ ជួនជាឆ្នាំទ្ងរ បិទទ្វារព្រះនគរក្នុងវេលា

រសៀល ។ អាមាត្យតាំងឡាយនោះ នាំទុក្កម្មានិកបុរសទៅកាន់ទ្វារទាងកើត ហៅឆ្នាំទ្វារថា នៃនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារធាប់ឡើង យើងនឹងនាំវាទៅសម្លាប់ក្នុងថ្ងៃនេះ ។ ឆ្នាំទ្វារធ្វើយថា បើព្រះរាជាពុំទាន់ជំនុំជំរះទោសបុរសនេះទេ, ទ្វាំមិនបើកទ្វារអស់ ៣ ថ្ងៃ, ព្រោះថាព្រះរាជា សម្លាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់បានពិចារណាទៅឡើយ ហើយធ្វើហ្លសទៅ សុទ្ធតែបានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ អាមាត្យសួរថា រឿងដែលគេមិនបានពិចារណាកន្ធងទៅហើយនោះតើជូចម្តេច? អ្នកឯងនិយាយរឿងនោះមកមើល ។ ឆ្នាំទ្វារនិយាយថា ពីដើមមានប្តីប្រពន្ធពីរនាក់ មានកូនប្រុសមួយ, អ្នកតាំងពីរនាក់នោះ ចិញ្ចឹមស្ការមួយជាទីស្រឡាញ់ប្រហែលនឹងកូន ។ ថ្ងៃមួយ ប្តីប្រពន្ធតាំងពីរនាក់ផ្តេកកូនទុកនៅឯផ្ទះ ហើយនាំគ្នាទៅស្រែ ចួនជាមានពស់មួយប៉ុនឈើច្រត់មកចឹកកូនរបស់អ្នកតាំងពីរនោះ ។ ស្ការក៏ស្ទុះទៅប្រទាំគ្នានឹងពស់, ទាំពស់ជាច់ជាកំណាត់ ។, ពស់ស្លាប់ទៅ កូនគាត់នោះក៏ស្លាប់ដែរ; ស្ការរត់ទៅទ្យជំណឹងដល់ម្ចាស់ឯស្រែ, ម្ចាស់យល់សេចក្តីនោះពុំបាន ដោយបានឃើញទ្លួនស្ការប្រឡាក់ឈាម ក៏គិតស្មានថាជាស្ការទាំកូនរបស់ទ្លួន ទើបនិយាយថា "យីអើ! យើងចិញ្ចឹមស្ការនេះស្រឡាញ់វាប្រហែលនឹងកូន ឥឡូវវាហ៊ានសម្លាប់កូនយើង", ថាតែប៉ុណ្ណោះ ក៏សំពងស្ការនោះដោយទំពក់រនាស់ទាល់តែស្ការស្លាប់ទៅ ។ ប្តីប្រពន្ធតាំងពីរនាក់ មកដល់ផ្ទះបានឃើញខ្មោចពស់នៅកៀនជញ្ជាំង ឃើញតាំងកូនស្លាប់នៅក្សែរពស់

នោះផង ទើបដឹងពិតជាកូនស្វាប់ដោយពស់ចឹក ក៏យំទួញបោកប្រះបម្រះ
នឿលនៅទីនោះ ។ ឆ្នាំទ្វារនិយាយថា ហេតុដែលស្តេចម្ចាស់យើង
មិនបានតិតឲ្យស្រេច ក្រែងកន្ទងទៅៗជាជូច្នោះទេដឹង ។

អាមាត្យទាំងអស់ ក៏នាំទុក្ខម្នានិកបុរសទៅកាន់ទ្វារខាងត្បូងទៀត,
ហៅឆ្នាំទ្វារប្រាប់ថា ម្នាលនាយ, បុរសនេះជាចោរកំណាច, អ្នកឯង
បើកទ្វារឆាប់ឡើង យើងនឹងនាំរាទៅសម្ចាប់ក្នុងថ្ងៃនេះ ។ ឆ្នាំទ្វារ
ឆ្វើយថា បើព្រះរាជាពុំទាន់ជំនុំជំរះទោសបុរសនេះទេ, ខ្ញុំមិនបើកទ្វារ
អស់ ៣ ថ្ងៃ ព្រោះព្រះរាជាសម្ចាប់មនុស្សមិនមែនជាចោរកំណាច, អំពើ
ដែលទ្រង់ពុំទាន់បានពិចារណានៅឡើយ ហើយកន្ទងហួសទៅ សុទ្ធតែ
បានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ អាមាត្យសួរថា រឿងដែល
គេមិនបានពិចារណាកន្ទងទៅហើយនោះគើជូចម្តេច? អ្នកឯងនិយាយ
រឿងនោះមកមើល ។ ឆ្នាំទ្វារនិយាយថា មានបុរសម្នាក់ជាព្រានសត្ត
ស្វាប ចិញ្ចឹមសត្វខ្ទែងមួយ ។ ថ្ងៃមួយ បុរសនោះទៅព្រៃ ដើម្បី
សម្ចាប់សត្វស្វាប ។ ខ្ទែងក៏បានទៅជាមួយផង ។ បុរសនោះស្រេកទឹក
ក៏ចូលទៅក្នុងស្ទឹងដើម្បីផឹកទឹក ។ មានពស់មួយនៅក្នុងទីកំបាំង; បុរស
ស្រេកទឹកខ្ទាំង ប្រឹងតែមមុលចូលទៅដើម្បីផឹកទឹក មិនបានឃើញពស់
នោះសោះ ។ ខ្ទែងឃើញពស់នោះហើយ ក៏គិតថា "ឧហ្នា! ម្ចាស់អញ
មិនឃើញពស់នេះទេតើ, បើជូច្នេះអញនឹងឃាត់គាត់អេះ", គិតជូច្នេះ
ហើយក៏ទទះស្វាបកព្រោ្ជាកទឹកកុំឲ្យផឹក ។ បុរសនោះ ក៏រាយក្បាល
ខ្ទែងដោយជងផ្ទូ ខ្ទែងនោះក៏ស្វាប់ទៅ ។ បុរសឈ្លោកផឹកទឹកទៀត

ពស់ស្ទុះក្នែតមកចឹកផ្ទប់ចំក្នែក; បុរសក៏ស្រែកទ្រហោយំឡើងដោយគិតថា ខ្ញែងនេះយើញក៏យនេះហើយតើ បានជាវាយាត់អញ ។ បុរសនោះវេងកើតទុក្ខម្នេញ ដោយស្តាយខ្ញែងជាទីស្រឡាញ់ផ្សំទាំងខ្ចប្រក្នែកនោះផង ។ ឆ្នាំទ្វារនិយាយនឹងអាមាត្យទាំងឡាយថា ហេតុដែលស្តេចម្ចាស់យើងមិនបានគិតឲ្យស្រេច ក្រែងកន្ទងហ្លួសទៅ ។ ជាជូច្នោះទេដឹង ។

អាមាត្យទាំងឡាយនោះ នាំទុក្ខម្នានិកបុរសទៅកាន់ទ្វារទាងលិចទ្រៃត, ហៅឆ្នាំទ្វារប្រាប់ថា ម្នាលនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារធាប់ឡើង យើងនឹងនាំវាទៅសម្ចាប់ក្នុងថ្ងៃនេះ ។ ឆ្នាំទ្វារធ្វើយថា បើព្រះរាជាពុំទាន់ជំនុំជំរះទោសបុរសនេះទេ ខ្ញុំមិនបើកទ្វារអស់ ៣ ថ្ងៃ. ព្រោះថា ព្រះរាជាសម្ចាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់ពិចារណានៅឡើយ ហើយកន្ទងហ្លួសទៅ សុទ្ធតែបានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ អាមាត្យស្លូរថា រឿងដែលគេមិនបានពិចារណាកន្ទងទៅហើយនោះ តើដូចម្តេច? អ្នកឯងនិយាយរឿងនោះមកមើល ។ ឆ្នាំទ្វារនិយាយថា បពិត្រអ្នកទាំងឡាយដ៏ចំរើន, បានពុតមកថា មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី; ព្រះរាជាអង្គនោះ មានព្រះរាជធីតាមួយព្រះអង្គ ព្រះនាមនាងសុនូរា តែងទៅស្រងក្រសាលក្នុងស្រះបោក្ខរណីរាល់ ។ ថ្ងៃ; មានធ្វែមួយតែងទៅតាមព្រះរាជធីតានោះផង, ព្រះរាជធីតាទ្រង់ពាក់គ្រឿងប្រដាប់ឲ្យដ៏ព្រះស្ងរងសុទ្ធសឹងតែមាសនឹងពេជ្ជ ទ្រង់ស្តេចទៅដល់ទីជិតស្រះបោក្ខរណី ចួនជាមានបុរសម្នាក់

ជាអ្នកមានពៀរនឹងព្រះរាជា មកលបបង្ក្ប់ចំរូងក្បែរមាត់ស្រះបោក្ខរណី ដើម្បីឲ្យជង់ព្រះរាជធីតានោះ ឥតមានទរណាម្ជយជឹងហេតុនោះស្រាះ ។ ឆ្កែបានឃើញហេតុនោះហើយ ក៏ស្ទុះទៅស្ទាក់យាត់ព្រះរាជធីតា ដែលកំពុងយាត្រាទៅ ។ ព្រះរាជធីតានោះក៏ចចេសតែទៅ ។ ជាន់ចំរូងដែលបុរសមានពៀរបង្ក្ប់ទុក មុតសុគតក្នុងទីនោះទៅ ។ ឆ្កែដឹងជាមានគ្រោះថ្នាក់ពុំល្អដូច្នោះ ក៏ស្ទុះទៅពាំទាញគ្រឿងប្រដាប់របស់ព្រះរាជធីតា នាំយកទៅដំកល់ទុក ក្នុងទីជិតព្រះរាជា ដើម្បីថ្ទាយដំណឹង ។ ព្រះរាជាទ្រង់ទស្សនាការឃើញឆ្កែពាំគ្រឿងប្រដាប់រត់មកដូច្នោះ ក៏ទ្រង់គិតស្មានថា "ធីតារបស់អញប្រាកដជាឆ្កែនេះសម្ងាប់ហើយ បានជារាពាំគ្រឿងប្រដាប់មក", ហើយទ្រង់ឲ្យសម្ងាប់ឆ្កែនោះភ្ងាម ។ លុះទ្រង់ជ្រាបជាព្រះរាជធីតាសុគតដោយហេតុដទៃវិញ, ទើបទ្រង់ជាទុក្ខម្នេញទ្រង់ព្រះកន្សែងសោកបោកប្រះព្រះអង្គ គង់ជ្រប់ទូវអស់កាលជាយូរអង្វែង ទ្រង់ព្រះកន្សែងថ្ងៃងរិយោគសោកស្ពាយថា ឲ! អាត្មាអញអើយ, មិនដឹងហេតុនោះស្រាះ! ឥឡូវនេះខុសអស់ឲ្យគេសម្ងាប់ឆ្កែជ្រុលទៅ ។ ឆ្មាំទ្វារនិយាយនឹងអាមាត្យតាំងឡាយថា ហេតុដែលស្ពេចម្ចាស់យើងមិនបានគិតឲ្យស្រេច ក្រែងកន្ទងហ្ជសទៅ ។ ជាដូច្នោះទេដឹង ។

អាមាត្យតាំងឡាយនោះ នាំទុក្ខម្មានិកបុរសទៅកាន់ទ្វារខាងជើងទៀត, ហៅឆ្មាំទ្វារប្រាប់ថា ម្នាលនាយ, បុរសនេះជាចោរកំណាច, អ្នកឯងបើកទ្វារធាប់ឡើង យើងនឹងនាំរាទៅសម្ងាប់ក្នុងថ្ងៃនេះ ។ ឆ្មាំទ្វារឆ្ងើយថា បើព្រះរាជាពុំទាន់ជំនុំជំរះទោសបុរសនេះទេ, ខ្ញុំមិនបើកទ្វារ

អស់ ៣ ថ្ងៃ, ព្រោះថា ព្រះរាជាសម្ចាប់មនុស្សមិនមែនជាចោរកំណាច, អំពើដែលទ្រង់ពុំទាន់បានពិចារណានៅឡើយ ហើយកន្ធងហ្លួសទៅ សុទ្ធតែបានសេចក្តីក្តៅក្រហាយស្តាយក្រោយ ។ អាមាត្យស្លូរថា រឿងដែលគេមិនបានពិចារណាកន្ធងទៅហើយនោះតើដូចម្តេច? អ្នកឯងនិយាយរឿងនោះមកមើល ។ ឆ្នាំទ្ធារនិយាយថា បានពុមកថា មានបុរសជាសំឡាញ់នឹងគ្នាពីរនាក់ស្រឡាញ់គ្នាណាស់ ម្នាក់នៅស្រុកខាងលិច ម្នាក់នៅស្រុកខាងកើត ។ សំឡាញ់នៅស្រុកខាងលិច ទៅផ្ទះសំឡាញ់នៅស្រុកខាងកើត ។ សំឡាញ់នៅស្រុកខាងកើតនោះ មានចិញ្ចឹមឆ្កែមួយ ជាទីស្រឡាញ់ពេញចិត្តណាស់, ប៉ុន្តែទាល់នឹងគ្មានអ្វីឲ្យជាទីពុកដល់សម្ចាញ់ដែលមកលេងសោះ ក៏ឲ្យឆ្កែនោះថា សំឡាញ់, ឆ្កែនេះ ខ្ញុំឲ្យអ្នកឯង, ចូរអ្នកឯងយកវាទៅចិញ្ចឹមចុះ ។ សំឡាញ់នៅស្រុកខាងលិចនោះ ក៏ទទ្លួលយកឆ្កែហើយលាសំឡាញ់ថា "សំឡាញ់អើយ, អ្នកឯងឲ្យឆ្កែខ្ញុំ។ អរគុណហើយ, ចូរអ្នកឯងនៅឲ្យសុខ កុំបីមានទុក្ខសោករោគភ័យឡើយ" ហើយក៏បបោសអង្អែលឆ្កែនោះ នាំទៅកាន់ទីលំនៅរបស់ខ្លួន ដោយសេចក្តីពេញចិត្ត ។ លុះចំណេរមកខាងក្រោយបុរសនោះចងខ្សែ(១) នៅកឆ្កែ ហើយបញ្ជូនទៅកាន់សំឡាញ់ខាងកើត ដើម្បីឲ្យដំណឹងសុខ-ទុក្ខ ។ ឆ្កែគិតថា "ម្ចាស់អញនេះ ចងខ្សែឲ្យអញដោយផ្ចិតផ្ចង់ណាស់, បើដូច្នេះ គ្លូរតែអញទៅប្រាប់ដល់ម្ចាស់ដើមសិនចុះ" គិតតែប៉ុណ្ណោះ

---

១ ខ្សែនេះប្រហែលជាខ្សែមាសឬខ្សែអ្វីដែលមានជម្លៃច្រើន, បានជាម្ចាស់ដើមសំគាល់ថាឆ្កែនេះលួច ។

កំពៅភ្លាម ។ បុរសនៅស្រុកខាងកើតឃើញឆ្កែមកដល់ គិតថា "ឆ្កែនេះលួចទ្រព្យសំឡាញ់អញរត់មកហើយតើ" តែតាប់ណ្លេះក៏សំពងក្បាលឆ្កែដោយដំបង ឆ្កែនោះក៏ស្លាប់ទៅ ។ ចំណែកខាងសំឡាញ់នៅស្រុកខាងលិច កាលបើបាត់ឆ្កែនោះយូរពេក ក៏ទៅតាម, សួរសំឡាញ់នៅស្រុកខាងកើតថា ខ្ញុំបានចងវែទ្រនៅកឆ្កែហើយបញ្ជូនវាមក, តើអ្នកឯងបានឃើញវាឬទេ? ។ សំឡាញ់នៅស្រុកខាងកើតឆ្លើយថា ខ្ញុំឃើញដែរ, ប៉ុន្តែខ្ញុំស្មានជាវាលួចទ្រព្យអ្នកមក ឃុនជាខ្ញុំវាយវា, ឥឡូវវាក្រុយទៅហើយ ។ បុរសខាងពីរនាក់ក៏ជាខ្ពុកខ្ពួញយំគ្នាគ្រហាយស្ពាយក្រោយយ៉ាងខ្លាំង ។ ឆ្មាំព្រានិយាយនឹងអាមាត្យទាំងឮយថា ហេតុដែលស្តេចម្ចាស់យើង មិនបានគិតឲ្យស្រេចក្រែងកន្ទុងហួសទៅ។ ជាដូច្នោះទេដឹង ។

កាលឆ្មាំព្រានឹងអាមាត្យទាំងនោះ កំពុងនិយាយគ្នាយ៉ាងនេះ ក៏ពក្រីក្លីស្វាងឡើង; អាមាត្យទាំងឮយ ក៏នាំខ្ពុកម្នាងកបុរសនោះទៅក្រាបបង្គំទូលព្រះពជាវិញ ។ ព្រះពជាទ្រង់ទស្សនាការ ឃើញពជបុរសទាំងឮយនាំខ្ពុកម្នាងកបុរសមកវិញ ទ្រង់ត្រាស់សួរថា អញឲ្យយកវាទៅសម្ងាប់ ម្តេចក៏មិនសម្ងាប់ បែរជានាំវាមកវិញ? ។ អាមាត្យទាំងឮយនោះ ក្រាបបង្គំទូលព្រះពជាតាមដំណើរសេចក្តីដែលឆ្មាំព្រាទាំងឮយនិយាយ សព្វគ្រប់ប្រការ ។ ព្រះពជាទ្រង់ព្រះសារនាការហើយទ្រង់សួរខ្ពុកម្នាងកបុរសថា អ្នកឯងចង់និយាយដូចម្តេច? ។ គានោះខ្ពុកម្នាងកពោធិសត្វក្រាបបង្គំទូលព្រះពជាថា បពិត្រព្រះពជសម្ភារ,

កាលដែលបិតារបស់ទូលព្រះបន្ទំជាខ្ញុំ ស្រៀបនឹងទទួលអនិច្ចកម្មទៅ គាត់
បានឲ្យឧវាទដល់ទូលព្រះបន្ទំជាខ្ញុំសព្វគ្រប់ ទើបគាត់ទទួលអនិច្ចកម្មទៅ,
ទូលព្រះបន្ទំជាខ្ញុំចង់ល្ឆងពាក្យបិតា បានជាធ្វើយ៉ងនេះ, ប៉ុន្តែឥតប្រាប់
នរណា ដទៃដល់ម្នាក់សោះ ប្រាប់ត្រឹមតែប្រពន្ធមួយប៉ុណ្ណោះ, ដល់ម្ចោ៉ះ
គង់តែមានគេដឹងសាយសុះ; កាលដែលព្រះអង្គឲ្យគេចាប់ទូលព្រះបន្ទំជា
ខ្ញុំមកនោះ ស្រាប់តែទូលព្រះបន្ទំជាខ្ញុំបានយើញសំឡាញ់ម្នាក់ស្ទុះមក,
វាក៏កើចសំពត់មួយរបស់ទូលព្រះបន្ទំជាខ្ញុំ ដែលប្រឡាក់ដោយឈាមយក
បាត់ទៅ, ទូលព្រះបន្ទំជាខ្ញុំ ក៏សុខចិត្តឲ្យវាឥតស្តាយស្រណោះ; ណ្ហើយ
ស្រឹងសំឡាញ់នោះ កុំបាច់ថ្ងៃងចុះ, ចំណែកខាងហង្សនោះទូលព្រះ
បន្ទំជាខ្ញុំទុកនៅទីត្រង់ណោះ ពុំបានសម្ងាប់ទេព្រះអង្គ ។ ព្រះរាជាត្រាស់
ថា អ្នកឯងចូរទៅយកហង្សមក ។ ព្រះពោធិសត្វក៏ទៅនាំហង្សមកដំកល់
ទុកក្នុងព្រះរាជលាន ។ ត្រានោះ ព្រះរាជាទ្រង់ត្រាស់ស្តូរអំពីបណ្តាំ
បិតា លុះបានជ្រាបសព្វគ្រប់ប្រការ ទើបទ្រង់ត្រាស់ថា "ហៃមហាបុរស,
ចូរអ្នកទទួលយកនូវសម្ឆត្តិឧបរាជចុះ" ហើយទ្រង់ប្រគល់រាជសម្ឆត្តិ
ពាក់កណ្តាល ។ មហាបុរសក៏ទូលទាស់ព្រះរាជឧន្ទ្ការថា "បពិត្រ
ព្រះរាជសម្ការ, បិតារបស់ទូលព្រះបន្ទំជាខ្ញុំ បានផ្តាំថា "ស្តេចណាឥត
ពិចារណា, កូនឯងកុំនៅក្រោមបង្គាប់ស្តេចនោះឡើយ", ឥឡូវនេះព្រះ
សម្មតិទេព ជាស្តេចឥតពិចារណា, ឲ្យគេសម្ងាប់ទូលព្រះបន្ទំជាខ្ញុំ
ដែលជាមនុស្សមិនទាន់គ្លូរដល់ការសម្ងាប់, ទូលព្រះបន្ទំជាខ្ញុំពុំនៅក្នុង

ដែនព្រះអង្គទេ", មហាសត្វទូលទាស់ព្រះរាជទង្ការដូច្នេះហើយ ទើប
ពោលជាបទគាថាដូច្នេះថា:

យោ បុគ្គលោ ទោសជនោ ន សហាយោ ទុក្ខប្បត្តោ
សុខិតោ យាជយិ មិត្តំ ទីឃំ កាលំ ទុក្ខំ បត្តោ
យា ឥត្ថីបិ តិរិធរា. ន ភរិយា ទុក្ខប្បត្តោ
សុខិតា យាតិ វិនាសំ ទីឃំ កាលំ ទុក្ខំ បត្តោ

បុគ្គលឯណា ជាជនកាចអាក្រក់, អ្នកផងមិនត្រូវយកជា
សំឡាញ់ឡើយ, ព្រោះវានឹងនាំឲ្យដល់ទូវសេចក្តីទុក្ខ, គឺថា
បើវាបានសុខហើយ អាចនឹងហ៊ានសម្ងាប់មិត្ត ធ្វើមិត្ត
ឲ្យដល់ទូវសេចក្តីទុក្ខអស់កាលជាយូរអង្វែងទៅ, ស្រីដែល
មេម៉ាយបីជង អ្នកផងមិនត្រូវយកជាភិរិយាឡើយ, ព្រោះវា
នឹងនាំឲ្យដល់ទូវសេចក្តីទុក្ខ, គឺថាបើវាបានសុខហើយ វានឹង
នាំទៅកាន់សេចក្តីវិនាស ធ្វើឲ្យដល់ទូវសេចក្តីទុក្ខអស់កាល
ជាអង្វែង; បុគ្គលឯណាប្រព្រឹត្តកន្ធងធម៌ គឺលុះក្នុងអំណាច
ឆន្ទាគតិ ទោសាគតិ ភយាគតិ មោហាគតិ, បុគ្គលនោះ
នឹងសាបសូន្យចាកយស ដូចជាព្រះចន្ទខាងរនោច, បុគ្គល
ឯណាមិនប្រព្រឹត្តកន្ធងធម៌ គឺមិនលុះក្នុងអំណាច ឆន្ទាគតិ
ទោសាគតិ ភយាគតិ មោហាគតិទេ, បុគ្គលនោះនឹងពេញ
ដោយយសដូចព្រះចន្ទខាងខ្នើត, បពិត្រព្រះរាជា, ព្រះចន្ទ

រនោច រមែងសាបសូន្យទៅមួយថ្ងៃបន្ទិចៗដូចម្តេចមិញ, បុគ្គលដែលសមាគមគប់នឹងអសប្ប្យុរស ក៏ដូចជាព្រះចន្ទខាងរនោចដូច្នោះ; បពិត្រព្រះរាជា ឯព្រះចន្ទខាងខ្នើត រមែងចំរើនឡើងមួយថ្ងៃបន្ទិចៗ ដូចម្តេចមិញ បុគ្គលដែលសមគប់នឹងសប្ប្យុរស ក៏ដូចជាព្រះចន្ទខាងខ្នើតដូច្នោះ ។ មួយយ៉ាងទៀត ជាតិសត្វទឹកមានត្រីជាដើម ដែលធ្លាប់នៅក្នុងទីទំនាប រមែងពុំត្រេកអរលើទីទួលសោះ ដូចម្តេចមិញ, ក៏ចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ ពុំបានលូតលាស់ស្រស់ស្រាយទៅរកការសេពគប់នឹងអសប្ប្យុរសដូច្នោះដែរ, បពិត្រព្រះជិនិន្ទពិនប្រជា, ជាតិសត្វទឹកចូលចិត្តនៅក្នុងទឹក ដែលខ្ជូនធ្លាប់អាស្រ័យនៅយូរហើយយ៉ាងណា, ទូលព្រះបង្គំជាខ្ញុំ ក៏ពេញចិត្តចំពោះការសមគប់នឹងសប្ប្យុរស ដែលធ្លាប់សមគប់មកយូរហើយយ៉ាងនោះដែរ ។ ស្តេចឯណា ផ្ទាញ់មនុស្សដែលមិនគ្ជរផ្ទាញ់, ស្តេចនោះ ឈ្មោះថាស្តេចកំណាចកាចអាក្រក់; បុគ្គលឯណា ផ្ទាញ់មិត្តសំឡាញ់របស់ឯង, បុគ្គលនោះមិនឈ្មោះថាសំ-ឡាញ់ទេ; ស្រីឯណាហ៊ានប្រាថ្នាអាក្រក់ឥតខ្វាច, ស្រីនោះមិនឈ្មោះថាកិយាទេ; ជនឯណាមិនចិញ្ចឹមមាតាបិតា, ជននោះមិនឈ្មោះថាកូនទេ; ជនឯណាមានចិត្តមិនស្ងប់រម្ងាប់, ជននោះមិនឈ្មោះថាសប្ប្យុរសទេ; ជនឯណាមិនពោលនូវធម៌, ជននោះឈ្មោះថាអសប្ប្យុរស ។

កាលបើព្រះពោធិសត្ត និយាយយ៉ាងនេះហើយ, ព្រះរាជាទ្រង់ត្រាស់ថា បពិត្រមហាបុរស, ខ្ញុំនឹងតាំងនោក្នុងឧរាទរបស់អ្នកឯងដោយពិត, សូមអ្នកនោក្នុងទីនេះចុះ ។ ព្រះពោធិសត្ត ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ពាក្យបិតារបស់ទូលព្រះបង្គំជាខ្ញុំផ្តាំយ៉ាងណា ទូលព្រះបង្គំជាខ្ញុំធ្វើតាមយ៉ាងនោះពុំឲ្យយ្រៀងឃ្នាត, ឯព្រះរាជឧង្ការរបស់ព្រះអង្គ សូម្បីមួយព្រះឧស្ម ឬពីរព្រះឧស្ម ក៏ទូលព្រះបង្គំជាខ្ញុំពុំធ្វើតាមដែរ ។ ព្រះរាជាទ្រង់ត្រាស់តទៅទៀតថា បពិត្រមហាបុរសដ៏ចំរើន, ចូរអ្នកឯងជាស្តេចសោយរាជ្យប្រកបដោយធម៌ចុះ កុំទៅប្រទេសដទៃឡើយ ។ មហាបុរសក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំពុំនៅក្នុងនគររបស់ស្តេច ដែលធ្វើការឥតពិចារណាទេ", ថាតែប៉ុណ្ណោះក៏សូមឲ្យព្រះរាជាអត់ទោសខ្ជូន ហើយចេញក្រូសទៅឯនគរតក្កសិលា ទៅសម្រាន្តសម្រាកអាត្មានៅលើថ្មមង្គលសិលា នាព្រះរាជ-ឧទ្យាន ។ ខណៈនោះ ព្រះរាជាក្រុងតក្កសិលា ទ្រង់សោយព្រះទិវង្គតរលត់ព្រះជន្មទៅ ។ ពួកអាមាត្យក៏បានរៀបពិធីបុណ្យបូជាព្រះបរមសពអស់ ៧ ថ្ងៃ; ដល់ថ្ងៃគំរប់ ៧ អាមាត្យទាំងនោះ ក៏បានប្រជុំមហាសន្និបាតប្រឹក្សាគ្នាថា ឥឡូវនេះ យើងឥតពីព្រះរាជាទៅ មិនអាចរក្សានគរបានទេ, ចុះយើងនឹងធ្វើដូចម្តេច? ។ គ្រានោះ មានអាមាត្យអ្នកធ្ងាតម្នាក់និយាយឡើងថា អស់លោកទាំងឡាយ, ឆ្លូវតែយើងទាំងឡាយ ទឹមបុស្សរថ បញ្ជូនទៅ,ប៉ើបុស្សរថទៅសំដៅផ្ទះអ្នកណាអ្នកនោះឯងហើយជាស្តេច ។ អាមាត្យទាំងនោះ ក៏ទឹមបុស្សរថ

ដោយសេះសន្ធព ៤ គូ និយាយបួងសួងថា "សូមបុស្សរថចូលទៅ
កាន់ផ្ទះអ្នកមានបុណ្យ ដែលគ្ឆរជាស្តេចម្ចាស់យើង" ដូច្នេះហើយលែង
បុស្សរថនោះទៅ ។ បុស្សរថនោះប្រទក្សិណព្រះរាជនិវេសន៍ ឥតទៅ
កាន់ផ្ទះនរណាមួយសោះ, ចេញទៅខាងក្រៅនគរ ហើយចូលទៅក្នុង
ទ្យាន ។ អាមាត្យទាំងអស់ ក៏ផ្ទងតូរ្យតន្ត្រីគ្រប់បែបហៅតាម
ក្រោយបុស្សរថ ។ បុស្សរថ ប្រទក្សិណដែនថ្មមង្គលសិលាដែលព្រះ
ពោធិសត្វសម្រាក ហើយឈរនឹងថ្ពល់នៅកន្ទែងនោះ ។ គ្រានោះ
បុរោហិត បានឃើញលក្ខណៈត្រង់ព្រះបាទមហាបុរស ក៏និយាយឡើង
ថា "បុរសនេះ ជាអ្នកបុាជ្ញ អាចសោយរាជ្យក្នុងទ្វីបទាំង ៤ មានទ្វីប
តូច ៨ ពាន់ជាបរិវារបាន", ទើបបុរោហិតនិយាយទៅកាន់មហាបុរស
ថា រាជសម្ឈត្តិរបស់ព្រះអង្គដល់មកហើយ, សូមព្រះអង្គសោយរាជ្យ
ចុះ ។ ព្រះពោធិសត្វឌ្ឍពាក្យនោះហើយស្ឆរថា ស្តេចរបស់អ្នកទាំង
ឡាយ ឥតព្រះរាជបុត្រ ឥតព្រះរាជវង្សានុវង្សទេឬអ្វី? ។ អាមាត្យ
ទាំងឡាយធ្វើយថា ត្មានទេព្រះអង្គ ។ ព្រះពោធិសត្វស្ឆរទៀតថា ចុះ
អ្នកទាំងឡាយគាប់ចិត្តចំពោះខ្ញុំ ព្រមចិត្តគំនិតគ្នាហើយឬ? ។ អាមាត្យ
ទាំងអស់ក៏ធ្វើយព្រមគ្នាឡើងថា បពិត្រព្រះសម្មតិទេព, ទូលព្រះបង្គំជាខ្ញុំ
ទាំងអស់គ្នា គាប់ចិត្តចំពោះព្រះអង្គ ឥតមាននរណាមួយយល់ទាស់ឡើយ;
សូមទ្រង់ព្រះមេត្តាប្រោស ទទួលសោយរាជសម្ឈត្តិកុំប្រកែកឡើយ ។
ព្រះពោធិសត្ត ក៏ទទួលព្រម ។ បុរោហិតមានសេចក្តីសោមនស្ស បាន
រៀបចំអភិសេកព្រះពោធិសត្វក្នុងទីនោះតែម្តង ហើយអញ្ជើញព្រះ

ពោធិសត្វឲ្យឡើងគង់លើបុស្សរថ នាំចូលទៅកាន់ព្រះនគរ ។ បណ្ណាជន
ទាំងអស់នោះក៏ផ្គងតូរ្យតន្ត្រីឡើង អ្នកខ្លះទៅខាងមុខ អ្នកខ្លះនៅខាង
ក្រោយ ហែហមតាមលំដាប់លំដោយចូលទៅក្នុងព្រះនគរ ។ ព្រះ
ពោធិសត្វទ្រង់សោយរាជសម្បត្តិប្រកបដោយធម៌ ។ តាំងពីថ្ងៃនោះមក
ទ្រង់ឲ្យធ្វើសាលាទាន ៦ ខ្នង គឺទៀបទ្វារនគរទាំងបួន ៤ ខ្នង ត្រង់ពាក់
កណ្ណាលនគរមួយខ្នង ទៀបទ្វារព្រះរាជនិវេសន៍ ១ ខ្នង ហើយទ្រង់
ចំណាយព្រះរាជទ្រព្យ ៦ សែនកហាបណៈ ឲ្យជាទានដល់អ្នកកំសត់
ទុគិតរាល់ៗថ្ងៃ ។

ចំណែកខាងស្រីជាប្រពន្ធដើម នឹងបុរសជាសំឡាញ់របស់ព្រះ
ពោធិសត្វនោះ បានយកគ្នាជាប្តីប្រពន្ធ នៅរួមសំរាសជាមួយគ្នា ជា
មនុស្សមិនដែលធ្វើបុណ្យកុសលអ្វីបន្ទិចបន្ទួចសេះ, ប្រព្រឹត្តធ្វើតែអំពើ
បាបប៉ុណ្ណោះ, ក៏ចុះធ្លាក់ខ្លួនជាអ្នកកំសត់ទុគិតទីលក្រ ។ ថ្ងៃមួយបុរស
នោះនិយាយនឹងភរិយាថា ព្រះរាជាក្នុងនគរតក្កសិលា ព្រះរាជទានទ្រព្យ
សម្បត្តិដល់អ្នកកំសត់អនាថាច្រើនណាស់, បើដូច្នេះមានតែយើងទៅ
សូមទានព្រះអង្គគ្រាន់នឹងចិញ្ចឹមជីវិត ។ ជនទាំងពីរនាក់នោះ ក៏ទៅឯ
នគរតក្កសិលា, ដល់ទៅសាលាទានរបស់ព្រះរាជា ក៏ព្រះអង្គទ្រង់
ស្គាល់ច្បាស់ ហើយទ្រង់ត្រាស់សួរថា នែអ្នកទាំងពីរនាក់, អ្នកឯង
នាងឯងជាប្តីប្រពន្ធនឹងគ្នាឬ? ។ ជនទាំងពីរនាក់ ក្រាបបង្គំទូលថា ព្រះ
ករុណាថ្ងៃវិសេស ។ ទើបព្រះរាជាទ្រង់ត្រាស់បង្គាប់រាជបុរសទាំងឡាយ
ថា នែវ៉ុយ, ក្នាក់ងាររាជការ, ចូរអ្នកទាំងឡាយចាប់អានេះមេនេះចង

ក្ឆាប់ត្នា ហើយបណ្តោញទៅនគរដទៃឯណោះទៅ ។ រាជបុរស
ទាំងឡាយ ក៏ទទួលធ្វើតាមព្រះរាជឧត្តារ ។ ព្រះមហាសត្ត ក៏ប្រព្រឹត្ត
ធ្វើបុណ្យទានមានសភាពជូច្នោះជាដរាបតមកទៀត ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលព្រះសាស្តាទ្រង់ប្រកាស
សេចក្តីនោះ ទ្រង់ត្រាស់ថា

ត្រានោះ ព្រះបាទតក្តសិលាដែលបុញ្ញកម្មនាំមកហើយ ទ្រង់
បានជាស្តេចសោយរាជ្យប្រកបដោយសិរីថ្ថៃថ្ថា មានបុទ្ធិមាន
បុណ្យ មានប្រាជ្ញា មានញាតិ មានយស មានកំឡាំង
មានតេជះជាច្រើន ជាស្តេចទ្រទ្រង់នូវបុណ្យ ជាស្តេច
ដ៏ប្រសើរគ្រប់គ្រងនូវសិរីរាជសម្បត្តិ ។

អង្គសម្តេចព្រះបរមសាស្តាបារ្យជាម្ចាស់ ទ្រង់នាំព្រះធម៌ទេសនា
នេះមកសំដែងហើយ ទ្រង់ប្រកាសនូវសច្ចៈទាំង ៤ ប្រការ, បណ្តាជន
ជាច្រើនត្នា ក៏បានសម្រេចសោតាបត្តិផលជាដើម ។ ទ្រីបសម្តេច
ព្រ៉ះជិនស្រីទ្រង់ប្រជុំជាតកត្រាស់សំដែងថា

មាតាព្រះពោធិសត្ថក្នុងកាលនោះ ចេរិលវិងមក បានមក
កើតជាព្រះនាងមហាមាយា, បិតាបានជាព្រះបាទសុទ្ធោទនៈ,
បុរសដែលប្រទុស្តចំពោះព្រះអង្គ បានជាទេវទត្ត, ភរិយា
ទ្រុស្តសីល បានជានាងចិញ្ចមាណវិកា, ឆ្មាំទ្វារទាំង ៤
បានជាព្រះថេរៈអ្នកទ្រទ្រង់នូវធុតង្គ, ពួកបរិសទ្យក្រៅពី

នោះ ឋានជាពុទ្ធបរិសទ្យទាំងអស់; ឯព្រះឋាទទុក្ពម្ចានិក
នោះ ឋានត្រាស់ជាសម្ចាសម្ពុទ្ធ . គឺតថាគតដែលជា
លោកនាថហ្នឹងឯង; អ្នកទាំងឡាយចូរទ្រទ្រង់ចាំទុកនូវ
ជាតកយ៉ាងនេះចុះ ។

ចប់ ទុក្ពម្ចានិកជាតក ទី ១៣ ។

ធម៌ ៤ សម្រាប់បុគ្គល ២ ពួក

ដេក់លើផែនដី ១ ប្រព្រឹត្តធ្វើល្អ ១ សភាពជាអ្នកស្តាំងស្តម ១ បរិភោគបន្ពិចបន្ពួច ១ ធម៌ទាំង ៤ ប្រការនេះ តែងកើតមានចំពោះ តែបុគ្គល ២ ពួក គឺ ខ្ញុំបំរើគេ ១ តាបស ១ តែបើពោលដោយ វិសេស ពួកមួយកើតឋានជាអាក្រក់ ពួកមួយកើតឋានជាល្អ ។

ខ្ញុំបំរើគេតែងធន់ទ្រាំនូវសេចក្ពីទុក្ខទាំងឡាយ មានត្រជាក់ នឹងក្តៅជាដើម តែសេចក្ពីទុក្ខដើម្បីប្រាថ្នាទ្រព្យទាំងឡាយនេះ បន្ពិចបន្ពួចទេ ថាបើខ្ញុំបំរើនោះមិនលះបង់ចោលធម៌ ។

ផ្នែកអក្សរសាស្ត្រ

រឿងសៅរ៍សោយ

(សិសោរដាតក)

ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រាស្វឹកវិត

(តពីវិឡលេខ ១ ឆ្នាំ· ១៩៥៥)

ព្រះបាទក្សត្រា ទំទប់អាត្មា ស្ងួរថា"ហេតុអ្វី បានដាវាយដំ ខ្ងួនខ្ញុំនេះខ្មី ពុំត្រូវសេចក្តី ដល់តិចឡើយហោង ។ បើដេរបើវាយ ត្ងួរស្ងួរនិយាយ ឲ្យដឹងដើមទង មកវាយយ៉ាងហ្នឹង មិនដឹងខុសឆ្គង ពុំសមទំនង ឥតហេតុបច្ច័យ" ។

អ្នកទាំង ៥ នោះ ពុស្តេចថាហ្នោះ រឹងខឹងខ្ជាំងកៃ ដេរថា"អាពាលចណ្ឌាលចង្រៃ មឹងចេះកែវិទ ថាអញវាយខុស ។ ថាវាយមិនត្រូវ បើហ្នោះឥឡូវ មើលទៅខ្ងងចុះ ថាវាយមិនត្រូវ វាយទៅវាខុស ត្រាន់តែ រលុស ខ្ងងមឹងហ្នឹងនៃ ។ អាចោរចំណាប់ ល្ងចគោមកកាប់ ឈាម ជាប់នៅដៃ ល្ងចគោអញមក អញរកស្ងើរក្ស័យ ឥឡូវនេះនៃ ឃើញមឹងសម្ជាប់" ។

ទើបពុទ្ធង្ក្ុរ មានព្រះបន្ទូល និយាយប្រាយប្រាប់ "ខ្ញុំមិនចោរល្ងួច ដើរល្ងចគោកាប់ អ្នកមកប្រចាប់ ខុសច្បាប់ព្រងើយ ។ ខ្ញុំមិនបានល្ងួច

ទ្រព្យអ្នកកាន់កូច តិចតួចសោះឡើយ ម្តេចអ្នកជាក់ច្រឹ ។ ឯយខ្ញុំអ្នកអើយ ខ្ញុំមិនចោរឡើយ ពិតជាត្រង់ស្មោះ" ។

បុរស៥នាក់ ឮានស្តាប់សព្ទជាក់ រឹងចិត្តទ្រគោះ ដេរថា "អាឆ្កួតមកអួតថាស្មោះ ថាអ្វីដូច្នោះ អញ្ជាឃើញនឹងភ្នែក ។ ឃើញពិតទាំងអស់សាច់ឈាមស្រស់ ។ ទាំងពោះវៀនស្បែក ពេញទាំងថ្លាងធំ ទៅទំប្រកែក មាត់ធ្ងន់ជជែក ប្រកែកតែចៃ" ។

ព្រះចាទសិសៅរ៍ មានបន្ទូលទៅ ថា "ខ្ញុំសព្វថ្ងៃ មិនមែនជាចោរលួចគោឡើយនៃ ខ្លួនខ្ញុំសព្វថ្ងៃ អាស្រ័យនឹងវត្ត ។ ខ្ញុំមិនជាចោរពេលនេះខ្ញុំស្មោះ ក្រាក់ទ្រអម្ចត់ ដល់ចិត្ត វត្តពន្ធភ្ញាកជ ដោយចិត្តកំណត់ នឹងបព្វជ្ជា ។ បួសធ្វើជាសង្ឃ សំណាក់ត្រែកត្រង់ ក្នុងព្រះសាសនា បើមិនដឿកូវ ទៅសួរលោកព្រ" កុំអ្នកមកថា ខ្ញុំលួចគោកាប់ ។ គួរពិចារណា ឲ្យជាក់សិនព្រ" សឹមមកប្រចាប់ ជាក់ចុះលោភយ យល់ដាយពុំគាប់ ពុំត្រូវដោយច្បាប់ ទំលាប់ពីនាយ ។ ខ្លួនខ្ញុំត្រង់ស្មោះ អ្នកឥតសួរសោះ លោស្ទុះមកវាយ បើមិនដឿទេ អ្នកវៅទៅនាយ សួរលោកទាំងឡាយ ទៅក្នុងវត្តស្រាប់" ។

បុរស៥នាក់ ស្តែងស្តាប់សព្ទជាក់ ថា "អើ! ចូរធាប់ រាជាណាស់ណា លោកជាសង្ឃស្រាប់ យើងនឹងសួរច្បាប់ រកកិត្យវិន័យ" ។ ថាហើយចូលចាប់ ចងជាប្រញាប់ កន្ត្រាក់ដឹកដៃ បណ្តើរសំដៅឆ្ពោះទៅវៃ។ ដល់លោកហើយនៃ ទូលតាមទំនង ។ "បពិត្រកុណា! ខ្ញុំទូលពុទ្ធដីកា ឲ្យជ្រាបជាម្តង ដ្បិតលោកជាសង្ឃ ត្រង់ដោយគន្ធង!

ដំណើរនេះហោង សូមុខានចាំស្តាប់ ។ គោឮ៉ាកថាត់ ឮ៉ាស្ងែនឡែនឡាត់ ស្តាត់ដើរស្ងើរស្ងៅ ឥឡូវយើញចោរ លួចគោមកកាប់ យើងឮ៉ាប្រាប់ ប្រាប់ថាខ្លួនត្រង់ ។ ហើយប្រាប់យើងថា ឲ្យយើងនេះណា ទៅស្នូរ លោកសង្ឃ ភ្នោះទើបឮ៉ាចាប់ នាំធាប់មកត្រង់ តើលោកគ្រប់អង្គ យល់ម្តេចទៅ៉ា? ។ អស់កិកុសង្ឃ ស្តាប់ពិតជ្រួតជ្រង់ គ្រប់អង្គហើយណា ទើបប្រាប់រឿងពិត ដោយឥតមុសា ថា "មនុស្សនេះណា មិនជាចោរសោះ ។ ចូរញោមចាំស្តាប់ អាត្មាសារសេពួ ប៉ុយប្រាប់រឿងនោះ ដោយចំក្រមក្រិត្យ ជាពិតចំពោះ ប្រាប់អ្នកជាក់ស្មោះ មិនលោះឡើយណា ។ នេះជាមហាក្សត្រ រង្វេងឡែនព្រាត់ ពីរដ្ឋសីមា ដើរមកម្នាក់ឯង រង្វេងមាគ៌ា តុំដឹងទិសា ខ្ទុកាខ្ចាំងកែ ។ ដើរមកហូរហែ កំលោស្រាប់តែ អ្នកស្រែចម្រែ ប្អូនមកុដសុវណ្ណ ព្រះខ័នពិជ័យ ទឹងអាជានេយ្យ តាំងបីទៅហ្មត់ ។ ឥឡូវដែះថា ចិត្តគិតប្រាថ្នា បួសជាប្រាកដ តែកាលដឹងថា ចីវរកៅឡត់ កំដោះសំពត់ ភូសាយ៉ាងធាប់ ។ ឲ្យកាត់ចីវរ យើងក៏ត្រៃកអរ នាំគ្នាប្រញាប់ កាត់ដេរស្រែចស្រួល ក៏ខូលបង្គាប់ ឲ្យស្តេចប្រញាប់ ជ្រលក់អម្ងត់ ។ អ្នកស្តេចនេះក៏ យកចីវរទៅ ទៅធ្លើក្រៅវត្ត រឿងពិតជួបច្នេះ ទើបយើងកំណត់ អ្នកនេះប្រាកដពុំជាចោរ ។ ពុំមែនអ្នកលួច ដើរទៅលបលួច គៅអ្នកឲ្យណា គឺពិតជាក្សត្រ ប្រាស់ព្រាត់រង្វេ មកសូមអាត្មា នៅជាតំនាក់ ។

បញ្ចូ ជនា បុរស ៥ គ្នា ជានស្តែងស្តាប់ជាក់ ពាក្យសង្ឃ៉ាប៉ាប់ ប្រាយប្រាប់ជ្រៅពក់ អ្នកតាំង ៥ នាក់ រឹងចិត្តឥតបី ។ ហើយតិះ

ដំណើរនេះហោង សូមុខានចាំស្តាប់ ។ គោឮ៉ាក់ថាត់ ឮស្វែងវែងឆ្ងាត់ ស្តាត់ដើរស្ងើរស្ងៅ ឥឡូវយើញចោរ លួចគោមកកាប់ យើងឮ៉ាប្រាប់ ប្តាប់ថាខ្លួនត្រង់ ។ ហើយប្តាប់យើងថា ឲ្យយើងនេះណា ទៅសួរ លោកសង្ឃ ភ្នោះទើបឮ៉ាចាប់ នាំធាប់មកត្រង់ តើលោកគ្រប់អង្គ យល់ ម្តេចទៅ៉ា? ។ អស់កិក្ខុសង្ឃ ស្តាប់ពិតផ្ទុតផ្ទង់ គ្រប់អង្គហើយណា ទើបប្តាប់រឿងពិត ដោយឥតមុសា ថា "មនុស្សនេះណា មិនជា ចោរសោះ ។ ចូរញោមចាំស្តាប់ អាត្មាសារសេពូ ប្តាយប្តាប់រឿង នោះ ដោយចំក្រមក្រិត្យ ជាពិតចំពោះ ប្តាប់អ្នកជាក់ស្មោះ មិនលោះ ឡើយណា ។ នេះជាមហាក្សត្រ វង្សឆ្ងែវែងត្រាត់ ពីរដ្ឋសីមា ដើរ មកម្ខាត់ឯង វង្សឆមាតិ ពុំដឹងទិសា ទុក្ខាខ្លាំងក្រៃ ។ ដើរមកហូរហែ កំលោសោប់តែ អ្នកស្រែចាំផ្លែ ឫទ្ធមកុដសុវណ្ណ ព្រះទ័នពិជ័យ នឹង អាជានេយ្យ ពាំងបីទៅហ្មត់ ។ ឥឡូវដែរថ្មា ចិត្តគិតប្តាថ្មា បួសជា ប្រាកដ តែកាលដឹងថា ចិរវាល់ឆ្ងាត់ កំដោះសំពត់ កូសាយ៉ាងឆាប់ ។ ឲ្យកាត់ចីវរ យើងកំត្រែកអរ នាំគ្នាប្រញាប់ កាត់ដេរស្រែចស្រួល កំទួលបង្គាប់ ឲ្យស្តេចប្រញាប់ ជ្រលក់អង្ករ ។ អ្នកស្តេចនេះកំ យក ចីវរសៅធ្លើក្រែវត្ត រឿងពិតដូច្នេះ ទើបយើងកំណត់ អ្នកនេះប្រាកដ ពុំជាចោរ ។ ពុំមែនអ្នកលួច ដើរទៅលបលួច គោអ្នកឲ្យណា គឺពិតជាក្សត្រ ប្រាស់ព្រាត់រង្គា មកសូមអាត្មា នៅជាពំនាក់ ។

បញ្ចជនា បុរស ៥ គ្នា ចានស្តែងស្តាប់ជាក់ ពាក្យសង្ឃ៉ាប្រាប់ ប្តាយប្តាប់ជ្រៅពាក់ អ្នកពាំង ៥ នាក់ រឹងចិត្តឥតបី ។ ហើយតិះ

ដៀលថា "សង្ឃអ្នកច្នេះណា ចេះតែស្រដី មានពាក្យអាក្រក់ កុហក ឥតបី រាល់តិចអី បួសធ្វើជាសង្ឃ ។ តាមតែចេះថា ស្រដីមុសា អួតថាខ្លួនត្រង់ ទើងបួសធ្វើអ្វី ខូចចិត្តស្បង់ កាន់ក្រឹត្យមិនគង់ ចង់ចាយចាសក ។ បំណាច់ធ្វើសង្ឃ ស្រដីឲ្យត្រង់ កុំចង់កុហក សង្ឃនេះជ្រោកជ្រាក កាន់ពាក្យអាក្រក់ អន់ជាងចាសក គេហៅសង្ឃ សោ ។ បួសសោះចៃខាំ បួសហើយចៃខាំ ចោរខុកលួចគោ ស្មោរចៃកន្ធាស៊ី ជាទីស្អប់ហ៊ា គេឃើញជ្រងោ នៅថាមនុស្សជា" ។

បុរស៩នោះ តិះដៀលគ្នាគោះ អស់សង្ឃនានា ដោយចិត្តខឹងខេរ តាមតែនឹងថា ផ្សែងៗពីគ្នា រួចតែពីមាត់ ។ ថាហើយស្ទុះទៅ ចាប់ព្រះសិរសៅរ៍ ខ្លះថងខ្លះទាត់ ទង់ៗញាកន្ត្រាក់ ចិធាក់វាយវាត់ អង្គព្រះមហាក្សត្រ ខុកក្តាត់ស្ទើរក្សយ ។ គេធ្វើខុកខោស តុំមានសន្តោស ច្រាណាច្រោសឡើយនៃ គេវាយគេធាក់ ប៉ូកប៉ាក់ខ្លាំងវៃក្រែ អួសទង់ៗញាដៃ ទៅតាលណោះណា ។

សាមណេរតូចនោះ ឃល់ហេតុគេច្នោះ ស្រណោះក្សត្រា ទប់ចំពុំបាន ប្រែច្រាណាសោកា គន់គិតអនិច្ច សង្វេគពេកក្តាត់ ។ ស្ទើរបែកខ្ទេងខ្ទាក ជា៧ភាគ អួលថ្ងើមប្រមាត់ រើងជាផ្សាចិត្ត អាណិតមហាក្សត្រ ទើបស្រែកខាំងឃាត់ អង្វរសូមទោស ។ ថា "ខុ! ញោមអើយ! កុំធ្វើទោសឡើយ សូមមេត្តាច្រោស អាត្មាបិណ្ឌបាត សូមអ្នកសន្តោស កុំបីធ្វើទោស អាត្មាជានា ។ សូមបានច្រាណាច្រោស អាត្មាសូមទោស សន្តោសលែង៎" បើសិនជាបាត់

អាត្មាជានា អ្នកចាប់អាត្មា ធ្វើទោសតាមចិត្ត ។ អាត្មាជំនួស ទទួលទោសជួស សុំដោះជីវិត បើស្តេចគេចប្រាណ ពុំបានទៅនិត្យ ខ្ជួនអាត្មាពិត រងជួសស្រាប់ហើយ ។

បុរស ៥ នាក់ ស្តែងស្តាប់សព្ទជាក់ នូវពាក្យនេនធ្វើយ ថាយក ខ្ជួនតាង ដំណាងច្នោះហើយ ចិត្តទន់ស្រន់ស្បើយ រហើយក្រោធា ។ ហេតុតែអាណិត សាមណេរមានចិត្ត យកខ្ជួនជានា អ្នកទាំង ៥ នោះ ព្រមដោះរាជា មានចិត្តសទ្ធា សាមណេរនោះឯង ។ ហើយប្រាប់ សង្ឆសត្យ ថា "លោកក្នុងវត្ត ប្រយ័ត្នប្រយែង កុំបីសមសេព មនុស្សបែបនេះឯង ជាចោរគួរស្រែង ហ៊ានលួចគោកាប់ ។ ពីថ្ងៃនេះ ទៅ បើលោករឹងនៅ សេពសមពុំស្តាប់ កុំបន្ទោសយើង ថាយើងមិន ប្រាប់ គង់បានទុក្ខធាប់ ចូរស្តាប់ឲ្យច្បាស់" ។

ថារួចកាលណា នាំគ្នាយាត្រា លីលាទៅផ្ទះ ក្រោយនោះរាជា រៃទនាខ្ចាំងណាស់ អស់ភិក្ខុក្មេងចាស់ រូតរះរក្សា ។ ផ្ទងព្រះសិស្យៃ រ ត្រាហ៍នាំយកទៅ លំនៅសាលា រកដាំទឹកក្តៅ ថ្នាំក្រៅក្នុងណា ថែទាំ រក្សា ពុំជិនធ្ងន់ឡើយ ។ យូរតិចទៅថ្ពាន ពេះមហាក្សត្រក្សាន្ត ក៏បានសះស្បើយ ជាចាករោគា ធម្មតាស្រេចហើយ ក្សត្រក្សាន្ត ត្រាណត្រើយ នៅជាសុខហោង ។

ភិក្ខុផងត្រប់គ្នា យល់ព្រះរាជា ជានាហ្មត់ហ្មង ទើបមានពុទ្ធដីកា ចរចាសាសង តាមដោយទំនង ថា "ហៃមហារាជ! ។ អាចក្តីនេះណា គិតពិចារណា យល់ថាមិនអាច អះអាងជានា តាំពារមហារាជ មនុស្ស

ផងប្រើនកាច ពុំខ្ជាចខុសត្រូវ ។ ឥឡូវនេះគេ រាយលេងទេ ឲ្យជាអាស្រូវ ពុំដឹងគិតម្ពេច ធ្វើម៉េចឥឡូវ ជ្យិតគេក្រោជ្ជូវ ឃាត់ទៅពុំបាន ។ ជ្យិតខ្ជូនជាសង្ស ប្រាប់ប្រាមតាមត្រង់ គេវឹងបំពាន ទំជួយគ្រប់យ៉ាង ឲ្យខាងតែបាន ប្រាប់គេប៉ុន្មាន គេគ្មានជឿឡើយ ។ ហេតុនេះតទៅ បើនឹងវឹងនៅ ក្រែងគេមិនស្បើយ គេមកកាលណា យល់មហារាជហើយ ពុំទាន់ស្រន់ស្បើយ គេធ្វើទុក្ខទៀត ។ អាត្មា យល់ថា គួរមហាក្សត្រា. លីលាឈ្ជបធ្ជៀត រកទីលំនៅ ឯក្រៅទៅ ទៀត ក្រែងគេលែងបៀត បានសុខតទៅ" ។

ស្តាប់សព្ជត្រប់ហើយ គិតពុំលង់ឡើយ បរមចមចៅ លាលោក ត្រប់អង្ត ក្នុងទ្រូងហ្មងសៅ លាលាកចាកទៅ ដោយនូវអាល័យ ។ ហើយទ្រង់ត្រាស់ថា "សូមទានករុណា នៅចុះម្ហាស់ថ្ជៃ ឲ្យបាសុខ សាន្ត សម្រាន្តព្រះទ័យ ប្រាសចាករោគក័យ ទោសពៃ៍តទៅ" ។

សាមណេរនោះណា យល់ក្សត្រយាត្រា ពុំបិតនិត្សនៅ ក្ពុកក្ពួល អួលចិត្ត អាណិតចមចៅ យំយោគសោកសៅ ក្ពួលក្ពៅកន្ជង ។ ហើយក៏លីលា តាមជូនរាជា ជល់នារបង ឈរយំទីនោះ មើលធ្ពោះ ច្បាស់ច្បង លុះលន់កន្ជង បាំងបាត់ផុតភ្នែក ។ ទើបវិលយាត្រា ចូល វត្តអាត្មា សោកាអនេក ឯព្រះរាជា លីលាឯងឯក ខ្សឹកខ្ជូលស្ទើរបែក សញ្ជែកទ្យរ ។ សង្រែងសង្រៃ ក្សត្រាអាល័យ សាមណេរខ្ជាំងក្ជា ពុំអាចចរលី ពីទីនោះណា ទើបតង់សោកា នាទីនោះឯង ។ កាល

ទ្រង់ចិត្តា ដល់អង្គអាត្មា រីឯជាចំមែង ឱ្យកន្ត្រាក្តួលក្តៅ ហួងសៅ
កម្សែង សោកាថ្ងាថ្ងែង ពិលាបទូញថា ៖

"ខុ! គួរសង្វែគ អាស្លូវខ្លួនពេក កម្មថ្លែកច្នេះណា ពីមុនអញធ្វើ
អំពើអ្វីវ៉ា ទើបអនាថា កំព្រាច្នេះហោង ។ ខ្លួនកេរសគ្នាន លោ
ស្រាប់តែមាន ទោសទ័ណ្ឌជាម្ត្រង ពុំគួរគេវាយ មើលងាយឡើយហោង
លោស្រាប់តែរំវង អ្នកផងមើលងាយ ។ ទីពុំសមដេក ខ្លួនឥតដំណេក
កំដេកផ្តួលកាយ អាហារនានា ឃើញជាគួរណាយ តែឃ្លានមាល្យាយ
បរិភោគសោះឃ្លាន ។ ពីមុនមកភូវ ពុំធ្លាប់ដើរផ្លូវ ឥឡូវត្រូវឈាន
ដើរស្វែងឯងឯក វែកលុកលុកពន ពុំដឹងរឹងថ្ពាន ទៅឋានទីណា ។
នរណាទៅអើយ ដែលឃើញយើងហើយ មានចិត្តមេត្តា នរណាគេ
ទ្វៀត ជាញាតិសខា មិត្តភក្តីអាត្មា គ្រាន់ជាតំនាក់ ។ នរណាទឹងដឹង
ថាខ្លួនយើងនឹង ជាអង្គស្តេចចក្រ . នរណាទឹងក្រែង ខ្លួនឯងតែម្នាក់
កម្មអ្វីឥតអាក់ ឥតឯរដោះ ។ ទៅនៅទីណា ទីនោះកើតជា ភ័យកិត
ឥតលោះ កើតភ័យទីណា ទុក្ខាទីនោះ គាលបើដួរច្បាះ តើរូបអាត្មា ។
ទៅពឹងអាស្រ័យ ទឹងអ្នកផងទៃ រូបណាទៅក៏ គ្រាន់ឃ្លានគោជន
សម្រន់គោក្តា គ្មានឃើញនរណា មេត្តាយើងឡើយ ។ បើដួរច្នេះនៃ
តើយើងអាស្រ័យ នរណាទៅអើយ គ្រាន់ឃ្លានគោជនា គោក្តាជា
ត្រើយ បើគ្មានឃ្លានហើយ គង់តែក្សីណាក្សយ ។ ក្តីស្ងាប់ស្វែងសល់
ពុំគួរនឹងឃល់ មកដល់ហើយនៃ ព្រោះខ្លះគោជនា គោក្តាអាស្រ័យ
កម្មអ្វីខ្ញាំងក្លៃ ឥតបីស្រាកស្រាន្ត ។ បើអាយុបុណ្យ យើងធ្វើពីមុន

ជាទុននៅមាន អាហារកោជន៍ផង យើងគង់នឹងបាន ប្រសិនបើគ្មាន
គង់ស្លាប់ពិតហើយ ។ ទុក្ខទោសនេះរ៉ា ពុំមាននរណា មកធ្វើឲ្យឡើយ
ខ្លួនអញ្ញទេតើ បានធ្វើជាត្រើយ ខ្លួននេះឯងហើយ ទីពឹងផងខ្លួន ។
នរណានឹងជា ទីពឹងនរណា ពិតជាគ្មានក្បួន នរណាធ្វើកម្ម អ្វីត្រាំ
ក្នុងខ្លួន អ្នកនោះត្រូវចួន សោយសួនផលនោះ ។ សត្វលោកគ្រប់កាយ
កុំបីមើលងាយ នូវកម្មឲ្យសោះ ថាកម្មស្ពួចស្ពើង ដែលយើងធ្វើនោះ
ពុំអាចមកផ្ពោះ ឲ្យផលយើងឡើយ ។ ព្រោះកម្មនោះណា ទោះតិច
ម្តេចម្តា ឲ្យតែធ្វើហើយ គង់តាមឲ្យផល ឥតសល់ខានឡើយ ទុក្ខតាម
គ្មានស្បើយ ហើយឥតកំណត់ ។ ដូចយើងនេះណា ដែលរងទុក្ខា
កំព្រាកំសត់ ព្រោះកម្មដែលយើង ធ្វើឡើងប្រាកដ ចួបចំកំណត់
ឲ្យទុក្ខឥតស្រាន្ត" ។

លុះស្ទាងសោកា ស្តេចក្សាយាត្រា ដោយព្រៃដងដាន នៀយ
និត្យល្ហិតល្ហៃ ព្រះទ័យពុំក្សាន្ត ទុក្ខពិតឥតមាន លោះខានឡើយនៃ ។
ស្តេចទ្រង់កន្សែង អនិច្ចាថ្ងាថ្ងៃង កណ្តែងក្នុងព្រៃ លុះព្រះរាជា លីលា
យូរក្រៃ សាយណ្ហក្សត្រថ្ងៃ ដល់ស្រុក ១ ណា ។ ឃើញផ្ទះគេនៅ
រាលស្រែឯក្រៅ ចមៀចៅតិតថា "អញនឹងចូលទៅ លំនៅនេះណា
សូមគេនិត្រា សម្រាកដេកនៅ" ។ លុះតិតច្នោះហើយ ពិតពុំលង់
ឡើយ ត្រាណត្រើយចូលទៅ ឃើញជូនចំណាស់ តាចាស់និត្យនៅ
ពីរគ្នាឯក្រៅ ប្រពន្ធនឹងប្ពី ។ សម្តេចសិស្យាវ៍ មានបន្ទូលទៅ នឹង
យាយនោះខ្មី ថា "ទ! យាយអើយ! សូមយាយប្រណី ជ្យិតខ្ញុំ

នេះខ្លី មកពីទីឆ្ងាយ ។ ចួបចួនព្រលប់ ទើបមកសូមឈប់ ស្នាក់នឹងលោកយាយ ត្រឹម ១ ពត្រី កុំបីដំនណាយ សូមទានលោកយាយ អាណិតខ្ញុំ" ។

រីឯដូនចាស់ បានដឹងខឹងណាស់ ទើបឆ្លាស់ឆ្លើយថា "ឯងកាលពីថ្ងៃ អស្រែយឯណា យប់ទើបយាត្រា មកសូមផ្ទះស្នាក់ ។ យើងពុំដឹងថា ឯងគាចប្តូជា ជាប្រាកដដាក់" តាត្តុះហើយ ទើបឆ្លើយឡើងស្ងាត់ថា "ឲ្យគ្នាស្នាក់ ៗសៅចុះណា យាយ ! ។ កុំខាំរាំងរាំង ដូរតគ្នាលីលាមកពីទីឆ្ងាយ ស្នាក់ ១ ពត្រី កុំបីហ្នឹនហ្មាយ នឹកនាឯយាយ អាយនាយដូច្នោះ ។ ចួបចួនព្រលប់ គ្នាមកសូមឈប់ មួយយប់ប៉ុណ្ណោះ វាមិនជាអ្វី ឥតបីមានមោះ ខំនឹគាត់នោះ ត្រង់ស្មោះទេណា" ។

ចមកពនរបតី ស្តេចស្តាប់សំដី ពាក្យយាយនឹតា យល់ស្មោះស្រុះស្រួល ទទួលហើយណា ទើបស្តេចយាត្រា ចូលក្នុងផ្ទះនោះ ។ នៅយប់នោះភ្លាម យាយតាពីរច្បាណ ដេកគ្មានលក់សោះ ទើបក្រែកសន្ធូនា ប្រឹក្សាពីគ្រោះ ពិរឿងនេះនោះ តាមការអ្នកក្រ ។ "យាយអើយ ! យប់ជ្រៅ នេះអញគិតសៅ ឃើញផ្ទៃ ១ ល្អ គ្រាប់ឃ្លោកសៅត្រឡាចន្ទវិល្ស ត្រសក់នោះក៏ យើងមានជារៀន ។ យើងគិតដាំវាហើយថែរក្សា ឲ្យវាចំរើន បេះផ្លែសៅលក់ បានលុយមករៀន ហើយយើងក្រែរើន សន្សៅមុខ ។ បានរៀនកាលណា យើងលោះទាសាទាសីមកទុក ឲ្យបក់ផ្ទៃតយើង ធ្វេងស្តាំក្រោយមុខ យើងនឹងបានសុខស្រណុកឯចាស់" ។

(មានត)

អនុស្សាវរីយ៍

បំពោះព្រះបាទសម្តេច ព្រះនពាត្ថម-សីហនុ វ្រ៉ន

ព្រះបោប្រទេសកម្ពុជា

លោក អ៊ុង-ស៊ុមន៍ លេខាធិការរង

អនុវិទ្យាល័យ ព្រះសីហនុ កំពង់ចាម

រៀបរៀង

លោក ចាប-ពិន ក្រុមជំនុំទំនៀបទម្លាប់ខ្មែរ

ពិនិត្យកែសម្រួលតាមក្លឆកាព្យ

គេស្វើចសរសើរព្ធលាន់លោក ជ័យដោតរាសនាកម្ពុជា
ឆ្ងងទុក្ខបានសុខត្រប់ ៗ ត្នា ដោយព្រះរាជាក្សត្រប្រិមប្រិយ ៗ
ព្រះបាទសីហនុ វ្រ៉ន ព្រះទ័យណែនណាន់កាន់ខន្ធី
ព្យាយាមកសាងផែនទឹកដី ដោយប្រោសប្រណីខ្មែរយ៉ាងខ្ជាំង ៗ
ទ្រង់ហោះចាកដែនកម្ពុជា លីលាទៅកាន់ស្រុកបារាំង
ទាមទារឯករាជ្យដោយកម្ជាំង ព្រះប្រីជាខ្ជាំងឥតប្រណី ៗ
ជដែកតវ៉ានឹងបារាំង គេខំបិទបាំងមិនចង់ស្តី
ព្រះអង្គឈ្វេងយល់ហោះចញខ្នី សំដៅបុរីកាណាដា ៗ
ហើយទ្រង់យាងទៅក្រុងញីវយ៉ក ទ្រង់ស្រែកសង្ឆកយ៉ាងសង្ហា
ព្រះឧស្ថព្រះអង្គហាក់សរថ្ជា វិទ្យុឃោសនាផ្ទើលផែនដី ៗ
កាសែតព្រោងព្រាតត្រប់ជាតិសាសន៍ ផ្សាយដំណឹងដាសលើប្រថពី
ញាប់ញ៉ាវខ្ជ៉ូរខ្ជូរត្រប់ទិសទី ស្តីពីបារាំងគ្មានសេសសល់ ៗ

សាកលលោកស្ងើចមហាក្សត្រយើង ថាជ្រាបថ្កើងឥតគេដល់
ក្មេងព្រះអង្គទៅតែប្រតិភាល មានព្រះយោបល់ស្គាល់កោះត្រើយ ។
ព្រះអង្គទ្រង់ប្តូរព្រះជន្ម ឥតមានរញ្ជាកខ្លាចមរណ៍ឡើយ
ព្រោះការស្ងប់រស់តែងមានហើយ ឲ្យតែដល់ត្រើយឯកពជ្រជាតិ ។
ទ្រង់ចាកអាមេរិកទៅជប៉ុន ឲ្យគេការុណ្យជួយគាស់ឥត
នាវាឯកពជ្រខេមរជាតិ ដល់ត្រើយកុំឃ្លាតនាប់ៗវៃ ។
ដល់ស្រុកជប៉ុនទ្រង់ព័យព័ប់ រឿងឯកពជ្រជ្រាបឲ្យជួយលៃ
ជប៉ុនបានឮព្រះទុស្ខថ្លៃ ថានឹងតែចៃដួយកម្ពុជា ។
រួចទ្រង់បន្តបេសកកម្ម ដោយទ្រង់ផ្ញើផ្ញាំព្រះបិតា
អនុសិទ្ធិពជ្ជយក្សត្រា លាព្រះមាតាយាងសៀមពេ ។
ប្រគល់រាជ្ជាភិបាលបែន - នុត ឲ្យធ្វើការមុតតាមសភាព
ព្រះអង្គស្តេចយាងចាកសៀមពេ ដោយទៅកាន់ប្រទេសថៃ ។
ទ្វៃស្រុកថៃស្រែកយោសនា ចេញមុខសង្ឃាពីរបីថ្ងៃ
ក្រោយមករាជ្ជាភិបាលថៃ ថាមហាក្សត្រថ្ងៃទ្រង់ស្តេចយាង ។
មកនេះជាក្បៀវគ័ត្តិយស យ៉ាងខ្ពស់ប្រាកដឃើញរូបកាង
ដោយថៃនឹងខ្មែរនោដិតខាង គួរតែគរអាងជួយក្សត្រក្បាច ។
ចាកថៃមកកាន់ជាត់ដំបង ព្រះទ័យប៉ុនប៉ងមានឡាក់ឋាន
ថាបើឯកពជ្រមិនទាន់បាន ក្សត្រក្បាច្ចមិនជាន់ពជកំងដ៏យ ។
ទ្រង់ផ្តើមដែនកាណ៌យ៉ាងអង់អាច ព្រះសីហនុពជយ៉ាងនិរ៉ាយ
កងជីវពលហាត់យ៉ាងម្រៃដៃ ធាប់វៃពេញរដ្ឋខ្មែរគ្មានសល់ ។

នារីក្នាហានហ៊ានតាំងចិត្ត ព្រមព្រៀងគំនិតធ្វើជីវពល
ជួយជាកម្ចាំងព្រះនិមិល ឲ្យធាប់បានជល់ទៅត្រើយនាយ ។
កាំភ្លើងឈើខាត់រលោងស្រិល ហាត់បាញ់ឥតខ្ជិលញញឹមព្រាយ
ទុកជានឿយហត់គង់ខ្ចល់ខ្ចាយ ព្រោះចិត្តរីករាយនឹងមហាក្សត្រ ។
រំលងពេលខ្ចីមហាក្សត្រា ជជែកតវ៉ាដោយម៉ឺងម៉ាត់
តវ៉ាជ្ជួន ៗ ច្រើនសង្ការត់ ខ្ចាចកើតរិបត្តិបាវាំងថ្ងាយ ។
ឯករាជ្យបរិបូណិឲ្យទេមរា ថ្ងៃត្រោយព្រះមហាក្សត្រធោមធាយ
ចូលកំពង់ចាមតាមផ្ទូវធ្ងាយ ជីវពលរៀបថ្ងាយទស្សនាការ ។
ដើររៀបជាក្សួនជ្ជរយ៉ាងវែង សំដែងគោរពដ៏ទ្យាន
ទតហើយទ្រង់មានព្រះទង្ការ ថានេះអស្ចារ្យក្សួនហែធំ ។
+ន្ទុះវិទ្យាល័យកំពង់ចាម តាងនាមរាជាដ៏សុខុម
វិទ្យាល័យព្រះសីហនុថ្ពុ- ថ្ពើងហំសមស័ក្តិអ្ចីម្ចេ៉ះណា+ ។
ទ្រង់គង់ក្រសាលដោយក្សេមក្សាន្ត មិនយូរប៉ុន្មានទ្រង់យាត្រា
ព្រោះគេត្រៀមចាំព្រះរាជា អគ្គបញ្ជាលើពលរដ្ឋ ។
ព្រះអង្គយាងចូលរាជធានី ទៅតាមវិធីក្សួនហ្មត់ចត់
រាស្ត្រក្នុងក្រុងក្រៅញឹកជូចញាត់ ចោមរោមមហាក្សត្រដោយចិត្តស្មោះ ។
ទីក្រុងគ្នំពេញពេញមហាប្ងៃក ត្រប់ផ្ទូរជ្រៀតជ្រែកគ្មានចន្ទោះ
ណែនណាន់តាន់តាប់ចកកៀនកោះ ទទ្ជួលចំពោះព្រះចក្រី ។
មើលផ្ទូវព្រះប្រិយមហាក្សត្រ ព្រោះស្តេចយាងបាត់យូររាត្រី
ថ្ងៃនោះជាថ្ងៃមានសួស្ត្រី ព្រោះព្រះនរបតីស្តេចយាងមក ។

ទីក្រុងភ្នំពេញ ឧឡារិក ភ្ជៀងឧហូរទឹកគ្រប់ច្រកល្ហក
កងជីវពលឈរកុញកក ឆ្នានជកខ្ជូនជ្រកថយក្រោយទេ ។
រាស្ត្រស្ថិប្ត្ចរចិត្តដោយស្នេហា នឹងមហាក្សត្រាជាមហាមេ
ប្រឹងដោះទុក្ខរាស្ត្ររួចពីវេ- ទនាទើបគេអរពេកក្រៃ ។
ពីថ្ងៃនោះរាស្ត្រប្ត្ចរជីវិត ដើរកិតតាមក្រោយមហាក្សត្រថ្ងៃ
ដោយទ្រង់ព្យាយាមទាមកែទៃ ឯកវាជ្យឲ្យថ្ងៃពេញបរិបូណិ ។
សត្រូវណាប្រៀតហ៊ានកំទេច ព្រោះគេមិនភ្ជាចស្ត្រចថ្ងៃថ្នូរ
ព្រះមហាក្សត្រវ្ទៃរមានហៃហូរ អម្ប្យូរអង្គរថ្ពើងណាស់អឺយ ។

ពន្លឺភ្លើងចន្ទុះនៅស្រុកស្រែ

ពន្យល់ក្ស្ជនកាព្យ

ពាក្យកាព្យដែលមានគោលត្រូវល្អ ឃ្លាមុនឯល់ស៊ប្រកបចួន
ឃ្លាក្រោយប្រើឯល់ស៊ទៀតផ្ជួន មិនប្រើពាក្យចួនវិសញ្ជានី ។
ឃ្លាមុនវិសញ្ជានីរះមុឯ (ះ) ឃ្លាក្រោយគេទុកចួនពេញទី
ជាឯល់រះមុឯវិសញ្ជានី តាមទីដែលត្រូវប្រកបចួន ។
ឃ្លាមុនមានឯល់ឯប្រកប ឃ្លាក្រោយប្រើឯ្យ៉ាល់ ~~ប្រម~~ ឯផ្ជួន
មិនឲ្យវ្ទៃងឯល់សម្ជស្សចួន នោះទើបត្រូវក្ស្ជនកាព្យល្អអឺយ !

ជឿងសាមកុក

កណ្ឌទី ៤០

ឧកញ៉ាវិបុលរាជសេនា ឆូ-កន ប្រៃជ្រៀបជ្រៀង

(ឥមក)

ជឿងសាមកុកទុកជាឃុទ្ធសាស្ត្រ
អ្នកវាងជ្ញាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ទានស្នេហាជាតិ ។

ចូធូយល់ឃើញត្រូវផង ទើបប្រើឡៅហ្ជីដែលមានសតិបញ្ញាឲ្យទៅបញ្ជុះបញ្ជូលតៀវស៊ីវ ។ ឡៅហ្ជីក៏លាចូធូទៅដល់ស្រុកធេង-អៀង ហើយចូលទៅគំនាប់កាសៀងដែលជាទិប្រឹក្សាតៀវស៊ីវ ហើយនិយាយថា គ្រានេះចូធូបានជាទីមហាឧបរាជមានចិត្តធ្លូវទូលាយ រួសរាយរាប់អានសេនាទាហានទាំងឡាយទាំងពួងល្អណាស់ បានជាប្រើខ្ញុំឲ្យមកនិយាយនឹងតៀវស៊ីវដែលបានធ្វើសង្គ្រាមនឹងគ្នាមកពីមុននោះ កុំបីឲ្យមានចិត្តគិតអាឃាដញ្យាបាទគ្នាតទៅមុខទៀត ចូរគិតគូររួមគំនិតចិត្តមួយនឹងគ្នា ដើម្បីនឹងទំនុកបំរុងដែនដី ។ កាសៀងបានស្តាប់ដូច្នោះធ្វើយថា ថ្ងៃនេះចួនពេលក៏យប់ទៅហើយ ព្រឹកស្អែកខ្ញុំនឹងនាំអ្នកទៅជួបនឹងតៀវស៊ីវ ។ កាសៀងក៏ឲ្យរៀបតុលៀងកោជនាហារឲ្យ

ឡៅហ្ជីបរិកោគ លុះពេលព្រឹកឡើងកាសៀងក៏ឲ្យឡៅហ្ជីនៅ ។ ផ្ទះសិន
ខ្ជូនកាសៀងក៏ចូលទៅជំរាបតៀវស៊ីវគ្រប់ប្រការ ។ តៀវស៊ីវនៅមិន
ទាន់ធ្វើយតបថាដូចម្តេច ស្រាប់តែមានទាហានអ្ជិនសៀវយកសំបុត្រទៅ
ឲ្យតៀវស៊ីវ ។ ក៏ទទ្ជួលមកលាមើលនៅមុខកាសៀង ក្នុងសំបុត្រនោះមាន
សេចក្តីថា "អ្ជិនសៀវចៅហ្វាយស្រុកគីជីវមកដល់តៀវស៊ីវជ្រាប ដ្ឋិត
វេលានេះចូធូបានជាមហាឧបរាជ ទៅក្រុងហ្ជូតោ ធ្វើការអាក្រក់ផែនដី,
ព្រះចៅហៀនតេនឹងបណ្តានាហ្ជឹនសព្វមុខមន្ត្រី នូវអស់អាណាប្រជា-
នុរាស្ត្រទាំងពួងបានសេចក្តីក្តៅក្រហាយណាស់ បានជាយើងឲ្យសំបុត្រ
នេះអញ្ជើញអ្នក ដើម្បីឲ្យទៅជួយគិតការរាជការនឹងកំចាត់ចូធូចេញ ជា
ទីទំនុកបំរុងព្រះមហាក្សត្រឲ្យបានគង់ជាសុខក្សេមក្សាន្តក្នុងរាជសម្បត្តិ" ។
កាសៀងបានព្ទសំបុត្រនោះច្បាស់ហើយ ក៏ទាញយកពីដៃតៀវស៊ីវមក
កាន់ ហើយស្ងរបំរើនោះថា កាលពីខែកទ្របទយើងបានព្ទដំណឹងថា
អ្ជិនសៀវចៅហ្វាយស្រុកអ្នកឯង លើកងទ័ពទៅច្បាំងនឹងចូធូមិនដឹងចាញ់
ឬឈ្នះ ។ បំរើនោះធ្វើយថា ចៅហ្វាយខ្ញុំបាទលើកកងទ័ពទៅដល់
ដំបន់ឡេយ៉ុងចុងដែនស្រុកហ្ជូតោ ចូធូក៏លើកទ័ពមកតាំងបន្ទាយចម្ងាយ
ពីគ្នាប្រហែល ៨០០ សិន (៣២ គ.ម.) ទទ្ជួលទេសកាលចូលរដូវរងា
អ្ជិនសៀវឲ្យទាហានរាវង់បង្អង់ទុកមិនទាន់ចេញច្បាំងនឹងចូធូទេ ខ្ជូនចូធូ
នឹងអ្ជិនសៀវទាំងសងខាងក៏លើកទ័ពត្រឡប់ទៅស្រុកវិញរៀងខ្ជូន ។

កាសៀងបានស្តាប់ដូច្នោះខឹងណាស់ យកសំបុត្រឈ្ជីចោលហើយ
ស្តីថា "កាលគ្រាអ្ជិនសុតជាប្អូនចៅហ្វាយអ្នកឯង ក៏មិនបានប្រកែតី

យកចិត្តគ្នាទឹងអ៊ូនសៀវជាបង ឥឡូវមកលួងលោមអ្នកដទៃ មិនមែន
សាច់សាលោហិតទៅរួមគំនិតគិតការជាមួយផង ដូច្នេះធ្វើម្តេចនឹងយក
ជាការបាន" ថាហើយក៏បណ្តេញចំរើដែលកាន់សំបុត្រឲ្យដើរចេញ
មួយរំពេច ។ គៀវស៊ីវយើញការសៀងធ្វើដូច្នោះក៏ភ័យណាស់ទើបថា
ហេតុម្តេចបានជាអ្នកធ្វើផ្តេសផ្តាស់ ហែកសំបុត្រអ៊ូនសៀវចោលដូច្នេះ
ព្រោះវេលានេះ អ៊ូនសៀវមានថ្ងៃខ្លាំងពូកែហើយសេនាគាហានក៏មាន
ច្រើន បើអ៊ូនសៀវដឹងការហើយ សូម្បីទឹងលើកកងទ័ពមកធ្វើអន្តរាយ
ស្រុកយើង តើអ្នកនឹងគិតយ៉ាងម្តេចទៅវិញ? ។

ការសៀងតបថា បើលោកបារម្ភខ្លាចដូច្នោះ ខ្ញុំនឹងនាំលោកចូល
ទៅនៅធ្វើការខាងចូឆូវិញ ទោះបីអ៊ូនសៀវនឹងលើកទ័ពមកធ្វើអន្តរាយ
ដល់លោក ចូឆូនឹងបានជួយ ។ គៀវស៊ីវតបថា សព្វថ្ងៃនេះចូឆូ
បានជាមហាឧបរាជក៏មែន តែសេនាគាហានតិចជាងអ៊ូនសៀវ, ប្រការ ១
ចូឆូបានធ្វើសង្គ្រាមទឹងយើងមកពីមុន គង់មានចិត្តអាឃាតព្យាបាទនឹង
យើងមិនភ្លេច ។ ការសៀងឆ្លើយថា បើខ្លាចចូឆូព្យាបាទនោះ ខ្ញុំ
សុំកុំឲ្យលោកព្រួយជាទុក្ខឡើយ បើយើងទៅចូលខាងចូឆូហើយឃើញ
ត្រូវ ៣ ប្រការ : ប្រការ ១ ចូឆូបានជាមហាឧបរាជទោះបីទឹងធ្វើការអ្វី ។
ក៏កាន់យកព្រះតម្រាស់ព្រះចៅហៀនតេជាប្រមាណ នាហ៊ឺនមុខមន្ត្រីក្នុង
ស្រុកក្រុងទឹង ទៅតែគ្រាំគាំងអស់ រមែងគោតខ្លាចអំណាចចូឆូជាច្រើន;
ប្រការ ១ ទោះបីចូឆូមានគាហានតិចក្តីណា តែមានជម្រៃច្បាស់ជ្រៅ
ទូលាយណាស់ ទឹងធ្វើការសង្គ្រាមនៅតំណាវមែងមានជ័យជំនះច្រើន

ជាងឯទាញ់ ដែលលោកគិតទុកបម្អុនសៀវ ប្រជុំនឹងចូលទៅខាងអ្នក-
សៀវដែលមានគាហានច្រើននោះ ។បមាដូចជាមនុស្សមានទ្រព្យសម្បត្តិ
ច្រើន ហើយមានគេយកទ្រព្យរបស់ទៅឲ្យ ក៏មិនសូវត្រេកអរប៉ុន្មាន
ឯបូធូនោះដូចជាមនុស្សខ្សត់ទ្រព្យសម្បត្តិ បើមានគេយកទ្រព្យរបស់តែ
បន្តិចបន្តួចទៅឲ្យក៏មានសេចក្តីត្រេកអរណាស់; ប្រការ ១ ទៀតបូធូ
ធ្វើការគ្រានេះ មានចិត្តធូរធូលាយរួសពាយពាប់អានសេនាគាហានចាំង
ពួង ទោះបីនរណាធ្វើខុសក៏ធ្វើតាមខុស នរណាធ្វើត្រូវក៏ឲ្យចំណាប់
រង្វាន់តាមគុណគាប់គ្រប់គ្នា មិនដែលមានសេចក្តីព្យាបាទដល់អ្នកឯណា
គិតតែយកពាជការជាប្រមាណ ខ្ញុំបានយល់ឃើញហេតុទាំង ៣ ប្រការ
ដូច្នេះ ទើបជាឲ្យលោកទៅចូលខាងបូធូល្អជាជាងអ្នកសៀវ ។ តៀវ
ស៊ីក៏យល់ព្រមផង, ការសឹងក៏លាត្រឡប់ទៅផ្ទះវិញ ហើយនិយាយ
ប្រាប់ឡៅហ៊ីគ្រប់ប្រការ ។ ឡៅហ៊ីបានស្តាប់ពាក្យសឹងគ្រប់ប្រការ
ក៏មានសេចក្តីត្រេកអរពន់ពេក ឲ្យការសឹងនាំខ្លួនទៅជួបនឹងតៀវស៊ី
ដល់ហើយក៏ទទួនគំនាប់តាមសមគួរហើយនិយាយថា លោកកុំបីសន្ទិះ
សង្ស័យនឹងមហាឧបាជនោះឡើយ · បើជាមានចិត្តព្យាបាទទៅហើយ
ក៏នឹងលើកទ័ពមកច្បាំងនឹងលោកយកជ័យជំនះឲ្យត្រាតែបាន នេះអស់
សេចក្តីព្យាបាទហើយទើបប្រើខ្ញុំបានមក អញ្ជើញឲ្យលោកទៅជួយគិត
ការខំទុកចំរុងផែនដី ។ តៀវស៊ីបានឮសំដីឡៅហ៊ីនិយាយដូច្នោះ
ក៏មានចិត្តត្រេកអរណាស់ តាំងចាប់ផ្តើមកេណ្ឌប្រមូលសេនាគាហានបាន
គ្រប់គ្រាន់ ហើយក៏នាំការសឹងនឹងឡៅហ៊ីលើកទ័ពទៅក្រុងហ៊ូតោ ។

ឡៅហ្ជីក៏នាំតៀវស៊ីវនឹងកាសៀងចូលទៅគំនាប់ចូធូ តៀវស៊ីវនឹងកា-
សៀងក៏លុតជង្គង់គំនាប់ចូធូហើយអង្គុយនៅទីទាប ។

ចូធូឃើញតៀវស៊ីវនឹងកាសៀងចូលទៅដល់ ក៏មានចិត្តសោមនស្ស
ណាស់ ចុះទៅទាញដៃតៀវស៊ីវឲ្យក្រោកឡើងមកអង្គុយលើកៅអីដោយ
សមគួរហើយនិយាយថា "ពីដើមយើងបានប្រមាទធ្វើមោះមិនតាប់ត្រឡប់
ចងទោសដល់គ្នានឹងគ្នា សុំឲ្យអ្នកអភ័យទោសដល់យើងចុះ កុំបីមាន
អាឃាតព្យាបាទតទៅឡើយ" និយាយហើយចូធូក៏តាំងតៀវស៊ីវឲ្យធ្វើ
ជាទីអៀងប្ចិចុងគុណ គឺនាយទាហានធំ ឲ្យកាសៀងជាទីតិមជិមង៉
គឺទីប្រឹក្សា ហើយចូធូនិយាយនឹងតៀវស៊ីវ កាសៀងថា ឲ្យតែង
សំបុត្រទៅបញ្ចុះបញ្ចូលឡៅពៀវចៅហ្វាយស្រុកកេងជីវទៀត ។

កាសៀងធ្វើយថា ឡៅពៀវនោះជាមនុស្សរមែងគប់ប្រសព្ធនឹងអ្នក
មានសតិបញ្ញា បើនឹងឲ្យទៅបញ្ចុះបញ្ចូលវេលាណា ត្រូវចាត់ប្រើអ្នក
មានប្រាជ្ញស្មារតីចេះសំដីនិយាយដោះស្រាយឲ្យទៅនិយាយទើបបាន ។

ចូធូក៏ស្ងរទៅស៊ុនហ៊ីវថា អ្នកយល់ឃើញនរណាមានប្រាជ្ញាវាងវៃ
ដែលនឹងប្រើឲ្យទៅស្រដីល្ស្ងងល្ងងលោមឡៅពៀវបាន ។ ស៊ុនហ៊ីវ
ធ្វើយតបថា ដែលនឹងប្រើទៅបញ្ចុះបញ្ចូលឡៅពៀវនោះ ខ្ញុំបាទយល់
ឃើញតែខុងយ៉ុង ១ នេះគួរនឹងប្រើឲ្យទៅបាន ។ ចូធូក៏យល់ព្រមផង
ពេលនោះទីប្រឹក្សានឹងសេនាទាហានទាំងពួងក៏លាចូធូទៅផ្ទះរៀងខ្លួន ។

ស៊ុនហ៊ីវក៏ចូលទៅរកខុងយ៉ុងឯផ្ទះហើយនិយាយថា ឥឡូវនេះចូធូ
រើសរកអ្នកមានសតិបញ្ញា នឹងប្រើឲ្យទៅនិយាយការដើម្បីនឹងបញ្ចុះ

បញ្ចូលខ្លៅពៀវ ខ្ញុំធ្វើយថាឃើញតែអ្នកម្នាក់ឯង ទើបអាចទៅបញ្ចុះបញ្ចូលខ្លៅពៀវបាន ។ ពុទ្ធយ៉ាងបានត្រដួចខ្លោះក៏ធ្វើយថា ខ្លួនខ្ញុំជាអ្នកចេះដឹងតិច ហេតុម្តេចបានជាអ្នកទៅនិយាយដូច្នេះ ប្រសិនបើខ្ញុំទៅនិយាយមិនសម្រេចការរបស់ចូរ អ្នកនឹងខ្ញុំគង់មិនរួចអំពីទោសពុំសឡើយ ។

ស៊ុនហ៊ីវសួរថា អ្នកឃើញនរណាដែលមានដំរេះច្បាស់ជាងអ្នកទៅទៀត? ។ ពុទ្ធយ៉ាងធ្វើយតបថា សំឡាញ់របស់ខ្ញុំម្នាក់ឈ្មោះយីអេង មានសតិបញ្ញាយ៉ាងជ្រៅលើសច្បាស់ខ្ញុំ ១០ ភាគ កុំថាឡើយតែប្រើទៅនិយាយបញ្ចុះបញ្ចូលខ្លៅពៀវប៉ុណ្ណោះ ទោះនឹងឲ្យធ្វើនាហ្មឺនធំក្នុងពាជការព្រះចៅហ៊ានតេកំបាន ខ្ញុំគិតនឹងធ្វើរឿងក៏វាគ្រាបបង្គំទូលព្រះចៅហ៊ានតេ ឲ្យទ្រង់ច្បាស់តាំងយីអេងជានាហ្មឺនមានយសស័ក្តិ រួចសឹមឲ្យទៅនិយាយបញ្ចុះបញ្ចូលខ្លៅពៀវ ។ ស៊ុនហ៊ីវក៏យល់ព្រមផង ទើបពុទ្ធយ៉ាងតែងរឿងក៏វាជាសេចក្តីថា ទូលព្រះបង្គំជាខ្ញុំពុទ្ធយ៉ាង សូមគ្រាបបង្គំទូលថ្វាយ សូមទ្រង់ជ្រាបក្រាមល្អង់ទូលីព្រះបាទ ដ្បិតយីអេងនេះអាយុ ២០ ឆ្នាំ ទៅកង់ស្រុកឡ មានសតិបញ្ញាឆ្លៀវឆ្លាតច្រើន ក្អែកក្រឡេកមើលទៅឃើញរបស់អ្វី ត្រចៀកបានឮសំឡេងអ្វី ចិត្តនោះក៏គិតឆ្ងុំឆ្ងាយរហូតមិនទើសខាល់ ប្រមាណការអ្វីក៏ត្រូវគ្រប់ប្រការ សូមឲ្យទ្រង់យកយីអេងមកប្រើជាខ្ញុំព្រះពាជការ ហើយចាត់ឲ្យទៅនិយាយបញ្ចុះបញ្ចូលខ្លៅពៀវឃើញនឹងធ្វានដោយងាយ" ។

(មានត)

ដំណើរតាមឡាល់ក្នុងតំបន់ភ្នំ

លោក ធើង់-ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុកិច្ចភ្នំពេញ

ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តពីខ្សែលេខ ១ ឆ្នាំ ១៩៥៥)

លោកអែយ៉ាដ មានធម៌សប្បុរស

ព្រះអាទិត្យទើបតែនឹងអស្តង្គត កាលដែលលោកអនុសេនីយ៍ទោ សេលីមជាកូនព្រះចៅ មុយន៍ចា៉ាថា នាំពួកឈ្លើយចូលដល់តំបន់កាសិ-តាពប៊ូលី ។

ថ្ងៃពេលថ្មើរនេះ ដែលឈ្លើយទៅដល់ បណ្តាលឲ្យមហាជនផ្អើលឈូឆរមកមើល ព្រោះតុកាសនោះ ត្រូវពួកស្រីៗ កាន់សំបកឃ្លោកសាយ-ដៀវមួយម្នាក់ចេញទៅជង់តំកអណ្តាង ប៉ុន្តែរឿងនេះមិនសូវសប្បាយមើលដល់ពួកអ្នកកំថ្លង កំលេងចាក់តុកក្រមាច់ក្រមើមនោះកណ្តាលជនអ្នកមើលឡើយ ហើយការកម្សាន្តនេះស្ថិតនៅបន្ទាយពេលរហូតដល់ជិតយប់ ។

ព្រះអាទិត្យជាមេធំនៃកិច្ចការអាជីវៈក្នុងបូពាំប្រទេសដោយពិត ប៉ុន្តែមិនត្រូវភ្លេចឲ្យសោះថា ក្នុងវេលាថ្ងៃ គេអាស្រ័យពួននៅគ្រឹះស្ថានដ៏ត្រជាក់សុខុម មានរបៀងយ៉ាងខ្ពស់សម្រាប់ឲ្យពន្ធឹថ្ងៃចាំងចូលខាងក្នុង ត្រូវកុំភ្លេចថា គេត្រូវការចេញពីក្នុងផ្ទះមកលេងខាងក្រៅ នាសាយណ្ហសម័យ ។ គឺជាតុកាសដែលពួកកម្មករចេញពីពេងជំនាង ដើរយកអាកាសត្រជាក់ពេលល្ងាច មើលភ្នេងលេងល្បែង មើលស្រីដើរដង្ហែគ្នាទៅជង់តំក ។

*

* *

ពួកគាហាននាំឈ្វើយមកបញ្ឈប់ត្រង់កន្ទែងមួយ ។

លោកអនុសេនីយ៍គេ បង្គាប់ឲ្យលោកតាម៉ាព្រុកដើរតាមរហូត
បន្ទាយកងទ័ព ហើយដែលជាទីលំនៅរបស់លោកម៉ាហូម៉េដណាប៊ីប៊ី
ជាវរសេនីយ៍ត្រីតួរគី ។ ចំណែកឈ្វើយដទៃត្រូវរង់ចាំស្តាប់ការណ៍របស់
នាយគាហាន គេនាំគ្នាឈប់នៅក្នុងទីធ្លា តាមថ្នល់មាននាយគាហានរង
នឹងកូនគាហានជាអ្នកត្រួតមើល ។ គេហាមមិនឲ្យពួកអាវ៉ាប់និយាយគ្នា
ឲ្យឹបឲ្យ៉ៀវអ្វីឡើយ ។

លោកព្រិន្ទបាលម៉ាវិយោលោតចុះពីសេះ មិនរវល់នឹងអ្វីទាំងអស់
គាត់គិតតែប្រេមប្រុំនឹងនារីឈ្វើយរបស់គាត់ ។ គាហានដែលលោក
ព្រិន្ទបាលផ្ញើនាងឲ្យីឲ្យា ចង់យកគាប់គួរនឹងនាយចៅហ្វាយ ក៏ជាក់នាង
ក្រមុំពីឲ្នងសេះ ហើយនាំទៅជូនលោកនាយគាហានភ្លាម ។

នាងឲ្យីឲ្យា តាំងពីដំបូង តែងមានសេចក្តីជិនធ្មន់ឡើមលោក
ម៉ាវិយោ ដែលជាមនុស្សយកតែកម្ចាំងកាយនឹងអំណាចមកក្រើ ។

ពួកស្រីក្រមុំព្រហ្មចារ្យតែងមានរហសញ្ញាណមួយជាធម្មតា គឺរហ-
សញ្ញាណនេះហើយដែលឲ្យដំណឹងថា មិនត្រូវស្នេហាចំពោះសាសន៍
តួរគី ។ អនិជ្ជារម្មណ៍ គឺការគំនុំជាទ្វេភាគកើតមានឡើងជល់នាងឲ្យីឲ្យា
ចំពោះ លីសាសន៍នេះ; មួយគឺមកពីចិត្តនាង មួយទៀត គឺបុព្វបុរស
របស់នាងតែងប្រដៅកុំឲ្យចូលចិត្ត គឺសាសន៍តួរគីជាជាតិត្រៃ ជាជាតិ
អសប្ឈុរស ។ នាងឈរញ៉ាំរចំប្រប់នឹកជល់ព្រងរាសនារបស់បងស្រីនាង
ដែលអនាថាតែម្នាក់ឯងលើរាលឲ្យាច់ ។ ពេលថ្មើរនេះសមបងស្រីចាំ

មើលផ្ទូវនាង ចំណែកតួរូបនាងៗ មិនសូវជាតិតប៉ុន្មាន ។ នាងក្រឡេក
មើលជុំវិញខ្លួន ក្រែងលោមានមនុស្សណាស្គាល់នឹងពឹងឲ្យគេជួយ ប៉ុន្តែ
មនុស្សទាំងអស់នេះសុទ្ធតែជាជាតិផ្សេងដែលគេទុកជាអ្នកបំរើ ព្រោះ
នាងគេចាប់មកនៅក្នុងពួកមនុស្សចុងហ្ទូង ។ លោកតាម៉ាព្រុកដោយ
ជំណើរតាត់យឺត ឡានជាមកនៅជាមួយនឹងពួកនេះ ។ ចំណែកពួក
ហ្ទូងធំប្រកបដោយជនជាសាច់ញាតិនឹងនាងឡើឡា ដូចជាម្តាយរបស់
នាង ត្រូវគេបញ្ជូនឲ្យទៅជាមួយលោកតាម៉ាព្រុក នៅមុខលោកអនុ-
សេនីយ៍ត្រីឯណោះ ។ នាងឡើឡាពេលនេះជានារីឯកា ជាច់សង្ឆែង
បណ្តោយខ្លួនទៅលើអាមនុស្សចិត្តអាក្រក់កណ្តាលស្រុកគេ ។

លោកព្រិនូឡាលម៉ារិយោ ឃើញថាទុកាសនេះចំជាមហាស្លួល
របស់លោក ។ ព្រោះនៅទីនោះ មនុស្សទាំងប៉ុន្មានសុទ្ធតែជាអ្នកបំរើ
នឹងជាទាហានរបស់លោក ហើយនឹងអាក៉ប់ខ្ទះដែលមកចោមរោមមើល ។
បើប្រសិនពួកនេះជួយការពារក្នុងពេលដែលនាងមិនព្រមដោយតាម កាន់
តែជាវត្រីជន្ទរទៅ អាអស់នេះនឹងត្រាកអស់មួយរំពេច ហើយតាត់
ជឿជាក់ថា នាងនេះមុខជានឹងតាមតាត់រហូតជល់ខួមដែលនៅខាងក្រៅ
ក្រុងជាមិនខាន ។ អំណាចអានុភាពទឹកស្រវឹងបង្ខិលខួរក្បាលតាត់មិន
ឲ្យយល់អ្វីទាំងអស់ ។ តាត់គិតមិនឃើញជល់ការចលាចលនឹងទីកន្ទែង
ដ៏មិនគួរសម ។ ចិត្តរបស់លោកខាងក្នុងកើតមានកាមរាគយ៉ាងខ្ទាំង
ចំពោះនាងកុមារីព្រហ្មចារ្យនេះពេក គឺជាចំណង់ដែលតាត់ត្រូវតែបំពេញ
ឲ្យសម្រេច មិនគោងការគិតក្រែងរអែងអ្វីទាំងពួងឡើយ ។

*

* *

លោកត្រីនូបាលគោ ដើរចូលមកកាន់ឡើងៗ ចំច្រឹងសំដែងអាការខន់ក្លួនញញឹមពាំងមាត់គ្រហឹប ។ ឃើញដូច្នោះ នាងថយក្រោយដោយឥតដឹងខ្លួនដូចជាគេឃើញសត្វសាហាវយង់ឃ្នង ។ ខណៈនោះ គាត់កំហែងចាប់នាងក្តាម ឲញ្ជាមកផ្តាច់ទឹងឯកសណ្ឋានរបស់គាត់ ហើយនិយាយថា:

- "នាងឯងត្រូវមកនៅនឹងអញ! ម៉េចព្រមឬទេ?" ។

ក្អែកនាងត្រឡប់បើកឡើង នៅចំមុខដ៏គួរស្រឡាញ់ដែលនុនមកកកហាក់ដូចគេបើកក្អែកនៅចំពោះទឹកជ្រាំកខ្វក់ គឺជាការឃើញគួរឲ្យតក់ស្លុតចំពោះមុខដែលស្រាន់តែកំហុសផ្សេងៗ ខុសស្មាមនៅក្រឡៅ ជាមុខឥតធម៌ ខ្លួននាងស្មានដូចជាស្ថិតនៅពីមុខប្រែត ។ នាងនឹកដល់រឿងព្រេងដែលម្តាយនាងនិយាយប្រាប់កាលនៅពីតូច អំពីពួកឆ្មប់កំបាបចាប់ម្ចាស់ក្បែរយកទៅលែងឲ្យនៅកណ្តាលហ្វូងកង្វាដំរីឡើងៗ មានពិស ។ ម្ល៉ោះហើយយុវភាពដូចបុប្ផាកំពុងរីក ជាតិសប្បាយនឹងព្រហ្មចារ្យរបស់នាងតាំងចាប់ប្រឡោតឡើង ។ នាងស្រែកថា: "ទេ! ទេ!,, ។

លោក"រីយោ សើចចំអកឲ្យ ហើយថាត្រាប់សំដីនាង: ទេ! ទេ! ម៉ែប្រមក់! ម៉ែរើសូរ! រួចទឹកមុខគាត់ឡើងក្រហម គាត់ចាប់ទាញកន្ត្រាក់នាងនាំតាំងបង្ខំមកជួបនឹងដើមទ្រូងគាត់ ។ ដៃគាត់ចាប់អារម្មណ៍ដឹងថាតុណកាយនៃនាងញ័ររញ្ជាក់ទៅនឹកឮដូចនាងកូនសំលៀកបំពាក់ គាត់បានជួបប្រទះនឹងកាយដ៏ទន់ភ្លន់ គាត់នឹកដល់ត្រគាកទាំងពីរស្ទីគ្នាពេក ហើយនឹងថនាដូចផ្លែទន្លាប់ខាងកូន ។ ក្តៅងាត កំឆេះឡើងក្តាម

ដូចទឹកស្រវឹងយ៉ាងខ្លាំង ចំពោះរូបតាត់ ដោយអានុភាពសុរា តរុណភាព
នឹងរូបសម្បត្តិនៃនាងក្រមុំឡីឡា ។ តាត់ចាប់ត្រញេចក្បាលនាងក្នុងដៃ
ទាំងពីរ ។ នាងខំត្រជរបម្រះដើម្បីដោះខ្លួនចេញ ប៉ុន្តែតាត់ចាប់ឧប
នាងយ៉ាងជាប់រឹងតាំង កំរើកមិនរួច ហើយមុខតាត់ឧនជាក់ទៅលើបបូរ
មាត់ក្រហមធិល ។ នាងបិទក្នែក ហើយស្រែកដោយសំឡេងតក់ស្ទុត
ស្ទើរបាត់វិញ្ញាណ (ឧ! ត្លូរឲ្យខ្ពើមរអើមយ៉ាងណាទៅ មាត់ចាស់ត្រ-
ហុប ធុំសុទ្ធតែកូនស្រាអសោច៏ ហើយយកមកផ្ទិបនឹងមាត់បរិសុទ្ធដូចផ្ការ
កូឡាបទើបនឹងរីកក្នុងបុព្ទណ្ហសម័យ) ។ ខណៈនោះ លោកម៉ារិយោ
ញេញផ្ទេញបង្ហើបមាត់ឧនជញ្ជក់មាត់នាងឡីឡា ដែលប្រកបដោយ
រសជាតិ ដូចតេជញ្ជក់ផ្លែឈើទុំ. តែតាត់ពុំទាន់បានទំលុះព្រហ្ម្ចចារ្យធម៌
របស់នាងនៅឡើយទេ ។

ធម្មតា យុវភាពដ៏បរិសុទ្ធ ហើយយ៉ាងស្អាត មិនសមឲ្យប្រឡាក់
ដោយដៃអាមនុស្សប្រេតដិតចូលរណ្តៅឡើយ ។

រៀលានោះ ស្រាប់តែមានដៃម្ខយយ៉ាងរឹងដូចដែក ចាប់សង្កត់ស្មា
លោកព្រិន្ទ្ធ៉ាលម៉ារិយោ ហើយកន្ត្រាក់ត្រវត់ទៅក្រោយ ចំណែកនាង
ឡីឡាស្រឡាំងកាំងម្ខយក្នែត ទើបស្គាល់ជាអ្នកជិះសេះម្នាក់ ដែលនាង
ឃានប្រទះក្នុងប៉ុន្មានថ្ងមុន ដោយសារសំលៀកបំពាក់ឯកសណ្ឋានយ៉ាង
សម ។ នាងស្រែកថា: – "អ៊ុស្មាអ៊ុល!" ។

ហើយដោយអាការកតញ្ញូ នាងស្ទុះទៅរក, អ្នកកំឡោះក៏ចាប់ដៃ

នាងសើចញឹមៗ ។ វេលានោះ នាយគាហានឆ្លងដូចគេភ្ញាក់ផើបខ្លួន ញេញធ្មេញជាក់ ហើយស្រែកថា:

– " នាងនេះរបស់អញ។ ចាប់យកតាំងពីក្មេងរហូតមក " ។

អ៊ុស្មាអ៊ីលឆ្លើយដោយសំដីយ៉ាតម្មឹងម៉ាត់ថា:

– " នាងក្រមុំនេះ មិនជាស្រីអាយ៉ាត់គេទេ "

រួចយកដៃកៀកឡឺឡា ដើម្បីជួយការពារឲ្យនាងកក់ក្តៅ ។

កំហឹងឡើងពេញដើមកនៃលោកត្រឹន្ទុបាលម៉ារីយោៗស្រែកដេរថា

– " អាឆ្កែ ! អាកំណើតតីឆ្កែ ! អាឯងមានការណ៍អ្វីមកលាយឡំនឹងរឿងផងអញ ? អាអាប់សំអុយ ! អញមិនត្រូវស្តាប់អាឯងទេ អាឯងទេតើត្រូវស្តាប់អញ " ។ ខណៈនោះ គាត់លូកដៃទៅហួតដាវ ប៉ុន្តែរហ័សដូចផ្លេកបន្ទោរ អ៊ុស្មាអ៊ីលចាប់រំពាត់ដង្កត់មោងធ្វើពីក្អែក ហើយដាក់ចំសៀតផ្កាលោកត្រឹន្ទុបាលគោ ឈាមជាញាក់រៃ ។

លោកម៉ារីយោងឹងងោង ខ្វែតខ្វែត ដួលផ្កាប់មុខទៅដីប្រកាច់ញ័រៗដូចត្រីត្រូវក្បាលមួយដំបង មិនយូរប៉ុន្មានក៏ចាត់ស្មារតីទៅសូម្បីឈឺង ពួកកូនគាហានដែលនៅពេមជុំវិញ ឧទមើល ។ លោកត្រឹន្ទុបាលដាច់ខ្យល់ស្រេច ។ ក្នុងពេលនោះដោយការរោទ្បា ជ្រួលជ្រើមយ៉ាងខ្លាំងដែលបណ្តាលពីដំលោះនេះ មានទាយគាហានម្នាក់រត់មក ។ លោកឈ្លាកមើលខ្លោចសំឡឹងមើលកូនគាហានដែលនៅជុំវិញ រួចដើរសំដៅ អ៊ុស្មាអ៊ីល ហើយសួរដោយពាក្យតែត្បិតថា:

– " ឯងជាអ្វី ?

អ្នកកំណែ្ចះធ្វើយ ច្រៀបជាយសំដីតបថា :

— " ខ្ញុំបាទឈ្មោះ អ៊ុស្មាអ៊ីល បេនអៃយ៉ាដ ជាកូនលោកកាអ៊ីដ ខ្ញុំធ្វើទណ្ឌកម្មដល់មនុស្សនេះព្រោះវាជាចោរកំណាច ! " ។

នាយឥហានេះ ជញ្ជឹងគិតយ៉ាងជ្រៅ ហើយទឹកថា ដែលនឹងធ្វើទុក្ខទោសដល់កូនលោកកាអ៊ីដ គឺជាការប្រែហេសណាស់ ឬដូចម្តេចអេះ ដ្បិតសម័យនេះ ជាសម័យដែលរដ្ឋាភិបាលតួរតែត្រូវការពីងយ៉ាងមាំមានមិនបានលើមេអាក៉ាប់ដែលមានអានុភាពខ្លាំងនេះ ។

ម្យ៉ាងទៀត នាយឥហាននេះស្គាល់ច្បាស់នូវឫកជនាលោកព្រិនូបាលទោមារិយោ គឺជាមនុស្សដែលនាំបណ្តាលក្តៅខ្លួនឲ្យកើតមានជាញឹកញាយក្នុងកំឡុងកងទ័ព ។ ក្នុងទីបំផុត លោកដឹងថា ខាងក្រោយពេជានកម្មនៃពួកអាក៉ាប់ចកចក់ ហេតុថែបនេះកើតមានឡើង ហើយមិនបាត់ស្ងាត់ នោះនឹងធ្វើឲ្យប្រជាជនមិនតាំងនៅក្នុងរបៀបផង នឹងធ្វើឲ្យមនុស្សដែលរកតលុះចូលតាំងអស់តាំងពីដើមមក ត្រឡប់ទៅជាបះ-ចោរឡើងវិញផង ។ ណ្តើយចុះ ការនិងាសនាយឥហានរងមួយនេះ ក៏ជាអំពើមួយយ៉ាងប្រពៃដល់កងទ័ពតួរតែដែរ ហើយមិនបាច់ដំនុំនឹងមិត្តភ័ក្តិដែលទៅជួបជុំ លោកបែរទៅរក អ៊ុស្មាអ៊ីល ហើយច្រៀបថា :

— " ល្អហើយ ! ឯងរួចខ្លួន ! " ។

កាលនោះ អ្នកកំណែ្ចះកៀកនាងត្រមុំឡើងជើរតិច ។ តម្រង់ផ្ទះអាពុក ដែលមើលឃើញកំពូលស ។ លេចឡើងខ្ពស់ជាងគេក្នុងក្រុង ។

(មានត)

ឡើងបល្ស័ង្ក៦ទិព្យ សាមសិបពីរឡើង

ឡើងព្រេងឥណ្ឌៀ

លោកសមិន ម្ចាត្យ៉ងជម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែជៀបជៀង

(តមក)

ដល់រៀលាក្រោយមក, មិនយូរប៉ុន្មាន ព្រះអគ្គមហេសីប្រសូត ព្រះរាជបុត្រ ហើយព្រះនាងប្រគល់ព្រះរាជបុត្រនោះទៅឲ្យព្រះរាជទី ប្រឹក្សា រួចព្រះនាងបូជាព្រះរូបរបស់ព្រះនាងចំពោះព្រះអគ្គី សោយ ព្រះវិលាល័យ ដោយមានព្រះរាជបំណងនឹងឲ្យបានទៅសោយទិព្វសម្បត្តិ ជាមួយនឹងព្រះមហាក្សត្រិយ៍វិក្រមទិត្យ ជាព្រះរាជស្វាមីឯស្ថានសួគិ ។

ព្រះបាទវិក្រមសេន ព្រះរាជបុត្រនៃព្រះបាទវិក្រមទិត្យ ទ្រង់បាន ទទួលព្រះរាជាភិសេក ហើយទ្រង់បានឡបត្ថម្ភសត្វលោក ឲ្យបានសុខ ស្ថួលគ្រប់យ៉ាង ដូចជាព្រះរាជបិតា, តែមិនអាចគង់លើព្រះបល្ស័ង្ក៦ទិព្យ ដែលជាអំណោយរបស់ព្រះឥន្ទ្រាធិរាជបាន" ។

ឧមហារាជកោជ:, សូមទ្រង់ជ្រាបថាតាំងពីនោះមិនដែលមានមហា-ក្សត្រអង្គណាដែលមានសមត្ថភាព អាចគង់លើព្រះបល្ស័ង្ក៦ទិព្យនេះបាន ឡើយ ។ ព្រោះមានសំឡេងខាងលើអាកាសបន្ទឹថា: នៅក្នុងពិភព លោកនេះ គ្មានបុគ្គលណាអាចគង់លើព្រះបល្ស័ង្ក៦ទិព្យនេះបានទេ ដូច្នេះ សូមឲ្យព្រះអង្គជីកដីហើយកប់ព្រះបល្ស័ង្ក៦ទិព្យនេះតំកល់ទុកក្នុងកន្ទែងដើម

វិញ្ញាឡៅ ។ រូបទេពនិម្មិតទីមួយនោះពោលឡៅទ្រៅតថា: "សូមព្រះអង្គទ្រង់ជ្រាប, ព្រះបល្ល័ង្កនេះ គឺព្រះបល្ល័ង្កដែលព្រះអង្គទ្រង់បានចាត់ឲ្យរកឃើញនេះឯង"

ពាក្យនិទាននៃរូបទេពនិម្មិតទីមួយ

រូបទេពនិម្មិតទីមួយពោលថា: ឧមហារាជកោជ: សូមព្រះអង្គសវនាអំពីកិត្តិគុណនៃព្រះមហាក្សត្រិយ៍វិក្រមទិត្យជូចតឡៅនេះ ។ មានកាលមួយថ្ងៃ ព្រះបាទវិក្រមទិត្យ ទ្រង់គង់លើព្រះបល្ល័ង្កទិព្យ ក្នុងកណ្ណាលមន្ទីរព្រះរាជក្រុមប្រឹក្សាក្នុងព្រះបរមរាជវាំង ក្នុងព្រះរាជធានីអវន្ទី, ស្រាប់តែមានទុគ្គតបុរសម្នាក់មកជល់ទីនោះ បានចូលឡៅជិតព្រះអង្គ ឈរស្ទ្រាមស្ទាត់ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានទតឃើញដូច្នោះ, ទ្រង់ព្រះចិន្តាថា: "ជនជាស្ទូមយាចកប្រៀបដូចជាបុគ្គលដែលជិតផ្ទើមរណភាព តែងមានកាយញ្ញាប់ញ័រ, មាត់ស្ទ្រាមស្ទាត់ មិនអាចមានស័ព្ទសំដីមួយម៉ាត់ចេញសោះឡើយ ។ ប៉ើអញប្រៀបធៀបនូវសភាពទាំងពីរបែបនេះ ខ្ជួនអញយល់ថា មនុស្សនេះមកដើម្បីសុំទាន បានជាមិនអាចពោលស័ព្ទសំដីមួយម៉ាត់ឡើយ" ។ ដល់ព្រះមហាក្សត្រិយ៍ទ្រង់ព្រះតម្រិះដូច្នោះហើយ ព្រះអង្គបានប្រគល់ប្រាក់មួយពាន់ប៉ាកូដ (1) ឲ្យបុគ្គលនោះ។ ទទួលហើយ នៅឈរស្ទ្រាមមួយកន្ទ្រង់តឡៅទ្រៅត ឥតមានពោលពាក្យអ្វីឡើយ ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលសួរថា: "នៃ

---

1 ប៉ាកូដ ជារូបបិយវត្ថុមាសនៅប្រទេសឥណ្ឌា មានតម្លៃ ៨ ស្ទ៍ង ឬ ១០ ត្រណោត; ប៉ាកូដ ប៉ើហៅតាមភាសាឥណ្ឌា ថា «ហ្ទន» ។

សូម, អ្នកឯងម្តេចក៏មិននិយាយអ្វីដូច្នេះ?" ។ បុរសនោះក្រាបទូលថា "មកពីមានសេចក្តីអៀនខ្មាស បានជាទូលបង្គំជាខ្ញុំពោលពាក្យអ្វីមិនកើត" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់នូវពាក្យបុរសនេះហើយ ទ្រង់ចាត់ឲ្យប្រគល់ប្រាក់មួយពាន់ប៉ាកូដទៀត ហើយទ្រង់មានព្រះរាជ-ឧង្ការទៅកាន់បុរសនោះថា: "នែបុរស បើអ្នកចង់ពោលពាក្យអ្វីក៏ពោលមកចុះ" ។ បុរសនោះក៏ក្រាបថ្វាយបង្គំទូលតបវិញថា "បពិត្រមហារាជ, កិត្តិគុណនៃបច្ចាមិត្តរបស់ព្រះអង្គមិនអាចចេញចាកគេហស្ថានរបស់រាបាន, មិនអាចផ្សាយពាសពេញទៅខាងក្រៅបានទេ បណ្ឌិតពោលថា កិត្តិគុណនោះជាលាមកជាយ៉ាងក្រៃលែង; ចំណែកកិត្តិគុណរបស់ព្រះអង្គអាចផ្ទើឲ្យវង្វេងពួកជីវលោកនៅក្នុងបាតាល, អ្នកកវីពោលថា កិត្តិគុណរបស់ទ្រង់នេះវិសេសវិសាលណាស់, នេះគួរឲ្យធ្ងល់ពន់ពេកណាស់" ។ ព្រះមហាក្សត្រិយ៍ទ្រង់បានសវនានូវរាចាបុរសនោះហើយ មានព្រះទ័យសោមនស្សពន់ពេក ទ្រង់ក៏ចាត់ឲ្យប្រគល់ប្រាក់មួយពាន់ប៉ាកូដទៀត ។ ក្នុងពេលនោះទុគ្គតបុរសក៏ក្រាបបង្គំទូលថា "បពិត្រព្រះមហាក្សត្រិយ៍, ទូលព្រះបង្គំមានប្រាថ្នាចង់ដឹងថា បើព្រះមហាក្សត្រិយ៍អង្គណាមួយមានគុណសម្បត្តិ ដោយទ្រង់ទបត្ថម្ភប្រជាកស្ត្ររបស់ព្រះអង្គយ៉ាងដិតស្មិទ្ធ, ព្រះមហាក្សត្រិយ៍អង្គនោះមិនបានទទួលនូវសេចក្តីនិន្ទាពីប្រជាកស្ត្រឡើយ ហើយអាចនឹងចៀសផុតពីសេចក្តីលំបាកសព្វយ៉ាង, សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសវនានូវរឿងដូចខាងក្រោមនេះ ៖

មានព្រះមហាក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាម នន្ទ: សោយរាជ្យ
នៅទីក្រុងឈ្មោះ វិសាលា ។ ស្តេចអង្គនេះមានព្រះរាជបុត្រព្រះនាម
វិជយបាល, ព្រះរាជទីប្រឹក្សាឈ្មោះ ពហុស្ចុត, លោកសារទានន្ទ
ជារាជត្រូ, ព្រះនាងរានី(1) ភាណុមតី ជាអគ្គមហេសី ។ ព្រះ
មហាក្សត្រិយ៍ ទ្រង់សព្វព្រះរាជហ្ចូទ័យពន់ពេកនឹងរូបឆោមលោមពណ៌
នៃព្រះនាងរានី ភាណុមតី ទាល់តែទ្រង់ភ្លេចមិនបានទ្រង់ព្រះចិន្តាជល់
រជ្ជបុរសព្រះអង្គ តើសម្ស្យណ៌ដោយភោគទ្រព្យប្ចលំបាកយ៉ាងណា: សោះ
ឡើយ ។ ហើព្រះអង្គទ្រង់បំពេញព្រះរាជករណ៌យកិច្ច ក្នុងរយ:
រៃលាម្ពងមួយកាល- ក៏ទ្រង់គង់នៅលើព្រះបល្ស័ង្គទិព្យជិតព្រះនាងរានី
ភាណុមតី ។ មានមួយថ្ងៃ ព្រះរាជទីប្រឹក្សា បានក្រាបបង្គំទូលថា
"សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោសព្រះរាជានុញ្ញាត ទូលព្រះបង្គំជា
ខ្ញុំសូមថ្វាយយោបល់ សូមទ្រង់ជ្រាបថា: ព្រះអង្គមិនគួរឲ្យព្រះនាងរានី
ចូលមកប្រជុំជាមួយក្រុមប្រឹក្សាក្នុងព្រះបរមរាជរាំងឡើយ" ។ ព្រះ
មហាក្សត្រិយ៍ទ្រង់តបវិញថា: "លោកទីប្រឹក្សា! អ្នកឯងពោលនេះ
ប្រកបដោយវិចារណញ្ញាណពិតហើយ តែយើងមិនអាចស្ថិតនៅបាន
តែមួយនាទី ដោយមិនឃើញព្រះនាងរានីសោះឡើយ" ។ ព្រះរាជទី
ប្រឹក្សាក្រាបទូលទៀតថា "សូមព្រះអង្គទ្រង់ចាត់ឲ្យពួកវិចិត្រការគូររូប
ព្រះនាងរានី ភាណុមតី នៅលើសំពត់ក្រាស់ ហើយទ្រង់រក្សាទុកជិត
ព្រះអង្គ" ។ ព្រះមហាក្សត្រិយ៍ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យពួកវិចិត្រការ

---

1 រានី ព្រះអគ្គមហេសី ទីមួយ ។

មើលនូវសភាពលំអ ធវីវណ្ណនៃរូបព្រះនាងកនី ភាណុមតី ហើយក៏យក
លំអនោះទៅប្រតិស្ឋានទៅលើសំពត់ ។ ពួកវិចិត្រករបានធ្វើតាមព្រះ
រាជឧត្តារហើយ ក៏ថ្វាយទៅព្រះមហាក្សត្រិយ៍ ។ បានបង្ហាញរូបគំនូរនោះ
ទៅលោកត្រូសារទាន្ធ ហើយមានព្រះបន្ទូលថា "តើលោកត្រូមើល
រូបគំនូរនេះយល់ឃើញដូចម្តេច?" ។ លោកសារទាន្ធទូលតបថា:
"នេះជារូបគំនូរព្រះនាងកនីភាណុមតីហើយ តែព្រះនាងមានត្រាប់លំអ
កិនភាគគួរឲ្យស្នេហា.(១) ស្ថិតនៅភ្លៅទាងធ្វេង ដែលពួកវិចិត្រករភ្លេច
គូរនៅលើរូបនេះ គឺជាគុណវិបត្តិតែម្យ៉ាងនៃរូបគំនូរនេះ" ។ ព្រះមហា-
ក្សត្រិយ៍ទ្រង់សវនានូវរាចាលោកត្រូនេះហើយ ទ្រង់ព្រះតម្រិះថា: "ហេតុ
ម្តេច ក៏លោកត្រូសារទាន្ធបានឃើញនូវត្រាប់លំអ ស្ថិតនៅភ្លៅព្រះ
នាងកនីភាណុមតី? ប្រហែលជាមានហេតុអ្វីមួយក្នុងរឿងនេះ" ។ ព្រះ
មហាក្សត្រិយ៍ទ្រង់ព្រះក្រោធជាទ្វាំង ក៏ទ្រង់ចាត់ឲ្យព្រះរាជាទីប្រឹក្សាយក
លោកត្រូសារទាន្ធទៅពិឃាដចោល ។ ព្រះរាជទីប្រឹក្សាបាននាំលោក
សារទាន្ធទៅឯគេហដ្ឋានរបស់ខ្លួន ហើយក៏នឹកពិចារណារឿងនេះថា:
ព្រះមហាក្សត្រិយ៍ ទ្រង់មិនបានតម្រិះឲ្យហ្មត់ចត់នូវបទឧក្រិដ្ឋនៃលោក
សារទាន្ធ ហើយទ្រង់ត្រាស់បង្គាប់ឲ្យយកទៅធ្វើឃាដកម្ម; អញមិនគួរ
នឹងសម្ងាប់នូវមហាបុរសនេះដោយមិនដឹងហេតុពិតប្រាកដយ៉ាងនេះសោះ,
ប៉ើអញចាត់ឲ្យធ្វើឃាដកម្មលោកនេះ គឺទុកជាអញធ្វើឲ្យព្រះមហាក្សត្រិយ៍

---

១ ប៉ើតាមញ្ញាន:ថា ត្រាប់ល្ង ជាសម្មតិនាម ប្រែថា ភិនភាគដ៏ល្អផុត ។
ភិនភាគនេះ ប្រហែលជាប្រជ្រុយទេដឹង ! ។

ប្រែត្រឡប់ទៅក្រដូវវិញ" ។ ព្រះពាជទីប្រឹក្សាដល់បានពិចារណារឿង នេះសព្វគ្រប់ទៅ បានចាត់ឲ្យធ្វើកន្ទែងមួយនៅក្នុងដីកងគេហដ្ឋានរបស់ លោក ហើយកំលាក់បំពួនខ្លួនលោកគ្រូសារនានូនៅទីនោះ ។

មានកាលមួយថ្ងៃ, ព្រះអង្គម្ចាស់វិជយចាលជាព្រះពាជបុត្រីព្រះ មហាក្សត្រិយ៍នន្ទ ទ្រង់យាងទៅចាញ់សត្វក្នុងព្រៃ ។ កាលព្រះអង្គម្ចាស់ ទ្រង់យាងដល់អរញ្ញប្រទេស ទ្រង់បានទតឃើញជ្រកព្រៃមួយហើយក៏ ទ្រង់ដេញតាមរហូតទៅដល់ព្រៃជ្រៅ ដើម្បីនឹងសម្លាប់នូវជ្រកព្រៃនោះ។ ព្រះពាជបរិវារក៏រវើរវាយខ្ចាត់ខ្ចាយពីគ្នា មិនដឹងទៅទិសតំបន់ណា ។ ព្រះអង្គ ម្ចាស់ ដោយទ្រង់ស្រេកព្រះសីតវាស ក៏ទ្រង់ទំសែងរកទីដែលមានទឹក, ទ្រង់បានជួបប្រទះនូវត្រពាំងមួយ ហើយក៏ទ្រង់ឈប់ដើម្បីនឹងសោយ នូវព្រះទេកៈ ។ ក្នុងពេលនោះទ្រូលមានខ្លាមួយមកដល់ ។ ព្រះ អង្គម្ចាស់វិជយចាលកាលទតឃើញនូវខ្លានោះ ទ្រង់ទំឡើងលើរុក្ខជាតិមួយ ដើម ដែលមានពានមួយនៅទីនោះ ។ ពានរនោះក៏ក្រាបទូលព្រះ ពាជបុត្រថា: "សូមព្រះអង្គម្ចាស់ទ្រង់ជ្រាបថានៅទីនេះ ទ្រង់មិនត្រូវ ខ្លាចអ្វីឡើយ, ទ្រង់ស្តេចមកខាងលើដីតទូលបង្គំជាខ្ញុំចុះ" ។ ព្រះ ពាជបុត្រក៏ទ្រង់ឡើងទៅលើព្រឹក្សជាតិ តាមពាក្យពានរ ។

(មានត)

កំណាត់នៃប្រវត្តិការណ៍

សុន្ទរកថា

ថ្លែងក្នុងឧកាសពិធីបុណ្យស្រោចទឹកចំពោះព្រះជន្ម នៃសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក គណៈធម្មយុត្តិវត្តបទុមវតី ដែលធ្វើឡើងក្រោមព្រះរាជាធិបតីនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង កាលពីព្រឹកថ្ងៃទី ២០ កុម្ភៈ ឆ្នាំ ១៩៥៥

របស់អាចារ្យវត្តបទុមវតី

សូមព្រះតេជៈដ៏កល់លើត្បូង

សូមព្រះពជគានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, ទ្រង់, ឯកឧត្តម

អស់លោកអ្នកគាំង ឬក្បាយ!

សម័យនេះ ខ្ញុំបាទ នឹងឧបាសកឧបាសិកា ព្រមទាំងព្រះថេរានុត្ថេរ ក្នុងក្រុងកំពេញទឹងខែត្រក្រៅ មានព្រះមង្គលទេឝ្ឋាចារ្យជាប្រធាន, មានឥតវេទិតាធម៌កើតមានទៀងចំពោះសម្តេចព្រះសុធម្មាធិបតីជាសង្ឃនាយកគណៈធម្មយុត្តិ ដែលជាមហាថេរ ១ អង្គប្រកបដោយគុណសម្បត្តិ, ទាំងមានទឹកព្រះវិញ្ញ ប្រកបដោយឱជ្ជាមេត្តាឧកៈ នឹងសោរច្ចៈស្មោះស្ម័គ្រចំពោះពុទ្ធសាសនា នឹងពុទ្ធបរិស័ទជានិច្ច ។

សម្តេចព្រះសុធម្មាធិបតីអង្គនេះ ជាព្រះសមណៈមួយរូបមានគុណធម៌ដ៏បរិសុទ្ធ ជាមហាស្ថាវរៈ ទាំងចរិយាវត្ត ផ្លូវកាយនឹងវាចាក៏រៀបរយសមរម្យល្អគួរជាទីគោរព គួរជាទីនមស្ការបស់បពូជនទាំងគ្រហស្ថទាំងពួង ។

តេជាទុកាពរបស់ព្រះអង្គលោកបែបនេះ មានអាការហាក់បីដូចជាមកចាប់ចុចកន្ត្រាក់ចិត្តចេតសិករបស់ទូលព្រះបង្គំខ្ញុំប្របាទជានិរន្តរ์ ។ បានជាព្រះថេរានុត្ថេរ: នឹងទូលព្រះបង្គំខ្ញុំប្របាទព្រមទាំងឧបាសកឧបាសិកា រួមគំនិតគ្នាជាឯកច្ឆន្ទ ប្រារព្ធធ្វើបុណ្យចំរើនព្រះជន្មព្រះអង្គលោកគឺបន្ពព្រះជន្មឲ្យបានឋិតថេរចិរកាលតវែងទៅ ដើម្បីអប់រំតាំទ្រនូវព្រះពុទ្ធសាសនា នឹងពុទ្ធបរិស័ទទាំងអស់ ឲ្យបានរុងរឿងថ្ពំថ្ពើងដោតនាការជាវិបុលភាព ។

បុណ្យអាយុវឌ្ឍន:នេះ ជាបុណ្យមួយដែលកវីបណ្ឌិតព្រឹទ្ធាចារ្យទាំងឡាយធ្លាប់បដិវត្តន៍មកហើយ ដោយអនុវត្តន៍តាមគម្ពីរ ដិណកាលមាលិនី ទំព័រ ៦៨ បន្ទាត់ ១៦ និព័ន្ធទុកមកថា ក្នុងក្រុងលង្ការទ្វីប មានមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាម វសភរាជ ព្រះអង្គមានព្រះរាជឧង្ការស្លូរហោរាថា ខ្ជូនយើងនេះនៅប៉ុន្មានឆ្នាំទៀតនឹងទិវង្គត ។ ហោរាគិតគូរតាមក្ស្ជូនហោរាសាស្ត្រក៏ក្រាបទូលថា ព្រះករុណាជាអម្ចាស់ជីវិតលើត្ស្ជូងនៅតែ ១៦ ឆ្នាំទៀតនឹងទិវង្គត ។ ព្រះមហាក្សត្រទ្រង់មានព្រះរាជឧង្ការស្លូរថា យើងគិតធ្វើដូចម្តេច នឹងបន្ពព្រះជន្មឲ្យបានយឺនយូរទៅទៀត? ។ ហោរាក្រាបទូលថា រឿងនេះ ត្លូរស្លូរព្រះសង្ឃទើបជ្រាបប្រាកដ ។ ព្រះនរបតីទ្រង់មានព្រះរាជឧង្ការស្លូរព្រះសង្ឃ ។ ថ្វាយព្រះពរថា ហេតុដែលនាំឲ្យចំរើនព្រះជន្មមាន ៦ ប្រការ ឈ្មោះថាអន្ពរាយវិមោចនធមិប្រែថា "ធមិកំចាត់បំបាត់បង់នូវសេចក្តីអន្ពរាយ" គឺ:

๑ – បរិសោវិទាធំ ឲ្យធម្មក្រែកសម្រាប់ត្រងទឹក

๒ – អារិសទាធំ កសាងអាវុស

๓ – គិលានវត្តុទាធំ ធ្វើគិលានវត្ត (ថ្នាំកែរោគ)

๔ – កាតព្វដិណកាវិសំ ដួសដុលអាវុសចាស់

๕ – បញ្ចសីលសមាទាធំ សមាទានសីល

๖ – ឧបោសថ្ងបុប្ផវិសោ រក្សាឧបោសថ ។

ព្រះប្រិយមហាក្សត្រខ្ញុំព្រះអង្គកំរិយាយាម កសាងធម៌ទាំង ๖ យ៉ាងនេះ ត្រឹមទាំងវិសាខបូជា ព្រះជន្មាយុរបស់ព្រះអង្គកំរិយាវឌ្ឍនាការបាន ๔๔ ឆ្នាំ ទើបទិវង្គត ។

ដោយអំណាចសច្ចិចេតនារបស់ព្រះថេរានុត្ថេរៈ នឹងទូលព្រះបង្គំ, ខ្ញុំ ប្រចាទ ត្រឹមទាំង ឧបាសក ឧបាសិកា ដែលប្រឹងប្រែងកសាងដោយផ្លូវ កាយ - វាចា - ចិត្តយ៉ាងនេះ សូមប្រគេនបុញ្ញភាគីដែលដុះផុះចេញអំពី សុទ្ធិចេតនាចំពោះសម្តេចជាម្ចាស់ ដែលជាប្រមុខនៃពុទ្ធសាសនិកជន គណៈធម្មយុត្តិកនិកាយ សូមសម្តេចជាម្ចាស់ទទួលអនុមោទនាយកភាគ ផលនេះ ហើយសូមប្រកបដោយព្រះជន្មាយុយឺនយូរតរៀងទៅ ព្រះ ទ័យបំណងប្រៃបណា សូមសំរេចតាមប្រាថ្នាសព្វកាលទាំងពួង ។

ម្យ៉ាងទៀតព្រះថេរានុត្ថេរៈទាំងឡាយ នឹងទូលព្រះបង្គំ, ខ្ញុំប្រចាទ សូមព្រះពជទាងព្រះបរមពជវរោកាស សូមថ្វាយព្រះពជកុសលជល់ ព្រះកុណាជាអ្នកម្ចាស់ដីវិតលើត្បូង នឹងសម្តេចព្រះបរមពជបិតា សម្តេច

ព្រះវរាជជនន៊ីនាថ ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយ ព្រះជន្មាយុបិតថេរចិរកាល សូមព្រះក្សេមសុខក្នុងសិរីរាជសម្បត្តិសព្ទ-ទិនទិវារាត្រី ។

នៅទីបំផុតនេះ ដោយអំណាចតេជះនៃពុទ្ធសាសនានឹងតេជះនៃ សកលលោក សូមពួកទេព្តាទាំងឡាយដែលមានឥទ្ធានុភាពដ៏ធំទូលាយ មេត្តាអភិបាលសម្តេចព្រះសុធម្មាធិបតីសង្ឆនាយកគណធម្មយុត្តិកនិកាយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្សូង សម្តេចព្រះបរមរាជបិតា, សម្តេចព្រះ វរាជជនន៊ីនាថ នឹងព្រះរាជវង្សានុវង្ស នឹងនាឿនសព្ទមុខមន្ត្រី ព្រម ទាំងយើងខ្ញុំទាំងអស់គ្នាកុំបីឃ្លៀងឃ្លាតឡើយ ។

ទោសក្សត់ម្ចាស់ផែនដី

នរជនណា ដែលម្ចាស់បានតែងតាំងក្នុងហានៈជាមន្ត្រីហើយ ។ ក្សត់ទំលាយការសម្ងាត់នៃម្ចាស់ នរជននោះ នឹងធ្លាក់ទៅនរកដោយ ខ្លួនឯង ព្រោះហេតុតែបំផ្លាញការងារនៃម្ចាស់នោះឯង ។

មន្ត្រីណា ក្សត់ទំលាយការសម្ងាត់នៃម្ចាស់ផែនដីណា ម្ចាស់ផែនដីនោះ នឹងត្រូវសម្ងាប់មន្ត្រីនោះ ដោយមិនបាច់ប្រើអាវុធ នេះជាច្បាប់នៃអ្នកប្រាជ្ញនារទៈ ។

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់ក្រសួងធម្មការ

(តពីខ្សែលេខ ១ ឆ្នាំ ១៩៥៥)

សញ្ញាប័ត្រលេខ ៩៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-តាំង នាមធាយា ឥន្ទត្ថេរ កើតឆ្នាំមមែ អាយុ ៦៣ វស្សា ២០ ជាគ្រូសូត្រស្ពាំ វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កិម-ផាន់ នាមធាយា នន្ទប្បញ្ញា កើតឆ្នាំជូត អាយុ ២៦ វស្សា ២ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រាប-ហង់ នាមធាយា ចន្ទត្ថេរ កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣៦ ជាចៅអធិការ វត្តចិញ្ចេង ឃុំដើងកួន ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ក៉-ពៅ នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំមមែ អាយុ ៥៥ វស្សា ៣៦ ជាគ្រូសូត្រស្ពាំ វត្ត-ឃុំ ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សំរិត-ផាន់ នាមធាយា ធម្មដោត កើតឆ្នាំច អាយុ ២៨ វស្សា ៩ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ

សេន-ម៉ុម នាមធាយា ជោតត្ទេរ កើតឆ្នាំវក អាយុ ៤២ វស្សា ២០ ជាចៅអធិការ វត្តប្រាសាទនាងខ្ទៅ ឃុំរវៀង ស្រុក-ខែត្រជជែល ។

សញ្ញាបំត្រលេខ ៩៣៨ ចុះកាលបរិច្ចេទជជែល តាំងលោកត្រូ សុខ-លុយ នាមធាយា សុវណ្ណត្ទេរ កើតឆ្នាំកុរ អាយុ ៣៩ វស្សា ២០ ជាត្រូសូត្រស្ពាំ វត្ត-ឃុំ-ស្រុក-ខែត្រជជែល ។

សញ្ញាបំត្រលេខ ៩៣៩ ចុះកាលបរិច្ចេទជជែល តាំងលោកត្រូ ឆង-ឈួង នាមធាយា សុវណ្ណជោត កើតឆ្នាំធ្ងូរ អាយុ ៣៧ វស្សា ១៧ ជាត្រូសូត្រធ្ងង វត្ត-ឃុំ ស្រុក-ខែត្រជជែល ។

សញ្ញាបំត្រលេខ ៩៤០ ចុះកាលបរិច្ចេទជជែល តាំងលោកត្រូ ហ៊ាន-ចេង នាមធាយា សុធម្មត្ទេរ កើតឆ្នាំរកា អាយុ ៤១ វស្សា ១៩ ជាចៅអធិការ វត្តជើងកួន ឃុំជើងកួន ស្រុក ខែត្រជជែល ។

សញ្ញាបំត្រលេខ ៩៤១ ចុះកាលបរិច្ចេទជជែល តាំងលោកត្រូ អ៊ុក នន់ នាមធាយា ឥន្ទជោត កើតឆ្នាំរកា អាយុ ៦៥ វស្សា ១៦ ជាត្រូសូត្រធ្ងង វត្តស្ងារម ឃុំរវៀង ស្រុក-ខែត្រជជែល ។

សញ្ញាបំត្រលេខ ៩៤២ ចុះកាលបរិច្ចេទជជែល តាំងលោកត្រូ ម៉ី មាច នាមធាយា ឥន្ទបញ្ញា កើតឆ្នាំកុរ អាយុ ៣៩ វស្សា ២០ ជាត្រូសូត្រស្ពាំ វត្ត ឃុំ-ស្រុក-ខែត្រជជែល ។

(មានត)



ឥន្ទ្រសន្ទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមេសា លេខ ៤

ព.ស. ២៤៩៣ – គ.ស. ១៩៤៤

D L 26-5-5



តារាមសនៈយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

មាតិកា

ផ្នែកសាសនា		ទំព័រ
—វិបារណកថា	លោកប៊ូ-ប៊ូ	២៤៣
— ឃ្លោកលិចអំបែងអណ្តែត	ព្រះទេពសត្ថា កឹម-គូ	២៥៣
— បញ្ញាសជាតក ភាគទី ៣ (តមក)	បណ្ឌិតមហា ឈឹម -ស៊ុម	២៦១
ផ្នែកអក្សរសាស្ត្រ		
— រឿងសៅរសោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង—ប៊ម ...	២៦៩
— រឿងសាមកុក (តមក)	ឧកញ៉ា ឆូ- កន	២៧៤
— ដំណឹងតាមខ្សែក្នុងកន្ទារៈ (តមក) ...	លោក ផេង - ជ្រឹរ	២៨២
— រឿងបល្ល័ង្កទិព្យ (តមក)	លោក វ៉ាយ- ប៊ុក	២៨៨
កំណត់ទឹនប្រវត្តិការណ៍		
— ពិធីបែកព្រហ្មចារ ដាល់សមណនិស្សិត សាលាបាលីដាន់ខ្ពស់	ពុទ្ធសាសនបណ្ឌិត្យ	២៩៥
— ពិធីបុណ្យបូជាសពលោកគ្រូ ប៊ិន - ទិត ចៅអធិការវត្តបឹងវ៉ៃខ្ទែស្រុកយៃរៀង	លោក ញ៉ែម - ទឹម	៣១០
—បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក)	ក្រសួងធម្មការ	៣១៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Editorial	M. BOU-PO	243
— Proverbe cambodgien	Vén. KEM-TO	253
— Pannasajataka- vol.3 (suite) .	M. CHHIM-SOUM	261

PARTIE LITTERAIRE:

— Le «SAU SOY» ou l'influence saturnienne (suite)	Vén. PEUNG-PAM	269
— Histoire de samkok (suite). .	Oknha NOU-KAN	274
— Le souffle du désert (suite) . .	M. PHENG-CHRIV	282
— Les trente deux récits du Trône (suite)	M. RAY-BUC	288

NOTES ET CHRONIQUES:

— Distribution des prix à l'Ecole Supérieure de Pâli	Institut Bouddhique	295
— L'incinération du vén. CHEN-TIT, Chef de la pagode de Beng-Rai (Svay-Rieng)	M. NHEM-KHEM	310
— Nomination des nouveaux Chau Adhikars (suite)	Ministère des Cultes . . .	319

Prix d'abonnement annuel (comprenant 12 numéros) 210$00

វិចារណាកថា

យុនបណ្ណានុរក្សប្ប៊ - ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ជ្រៀបជ្រៀង

លោកមុខមានមែនឬទេ ?[1]

លោកមុខ បើនិយាយតាមពុទ្ធសាសនា ថាលោកមុខមានមែនព្រោះមានស្ថានសួគិ, ស្ថាននរក; បើនិយាយតាមមតិនៃអ្នកប្រាជ្ញខាងពុទ្ធសាសនាថា ចាប់តាំងពីពេលផុតអស់ឱ្យល់ដង្ហើមចេញចូល គឺស្លាប់ហៅថា លោកមុខ ។ នានាជាតិក្នុងលោកប្រើនប្រកាន់ជឿថា លោកមុខមានមែន សឹងមានទំនៀមទម្លាប់ប្រព្រឹត្តជាប់មកជាកស្ពុតាងស្រាប់ដូច :

ទំនៀមខ្មែរ, ខ្មែរប្រកាន់ជឿថាអ្នកស្លាប់ហើយត្រូវកើតទៀត ហើយត្រូវកាន់យកវត្ថុផ្សេងៗពីលោកនេះទៅប្រើប្រាស់ក្នុងលោកខាងមុខ ព្រោះតែជំនឿយ៉ាងនេះ ទើបគេយកវត្ថុសម្រាប់ប្រើប្រាស់នោះជាក់កប់ជាមួយនឹងរូបបុគ្គលដែលស្លាប់ហើយ ដូចជាកាលពីឆ្នាំមុន ពួកអ្នកជីកដីរុករកបុរាណវត្ថុក្នុងប្រទេសខ្មែរ គេជីកដីទៅត្រូវចំលើរណ្ណៅខ្មោច, ក្នុងរណ្ណៅនោះគេឃើញមានកាំបិត, ប៉ូវថៅ, ដាវ និងគ្រឿងប្រើប្រាសផ្សេងៗទៀតមានតុ ថាស ចាន ឆ្នាំងជាដើម ។ ម្យ៉ាងទៀត តាមទំនៀមទម្លាប់ខ្មែរបុរាណ, ចំពោះមនុស្សចាស់ជរា កាលបើដឹងខ្លួនថាជិតស្លាប់ហើយប្រើនតែប្រាប់កូនចៅឲ្យរៀបចំគ្រឿងបន្ទុងទុកបុងឲ្យខ្លួនជាមុន បើដល់ខ្លួន

---

[1] ជ្រៀបជ្រៀងតាមប្រវត្តិរបស់នានាជាតិដែលមានសេចក្តីពិស្ទារក្នុងច្បាប់ប្រវត្តិសាស្ត្រសាកល ។

ស្វាប់ហើយ ឲ្យកូនចៅនិមន្តព្រះសង្ឆមកទស់យកទៅ ដោយសំគាល់ថា របស់ទាំងនោះនឹងបានជល់ខ្លួនៗ នឹងប្រើប្រាស់នៅលោកមុខទៀត ។ ចំណែកកូនចៅ កាលដ្រើសយករបស់ដាក់ប្ចុង ប្រើនតែរើសយករបស់ដែលមើ៉ឡធ្ងាប់ប្រើប្រាស់. ធ្ងាប់ស្រឡាញ់ នឹងរបស់ដែលមានជំឡៃជ្លនកាលទិញរបស់ថ្មីៗ ពីផ្សារមកធ្វើជាបន្ទុងតែម្តង, ត្រឿងបន្ទុងនេះ អ្នកខ្ងះនិមន្តព្រះសង្ឆទស់យកទៅកុដិ, អ្នកខ្ងះជីកដីកប់ក្នុងផ្ទូរសពនោះ ប៉ុន្តែមិនមែនមានដាក់ត្រប់តែរណ្តៅទេ ព្រោះរណ្តៅខ្ងះគេដាក់ ខ្ងះគេមិនដាក់ នេះទំនៀមខ្មែរ ។

ទំនៀមបិន, ព្រះរាជាធិរាជប្រទេសបិន កាលមុននឹងទិវង្គតទ្រង់ បង្គាប់ឲ្យសាងម៉ុងទុកជាស្រេប លុះព្រះអង្គទិវង្គតហើយ អាមាត្យមុខមន្ត្រីយកព្រះរាជទ្រព្យដ៏មានជំឡៃទៅដំកល់ទុកថ្ងាយក្នុងម៉ុង មិនតែប៉ុណ្ណោះ ថែមទាំងកប់ស្រីស្នំ ឬខ្ញុំប្រុសស្រីជាទីសព្ងព្រះរាជបូហទ័យទៅក្នុងរណ្តៅទាំងរស់ ដោយតាំងចិត្តថា ឲ្យទៅនៅចាំគាល់បំរើព្រះមហាក្សត្រក្នុងលោកមុខទៀត ។ ឯអ្នកដែលត្រូវគេជីកកប់ទាំងរស់នោះ ក៏សុខចិត្តស្ងាប់ ឥតធុញថប់ ឬឥតគេបង្ខិតបង្ខំចិត្តឡើយ ជ្យិតគេតាំងចិត្តថានឹងតបស្នងព្រះគេជៈព្រះគុណនៃព្រះមហាក្សត្ររបស់ខ្លួន ដែលរាប់ថាជាការបានបុណ្ឆយ៉ាងប្រើនក្រៃលែង ។

មិនតែប៉ុណ្ណោះ ទំនៀមបិន មុននឹងកប់សពរបស់គេ បើជាអ្នកមានធនធានស្តុកស្តម្ភ គេរៀបចំតែងតួសពជូចជាមន្ត្រី ធ្វើម៉ុងល្អសម្បើមណាស់ យកក្រដាសធ្វើជាប្រាក់សន្ទឹក, ជារូបមនុស្សបំរើ, ជារូបផ្ទះ,

ជារូបយានពាហនៈ នឹងជាគ្រឿងប្រើប្រាស់ផ្សេងៗ ទៀត ប៉ុន្តែ រត្ទុតាំង
នេះមិនកប់ជាមួយនឹងសពទេ គេជុតក្ងើងឲ្យធេះតាំងអស់ ដោយតាំងចិត្ត
ទុទ្ធិសបញ្ជូនទៅឲ្យអ្នកស្លាប់ទៅលោកមុខនោះ ។

ទំនៀមជប៉ុន, សម័យបុរាណ ជប៉ុនធ្វើព្រះរាជពិធីព្រះបរមសព
នៃព្រះរាជាធិរាជជប៉ុន ដូចជាព្រះរាជាធិរាជចិនដែរ ។ ក្នុងរជ្ជកាលមួយ
នោះ មានមន្ត្រីជាន់ខ្ពស់ម្នាក់ជាតិជប៉ុន បានសុខចិត្តឲ្យគេកប់ខ្លួនតាំងរស់
ទៅក្នុងដី ដើម្បីតាមហែព្រះមហាក្សត្ររបស់ខ្លួន ដែលស្តេចយាងទៅ
លោកមុខ នៅថ្ងៃដែលគេធ្វើព្រះរាជពិធីបញ្ចុះព្រះបរមសពនោះ ។
តែឥឡូវនេះ មានបញ្ញត្តិហាមមិនឲ្យកប់មនុស្សតាំងរស់ទៅតាមសព ។

ទំនៀមអ៊ីហ្សិប, ប្រជាជនជាតិអ៊ីហ្សិបសម័យបុរាណ កប់សព
ដូចចិននឹងជប៉ុនដែរ ប៉ុន្តែគេចេះរក្សាសពទុកឲ្យបានយូរអង្វែង មិនឲ្យ
ស្អុយរលួយ (១) ដោយគេជាក់ថ្នាំរក្សាសព ហើយគេជំកល់សពទុកក្នុងទី
កន្ទែងដ៏ល្អល្អះមាំមួនផង គេយកចំណីអាហារនឹងគ្រឿងប្រើប្រាស់ផ្សេងៗ
ទៅជំកល់ទុកក្នុងទីជំកល់សពផង ព្រោះគេជឿថា "មនុស្សស្លាប់ហើយ
វិញ្ញាណនឹងត្រឡប់មកចូលកុងរាងកាយដើមវិញទៀត" ព្រោះហេតុនោះ
បានជាគេចាត់ការធ្វើទីជំកល់សពរបស់ខ្លួនទុកជាមុន តាំងពីនៅមានជីវិត
នៅឡើយ ។

---

១ នៅប្រទេសអ៊ីហ្សិប មានជាងស៊ីឈ្នួលកប់សពប្រើនណាស់ ។

ទំនៀមអ្នកកាន់សាសនាគ្រិស្ត និងសាសនាអិស្លាម, ជន
កាន់សាសនាទាំងពីរនេះក៏កប់សពជូចជាតិចិន, ជប៉ុន និងអ៊ីហ្សុ៊ីបដែរ ។
លទ្ធិសាសនាទាំងពីរនេះ យល់ឃើញស្របគ្នាថា កាលដល់ "ថ្ងៃកាត់
សេចក្ដី ឬថ្ងៃតពីនោះមកទៀត លោកនៃមនុស្សយើងនេះនឹងមិនមាន
ទៀតទេ មនុស្សស្លាប់ហើយនឹងរស់ឡើងវិញទាំងអស់គ្នា អ្នកធ្វើល្អបាន
ឡើងស្ថានសួគិ អ្នកធ្វើអាក្រក់ចុះនរក" ។ ប៉ុន្តែ ខាងលទ្ធិសាសនា
អ៊ីស្លាមយល់ខុសពីសាសនាគ្រិស្តខ្លះថា "មនុស្សស្លាប់ហើយវិញ្ញាណ
ត្រូវទៅរាយការណ៍របស់ខ្លួនចំពោះព្រះម្ចាស់សួគិ ហើយត្រឡប់មកនៅ
និងរាងកាយដើមវិញ រង់ចាំថ្ងៃកាត់សេចក្ដី" ។ ចំណែកសាសនាគ្រិស្ត
ដៀថា 'វិញ្ញាណរបស់អ្នកស្លាប់ហើយ ត្រូវទៅរក ត្រូវងជម្រះ រង់ចាំ
ថ្ងៃកាត់សេចក្ដីដែរ" ។ ហេតុនេះ បានជាជាតិបារាំងមិនចងរឹតរួតសព
ជូចខ្មែរយើងទេ ជ្យិតគេមិនទុកសពឲ្យយូរហួសពី ៤៨ ម៉ោងឡើយ ។

ទំនៀមហិណ្ឌូ, ប្រជាជនជាតិហិណ្ឌូសម័យបុរាណ ធ្វើពិធីដុត-
សព ។ ជនជាតិនេះធ្វើពិធីដុតសពវិសេសប្លែកជាងជាតិឯទៀតត្រង់កិច្ច
មួយគឺក្នុងវេលាដែលគេដុតសពប្ដី ប្រពន្ធត្រូវតាក់តែងខ្លួនឲ ល្អស្រស់
ដោយគ្រឿងមង្គលការ ហើយចូលទៅអង្គុយនបប្ដីលើដើងថ្ការ ឲ្យគេដុត
ខ្លួនទាំងរស់ ដោយតាំងចិត្តថា "នឹងទៅរៀបមង្គលការជាមួយនឹងប្ដីនៅ
លោកមុខម្តងទៀត" ។ ចំណែកប្ដីវិញ បើប្រពន្ធស្លាប់ហើយមិនត្រូវដុត-
ខ្លួនឲ្យស្លាប់ទៅតាមប្រពន្ធទេ សុខចិត្តឲ្យប្រពន្ធស្លាប់ទៅតែម្នាក់ឯងចុះ ។

ជឿងប្រពន្ធដុតខ្លួនឲ្យស្លាប់ទៅតាមប្តី (1)

កាលពីក្នុងឆ្នាំ ព.ស. ៦៤៨០ នាងរូបាតានី ជាតិឥណ្ឌា កាលប្តីស្លាប់ហើយ ត្រូពេឲ្យប្រចាំតំបន់មកពិនិត្យសពនឹងប្រកាសមរណកាពក្នុងវេលាល្ងាចនៃថ្ងៃនោះ ។ នាងរូបាតានីក៏ស្នើបំណងរបស់នាងឲ្យពពួកញាតិមិត្រតាំងឡាយបានជ្រាប ព្រមតាំងបង្អង់ការឈាបនកិច្ចទុកជល់ថ្ងៃស្អែកឡើង ដើម្បីនាងនឹងមានឧកាសធ្វើកិច្ចដែលគួរធ្វើរបស់នាង ។ ត្រានោះ ពួកអ្នកដែលមកប្រជុំក្នុងបុណ្យសពនោះ តាំងប្រុសតាំងស្រី តាំងអ្នកជិតតាំងអ្នកឆ្ងាយ រហូតជល់ទៅទ្រុំប្រុសទ្រុំស្រីរបស់នាងក៏ចូលទៅអង្ករកហាមឃាត់នាង មិនឲ្យធ្វើកម្មណាមួយដែលជាការល្មើសច្បាប់អង់គ្លេស ដែលបញ្ញត្តលុបលាងមិនឲ្យប្រពន្ធដុតខ្លួនតាំងរស់ទៅតាមសពប្តីជាដាច់ខាត ។ ប៉ុន្តែនាងមេម៉ាយធ្វើយតបតាមបទបញ្ញត្តិដែលមានក្នុងគម្ពីរហិណ្ឌូថា "មុខងាររបស់កនិយា គឺនៅត្រង់មិនព្រមឃ្លាតចាកស្វាមីក្នុងយាមរស់ប្ដក្នុងយាមស្លាប់" ។ ពួកញាតិមិត្រឆ្ងជូច្នោះក៏មិនអាចហាមឃាត់នាងបាន ប៉ុន្តែបានស្នើរឿងនោះឲ្យរាជការជ្រាបសព្វគ្រប់ ។

ត្រានោះ មានយោគីកន្ធាត់ម្នាក់នៅក្នុងស្រុកនោះ ជាអ្នកបំភ្លឺទំនៀមទម្លាប់នៃឈាបនកិច្ចក្នុងឥណ្ឌាថា គេប្រើនតែធ្វើឈាបនកិច្ចក្នុងវេលាពីរបីម៉ោងជាខាងក្រោយពេលស្លាប់ហើយ រឿរតែអ្នកស្លាប់ក្នុងវេលាល្ងាចដែលមិនអាចនឹងចាត់ការឲ្យទាន់ពេលបាន ។ ការមរណកាពនៃប្តីនាង

---

1 ស្រង់ចាកប្រវត្តិរបស់ប្រជាជាតិឥណ្ឌា ក្នុងច្បាប់ប្រវត្តិសស្ត្រសាកល ។

រូបាតានីនៅវេលារដូវរដាខ្ចាំង នាងទើបបង្អង់ការឈាបនកិច្ចឲ្យយឺតយូរ
បន្តិច ដើម្បីប្រុងប្រៀបការដែលនាងត្រូវធ្វើឲ្យរួចជាមុនសិន ។ លុះ
វេលាព្រឹកឡើងអរុណជិតរះហើយ នាងរូបាតានីក៏ចាត់ចែងបំពាក់គ្រឿង
អមរណ៍ឲ្យប្តីយ៉ាងផ្ចិតផ្ចង់តាមទំនៀមស្រុក រួចហើយបែរមកតាក់តែង
ខ្លួនរបស់នាងវិញ គឺនាងស្លៀកពាក់គ្រឿងវិវាហមង្គល ហើយសៀត
ផ្តាឈើនឹងពាក់មាសពេជ្រគ្រឿងប្រដាប់ដទៃទៀត នាងយកជាតហិង្គុល
សម្បុរក្រហមស្រស់មកដៅត្រង់ថ្ពាសរបស់នាង ជាសញ្ញានៃកិរិយាភាព
ក្នុងត្រាចុងក្រោយបំផុត ស្រេចហើយនាងបើកទ្វារចេញទៅ មានកិរិយា
ឬកពាជាសុខតាមធម្មតា ហាក់ដូចជានាងក្រមុដែលកំពុងតែបែរមុខទៅ
រកមធុមាស(១) ជាមួយប្តីរបស់នាង មើលទៅដូចជាមិនមែនស្រីមេម៉ាយ
ដែលប្រុងនឹងដុតខ្លួនឲ្យស្លាប់ទៅតាមប្តីទេ ។ នៅវេលាដែលនាងចេញ
មកក្រៅធ្លះ មានស្រីជាញាតិមិត្រមួយពួកបានគ្រឿនស្មារតីឲ្យនាងត្រិះរិះ
ជាថ្មីឲ្យស្រួលបួលសិន ក្នុងការដែលនាងធ្វើល្មើសច្បាប់លោកដូច្នោះ
ប៉ុន្តែ ពាក្យធ្វើយរបស់នាង ធ្វើឲ្យអ្នកទាំងនោះស្ងាត់មាត់ប្រៀបដូចគេចុក
ថា " ពួកអ្នករាល់គ្នាដែលមកហាមឃាត់ខ្ញុំដូច្នេះ នឹងត្រូវបណ្តាសា
ទេពតាឲ្យបាក់ធ្មឹងធ្មេងរហូតទៅ ព្រោះការដែលខ្ញុំធ្វើពិធីនេះ គឺខ្ញុំធ្វើ
ដោយសេចក្តីស្មោះត្រង់នឹងស្វាមីរបស់ខ្ញុំ នឹងចំពោះទេពតាដែលជាទី
គោរពរបស់ខ្ញុំ " ។

---

១ គឺខែដែលរៀបមង្គលការ ជាខែមានឧជារសផ្អែមឈ្ងុយឆ្ងាញ់ពិសាដូចទឹកឃ្មុំថ្មី ។

ខណៈនោះ គេចាប់សែងគ្រែសពប្តីរបស់នាងចេញមកដាក់នៅ
ធរណីទ្វារអស់ពេល ៦ ឬ ៥ នាទី ដើម្បីទទួលទឹកពរបស់អ្នកបួស ដែល
ជាពិធីដំបូង ។ គ្រានោះ នាងរូបាតានីបានយកជាយសំពត់វិវាហមង្គល
របស់នាងទៅចងភ្ជាប់នឹងគ្រែជាក់សពប្តី ដើម្បីជាសញ្ញាក្នុងគ្រាចុងបំផុត
ថា "នាងជាកវិយាពិត មិនមែនជាស្រីមេម៉ាយទេ" ។ កាលអ្នកបួសឲ្យ
ពរទឹកចប់ហើយ នាងក៏ដើរបំបាំងខ្លួនទៅក្នុងពួកនិករជន លុះទៅដល់ទី
ផុតសពហើយ នាងរូបាតានីក៏ទៅពួនលាក់ខ្លួនក្បែរដើងថ្ពរ ។ អ្នកបួស
ក៏មកសូត្រមន្តឲ្យពរម្តងទៀត លុះចប់ហើយ គេក៏លើកសពជាក់ទៅលើ
ដើងថ្ពរ ។ គ្រឿងតូរ្យតន្ត្រីក៏ប្រគំឡើងលាន់ទ្រហឹងអឹងកងព្រមគ្នា ។
រៀលានោះ ព្រះក្វើងធ៏ធេះសន្ទោឡើង ។ នាងរូបាតានីបានលបលាបប្រេង
ជោកខ្លួនទាំងមូល ហើយក៏ស្ទុះចូលទៅឧបប្តីក្នុងគំនរក្វើងមួយរំពេច ។
សេចក្តីនេះជ្រាបទៅដល់ពួកកងក្រវែល ។ បីនាក់បានរត់ចូលមកការពារ
ប៉ុន្តែការពារមិនឈ្នះ ព្រោះរៀលានោះមានស្រី ៩ នាក់ដែលជាញាតិមិត្ត
របស់នាងបានរាំងរាមិនឲ្យពួកកងក្រវែលចូលចុះ ។ ពេលនោះ គេព្ធសូរ
សំឡេងនាងស្រែកធ្វេក ។ ដោយអំណាចត្រូវកំដៅក្វើងយ៉ាងក្តៅខ្លាំង
ដែលនាងមិនអាចនឹងទ្រាំបាន ហើយក៏បាត់ឈឹងសូន្យទៅវិញ ព្ធតែសូរ
សន្ធឹកព្រះក្វើងធេះគឹក ។ ឡើង ។ អ្នកបួសក៏តាំងសូត្រធមិម្តងទៀតជាការ
បង្ហើយកិច្ច ។ ចំណែកគ្រហស្ថក៏ស្រែកសូត្រឲ្យសពួសាធុការពរព្រម
គ្នាឡើង ។ រៀលានោះ វិញ្ញាណរបស់នាងរូបាតានី ក៏រលត់បាត់ឈឹងសូន្យ

ទៅដោយប្រការដូច្នេះ ។ ពិធីដែលប្រពន្ធដុតខ្លួនទាំងរស់ទៅតាមសពប្តីនេះ ជាតិឥណ្ឌៀបញ្ញត្តិហៅថា "លទ្ធិកម្មសុត្តី" ។

ប្រជាជនជាតិហិណ្ឌូដៀថា "មនុស្សស្លាប់ហើយ វិញ្ញាណចេញពីរាងកាយចាស់ ទៅចូលនៅក្នុងរាងកាយថ្មីទៀត វិលស្លាប់វិលកើតនៅក្នុងតពផ្សង ។ ទាល់តែដល់វិញ្ញាណស្អាតបរិសុទ្ធហើយ ទើបចូលទៅនៅរួមជាមួយនឹងព្រះព្រហ្មលើស្ថានសួគិ" ។

ប្រពៃណីរបស់ជនជាតិខ្មែរ, លាវ នឹង ថៃ

ជនជាតិទាំង ៣ នេះ និយមការដុតសពជូចជាតិហិណ្ឌូដែរ មានខ្មែរយើងខ្លះកប់សពក្នុងដីជាបណ្តោះអាសន្ន ដោយតាំងចិត្តថាថ្ងៃ ខែ ឆ្នាំណាស្រួល នឹងតាស់សពឡើងដុត ។ តាមទំនៀមទម្លាប់របស់ជនជាតិខ្មែរ : កាលមនុស្សស្លាប់ហើយ មុនដំបូងគេលាងជម្រះសពឲ្យស្អាត រួចស្លៀកបំពាក់សពនោះដោយសំពត់អាវយ៉ាងល្អថ្មីៗ ហើយគេដាក់ប្រាក់ ១ កាក់ក្នុងមាត់សពផង ដោយខ្លាចក្រែងសពនោះគ្មានសំពត់អាវស្លៀកពាក់ នឹងគ្មានប្រាក់ចាយក្នុងលោកមុខទៀត សូម្បីចាន, ឆ្នាំង, ដើងក្រាន, អង្ក្រ, ត្រី គេក៏ដាក់ហ្នុងឲ្យសពយកទៅបរិភោគនៅលោកមុខដែរ ។ បើជាអ្នកមានធនធានច្រើន កាលគេដុតសពសុះហើយ គេរើសយកឆ្អឹងធាតុទៅធ្វើពិធីដុតក្នុងទីដទៃម្តងទៀត ។ កិច្ចធ្វើបុណ្យសពនៅប្រទេសខ្មែរមានច្រើនផ្នែកណាស់ គឺគេធ្វើតាមទំនៀមទម្លាប់ស្រុកខ្មែរខ្លះ តាមគម្ពីរសាសនាព្រះពុទ្ធខ្លះ តាមសាសនា

ព្រាហ្មណ៍ទ្ងះ ។ កិច្ចសពនេះមានរបៀបកំបុិកកំបុ៉កច្រើនណាស់ ទ្ងុំរៀបរាប់ក្នុងទីនេះមិនល្មមវេលាទេ ។

ខាងសាសនាព្រាហ្មណ៍ប្រកាន់ថា "វិញ្ញាណជាអត្តា" ។ ឯខាងព្រះពុទ្ធសាសនាប្រកាន់ថា "វិញ្ញាណជាអនត្តា" ព្រោះមានព្រះពុទ្ធដីកាថា "របស់ផ្សង ៗ នៃគ្រឿងរថ បើរួបរួមចូលគ្នា ទើបយើងហៅថា "រថ" បាន បើគេដោះរបស់អស់នោះឲ្យដាច់ចេញដោយឡែកពីគ្នាហើយ យើងនឹងហៅរបស់ផ្សង ៗ នោះថា "រថ" មិនបានទេ ។ រថ ប្រៀបដូចរូបមនុស្សទាំងមូល ដែលមានរាងកាយនឹងចិត្តថ្វើមនៅរួបរួមគ្នា សន្ធតឈ្មោះផ្សង ៗ គ្នាថា ដៃ, ជើង, ក្បាលជាដើម ដល់វេលាស្លាប់ហើយ អវយវៈទាំងអស់មានដៃ, ជើង, ក្បាលជាដើមនោះ ក៏បែកខ្ចែកចេញពីគ្នាអស់ មិននៅរួមគ្នាដូចកាលមានជីវិតឡើយ ។ ដូច្នេះ ពុទ្ធសាសនាក៏បានយល់ឃើញថា "លោកមុខមានមែន" ព្រោះមនុស្សគ្រប់រូបទៀងតែស្លាប់ ៗ ហើយទៀងតែកើតទៀត, គ្រង់ការស្លាប់ហើយកើតទៀតនោះ ឈ្មោះថា លោកមុខ ។ ជួនកាលគេហៅថា "ភពមុខ" ត្រូវនឹងពាក្យជាគូគ្នាថា "លោកនេះ ជាគូនឹងលោកមុខ, ភពនេះ ជាគូនឹងភពមុខ, ជាតិនេះ ជាគូនឹងជាតិមុខ" ។ ពួកបុថុជ្ជនទាំងអស់ទៀងតែមានលោកមុខ ឬ ភពមុខ ។ មានតែពួកព្រះអរហន្ត មួយពួកទេ ដែលគ្មានលោកមុខ ជ្យិតលោកចូលនិព្វានហើយ ។

ប្រជាជនជាតិរុស្សីសម័យបច្ចុប្បន្ននេះ គេប្រដៅពួកអ្នកស្រុកគេថា

"យើងធ្វើការក្នុងលោកនេះ យើងត្រូវតែប្រាថ្នាយកផលប្រយោជន៍ឲ្យ
បានក្នុងលោកនេះ ឲ្យខាន់ចិត្ត កុំបង្អង់ចាំយកផលក្នុងលោកមុខ" ។ ការ
យល់ឃើញរបស់ជាតិរុស្ស៊ីនេះ បើទុកជាខុសផ្ទុយនឹងសាសនានានា
ក្នុងលោកនេះ ក៏នៅតែមានមនុស្សភាគច្រើនយល់ស្របតាមមតិនៃប្រជា
ជាតិរុស្ស៊ីដែរ ព្រោះលទ្ធិសាសនានានាក៏បានប្រដៅថា "កើតជាមនុស្ស
ត្រូវតែមានមានៈព្យាយាមធ្វើការ ខំធ្វើការឲ្យខាល់តែបានផលនៅនា
លោកិយឲ្យខាន់ក្អែក ហើយធ្វើតែការសុចរិតល្អផង ដើម្បីឲ្យបានផល
ទៅបរលោក គឺសាសនាខ្លះប្រដៅថា អ្នកធ្វើល្អនឹងបានឡើងទៅនៅជា
មួយព្រះព្រហ្មឯស្ថានព្រហ្ម, សាសនាព្រះពុទ្ធ ប្រដៅថា អ្នកធ្វើល្អនឹង
បានទៅនៅរួមជាមួយព្រះអរហន្ត (និព្វាន) ។ ហេតុនេះមនុស្សក្នុង
លោកភាគច្រើនប្រកាន់ជឿថា លោកមុខមានមែន នេះជាការដោះស្រាយ
ប្រស្នាថា លោកមុខមានមែនឬទេ ។

ផ្នែកសាសនា

ឃ្វោកលិច អំបែងអណ្តែត

ព្រះទេពសត្តា កិម-ត្ថ

៤ៀប៤ៀង

ពាក្យថា "ឃ្វោកលិច អំបែងអណ្តែត" នេះ ជាពាក្យដែលយើងធ្លាប់និយាយរត់មាត់មកហើយ មិនមែនជាពាក្យទំនើបទើបនឹងមានថ្មីទេ ។ ពាក្យនេះ ជាសុភាសិតបុរាណ កើតមានតាំងពីជាន់ពុទ្ធសម័យ រវាង ២៥ សតវត្សមកហើយ ដែលព្រះសម្ពុទ្ធជាម្ចាស់នៃយើងទ្រង់ព្យាករដោយសេចក្តីទបមាទបមេយ្យ ចំពោះព្រះបាទបសេនទិកោសលដែលក្រាបបង្គំទូលសួរ ។

យើងនឹងលើកពាក្យនេះ មកអត្ថាធិប្បាយឲ្យត្រូវតាមគោលបំណងនៃសុភាសិតនោះ ដើម្បីឲ្យអស់លោកអ្នកអាន គ្រាន់នឹងបានជាគតិព្រោះអស់លោកអ្នកខ្ជះចេះថា "ឃ្វោកលិច អំបែងអណ្តែត" ដែរ ប៉ុន្តែមិនសូវយល់សេចក្តីជាក់លាក់ ឬក៏យល់ឃ្វាងពីគោលបំណងក្នុងសុភាសិតនេះ ក៏សឹងមាន ។ ដូចត្រង់ពាក្យ "ឃ្វោកលិច" គេច្រើនយល់ថា អ្នកណាមួយកើតក្នុងត្រកូលខ្ពង់ខ្ពស់ ដែលគួរតែទទួលហានៈ ជាអ្នកមានយសសក្តិមានទ្រព្យធន ជាហេតុធ្វើរង្សត្រកូលខ្លួនឲ្យខ្ពង់ខ្ពស់តទៅទៀត តែមិនដូច្នោះ ត្រឡប់ជាលិចបុះក្នុងហីនភាពជាអ្នកគ្មាន

យសសក្តិវិនាសទ្រព្យសម្បត្តិធ្លាក់ខ្ជិនជាមនុស្សក្រីក្រអនាថា គេប្រដូចមនុស្សនោះទៅនឹងឃ្លោកដែលជាវត្ថុស្រាលគ្ជរតែអណ្តែតលើទឹក តែបែរជាលិចក្នុងទឹកទៅវិញ ។ ត្រង់ពាក្យ "អំបែងអណ្តែត" គេយល់ថាអ្នកណាមួយកើតក្នុងត្រកូលថោកទាបខ្សត់ខ្សោយ គ្ជរនឹងលិចចុះទៅក្នុងហានៈទាបថោកដរាបទៅ តែបែរជាអណ្តែតមានហានៈខ្ពង់ខ្ពស់មានយស-សក្តិវិថ្ងថ្ងាគេប្រដូចមនុស្សនោះទៅនឹងអំបែង ដែលជាវត្ថុមានទម្ងន់គ្ជរតែលិចចុះទៅក្នុងទឹក តែត្រឡប់ជាអណ្តែតទឹកវិញ ។ សេចក្តីយល់បែបនេះមិនត្រូវតាមពុទ្ធដីកាដែលសំដែងទេ ។ ហេតុនេះ យើងសូមធ្វើសេចក្តីបរិយាយសុភាសិតនេះ តាមគម្ពីរជាតកឯកនិបាតដែលមានសេចក្តីជ្រាលជ្រៅឲ្យទៅជារាក់ងាយស្តាប់ តាមលំដាប់ហូរហែដូចតទៅនេះ ៖

ពាក្យថា "ឃ្លោកលិច អំបែងអណ្តែត" នេះ បើគេសំឡឹងមើលនូវរូបវត្ថុនេះដោយមំសចក្ខុ យើញថាផ្ទុយពីពាក្យនេះស្រឡះ ។ ធម្មតាសំបកឃ្លោកដែលក្រៀមស្ងួតស្រាលស្ងើក បើគេយកទៅបោះក្នុងទឹក ពិតជាអណ្តែត ចុះហេតុអ្វីពាក្យនេះបែរជាថា "ឃ្លោកលិច" ទៅវិញ? ធម្មតាអំបែងមានអំបែងចានឬអំបែងឬជាដើម ជាធម្មជាតធ្ងន់ បើគេយកទៅបោះក្នុងទឹក ពិតជាលិចចុះបាត់ទៅក្នុងទឹកមួយរំពេច ចុះហេតុអ្វីពាក្យនេះបែរជាថា "អំបែងអណ្តែត" ទៅវិញ? ហេតុនេះពាក្យទាំងពីរម៉ាត់នេះ ជាសេចក្តីប្រៀប ជាពាក្យប្រដូចដោយពិត ។

យើងសូមទាញយកពាក្យខាងឧបមេយ្យមកអធិប្បាយផ្ជូរគ្នានឹងពាក្យឧបមាខាងលើនោះឲ្យឃើញស្របគ្នាថា: ក្នុងលោកទាំងមូល តាមតែ

ប្រទេសណាជាតិណាក៏ដោយ តែងតែមានមនុស្សជាន់ទាប, ជាន់ខ្ពស់ គឺមនុស្សល្ងង់, មនុស្សចេះ, មនុស្សទុច្ចរិត, មនុស្សសុចរិត, មនុស្ស អាក្រក់, មនុស្សល្អ, មនុស្សពាល, មនុស្សបណ្ឌិត, នៅប្រចូក ប្រចល់លាយឡំជាមួយគ្នាជាដរាប គ្រាន់តែមានចំនួនតិចនឹងច្រើនជាងគ្នា ប៉ុណ្ណោះ ។ មនុស្សទាំងប៉ុន្មានប្រកេទដូចថាមកនេះ បើតាមប្រទេស ដែលកាន់ពុទ្ធសាសនា ចែកជាពីរផ្នែកគឺ គ្រហស្ថ ១ ផ្នែក បព្ជិត ១ ផ្នែក ។ មនុស្សទាំងពីរផ្នែកនេះមានវត្ថុបំណងស្របគ្នាតែបែបមួយ គឺចង់បានសុខ, ចង់រស់នៅយឺនយូរចង់បានហានៈដ៏ខ្ពង់ខ្ពស់ ។ ល ។ វត្ថុបំណងទាំងនេះឯង ដែលដឹកនាំមនុស្សនីមួយ ៗ ទាំងធំទាំងតូចឲ្យមានជំណើរទំស្ទុះស្ទាស្ទែង រកតាមផ្លូវទឹកផ្លូវគោកជានិច្ច ។

នៅក្នុងយុគខ្ងះ បើមនុស្សលោកវិលប្រែប្រួលហើយ សង្ខារលោក ក៏វិលប្រែប្រួលទៅតាមដែរ ឬថា មនុស្សលោកវិលទៅតាមសង្ខារលោក ក៏ថាបាន សង្ខារលោកវិលទៅតាមមនុស្សលោក ក៏ថាបាន ។ សូមទាញ ឧទាហរណ៍មួយយ៉ាងឯាយ មកពិចារណាមើលចុះ ដូចគ្រឹងសម្ងៀក បំពាក់មានខោ អាវជាដើម ដែលមនុស្សប្រើប្រាស់ សម័យខ្ងះ ដើង ខោធំទូលាយស្រុងចុះក្រោម, សម័យខ្ងះដើងខោតូចចង្អៀតខើចឡើងលើ; ចំណែកខាងអាវសោតទៀត សម័យខ្ងះគេប្រើឡេវតិច, សម័យខ្ងះគេ ប្រើឡេវច្រើន គឺវិលទៅតាមលោកនិយម ។ ន័យឯទៀតក្រៅពីនេះ គប្បីលើកយកមកពិចារណាផងចុះ តើវិនិច្ឆ័យថា មនុស្សវិលទៅតាម សង្ខារលោក ឬថាសង្ខារលោកវិលទៅតាមមនុស្ស? យើងអាចសន្និដ្ឋាន

ជានថា អផ្សាស្រ័យគឺចិត្តគំនិត ព្រមទាំងការយល់របស់មនុស្សប្រព្រឹត្ត
ទៅបែបណា សង្ខារលោកក៏ប្រព្រឹត្តទៅបែបនោះដែរ ។ ព្រោះហេតុនោះ
ក្នុងសម័យណា អំពើទុច្ចរិតរបស់មនុស្សមានកម្ចាំងខ្ចាំងឡើង, ក្នុង
សម័យនោះ អំពើទុច្ចរិតនោះឯង អាចទៅបំបែរបំបត់សង្ខារលោកដែល
ជារបស់គ្មានចិត្ត គ្មានវិញ្ញាណ ឲ្យទៅជារបស់ហាក់ដូចជាមានចិត្តមាន
វិញ្ញាណក្ខាហានកាចសាហាវ អាចទៅប្រៀតប្រៀនមនុស្សឲ្យទទួលទុក្ខវេ-
ទនាឬទៅប្រៀតប្រៀនសង្ខារលោកដូចគ្នា ឲ្យដល់នូវសេចក្តីវិនាសអន្តរាយ
ដោយសារកម្ចាំងរបស់ខ្លួន នឹងចាំបាច់និយាយថ្ងីដល់មនុស្សផងគ្នា ។ ម្ជុយ
ទៀត ក្នុងសម័យណា អំពើសុចរិតរបស់មនុស្សមានកម្ចាំងខ្ចាំងក្ខាឡើង,
ក្នុងសម័យនោះ អំពើសុចរិតនោះឯង អាចទៅបំបែរបំបត់លៃលកសង្ខារ
លោកដែលគ្មានចិត្ត គ្មានវិញ្ញាណ ឲ្យទៅជារបស់ហាក់ដូចជាមានចិត្ត
មានវិញ្ញាណឲ្យទៅជាស្ងួតបូត ជារបស់មានប្រយោជន៍ ឲ្យសេចក្តីសុខ
ដល់មនុស្សទួទៅ ដោយសារកម្ចាំងរបស់ខ្លួន ។

មនុស្សទុច្ចរិត ច្រើនមានអផ្សាស្រ័យត្រូវគ្នានឹងមនុស្សទុច្ចរិតដូចគ្នា
ឯមនុស្សសុចរិត ក៏ច្រើនមានអផ្សាស្រ័យត្រូវគ្នានឹងមនុស្សសុចរិតដូចគ្នា,
ដែរ ។ ខាងពុទ្ធសាសនាចាត់មនុស្សពាលប្រព្រឹត្តទុច្ចរិតថាជាមនុស្ស
អសប្ឋុរសលាមកអាក្រក់ថោកទាប ជាមនុស្សអស់តម្លៃស្រាលស្ងើកដូច
សំបកឃ្ងោក; មនុស្សសំបកឃ្ងោកនេះ ត្លូវតែមានទោសទុក្ខជាប់គុក ត្រូវ
ទណ្ឌកម្មតាមយថាកម្មរបស់ខ្លួន តែមិនដូច្នោះ ត្រឲ្យប់ជាគេលើកតំកើង
ឲ្យមានយសស័ក្តិ ជាមេបាគ្រប់គ្រងត្រួតត្រាកុងក្រុម ក្នុងសង្គមឬក៏ក្នុង

តំណែងជាន់ខ្ពស់ ។ មួយទៀត សំដីរបស់មនុស្សសំបកឃ្វោក
នោះឯង កាលបើហានិយាយអ្វីទៅរកអ្នកធំអ្នកតូចហើយ សំដីនោះ
ស្រាលស្ទើកគ្មានខ្វឹមសារអ្វីសោះ គួរណាស់តែអណ្តែតរសាត់ចាត់ទៅ
តែមិនជូច្នោះ សំដីនោះបែរទៅជាលិចចុះទៅប្រតិស្ឋានដិតជក់ជាប់នៅជា
និច្ចក្នុងចិត្តគំនិតរបស់អ្នកធំអ្នកតូច ជាសំដីត្រូវគេជឿស្តាប់ធ្វើតាមទៅវិញ
ជូចគ្នានឹងសំបកឃ្វោកជារបស់ស្រាលសោះ គួរតែអណ្តែតរសាត់ចាត់
ទៅ មិនជូច្នោះ បែរទៅជាលិចចុះក្នុងទឹកវិញក៏ជូច្នោះដែរ ។

ចំណែកខាង មនុស្សបណ្ឌិតប្រព្រឹត្តសុចរិតមានសន្តានចិត្តសប្ប្សរស
ចេះដឹងល្អ ទុកជាមនុស្សមានជំវិញ ឬមានទម្ងន់ជូចអំបែងថ្មពេជ្ជ ។
មនុស្សថ្មពេជ្ជនេះ គួរតែគេលើកតំកើងក្នុងហានៈខ្ពង់ខ្ពស់ មានតំណែង
រជ្ជមន្ត្រី តំណែងតុលាការវិនិច្ឆ័យកាត់ក្តីជាដើម តែបែរទៅជាអាប់ទន
ជ្ជាក់ខ្ជូនចុះទៅកាន់ហានៈដ៏ថោកទាប ចាត់ក្តេ៍ឈ្មោះ គ្មានយសសក្តិ
ទៅជាអាយ័ត្តរបស់មនុស្សសំបកឃ្វោកទៅវិញ មួយទៀតមនុស្សថ្មពេជ្ជ
បើហានិយាយពីអ្វីទៅរកអ្នកធំអ្នកតូច សំដីនោះសូម្បីពិតមានប្រយោជន៍
មានខ្វឹមសារ មានទម្ងន់ធ្ងន់ជូចអំបែងថ្ម គួរតែលិចចុះប្រតិស្ឋានដិត
ជក់ជាប់នៅ ក្នុងចិត្តគំនិតរបស់អ្នកធំអ្នកតូច តែមិនជូច្នោះ ទៅជាសំដី
ស្រាលស្ទើកអណ្តែតរសាត់ជាត់ចាត់ទៅ គេមិនអើពើជឿស្តាប់ធ្វើតាម
ទៅវិញ ជូចគ្នានឹងអំបែងថ្មជារបស់ធ្ងន់ គួរតែលិចចុះទៅក្នុងទឹក មិន
ជូច្នោះ បែរជាអណ្តែតរសាត់ទៅតាមទឹកវិញជូច្នោះឯង ។

ពាក្យថា "ឃ្វោកលិច អំបែងអណ្តែត" នេះ ជាសេចក្តីឧបមា

ជាព្រះផ្ទូលទៅតាមស្ថានការណ៍លោកប្ដប្រទេស ដែលមានការវិបត្តិ
ប្រែប្រួល ។ សេចក្តីនេះមានពិតក្នុងគម្ពីរជាតកឯកនិបាត, យើងសូម
ទាញយកវ្យឹងនោះ មកវ្យបវ្យងទុកក្នុងទីនេះថែមទៀត ដើម្បីបញ្ជាក់
ឲ្យយើញជាតួយ៉ាង ៖

ក្នុងសម័យ ដែលព្រះសព្វញ្ញុពុទ្ធជាម្ចាស់នៃយើង បានត្រាស់
ឡើងក្នុងលោកហើយ, ត្រានោះឯង មានព្រះមហាក្សត្រមួយព្រះអង្ត
ព្រះនាម បសេនទិកោសល ទ្រង់ផ្ទំលក់ស្ពប់ស្ពល់ក្នុងរាត្រីមួយ, ទ្រង់
យើញសុបិននិមិត្តមួយចំឡែកអស្ចារ្យ ដែលព្រះអង្គមិនធ្លាប់ដែលប្រទះ
យើញម្តងណាសោះឡើយ គឺទ្រង់យើញសំបកយ្លោកស្ងួតស្រាលស្លើក
លិចចុះស្រឹមបាត់ទៅក្នុងទឹក, មួយទៀត ទ្រង់យើញដុំថ្មតាន់ធំ ៗ ប៉ុនទូក
ប៉ុនផ្ទះ អណ្តែតធ្លាលទើរនៅលើទឹក, លុះដល់វេលាព្រឹក ទ្រង់តើនឡើង
ហើយ មិនអាចវិនិច្ឆ័យសុបិននិមិត្តនោះដោយព្រះអង្គឯងបានឡើយ,
ទ្រង់រ្យបព្រះរាជដំណើរចូលទៅតាល់ព្រះសម្ពុទ្ធ ដែលទ្រង់គង់នៅនាវត្ត-
ជេតពន ដើម្បីទូលសូមឲ្យព្រះអង្គព្យាករសុបិននិមិត្តនោះ ។

ខណៈនោះ ព្រះអង្គទ្រង់ព្យាករថ្វាយថា បពិត្រមហារាជ, ក្នុង
អនាគត កាលបើអធម្មិករាជ (ព្រះរាជាមិនប្រព្រឹត្តតាមធម៌ ឬមិន
ប្រព្រឹត្តតាមច្បាប់) កើតឡើង, លោកគឺប្រជាជន ក៏វិបត្តិប្រែប្រួលមិន
ប្រព្រឹត្តតាមធម៌ តាមច្បាប់ដែរ ។ អធម្មិករាជនោះ ទ្រង់មិនលើកតំកើង
មិនប្រទានយសស័ក្តិ អំណាចឲ្យដល់ពួកកុលបុត្តដែលមានជាតិខ្ពង់ខ្ពស់
ដែលជាអ្នកសុចរិតមានចំណេះវិជ្ជាចេះដឹងច្រើនទេ ប៉ែរជាទ្រង់លើក

តម្កើងម្ចើងប្រកាន់យកសេចក្តីអំណាចឲ្យដល់ពួកកុលបុត្រ ដែលមានត្រកូលខាបថោកជាមនុស្សទុច្ចរិតល្ងង់ខ្លៅ គ្មានចំណេះវិជ្ជាទៅវិញ, ម្ល៉ោះហើយពួកកុលបុត្តដែលមានត្រកូលថោកខាបនោះ ក៏ឡើងទៅកាន់ឋានៈជាឥស្សរៈដ៏នាក់ការផ្សេងៗ ឯពួកកុលបុត្តដែលមានជាតិខ្ពង់ខ្ពស់ស្រែ៉ពីនេះ ក៏ធ្លាក់ខ្លួនចុះទៅកាន់ឋានៈជាទាសិកភាព សំដីរបស់ពួកកុលបុត្តដែលមានត្រកូលថោកខាប ស្រដៀងគ្នានឹងសំបកឃ្លោក ប៉ុន្តែបែរទៅជាធ្ងន់លិចចុះទៅប្រតិស្ឋានដ៏តជាប់ទៅជានិច្ច ក្នុងទីចំពោះព្រះគម្ពីរព្រះពុទ្ធជាដើម ក្នុងព្រះពុទ្ធវចនៈដើម ក្នុងទីចំពោះមុខអាមាត្យមន្ត្រីជាដើមក្នុងទីសម្រាប់វិនិច្ឆ័យកិច្ចការផ្សេងៗជាដើម ។

មួយទៀត បើខាងព្រះពុទ្ធសាសនាវិញ ពួកបព្វជិតល្ងង់ខ្លៅ ជាបុគ្គលថោកបន្ទាបស្តើរ ដែលស្រដៀងគ្នានឹងសំបកឃ្លោកស្រាលស្តើរមិនមានខ្លឹមសារអ្វី បែរជាបានប្រតិស្ឋានក្នុងតំណែងជាន់ខ្ពស់តាំងទៅក្នុងសង្ឃសន្និបាតជាដើម ក្នុងសង្ឃកម្មជាដើម ក្នុងទីសម្រាប់វិនិច្ឆ័យកិច្ចការរបស់សង្ឃជាដើមទៅវិញ, ឯពួកបព្វជិតជាបណ្ឌិត អ្នកមានសីលមានសេចក្តីអៀនខ្មាស ពោលភាក្យសំដីប្រកបដោយប្រយោជន៍បានការគ្រប់អន្ទឹមមានទម្ងន់ដូចឬទ្ធ គួរតែធ្ងន់លិចចុះប្រតិស្ឋានតាំងទៅក្នុងឋានជាន់លើ ទីដ៏ប្រសើរ មិនដូច្នោះបែរជាអណ្តែតសោត់ទៅកាន់ឋានៈទន់ខាបវិញ ។ បពិត្រមហាភាជ, សូមព្រះអង្គទ្រង់ជ្រាបថា សុបិននិមិត្តនេះ មិនមានហេតុកើតអ្វីដល់ព្រះអង្គក្នុងបច្ចុប្បន្ននេះទេ ជាសុបិននិមិត្តព្រះផលបង្ហើយហេតុកើតដែលនឹងត្រូវកើតមានតទៅអនាគតខាងមុខ ។

សេចក្តីរួបរួមបញ្ជាក់យ៉ាងខ្ជីថា មនុស្សទុច្ចរិតនឹងសំដីរបស់មនុស្សទុច្ចរិត ដូចជាសំបកឃ្លាកដែលលិចចុះទៅក្នុងទឹក, មនុស្សសុចរិតនឹងសំដីរបស់មនុស្សសុចរិត ដូចជាអំបែងថ្មដែលអណ្តែតនៅលើទឹក ។

ត្លរជាក់មនុស្សសំបកឃ្លាក
ត្លរលើកមនុស្សថ្មរពេជ្រ

មនុស្សឃ្លាកទុំគឺមនុស្សពាលទុច្ចរិត
តែងប្រព្រឹត្តពិតបង្ហិនជាតិផងខ្លួន
ត្រូវកុំលើកកុំតំកើងឲ្យធំធួន
ត្រូវធ្វើទោសតាមសំនួនបទដែលល្មើស ។
ធ្វើយ៉ាងនេះជាតិប្រទេសនឹងថ្កំថ្កើង
ព្រោះនាំយើងឲ្យសាមគ្គីគ្មានឃ្មងឃ្នើស;
មនុស្សថ្មរពេជ្រគឺមនុស្សបណ្ឌិតត្រើស
ចេះដឹងលើសហើយយិតយោងជាតិឲ្យថ្លៃ ។
ត្រូវលើកឡើងស្លួយតំកើងឲ្យពេញមុខ
ត្រូវកុំទុកក្នុងហានៈទាបពេកក្រៃ
ធ្វើយ៉ាងនេះទើបគេហៅសុវិទ្យៃ
ជាតិក៏ថ្លៃទៅដោយសារការណ៍នេះអឺយ ।

ប ញ្ញាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម-សុម សាស្ត្រាចារ្ស

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្ជនឯង

កាលដែលនៅភេទបញ្ចដិតពី ព.ស. ២៤៨៦ ត.ស. ១៩៤៣

(តមក)

មហាសុរសេនជាតក ទី ៧៤

លោកអាចារ្ស ម្រៀវ-នន្ទ វត្តលង្កា

ប្រែពីបាលី

បត្តំ ទត្វាន យេ ធីរាតិ ឥទំ សត្ថា ជេតវនេ
វិហរន្តោ អដ្ឋបរិក្ខារទានំ អារព្ភ កបេសិ ។

សត្ថា កាលអង្គសម្តេចព្រះបរមសាស្តាគង់ក្នុងវត្តជេតពន ទ្រង់ផ្តើម អំពីការឲ្យទានគ្រឿងអដ្ឋបរិក្ខារ ហើយទើបសំដែងព្រះធម្មទេសនា មានបទគាថា ថា បត្តំ ទត្វាន យេ ធីរា ដូច្នេះជាដើម ។

សេចក្តីដំណាលថា កាលពីដើម ក្នុងក្រុងសាវត្ថី មានភិក្ខុ ១ រូប មានប្រាជ្ញាមុះមុតខ្ចាំងក្លា ប្លសក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកោ-នាគមន:, ជាអ្នកមានលាភដ៏ខ្ពង់ខ្ពស់ មានយស់ដ៏ថ្លៃថ្លា មានបរិវារច្រើន ជាអ្នកចេះចប់ព្រះត្រៃបិដក មានសិស្សគណរាប់មិនអស់ ស្ទើរតែមិន ស្គាល់សិស្សានុសិស្សរបស់ខ្លួនផង លោកគិតចង់បូជាព្រះពុទ្ធរតន: ព្រះ ធម្មរតន: នឹងព្រះសង្ឆរតន: ទើបឲ្យដំណឹងដល់សិស្សានុសិស្សថា ខ្ញុំ

នឹងឲ្យទានគ្រឿងអដ្ឋបរិក្ខារនឹងបាយទឹកជាដើមច្រើនប្រការ ដល់ភិក្ខុ ១.០០០ រូប សាមណេរ ១.០០០ រូប នឹងឲ្យទានសំពត់ដល់ពួកអន្យតិរ្ថី នឹងពួកគ្រហស្ថផង, អ្នកទាំងឡាយចូរនាំគ្នាចាត់ចែងរោងទានឲ្យបាន សមគួរផងចុះ ។ ពួកបរិវារក៏បានធ្វើតាមបង្គាប់ ។ កាលនោះ ព្រះពុទ្ធ ទ្រង់ព្រះនាមកោនាគមន: ទ្រង់ជ្រាបដោយសំណាញ់ញាណថា ភិក្ខុនេះ ជាពន្ធកនៃព្រះពុទ្ធខ្ពង់ខ្ពស់បំផុតក្នុងលោក ។ ឯភិក្ខុនោះ លុះឲ្យគេធ្វើ មណ្ឌបរួចហើយ ទើបនិមន្ត្រព្រះសង្ឆមកប្រគល់មណ្ឌប ហើយប្រគេន គ្រឿងអដ្ឋបរិក្ខារយ៉ាងច្រើន ។ ភិក្ខុនោះ បានប្រគេនអដ្ឋបរិក្ខាររហូត ៧ថ្ងៃ ឥតមានចន្ទោះថ្ងៃណាមួយឡើយ ហើយប្រគេនបរិក្ខារដទៃទៀត ឥតមានសេសសល់ហើយចូលទៅនៅក្នុងព្រៃ ប្រារព្ធនូវធុតង្គទាំង ១៣ មានពួកភិក្ខុអ្នកនៅព្រៃចោមរោមជាច្រើន: លោកចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏ទទួលអនិច្ចកម្មទៅ បានទៅកើតក្នុងព្រហ្មលោក ។

សម្តេចព្រះដ៏មានដោគទ្រង់ព្រះនាមកោនាគមន: ទ្រង់ត្រាស់សរ-សើរនូវអំណោយគ្រឿងបរិក្ខារ ៨ យ៉ាងសេចហើយ ទើបទ្រង់ព្រះចិន្ត-នាការគិតថា "ឥឡូវនេះ គួរតែតថាគតញ៉ាំងសេចក្តីសោមនស្សឲ្យកើត ឡើងដល់ភិក្ខុទាំងឡាយ" ទើបទ្រង់ត្រាស់ថា "អ្នកមានសទ្ធាត្រូវតែ ឲ្យទានដើម្បីជាប្រយោជន៍ដល់ពួកស្មូមដែលមកដល់, មានអ្នកប្រាជ្ញពី បុរាណ បានឲ្យទានយ៉ាងច្រើន ព្រមទាំងឲ្យក្សាលរបស់ខ្លួនទៀតផង"; ព្រះអង្គមានព្រះពុទ្ធដីកាតែប៉ុណ្ណោះ ក៏ទ្រង់គង់ស្ងៀម, ទាល់តែពួកភិក្ខុ

អាវាធនា ទើបទ្រង់នាំរឿងវ៉ាវដែលកន្ធងទៅហើយមកសំដែងថា (១)

អតីតេ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ, ក្នុងកាលកន្ធងរំលងទៅ ហើយ មានព្រះមហាក្សត្រ ១ ព្រះអង្គទ្រង់ព្រះនាម មហាសុរសេន សោយរាជសម្បត្តិក្នុងនគរពារាណសី មានព្រះអគ្គមហេសីទ្រង់ព្រះនាម រិជ្ជុលតាទេវី ។ ព្រះ ទមហាសុរសេនរាជ ទ្រង់ទូន្មានប្រៀនប្រដៅ អស់មហាជនមានអាមាត្យជាប្រធាន រាល់ព្រឹករាល់ល្ងាចថា អ្នកទាំង-ឡាយកុំធ្វេសប្រហែស, ចូរធ្វើបុណ្យ, ចូររក្សាសីល, ចូរឲ្យទាន ។ ចំណែកខាងព្រះអង្គ ទ្រង់សាងសាលាទាន ៦ ហើយព្រះរាជទានអស់ទ្រព្យរាប់សែនក្នុងមួយថ្ងៃ ។, ទ្រង់រក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥, ព្រះអង្គតែងទ្រង់កក់ព្រះសិរអំពីព្រឹក ហើយទ្រង់គ្រឿងប្រដាប់សព្វ អលង្ការទ្វើងគង់ព្រះទីនាំងគជេន្ទ្រឈ្មោះមហាបុណ្ឌរិក ស្តេចទៅកាន់ សាលាទានទ្រង់ព្រះរាជទាន ជល់ពួកស្មូមដោយព្រះហស្តព្រះអង្គ ។ ស្តេចទ្រង់ប្រគល់ការឲ្យពួកអាមាត្យថា "អ្នករាល់គ្នា ចូរឲ្យទានតាម បែបនេះតទៅទៀតចុះ" ហើយព្រះអង្គទ្បើងគង់លើជំរីឈ្មោះមហា-បុណ្ឌរិក ស្តេចត្រឡប់ចូលទៅព្រះរាជវាំងវិញ ។ មានកាលសម័យថ្ងៃមួយ ក្នុងពេលព្រឹកព្រាងស្ងាងព្រះសុរិយា ព្រះពោធិសត្វស្តេចទ្រង់តើន ចាកសយនាក្រឡាបន្ទំ គង់ពែនក្នែនរំពឹងជល់ទានរបស់ព្រះអង្គថា អញធ្លាប់ឲ្យតែពាហិរកទាន (ទានក្រៅពីខ្លួន), ទាននោះមិនទាន់ពេញ

---

១ ជាតកនេះ ប្លែកពីជាតកឯទៀតណាស់, ព្រោះជាតកឯទៀតសុទ្ធតែព្រះសមណគោតម ទ្រង់សំដែងពជាតិកំណើតរបស់ព្រះអង្គ, ជាតកនេះត្រឡប់ឃើញឯព្រះកោនាគមនៈសំដែងវិញ ។

ចិត្តអញនៅឡើយ ធ្វើម្តេចនឹងមានសូមមកសូមអជ្ឈត្តិកទាន (ទានក្នុងខ្លួន) អញទៀតអេះ! ប្រសិនបើមានសូមមកសូមក្នែកវបស់អញក្តី ហេះជូងក្តី ខ្លួនមួយកំណាត់ក្តី, អញមុខជាឲ្យមិនខាងឡើយ ។ កំពុងតែទ្រង់ព្រះចិន្តាជូច្នោះ ក៏ស្រាប់តែក្តៅរំជួលជល់ពិភពសម្តេចឥន្ទ្រាធិរាជ; ព្រះឥន្ទ្រពិចារណាមើលហេតុ ក៏ជ្រាបរឿងក៉វនោះហើយត្រេកអរណាស់ ក្នុងព្រះហ្ហូទ័យថា អើហ្នា! ព្រះជ្រាទមហាសុរសេនជាពុទ្ធង្ក្ទរបណ្ណូលសពិជ្ឋ កំពុងតែចង់ឲ្យអជ្ឈត្តិកទានតើ, តទៅក្នុងអនាគតកាលព្រះអង្គនឹងជ្រានត្រាស់ជាព្រះពុទ្ធ ជាទីពឹងនៃសត្វក្នុងលោក, ព្រះពោធិសត្វពីដើម។ មក ក៏ជ្ជាប់តែបំពេញមហាបរិច្ចាគទានទាំង ៥ ដែរទើបជ្រានត្រាស់ជាព្រះពុទ្ធ; ហេតុនេះ អញនឹងបំពេញព្រះរាជហ្ហូទ័យព្រះអង្គទើបគួរ" ។ លុះទ្រង់ព្រះចិន្តាស្រេច ស្តេចចុះចាកវិមានហានទេវលោកមកនិម្មិតអាត្មាជាមាណពឥតក្ឈាល កាន់ឈើច្រត់ឈរបង្ហាញខ្លួននៅនាព្រះរាជលាន ។

ឯព្រះមហាសត្ត ទ្រង់តើនស្រេច ស្តេចប្រជាប់ត្រឿងអលង្ការមានមហាជនចោមរោមជាបរិវារ ឡើងគង់លើព្រះទីនាំងគជេន្ទ្រជាមង្គលស្តេចទៅព្រះរាជទានឯសាលាទាន ។ ឯសក្តទេវរាជក៏បង្ហាញខ្លួនក្នុងកណ្ណាលចំណោមនៃមហាជន លើកដៃស្តាំឡើងនិយាយថា បពិត្រព្រះសម្មតិទេព, ខ្ញុំព្រះអង្គជាមនុស្សឥតក្ឈាល, មកសូមទានព្រះសិរព្រះអង្គ, សូមទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានជល់ខ្ញុំព្រះអង្គកុំខាន(1) ។

---

1 ត្លូរធ្លល់: ចើជ្មានក្ឈាលម្តេចក៏និយាយកើត ។

ពួកជនពាំងអស់បានឃើញដូច្នោះក៏មានចិត្តតក់ស្ទុតរន្ធត់ជាអស្ចារ្យ ។ ព្រះពោធិសត្ត ទតយល់ហើយទ្រង់រំពឹងថា បុរសនេះជាអ្វី? ទើបទ្រង់សន្ទិដ្ឋានក្នុងព្រះទ័យថា "បុរសនេះមិនមែនជាមនុស្សទេ ពិតជាទេវតា ហើយទ្រង់ព្រះចិន្តនាការថា "ព្រាហ្មណ៍នេះមកបំពេញបំណងអញ ហើយ" ទើបព្រះអង្គមានព្រះរាជឧន្ការថា:

អ្នកសូមរបស់អ្វី, យើងក៏ឲ្យរបស់នោះឥតទើសទាល់, យើងនឹងបំពេញបំណងរបស់យើងផង របស់អ្នកផង, ថ្ងៃនេះ យើងឲ្យទាន សូមឲ្យយើងបានត្រាស់ជាព្រះពុទ្ធប្រាកដកុំបីឃ្លាត បានឈ្នះមារសត្រូវទៅក្នុងអនាគត ចំឡងពួកមនុស្ស លោក ព្រមទាំងទេវលោកអំពីភពទាំងឡាយ យើងនឹងផ្តាច់បង់នូវធម៌ជាបុសគល់នៃសង្សារ ប្រាថ្នាពោធិញ្ញាណ ញុំងសត្វទាំងប៉ុន្មាន ដែលមានរាគនៅឡើយឲ្យធ្លងផុតអំពីទុក្ខភ័យ ។

លុះព្រះមហាសត្តមានព្រះរាជឧន្ការយ៉ាងនេះហើយ ទើបទ្រង់ត្រាស់នឹងអាមាត្យឈ្មោះមហាសុបិនថា នែមហាសុបិន, ចូរអ្នកឯងនាំអ្នកឥតក្សាលនេះទៅឯរាជដំណាក់ ។ អាមាត្យទទួលព្រះរាជឧន្ការថា "ព្រះករុណាថ្ងៃពិសេស", ហើយនាំមនុស្សឥតក្សាលទៅឯរាជដំណាក់ ថ្វាយដល់ព្រះរាជាហើយ ក៏ឲ្យអង្គុយនៅក្នុងទីដ៏សមគួរមួយ ។ ព្រះមហាក្សត្រគង់លើអាសនៈជាមួយនឹងមនុស្សឥតក្សាល ត្រាស់ហៅវរជោតិកុមារ ជាព្រះរាជបុត្រសំឡាញ់ ឲ្យមកគង់លើគំនរវតនវត្ថុហើយអភិសេកឲ្យសោយរាជ្យស្នងព្រះអង្គ ត្រាស់ហៅនាងទេវីមកថា "ប្អូន

អើយ, ចូរនាងស្តាប់ពាក្យបង, ចូរនាងមើលទានរបស់បង ជាទានធ្វើឲ្យកើតប្រយោជន៍ ជាទានដែលកម្រមានឲ្យបាន, ថ្ងៃនេះនាងមើលបងឲ្យទានក្បាល ដែលព្រះពុទ្ធតែងទ្រង់សរសើរគ្រប់ព្រះអង្គ ។

ពួកស្រីស្នំមាននាងទេវីជាប្រធាន ទើងពួកមហាជនមានអាមាត្យជាដើម ក៏កើតកោលាហលជ្រួលជ្រើមឡើង ។ ឯព្រះនាងទេវីក្រាបថ្វាយទៀបព្រះបាទានៃព្រះមហាក្សត្រ ហើយទ្រង់ព្រះតន្ទៃរ៉ងថា បពិត្រព្រះសម្មតិទេព, ហេតុអ្វីក៏ទ្រង់ធ្វើយ៉ាងនេះ? ម្ចាស់ថ្លៃថ្នូនអើយ, ខ្ញុំម្ចាស់បើពាត់ប្តាស់ព្រះអង្គហើយ ខ្ញុំម្ចាស់កើតទុក្ខធ្ងន់ណាស់ ។ មហាសត្តទ្រង់ព្រះចិន្តាថា "តែអញនៅក្នុងទីនេះ មុខជាបំពេញបរមត្ថបារមីមិនបានទេ, បើដូច្នេះអញទៅខាងក្រៅនគរវិញចុះ", ទើបព្រះអង្គទ្រង់ប្តូរនាងពួកស្រីស្នំមាននាងទេវីជាប្រធាន ទើងពួកមហាជនមានអាមាត្យជាដើម ទ្រង់ដំកល់ព្រះអង្គគង់ពាជធម្មដ៏ប្រសើរ ត្រេកអរឆ្អែតកាយឆ្អែតចិត្ត ទ្រង់ចាប់យកព្រះខាន់វតន៍ នាំអាមាត្យទើងមាណពឥតក្បាលទៅឯខ្សាច ។

កាលនោះ ពួកអ្នកនគរទើងពួកមហេសីស្រីស្នំ សឹងរំសាយសក់គក់ឆ្ង ចុះចាកប្រាសាទសង្ឃាតទៅតាមស្តេច ។ ព្រះពោធិសត្វមិនអាចបង្គាប់ឲ្យមហាជនត្រឡប់វិញបាន ទើបព្រះអង្គត្រាស់សួរអាមាត្យថា អ្នកណាសោយភក្ត្រក្នុងនគរពារាណសី? អាមាត្យក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស ព្រះអង្គហ្នឹងហើយ" ។ ទើបស្តេចយកព្រះខាន់គូសផែនដី ហើយបញ្ញត្តថា តែអ្នកណាតាមម៉ាត់រំលងគំនូសនេះទើងត្រូវអាជ្ញាជាខ្លាំង ។ អ្នកនគរមិនហ៊ានជើរំលងគំនូស ក៏ប្រែជាកល់ក្បាល

ត្រឹមតំនូសនោះននៀលទៅមកៗ ស្រែកទ្រហោយំអឺងអាប់សំពួកងរំពង ។ ព្រះកជាបានជល់ទ្យានក៏យកទ្យែមាសមកចងព្រះអង្គត្រង់ពាក់កណ្ណាលខ្ទួន ផ្ទាប់ទឹងឈើយ៉ាងធំ ហើយត្រាស់ហៅមាណពឥតក្សាលថា អ្នកសប្ប្សរសនៅឯណា? ពួកអាមាត្យនាំមាណពឥតក្សាលចូលទៅជិត ទើបព្រះអង្គត្រាស់បង្គាប់អាមាត្យឈ្មោះសុចិថា នែសុចិ, ប្រស្ទែងយកព្រះខាន់មកកាត់ក្សាលអញឲ្យទៅគាត់ចុះ ។ អាមាត្យឈរសំរក់តែទឹកភ្នែក ។ ទើបព្រះមហាសត្តចាប់ព្រះខាន់ដោយព្រះអង្គឯង បំរុងនឹងកាត់ព្រះសិរសា បែរព្រះកក្ត្រាទតទៅអាកាសត្រាស់ថា ទេវតាអើយ, សូមអ្នកមើលការបរិច្ចាគរបស់ខ្ញុំ, ដោយការបរិច្ចាគនេះ ខ្ញុំមិនប្រាថ្នាសម្បត្តិចក្រពត្តិមិនប្រាថ្នាសម្បត្តិសួគិកាមាវចរទាំង ៦ ជាន់ មិនប្រាថ្នាសម្បត្តិព្រហ្ម មិនប្រាថ្នាសម្បត្តិព្រះបច្ចេកពុទ្ធទ្បើយ, ខ្ញុំប្រាថ្នាឲ្យតែបានជាបច្ច័យនៃសព្វញ្ញុតញ្ញាណ ដែលផ្ទើប្រយោជន៍ដល់សត្វក្នុងលោកទាំងមូលតែម្យ៉ាង ។ លុះទ្រង់ត្រាស់យ៉ាងនេះហើយ ទើបពោលពាក្យជាគាថាថា

ពុទ្ធោ បពោធេយ្យ ជនំ បស្ប្ជន្ត្តោ ទុក្ខសោកិកំ
អហំ តារយន្ត្តោ ជនំ ពុទ្ធោស្មិ អនន្ត្ពញ្ញាណោ

ព្រះសព្វញ្ញុពុទ្ធ កាលឃើញប្រជាជនមានទុក្ខសោក រមែងជាស់ឲ្យក្រាក់រលឹកទ្បើង; ខ្ញុំក៏សូមឲ្យបានត្រាស់ជាព្រះពុទ្ធមានប្រាជ្ញាញាណកប់មិនបាន បានចម្ទងប្រជាជនដូច្នោះ ។

ប៉ើខ្ញុំមិនទាន់បានត្រាស់នៅឡើយ នៅអន្ទោលទៅក្នុង
វដ្តសង្សារក្នុងកាលជាអនាគត ទោះបីប៉ុន្ទានរយជាតិក៏ដោយ
ខ្ញុំសូមឲ្យបានជាអ្នកបេះសំដែងធម៌ ដល់សត្វទាំងឡាយ
ក្នុងទីប្រជុំលោកិយជន កុំឲ្យមានអាក់ ។

មហាសត្តទ្រង់ត្រាស់យ៉ាងនេះហើយ ក៏ឥតមានភិតភ័យ បីដូចជា
ទាហានធ្វាប់ចុះស្នាមក្នុងសង្គ្រាម មានជ័យជំនះប្រើនដងមកហើយ ។
ស្តេចទ្រង់ប្រុងប្រៀបនឹងកាត់ព្រះសិររបស់ព្រះអង្គ ។ ត្រានោះ
ក៏កក្រើកញ្ជាប់ញ័រខ្ទ័រមហាប្រឹថពីដល់ទីបំផុតទឹក ស្ទរស័ព្ទសន្ធឹកផ្គរលាន់
ក៏លាន់ព្ទតត្រាំតត្រេង មានទាំងភ្លៀងផ្ការ ៥ ព័ណ៌បង្អ្សារចុះមកដោយ
គេជះទាននៃព្រះមហាសត្តនោះ ។ ទេវតាទាំងឡាយសឹងថ្វាយស័ព្ទ
សាធុការ, សេចក្តីអស្ចារ្យកើតឡើងប្រែកៗ ជាអនេកប្រការ; ព្រះអង្គ
ទ្រង់កាត់ព្រះសិរសាហើយប្រទានដល់មាណពឥតក្សាល; មាណព
នោះឈរនិយាយថ្វាយពរថា "សូមព្រះអង្គជាសប្ឋុរសទ្រង់ប្រកប
ដោយសេចក្តីសុខ"; និយាយតែប៉ុណ្ណោះក៏បាត់ក្នុងទីនោះទៅ ។

(មានត)

ផ្នែកអក្សរសាស្ត្រ

រឿងសៅរ៍សោយ

(សិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
ជៀបជៀងតាមតម្រាយសាស្ត្រាស្លឹកវិត

(តមក)

យាយចាស់ព្ទហើយ ពុំអាចអត់ឡើយ សើចឡើងហាស់ ៗ! ថា"នៅមិនទាន់ បានឃើញទឹកច្បាស់ លោមកក្រឡះ គិតកាត់បំពង់ ៗ បើរឿងនេះគេច ពុំបានសម្រេច រូបយើងនេះគង់ បានក្តីអៀនខ្មាស អាម៉ាស់យូរលង់ ណ្ហើយសុំបង្អង់ គិតបង់សិនក៉" ៗ ព្រឹកព្រាងជាងជាក់ យាយតាពីរនាក់ ស្ទៀកពាក់អាត្មា ហើយចូលទៅរក យកពូជនានា នឹងអាលលីលា ទៅចំការហោង ៗ រកសព្វ ៗ ទៅ ពុំឃើញមាននៅ បាត់ទៅជាម្ពង យាយថា"ខ្ញុំខ្ជប់ គ្រប់សព្វហ្មត់ហ្មង កាលសព្វ ១ ជង នៅហ្នឹងធម្មតា ៗ ទើបតែយប់ជ្រៅ នេះមានមនុស្សក្រៅ មកស្នាក់អាត្មា បាត់ពូជទាំងហ្នឹង ពុំដឹងទៅណា"; ព្រះមហាក្សត្រា ព្ទហើយធ្វើយថ្កាន ៗ ថា"ខ្ញុំនេះណា ពុំលួចយាយតាមេត្តាជ្រាសជ្រាណ ខ្ញុំលួចពូជឈើ មកធ្វើអ្វីបាន សូមកុំនឹកស្មាន

ថាខ្ញុំចោរឡើយ ។ គ្រាន់តែឲ្យស្នាក់ ពំនឹងពឹងពាក់ គុណណាស់ ទៅហើយ បើពុំដឿឮ្នោះ ផែកចុះលោកអើយ បើឃើញពិតហើយ ខ្ញុំពុំបើថា” ។ យាយតាទាំងពីរ ស្តាប់សព្វពោធ៍ ម្នាម្ចឹតត្រួតត្រា ផែកគេ សព្វគ្រប់ ជាន្តកប់កូសា ឃើញជាយនោះណា ចង់ជាតំខ្លួច ។ តើត ក្តីកង្វា ខើបសូមត្រួតត្រា កូសាដែលក្លួច ស្រាប់តែពេលនោះ ជាប គ្រោះតិចតួច ដែលខ្លួនឆ្លើមខ្លួច ធ្លើពីបុរេ ។ បណ្តាលឲ្យពេជ្រ ដែលខ្លួនចង់វេច គេចតែខ្លះ ទៅជាតូជណា យាយតាទាំងពីរ ពុំអត់ ខ្វៃតទេ តាំងដេរដៀលថា ។ “អាចោរអប្បលំគួណ៌ អញឲ្យផ្ទះស្នាក់ ពឹងពាក់អាត្មា ហ៊ានលួចតូជអញ គួរខ្នាញ់ណាស់ណា គ្រាប់ទឹងតើអា ជ្រុថ្នាធ្លើអ្វី” ។ ព្រះមហាសត្វគ្រា ញុះហើយធ្លើយថា “មេត្តាប្រណី ខ្ញុំពុំ អ្នកលួច លបលួចអ្វី។ ហ្នឹងពេជ្រវង្សី នៃខ្ញុំពិតណា ។ ម្តេចលោក ក្រែវក្រោធ បំពានបំពោត មកចោទខ្ញុំថា លបលួចគ្រាប់តូជ ឃើញ ដូចមុសា សូមលោកយាយតា កុំថាច្មោះឡើយ” ។ ឮបានឮហើយសោត យាយតាវឹងក្រោធ ច្រឡោតឥតសៀវឿយ ដេរថា “អាកេ! លួចគេពិត ហ៊ាយ នៅរឹងត្អឹងធ្លើយ នែវើយអាខ្លា! ។ អញឃើញទឹងក្អែក រឹងឈរជជែក ថា ពេជ្រផងអា មុខអាកំខេច ឮបានពេជ្រពីណា កុំឈរតវ៉ា មុសាណាវ៉ី!” ។ ថាហើយនាំគ្នា ប្រតាយកជា ឥតត្រាប្រណី ដេញចេញពីផ្ទះ រហ័ស ខ្លី ។ យកពេជ្រវង្សី ដែលក្លាយនោះទុក ។ ព្រះជាទេសិសាវ៍ ទុកតួល អួលក្តៅ ហួងសៅឡើមុខ ចាកផ្ទះយាយតា យាត្រាបុកលុក ណាមួយ សោយទុក្ខ ចុកចប់សព្វកាយ ។ ព្រះពោធិសត្វ ពន្ធុកប្រមាត់ ទុកឥត

វសាយ វកវោសខុសគ្នាខ ក្នុងជ្រាណអង្គកាយ ស្រាប់តែគេវាយ ឥត
ប៊ីមេត្តា ។ ស្តេចចរចេញទៅ ពុំដឹងនឹងដៅ ឆ្ពោះទៅទិណា កណ្តែង
កណ្តាច ត្រមោចកំព្រា តែឯងឯកា ឥតគ្នាពីរផង ។ លេចវាលចូល
ព្រៃ សឹងស្បៃស្បាតព្រៃ ដាសព្រៃនោះហោង ហួសពីព្រៃគ្រាស់ ដល់
វាលធំផង រូតរះធ្លុះធ្លង ពុរពងបាទា ។ លំបាកយ៉ាកអង្គ ស្មារតីហ្មឹងហ្មង់
ចិត្តដ៏យាត្រា ទ្រាំកំដៅថ្ងៃ ក្សត្រថ្ងៃឈឺផ្សា ពុរពងជើងបាទា លើលាតាំង
ខ្លួន ។ ទ្រង់ព្រះកន្សែង សោកាថ្ងាថ្ងែង កណ្តែងកណ្តុក កណ្តាច
ខ្មោចក្រំ ដាលដំដោយខ្លួន ទឹកមុខត្រហួរចុក ស្រក់ស្រោចតក្តា ។
ព្រះបាទក្សត្រថ្ងៃ ខ្មៀយនិត្យល្ងិតល្ងៃ ស្មើរក្ស័យជីវ៉ា អត់ក្រយាស្មោយ
ខន់ខ្សោយកាយា ផេងផោងអង្គា វេទនាអស់អង្គ ។ បរមេចមកឥត
ស្រែចស្តេចគេចឈប់ ក្រែមម្ចប់ហើយគង់ សំពកកាយា ក្សត្រាវវែង
ត្រមោចត្រមង់ លន្ទង់ណាស់ណា ។ ព្នៃតែសត្វស្រែក ក្នុងព្រៃវិវែក
សត្វសេកសារិកា លលកចាបព្រាប ទំនៀបគ្នាវ៉ា មាន់ព្រៃទទា អា-
អូតច្រៃឡៃ ។ ចោ៉លតោកតាវ៉ៅ យំឮក្រែអៅ ទំនៅដកម៉ែ ករវែក
ឈ្មោលញី យំពីពោះព្រៃ ស្រងាត់ទាំងព្រៃ សូរឆ្ងាយលន្ធោច ។
កេងកងខ្លុកខ្លែ កូកាំងហូពូ ទាំងលលកខ្មោច យំដោយព្រៃព្រឹក្ស គួរ
ទឹកស្រែងោច សូរមាត់ស្វាខោច លន្ធោចទៅឆ្ងាយ ។ អង្គព្រះបាស់
ប្បាង ឮមាត់សត្វផង ក្នុងទ្រូងស្មើរឆ្ងាយ ឥតមានគ្គីគ្នា កំព្រាអង្គកាយ
ខ្លួនឥតរសាយ លោយខ្សោយណា ។ កាលព្រះបមកឥត ស្តេចទ្រង់គង់
ឈប់ ក្រែមម្ចប់ព្រឹក្ស ទ្រង់គង់សញ្ជឹង ពុំដឹងនឹងថា ទៅឋានហានណា

ក្សត្រាវិនិច្ឆ័យ ។ បន្តិចពាក្យ ត្រៃកង្ឆើងម្ចីមា លីលាទៅមុខ តណ្តែង
ឯងឯក ជ្រៀតជ្រែកវែកលុក ពាក្យពោនពាក្យពុក ចាន់ច្នុកស្ទើរមរណ៍ ។
យូរទៅទេសពល ក្សត្រកន្ត្រាន្តចាន់ដល់ អចលនគរ នៅត្រឹកនោះណា
ក្សត្រាកូធរ ឃើញស្នមរឹកវរ ត្រាច់ចរសូមទាន ។ បរមចមកព
ស្តេចទ្រង់ឆ្ងល់ឈប់ ទតត្រាប់សព្វថ្កាណ លុះស្នមស្រឡះ ទើបព្រះ
ផ្ទាស់ថ្កាន ឫមថ្ងៃនឹងតែងថ្កាណ សូមទានដែរណា ។ ពេលនោះទេស
ពល ចាន់អស់កស្តុផល ល្មមស្តុលអាត្មា ស្រែចស្តេចគេចគ្រាយ
មកសោយក្រយា ត្រង់តៀម ๑ ណា ក្នុងផ្សារដិតនោះ ។ ជាតៀម
លក់ទំ មានតូចមានធំ សក្តិសមឥតមាន សោយស្រែចស្តេចស្តែង
ថ្លាថ្លែងចំពោះ ច្រាប់ស្រីលក់នោះ ដោយស្មោះចិត្តា ។ ថា "ម៉ែហ្ងួន
ស្រី ខ្ញុំនឹងតែកើ ឥតអ្វីពីសា ចង់សុំទំនាង សូមនាងមេត្តា ឲ្យទាន
តិចវ៉ា គោក្តាចាន់ម្តង" ។ ឯស្រីលក់ទំ យល់ព្រះបរម ខត្តមច្បាស់
ច្បង មានរូបល្អស្រស់ ថ្លៃកអស់ប្រុសផង មានចិត្តដិតចង ប៉ុនប៉ង
ស្នេហា ។ ទើបនាងរើសវាក ទំនែកចែកមក ពន្ធកក្សត្រា ស្តេច
ទទួលយក ទំមកហើយណា ក៏បរិភោគ្តា នៅទានោះនៃ ។ សោយ
ស្រែចស្តេចស្កាក់ ចាំនឹងពឹងពាក់ សំណាក់អាស្រ័យ នៅភាននោះថ្កាន
កំសាន្តព្រៃទំយ អស់ ๒-๓ ថ្ងៃ ឥតបីទៅណា ។ រយៈស្កាក់នៅ
ស្តេចស្តែងតែងទៅ សុំទូរក្រយា ពីតៀមដិតនោះ ឥតលោះថ្ងៃណា
ចិញ្ចឹមអាត្មា ជាប់ជាប្រក្រតី ។ រីដំណើរនេះ បញ្ឈប់ទប់ស្ទះ ត្រឹម
ណោះឯងខ្ញី នឹងចារថ្លាថ្លែង សំដែងសេចក្តី ពីព្រះចក្រី ធិបតីមណ្ឌល ។

ការណ៍ណោះមែនមាន ស្តេចនេះស្តេចទៅជ្រាណា សំពាធការយពល តង់កងនគរ បវរនិមិល ឈ្មោះនោះសោតសល់ អចលនគរ ។ រីឯស្តេចនោះ មានឧទាមចំពោះ ជាឈ្មោះបវរ ថាកំនុំវត្ត ជ្រាកជនាមករ មហេសីបវរ ល្អល្អឹមប្រិមប្រិយ ។ មហេសីនោះ នាមសមចំពោះ សុទ្ធិវតី មានបុត្រីមួយ ជាត្រួយបែតី ល្អល្អះលើសស្រី បុរីនគរ ។ នាមករសោភ័ សុទត្តទេវី ជាទីត្រេកអរ ល្អល្អះស្មើ ហាក់ស្រីអប្សរ ស្រស់បស់បវរ ល្អល្អះណាស់ណា ។ ព្រះជន្មច្បងចប់ ជ្រាំមួយជណ្តប់ ត្រូវព្រះរាជ្យ សក្តិសមទ្រង់ត្រាយ ធោមធាយកាយា ពេញចិត្តមាតា បិតាពេកក្រៃ ។ យប់មួយនោះណា ព្រះជាទេវត្តា សេយ្យាហើយនៃ ជល់ពេលឧទ្ទុះ បច្ចូសសម័យ ជិតព្រឹកក្បែរថ្ងៃ តើនចាកបន្ទំ ។ ទ្រង់ជម្រិះថា "ព្រះពាជធីតា អាត្មាក៏ធំ កាលណាទៅហ្ន៎! ទើបវិនត្តម មានគូដណ្តឹង សក្តិសមល្មមគ្នា" ។ ព្រឹកព្រាងស្អាងច្បាស់ បវរមន្ត្រីស្រាស់ ទ្រង់ត្រាស់បញ្ជា ឲ្យបុរោហិត ចូលដំគម្ចីមា គាល់ព្រះពាជា រៀលាប់ ។ ។ កាលពាជហោរ មកដល់ហើយណា ក្បែរទ្រង់ជ្រាប់ ឲ្យមើលការ បុត្រីចំណាប់ ជាខ្លួនឯង ប្រញាប់ធាប់ឆ្ងី ។ "ហោរើយឥឡូវ បុត្រីអញកូវ រាងៅគ្មានប្តី ចូរហោរគុណហារ ដឹងការអំពីបុត្រី មានប្តីកាលណា ។ រីប្តីនោះឯង ជាតិជាស្តេចស្តែង គួរស្មើនឹងស្តាប្អូយអ្នកខ្សត់ ទុគ្គតឯកា ចូរហោរទាយថា ធាប់ក៏ហោរអើយ" ។

(មានត)

រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

កណ្ឌទី ២១

តាំងពីឧងយ៉ុងនាំរឿងវ៉ាវៃទៅក្រាបទូលព្រះបាទហៀនត រហូតដល់ចូធូធិតលើកទ័ពទៅបាប់មាន់ជងនឹងឡៅពី ដែលសមគំនិតឆ្នានឹងតាំងសិន ។

លុះវេលាព្រឹកឡើង នាហ្ម៉ឹទសព្វមុខមន្ត្រីទាំងពួងចូលក្រាបបង្គំតាល់ព្រះរាជាព្រមគ្នា ។ ឧងយ៉ុងក៏នាំរឿងវ៉ាវនោះទៅក្រាបបង្គំទូលថ្វាយព្រះចៅហៀនតេ។. ទ្រង់ទតហើយមិនបានត្រាស់ថាប្រការម្តេច ទើបយកសំបុត្រនោះទៅឲ្យចូធូហើយត្រាស់ថា ការទាំងនេះតាមតែមហាឧបរាជនឹងវិះគិតចាត់ចែងចុះ ។ ចូធូបានទទួលព្រះតម្រាស់ហើយ លុះត្រឲ្យប់មកផ្ទះក៏ឲ្យបំរើទៅហៅយ៉ុអេង ។ ចូលមកដល់ក៏គំនាប់ចូធូ ។ មិនបានទទួលគួរសមមិនបានប្រ្ចស្រ័យតាមយ៉ាងទំនៀមធម្មតា ។ យ៉ុអេងមានសេចក្តីតូចចិត្តណាស់ក៏នៅស្ងៀមហើយដកដង្ហើមធំ ទើបនិយាយដោយកំឡាំងរោហារ

ថា ដែនដីនេះធំទូលាយណាស់ ប្រសិនបើខាតបង់មនុស្សម្នាក់ចេញទៅ
ក៏មិនជាអ្វីណាស់ណាទេ ។

ចូធូបានឮ យ៉ូអេងនិយាយប្រៀបធៀបដូច្នោះ មិនទាន់ដឹងជាប្រាកដ
ក៏សង្កេតទុសទៅ ទើបស្សរថាដែនដីយើងនេះ ទីប្រឹក្សានឹងសេនាទាហាន
ដែលមានថ្ងៃដែក៏ច្រើន ហេតុម្តេចខ្លួនក៏ថាមិនមានមនុស្សល្អ ។ យ៉ូអេង
បានស្តាប់ដូច្នោះ យើញថាចូធូដឹងមិនដល់ ទើបតបថា មហាឧបរាជ
អ្ហតថាមានទីប្រឹក្សានឹងទាហានដែលមានថ្ងៃដែនោះតីនរណាខ្លះ? ខ្ញុំបាទ
មិនស្គាល់ច្បាស់ ។ ចូធូថា ស៊ុនហុក, ស៊ុនហ៊ុវ, តុយកែ, ធៀយ៉ុក,
ទីប្រឹក្សារបស់យើង ៤ នាក់នេះ សុទ្ធតែមានដំរេះប្រាជ្ញាយ៉ាងជ្រៅទូលាយ
សូម្បីសៀវហោនឹងតាន់ផេង ដែលជាអ្នកប្រាជ្ញរបស់ព្រះចៅកោចោពី
បុរាណក៏មិនបានស្មើ ដល់នឹងទីប្រឹក្សារបស់យើង, ឯទាហានឯករបស់
យើងដែលមានថ្ងៃដែនោះគឺ តៀវលៀវ, ទៅធូ, លីទៀន, ងាក់ដិន ៤
នាក់នេះ សុទ្ធតែមានថ្ងៃដែខ្ចាំងពូកែដំនាញស្ទាញស្ទាត់ក្នុងការរៀណរង្គ
សង្គ្រាម លើសជាងងៀមងឹងនឹងម៉ាប៉ូដែលជាសេនាព្រះចៅហាន់កង់ប៉ូ
ទៅទៀត. ឯលីយ៉ូយនឹងម៉ាន់ថង ៤ នាក់នេះ ជាទីប្រឹក្សារងរបស់យើង
ហែហ្ហូទុន, អ៊ីកឹម, ស៊ីឡុង ជាសេនាយ៉ាងនេះក៏ពប់រយនាក់ ហេតុម្តេចខ្លួន
ថា ដែនដីនេះនឹងរកអ្នកមានសតិបញ្ញានឹងថ្ងៃដែខ្ចាំងពូកែមិនមានសោះ ។

យ៉ូអេងបានឮដូច្នោះ ក៏អស់សំណើចហើយតបថា លោកមាន
ប្រសាសន៍នេះ ខ្ញុំមិនយល់យើញផងទេ មនុស្សទាំងអស់នេះខ្ញុំក៏បាន
ដឹងយល់ស្គាល់ គំនិតមារយាទនឹងដំរេះប្រាជ្ញាហើយនឹងថ្ងៃដែអស់ហើយ

ឯស៊ុនហុកនោះមុខបីជូចជាតេយំ ត្បូរតែប្រើទៅស្បូរជម្ងឺប្ត សក្ការសព, ស៊ុនហ៉ីវនោះសមតែធ្វើអ្នកភ្ជុករក្សាសព, ធ្រៃយ៉ុកនោះសមតែប្រើឲ្យអង្គុយចាំជើងក្រាន, គុយកែនោះសមតែតែងឃ្វាងនឹងឲ្យមើលបទសាស្ត្រា, ត្រៀវលៀវនោះសមតែរាយស្ពរនឹងរតាំង, ទៅធូនោះសមតែឃ្វាលគោនឹងសេះ, លីទ្រៃនោះសមតែឲ្យមើលពាក្យក្តី, ងាក់ជិននោះសមតែប្រើឲ្យដើរចែកសំបុត្រ, លីយ៉យសមតែប្រើឲ្យជុសខាត់ត្រឿងអាវុធ, មាន់ថងនោះសមតែប្រើឲ្យផឹកស្រាទំពាធ្មឹងជ្ជូក, អ៊ីកឹមនោះសមតែប្រើឲ្យរែកក្ការទៅធ្វើបន្ទាយ, ស៊ីឡុងនោះសមតែប្រើឲ្យកាប់ជ្ជូកលក់, ហែហ្ជូទុននោះសមតែប្រើឲ្យចាំរក្សាខ្ជូន កុំឲ្យសត្រូវកាត់ក្សាលនឹងជើងធ្វេងស្តាំទៅបាន, ឯទីប្រឹក្សានឹងសេនាទាហានក្រៅអំពីនេះ សមតែប្រើឲ្យរែកស្ស្យៀងជូនកងទ័ព ដែលលោកនឹងរាប់ថា មានជំរេះប្រាជ្ញាខ្ជាំងពូកែនោះ ខ្ញុំមិនឃើញផងសោះ ។

ចូធូបានស្តាប់ជូច្នោះក៏ខឹងខ្ជាំងណាស់ ទើបស្ជរថា ខ្ជូនមកតិះដៀលទីប្រឹក្សានឹងសេនាទាហានរបស់យើងជូច្នេះ ខ្ជូនចេះដឹងអ្វីខ្ជះឲ្យលើសគេ ។ ឃ្ជីអេងតបថា ខ្ញុំចេះមើលផ្ការយលើអាកាស មើលធ្ជុះរហូតទៅក្រោមផែនដី ខ្ញុំចំណានស្ទាត់មើលដឹងយល់ស្ពាល់ភូមិលំនៅល្អនឹងអាកក់ ១ រិញទ្រៃត ខ្ញុំហានពិតទូលព្រះមហាក្សត្រ ឲ្យតាំងនៅក្នុងយុត្តិធម៌ ជូចព្រះចៅដៀវស៊ុំននោះក៏បាន ប្រការ ១ ខ្ញុំនឹងបញ្ចុះបញ្ចូលទូន្មានប្រជៅអាណាប្រជានុរាស្ត្រ ឲ្យមានចិត្តសុចរិតទ្រៃងត្រង់នឹងផែនដី ជូចត្រាខុងជូនឹងងាន់អៀន ដែលជាត្រូប្រជៅមនុស្សទាំងពួងឲ្យទ្រៃងត្រង់ក៏បាន

ដែលខ្ញុំសន្ទនានឹងលោកគ្រានេះ ឧបមាដូចជានិយាយនឹងមនុស្សឆ្កួត ដែលមិនចេះគាសាមនុស្ស ។

តៀវលៀវបានឮដូច្នោះខឹងណាស់ ហូតក្រហើចេញនឹងកាប់យ៉ីអេង។ ចូរឆ្កឹហាមឃាត់ថា កុំអាលធ្វើវីវរឡើយ ព្រោះសព្វថ្ងៃនេះ យើងនៅខ្វះមនុស្សម្នាក់សម្រាប់ឲយស្គរទ្វេលក្បៀវ បើទៅសម្លាប់យ៉ីអេងចេញក៏យើញថាស្ងាប់ទៅទេ ត្រូវតែយកវាទៅប្រើឲ្យឲយស្គរទ្វេលក្បៀវល្អជាង ។ តៀវលៀវក៏ស្តាប់ពាក្យចូរឆ្ង ។ ក៏ប្រើយ៉ីអេងឲ្យទៅចាំវាយស្គរ, ទ្វេលក្បៀវ ។ តៀវលៀវថា យ៉ីអេងនោះនិយាយពាក្យចាក់ដោតដល់លោកច្រើនណាស់ ហេតុម្តេចបានជាលោកអត់ធន់មិនសម្លាប់វាចេញ ។ ចូរឆ្កឹតបថា យើងបានឮដំណឹងរឿយ ។ ថា យ៉ីអេងនេះជាមនុស្សមានសតិបញ្ញាក្លាហាន គ្មានកោតញ្ញើតនរណាសោះ ដែលវាមកនិយាយទ្រគោះឲ្យយើងនោះ បើយើងទៅសម្លាប់វាចេញ មនុស្សទាំងពួងនឹងគរហានិន្ទាថា មានមនុស្សចេះដឹងល្អហើយសម្លាប់ចោលជាអសារប្រការ ១ អ្នកមានសតិបញ្ញាឯណាឲ្យថាចូលមកទៅនឹងយើង ក៏ឲ្យរួញាញ្ញើតថាយើងមិនឃានខ្មែកបុរាំងមនុស្សល្អ ឯយ៉ីអេងនេះជាមនុស្សអួតចេះ យើងត្រូវយកទុនវាទុកឲ្យវាយស្គរ ។

លុះថ្ងៃ ១ ចូរឆ្កឹឲ្យអញ្ជើញនាហ៊ុនសព្វមុខមន្ត្រីមកស៊ុំលៀង, យ៉ីអេងពាក់អាវកណ្តាចចេញមកវាយស្គរទ្វេលក្បៀវ, នាហ៊ុនទាំងពួងបានឮសំឡេងស្គរដែលយ៉ីអេងវាយនោះក៏ពីរោះចាប់ចិត្តបង្កើតកិស្សរ៉ង់, ឥហានដែលបំរើក្បៀវយើញយ៉ីអេងសំដែងអាកប្បកិរិយាមិនសមគួរ ក៏និយាយ

ថាថ្ងៃនេះមហាឧបាសិកាទទួលភ្ញៀវធំ ហេតុម្តេចខ្ញុំមកពាក់អាវតណ្ហាបដូច្នេះ ។ ឃ្មុំអើងបានឮថាហានស្រែកថាដូច្នេះ ក៏ដោះអាវនឹងស្បែកដើរចេញអស់ តែងវាយស្គរនៅតែខ្លួនទទេ ។ នាហ៊ុនតាំងពួងឃើញដូច្នោះ ក៏នឹងអៀនខ្មាសយកដៃខ្ទប់មុខតាំងអស់គ្នា ។ ឫឆ្កួយើញឃ្មុំអើងធ្វើដូច្នោះក៏ខឹងណាស់ស្រែកថា ឯកធ្វើឆ្គេសធ្ងាសដូច្នេះធ្វើបានឯងឲ្យអញលក់ឈ្មោះឬ? ។ ឃ្មុំអើងឆ្លើយតបថា អញដោះអាវនឹងស្បែកដើរចេញនៅតែខ្លួនទទេដូច្នេះ ដោយយល់ថា ជាការចេញមុខ ព្រោះកាយនេះជាទីស្អាត មានាបិតាឲ្យអញកើតមក ។ ឫឆ្កួថា ឯងឃើញថារូបកាយនរណាស្មោកគ្រោកនោះ ។ ឃ្មុំអើងតបថា ខ្លួនមិនបួលចិត្តឬ? យើងនឹងអធិប្បាយរូបកាយស្មោកគ្រោករបស់ខ្លួនឲ្យស្តាប់ : ប្រការ១ ខ្លួនមិនស្គាល់ច្បាស់មនុស្សល្អនឹងអាក្រក់ តែកររបស់ខ្លួននោះជាទីស្មោកគ្រោក, ប្រការ១ ដែលនរណាមានចិត្តសុចរិតទៀងត្រង់យល់ឃើញថាខ្លួនធ្វើការអាក្រក់ក៏រំលឹកហាមឃាត់ខ្លួនដោយសុចរិត ខ្លួនមិនបានស្តាប់តែចៀករបស់ខ្លួនក៏ជាទីស្មោកគ្រោក, ប្រការ១ ខ្លួនមិនមានចិត្តធូរធ្លាយរួសរាយពាប់អាននាហ៊ុនសព្វមុខមន្ត្រី នឹងចៅហ្វាយខៃតាំងពួង ហើយខ្លួនតែតក្សត់ចិត្តប្រទូសរ៉ាយ ឲ្យព្រះចៅហៀនតេព្រួយព្រះពជហឫទ័យបានសេចក្តីក្តៅក្រហាយ ចិត្តរបស់ខ្លួនក៏ជាទីស្មោកគ្រោក, សព្វថ្ងៃនេះមនុស្សក្នុងផែនដីពាប់អានថាយើងមានដំរេះប៉ាជ្យ ហើយខ្លួនមកប្រមាថមើលងាយឲ្យយើងជាអ្នកវាយស្គរ ព្រោះមិនបានស្គាល់យើងជាមនុស្ស

ស្អ ពេលនេះខ្ញុំគិតការដ៏ធំពន្លឹក មិនគួរខ្ញុំមិនពាប់អានយើងជាអ្នកមានសតិបញ្ញាសោះ ។

ខុងយ៉ឺងបានឮយ៉ឺអេងថាដូច្នោះ ក្នុចចូឆូមិនអត់ទឹងក្រោធចឹងឲ្យសម្លាប់យ៉ឺអេងសោះ ខុងយ៉ឺងក៏គំនាប់ចូឆូហើយថា កាលពីដើមខ្ញុំបានឃើញថា យ៉ឺអេងជាមនុស្សមានសតិបញ្ញា ទើបបញ្ជូលមកដើម្បីនឹងឲ្យទៅបញ្ចុះបញ្ចូលឡៅពៀវ ឥឡូវយ៉ឺអេងនិយាយទ្រគោះមើលងាយលោកជាច្រើនហួសពេក ទោសនោះដល់ស្លាប់ ខ្ញុំបាទសុំអាយុជីវិតខ្មុកម្ពង់ចុះ ។ ចូឆូបានស្តាប់ខុងយ៉ឺងនិយាយក៏សួរទៅយ៉ឺអេងថា ទោសដែលខ្ញុំពោលប្រមាថមើលងាយដល់យើងនោះ យើងលើកលែងចោលហើយតែខ្ញុំនឹកអាណិតថាមានដំរេះច្បាស់ល្អនោះ យើងនឹងប្រើឲ្យទៅនិយាយបញ្ចុះបញ្ចូលឡៅពៀវចៅហ្វាយស្រុកគេវិញ បើបានការនឹងឲ្យចំណាប់ផ្សាន់ ហើយនឹងតាំងឲ្យខ្ញុំធ្វើនាហ្មឺនធំ ។ យ៉ឺអេងមិនត្រមះត្រួលពាក្យចូឆូប្រើ ចូឆូឃើញយ៉ឺអេងធ្វើត្រដើយកន្តើយ ក៏ថយខ្លួនទៅរឿបប្រាប់ស៊ុនហុកនឹងនាហ្មឺនតាំងពួងថា ឲ្យទៅរៀបតុតាំងនៅគ្រាទិសខាងកើតឲ្យស្រេច បើឃើញយ៉ឺអេងចេញទៅដល់ទ្វារស្រុកណា ត្រូវនាំគ្នាសែនបញ្ជូនឲ្យចេញទៅឆុតដែនស្រុកទៅចុះ ។

ស៊ុនហុកនឹងនាហ្មឺនតាំងពួង ក៏ត្រូវទៅរៀបតុតាំងតាមការខុកជាស្រេចតាមពាក្យចូឆូបង្គាប់ ហើយស៊ុនហុកនិយាយនឹងនាហ្មឺនតាំងពួងថា បើយើងសែនបញ្ជូនហើយ អ្នកតាំងឡាយកុំបីនិយាយសាកសួរយ៉ឺអេងថាប្រការម្តេចឡើយ ។

ចូធូកឹនិយាយនឹងយ៉ូអេងទៀតថា ប៉ើខ្ញុនមិនព្រមទៅ យើងត្រូវ
សម្ចាប់កវិយាបុត្រវបស់ខ្ញុនឲ្យអស់ ។ ពេលនោះយ៉ូអេងក៏ព្រមទទួលពាក្យ
ថានឹងចេញទៅបញ្ជុះបញ្ជូលទ្បៅញ៉ៅ ។ ចូធូក៏បង្គាប់ឲ្យយកសេះ ១
មកឲ្យយ៉ូអេងជិះ ហើយឲ្យទាហាន ៦ នាក់កាន់កាប់ទៅជាមួយនឹងយ៉ូអេង
ផង ។ ឯយ៉ូអេងនឹងទាហាន ៦ នាក់ក៏ជិះសេះ នាំគ្នាទៅដល់ទ្វារស្រុក
ទិសខាងកើត មិនបានឃើញនាហ្ចឹនទាំងពួងចំអកជំទយដូចម្តេច យ៉ូអេង
ចុះពីលើសេះចូលទៅឈរកណ្តាលទីប្រជុំនាហ្ចឹនទាំងពួង ហើយយ៉ូអេងក៏
ផ្ទើជាយំ ។ ស៊ុនហុកមិនបានដឹងកលយ៉ូអេងក៏ស្ងរថា មហាឧបរាជប្រើ
ខ្ញុនឲ្យទៅជារាជការ ហេតុម្តេចបានជាឈរយំស្រែកដូច្នេះ ។ យ៉ូអេង
ផ្ទើយតបថា យើងយល់ឃើញអ្នកទាំងអស់គ្នា ឧបមាបីដូចជាសាកអសុក
យើងដើរចូលមកដូចជានៅកណ្តាលអសុក ទើបមានសេចក្តីអាណិតយំ
ស្រក់ទឹកក្នែកដូច្នេះ ។

ស៊ុនហុកនឹងមន្ត្រីទាំងពួង លុះបានឮយ៉ូអេងនិយាយដូច្នោះក៏ផ្ទើយតប
ថា ដែលថាខ្ញុនយើងជាអសុកនោះ ខ្ញុនអ្នកឯងក៏ជាខ្ចោចឥតក្បាលដែរ ។
មន្ត្រីទាំងនោះក៏នាំគ្នាទឹងប្រទ្បោតហូតក្រប៉ីប្រុងនឹងកាប់យ៉ូអេង ។
ស៊ុនហុកក៏ហាមឃាត់ថា យ៉ូអេងនេះឧបមាដូចជាសត្វតិរច្ឆានទៅហើយ
អ្នករាល់គ្នានឹងមកប្រកាន់ទោសសម្ចាប់រាចេញនោះគ្មានប្រយោជន៍អ្វីសោះ
នាំឈាមប្រទ្បាក់ក្រប៉ីទទេ ។ យ៉ូអេងផ្ទើយតបថា ខ្ញុនយើងមានសេចក្តី
ទឹងនឹងមិនទឹងតង់នៅចេះនិយាយត្រឹមត្រូវ ហេតុម្តេចអ្នកឯងដំណាលថា
យើងជាសត្វតិរច្ឆាន ឯអ្នកឯងរាល់គ្នាឧបមាដូចសត្វមមាចមិនខ្ចាចតំនរ

ក្លើង នាំគ្នាហើរឡើងចូលក្នុងក្លើងនោះក៏នឹងដល់ទូរសេចក្តីស្លាប់ ។ នាហ្នឹនតាំងអស់ស្ពាប់ហើយក៏ទឹងទ្លាំងណាស់ តែហាមប្រាមគ្នាឲ្យនៅស្ងៀម ហើយតាំងអុជទៀនធូបសែនបណ្ដោញយ៉ូអេងឲ្យចេញទៅ ហើយក៏នាំគ្នាត្រឡប់មកផ្ទះវិញ ។

យ៉ូអេងនឹងតាហាន ២ នាក់ ក៏នាំគ្នាទៅដល់ស្រុកកេងដីរ ទើបចូលទៅនិយាយនឹងឡៅពៀរ តាមដែលចូធឲ្យទៅនិយាយបញ្ចុះបញ្ចូលហើយយ៉ូអេងនិយាយអ្ជតចេះដឹង លើកទ្ជូនបន្ទាបគេ ធ្លើកិរិយាមើលងាយឡៅពៀរថាជាមនុស្សល្ងង់មិនមានដំរេះប្រាជ្ញា ។ ឡៅពៀរយើញកិរិយាយ៉ូអេងចរចាមើលងាយដូច្នោះក៏ទឹងណាស់ តែគិតទប់ចិត្តបាន ព្រោះចិត្តឡៅពៀរនោះ ជាមនុស្សធូរទូលាយរ្ជសរាយរាប់អានអ្នកតាំងពួងហើយនិយាយនឹងយ៉ូអេងថា ដែលចូធូប្រើឲ្យអ្នកឯងមកនិយាយបញ្ចុះបញ្ចូលយើង ។ នៅមិនតាន់ចុះចិត្តទេ បើកាលណាអ្នកឯងទៅនិយាយបញ្ចុះបញ្ចូលហងចចៅហ្ជាយស្រុកកាំងហែ ព្រមល្មមចុះចូលទៅនឹងចូធូហើយ យើងនឹងចុះចូលព្រមផង យ៉ូអេងក៏លាឡៅពៀរទៅស្រុកកាំងហែទៀត ។

(មានត)

ដំណឹងតាមឲ្យល់ក្នុងកាន្តារ:

លោកផេង-ជ្រីវិ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបាវាំងមកជាភាសាខ្មែរ

(តមក)

ចំណែកអ្នកកំឡោះនឹងនាងនារីដើរឆ្ងាយបន្តិចទៅ, មានអាវ៉ាប់ម្នាក់ញ្ញែកហ្ទូងមនុស្សដើរចូលមក អាវ៉ាប់នេះពួននៅក្បែរនោះក្នុងវេលាកើតហេតុនោះ, គេយើញអាការជំលោះរវាងអ៊ីស្មាអ៊ីល និងនាយទាហានរងគ្មានខ្ទះត្រង់សេចក្តីណាព្រមទាំងការចរចាគ្នាតមកទៀត ។ គេចូលទៅរកនាយទាហានដែលទើបនឹងអត់ទោសឲ្យអ៊ីស្មាអ៊ីល នៅកណ្តាលមហាជន ។ គេឧនគំនាប់តាមទំនៀមស្រុក ហើយនិយាយថា:

– "ខ្ញុំឈ្មោះរស្សីម ហេន អាប់ជាឲ្យ:" រួចសៀមមួយស្របក់ទើបចាប់និយាយទៀតថា :

– "លោកមិនដឹងទេម្ត កំឡោះដែលលោកមើលយើញនុះ គឺជាមនុស្សយាជទេតើ?" ។

នាយទាហានតួរគីសំឡឹងអាវ៉ាប់នោះសព្ទ ។ ក៏ស្តាល់ឈ្មោះស្តាល់សាវតារ ថាគេនេះជាមេភូមិក្នុងក្រុងតូចមួយនឹងគេដែរ តែពាក្យអ្នកស្រុកចោទថាគេជាមនុស្សប្រណែននឹងអ៊ីស្មាអ៊ីល ។

នាយទាហានដែលមានរឿងហេតុជាមួយនឹងអ៊ីស្មាអ៊ីលឆ្ងើយថា:

– ‘‘កូនប្រុសរបស់លោកអៃយ៉ាដ ចូលក្នុងបន្ទប់ម្ចាស់ដើម្បីការពារខ្លួន ។ ម្យ៉ាងទៀត រឿងនេះ ជាកិច្ចការរបស់យើងទេ ព្រោះនិយាយអំពីការស្លាប់របស់ខាហានយើង ។ នៃសំឡាញ់ ត្រូវចាំថា គេមិនមានប្រយោជន៍អ្វីនឹងទៅជួយរាល់គ្រាប់ស្រែកឆ្កែឆ្កួតទេឡើយ’’ ។

ស្ត្រីមេឆ្កែចាំមាត់ ។ នាយខាហានតបវិញដោយស្ងួតអាងពាក្យចំទៀមអាប់ ។ ក្នុងពេលនោះ ស្ត្រីមេមិនដាច់ចិត្តនឹងលះបង់បំណងអាក្រក់ដោយគ្មានជំទាស់ព្រួញដ៏ឆក់ទៅកអ៊ីស្មាអ៊ីលឡើយ ព្រោះអ៊ីស្មាអ៊ីលឆក់យកតាមមុខនូវស្រីដែលស្ត្រីមេត្រូវការ គឺជាស្រីតែមួយដែលស្ត្រីមេស្រឡាញ់ជាងស្តេចទាំងពួង ។ ស្ត្រីមេចុចបំហឹងដែលជិះជាន់សន្ធានចិត្ត ហើយធ្វើជាសើចនិយាយថា:

‘‘ខ្ញុំសូមសរសើរលោក អំពីការស្គាល់ទំនៀមទំលាប់របស់យើងយ៉ាងច្បាស់លាស់ ប៉ុន្តែបើគេមិនចេះពាក់ខ្លួនឯង ត្រូវតែពឹងអ្នកឆ្លាតក្នុងវិធីនូវខ្លួនដែលគេស្គាល់ច្បាស់ ណាជាស្រែវាល ណាជាស្រែសែ ណាជាស្រែវ ណាជាស្រែដែ ។ គឺអ៊ីស្មាអ៊ីលជាអ្នកនេះយ៉ាប្រាយអាក្រក់ ក៏មានគំនុំនឹងសាសន៍តបវិញ ហើយមើលងាយសាសន៍យើងផង’’ ។

នាយខាហានអង្គុតអំពីការព័យព៌ាប់ឥតប្រយោជន៍ ហើយមានបំណងនឹងបញ្ចប់ការចរចា ខ្ជិលនិយាយតទៅទៀត ក៏ឆ្លើយដោយសេចក្តីគួរសមថា:

– ‘‘ត្រូវមែន! ខ្ញុំអរគុណចំពោះយោបល់ដ៏ប្រពៃរបស់អ្នកហើយ សូមឲ្យព្រះអឡាស់តាមរក្សាអ្នកជានិច្ចកុំបីឃ្លាត’’ ។

លុះពោលដូច្នោះហើយ លោកឆាកមុខចេញ នាំពួកមិត្រសំឡាញ់ដើរសំដៅទៅក្រុង ។

*
* *

ផ្ទះលោកអ៉ីយ៉ាដ ដេកស្ងាត់ឈឹង កាលដែលអ៊ីស្មាអ៊ីលនឹងនាងក្រមុំឡីឡាដើរធ្ងងកាត់ជ្ងាទីមួយខាងក្នុង, នៅតាមក្បែរខាងជ្ងានេះ មានផ្ទះអ្នកបំរើនឹងក្រោលសេះ ។ នៅពីមុខរោងសេះ មានទ្រុងសម្រាប់ចិញ្ចឹមបក្សីពណ៌ផ្សេង ៗ ដូចជាអន្ទេប កុកសាប់ ក្សោក នឹងមាន់ចែពណ៌អុជ ៗ យកពីបូពាិប្រទេសមក ។ នៅក្បែរទ្រុងនោះ មានកូនក្រោលមួយកំពស់មួយជំហរមនុស្ស ជាកន្ទេងសម្រាប់ទុកចិញ្ចឹមសត្វលាសៀម (gazelle) អ្នកកំឡោះនឹងនាងក្រមុំគ្មានន៉ិយាយស្ពីអ្វីធ្ងើយធ្ងងគ្នាសោះ តាំងពីសុទ្ធរោ-កាសដែលអ៊ីស្មាអ៊ីលធក់នាងពីកណ្ណាប់នៃអសប្បុរស ម៉ាវិយោមក ។

តើជនទាំងពីរនឹងគិតបែបណា ?

ខ្ជួននាងឡីឡាទន់ដូចសំឡីំ ត្រាច់ចរល្ងាសល្ងន់ក្នុងដៃអ៊ីស្មាអ៊ីលហើយសឡាក់ដំណើរសិម ៗ បន្ទិតចូលរកគ្នាបន្ទិចម្តង ៗ ។ ម្ងោ៉ះហើយយុវជនទាំងពីរដូចជាត រកនិយាយកាន់គ្នាទៅវិញទៅមកថាដូចម្តេចមិនកើត ។ គេសោយឥដ្ឋារម្មណ៍ ឆឹសន្ទានដ៏ក្ងាហានយ៉ាងទន់ ហើយសេចក្ពីស្នេហាចំពោះគ្នានឹងគ្នាយាងចុះរហូតដួងហ្ចុទ័យរៀងខ្ជួន ព្រមទាំងស្រោចស្រពដោយពន្ធឹយ៉ាងត្រជាក់ ។ កាមកតដែលស្ថិតនៅយូរណាស់ក្នុងសន្ទានសត្វជាអ្នកអត់ធន់ នឹងជាអ្នកខ្មាស ក៏លោផុះផុលឡើងភ្ងាមដោយកំឡាំងមួយ រកអ្នកណាដឹងគ្មាន ។

សេចក្តីនឹកក្នកប្រើន ។ ចានជុះបុិចឡើងក្នុងជួងវិញ្ញាណនៃនាងនារីឡើឡា សេចក្តីនឹកក្នកនេះចាំតែវីក ចាំតែបញ្ចេញរាង ចាំតែក្ខាយទៅជាការណ៍ពិតដែលនាំឲ្យរំកើបចិត្ត ។

ចំណែកខ្ជួនអ៊ីស្មាអ៊ីលឯង ក៏មិនអាចទប់ទល់អាត្មាអំពីសន្ទានដ៏រំកើបនៅចំពោះមុខនាងក្រមុំជាតិជាមួយគ្នា ។ គេស្រឡាញ់ជាប់ចិត្តក្នុងនាងឡើឡា ហើយទុកនាងនេះជាកវិយាឯក នៅបណ្ណាស្ថ្ពីទាំងឡាយក្នុងក្រុមញាតិ ។ គេឈប់ត្រង់កណ្ណាលទីធ្ងា ពីមុខកញ្ចុចទឹកប្រកបដោយសូរស័ព្ទស្រដេះស្រដោចលាយឡំនឹងសូរសន្ធឹកសំឡេងផ្សង ។ ក្នុងអាកាសរហ្រ៉ក ។ ពេលរាត្រី ។ ទ្វារក្រោលសេះរបើកឡើង នៅទីកណ្ណាលក្រោលដែលគេមើលឃើញ រាងសេះឡៅ សស្ទុង ។ ដេកលើចម្បើង មានចង្ក្រ៉ងគោមមួយអុជភ្ជឺបូងចុះបូងឡើងជូចជាក្ខើងអាបត្រាច់ក្នុងរាលស្រែ ។

អ៊ីស្មាអ៊ីលនិយាយឡឹប ។ ជាក់ត្រចៀកនាងឡើឡាថា:

– "តាឡិបមិនទាន់ដេកទេ! តាមបងមក!" ។

នាងដើរពីក្រោយចូលតាមទៅក្នុងក្រោលសេះ ដែលមានស្មៅក្ខិនប្រហើរទើបនឹងច្រូតមកថ្មី ។ ប្រាប់ឲ្យដឹងថាអ្នកម្ចាស់ផ្ទះសម្ស្យរស្មៅណាស់ ។

អ្នកបំរើរត់មកជួបនឹងចៅហ្វាយកំឡោះ គឺជាមនុស្សប្រុសអាយុប្រហែលហាសិបឆ្នាំ បើគេសំឡឹងមើលតាមស្បែកមុខជ្ជុញស្ងិត. តែដែលតាមពិតនោះ អ្នកនោះមិនជាចាស់ប៉ុន្មាន ។ គាត់ជាអ្នកកំព្រា, គេបោះបង់ចោល, លោកអៃយ៉ាដ រើសយកមកចិញ្ចឹមទុកប្រើជូចជាធ្ពែសម្រាប់ចាំ

ផ្ទះ ។ គាឡិបស្រឡាញ់ក្រមគ្រូរសោលោកអៃយ៉ាដ ដោយចិត្តស្មោះស្ម័គ្រ
អស់ពីពោះពីពុង តែដែលគាត់ស្រឡាញ់ជាងគេគឺ អ៊ុស្មាអ៊ុល ដែល
គាត់ចានយើញកើតមក ហើយដែលជាអ្នកបង្ហាត់ឲ្យរៀនដើរ ខាង
ក្រោយប្រពន្ធទីមួយរបស់លោកអៃយ៉ាដអនិច្ចកម្មទៅ ។ តមកគឺគាត់ហ៊ឺន
ហើយជាអ្នកមេគំនិតខាងបង្រៀនអ៊ុស្មាអ៊ុល ឲ្យចូលចិត្តក្នុងការចាញ់ ។
គាត់បង្រៀនចំណេះចាប់សត្វស្វាប ដោយយកចាមទៅលាបបង្គុង ត្រង់
កន្ទែងដែលសត្វធ្លាប់ទំ ។ គាត់ប្រាប់រេបៀបកូនសេះកៀបទឹងខ្នងដើរ
លើខ្នងអូដ្ឋ រាប់គីឡូម៉ែត្រមិនអស់កំឡុងធ ។

គាឡិបចានធ្វើឲ្យស្គាល់មហាលំអនៃធម្មជាតិ ដ៏ក្សាំងសំបុកខ្ទ-
យុក ចានធ្វើឲ្យស្គាល់ទស្សនាការដ៏ពាសពេញក្នុងរាលៗប់ ចំពោះដួង
តុណវិញ្ញាណដែលកំពុងចូលចិត្តចង់ដឹងចង់យល់ ដែលទើបនឹងឈាន
ចូលក្នុងពន្ធឹលោក កាលណាឲ្យលំបាកមកពីតួង ហាក់ដូចកេលដើមទ្រូង
កាលណាបក្សីអកចេញពីសំបុក ហើរចុះតួយយ៉ាងខ្លះពីខាងលើឲ្យលំ
លើ ដូចជាអ្នកនាំដណ្តឹងអាត្រក់ កាលណាលំអចាប់ចិត្តពេលល្ងាចពណ្តា
ក្រហមរន្ធាល កាលណាព្រះអាទិត្យរៀបលិចឯណោះ ក្នុងសាគរ នៅ
ត្រើយនាយខាងទីប៊ូលី ជាទីដែលគាឡិបមិនស្គាល់ តែគាត់ប្រាថ្នាចង់
ដឹងវែកពេកតែក្នុងចិត្ត ព្រោះគាត់នឹកដល់សំរែកក្តោងក្រមៅ ដល់នាង
ស្រាលៗ ទឹងនាងធំៗ ដូចជាដួងដែលផ្សែងហុយចេញពីបំពង់ក្តៅឡើងទៅឲ្យ
ហើយរសាត់អណ្តែតទៅលាយឡំនឹងពពកឯអាកាសវេហាស៍ ។

ស្រឹងព្រេងនឹងស្រឹងស្រមាក់ស្រមៃនៃអតីតកាលតែងមានជាប់នៅក្នុងជួងព្រលឹងតាឡិបជាធម្មតា អតីតការណ៍បណ្តាលឡើងនឹងធ្វើឲ្យបាំងស្មើឡើង កាលណាតាត់ទុកចិត្តអ្នកដែលតាត់ស្រឡាញ់ ហើយតាត់និយាយបើកកកាយប្រាប់ឥតមានលាក់ ។

តាឡិបបើកក្រពេះចេញពីក្បាលត្រងាល ដើម្បីសំដែងសេចក្តីគ្លរសម ។ គេឃើញមុខតាត់ដោយសារពន្ធឹត្រើងគោម ។ មុខនោះជារបៀបធម្មតាតែស្បែកបែបក្រាស់បន្តិច ក្នែកមានប្រាជ្ញា ផ្នត់បបូរមាត់ស្តើងប្រាប់ឲ្យដឹងថាជាអ្នកមានល្បិច កិច្ចកលឧបាយ ថ្ងីជ្ឋិតកាយតាត់គំរាំងឃាំង ។

អ៊ីស្មាអ៊ីលរុញនាងឡីឡាចូលទៅហើយប្រាប់ថា:

– "លោកតា! ឱ្យសុំផ្ញើដុំមាសមួយនេះនឹងតាផង!" ។

តាឡិបងក់ក្បាលចំពោះនាងក្រមុំដែលតាត់ស្គាល់ជាស្ត្រីជាតិជាមួយគ្នា ហើយតាត់និយាយឡឹបៗថា:

– "សូមព្រះអាឡស់តាមរក្សាអ្នក!" ។

អ៊ីស្មាអ៊ីលប្រាប់ទៀតថា:

– "លាក់នាងទុកឲ្យស្ងួលណ៉ា! មិនត្រូវឲ្យអ្នកណាសង្ស័យថាមាននាងនៅក្នុងទីនេះឡើយ ។ សូមលោកតាធ្វើយដោយងក់ក្បាលបានហើយ!" ។

តាឡឹបដើយសំឡឹងមេឃ នឹកអំពាវនាវរកព្រះជាម្ចាស់ ហើយយកដៃជាក់ត្រង់ដើមទ្រូង តាត់ស្សថចំពោះព្រះនាមនៃម៉ាហូម៉ែត ។ (មានត)

រឿងបុស្ស័ន្ធទិព្យ សាមសិបតំរាវរឿង

រឿងព្រេងតំណៀ

លោកសមិធ ម្ចូត្យ៉ងជិម: តែង
លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ដល់សាយណ្ហសម័យ, ពានរបានយល់ថា: ព្រះរាជបុត្រទ្រង់ទ្បើយ ព្រះកាយតស កំក្រាបទូលថា: "ទ្រព្រះអង្គម្ចាស់ ខ្ញុំនៅក្រោមដើមឈើនេះ, សូមផ្ទំសម្រាកព្រះកាយតាមព្រះទ័យនៅទីនេះហើយ ។ ព្រះអង្គ-ម្ចាស់ទ្រង់ក៏រៀបចំព្រះកាយដើម្បីនឹងផ្ទំនៅទីនោះ" ។ ខ្ញុំពោលទៅកាន់ពានរថា: "ឧពានរ អ្នកកុំទុកចិត្តជាតិមនុស្សឲ្យសោះ. អ្នកឯង ត្រូវចោះព្រះរាជបុត្រមកឲ្យខ្ញុំមក; ចំណីខ្ញុំមកពីសេចក្តីសោមនស្សរបស់អ្នកឯងដោយពិត" ។ ពានរក៏តបទៅវិញថា: "បងខ្ញុំ ចូរអ្នកស្តាប់ខ្ញុំ, ព្រះរាជបុត្របានទុកចិត្តខ្ញុំ ។ មិនធ្វើយាដទ្រង់ទេ" ។ ដល់ខ្ញុំបានស្តាប់ ពាក្យពានរក៏ស្ងៀតនៅស្ងាត់ស្ងៀម ។

ដល់យូរបន្តិច, ព្រះរាជបុត្រទ្រង់តើនពីក្រឡាព្រះបន្ទំ ។ ពានរ ក៏យកក្បាលដាក់លើភ្លៅព្រះរាជបុត្រហើយក៏ដេកលក់ទៅ ។ ខ្ញុំក៏ពោលទៅកាន់ព្រះរាជបុត្រថា: 'ទ្រព្រះអង្គម្ចាស់, ហេតុដូចម្តេចបានជាទ្រង់សព្វព្រះទ័យនឹងពួកពានរ, សូមទ្រង់ចោះពានរនេះមកខាងក្រោម, ពានរនេះជាអាហាររបស់ទូលបង្គំ, កុំឲ្យទ្រង់ខ្ញុំចទូលបង្គំឡើយ" ។

ព្រះអង្គម្ចាស់ទ្រង់ព្រះសណ្ឋាប់នូវវាចារបស់ខ្ញា ទ្រង់ក៏បោះពានរនោះ ទៅខាងក្រោម ។ តែក្នុងខណៈនោះ, ពានរបានចាប់មែកឈើតោងទាន់, មិនបានធ្លាក់មកដល់ដី ។ ព្រះរាជបុត្រដល់ឃើញដូច្នោះ ទ្រង់ខ្មាស អៀនពន់ពេក ។ ពានរក្រាបបង្គំទូលព្រះរាជបុត្រថា: "កុំឲ្យទ្រង់ព្ឱយ បារម្ភអ្វីឡើយ" ។

ដល់បុព្វណ្ហសម័យ, ខ្ញាក៏ចេញពីទីនោះ ចំណែកព្រះរាជបុត្រ ទ្រង់ត្រឲ្យប់ទៅជាមានទម្មត្តកភាព ធ្ពូត) ក៏បានត្រេចវង្វេងនៅក្នុងអរញ្ញ-ប្រទេសនោះ ទ្រង់ចេះតែមានព្រិះបន្ទូលថា: វិ.សេ.មិ.ភ. វិ.សេ.មិ.ភ.។

ព្រះទីនាំងអស្សតរព្រះអង្គម្ចាស់ បានវិលត្រឲ្យប់ទៅព្រះរាជធានី តម្រង់ទៅកាន់អស្ទសាលាវិញ ។ ព្រះមហាក្សត្រិយ៍ទ្រង់ទតយល់ពាជី ត្រឲ្យប់វិលមកព្រះរាជនិវេសនដ្ឋានវិញ ដោយបាត់ព្រះអង្គម្ចាស់ដូច្នោះ ក៏ទ្រង់ព្ឱយព្រះរាជហ្ឫទ័យពន់ពេក ។ ព្រះមហាក្សត្រិយ៍ទ្រង់ស្តេច យាងជាមួយនឹងព្រះរាជបរិវារទៅក្នុងអជនប្រទេស ដើម្បីនឹងស្វែងរក ព្រះរាជបុត្រ; ទ្រង់បានជួបនឹងព្រះរាជបុត្រដែលត្រេចវង្វេងក្នុងវនប្ស-ទេស កំពុងមានព្រះទុន្ទារថា: វិ.សេ.មិ.ភ. វិ.សេ.មិ.ភ.។

ព្រះមហាក្សត្រិយ៍ទ្រង់បាននាំព្រះរាជបុត្រ ត្រឲ្យប់ទៅព្រះបរមរាជវាំង វិញហើយ ទ្រង់បានឲ្យប្រសិទ្ធីនូវមន្ត្រនឹងឲ្យសោយនូវទុសថ យ៉ាង ចំណាន, តែទោះបីព្រះអង្គទ្រង់ប្រើនូវព្រះមធ្យាបាយយ៉ាងណាក៏មិន អាចធ្វើឲ្យសះស្បើយនូវទម្មត្តកភាពនៃព្រះរាជបុត្របានឡើយ ។ ព្រះ

មហាក្សត្រិយ៍មានព្រះឌន្ធារថា: "បើលោកត្រូសារទានន្ធនៅទីនេះ
លោកអាចជ្រាបនូវព្រះរាតនៃព្រះរាជបុត្រនេះបាន ត្រយើងបានចាត់
ឲ្យគេយកលោកទៅពិយាជបាត់បង់ទៅហើយ ។ ក្នុងពេលនោះព្រះ
រាជទីប្រឹក្សាបានក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ថា "សូមមហារាជទ្រង់
ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំ សូមស្នើព្រះរាជយោបល់ថា:
ទ្រង់ប្រើឧសថទាំងអស់មិនបានការ ព្រះអង្គនោតែទ្រង់ព្ឋយព្រះរាជ
ឬហទ័យជដែល តើព្រះអង្គនឹងទ្រង់ព្រះចិន្តាជូចម្តេចទៀត? សូមទ្រង់
ចាត់ឲ្យអាមាត្យស្រែកអំពាវនាវអ្នកជុំវិញព្រះរាជធានី ដោយព្រះរាជ-
ប្រកាសនេះថា: "អ្នកណាមើលព្រះរោគព្រះអង្គម្ចាស់ជាសះស្បើយបាន
យើងនឹងប្រគល់ព្រះរាជអាណាចក្រពាក់កណ្តាល ឲ្យត្រួតត្រាកាន់
កាប់" ។ ព្រះមហាក្សត្រិយ៍ក៏ទ្រង់ព្រមតាមយោបល់ព្រះរាជទីប្រឹក្សា
ហើយក៏ចាត់អាមាត្យស្រែកឃោសនាជ្សាយព្រះរាជប្រកាស ឲ្យប្រជាជន
នៅជុំវិញទីក្រុងឌ្ឍត្រប់ត្នា ។ ព្រះរាជទីប្រឹក្សា បានវិលត្រឲ្យប់មកកាន់
គេហដ្ឋានវិញ ហើយក៏បាននៃទានរឿងនេះឲ្យលោកត្រូសារទានន្ធជ្រាប ។
លោកសារទានន្ធ ក៏ពោលទៅកាន់ព្រះរាជទីប្រឹក្សាថា: "ចូរលោក
អញ្ជើញទៅក្រាបបង្គំទូលព្រះមហាក្សត្រយ៍ថា ខ្ញុំមានយុវនីមួយនាក់
អាយុ ៧ ឆ្នាំ បើនាងយុវនីនេះមើលចំទៅព្រះរាជបុត្រ ។ នឹងបានជាសះ
ស្បើយរោគភ្លាម" ។ ព្រះរាជទីប្រឹក្សាបានយកសេចក្តីនោះទៅក្រាប
បង្គំទូលព្រះមហាក្សត្រិយ៍ ។ ទ្រង់សវនាហើយ ទ្រង់បាននាំព្រះ

រាជបុត្រមកកាន់គេហដ្ឋាន នៃព្រះរាជទីប្រឹក្សាៗបានយកវាំងនន មួយបាំងត្រង់បន្ទប់ដែលលោកសារទាន្ទូនៅ, ព្រះមហាក្សត្រិយ៍នឹងព្រះរាជបុត្រទ្រង់គង់នៅខាងក្រៅវាំងនន ។

លោកសារទាន្ទូនៅពីក្រោយវាំងនន ពោលថា "អ្នក វិស្សាស: ណាដែលនិត្រាលក់លើក្តៅមិត្ត ហើយបានប្តេជ្ញាថាទុកចិត្តមិត្តនោះហើយ អ្នកនោះបោកបញ្ឆោតទៅវិញ, តើនឹងទុកអ្នកនោះ ថាជាអ្នកសប្បុរសបានឬ? (គេបានយករឿងនោះទៅនិពន្ធជាកាព្យ) ។

ព្រះរាជបុត្រទ្រង់សវនាន្ទូវវាចាជាសុកាសិត នៃលោកត្រូសារទាន្ទូ ក៏បំបាត់អក្សរ វិ. ចេញបាន ត្រឲ្យប់ពោលតែពាក្យថា សេ.មិ.វា. ។

លោកសារទាន្ទូពោលថា: "តាំងពីស្ពាន សេតុពន្ធ(១) បានធ្វើធ្ងងទៅដល់ទន្ទេគង្គា, ការប្រព្រឹត្តិបទឧក្រិដ្ឋទៅលើព្រាហ្មណ៍ឬបទឧក្រិដ្ឋដែលប្រព្រឹត្តទៅលើកល្យាណមិត្តរបស់ខ្លួន មិនអាចនឹងរលុបរលាយបានឡើយ" ។ ព្រះរាជបុត្រទ្រង់ព្រះសណ្តាប់ន្ទូវពាក្យដម្បូន្មានលោកត្រូសារទាន្ទូហើយ ក៏បំបាត់អក្សរ សេ· ចេញ, ទ្រង់ពោលតែត្រឹមពាក្យ មិ.វា. វិញ ។

លោកសារទាន្ទូថ្វែងតទៅទៀតថា "អ្នកណាដែលព្យាបាទមិត្តរបស់ខ្លួន (មិត្រហិម្សក:) ជាអ្នកអកតញ្ញូ, ជាបុគ្គលពាលប្រព្រឹត្តទុច្ចរិត

---

១ សេតុពន្ធ ពឺស្ពានព្រះរាម នៅខាងត្បូងប្រទេសឥណ្ឌៀ ឬ ជាកោះតូចៗ ដែលស្ថិតនៅរវាងប្រទេសឥណ្ឌៀនឹងកោះលង្កា ។

អ្នកនោះត្រូវទៅសោយទុក្ខឯនរក ក្នុងរយៈវេលាកំណត់តាមកាលដែល ព្រះអាទិត្យនឹងព្រះចន្ទូស្ថិតនៅក្នុងលោក" ។

ព្រះរាជបុត្រទ្រង់បានសណ្ឋាប់នូវវាចាលោកសារទាន្ទូហើយ ក៏ បំបាត់អក្សរ ម៉ិ. ចេញ, ទ្រង់ពោលតែអក្សរ ភ. វិញ ។

លោកសារទាន្ទូ ពោលតទៅទ្រតថា: ភជិ: បើទ្រង់ចង់ឲ្យបានសេចក្តីសុខ ដល់ព្រះរាជបុត្រ, ទ្រង់ត្រូវតែបវិច្ចាគទ្រព្យសម្បត្តិផ្សេង ៗ ឲ្យទៅដល់ពួកព្រាហ្មណ៍ ។ ការធ្វើព្រះរាជអំណោយដល់ពួកម្ចាស់គេហ-ដ្ឋាននេះនាំឲ្យរលត់រលាយនូវបាបអកុសល ដែលទ្រង់បានប្រព្រឹត្ត" ។

ព្រះរាជបុត្រទ្រង់ព្រះសណ្ឋាប់នូវពាក្យនេះហើយ ទ្រង់ក៏ជាសះស្បើយនូវទម្ងត្តកវោគនោះជ្រះស្រឡះ ។

កាលអ្នកទាំងអស់គ្នានេះ បានស្តាប់នូវរឿងព្រះរាជបុត្រ, ខ្ទានឹងពានរហើយ ក៏មានចិត្តសោមនស្សពន់ពេក ។

ព្រះមហាក្សត្រិយ៍ទ្រង់វិចិកិច្ចាក៏មានព្រះទន្ទ្រារស្សរទៅនាងទាវិកាថា "ទនាងទាវិកា, គេហដ្ឋាននាងឯងនៅឯណា? ឬជានាងឯងស្ថិតនៅក្នុងគ្រឹហានេះ, ម្តេចក៏នាងឯងបានដឹងរឿងរ៉ាវខ្ទា, ពានរនឹងព្រះរាជបុត្រនេះសព្វគ្រប់ ដែលជារឿងកើតមាននៅក្នុងអរញ្ញប្រទេស ។ លោកសារទាន្ទូ កាលបានស្តាប់ព្រះរាជទន្ទ្រារនេះហើយ ក៏ក្រាបបង្គំទូលថា: "ដោយសេចក្តីអនុគ្រោះនៃពួកអាទិទេពដ៏ប្រកបដោយពលភាពអស្ចារ្យ, ព្រះនាងសរស្ទតី (អាទិទេវីនៃវាទសិល្ប:) ស្ថិតនៅចុងជិវ្ហប្រសាទ

ទូលបង្គំនាំឲ្យទូលបង្គំដឹងទាំងអស់ ដូចជាទូលបង្គំបានមើលឃើញគ្រាប់
លំអ (កិនសោកា) នៅឲ្យដឹកៀព្រះនាងកាណុមតីដូច្នោះដែរ" ។ ព្រះ
មហាក្សត្រិយ៍ដល់ទ្រង់ព្រះសណ្ឋាប់ នូវពាក្យក្រោយបង្អ់ស់ក៏មានព្រះ
បន្ទូលហៅ "លោកគ្រូសារទាន្ទ ។" ហើយទ្រង់ក៏បើកវាំងនន្យើង
រួចទ្រង់សរសើរសំណាងព្រះរាជបុត្រ ដែលបានចួបលោកគ្រូសារទាន្ទ ។
ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជឧត្តារសរសើរ ជាយ៉ាងក្សោះក្សាយ
ចំពោះព្រះរាជទីប្រឹក្សាថា "ព្រះរាជទីប្រឹក្សា! លោកជាមហាបុរស,
យើងត្រូវទុកលោកជាអ្នកមានគុណជាយ៉ាងវិក្រលែង ដោយលោកបាន
ឲ្យជីវិតដល់លោកគ្រូនឹងព្រះរាជបុត្រយើង" ។

ទុគ្គតបុរសកាលបានថ្វែងរឿងនេះថ្វាយព្រះមហាក្សត្រិវិក្រមទិត្យចប់
ហើយទើបក្រាបទូលថា "មហារាជ, សូមព្រះអង្គទ្រង់ជ្រាបថា អ្នកណា
មួយសេពគប់នឹងបុគ្គលសប្ឋុរសអ្នកនោះតែងបានប្រយោជន៍ជាអនេកប្ឋ-
ការ" ។

ព្រះមហាក្សត្រិយ៍វិក្រមទិត្យ ទ្រង់ព្រះសណ្ឋាប់នូវសុន្ទរកថា
ដែលព្រាហ្មណ៍នេះពោលហើយ ទ្រង់មានព្រះរាជហ្ជុទ័យសោមនស្សពន់
ពេក ហើយទ្រង់បូជាប្រាក់ដប់លានប៉ាកូដ (កហាបណ) ដល់
ព្រាហ្មណ៍នេះ ។ ទុគ្គតបុរសទទួលព្រះរាជអំណោយហើយ ក៏វិល
ត្រឲ្យប់ទៅគេហដ្ឋានវិញ ។

ព្រះបាទវិក្រមទិត្យ ទ្រង់មានព្រះរាជឧត្តារទៅកាន់រាជកោដ្ឋាគារិក

អគ្គហ៊ិរញ្ញិកថា "បើមានសូមយាចកមកក្នុងទីនេះ ឲ្យលោកចំណាយជ្រាក់មួយពាន់ជ្យ៉ាកូដប្រគល់ឲ្យជាទានកុំខាន; លោកឲ្យមួយម៉ឺនជ្យ៉ាកូដ ចំពោះពួកទុគ្គតបុរសណាដែលគ្រាន់តែសូម, ដប់ម៉ឺនជ្យ៉ាកូដ ចំពោះពួកទុគ្គត-បុរសណាជ្យានថ្ងៃងរឿងដែលមាននៅក្នុងសាស្ត្រ:; លុះត្រាតែមានបង្ហាប់ពីយើង ទើបលោកឲ្យដប់លានជ្យ៉ាកូដជ្យាន" ។

រូបទេពនិម្មិតទី ១ ពោលបន្ទែមថា: សូមទ្រង់ព្រះមេត្តាប្រោស, សូមទ្រង់ព្រះសណ្តាប់, បពិតព្រះមហារាជភោជ: ទូលព្រះបង្គំជាខ្ញុំជ្យានក្រាបបង្គំទូលនូវព្រះរាជតេជានុភាព, ព្រះមហាសប្ឋុរសធម៌, ព្រះពលភាពនៃព្រះជ្យាទវិក្រមទិត្យ ដូចសំដែងមកនេះ ។ បើព្រះរាជគុណសម្ឋត្តិទាំងនេះ មាននៅចំពោះព្រះអង្គ។អាចនឹងគង់លើបល្ងង្គទិព្យនេះជ្យាន ។

(មានត)

ឧរាទេវពុក

ឧកូនអឺយ អ្នកកើតមកជាមនុស្សហើយ ត្រូវឲ្យមានគុណធម៌ក្នុងខ្លួន បើមិនដូច្នោះទេ កូនឯងមិនប្ងែកអំពីសត្វតិរច្ឆានទ្បើយ ។

មួយទៀត កូនឯងត្រូវរៀនវិជ្ជា បើគ្មានវិជ្ជាទេ កូនឯងក៏មិនខុសអំពីសត្វតិរច្ឆានដែរ ។

យ. អ.

កំណត់ដឹងប្រវត្តិការណ៍

ពិធីចែកព្រហ្មទាន

ដល់សមណនិស្សិតសាលាបាលីជាន់ខ្ពស់,

ក្រោមអធិបតីភាពឯកឧត្តម ឃឹម-ទិត ជាព្រះរាជតំណាង

របស់ពុទ្ធសាសនបណ្ឌិត្យ

កាលពីថ្ងៃទី ៦ កុម្ភៈ ១៩៥៥ នៅយ៉សាលាបាលីជាន់ខ្ពស់ មានធ្វើពិធីចែកព្រហ្មទានយ៉ាងឧឡារិក ដល់សមណសិស្សសាលាបាលីជាន់ខ្ពស់ ដែលប្រឡងកាលពីថ្ងៃទី ១ ខែ កុម្ភៈ ជាប់បានសញ្ញាបត្រចំនួន ៩១ អង្ក នឹងសិស្សដែលប្រឡងជាប់បានឡើងថ្នាក់ប្រចាំឆ្នាំ ១៩៥៥ ពីទី ១-២-៣ ដល់ទី ៤ ចំនួន ៦០ អង្ក ក្រោមអធិបតីភាពនៃឯកឧត្តម ឃឹម ទិត ជាព្រះរាជតំណាងនៃព្រះករុណាជាម្ចាស់ជីវិតលើត្សូង ។

ពិធីបុណ្យនេះ សមាគមមិត្តសាលាបាលិ បានផ្តើមធ្វើឡើងរៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៥០ ដរាបមក ។ គេចាត់ទុកជាកុសលចរិយាមួយដែលជួយឧបត្ថម្ភដល់កិច្ចសិក្សាខាងព្រិះពុទ្ធសាសនា ឲ្យមានវឌ្ឍនភាព កានតែជុះជាលឡើងក្នុងប្រទេសកម្ពុជា ។

ចាប់តាំងពីម៉ោង ១៦-៣០ នាទីទៅ គេឃើញឯកឧត្តមឡេង-ដ៉ីតនាយករដ្ឋមន្ត្រី, ឯកឧត្តមប្រាក់-ប្រាត្រៀង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងការពារលើផ្ទៃប្រទេស, ឯកឧត្តមម៉ី-នរសីហ៍ រដ្ឋមន្ត្រីក្រសួងធម្មការ, សមាជិករាជរដ្ឋាភិបាល, លោកឯកអគ្គរាជទូតអង់គ្លេស-ជប៉ុន នឹងលោក

ភ្ញៀវជាហូត់កុម្មីស្សែរ ប្រទេសថៃកំណើត ប្រចាំប្រទេសកម្ពុជា បានអញ្ជើញទៅ ។ ក្នុងពេលជាបន្តាប់មកទៀត គេឃើញព្រះសង្ឃគឺសម្តេចព្រះធម្មលិខិតឧត្តមប្រីក្សា, ព្រះអរិយកសម្បៈអ៊ុច ជាតំណាងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ, ព្រះពោធិវ័ង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់, ព្រះមហាព្រហ្មមុនី អ៊ូ ចាងហ្វាងវិនិច្ឆ័យព្រះសង្ឃជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ព្រមទាំងឧបាសក ឧបាសិកាជាពុទ្ធបរិស័ទច្រើននាក់ បាននិមន្តបានយាងអញ្ជើញទៅជាអធិបតីកិច្ចពិធីបុណ្យនេះ ។

ទៅមោង ๑๗ ឯកឧត្តម ឃឹម ទិត ជាព្រះរាជតំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូងអញ្ជើញទៅដល់, លុះគោរពក្រងជាតិរួចហើយ ឯកឧត្តមអញ្ជើញទៅអង្គុយលើកៅអី ដែលគេបានរៀបតាក់តែងជូនជាកិត្តិយសកងយ៉ាសាលាបាលីជាន់ខ្ពស់ ។

ពេលក្រោយក្រៀវ ដែលបាននិមន្តអញ្ជើញទៅជួបជុំហើយ លោកយ៉ាយ-ប៊ុក ប្រធានសមាគមមិត្តសាលាបាលី ក៏បានសូត្រសុន្ទរកថាមួយ អធិប្បាយអំពីកំណើតនៃពិធីបុណ្យត្រហ្មាន និងប្រយោជន៍នៃសមាគមមិត្តសាលាបាលី ដែលបានឧបត្ថម្ភការសិក្សាខាងព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងទៅតាមសមត្ថភាពរបស់សមាគមនេះ ។ បន្តាប់មក ព្រះតេជព្រះគុណព្រះពោធិវ័ង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ បានសូត្រសុន្ទរកថាមួយ អធិប្បាយអំពីកិច្ចសិក្សាខាងព្រះពុទ្ធសាសនាក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីរំលឹកជាស់តឿន

ដល់សិស្សទាំងនោះ ឲ្យកើតមានវិរិយៈនឹងឧស្សាហៈក្នុងការសិក្សាបន្តទៅ
ទៀត ដើម្បីជាប្រយោជន៍ដល់ខ្លួននឹងព្រះពុទ្ធសាសនា ឲ្យមានវិឌ្ឍនា-
ការទៅមុខជាលំដាប់ ។

ក្រោយដែលចប់សុន្ទរកថាទាំងពីរនេះ មានការប្រគេនព្រហ្មទាន
ដល់ព្រះសង្ឃជាសិស្ស តាមលំដាប់លំដោយ ៖ ព្រហ្មទានទី ១ ដែល
ជាទេយ្យវត្ថុនៃសម្តេចព្រះនរោត្តម-សីហនុ ត្រូវឯកឧត្តម ឃឹម ទិត
ជាព្រះរាជតំណាងប្រគេនដល់ព្រះមហា សម-សុ១ គង់វត្តលង្កា ដែល
ប្រឡងជាប់លេខ ១; ព្រហ្មទានទី ២ ដែលជាទេយ្យវត្ថុនៃព្រះករុណា
ជាអម្ចាស់ជីវិតលើត្បូង ត្រូវលោកឧកញ៉ាហ៊ូត់កុម្មីស៊ីប្រចេសចាំង
ប្រចាំប្រចេសកម្ពុជា ប្រគេនដល់ព្រះមហា ឈឹម មួន គង់នៅវត្ត
ឧណ្ណាលោម ដែលប្រឡងជាប់លេខ ២; ព្រហ្មទានទី ៣ ជាទេយ្យវត្ថុនៃ
សម្តេចព្រះអគ្គមហេសី ត្រូវឯកឧត្តមនាយកវរដ្ឋមន្ត្រីប្រគេនដល់ព្រះ
មហាអិត ៣ គង់នៅវត្តឧណ្ណាលោម ដែលបានប្រឡងជាប់លេខ ៣ ។
ក្រៅពីនេះ ក្រុមចាត់ការពិធីបុណ្យ បានលើកព្រហ្មទានឯទៀតៗ ដូច
ឥស្សរជនខ្មែរនឹងបរទេសឲ្យប្រគេនព្រះសង្ឃជាសិស្សទៅតាមលំដាប់ ។

ដោយចំនួនសិស្សច្រើនពេក រៀលក៏កាន់តែខ្វើច ការចែកព្រហ្ម-
ទាននេះក៏បានផ្អាកសិន ដែលនៅពេលនោះ ឯកឧត្តមជាព្រះរាជតំណាង
បានថ្លែងសង្កថាមួយ ដោយឥតបានព្រាងទុកជាមុនទៅកាន់ព្រះសង្ឃជា
សិស្សទាំងនោះយ៉ាងពីពេះក្បោះក្បាយ ។ ឯកឧត្តមបានមានប្រសាសន៍
អំពីការសិក្សាសាធារណៈក្នុងព្រះពុទ្ធសាសនា ដែលមានវិឌ្ឍនាការរើប ។

តាំងពី ៤០ ឆ្នាំកន្លងមកហើយ មកទល់នឹងសម័យបច្ចុប្បន្ននេះ ដែលមានសេចក្តីរុងរឿងចេះតែដឿនទៅមុខជាលំដាប់ ។ គម្រក ឯកទត្តម អធិប្បាយអំពីការសិក្សាខាងផ្លូវលោកនឹងផ្លូវធម៌ ដែលមានសេចក្តីចំរើនជាបន្តបន្ទាប់គ្នា ហើយជាគំរូល្អដល់បរទេស ។ លុះដល់ម៉ោង ១៧ នឹង ៥៥ ឯកទត្តមក៏បញ្ចប់ ហើយថ្វាយបង្គំលាព្រះសង្ឃអញ្ជើញត្រឡប់ទៅវិញ ។ ឯការចែកព្រហ្មទានក៏ចាប់ផ្តើមធ្វើតទៅទៀត ដែលបានចប់សព្វគ្រប់នៅម៉ោង ១៨,៣០ នាទី កន្លងបរិយាកាសប្រកបដោយសេចក្តីរីករាយជាគំរោភាព ។

តអំពីនេះ យើងលើកយកសុន្ទរកថារបស់សមាគមមិត្តសាលាចាស់នឹងរបស់សាលាចាស់ជាន់ខ្ពស់ មកទុកក្នុងទីនេះ ដូចតទៅនេះ ៖

សុន្ទរកថារបស់សមាគមមិត្តសាលាចាស់

សូមព្រះតេជៈដំកល់រស់លើត្បូង

សូមព្រះពជ្ជាទត្តាបបង្គំទូលព្រះកុរណាជាអម្ចាស់ដ៏វិតលើត្បូង សូមទ្រង់ជ្រាបក្រាមល្អឯងចូលីព្រះចាត ។

កន្លងមកនៃសមាគមមិត្តសាលាចាស់ ទូលព្រះបង្គំជាខ្ញុំសូមថ្វាយសេចក្តីកតញ្ញូ នឹងសេចក្តីគោរពយ៉ាងជ្រាលជ្រៅ ចំពោះព្រះកុរណាជាអម្ចាស់ដ៏វិត ដ៏ទ្រង់ព្រះមហាកុរណាធិគុណ ដែលបានទ្រង់ស្តេចយាងមកជាព្រះពជ្ជាធិបតីភាព កន្លងពិធីចែកព្រហ្មទានទៅពេលនេះ ដើម្បីលើកកិត្តិយសចំពោះសមាគម នឹងធ្វើឲ្យពិធីនេះបានទៅជាទក្ខិណ ។

ការចែកព្រហ្មទានដល់សិស្សសាលាចាស់ជាន់ខ្ពស់ ដែលប្រឡង

ជាប់សញ្ញាប័ត្រ ទាំងសិស្សដែលប្រឡងជាប់ឡើងថ្នាក់នេះ សមាគម
បានចាត់ចែងធ្វើជាលើកដំបូងនៅឆ្នាំ ១៩៥០ ឥឡូវនេះ ពិធីនេះក៏ក្លាយ
ជាប់ទៅជាប្រពៃណីមួយផ្នែកក្នុងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា
តទៅអនាគត ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនាដែលកំពុងតែល្បីរន្ទឺខ្ចរខ្ចាយ
ពេញសាកលលោកទៅហើយ ឲ្យរឹងរិតតែចំរើនជាកិយ្យោកាពឡើង
ទ្រៀត ព្រមទាំងដើម្បីលើកទឹកចិត្តសិក្ខាកាមកុលបុត្រដែលបានចំព្យាយាម
រៀនសូត្រដរាបដល់បានផលល្អប្រពៃនៃបំណាច់ឆ្នាំសិក្សាម្តងៗផង ។

បពិត្រព្រះសម្មតិទេព ! សមាគមមិត្តសាលាបាលីនេះ តាំងពីចាប់
កំណើតមកមិនទាន់បានរឹងជំហរ ដោយកោគទ្រព្យនៅឡើយទេ ដោយ
ប្រាក់ចំណូលក្នុងមួយឆ្នាំ ។ ដែលបានមកពីកាគទានប្រចាំខែស្ពួចស្ពើង
ពន់ពេក ប៉ុន្តែ ទោះបីស្ពួចស្ពើងយ៉ាងណា ក៏សមាគមនៅតែចំត្រជរបំ-
ពេញសកម្មកាពរបស់ខ្លួន ដែលល្មមកម្លាំងធ្វើទៅបានពល់តែឆ្នាំពុំដែល
អាក់ខាន ។ ដែលសមាគមបំពេញសកម្មកាពបាន ក៏ដោយសារព្រះ
ករុណាជាអម្ចាស់ជីវិត បានទ្រង់សព្វព្រះពជប្រហាទ័យប្រោសព្រះពជ-
ទានព្រះពជទ្រព្យជាអំណោយ នឹងដោយសារសេចក្តីសប្បុរសរបស់
អស់លោក - អ្នកជាពុទ្ធបរិស័ទជួយជាកម្លាំង យកមកជ្សំនឹងប្រាក់របស់
សមាគមបន្ថិចបន្ថួចផង ។

សកម្មកាពដែលសមាគមបានបំពេញក្នុងឆ្នាំ ដែលកន្លងទៅហើយ
នោះ មានជូច្នេះជាដើម គឺ ៖

៦ - ទំនុកបំរុងសមណនិស្សិតដែលនិមន្តទៅ បន្តវិជ្ជានៅប្រទេស
នេបាល់ ជាមួយនឹងពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ;

៧ - ធ្វើបុណ្យផ្ការយកកម្រៃទៅជួយសាងសង់វិហារមួយខ្នងសម្រាប់
ព្រះសង្ឆក្នុងព្រះពុទ្ធសាសនា នៅក្រុងវ៉ាស៊ីងតុនប្រទេសអាមេរិក ជា
នៃមួយនឹងពុទ្ធិកសមាគមកម្ពុជរដ្ឋ,

៣ - រៀបទទួលជាកិត្តិយសចំពោះព្រះពុទ្ធរូបពីរព្រះអង្គជាវិការ:
មាស នឹងភ្ជុកដែលពុទ្ធបរិស័ទនៃប្រទេសភូមា នឹងថៃ បានឧទ្ទិសបូជា
ចំពោះប្រទេសកម្ពុជា;

៤ - បញ្ជូនសមណនិស្សិត ៣ រូបឲ្យទៅបន្តវិជ្ជាព្រះពុទ្ធសាសនា
នៅវិជ្ជាស្ថាននាលន្ទាប្រទេសឥណ្ឌា ក្រោមការឧបត្ថម្ភដោយអាហា-
រូបករណ៍នៃវិជ្ជាស្ថាននេះ ។

ទើបនឹងខ្ទល់ខ្ទាយបញ្ជូនសមណៈនិស្សិតទៅនៅពេលថ្មីៗ ជួនពេល
ត្រូវចែកព្រហ្មទានក៏លូនចូលមកជល់ទៀត ម្ជុ៉ះហើយសមាគមត្រូវតែ
ប្រឹងក្រោកឈរបំពេញការណីយកិច្ចដែលខានពុំបាន ដោយការអំពាវនាវ
ដល់កម្ចាំងរបស់អស់លោក អ្នកសប្ឈុរសមានព្រះករុណាជាអម្ចាស់ជីវិតជា
ដើម សូមទ្រង់ជួយនឹងជួយទំនុកបំរុង ។ សេចក្តីអំពាវនាវរបស់សមាគម
ក៏បានទទួលនូវលទ្ធផលដ៏ល្អជូចប្រាថ្នា ។ សមាគមមិត្តសាលាបាលី
សូមធ្វៀតឧកាសនេះ ថ្វែងសេចក្តីកតញ្ញូចំពោះព្រះករុណាជាអម្ចាស់ជីវិត
ព្រមទាំងអស់លោក - អ្នកដែលបានបរិច្ចាគធនធាន ដើម្បីជួយជាកម្ចាំងឲ្យ
ចាត់ចែងពិធីនេះបានជូចបំណង ជូចមានទេយ្យវត្ថុត្រៀបត្រាខ្ចប់ដោយ

ក្រែងសំលេចពណ៌ នៅលើតុនេះ គួរឲ្យចាប់ចិត្តជាកស្តីតាងស្រាប់ ។

មុននឹងបញ្ចប់សុន្ទរកថានេះ ខ្ញុំលោកព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាប្រោស ព្រះបរមរាជវរោកាស សំណេះសំណាលជាមួយនឹងសមណៈដែលត្រូវបានវត្ថាន់នេះ ។

បពិត្រព្រះសមណសិស្សទាំងឡាយ! នៅពេលដែលសេចក្តីចំរើនរបស់វិទ្យាសាស្ត្រធ្វើឲ្យផែនដីរួញចូលគ្នា ឲ្យមនុស្សត្រាច់ចរកាន់គ្នាបានយ៉ាងឆាប់រហ័ស ខុសពីសម័យបុរាណនេះ យើងខ្ញុំទាំងឡាយនឹកសង្ឃឹមទៅអនាគតថា ព្រះពុទ្ធសាសនានឹងបានបញ្ចេញមុខផ្សព្វផ្សាយ ក្នុងលោកយ៉ាងធ្ងន់ធ្ងរ ដូចមានពុំខាន ព្រោះ ៖

១ – ពុទ្ធិកសមាគមពិភពលោក នឹងចាត់ធម្មទូតឲ្យទៅផ្សាយអនុត្តរធម៌ព្រះសម្មាសម្ពុទ្ធទៅប្រទេសដទៃទៅពេលឆាប់ៗ នេះហើយ ។

២ – នៅប្រទេសយើងបានបង្កើតឲ្យមានមហាវិទ្យាល័យព្រះពុទ្ធសាសនាជាគ្រឹះស្ថានសិក្សាជាន់ខ្ពស់ ដែលនឹងបើកទ្វារឲ្យសិក្ខាកាមកុលបុត្រចូលរៀនទៅពេលឆាប់ៗ នេះ ។

ដូច្នេះ ដើម្បីកិត្តិយសចំពោះព្រះពុទ្ធសាសនានឹងការប្រព្រឹត្តទៅនៃអនាគតពុទ្ធិកមហាវិទ្យាល័យនេះ, សមាគមមិត្តសាលាជាលីសូមអង្វរព្រះទ័យ ចំពោះលោកម្ចាស់អង្គណា ដែលមានសុខភាពល្អមានឱកាសរៀនសូត្រទៅមុខទៀតបានទោះ ឲ្យអត់ធ្មត់បំពេញប្រយោជន៍ដ៏ខ្ពង់ខ្ពស់នេះតទៅទៀត ហើយទៅអនាគតបើសមាគមមានកម្លាំងល្មមគ្រប់គ្រាន់បានកំមុខជាមិនរួមលំណាំកង្វះខាតគ្រួនេះសោះឡើយ ។

នៅអាសាននេះ សមាគមមិត្តសាលាចាស់ សូមគុណព្រះរតនត្រ័យជួយឧបត្ថម្ភព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់គង់នៅជាសុខក្នុងសេរីរាជសម្បត្តិព្រមទាំងព្រះរាជវង្សានុវង្ស, សូមគេជានុគាពនៃព្រះរតនត្រ័យរក្សាព្រះពុទ្ធសាសនាព្រមទាំងពុទ្ធមាមកជន ទោះនៅប្រទេសកម្ពុជាក្តី នៅកន្លែងពិភពលោកក្តី ឲ្យប្រកបតែនឹងសេរីសួស្តីជយមង្គលគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

សុន្ទរកថារបស់សាលាចាស់ជាន់ខ្ពស់

សូមចំរើនពរឯកឧត្តម ជាព្រះរាជតំណាងព្រះករុណាជាអម្ចាស់ជីវិត !

សូមថ្វាយបង្គំដោយគោរពចំពោះសម្តេច !

សូមថ្វាយព្រះពរទ្រង់ !

សូមចំរើនពរឯកឧត្តមនឹងអស់លោកទាំងឡាយ !

អាត្មាភាពជាតំណាងបុគ្គលិកទាំងអស់ក្នុងសាលានេះ មានអំណរដ៏ក្រៃលែងចំពោះឯកឧត្តមជាព្រះរាជតំណាង ចំពោះសម្តេច, ទ្រង់; ឯកឧត្តមនឹងអស់លោក អ្នកទាំងឡាយ ដែលបានអញ្ជើញមក និមន្តមកស្តេចមកជាអធិបតី ជាកិត្តិយស ទឹងជាមង្គលកុងឧកាសបុណ្យ ចែកព្រហ្មចារីនេះព្រោះទស្សនកិច្ចកន្លងទីនេះ ប្រាកដដូចជាបាននាំយកនូវកិត្តិយសដ៏ខ្ពង់ខ្ពស់នូវសិរីសួស្តីដ៏ប្រសើរ នូវរាជគជ័យដ៏ឧត្តម មកប្រគល់ដល់សាលាចាស់ជាន់ខ្ពស់នេះ ។ កិត្តិយសជាដើមនេះហើយ ដែលនាំឲ្យសាលានេះមានដំណើរទៅកាន់សេចក្តីចំរើន ដោយស្រួលកន្លងអនាគតបាន ។

លំដាប់អំពីនេះ អាត្មាភាពសូមឧកាសចន្លោះ ដើម្បីថ្លែងអំណរចំពោះ

សមាគមមិត្តសាលាបាឡី នឹងដើម្បីគ្រើនរំលឹកប្រស្រ៉យនឹងព្រះសង្ឆជា
និស្សិតនៃសាលានេះ ជូចតទៅនេះ :

• អម្បាញ់មិញនេះ លោកប្រធាននៃសមាគមមិត្តសាលាបាលីបាន
ថ្វែងសេចក្តីអំពីការប្រគេនរង្វាន់ដល់ព្រះសង្ឆជានិស្សិត ដែលទើប
ប្រឡងចេញពីសាលានេះ នឹងសិស្សខ្ទះកំពុងសិក្សាដែលបានពិនុដ
ប្រសើរក្នុងថ្នាក់រៀន ។

ការចែករង្វាន់ជូច្នេះ អាចរាប់បញ្ចូលទៅក្នុងការកុសលដែលនឹងជូន
លទ្ធផលក្នុងបច្ចុប្បន្ននឹងបរលោកបាន ។ សាលាបាលិជាន់ខ្ពស់សូមទទួល
អំណរដ៏ក្រៃលែង ចំពោះសមាគមមិត្តសាលាបាលីដែលផ្តើមធ្វើការកុសល
ជូច្នេះជាច្រើនឆ្នាំមកហើយដោយឥតរួញរា ប៉ុន្តែសមាគមដែលអាចធ្វើ
ជូច្នេះបាន ដោយអាស្រ៉យការទបត្ថម្ភអំពីព្រះករុណាជាអម្ចាស់ជីវិត
អំពីទ្រង់ ឯកទត្តម នឹងឥស្សរជនទាំងឡាយ ព្រមទាំងពួកពុទ្ធបរិស័ទជួយ
ដោយសទ្ធាជ្រះថ្លាផងដែរ ទើបអាចធ្វើកល្យាណកម្មនេះឲ្យសម្រេចបាន ។

សាលាបាលីជាន់ខ្ពស់សូមអរគុណចំពោះសមាគមមិត្តសាលាបាលី
ជាច្រើនអនេក ដោយឃើញថាសមាគមនេះបានបំពេញកិច្ចដ៏ប្រសើរ
ច្រើនយ៉ាង ដែលជាកិច្ចជួយឲ្យកម្ចាំងដល់ការសិក្សាខាងព្រះពុទ្ធសាសនា
មានការចែករត្ថុសម្រាប់សិក្សាដល់សាលាបាលីរងជាង ៤០០ សាលាក្នុង
ព្រះរាជអាណាចក្រកម្ពុជាផង ជួយផ្តើមធ្វើបុណ្យចែកព្រហ្មទានដល់
សិស្សក្នុងសាលាបាលីជាន់ខ្ពស់រាល់ឆ្នាំផង មិនតែប៉ុណ្ណោះ ធ្វៀតឧកាស
ជួយទបត្ថម្ភក្នុងការចាត់ព្រះសង្ឆជានិស្សិតចេញពីសាលានេះ ឲ្យទៅបន្ត

ការសិក្សាក្នុងប្រទេសក្រៅផងទៀត ដូចកាលពីថ្ងៃសុក្រទី ៤ មីនានេះ មាននិស្សិត ៣ រូបបានចេញទៅបន្ត ការសិក្សាក្នុងវិជ្ជាស្ថានបាលី នៅនាលន្ទាប្រទេសឥណ្ឌា, ការចាត់ឲ្យទៅសិក្សានេះជាបន្ទុកនៃសមាគមមិត្តសាលាបាលី ។

ឥពីនេះ សូមរំលឹកប្រស្រ័យដល់ព្រះសង្ឆ ជានិស្សិតនៃសាលានេះ:

អស់លោកជានិស្សិតទាំងឡាយ! ការសិក្សារៀនសូត្រចំណេះវិជ្ជាត្រប់ប្រភេទក្នុងលោកនេះ រមែងដឹកនាំមនុស្សជាតិនឹងពិភពលោកឲ្យមានការប្រែប្រួល ត្រឡប់ពីអាក្រក់ទៅល្អ ពីហានៈថយថោកទៅកាន់ហានៈដ៏ខ្ពង់ខ្ពស់ ពីការល្ងង់ខ្លៅទៅកាន់ការចេះដឹង ដូចយើងបានឃើញនឹងភ្នែកស្រាប់ហើយ, សេចក្តីថ្កំថ្កើង សេចក្តីចំរើនរុងរឿងជាផលបានមកអំពីចំណេះវិជ្ជាៗ បានមកអំពីការសិក្សារៀនសូត្ររបស់មនុស្សក្នុងលោក ។ បណ្តាចំណេះវិជ្ជាទាំងនោះ ការសិក្សាព្រះបរិយត្តិធម៌ នឹងការសិក្សាវិជ្ជាផ្សេងៗ ក្នុងសាលាបាលីជាន់ខ្ពស់នេះមានវិទ្យាសាស្ត្រ បវត្តិសាស្ត្រ គណិតសាស្ត្រ នឹងភូមិសាស្ត្រជាដើម អាចរាប់បញ្ចូលទៅក្នុងចំណេះវិជ្ជាផ្នែក ១ ក្នុងលោកបានដែរ បើចំពោះប្រទេសកម្ពុជាយើងនេះ ជនជាតិខ្មែរយើង ក្នុងអតីតកាលបានធ្លាប់និយមរាប់អានថាជាចំណេះវិជ្ជាជាន់ខ្ពស់បំផុតរបស់ជាតិព្រោះគោលចារិកសំខាន់ៗ នៃវឌ្ឍនធម៌ខ្មែរមានអក្សរសាស្ត្រជាដើម តាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្ឆន្ននេះ រមែងពឹងផ្អែកទៅលើព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ។

អស់លោកជាសិស្សទាំងឡាយ! អស់លោកដែលបានប្រឡងចេញ

ពីសាលាហើយ ខុកជាចប់កិច្ចរបស់លោកក្នុងសាលានេះហើយ ប៉ុន្តែ សូមកុំឲ្យភ័ន្តច្រឡំថា "កិច្ចសិក្សាចំណេះវិជ្ជាចប់ស្រេច ត្រឹមបានទទួលសញ្ញាប័ត្រពីសាលានេះ" ដូច្នេះឡើយ ហើយចោះបង់តំនិត ក្នុងការសិក្សាតទៅទៀត ។ រីឯការសិក្សាក្នុងសាលាថ្មីជាន់ខ្ពស់នេះ កាលបើយកទៅប្រៀបផ្ទឹម នឹងការសិក្សាក្នុងសាលារៀនខាងព្រះពុទ្ធសាសនានៅប្រទេសឯទៀត នៅអនុថយច្រើនជាងគេ ។ ដូចប្រទេសដែលមានព្រះពុទ្ធសាសនាដូចប្រទេសយើងសព្វថ្ងៃនេះ គឺប្រទេសថៃ, កូមា, និងសេរីលង្កា គេបានបង្កើតមហាវិទ្យាល័យ នឹងវិទ្យាល័យខាងព្រះពុទ្ធសាសនាឲ្យមានឡើងជាយូរឆ្នាំមកហើយ ព្រោះប្រទេសទាំងនោះមានឧត្តមគតិដ៏ប្រសើរ ១ យ៉ាង គឺចង់ឲ្យព្រះសង្ឃបានចេះដឹងវិជ្ជាខាងផ្លូវលោកនឹងផ្លូវធម៌ឲ្យមាំមួន ព្រមទាំងភាសាបរទេសផង កាលបើព្រះសង្ឃបានចេះដឹងហើយ នឹងបញ្ជូនព្រះសង្ឃទាំងនោះទៅកាន់នានាប្រទេស នឹងប្រកាសពីព្រះពុទ្ធសាសនា ដើម្បីឲ្យប្រទេសទាំងនោះបានស្គាល់នូវព្រះពុទ្ធសាសនាយ៉ាងជាក់ច្បាស់ ។

សព្វថ្ងៃនេះ ប្រទេសលង្កាកំពុងចាត់ព្រះសង្ឃចេញទៅកាន់ប្រទេសផ្សេង ។, ប្រទេសកូមាក៏កំពុងទំាងបង្កើតវិទ្យាល័យធម្មទូតសម្រាប់ព្រះសង្ឃរៀនសូត្រ ។ ក្នុងវិទ្យាល័យធម្មទូតនៅប្រទេសកូមានោះ សព្វថ្ងៃនេះ មានព្រះសង្ឃខ្មែរជានិស្សិតនៃសាលានេះចំនួន ១១ រូប ឯានចូលទៅសិក្សារួមជាមួយនឹងព្រះសង្ឃកូមា ឯានចេះភាសាកូមា នឹងភាសាអង់គ្លេសយ៉ាងមធ្យមហើយ, គោលបំណងនៃពុទ្ធសាសនសភា

នៅប្រទេសកូមាដែលមានរដ្ឋាភិបាលជួយឧបត្ថម្ភ ប្រាថ្នានឹងឲ្យព្រះសង្ឆ
ដែលរៀនក្នុងវិទ្យាល័យនោះ មានវិជ្ជាគ្រប់គ្រាន់ ល្មមធ្វើជាធម្មទូត
ចេញទៅប្រកាសព្រះពុទ្ធសាសនាក្នុងនានាប្រទេសបាន ។

កុំបាច់ពោលចំពោះប្រទេសដែលមានព្រះពុទ្ធសាសនា យ៉ាង
បរិបូណិ ដូចប្រទេសថៃ, កូមា នឹងលង្ក្រាដូច្នោះទ្បើយ សូម្បីតែ
ប្រទេសតណ្ហៀដែលក្នុងសម័យនេះ មានអ្នកកាន់ព្រះពុទ្ធសាសនាមាន
ចំនួនតិច មានពួកបព្វជិតត្រឹម ២០ ឬ ៣០ រូបប៉ុណ្ណោះ ក៏គេបានបង្កើត
វិជ្ជាស្ថានខាងព្រះពុទ្ធសាសនា ១ នៅនាលន្ទា មានភិក្ខុ ១ រូបឈ្មោះ
កស្សប ជាអធិបតី អាចណែនាំជនអឺ៉ុបឲ្យចូលបួសបានខ្ទះ; វិជ្ជាស្ថាន
នោះ គេបម្រុងនឹងរៀបចំឲ្យទៅជាមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា
ក្នុងពេលយ៉ាងខ្ទីខាងមុខនេះ ។ សព្វថ្ងៃនេះ គេបានផ្សាយដំណឹងទៅ
ក្នុងលោកថា.បើមានអ្នកណាទៅសិក្សាក្នុងសាលានោះ គេនឹងជួយឧបត្ថម្ភ
ដោយអាហារូបករណ៍ផងទៀត ។ សាលានៅនាលន្ទានោះហើយ ដែល
សិស្សសាលាយើងនេះចំនួន ៣ រូបចេញទៅសិក្សាពីថ្ងៃសុក្រមុននោះក្នុង
សេចក្តីឧបត្ថម្ភនៃសមាគមមិត្តសាលាបាលី ។

តាមដំណឹងពីភិក្ខុកស្សប ជាអធិបតីនៃវិជ្ជាស្ថាននោះថា សាលា
សិក្សាព្រះពុទ្ធសាសនានោះ រដ្ឋាភិបាលប្រទេសតណ្ហៀដែលមានលោក
បណ្ឌិតណេរុ ជាប្រមុខជួយឧបត្ថម្ភ ។ ឯរដ្ឋាភិបាលតណ្ហៀមិនមែនជា
ក្រុមអ្នកកាន់ព្រះពុទ្ធសាសនាទេ តែជួយឧបត្ថម្ភក្នុងហានៈជាអ្នកគ្រប់គ្រង
កិច្ចការក្នុងប្រទេស ។

ចំណែកខាងប្រទេសយើងវិញ សម័យបច្ចុប្បន្ននេះ ព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វ្ឋ័ន ទ្រង់ជាអត្តសាស-នូបត្ថម្ភក៍ ទ្រង់សព្វព្រះរាជប្ចហទ័យចង់ឲ្យការសិក្សាក្នុងព្រះពុទ្ធសាសនាមានជំណើរលឿនទៅមុខ ឲ្យសមតាមកាលៈទេសៈ ដើម្បីកុំឲ្យអន់ថយជាងប្រទេសនានា ដែលកាន់ព្រះពុទ្ធសាសនាជូចគ្នា ទើបទ្រង់មានព្រះរាជបញ្ជាឲ្យក្រសួងធម្មការ (កាលឯកទត្តម សម-ញាណ ជារដ្ឋមន្ត្រី) ចាត់ការពិនិត្យ ព្រមទាំងរៀបចំការសិក្សាខាងព្រះពុទ្ធសាសនា ឲ្យមានសេចក្តីចំរើនឡើងជូចប្រទេសជិតខាង ។ ក្រសួងធម្មការក៏បានចាត់ការរៀបចំកែប្រែការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់ ព្រមទាំងបង្កើតឲ្យមានការសិក្សាជាន់ខ្ពស់ឡើងទៀត គឺបង្កើតឲ្យមានមហាវិទ្យាល័យ ខាងព្រះពុទ្ធសាសនា មាននាមថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។ មហាវិទ្យាល័យនេះ កើតឡើងដោយព្រះរាជក្រមលេខ ៨៧៩ ន. ស. ចុះថ្ងៃទី ១ កក្កដា ១៩៥៦ ។

មហាវិទ្យាល័យនេះ សព្វថ្ងៃពុំទាន់បានបើកទ្វារបញ្ចូលសិស្សឲ្យរៀននៅឡើយទេ ដោយមានការរៀបចំពុំទាន់ហើយស្រេច ។ ព្រះករុណាជាអម្ចាស់ជីវិត កាលក្រោយដែលទ្រង់លាលះរាជសម្បត្តិហើយបាន ៦-៣ ថ្ងៃ ទ្រង់នៅមានព្រះរាជហប្ចទ័យប្រារព្ធមកំលើពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះឲ្យមានជំណើរទៅមុខ ទើបទ្រង់ប្រោសព្រះរាជទានប្រាក់ ១ លាន ៥ សែនរៀល ក្នុងការកសាងគ្រឹះស្ថានឲ្យបានគ្រប់-គ្រាន់ ។ ឯគ្រិះស្ថានដែលកំពុងសង់សព្វថ្ងៃ គឺឧបាសកមេ-ហាធ

អ្នកជំនួញមានសទ្ធាជ្រះថ្លាចំណាយធនធានរបស់ខ្លួនកសាង ដើម្បីឧទ្ទិស
ចំពោះព្រះពុទ្ធសាសនា ជូនដល់ព្រះរាជរដ្ឋាភិបាលឲ្យចាត់ចែងជាកន្លែង
សិក្សានៃពុទ្ធិកមហាវិទ្យាល័យតទៅ ។

មហាវិទ្យាល័យនេះហើយ ដែលបម្រុងខ្លួនចាំទទួលអស់លោកជា
និស្សិតទាំងឡាយ ដែលចេញពីសាលានេះឲ្យសិក្សាតទៅទៀត ។
ដូច្នេះ សុំឲ្យអស់លោកទាំងឡាយតាំងចិត្តព្យាយាមឲ្យមាំមួន ក្នុងការបន្ត
កិច្ចសិក្សាទៅទៀត ។ សុំឲ្យអស់លោកតាំងចិត្តអាណិតខ្លួន កុំឲ្យខ្លួន
អន់ថយដោយចំណេះវិជ្ជា, អាណិតព្រះពុទ្ធសាសនា កុំឲ្យព្រះពុទ្ធសា-
សនាទន់ខ្សោយ ដោយខ្លះខាតអ្នកចេះដឹង, អាណិតប្រទេសជាតិ កុំឲ្យ
ប្រទេសជាតិខ្លះខាតបព្ចជិតដែលមានចំណេះវិជ្ជាច្រើន ។ សុំឲ្យអស់-
លោកទាំងឡាយតាំងចិត្តអធិដ្ឋានដំកល់ព្យាយាម ឲ្យរឹងបឹងក្នុងការសិក្សា
វិជ្ជាផ្ទូរសាសនា នឹងផ្ទូរលោកតទៅទៀត ឲ្យត្រាតែបានសម្រេច កុំអាល
ប្រាះបង់ចោលការសិក្សាទៅមុខ ត្រូវយកតម្រាប់តាមព្រះបរមត្រូនៃយើង
កាលដែលព្រះអង្គនៅជាព្រះបរមពោធិសត្តមាននាមថា មហាជនក: ព្រះ
អង្គបានស្រែកប្រកាសក្នុងមហាសមុទ្រចំពោះទេវតាថា "ក្រើតមកជា
ក្លូនប្រុស ត្រូវតែខំព្យាយាមត្រាតែបានសម្រេចប្រយោជន៍" ។

អស់លោកជាសិស្សទាំងឡាយ! ខ្ញុំសូមរំលឹកជាថ្មីម្តងទៀត សូម
លោកជាសិស្សទាំងឡាយ កុំបីមានតំនិតតិតថា ការជ្រោមជ្រែងព្រះ
ពុទ្ធសាសនា ឲ្យចំរើនរុងរឿងឲ្យធំទូលាយឡើង ទុកឲ្យអស់លោក

ឯទៀត ៗ ចុះ ប្រសិនបើគិតដូច្នេះតែទាំងអស់គ្នា តើបព្វជិតរូបណានឹងនៅ ទ្រទ្រង់ព្រះពុទ្ធសាសនាទៅមុខ? ព្រោះព្រះពុទ្ធសាសនាក្នុងអនាគត មានសង្ឃឹមដោយច្រើន ចំពោះលើអស់លោកជានិស្សិតកេទបព្វជិត ជាអ្នករៀនសូត្រ បានចេះដឹងវិជ្ជាខាងព្រះពុទ្ធសាសនាទាំងនេះហើយ, ព្រោះ បព្វជិតទោះបីមានចំនួនច្រើនរាប់ពាន់រាប់ហ្វឹន ប៉ុន្តែបើឥតមានចំណេះវិជ្ជា ឥតមានសណ្ឌាប់ធ្នាប់ល្អ ឥតមានការប្រព្រឹត្តត្រឹមត្រូវ ឥតមានការរៈវាងវៃ ជាបព្វជិតពុំសូវមានតម្លៃ មិនគួរដល់ការទទួលយកនូវសេចក្តីគោរពរាប់ អានអំពីមហាជន, តើបព្វជិតទាំងនោះប្ត ដែលអាចជួយជ្រោមជ្រែង ព្រះពុទ្ធសាសនាក្នុងអនាគត? ឃើញថាជួយជ្រោមជ្រែងពុំកើតទេ ។

ហេតុនេះ សុំឲ្យអស់លោកជានិស្សិតទាំងឡាយ ខំគិតរំពឹងពិចារ-ណាឲ្យវែងឆ្ងាយ, ផ្ទើចិត្តឲ្យធ្ងន់ឲ្យនឹងធឹងហើយខំសិក្សាចំណេះវិជ្ជាឲ្យ បានចេះដឹង ឲ្យបានសមល្មមជាទីពឹងជាបង្អែកនៃពុទ្ធសាសនិកជនទួទៅ ។

ក្នុងអវសានកថានេះ អាត្មាកាពសូមសំបូងសង្រូងគុណព្រះស្រី រតនត្រ័យ សូមឲ្យជួយអភិបាលរក្សាព្រះករុណាជាអម្ចាស់ជីវិត សូម ព្រះអង្គបានប្រកបដោយជោគជ័យសុវត្ថិមង្គលគ្រប់ប្រការ សូមបាន ប្រកបដោយព្រះជន្មាយុយឺនយូរ ស់កាលជាអង្រូង, ទាំងសម្តេច, ទ្រង់, ឯកឧត្តម, ព្រះតេជព្រះគុណនូវអស់លោក - អ្នកទាំងឡាយជាពុទ្ធ-បរិស័ទទួទៅ ក៏សូមឲ្យបានប្រកបដោយសេចក្តីសុខសេចក្តីចំរើន អស់ កាលជានិរន្តរ៍កុំបីអាក់ខានឡើយ ។

ពិធីបុណ្យបូជាសពលោកគ្រូ ចិន-ទិត

ចៅអធិការវត្តបឹងវ៉ៃ ឃុំក្រោលគោ ខេត្រស្វាយរៀង

លោក ញ៉ែម-ទឹម

លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

កាលពីថ្ងៃ ១-២-៣ រោច ខែផល្គុន ឆ្នាំមមីធស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៩-១០-១១ មីនា ១៩៥៥ មានធ្វើពិធីបុណ្យបូជាសពលោកគ្រូ ចិន-ទិត ជាចៅអធិការវត្តបឹងវ៉ៃ ឃុំក្រោលគោ ខេត្រស្វាយរៀង ដែលអនិច្ចធម្មពីថ្ងៃ ៣ កើតខែអស្សុជឆ្នាំមមីធស័ក ព ស ២៤៩៧ ក្រោមអធិបតីភាពនៃព្រះតេជព្រះគុណព្រះឧបាលិវង្ស សូរ-ហាយ វត្តឧណ្ណាលោម ភ្នំពេញ ។

ពិធីបុណ្យនេះ មានចាត់ជាគណៈកម្មការ ៧ ក្រុម ដើម្បីជាការស្រួលក្នុងកិច្ចកុសលដ៏ធំនេះ គឺគណៈកម្មការផ្គត់ផ្គង់ទឹក ១ គណៈកម្មការភោជន ១ គណៈកម្មការភេសជ្ជៈ ១ គណៈកម្មការអុជចង្កៀង ១ គណៈកម្មការទទួលភ្ញៀវគ្រហស្ថ ១ គណៈកម្មការទទួលភ្ញៀវព្រះសង្ឆ ១ គណៈកម្មការអគ្គានុរក្ស ១ ។ ក្នុងគណៈកម្មការមួយៗ មានសមាជិក ៥ នាក់ខ្ទះ, ១០ នាក់ខ្ទះ, ១៥ នាក់ខ្ទះ ។

ខ្ញុំជាសិស្សម្នាក់ នៃលោកគ្រូព្រះសពអង្គនេះ ប៉ុន្តែខ្ញុំនៅរៀនសូត្រឯក្រុងភ្នំពេញ បានទៅធ្វើបុណ្យនោះដែរ ។ កាលខ្ញុំចុះពីរថយន្តភ្លាមក៏ដើរចូលទៅក្នុងវត្តក្រោមកំដៅនៃព្រះអាទិត្យ បានឃើញក្លាងទ្វារ

វត្តរចនាដោយស្ថឹករុក្ខជាតិផ្សេង ៗ មានផ្ទាំងសំពត់សស្ត្ថុសសន្ធឹងពីលើ
ស៊ុមស្ថឹកឈើ ចារឹកដោយអក្សរធំ ៗ ថា បុណ្យបូជាព្រះសពព្រះនាម
បិន-ទិត ។ នៅអមក្នោងទ្វារនោះ មានទង់ជាតិនឹងទង់ពុទ្ធសាសនា
កំពុងតែបក់រវិច ៗ រកត្នាតាមជំនោរខ្យល់បក់ ហាក់ដូចជាឲ្យសញ្ញា ដល់
អ្នកមកបុណ្យថា "ប្ងូរយើងបំពេញសេចក្ត្តីល្អឲ្យហើយ ទាន់
មានជីវភាពនៅឡើយ! យើងកុំសប្ប្យ ក្នុងផ្ទូវកាមគុណ
ពេក! យើងកុំភ្លេចព្រះពុទ្ធសាសនា!" ។

នៅក្បែរខាងផ្ទូវចូលទៅវត្ត មានរានតូច ៗ អមផ្ទូវរៀបតម្រង់ជួរគ្ឆ
ឲ្យល្អមើលណាស់ ។ ពួករាននេះជាកន្ទែងលក់ផ្ទូរបស់អ្នកជំនួញវ្ទែ
ដែលកំពុងរៀនរកស៊ីលក់ផ្ទូ នាំគ្នាអង្ត្ថុយរហង់លក់នំចំណីទឹកកក ទឹក
ក្រូចជាដើម ។

បន្ទាប់ពីនោះមក ខ្ញុំក៏ដើរចូលបន្ទិចម្ត្ថង ៗ ដល់ទៅក្នុងវត្ត ដោយ
សេចក្ត្តីគោរព នឹងសេចក្ត្តីរីករាយចំពោះបុណ្យជាអនេក ព្រោះឃើញ
ទីវត្ត្ថស្អាតល្អ ទាំងការរៀបចំក៏ប្ងែកអស្ចារ្យ, មនុស្សប្រុសស្រីតូចធំ
ត្រៀបត្រាមីរដេរជាស ។ នៅត្រប់មាត់ទ្វារកុដិនឹងរោងបុណ្យ សុទ្ធតែ
ប្រជាប់ដោយទង់ជាតិ, ទង់ព្រះពុទ្ធសាសនា, ផ្ការ៉ាវ្ទីនឹងស្ថឹករុក្ខជាតិ
ដែលគេចងស្រោបត្រប់សសរបាកំកំពូលនឹងរោងបុណ្យ មានពណ៌ឱ្យ
ស្រងាត់ជាលំអគ្ឆ្លរទស្សនានៃប្រជាជន ។ នៅទិសទាំង ៨ នៃវត្តបឹងរៃនេះ
សុទ្ធតែមានផ្ទាំងសំពត់បិទអក្សរធំ ៗ ដែលជាពុទ្ធភាសិតយ៉ាងពីរោះ ៗ ។

ការរៀបចំបុណ្យបូជាព្រះសពនេះ មានរបៀបល្អណាស់ជាងទីឯ-
ទៀតដែលខ្ញុំធ្លាប់បានឃើញ ។ លំអអាវមដោយការរៀបចំនេះ ជា
ទស្សនីយភាពនៃខ្ញុំដោយទ្បែកហើយ ប៉ុន្តែពុំមែនតាំងខ្ញុំប្រែកចិត្តនឹក
ស្លើចប៉ុន្ទានទេ គឺនៅមានទស្សនីយភាពដែលនាំងខ្ញុំចង់មើលហើយ
ចង់មើលទៀតនោះ គឺបាវាំកំពូល (ទីបូជាព្រះសព) នឹងក្តារមឈូស ។
ព្រោះបាវាំកំពូលសង់ក្នុងទីធ្លាធំខាងត្បូងឧបដ្ឋានសាលា មានលំអប្រែក
អស្ចារ្យណាស់ ទាំងក្តារមឈូសក៏ល្អត្រកាលដោយបិទក្បាច់រំលេចរចនា
ផ្កាភ្ញី អំពីក្រុដាសទឹកមាសចាំងពណិផ្ទេក ។ ទាំងគំរបក្តារមឈូសក៏រំលេច
ដោយផ្កាឈើប្រើនពណិ មានភ្ជិនក្រអូបឈ្ងុយឈ្ងប់ឆ្ងរជាទីមនោរម្ស
ដែលបន្ថើតខ្ពស់ត្រដែតនៅក្នុងបាវាំកំពូល ។ លំអដ៏ធើតធាយនៃបាវាំ
កំពូលនឹងក្តារមឈូសនេះកើតឡើងដោយស្នាដៃនៃជាង សុឹម នឹងជាង ជា
ជាឧបាសកវត្តនិរោធរង្សី ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខែត្រ
កណ្តាល ។ បណ្តាជនដែលបានមកទស្សនាបុណ្យនេះ ប្រើនតែលាន់
មាត់សរសើរថា "បាវាំកំពូលនឹងក្តារមឈូសនេះចំជាល្អរុងរឿងមែន" ។
បាវាំកំពូលនោះ មានកំពស់ប្រមាណ ១២ ម៉ែត្រ, មានទ័ពទាយសារពើ
សូត្រនៃបាវាំនោះ ៨ ម៉ែត្រ ៤ ជ្រុង សុទ្ធតែផ្ទើអំពីសំពត់ទេសឯក,
មានក្ងោងទ្វារ ៤, មានសំពត់ចាំងសែង ៤, មានសន្ទិយាក៏ ៤ ដែរ ។
សំពត់ទាំងអស់សុទ្ធតែមានរាយផ្កាយនឹងជរពណិមាស, នៅវេលាយប់
មានរំលេចដោយភ្ជើងអគ្គិសនី ដាក់អំពូលតូច ។ មានពណិ ៥ ព័ទ្ធជុំវិញ
ក្តារមឈូសនឹងបាវាំកំពូល ភ្ជឿងចិញ្ចៃងចិញ្ចាច ។

ម៉ោង ៩ យប់នៃថ្ងៃចូលបុណ្យគឺថ្ងៃ ១ កេចខែផល្គុន ពួក ឧបាសក ឧបាសិកានាំគ្នាមកស្តាប់ព្រះតេនត្រ័យ, សមាទានសីល, និមន្តព្រះសង្ឃចំរើនព្រះបរិត្ត រួចនិមន្តព្រះតេជព្រះគុណព្រះមុនីកោសល វត្តនិកេធរង្សី មេគណខេត្តកណ្តាល ទេសនាធម្មគោរពនឹងធម៌មហាមត្រាស់តាមប្រពៃណីនិយម ។ សំឡេងដែលធ្លាប់តែឮអ្នកភូមិកេងពេលមុនទេសនាលុះដល់ពេលទេសនា ស្រាប់តែស្ងប់ស្ងាត់ឈឹងដោយពុទ្ធបរិស័ទគោរពស្តាប់ធម៌ផង គោរពចំពោះវិញ្ញាណក្ខន្ធនៃព្រះសពផង ។

លុះស្អែកឡើងជាថ្ងៃ ២ កេចខែផល្គុន ពុទ្ធបរិស័ទជិតឆ្ងាយក៏បបួលគ្នាចាត់ចែងយាគូប្រគេនព្រះសង្ឃក្នុងវេលាព្រឹក, លុះដល់ថ្ងៃត្រង់វេចភ្ជាន់សង្ឃទៀត ។ ប៉ុន្តែថ្ងៃ ២ កេចនេះ មានពួក ឧបាសក ឧបាសិកាកាន់តែច្រើនណាស់លើសពីថ្ងៃមុន ព្រោះក្នុងវេលាកន្ត្រៃនៃថ្ងៃ ២ កេចនោះ ត្រូវទេសនាសង្គ្រាយនាគ្រែ ៣ លុះចប់ហើយទើបធ្វើឈាបនកិច្ចបូជាសពជាក្រោយ ។ មុនទឹងទេសនាសង្គ្រាយនា ព្រះតេជព្រះគុណព្រះឧបាលីវង្ស សូរ - ហាយ ថ្លែងសុន្ទរកថាមួយកន្លះកណ្តាលពុទ្ធបរិស័ទពាក់ពាន់ ពណិនាអំពីគុណសម្បត្តិលោកគ្រូព្រះសព ចិន - ខិត ព្រមទាំងថ្លែងខួលអំណរគុណពុទ្ធបរិស័ទដែលជួយឧបត្ថម្ភកិច្ចការកុសលនេះ ។

លុះព្រឹកឡើងថ្ងៃ ៣ កេចក៏មានការប្រគេនយាគូចំពោះព្រះសង្ឃថ្ងៃត្រង់វេកត្តឧទ្ទិសផល ប្រគេនចំពោះវិញ្ញាណក្ខន្ធលោកគ្រូព្រះសព ចិន - ខិត, ព្រមទាំងប្រគេនទេយ្យទានមានសៀវភៅធម៌ទឹងចីវរជាដើម

ចំពោះព្រះសង្ឃ ៦៤ អង្គ តាមជន្លាយុនៃព្រះសព រួចធ្វើបុណ្យ
បង្ហើយក្នុងថ្ងៃ ៣ រោចនោះ ។

សុទ្ធរកថា

ព្រះឧបាលិវង្ស ថ្លែង

ព្រះតេជព្រះគុណាមេគណ, ព្រះចៅពន្ធុត្ថេរៈគាំងឡាយ !
លោកចៅហ្វាយស្រុក ព្រមទាំងអស់លោកជាសហការី !
លោក-អ្នកសប្បុរស ពុទ្ធបរិស័ទទាំងឡាយ !

ពេលនុកាសនេះជាពេលដែលខ្ញុំព្រះករុណា អាត្មាភាពនឹងពុទ្ធបរិស័ទ
ជាសិស្សានុសិស្សនៃព្រះសព ធ្វើមរណៈបុណ្យបូជាសពនៃលោកគ្រូចៅ
អធិការវត្តបំនីវ៉ែនេះ តាមប្រពៃណីរបស់ពុទ្ធសាសនិកជន ។

នៅពេលរៀបចំពីធីបូជាសពនេះ ជានប្លែកបុណ្យកន្ទុំងមកមួយ
យប់ហើយ ។ ក្នុងរយៈវេលាយប់ពីនេះ នឹងបូជាព្រះសពព្រមទាំង
ទេសនាសង្គាយនា ។ ឥឡូវនេះ ព្រះតេជព្រះគុណាមេគណនឹងលោក
ចៅហ្វាយស្រុក, អស់លោកជាសហការី ជានធ្វើតរកនុកាសល្អ និមន្ត-
អញ្ជើញមកដួយបំពេញកិច្ចបុណ្យ ដើម្បីជាកិត្តិយសនៃបុណ្យផង ដើម្បី
សំដែងមិត្តភាព សាមគ្គីភាពក្នុងរវាងប្រជាជននឹងលោក-អ្នកពាជការផង
ដែលតែងតែប្រស័យទាក់ទងគ្នាឲ្យជិតស្និទ្ធ តាំងពីព្រៃងនាយមកហើយ។
រៀលនុត្តប្បុក្ខ ពត្តិទីពីរនេះ ខ្ញុំព្រះករុណា-អាត្មាភាពសូមថ្លែងវិរៈយោគ
(ការព្រាត់ច្បាស) នឹងការទទួលអំណរក្នុងនាមនៃពុទ្ធបរិស័ទ ចំពោះ

លោកបៅហ្ចាយ នឹងអស់លោក - អ្នកទាំងឡាយ ជួបសេចក្តីរៀបរាប់
តទៅនេះ ៖

លោកគ្រូព្រះសពព្រះនាមចិន - ទិតនេះជាបព្ចជិតមួយរូបដែលមាន
សំវរធម៌ គឺការសង្រួមឥន្ទ្រិយល្អហ្មត់ចត់ណាស់ ទាំងមានការពេញចិត្ត
ក្នុងកិច្ចសិក្សាធម៌វិន័យក៏យូរធ្នាំណាស់ហើយ ប៉ុន្តែពេលនេះពុំបានថ្ងៃង
ថេរប្សវត្តិរបស់លោកទៀតទេ ព្រោះមានថ្ងៃងពីយប់ ១ រោច ម្ពងរួច
ហើយ ។

លោកគ្រូព្រះនាមចិន - ទិត អង្គនេះ ជាព្រះថេរ: ស្រគត់ស្រគំ ពុំសូវ
មានមាត់ពាក្យព្ចខ្ចាំងទេ មានពុទ្ធដីកាតិចៗ ជាលក្ខណ:រាចារបស់អ្នកកាន់
វិន័យ ប៉ុន្តែរបៀបកម្រងពាក្យរបស់លោក មានប្រយោគប្រជានរៀប
រៀងត្រូវតាមអក្ខរាវិរុទ្ធមានជើងសម្ពន្ធល្អណាស់, មានពុទ្ធដីកាសុទ្ធតែ
រាចាពិតរាចាមែន មិនដែលនិយាយលេងសើចរឡេះរឡោះទេ ។ ព្រះ
ថេរ:អង្គនេះមានព្រះទ័យធ្ងន់ គំនិតជ្រៅ ឃើញកាលវៃង តាមដែល
ខ្ញុំព្រះករុណា - អាត្មាភាព បានសន្ទនាជាមួយនឹងលោកអំពីហេតុការណ៍
ផ្ទូវលោកផ្ទូវធម៌ជារឿយ ៗ ។ លោកចេះមានពុទ្ធដីកាត្រូវច្រើនជង ច្រើន
កន្ទៃងណាស់ដោយគំនិតលោកមានស្រាប់ ។ កាលពីគ្រិស្តសករាជ
១៩៣៣ គឺធ្នាំដែលខ្ញុំព្រះករុណាអាត្មាភាពប្រឡងចេញពីសាលាបាលី
ជាន់ខ្ពស់ ហើយបានមកឯវត្ត ជួបនឹងលោកក៏លោកមានរាចាសាកសួរអំពី
ការប្រឡងចេញ លុះខ្ញុំព្រះករុណា - អាត្មាភាព ពិតលោកតាមជំណើរ
នៃការប្រឡងហើយ លោកក៏អរណាស់ហើយមានថេរដីកាថា "លោក!

ខ្ញុំសង្ឃឹមលោកណាស់ អំណើះតទៅលោកនឹងបានជាមុខជាមាត់ជាចន្ទល់
នៃព្រះពុទ្ធសាសនាមួយរូប ខ្ញុំនឹកសង្ឃឹមលើលោកហើយ, លោកនៅ
បំរើព្រះពុទ្ធសាសនា ទាំងកេទបព្វជិតអ៊ីចឹងហើយ កុំសឹកទៅបំរើកាមគុណ
ឲ្យសោះ ឯខ្លួនខ្ញុំទោះបីជាបព្វជិតល្ងង់ខ្លៅមែន ប៉ុន្តែជាតិនេះខ្ញុំមិនត្រូវការ
ទៅបំរើកាមគុណទេ ខ្ញុំស៊ូនៅប្រតល់កាយថ្វាយខ្លួនបំរើព្រះសាសនាអស់
មួយជីវិតហើយ " ។ ថេរវាចានេះជាវាចាប្រសើរបំផុតត្រូវល្អណាស់ ។
សង្កេតអំពីបវត្តិការណ៍របស់លោក ឃើញថាលោកមានការប្រព្រឹត្តិធម៌
វិន័យត្រឹមត្រូវពិតមែន ។ ព្រះថេរ:ព្រះនាម ចិន ទិត មានជីវកាពស៊ូ
នៅបំរើព្រះសាសនា ទាំងកេទបព្វជិតទាល់តែសុគតក្រោមទង់ជ័យនៃ
ព្រះពុទ្ធសាសនា; ទាហានពិជ័យសង្គ្រាមដែលលើកទ័ពទៅតទល់នឹង
សត្រូវហើយ ចេះតែលុកចូលរុលទៅមុខមិនព្រមថយក្រោយ ស៊ូស្លាប់
ក្នុងកណ្តាលសមរភូមិបានយ៉ាងណា ព្រះថេរ:អង្គនេះក៏តស៊ូនឹងមច្ចុ-
សង្គ្រាមនៅក្នុងកេទបព្វជិតពុទ្ធសាសនា មិនរួញរាថយក្រោយ ចេះ
តែលុកចូលទៅមុខទាល់តែសុគតក្នុងទីសមរភូមិពុទ្ធសាសនា យ៉ាង
នោះដែរ ។

បពិត្រព្រះសព! ត្រោងកាយទាំងមូលរបស់ព្រះសព នៅក្នុងក្តា
ម្ស្យូសដែលជាងរចនាដ៏ប្រសើរ. បាវាំកំពូលក៏រចនាដ៏វិចិត្រត្រកាលល្អ
អស្ចារ្យណាស់ នេះជាសេចក្តីប្រឹងប្រែងរបស់ពុទ្ធបរិស័ទសិស្សគណ
ដោយសេចក្តីគោរពចំពោះព្រះសពដោយកតញ្ញុកាពនៃសិស្សានុសិស្ស ។
ឥឡូវនេះ យើងខ្ញុំជាពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ តាំងកម្មវិធីបុណ្យ

ឬជាព្រះសពពីរយប់បីថ្ងៃ ទើបឬជាកន្លងវេលានេះហើយ ។ ព្រះសពដែលបានទិមន្តទៅកាន់បរលោកនាយ សុំឲ្យបានសុខ-សប្បាយចុះ សុំកុំមានព្រះទ័យព្រួយឫរម្ភដល់យើងខ្ញុំឡើយ ។

ការងារកន្លងវត្តអាពាមដែលព្រះសពបានគ្រងទុកហើយ ដែលព្រះសពបានបំពេញសកម្មភាពតាំងប៉ុន្មាន យើងខ្ញុំទទួលធានាប់រងតាំងអស់ សុំកុំឲ្យព្រួយគំនិតគិតសារមកគ្រោយវិញ សុំឲ្យព្រះសពគិតតែទៅមុខឲ្យបានសុខសួស្តី ចំរើនទៅចុះ ។

បពិត្រព្រះសព! វិយោគធម៌គឺសេចក្តីព្រាត់ប្រាសកន្លងរៀងព្រះសពនឹងពុទ្ធបរិស័ទសិស្សានុសិស្សនេះតែងមានជាធម្មតា ។ ការព្រាត់នេះជាទីបំផុតហើយ លែងបានជួប លែងបានឃើញគ្នាទៀតហើយ ។ ន! ព្រះសព! កាលបើមានជន្មាយុគង់ទៅទៀតគ្រាន់នឹងបានសិស្សគណប្រគេនវត្តណាមួយ មានចីវរជាដើមដោយផ្លាស់អគ្គិបានភ្លាមៗ ចុះបើទទួលអនិច្ចធម្មបាត់ឈឺទៅហើយ តើនឹងអាចប្រគេនផ្លាស់ដូចម្តេចកើត? ការណីនេះ មានតែផលនៃបុណ្យកុសលដែលយើងខ្ញុំបានបរិច្ចាគធ្វើបុណ្យពេលនេះ មានប្រជាប់បរិក្ខារ ត្រៃចីវរគ្រប់គ្រាន់ប្រគេនចំពោះព្រះសង្ឃ ២៨វត្ត មានព្រះធម្មទេសនាតាំងពីយប់ចូលបុណ្យ ដល់មកយប់នេះទេសនាសង្គ្រាយនា ត្រៃបិ ធ្វើសម្រេចនៅថ្ងៃស្អែកមួយពេលទៀត ។

ផលអាមិសទាន ធម្មទានតាំងនេះ យើងខ្ញុំសូមបង្ហើនដោយគោរពឧទ្ទិសប្រគេនចំពោះទៅព្រះសព សូមព្រះសពទទួលអនុមោទនាយកខ្លួវផលនៃកុសលកម្មនេះដោយបីតិសោមនស្សចុះ ហើយសូមព្រះសព

ប្រមើលមើលមកយើងខ្ញុំដែលនៅហានអាយ ដោយការផ្សាយមេត្តាករុណាដល់យើងខ្ញុំជាពុទ្ធបរិស័ទ សិស្សគណឲ្យបានសុខសប្បាយបំរើនគ្រប់ៗគ្នា ។

នៅទីបំផុតនៃសុន្ទរកថានេះ សូមប្រកាសនូវអំណរគុណដ៏ឧឡារ៏ក ចំពោះព្រះតេជព្រះគុណមេគណ: ចំពោះព្រះថេរានុត្តរ: គ្រប់អង្គ, ចំពោះលោកចៅហ្វាយ ព្រមទាំងអស់លោកអ្នកគ្រប់គ្នា ដែលបេះធ្ងៃតឧកាសនិមន្តអញ្ជើញមកជាអធិបតីជាកិត្តិយសនៃបុណ្យនេះ យើងខ្ញុំមានសេចក្តីត្រេកអរសាទរជាអនេក, សូមជូនបុណ្យកុសលនេះ ឲ្យបានសម្រេចដោយសេចក្តីសុខចំរើនតាំងពីវេលានេះតរៀងទៅ ។

កាលបើអស់លោកអ្នកសប្បុរសខាងគ្រហស្ថទាំងឡាយ មានចិត្តសុន្ទរកថាជូចថ្ងៃងមកនេះហើយ សូមបញ្ចេញនូវរាចាជាកំស្ពុតាងនៃត្រេកអរចំពោះអំណរថា សាធុ ឲ្យព្រមៗទៅហោង ។

រស់ក៏គាប់ ងាប់ក៏ត្លរ

កើតមកជាអង្គប្រុសក្នុងលោក ត្រូវធ្វើឲ្យជាប្រយោជន៍ដល់ជាតិប្រទេសនឹងសាសនា ល្មមជាទិដ្ឋានុគតិនៃជនខាងក្រោយយកតម្រាប់តាមជូច្នេះ ឈ្មោះថា រស់ក៏គាប់ ងាប់ក៏ត្លរ ។

ឃូរ - អ៊ុន

បញ្ជីឈ្មោះនាមចៅអធិការដែលតាំងថ្មី

របស់គ្រុសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៩៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពត-គាត នាមជាយា ឥន្ទជោត កើតឆ្នាំមមី អាយុ ៥៦ វស្សា ២៣ ជា ចៅអធិការវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុយ-ម៉ក់ នាមធាយា ឥន្ទប្បញ្ញា កើតឆ្នាំខាល អាយុ ២៤ វស្សា ៥ ជា គ្រូសូត្រធ្វើ វត្តអំពិលបី ឃុំសំពេង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន ប៉ុន នាមធាយា ធម្មសរ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសា-ពាយ-តុញ នាមធាយា ឥន្ទបញ្ញា កើតឆ្នាំកុរ អាយុ ២៧ វស្សា ៨ ជាគ្រូ សូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឆេង-ជុំ នាមធាយា ឥន្ទត្ថេរ កើតឆ្នាំរកា អាយុ ៦៥ វស្សា ៤៥ ជា ចៅអធិការវត្តខ្ទាប់ ឃុំសឹង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ

ឥន់-ជួន នាមធាយា សុធម្មបញ្ញា កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣៧ ជាគ្រូសូត្រស្ពាំ វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៤៩ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ឥម-សុខ នាមធាយា ជោតត្ថេរ កើតឆ្នាំខាល អាយុ ២៤ វស្សា ៥ ជាគ្រូសូត្រធ្ងន់ វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៥០ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ អ៊ុក-ម៉ម នាមធាយា ធមត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ១១ ជាចៅអធិការវត្តអង្គសូឃ្ងាំង ឃុំជំរះពេន ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៥១ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ហ៊ីង-ចក់ នាមធាយា ឥន្ទត្ថេរ កើតឆ្នាំជូត អាយុ ៥០ វស្សា ២៩ ជាចៅអធិការ វត្តអង្គចង្អេរ ឃុំស្ងា-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៥២ ចុះកាលបរិច្ចទដដែល តាំងលោកគ្រូ តារ-ញ៉ែម នាមធាយា ធម្មជោត កើតឆ្នាំធ្ងូវ អាយុ ៤៩ វស្សា ២៩ ជាគ្រូសូត្រស្ពាំ វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៥៣ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ការ-សុិន នាមធាយា ព្រហ្មត្ថេរ កើតឆ្នាំថោះ អាយុ ៤៧ វស្សា ២៧ ជាគ្រូសូត្រធ្ងន់-ឃុំ-ស្រុក-ខេត្រដដែល ។

(មានត)

ពន្ធបសុទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា គឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែទសភា ឈេទ៥

ព.ស.២៤៩៨ – គ.ស. ១៩៥៥



ធម្ពសន្ទិយា

ទស្សនាវិជ្ជី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ហ្រាះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា — *ទំព័រ*

— វិចារណកថា ..... ពុទ្ធសាសនបណ្ឌិត្យ ៤០៣
— ឈ្នះទ្ធនឯងប្រសើរបំផុត ..... លោក យូរ-អ៊ុន ៤០៨
— វិវាទមូល ..... ព្រះឌបាលិវង្ស មឹង-សែស .. ៤១២
— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម-ស៊ុម ៤២៣

ផ្នែកអក្សរសាស្ត្រ

— កំឡាងនៃសាមគ្គី ..... ព្រះមហា មៅ-ទាន់ ៤៣៤
— រឿងសៅរសោយ (តមក) ..... ព្រះមហាឌត្តមវិជ្ជា ប៊ុង—ប៉ម ... ៤៤៣
— រឿងសាមកុក (តមក) ..... ឌកញ៉ា នូ-កន ៤៥០
— ដំណឹងតាមឡល់ក្នុងកន្ទារៈ (តមក) ... លោក ផេង-ជ្រីវ ៤៥៦
— រឿងបល្ស័ង្កទិព្យ (តមក) ..... លោក ភ៉យ-ប៊ុក ៤៦២

កំណត់នឹងប្រវត្តិការណ៍

— តមនប្សវត្តិ ..... ព្រះមហា ទូត-ទិម ៤៦៩
— បញ្ជីភាយនាមបៅអធិការដែលតាំងថ្មី (តមក) ក្រសួងធម្មការ ៤៧៩

មួយឆ្នាំមាន ១២ ស្យៀវភៅ — ដំឡៃដាវ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

		Page
— Editorial	*Institut Bouddhique*	403
— La maitrise de soi	M. YOU-OUN	408
— Vivadamula	Vén. MENG-SES	412
— Pannasajataka- vol.3 (suite) .	M. CHHIM-SOUM	423

PARTIE LITTERAIRE:

— L'union fait la force	Vén. MAO-KHAN	434
— Le «SAU SOY» ou l'influence saturnienne (suite)	Vén. PEUNG-PAM	443
— Histoire de samkok (suite). .	Oknha NOU-KAN	450
— Le souffle du désert (suite) . .	M. PHENG-CHRIV	456
— Les trente deux récits du Trône (suite)	M. RAY-BUC	462

NOTES ET CHRONIQUES:

— Examen de sortie de l'Ecole de Pali de Soctrang	M. TUOT-TIM	469
— Nomination des nouveaux Chau Adhikars(suite)	Ministère des Cultes . . .	479

Prix d'abonnement annuel (comprenant 12 numéros) 210$00

វត្តបំណែងនៃពុទ្ធសាសនា

ប្រទេសកម្ពុជា ជាប្រទេសដែលបានកាន់ព្រះពុទ្ធសាសនាជាច្រើនសតវត្សរ៍មកហើយ តាំងចាប់ដំណើរមកម្ល៉ឹងម្ល៉ាញ សម្រាប់ប្រទេសខ្មែរតែងបានចាត់ទុកនូវពុទ្ធសាសនាថាជាសាសនាសម្រាប់រដ្ឋដែរ ។ ហេតុនេះ ពុទ្ធជនទាំងឡាយ គួរយកចិត្តទុកដាក់ពិចារណានូវកង្វះត្រង់ភាគច្រើនប្រជាជនខ្មែរ ដើម្បីនឹងខំនាំគ្នាបំពេញព្រះពុទ្ធសាសនាឲ្យបានរុងរឿង កុំឲ្យសាបសូន្យទៅដោយវិធីណាឡើយ ។ គប្បីពិគ្រោះមើលតាមហេតុផលនឹងតាមបែបច្បាប់ដែលលោកអ្នកប្រាជ្ញច្បាប់បានសំដែងទុកមក អំពីមុន ។ ឲ្យយល់ឃើញពិតប្រាកដ កុំបណ្តោយទុកឲ្យកើតទៅជាការវិនាសព្រោះទិដ្ឋិមិនស្របគ្នានោះ គួរឲ្យសាហ៍ព្រះករុណាធ្យាបាយ ដើម្បីសេចក្តីចំរើនដល់ពុទ្ធសាសនាកម្ពុជរដ្ឋទៅអនាគតកាលផង ។

ទិដ្ឋិ ប្រែថា "ដំណើរយល់ឃើញ, សេចក្តីប្រកាន់តាមការយល់" ។ ដំណើរយល់ឃើញត្រូវតាមសភាវធម៌ ហៅថា សម្មាទិដ្ឋិ, ដំណើរយល់ឃើញខុសអំពីគោលធម្មជាតិ ឬសេចក្តីប្រកាន់តាមការយល់ឃើញដែលជាទំនាស់នឹងគោលនៃសេចក្តីពិត ហៅថា មិច្ឆាទិដ្ឋិ ។

ពីនេះសូមអស់លោក-អ្នកពិចារណាតាមខ្ញុំដូចតទៅនេះ ៖

ព្រះពុទ្ធសាសនា មិនមែនជាសាសនាប្រជាមនុស្សឲ្យខ្ជិលច្រអូសដែលមិនហ៊ានតស៊ូនឹងគេទេ ។ រឿងនេះ បើយើងពិចារណាមើលតាម

ប្រវត្តិរបស់ព្រះសម្ពុទ្ធជាម្ចាស់ហើយ កំយើញថាបានថា ព្រះអង្គមានព្រះជាតិជាក្សត្រក្នុងវង្សគោតមសក្យរាជ គ្រងរាជសម្បត្តិនៅក្នុងក្រុងកបិលពស្តុមហានគរ, ព្រះអង្គទ្រង់ជាកំពូលនៃអ្នកចំបាំងដែលធ្លាប់ប្រឡងមានថ្វីព្រះហស្តឈ្នះគេមកហើយ ទ្រង់មានព្រះកាយពលខ្លាំងពូកែ ទាំងមានកម្លាំង ព្រះទ័យមិនខ្លាចសេចក្តីទុក្ខលំបាកក្នុងការលុកលៃផ្សេងឡើយ តែទោះបីព្រះអង្គពូកែឈ្លាសវៃក្នុងការច្បាំងដូច្នោះក៏ដោយ ក៏ព្រះអង្គត្រឡប់មកប្រៀនប្រដៅមនុស្សឲ្យតាំងនៅក្នុងសេចក្តីស្ងប់ មិនឲ្យគំរាមកំហែងបៀតបៀនគ្នាទៅវិញ ។ ព្រះសាស្តាទ្រង់ជាមគ្គុទ្ទេសក៍ បង្ហាញផ្លូវឲ្យយើញថា សីលធម៌ជារបស់មនុស្សមានរស្មីភ្លែត គឺបញ្ញា មិនឲ្យធ្លាក់ខ្លួនទៅជាទាសៈនៃសេចក្តីអន្ទះសា ដោយអំណាចសេចក្តីលោភ សេចក្តីក្រោធ ឬសេចក្តីវង្វេងឡើយ ។ មួយទៀត, ព្រះអង្គទ្រង់ត្រាស់ថា អ្នកជាកំពូលចំបាំង មិនមែនសន្មតយកអ្នកច្បាំងឈ្នះមនុស្សដ៏ទៃរាប់ម៉ឺនរាប់សែននាក់នោះទេ គឺព្រះអង្គទ្រង់សរសើរអ្នកច្បាំងឈ្នះខ្លួនឯង ដោយមិនបណ្តោយខ្លួនឲ្យធ្លាក់ទៅជាទាសៈរបស់កិលេស ដែលដេកគំនៅខាងក្នុងសន្តានចិត្ត ។

មួយវិញទៀត, ព្រះពុទ្ធសាសនា មិនមែនជាសាសនារបស់អ្នកបោកបញ្ឆោតមនុស្សដទៃឲ្យវង្វេងនៅក្រោមអំណាចរបស់ខ្លួនទេ ។ រឿងនេះបើពិចារណាឆៀបមើលដោយល្អិតល្អន់ហើយ កំយើញបានថា ព្រះពុទ្ធជាម្ចាស់មិនដែលប្រៀនប្រដៅនរណា ឲ្យជាទាសៈរបស់នរណាទេ, តែងតែទ្រង់ប្រៀនប្រដៅដួយចមូងមនុស្ស ឲ្យផុតចាកទាសភាពទាំង

ខាងផ្លូវកាយ តាំងខាងផ្លូវចិត្តខ្លួនឯងគ្រប់មនុស្សដោយឥតរើសមុខ ។ ផ្លូវកាយ, ទ្រង់ប្រៀនប្រដៅមិនឲ្យពុទ្ធសាសនិកជនទិញ ឥសៈលក់ឥសៈ, មិនឲ្យកំហែងមនុស្សដែលទន់ខ្សោយជាដើម , ឲ្យមានមេត្តាករុណាអាណិតអាសូរដល់មនុស្សដែលក្រលំបាក, ទ្រង់ប្រដៅឲ្យចេះខ្ចីពីគ្នាឲ្យនឯង មិនឲ្យរវៀរទៅអង្វរករស្រែកសូមអំពីឥតស័ក្តិសិទ្ធិ ដោយមិនបានធ្វើអ្វីឲ្យកើតផល, ឲ្យព្យាយាមធ្វើរបរចិញ្ចឹមជីវិតក្នុងផ្លូវដែលត្រូវ មិនតែប៉ុណ្ណោះថែមទាំងទ្រង់ប្រៀនប្រដៅមិនឲ្យប្រកាន់វណ្ណៈទៀតផង គឺទ្រង់ប្រដៅឲ្យប្រកាន់ការប្រព្រឹត្តិល្អជាគោល ។ អ្នកប្រតិបត្តិយ៉ាងនេះរមែងមិនជាឥសៈនរណាទាំងមិនធ្វើនរណាឲ្យជាឥសៈ ។ ចំណែកផ្លូវចិត្ត, ទ្រង់ប្រដៅមិនឲ្យមនុស្សធ្វើជាឥសៈរបស់កិលេសទាំងប្រភេទល្មោភចង់បានទាំងប្រភេទក្រោធ ទាំងប្រភេទវង្វេងឥតល្អ ។ កាលបើដូច្នេះ គួរឃើញប៉ាន់ថាព្រះពុទ្ធសាសនាប្រៀនប្រដៅ ដើម្បីរំដោះឥសៈតាជាយពិតៗ, សូម្បីព្រះសាស្តាក៏ទ្រង់មិនមានបំណងឲ្យនរណាមួយ មកធ្វើសក្ការៈគោរពបូជាព្រះអង្គដែរ ដូចទ្រង់ប្រកាសជាច្បាប់ថា ការប្រព្រឹត្តិព្រហ្មចារ្យមិនមែនដើម្បីលាភសក្ការៈនឹងការសរសើរទេ, ត្រង់អំពីនេះទៀតទ្រង់ប្រកាន់យកការប្រតិបត្តិត្រូវជាគោល គឺនរជនណាប្រតិបត្តិត្រូវ នរជននោះឈ្មោះថាបានបូជាព្រះអង្គដោយបូជាដ៏ខ្ពង់ខ្ពស់ ជាងការបូជាដោយទៀនធូបផ្កាឈើទៀតទៅទៀត ។ សូម្បីអ្នកគោរពជាយសង្ឃដីរបស់ព្រះអង្គ បើមិនបានប្រតិបត្តិឲ្យត្រឹមត្រូវទេ ក៏មិនឈ្មោះថានៅដិតព្រះអង្គដែរ ។ នេះឯងជាគ្រឿងបញ្ជាក់ឲ្យឃើញថា ព្រះបរមសាស្តាទ្រង់ប្រៀនប្រដៅដើម្បី

ប្រយោជន៍ដល់អ្នកប្រតិបត្តិប្រតិបត្តិត្រូវយ៉ាងពិតប្រាកដ មិនមែនមានបំណងនឹងបោកបញ្ឆោតយកលាភសក្ការៈទេ, បើព្រះអង្គមានបំណងយ៉ាងនោះមែន ទ្រង់គង់នៅជាក្បត្តែគ្រប់គ្រងលោកិយសម្បត្តិប្រៀសើរជាង ។

ព្រះសម្ពុទ្ធជាម្ចាស់ប្រដៅមនុស្សឲ្យប្រតិបត្តិល្អ យ៉ាងគ្រប់គ្រាន់ហើយបើនឹងលើកតំកើងវដនណា ក៏លើកតំកើងព្រោះសេចក្តីប្រតិបត្តិល្អរបស់នវដនោះ ឥតមានលើកតំកើងព្រោះទ្រព្យឬព្រោះវង្សត្រកូលឡើយ ។ ព្រោះហេតុនោះ នរណាដែលសំដែងខ្លួនថាជាអ្នកចេះដឹង មិនចំពោះតែផ្លូវលោកឬផ្លូវធម៌ទេ បើវាចារបស់គេដែលបន្ទឺចេញមកនោះប្រកបដោយសេចក្តីឫស្សា, អាឃាត, សេចក្តីក្រោធខឹងតោមនស្សតូចចិត្ត ជាវាចាដឹកនាំដើម្បីឲ្យបំផ្លាញចំពោះអ្នកដែលខ្លួនស្អប់ហើយ គប្បីដឹងច្បាស់ថា នេះយ៉ាយដូច្នោះជារបស់មនុស្សឆ្ងាយចាកព្រះពុទ្ធសាសនាដូចមានរឿងតំណាលថា ៖

សម័យមួយ ព្រះសម្ពុទ្ធបានស្តេចទៅកាន់ដែនមគធៈ, វស្សការព្រាហ្មណ៍មហាមាត្យនៃដែននោះបានមកគាល់ព្រះអង្គ ហើយក្រាបបង្គំទូលអំពីសេចក្តីយល់ឃើញរបស់ខ្លួនថា "អ្វីក៏ដោយ ដែលខ្ញុំព្រះអង្គបានឃើញ បានឮ ឬបានដឹងមក, បើខ្ញុំព្រះអង្គនិយាយទៅតាមការដែលដឹង ដែលឃើញនោះហើយ ក៏មិនមានទោសទេ" ។ ព្រះសម្ពុទ្ធត្រាស់តបថា តថាគតមិនពោលថា វត្ថុដែលបានឃើញ បានឮ ឬដឹងមកនោះជារបស់គួរនិយាយជានិច្ចទេ បើពាក្យឯណាដែលនិយាយទៅហើយ ជាហេតុឲ្យធម៌ចំណែកអាក្រក់ចំរើន ធម៌ចំណែកល្អសាបសូន្យ

ពាក្យនោះក៏មិនគួរនិយាយ; តែបើនិយាយទៅហើយ ជាហេតុឲ្យធម៌ចំណែកអាក្រក់សាបសូន្យ ធម៌ចំណែកល្អចំរើន ពាក្យនោះទើបគួរនិយាយ; តថាគតសរសើរចំពោះតែអ្នកដែលនិយាយសច្ចៈពិត ។ ព្រមទាំងត្រូវឲ្យស្គាល់កាលដែលគួរនិយាយផង ។ មនុស្សដែលកើតមកហើយ តែងមានអណ្ណាតកើតមកនៅក្នុងមាត់ផង ។ មនុស្សពាលដែលពោលវាចាអាក្រក់ថោកទាប ឈ្នោះថាប្រើអណ្ណាតនោះសម្ងាប់ខ្លួនឯង ។ នរណានឹងធ្វើការណា ។ ក៏ដោយ បើមានសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេងជាបុសតល់ហើយ សេចក្តីអាក្រក់ដទៃ ។ ដែលនៅមិនទាន់កើតឡើងក៏នឹងកើតឡើង ដែលកើតហើយ ក៏រិតតែចំរើនឡើង ។ មនុស្សពាលកាលបើពោលពាក្យអាក្រក់ ក៏សំគាល់ថាខ្លួនឈ្នះ ។ សេចក្តីអត់ធន់របស់មនុស្សអ្នកដឹងទាន់ ទើបជាជ័យជំនះដ៏ពិតប្រាកដ ។ អ្នកក្រោធតបមនុស្សដែលក្រោធ រមែងទាបថោកក្រៃលែងជាងមនុស្សដែលក្រោធមុននោះទៅទៀត ។ មនុស្សដែលមិនក្រោធតបចំពោះអ្នកដែលក្រោធ ឈ្នោះថាជាអ្នកឈ្នះសង្គ្រាមដែលកម្រនឹងឈ្នះបាន ។

ពុទ្ធមាមកជនទាំងឡាយ ចូរពិចារណាមើលចុះ ព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ គឺប្រដៅឲ្យពួកយើងស្រឡាញ់សន្តិភាព គឺឲ្យធ្វើការណា ។ ដោយប្រាសចាកសេចក្តីលោភ ក្រោធ វង្វេងជាតើមុន ។ ក្នុងទីបំផុត ព្រះអង្គទ្រង់ប្រដៅពួកយើងឲ្យឈ្នះសង្គ្រាមដែលកម្រនឹងឈ្នះបាន គឺឲ្យហាត់ពត់ចិត្តមិនក្រោធទឹងចំពោះមនុស្សទូទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ឈ្នះខ្លួនឯងប្រសើរបំផុត

យុនសុវ៉ត្ថិធីទី យូរ-អ៊ុន ជ្រៀបជ្រៀង

តាមធម្មតា មនុស្សក្នុងលោក ដែលរួមគ្នានៅជាសង្គមតូចក្តី ធំក្តី តែងមានការវិវាទឈ្លោះទាស់ទែងគ្នា ដោយការដណ្តើមយកត្រូវ ឬយកឈ្នះតែរៀងខ្លួន ។ ផលជម្លោះនេះ បើក្នុងសង្គមតូច ៗ បង្កើតទៅជារាយជាល់កាប់សម្លាប់គ្នា ឬក្តីក្តាំប្តឹងផ្តល់ដល់រាជការ ឲ្យវិនិច្ឆ័យរកខុសរកត្រូវឲ្យ, បើក្នុងសង្គមធំ ៗ បង្កទៅជាចំបាំងតស៊ូដោយកម្លាំងអាវុធ ជាហេតុធ្វើឲ្យជាតិប្រទេសវិនាសអន្តរាយ ។ ផលចុងបំផុតនៃជម្លោះ គឺអ្នកដែលកម្លាំងខ្សោយ ក៏ចាញ់, អ្នកដែលមានកម្លាំងខ្លាំង ក៏ឈ្នះ ។ បណ្តាការឈ្នះនឹងការចាញ់ ក្នុងការតស៊ូដោយកម្លាំងនេះ, ការឈ្នះ គេរាប់ថាប្រសើរបំផុត ព្រោះអាចរាតអំណាចចេញទៅតាមឥទ្ធិពលរបស់ខ្លួនបាន ។ តែចំបាំងនេះទុកថាជាចំបាំងខាងក្រៅ, ជ័យជំនះនៃចំបាំងខាងក្រៅនេះ អ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើមមិនសរសើរសោះឡើយ ព្រោះអ្នកដែលឈ្នះហើយ ជួនកាលត្រឡប់ទៅជាចាញ់វិញ ដោយហេតុអ្នកឈ្នះតែងទទួលពៀរ, អ្នកចាញ់តែងដេករករឿងនឹងសងសឹកវិញ ។

ក្នុងខ្លួនមនុស្សយើង មានសង្គមពីរ ដែលតែងប្រធាំងគ្នា គឺសង្គម ចិត្តកុសល និង សង្គមចិត្តអកុសល ។ ចិត្តទាំង ៤ ក្រុមនេះ តែងទាស់ ឈ្លោះគ្នាទៅវិញទៅមក ។ បើចិត្តអកុសលច្បាំងឈ្នះចិត្តកុសល ក៏ សង្កត់ផ្ទប់ចិត្តកុសលមិនឲ្យក្រោករួច ហើយដឹកនាំកាយឲ្យធ្វើអំពើពាល យង់ឃ្នងមានប្រការផ្សេងៗ, ដឹកនាំមាត់ឲ្យពោលពាក្យប្រកបដោយទោស ច្រើនយ៉ាង ។ ផលក្នុងទីបំផុត ចិត្តអកុសលក៏ផ្តល់ឲ្យមនុស្សយើង ទទួលរងទុក្ខលំបាកតាមស្ថានការណ៍ដែលបានប្រព្រឹត្ត រឿងនេះ ត្លូរ ឃើញដូចអ្នកលេងស្រី អ្នកផឹកស្រា អ្នកលេងល្បែងក្នាល់ អ្នកប្រព្រឹត្ត ធ្វើចោរកម្មលួចប្លន់ ធបោកយកទ្រព្យសម្បត្តិអ្នកដទៃជាដើម, ពួកជន អ្នកប្រព្រឹត្តអំពើពាលលាមកទាំងនេះ តែងវិនាសខ្លួន, វិនាសទ្រព្យ សម្បត្តិ ។ នេះឯងមកអំពីចិត្តអកុសលគ្របបាំងបិទចិត្តកុសល ។ ត្មានកម្ចាំងនឹងរើខ្លួនបាន ទើបធ្វើឲ្យគេងប់មុខស្ទុងចុះទៅក្នុងអំពើអាក្រក់ ឥត តក់ស្ទុត ឥតខ្មាសអៀនសោះឡើយ ។

ប្រសិនបើចិត្តកុសលច្បាំងឈ្នះចិត្តអកុសលវិញ ចិត្តកុសលក៏ដឹកនាំ មនុស្សយើង ឲ្យចូលចិត្តធ្វើតែអំពើល្អ និយាយតែពាក្យជាគុណប្រយោជន៍ ដឹកនាំឲ្យរៀបរឹកពាសុភាពរៀបសា ។ ពួកជនដែលមានចិត្តកុសល ឈ្នះចិត្តអកុសលនោះ តែងទទួលផលជាសុខ, ចំណែកលាភ, យស និង សេចក្តីសរសើរ ក៏ចេះតែកើតមានជាលំដាប់ ដូចចូឡេកសាដកព្រាហ្មណ៍ ដែលមានសំពត់ដណ្តប់តែមួយ ប្រើពីរនាក់ប្តីប្រពន្ធ ពេលមួយគាត់បាន ចូលទៅស្តាប់ធម៌ព្រះសម្ពុទ្ធ ក៏មានសទ្ធាចិត្ត (ចិត្តសទ្ធា) ចង់ថ្វាយសំពត់

ដណ្តប់នោះចំពោះព្រះអគ្គតែសទ្ធាចិត្តនេះ ច្បាំងនឹងមច្ឆេរចិត្ត(ចិត្តកំណាញ់មិនចង់ថ្វាយវិញ) តាំងពីព្រលប់រហូតដល់ជិតភ្លឺមិនអាចយកជ័យបាន ។ កន្លះវេលាមួយភាគនោះ ជួនកាលសទ្ធាចិត្តមានកម្លាំងសង្កត់មច្ឆេរចិត្ត, ជួនកាលមច្ឆេរចិត្តមានកម្លាំងសង្កត់សទ្ធាចិត្ត ។ លុះដល់ជិតភ្លឺ ចូឡកសាដកព្រាហ្មណ៍ ទើបដាច់ស្រេចក្នុងចិត្តឥតរើរុះថា ត្រូវតែថ្វាយសំពត់ដណ្តប់ ដល់ព្រះសម្ពុទ្ធ ខានពុំបាន ។ ត្រង់នេះ ទុកថាសទ្ធាចិត្តច្បាំងឈ្នះមច្ឆេរចិត្ត ។ ក្នុងកាលជាបន្ទាន់នេះ ចូឡកសាដកព្រាហ្មណ៍បានទទួលសេចក្តីសរសើរ ព្រមទាំងបានទទួលសំពត់សាដក ៣២ គូ នឹងខ្ញុំប្រុសខ្ញុំស្រី គោក្របីសេះជាដើមអំពីព្រះបាទបសេនទិកោសល ។ ការបានសេចក្តីសរសើរជាដើមនៃចូឡកសាដកព្រាហ្មណ៍នេះ គឺជាផលដែលកើតអំពីចិត្តកុសលផ្តល់មកឲ្យ ។

ចំបាំងនៃចិត្តកុសលនឹងចិត្តអកុសលនេះ ពាប់ថាជាចំបាំងខាងក្នុង ព្រោះកើតមានខាងក្នុងសន្ដានមនុស្សយើងរាល់រូប ។ បណ្តាជ័យដំនះខាងក្នុងនេះ ជ័យដំនះរបស់ចិត្តអកុសល បណ្ឌិតមិនពាប់ថាជាដំនះដ៏ប្រសើរទេ ព្រោះឲ្យផលជាទុក្ខដល់សត្វ, ជ័យដំនះរបស់ចិត្តកុសល ទើបពាប់ថាជាដំនះដ៏ប្រសើរ ព្រោះឲ្យផលជាសុខ តាមសមគួរដល់កម្លាំងកសាងមក ។

សេចក្តីនេះសមដូចព្រះពុទ្ធភាសិតថា អត្តា ហវេ ជិតំ សេយ្យោ ឈ្នះខ្លួនឯងប្រសើរ ។ ពាក្យថាខ្លួនឯង សំដៅយកចិត្ត, ឈ្នះខ្លួនឯង គឺឈ្នះចិត្តឯង, សំដៅយកចិត្តកុសលឈ្នះចិត្តអកុសលនោះឯង ។

ចិត្តកុសលដែលមានកម្លាំងអាចឈ្នះចិត្តអកុសលបាន ដោយ

អាស្រ័យធមិ ៤ ប្រការគឺសញ្ញម: (ការរវាង) នឹង ទម: (ការបង្ទឹក) ។ សញ្ញម:ជាធមិទី ១ មានការ:ខាងការសង្រ្ដម រវាង ប្រយ័ត្នឃ្ជាំមើលអារម្មណ៍ដែលចូលមកក្នុងទ្វារទាំង ៦ ឲ្យដឹងថាអារម្មណ៍នេះល្អឬមិនល្អ, កាលបើអារម្មណ៍ណាចូលមកហើយ នាំឲ្យកើតសោមនស្សឬទោមនស្ស ក៏ទប់ឃាត់ចិត្តមិនឲ្យសោមនស្ស មិនឲ្យទោមនស្ស ។ បន្ទាប់មកត្រូវមុខ ទម: ជាធមិទី ៤ ដែលមានការ:ខាងទូន្មានប្រៀនប្រដៅចិត្ត ឲ្យប្រព្រឹត្តទៅក្នុងផ្លូវមានសួស្ត្ថី ។ ទម: ធមិនេះទុកជាទម័កចិត្ត សម្រាប់ប្រដៅចិត្ត ឲ្យដើរទៅក្នុងទីប្រកបដោយគុណ ។ កុសលចិត្ត កាលបើមានធមិសញ្ញម: នឹង ទម:នេះមកជាអាវុធហើយ ក៏អាចឈ្នះចិត្តអកុសលបានដោយងាយ ។ ដូច្នេះ យើងជាពុទ្ធសាសនិកជនមិនគប្បីច្បាំងនឹងជនដទៃទេ គប្បីច្បាំងតែនឹងខ្លួនឯង ព្រោះឈ្នះខ្លួនឯងប្រសើរបំផុត ។

ឈ្នះអ្វីមិនប្រពៃស្មើនឹងឈ្នះចិត្ត
ដែលប្រព្រឹត្តធ្វើអំពើមិនសមស្លន
ប្រានចោលអស់ត្មានអាឡោះអាល័យស្លួន
អាចធ្វើខ្លួនមានសួស្ត្ថីជ័យដោគល្អ ។
ការចាញ់ចិត្តគឺបណ្តោយទៅតាមចង់
មិនគិតត្រង់អង្គខុសត្រូវផ្លូវឡោស
តែងមានទុក្ខឃើញទាន់ហន់តាមជាន់ក
លុះតំណទៅជាតិមុខទុក្ខអនន្ត៍ ។

ឃូរ - អ៊ុន

វិវាធមូល

ព្រះឧបាលិវង្ស ម៉ឹង-សេស

វិត្តមហាមន្ត្រី ក្រុងភ្នំពេញ

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង)

សូមនមស្សការ ចំពោះព្រះភគវន្តមុនី ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឆ ដោយសេចក្តីគោរព) ។

សូមសំដែងអំពីវិវាទមូល តាមទំនងដែលមានក្នុងខុទ្ទកវត្ថុវិភង្គ គម្ពីរវិភង្គ អភិធម្មបិដក ។

ធម៌ដែលជាបុសគល់ប្ដជាហេតុនាំឲ្យកើតសេចក្តីឈ្លោះ ហៅថាវិវាទមូល ។ វិវាទមូលនោះព្រះដ៏មានព្រះភាគ ទ្រង់សំដែងចែកចេញទៅជា ៦ ប្រការ គឺ:

១_ កោធោ សេចក្តីក្រោធ គឺសេចក្តីខឹងចងគំនុំគុំគួន ។

២_ មក្ខោ ការលុបបំបាត់គុណគេ ។

៣_ ឥស្សា សេចក្តីច្រណែនឈ្នានីសគេ ។

៤_ សាឋេយ្យំ ការប្រកាសគុណដែលមិនមានក្នុងខ្លួន គឺអួតអាងអំពើទិលខូច, អំពើធែបធប, ថោកប្រាស, អំពើដែលជាកិច្ចកលរបស់អ្នកលេង ។

៥_ ឧាបិប្ជតា សេចក្តីប្រាថ្នាអាក្រក់ ។

៦_ សន្ធិដ្ឋិបរាមាសិតា សេចក្តីប្រកាន់មាំនូវទិដ្ឋិ គឺប្រកាន់តាម់សេចក្តីយល់ឃើញរបស់ខ្លួនថាជាការត្រូវការពិត សេចក្តីយល់ឃើញរបស់អ្នកដទៃ សុទ្ធតែមិនត្រូវមិនពិត ។

អធិប្បាយវិវាទមូល ៦ ប្រការ

កោធោ = សេចក្តីក្រោធខឹង នេះ ជានដល់ការអាក់អន់ចិត្ត តូចចិត្ត, ថ្នាំងថ្នាក់ចិត្ត កន្ធួលចិត្ត ។ សេចក្តីក្រោធខឹងនេះមនុស្ស ជាបុថុជ្ជនតែងមានគ្រប់គ្នាជាធម្មតា ហេតុនោះជានជាមនុស្ស ជាបុថុជ្ជនច្រើនតែឈ្លោះទាស់ទែងគ្នា ។ សេចក្តីក្រោធនេះបណ្តាលមកអំពីការ ពុ្ទពាក្យតេជេរត្មះតិះដៀលឡឺដងបញ្ឈឺចិត្តខ្លះ បណ្តាលមកអំពីការបៀត បៀនដោយកាយ មានវាយដំតប់ទះជាដើមរបស់អ្នកដទៃខ្លះ, បណ្តាលមកអំពីការលេងល្បែងភ្នាល់ មានល្បែងបាស្ការ ល្បែងស៊ីសងជាដើមខ្លះ, បណ្តាលមកអំពីតេយកទ្រព្យសម្បត្តិបំផ្ទិចបំផ្ទាញទ្រព្យសម្បត្តិខ្លះ, កាលបើកើតក្រោធថ្នាំងថ្នាក់អាក់អន់ចិត្តហើយ ក៏កើតទៅជាឈ្លោះទាស់ទែងរហូតដល់ទៅចងពៀរព្យាបាទធ្វើគ្នាឲ្យវិនាសក៏មាន ។

ម្យ៉ាងទៀត សេចក្តីក្រោធនេះជាឧបក្កិលេសគ្រឿងមន្ទិលសៅហ្មងចិត្ត ប្រៀបដូចជាវត្ថុមានផ្សូងផេះកក់ជាដើម ជាមន្ទិលសៅហ្មងដល់សំពត់សស្អាត, ក៏ឯចិត្តនោះប្រសិនបើសៅហ្មងដោយឧបក្កិលេសគឺសេចក្តីក្រោធហើយ ក៏ជាហេតុឲ្យបានទុគ្គតិកត, ប្រសិនបើបរិសុទ្ធជ្រះស្អាត

ចាកឧបក្កិលេសគឺសេចក្តីក្រោធហើយក៏ជាហេតុឲ្យបានសុគតិភព, ដូច
គ្នានឹងសំពត់សស្អាតឥតមានប្រឡាក់ដោយមន្ទិលផ្សេង ។ មានផ្សែងផេះ
កក់ជាដើម រមែងជិតជាប់ដោយគ្រឿងជ្រលក់ទាំងពួង មានពណ៌ក្រហម
លឿងខៀវជាដើម នាំឲ្យសម្រេចប្រយោជន៍ដល់អ្នកដែលត្រូវការដោយ
ជ្រលក់សំពត់ ។

ជនជាសប្បុរស គួរគប្បីសង្កត់សេចក្តីក្រោធឲ្យខន់ខ្សាយកុំឲ្យក្លៀវ
ក្លាពេក ដោយធម៌ខន្តីសេចក្តីអត់ធន់នឹងមេត្តាសេចក្តីភប់អានស្រឡាញ់
គ្នាគ្នា ក្រឡេកមើលគ្នាដោយបិយចក្ខុ និយាយរកគ្នាដោយបិយវាចា
ដើម្បីកុំឲ្យមានវិវាទទាស់ខែងគ្នា ព្រោះការវិវាទនោះជាភេគមួយយ៉ាងធំ
ក្នុងសង្គមនៃមនុស្សលោក ។

ការគ្រប់សង្កត់បំបាត់សេចក្តីក្រោធនោះ មិនត្រឹមតែបាត់វិវាទប៉ុណ្ណោះ
ទេ ថែមទាំងអាចផ្គាញ់មនុស្សអ្នកក្រោធបានផង ថែមទាំងបានសុគតិ
ភពគឺឋានសួគ៌ទៀតលោក សមតាមបទព្រះបាឡីថា អក្កោធេន ជិនេ
កោធំ ប្រែថា "មនុស្សយើងអាចផ្គាញ់មនុស្សអ្នកក្រោធបាន ដោយ
សេចក្តីមិនក្រោធតប" ។

សប្ញំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ

ប្រែថា "មនុស្សយើងគួរនិយាយពាក្យពិតទៀងត្រង់ ១ មិនគួរក្រោធ ១ បើ
មានទេយ្យធម៌បន្តិចបន្តួច គួរឲ្យទានបន្តិចបន្តួចដល់សេមកុំខាន ១, មនុស្ស

យើងអាចទៅនៅក្នុងសំណាក់ទេវតាបាន ដោយហេតុទាំង ៣ នេះ ហេតុណាមួយក៏បាន" ។

មក្ខោ = ការលប់បំបាត់គុណគេ នោះ សេចក្ដីប្រហែលគ្នានឹងអកតញ្ញុតាធម៌ គឺការមិនដឹងគុណរបស់អ្នកដែលគេធ្វើគុណលើខ្ជួន ឬថាដឹងដែរតែធ្វើហាក់ដូចជាមិនដឹង បំបិទបំបាំងមិនឲ្យគេរាល់គ្នា ដឹងថាអ្នកនោះគេមានគុណលើខ្ជួន មានឧទាហរណ៍ដូចជាកិក្ខុមួយរូបរៀនសូត្រក្នុងសំណាក់អាចារ្យមួយរូប រៀនបានចេះដឹងគួរសមហើយក៏ទៅរៀនក្នុងសំណាក់អាចារ្យដទៃទៀត យូរ ៗ ទៅបានចេះដឹងប្រើនជាងអាចារ្យដើម មានលាភសក្ការៈនឹងសេចក្ដីសរសើរគ្រាន់បើជាងអាចារ្យដើម ក៏សំដែងអាការដូចជាមិនមែនសិស្សមិនមែនអាចារ្យ ធ្វើបូកស្មើ ៗ បន្ទំមិនឲ្យអ្នកដទៃដឹងថាខ្ជួនជាកូនសិស្ស ។ មានកិក្ខុខ្ទះរៀនសូត្រអំពីអាចារ្យប្រើនរូប តែគោរពរាប់អានបូជាបំពោះតែអាចារ្យណាដែលមានបុណ្យសក្ដិ មានមុខមាត់អំណាចរាសនាប្រើន ត្រង់អាចារ្យដទៀត ៗ ធ្វើហាក់ដូចជាមិនស្គាល់ ។ កិក្ខុខ្ទះទៀតឥតមានរៀននឹងគេសោះ ឃើញគេមានមុខមាត់យសស័ក្ដិលាភសក្ការៈប្រើន ក៏ខំយកចិត្ដទុកដាក់ផ្គាប់ផ្គុនគេដោយចង់បានផលប្រយោជន៍ក្នុងបច្ចុប្ឋន្ន ចោលត្រូអាចារ្យរបស់ខ្ជួនទទេ ឥតមាននឹកនាសោះ ។

ម្យ៉ាងទៀត ការលុបគុណសម្បត្ដិ គឺសេចក្ដីល្អរបស់គេចេញធ្ពឹសកកាយសេចក្ដីអាក្រក់របស់គេឲ្យអណ្ដែតខ្ពស់ឡើង ក៏ហៅថា

មក្ខោ ការលុបគុណគេដែរ, ដូចក្នុងគ្រាពុទ្ធកាល មានភិក្ខុ ២ រូបឈ្មោះ ធម្មកថិក ១ វិនយធរ ១ កើតវិវាទបែកគ្នាទៅជា ២ ពួក ។ ហេតុខាងដើម គឺធម្មកថិកបន្ទោបង់ទុច្ចរិត ហើយដំរិះទុច្ចរិតសល់តិចតួចក្នុងក្នុងដ៏តាជនៈ ជាក់កងបន្ទប់ទឹក ។ វិនយធរចូលទៅក្រោយឃើញទឹកនៅសល់ ហើយចេញមកវិញច្រាប់ធម្មកថិកថា លោកទុកទឹកដែលសល់អំពីដំរិះដូច្នេះ ខុសទាស់នឹងវិនយប្បញ្ញត្តិហើយ ។ ធម្មកថិកក៏ទទួលខុសគ្នានឹងខ្លឹង ។ ពេលក្រោយ វិនយធរនិយាយច្រាប់រឿងនោះដល់សិស្សរបស់ខ្លួន ។ ពួកសិស្សវិនយធរក៏នាំគ្នាពោលទោសច្រាប់ពួកសទ្ធិវិហារិករបស់ធម្មកថិក ថា ឧបជ្ឈាយ៍របស់លោកត្រូវអាបត្តិ មិនស្គាល់អាបត្តិ ។

រឿងហេតុនោះមិនមែនជាធំដុំទេ តែបណ្តាលទៅជាធំបាន បែកពួកបែកបក្ខជា ២ មកអំពីពួកវិនយធរគ្រប់លុបសេចក្តីល្អរបស់ធម្មកថិក ឆ្កឹសកកាយសេចក្តីខុសតែបន្តិច ឱ្យអណ្តែតខ្ពស់ឡើងច្រាប់គេពាល់គ្នាដូច្នេះ ក៏ហៅថាលុបគុណសម្បត្តិរបស់គេឱ្យបាត់សូន្យទៅ ទាញយកសេចក្តីអាក្រក់របស់គេមកប្រកាសនាំឱ្យកើតវិវាទ ។

មក្ខោ ការលុបគុណគេនេះ ជាឧបក្កិលេសរំខឹងសៅហ្មងដល់ចិត្តដូចជា (គោធា) វិវាទមូលធី ១ នោះដែរ ព្រោះហេតុនោះ ជនជាសប្បុរសគួរលះបង់នូវអំពើលុបគុណគេចោលចេញ ត្រូវដឹងគុណគ្រូអាចារ្យមាតាបិតានឹងអ្នកដែលគេបានសង្គ្រោះទុកបំរុងខ្លួន កុំភ្លេចឧបការគុណគេឡើយ ចំណែកឥស្សរជនទីមួយ ។ ត្រូវបើកចក្ខុក្រឡេកមើលឱ្យច្បាស់ ត្រូវផ្តង់សោតៈស្តាប់ឱ្យជាក់ ត្រូវយកបញ្ញាពិចារណាមើល

ឲ្យសព្វគ្រប់ ឲ្យស្គាល់ច្បាស់ថាមនុស្សនេះមានគុណសម្បត្តិប្រើន មនុស្ស
នោះមានគុណសម្បត្តិតិច ត្រូវសំរេចការទៅតាមហេតុកុំឲ្យកាន់ច្រឡំ ក្រែង
នឹងធ្លាក់ទៅក្នុងតម្រាស៊ុកគ្រលុក ។

ឥស្សា = សេចក្តីប្រណែនឈ្នានីសគេ, សេចក្តីថា ការ
ដែលបុគ្គល ឃើញគេមានលាភសក្ការ: សេចក្តីគោរពរាប់អានអំពី
ជនដទៃក៏ប្រណែនមិនចង់ឲ្យគេលើសខ្លួន ឬមិនចង់ឲ្យគេស្មើនឹងខ្លួន
ដោយលាភសក្ការ: នឹងសេចក្តីគោរពរាប់អានអំពីជនដទៃនោះ ដូច្នេះ
ជាដើមហេតុនាំឲ្យកើតវិវាទទាស់ទែងគ្នាពេញបន្ទុក ដូចជាព្រះទេវទត្ត
ឃើញគ្រហស្ថគោរពរាប់អានព្រះថេរៈទាំងឡាយ មានព្រះសារីបុត្តនឹង
ព្រះមោគ្គល្លានជាដើម គ្រង់ខ្លួនឯងគេមិនគោរពរាប់អាន ក៏កើតសេចក្តី
ប្រណែនឈ្នានីសឡើង បែកកន្ទែកទៅតែឯងស្វែងរកពួករកបក្ខមិត្រភក្តិ
បង្កហេតុវិវាទបំបែកសង្ឆ ត្រូវទោសអនន្តរិយកម្មបានបាបផ្ទន់បំផុត ។

ឥស្សា សេចក្តីប្រណែននេះ ជាឧបក្កិលេស គ្រឿងសៅហ្មងដល់
ចិត្តដូចគ្នានឹង (កោធោ) វិវាទមូលទី ១ នោះដែរ ព្រោះហេតុនោះពួក
សប្បុរសគួរបន្ទោបង់នូវសេចក្តីប្រណែនចេញ គួរចំរើនន្ទូវមុទិតាព្រហ្ម-
វិហារឲ្យជុះក្នុងសន្តាន នឹងបានស្ងប់ស្ងាត់បាត់ប្រណែនគេ វិវាទក៏បាត់
ស្ងន្យដោយអំណាចបាត់សេចក្តីប្រណែន ។ ឯមុទិតានោះ ប្រែថា
" សេចក្តីត្រេកអរវីកវាយនឹងសម្បត្តិរបស់អ្នកដទៃ " គឺឃើញអ្នកដទៃ
បរិបូណិដោយយសសក្តិទ្រព្យធនលាភសក្ការ: នឹងសេចក្តីសរសើរ
ក៏មានសេចក្តីត្រេកអរវីកវាយ គ្មានប្រណែន ។

សាឃេយ្យំ = ការប្រកាសគុណដែលមិនមានក្នុងខ្លួន នោះ
សេចក្តីថា ខ្លួនមិនមានសទ្ធា អ្នកខ្លួនថាមានសទ្ធា, ខ្លួនមិនមានសីល
បរិសុទ្ធ អ្នកខ្លួនថាមានសីលបរិសុទ្ធ, ខ្លួនចេះដឹងតិច អ្នកខ្លួនថាចេះដឹង
ច្រើន ជូច្នេះជាដើម ។ ត្រង់ពាក្យថា "អំពើទិលទូច, ធែបធប, ជ្រាក
ជ្រាស" សេចក្តីថា ការនិយាយមិនពិតមិនត្រឹមមិនទៀងត្រង់ ការ
ធែបធបទ្បែបទ្បបឲ្យតែទាងជ្រានស៊ី ត្រង់ទុសត្រូវមិនតិត ជូចត្រីឈ្មោះ
អានន្ទមច្ឆៈ មានកន្ទុយជាត្រី មានក្បាលជូចពស់ កាលបើជួបនឹងពួកត្រី
ក៏បង្ហាញកន្ទុយថាទ្រុំត្រីដែរ កាលបើជួបនឹងពួកពស់ ក៏បង្ហាញក្បាលថាទ្រុំ
ពស់ដែរ ។ ត្រង់ពាក្យថា "អំពើកិច្ចកលរបស់អ្នកលេង" នោះសេចក្តីថា ការ
ប្រើទជ្រាយកលច្រើន មិនឲ្យអ្នកដទៃស្គាល់ជ្រាកដថាទាងណាពោះ ទាង
ណាទ្នងជាដើម. ធ្វើអំពើទុសហើយចេះគេចខ្លួនដោះខ្លួនឲ្យរួចពីទោស - ។

ព្រះអដ្ឋកថាចារ្យ លោកលើកយកព្រះគាថា ១ មកពន្យល់អំពីបទ-
សាថេយ្យនេះថា :

ភាមេន សូកធា ហោតិ ទក្ខិណេន អជាមិកោ
សធេន ឯលកោ ហោតិ វិសាណេន ជរគ្គធា ។

ប្រែថា យក្ខសូករៈ (ខ្មោចជ្រូក) ១ គេមើលពីទាងធ្វេងជាជ្រូក
មើលពីទាងស្តាំជាពពែ ស្តាប់សំទ្បេងជាចៀម មើលទៅស្នែងជាគោ
ចាស់ ។ បណ្ឌិតគាប្បីដឹងសេចក្តីក្នុងបទសាថេយ្យជូច្នេះឯង ។

មួយទៀត សាថេយ្យនេះជាទបក្កិលេសត្រឿងសៅហ្មងចិត្តជូចគ្នា

ទីឆ (កោធោ) រំកិលមួលទី ១ នោះដែរ ព្រោះហេតុនោះ ពួកសប្បុរសគួរជួនាទ្ធនឲ្យល្អ គួរកុំប្រព្រឹត្តធម៌សាថេយ្យនេះឲ្យសោះ ទើបទីឆអាចបានសេចក្តីសុខស្រួលល្អឥតមានរំកិល ។

បាបិច្ឆតា = សេចក្តីប្រាថ្នាអាក្រក់ នោះតាមពុទ្ធាធិប្បាយថា បុគ្គលខ្វះកឆលោកនេះមិនមានសទ្ធា ចង់ឲ្យគេដឹងថាខ្លួនមានសទ្ធា, មិនមានសីលថាសីលខ្លួន ចង់ឲ្យគេដឹងថាខ្លួនមានសីលថាសីលខ្លួន, ចេះដឹងតិច ចង់ឲ្យគេដឹងថាខ្លួនចេះដឹងច្រើន, ត្រេកអរនឹងពួកគណៈ ចង់ឲ្យគេដឹងថាខ្លួនត្រេកអរនឹងទីស្ងាត់, ជាអ្នកឆ្កួលច្រអូស ចង់ឲ្យគេដឹងថាខ្លួនមានព្យាយាម, មានស្មារតីវង្វេងក្លេច ចង់ឲ្យគេដឹងថាខ្លួនមានស្មារតីខ្ជាប់ខ្ជួន, មិនមានសមាធិ ចង់ឲ្យគេដឹងថាខ្លួនមានសមាធិ, មិនមានបញ្ញា ចង់ឲ្យគេដឹងថាខ្លួនមានបញ្ញា, ចំណង់ដូចេះហៅថាសេចក្តីប្រាថ្នាអាក្រក់ ។

បាបិច្ឆតា សេចក្តីប្រាថ្នាអាក្រក់នេះ អាចបណ្តាលចេញទៅជាអំពើមិនសមគួរផ្សេងៗ ដោយកាយខ្វះដោយវាចាខ្វះ បណ្តាលជារំកិលផ្សេងៗ ។ ព្រោះហេតុនោះ ពួកសប្បុរសគួរលះបង់សេចក្តីប្រាថ្នាអាក្រក់នេះចេញ គួរតាំងទៅកន្លងសេចក្តីសន្តោស សេចក្តីប្រាថ្នាតិច ជាការគាប់ប្រសើរកន្លងលោក នាំឲ្យបានសេចក្តីសុខស្រួល នាំឲ្យឃុតរំកិលផង ។

សន្ទិដ្ឋិបរាមាសិតា = សេចក្តីប្រកាន់មាំនូវទិដ្ឋិ គឺប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួនថា ជាការត្រូវការពិត នោះជាមន្ទិលដល់ពួកក្រុមដ៏ទុំទាំងពួងកន្លងលោក តាំងអំពី ២ រូបឡើងទៅ នាំឲ្យ

សៅហ្មង ដល់កិច្ចការទាំងឡាយ របស់អ្នកដែលមានគ្នាច្រើន ។
ព្រោះមនុស្សក្នុងលោកនេះ មានទិដ្ឋិសេចក្តីយល់ឃើញខុសគ្នាដោយច្រើន
ព្រោះហេតុនោះ សាធុជនមិនគួរប្រកាន់សេចក្តីយល់ឃើញរបស់ខ្លួនថា
ត្រូវប្រកាន់សេចក្តីយល់ឃើញរបស់អ្នកដទៃថាខុសពេកឡើយ បើ
ប្រកាន់ណាស់ទៅ នឹងធ្លាក់ចុះក្នុងតម្រាខ្ទាក់ស្ទាបដំរីពុំខានឡើយ ដូច
មានរឿងក្នុងសុត្តន្តបិដកខុទ្ទកនិកាយ គម្ពីរ ធាន ថា

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តព្រះជេតពន ទ្រៀប
ក្រុងសាវត្ថី ។ សម័យនោះឯងមានពួកនានាតិត្ថិយបរិព្វាជក គឺអ្នកបួស
ដែលមានលទ្ធិផ្សេងៗ នៅក្នុងនគរសាវត្ថី មានវិវាទទាស់ទែងគ្នាដោយ
ហេតុប្រកាន់ធមិតាមយោបល់ចូលចិត្តតែរឿងៗ ខ្លួន ខ្លះប្រកាន់ថា
លោកទ្រៀង ខ្លះថាលោកមិនទ្រៀង ខ្លះថាលោកមានទិបំផុត ខ្លះថា
លោកមិនមានទីបំផុត ខ្លះថាជីវិតនឹងសរីរៈជាមួយគ្នាមិនដទៃពីគ្នា ខ្លះថា
ជីវិតដទៃ សិរីរៈដទៃ ជាដើម ។

នានាតិត្ថិយបរិព្វាជកទាំងនោះក៏ជជែកគ្នា ដណ្តើមយកត្រូវតែរឿង
ខ្លួន ហើយពោលពាក្យចាក់ដោតគ្នាទៅវិញទៅមក ។

ត្រានោះ មានភិក្ខុច្រើនអង្គនិមន្តចូលទៅយកបិណ្ឌបាត ក្នុងក្រុង
សាវត្ថី បានជ្រាបដំណើរនោះ លុះត្រឡប់មកអំពីបិណ្ឌបាតធ្វើភត្តកិច្ច
រួចហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ បានក្រាបបង្គំទូលដំណើរ
វិវាទ របស់ពួកនានាតិត្ថិយបរិព្វាជក តាំងអំពីដើមរហូតដល់ចប់ ។

ព្រះអង្គមានព្រះបន្ទូលថា បានជាពួកជនទាំងនោះ ទាស់ទែងគ្នា

មានសភាពដូច្នោះ ព្រោះសេចក្ដីលូន់ឡៅ មិនដឹងអត្ថមិនដឹងធម៌ពិត ប្រាកដ ហើយព្រះអង្គសំដែងរឿងព្រេងក្នុងនគរសាវត្ថី ជាទីសណ្ឋាប់ ដល់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពីមុនមកមានព្រះរាជា ១ ព្រះ អង្គ សោយរាជ្យក្នុងនគរសាវត្ថី ថ្ងៃមួយព្រះរាជានោះមានព្រះបន្ទូល ត្រាស់បង្គាប់បុរសម្នាក់ ឲ្យជ្រើសរើសរកយកបុគ្គលឆ្ងាក់អំពីកំណើត ក្នុង ក្រុងសាវត្ថីទាំងប៉ុន្មានឲ្យមកប្រជុំគ្នាក្នុងទី ១ បុរសនោះក៏ទទួលព្រះរាជ-ឧង្ការហើយ ក៏ចាត់ការប្រមូលអស់ពួកមនុស្សឆ្ងាក់អំពីកំណើតមកប្រជុំគ្នា តែក្នុងកន្ទែង ១ ហើយយកសេចក្ដីក្រាបបង្គំទូលតាមដំណើរ ។ ព្រះរាជា អង្គនោះមានព្រះរាជឧង្ការឲ្យយកដំរីមកឲ្យពួកជនឆ្ងាក់ទាំងនោះស្ទាបមើល តែពួកខ្វះឲ្យស្ទាបត្រង់ក្បាលដំរី ខ្វះឲ្យស្ទាបត្រចៀក ខ្វះឲ្យស្ទាបក្ងុក ខ្វះ ប្រមោយ ខ្វះខ្ជូន ខ្វះដើង ខ្វះខ្នង ខ្វះកន្ទុយ ខ្វះឲ្យស្ទាបត្រង់ចុងកន្ទុយ ។

បុរសនោះក៏ចាត់ការឲ្យស្ទាបដំរីតាមព្រះរាជឧង្ការសព្វគ្រប់ ក៏ត្រឡប់ មកក្រាបបង្គំទូលវិញ ។ ព្រះរាជាក៏ទ្រង់ស្តេចយាងទៅកាន់សំណាក់ ពួកជនឆ្ងាក់ទាំងនោះ ហើយទ្រង់មានព្រះរាជឧង្ការថា នែអ្នកទាំងឡាយ ចូរនិយាយតាមពិតតាមមែន ដោយចំណាំរបស់ខ្ជូន អ្នករាល់គ្នាធ្លាប់បាន ឃើញដំរីប្ដទេ? ដំរីតើដូចម្តេច? ដូចអ្វីខ្លះ? ។ ពួកជនងងឹតក្នែកពី កំណើតទាំងនោះ ក៏ក្រាបបង្គំទូលតាមសញ្ញារបស់ខ្ជូន គឺពួកអ្នកស្ទាប ក្បាលដំរី ក្រាបបង្គំទូលថាដំរីដូចក្អមទឹក, ពួកអ្នកស្ទាបត្រចៀកថាដំរី ដូចចង្អេរ, អ្នកស្ទាបក្ងុកថាដំរីដូចជាលនង្គ័ល, អ្នកស្ទាបប្រមោយថា ដំរីដូចយាមនង្គ័ល, អ្នកស្ទាបខ្ជូនថាដំរីដូចដោកស្ទូរ, អ្នកស្ទាបដើងថា

ជំរីដូចសសរផ្ទះ, អ្នកស្ថាបខ្នងថាជំរីដូចត្បាល់, អ្នកស្ថាបកន្ទុយថា ជំរីដូចអង្រ, ពួកអ្នកស្ថាបចុងកន្ទុយជំរី យកសេចក្តីក្រាបបង្គំទូលថា ជំរីដូចអំបោសសំរាប់បោសសំរាម ។ ពួកជនខ្វាក់ទាំងនោះក៏តាំង ប្រកែកគ្នា ជជែកគ្នាយ៉ាងម្ចឹងម៉ាត់ ជណ្តើមយកផ្ទូវត្រូវផ្ទូវពិតតែរៀងខ្លួន រហូតដល់ឈ្លោះគ្នាយ៉ាងធំ ទៅជាដាល់តប់គ្នាទាត់ជាក់គ្នាពេញទំហឹង ។ សម័យនោះព្រះរាជាក៏ទៃង់ព្រះសំរួលក្អាកក្អាយដោយអត់ទ្រាំពុំបាន ។

ម្នាលភិក្ខុទាំងឡាយ បរិព្វាជកទាំងនោះ គ្មានបញ្ញាចក្ខុងងឹត ងងល់ វង្វេងអត្ថក៏មិនដឹង មិនមែនអត្ថក៏មិនដឹង, ធម៌ក៏មិនដឹង មិនមែនធម៌ក៏ មិនដឹង ម្ហ៉ះហើយទៅជាឈ្លោះគ្នា ជណ្តើមយកត្រូវដោយសព្វខ្លួន ដូចបុគ្គលខ្វាក់អំពីកំណើតទាំងនោះឯង ។

សន្ធិដ្ឋិបរាមាសិតា សេចក្តីប្រកាន់មាំនូវសេចក្តីយល់ឃើញរបស់ ខ្លួនថាត្រូវថាពិត ថាការយល់ឃើញរបស់អ្នកដទៃ មិនត្រូវមិនពិតនេះ ក៏ជាហេតុឲ្យកើតវិវាទទាស់ទែងគ្នា ប្រហែលគ្នានឹងរឿងមនុស្សខ្វាក់ស្ថាប ជំរីនោះឯង ។

ចំណែកធម៌វិន័យព្រះពុទ្ធសាសនា ជ្រាលជ្រៅពេកណាស់ ច្រើន ក្រៃលង មិនងាយនឹងចេះចាំចូលចិត្តសព្វគ្រប់ ពុទ្ធសាសនិកជនខ្វះ ប្រកាន់ថាខ្លួនត្រូវ គេខុស បណ្តាលឲ្យទៅជាវិវាទទាស់ទែងគ្នា នាំឲ្យ ជ្រោកជ្រាកព្រះពុទ្ធសាសនា ក៏ដូចគ្នានឹងមនុស្សខ្វាក់ស្ថាបជំរីនោះដែរ ។

អាត្មាភាពសំដែងមកក្នុងវិវាទមូល ៦ ប្រការមកនេះ ក៏សូមបញ្ចប់ ទេសនាត្រឹមតែប៉ុណ្ណេះ ឯវំ ។

បញ្ញាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម-សុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្ជនឯង

កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦ ត.ស. ១៩៤៣

(តមក)

មហាសុរសេនជាតក ទី ១៤

លោកអាចារ្យ មៀវ-ឌន្ត វត្តលង្កា

ប្រែពីបាលី

ឯកស្មឹ កិរ សមយេ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

កិរ ជូចបានព្ទរៀងៗ មកថា ក្នុងកាលសម័យថ្ងៃមួយ សម្តេចព្រះភគវន្តាចារ្យសម្មាសម្ពុទ្ធ ទ្រង់គង់សម្រេចសម្រាន្តព្រះឥរិយាបថ ក្នុងវត្តជេតពនមហាវិហារ ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ត្រានោះព្រះដ៏មានសិរី ទ្រង់ត្រាស់ហៅភិក្ខុតាំងឡាយមកថា ភិក្ខវោ ម្មាលភិក្ខុតាំងឡាយ ចូរអ្នកតាំងឡាយមកអាយ ។ ភិក្ខុតាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថាព្រះករុណាវិសេស ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងដូច្នេះថា

អតីតេ ភិក្ខវេ ម្មាលភិក្ខុតាំងឡាយ, ក្នុងកាលភពកន្តកំបាំងបាត់ស្ងាត់យូរណាស់ហើយ មានមហាក្សត្រាធិរាជមួយព្រះអង្ត ព្រះនាម-

មហាកត្តុ សោយភាជសម្បត្តិកន្ទនវនេះឯង ។ មានអគ្គមហេសី ๑ ព្រះអង្គ ព្រះនាមចន្ទាទេវី ជាស្ត្រីប្រកបដោយកល្យាណធម៌ទាំង ๕ ប្រការគឺ បព្វជ្ជាយនី ជាស្ត្រីក្រោកឡើងមុនព្រះរាជា ๑, បច្ឆាទនីជាតិនី ជាស្ត្រីបរិភោគទឹកដុំក្រោយព្រះរាជា ๑, និពាសង្គបតិសេវិនី ជាស្ត្រីរួមសំវាសជាមួយនឹងស្វាមី ឥតមានគំនិតអាក្រក់ ๑, បិយភាណី ជាស្ត្រីមានសំនីយពីកេះ គួរឲ្យព្រះរាជាផ្ទៀងព្រះកាណ៌ចាំស្តាប់ ๑, មនាបថាវិនី ជាស្ត្រីចេះធ្វើបំផ្លុនព្រះរាជស្វាមីមិនឲ្យត្អូកឆ្អែតព្រះរាជហ្ឫទ័យសោះ ๑ ។ ព្រះនាងនោះជាទីស្រឡាញ់ពេញព្រះរាជហ្ឫទ័យ នៃព្រះរាជាព្រះអង្គនោះយ៉ាងក្រៃលែង ។ ព្រះរាជាអង្គនោះ ទ្រង់មានព្រះរាជបុត្រា ๕๐๐ ព្រះអង្គ ចំរើនវ័យធំឡើងហើយ សុទ្ធតែជាបុរសមានរូបឆោមលោមពណ៌ល្អប្លែក ๆ ។

គ្រានោះ ព្រះបរមពោធិសត្វ ទ្រង់ជាព្រះឥន្ទ្រាធិរាជគង់លើវេជយន្តប្រាសាទ ល្អស្អាងស្អាតនៅកន្លែងវិមាន ๑ ម៉ឺនយោជន៍ ហើយទ្រង់សោយទិព្វសម្បត្តិកន្ទនពិភពតាវត្តឹង្ស ទ្រង់ទតឃើញពួកមនុស្សកំសត់ទុគ្គតអនាថា ទើបទ្រង់ថ្លែងដើម្បីសង្គ្រោះដល់សព្វសត្វ ទ្រង់ប្រមើលមើលបញ្ចវិលោកនៈទាំង ๕ ប្រការគឺ កាល ๑ ប្រទេស ๑ ទ្វីប ๑ តក្កូល ๑ មាតា ๑ ទើបស្តេចចុតិមកចាប់បដិសន្ធិកន្លែងផ្នែនាងចន្ទាទេវីនោះឯង ។ លុះគ្រប់ខែ ๑๐ ព្រះនាងទ្រង់ប្រសូតព្រះរាជបុត្រ ល្អបំផុតដូចជាសុវណ្ណបតិមា ព្រោះហេតុនោះបានជាក្រុមព្រះរាជវង្សទ្រង់ថ្វាយព្រះនាមថាសុវណ្ណកុមារ ។ លុះចំរើនវ័យវឌ្ឍនាការឡើងកាលណា មានព្រះឆោម

ល្អឆ្ងែតនាយ មានព្រះកាយប្រកបដោយកម្លាំងច្រើន ចេះចប់សព្វវិជ្ជា
ល្បីខ្ចរខ្ចាយដោយសិល្បៈ ក្នុងគ្រាដែលមានព្រះជន្មគំរប់ ១៦ ព្រះវស្សា ។

ក្នុងថ្ងៃមួយ ព្រះពជាជាបិតាទ្រង់ចាត់ឲ្យពួកពលសកលយោធាមក
ប្រជុំគ្នាត្រៀបត្រា ទើបទ្រង់ត្រាស់ចំពោះមហាសេនាបតីថា "ម្នាលព្រះ
ស្តេងគាំងឡាយ, មហាសមុទ្រធំវែងឆ្ងាយល្វឹងល្វើយ មើលមិនឃើញ
កោះត្រើយ ពេញពាសដោយកែវសត្តប្រការ មានទំនងគួរឲ្យជ្រះថ្លា
យើងចង់យាត្រាទៅកំសាន្តឯមហាសមុទ្រនោះ យើងមុខជានឹងឃើញ
សេចក្តីអស្ចារ្យនៅនាសមុទ្រនោះមិនខាន ។" ទើបពួកសេនាយោធាក្រាប
បង្គំទូលថា បពិត្រមហារាជ អំពីមុនមកយើងខ្ញុំទូលព្រះបង្គំគាំងឡាយ
ក៏តុំដែលបានឃើញមហាសមុទ្រនោះដែរ ។ លំដាប់នោះ ព្រះពជា
ទ្រង់មានពួកពលសកលយោធាគាំង៤ក្រុមមានក្រុមសេនាគាហានជាដើម
ចោមរោមជាបរិវារ ព្រមគាំងព្រះពជបុត្រាមានសុវណ្ណកុមារជាប្រធាន
ហែហមអមព្រះអង្គទៅតាមផ្លូវ ដែលដោតទង់ជាយទង់ជ្រងគាសពេញ;
អាកាសវេហាស៍ ខ្ចរខ្ចាយដោយស័ព្ទក្ងេរក្ងូតត្បូរត្ងន្ទ្រឺ អង្គប្រាំប្រការ,
ទើបព្រះបរមពជា ទ្រង់ស្តេចយាត្រាចេញទៅតាមជាចិនទិសជាមួយនឹង
ពជកញ្ញាគាំងឡាយចំនួន ២ ម៉ឺនដូចជាដំណើរនៃព្រះឥន្ទ្រាធិពជ ដែល
ស្តេចទៅកាន់នន្ទវនុទ្យាន, ទ្រង់ស្តេចគគាតតាមហ្វូងហែ បែរព្រះ
កក្ខាគតកូមិភាគប្រទេសនានាតាមមគ្គាគួរឲ្យត្រេកអរ, នឹងសមុទ្រសា-
គរមានអង្គ ៤ ហើយមានព្រះពជហ្ឫទ័យពេញដោយបីតិ ទើបទ្រង់
ត្រាស់បង្គាប់អាមាត្យគាំងឡាយថា នែអ្នកគាំងឡាយអើយ, ចូរបបួល

គ្នាលង់ភ្លេងតូរ្យតន្ត្រី តាមសេចក្តីពេញចិត្តក្នុងដំនេះចុះ ។ ព្រះពាជានោះទ្រង់ក្រសាលក្នុងសមុទ្រអស់ប៉ុន្មានវេលា ទ្រង់ក្រសាលលេងផ្សេងៗនៅនាផ្នែរមហាសមុទ្រ ដោយតេជានុភាពនៃព្រះមហាសត្វ សូម្បីសព្វសត្វពាឡយដ៏ឃ្លង់មានក្រែពីនដ៏មក្កវជាដើម ក៏មិនហ៊ានបៀតបៀនអ្នកណាមួយឡើយ ។

ចំណែកខាងព្រះបរមពោធិសត្វ ទ្រង់ថ្វាយបង្គំសំដែងបុញ្ញានុភាពរបស់ព្រះអង្គ ទើបទ្រង់ព្រះចិន្តាថា កាលណាហ្ន៎! អាត្មាអញនឹងបានត្រែចទៅលើទឹកមហាសមុទ្រ ដូចជាត្រែចទៅលើផែនដីបាន ។ គ្រានោះពួកទេវតាដែលរក្សាសមុទ្រ ក៏នាំយកដំរីគជេន្ទនេន្ទ្រវ័តន៍ មានរូបពាន់សស្តុទ្ធ ប្រាកដជាដំរីមង្គល មកថ្វាយព្រះបរមពោធិសត្វ ក្នុងពេលដែលព្រះអាទិត្យរះឡើង ។ ព្រះបរមពោធិសត្វ កាលបានព្រះពាជយានដ៏ទុត្តមហើយ ក៏មានព្រះពាជហ្ឫទ័យរីករាយត្រែករអរ ទ្រង់ស្តេចទៅដោយព្រះពាជយានដំរីរតន៍ប្រពៃ ដូចស្តេចឡើងកាន់គជរ័តន៍. ក្នុងវេលាប្រកបដោយនក្ខត្តឫក្សល្អរង៉ាវរឿង ហាក់ដូចព្រះអាទិត្យពេញពន្លឺបិតនៅលើកំពូលភ្នំ ។ ឯពួកមហាជនបានឃើញហេតុអស្ចារ្យ ដែលមិនធ្លាប់កើតដូច្នោះហើយ ក៏រោមក៏ស្បែក គ្រហឹបឆ្អឹងព្រមៗគ្នា ។ ព្រះបរមពោធិសត្វ ស្តេចទ្រង់បវរព្រះទីនាំងគជេន្ទចូលក្នុងមហាសមុទ្រ ព្រមទាំងមហាជនចោមរោមហែហមជាបរិវារ ។ ឯដំរីគជសារនោះ បើមានមុខឆ្ពោះទៅត្រង់ណា, ទឹកសមុទ្រជលសាមានប្រមាណ ៨៤ យោជន៍ក៏កំរើករំកើបបែកខ្ញែកជាពីរចំណែកដូចជាជញ្ជាំងផ្ទះ ។ ដោយបុញ្ញានុភាព

ព្រះពោធិសត្ត មហាជនតាំងអស់ត្នាដែលដើរនៅកណ្ណាលសមុទ្រយ៉ាង
នេះ ក៏ឥតមានត្រូវដំណក់ទឹកមួយត្រាប់ទ្បើយ ត្បូរឲ្យអស្ចារ្យ ត្បូរឲ្យរីក
រាយពន់ពេកណាស់ ។ សមុទ្ទកញ្ញាតាំងឡាយ បានឃើញពួកមហាជន
មកកាន់មហាសមុទ្រដូច្នោះ ក៏រោយរាយលំអិតគន្ធពិដោរ យកផ្ការកម្រង
មកចងថ្វាយព្រះបរមពោធិសត្ត ហើយទៅបាំស្ការត់ពាក់កណ្ណាលផ្ទូវនោះ
យកកែវមណីសព្វប្រការ មករចនាជាផ្ការចង្ការមមាស ៥ ពណិ ព្យួនៅ
ទីតាំងសងខាងនៃជញ្ជាំងទឹក ។ ឯស្ពេចនាគរាជ ព្រមតាំងស្រីរបាំ
តាំងប៉ុន្មានមកចោមរោមជុំវិញ ។ ពោធិសត្ត ទ្រង់សោយភោជនាហារ
ដែលពួកសមុទ្ទកញ្ញា នឹងនាគរាជកញ្ញារៀបចំថ្វាយទ្រង់សោយសម្បត្តិ
ហាក់ដូចជាសម្បត្តិទិព្វគ្រប់ប្រការក្នុងមហាសមុទ្រនោះអស់ប៉ីថ្ងៃ ។

លំដាប់នោះ ព្រះវររាជមាតាបិតាតាំងឡាយ កាលដែលព្រះរាជ-
បុត្រស្ពេចចេញទៅយូរពេក ទ្រង់បញ្ជូនអាមាត្យឲ្យទៅតាមថា នៃព្រះ
ស្ពែងតាំងឡាយ, ចូរឯងទៅតាមយកកូនអញមកវិញ ។ ឯពួកអាមាត្យ
សោត ក៏ទៅកាន់មហាមុទ្របានដូចជាផ្ទូវមនុស្សដែរ ព្រោះតែតេជះ
ព្រះបរមពោធិសត្ត, ទើបថ្វាយបង្គំទូលសព្វសេចក្តី ។ ព្រះពោធិសត្ត
ទ្រង់ព្រះសណ្ណាប់ពាក្យនោះហើយ ទ្រង់ត្រាស់ថា "ល្អហើយ ។
អាមាត្យ" ។ ទើបទ្រង់ត្រាស់ហៅពួកសមុទ្ទទេវតា នឹងពួកនាគរាជមក-
ថា នៃអ្នកតាំងឡាយ យើងលាអ្នកតាំងឡាយហើយ, ព្រោះព្រះវររាជ-
មាតាបិតាយើងនៅធ្នេរសមុទ្រឯណោះ ទ្រង់បញ្ជូនរាជសារមកជល់យើង ។
លំដាប់នោះ សមុទ្ទទេវតាតាំងឡាយ ក៏នាំត្នាមកថ្វែងទុក្ខថា "ឧ ហ្នា

ម្ចុះគួរឱ្យស្តាយជីវិតរបស់យើងទាំងឡាយ រស់នៅឥតផលសោះ ព្រោះបើបាច់ថែរក្សាអ្នកណា អ្នកនោះទៅចោលឥតស្រណោះ" ទើបថ្វាយបង្គំផ្សេង ។ ដល់ព្រះបរមពោធិសត្វថា សូមព្រះអង្គឱ្យពួកអាមាត្យទូលគេរីឃោសនាប្រាប់មហាជនថា អ្នកណាត្រូវការតែវមណ៌ ចូរមកយកចុះកុំបង្អង់ ។ ពួកកងទ័ពទាំងអស់ក្តីដូច្នោះ ក៏ត្រេកអរសាទរជាពន្លឹក ហើយបវរខ្នេះសេះដ៏វិសេសតែកែវមានទឹមសារ ពេញការុងកន្ត្រែង ហើយថ្វាយគុណព្រះបរមពោធិសត្វទៀតថា ព្រះនាងចន្ទទេវីជាស្រីប្រកបដោយផល, ព្រះពជាសោត ក៏ជាបុគ្គលប្រកបដោយផលដែរ, ដៃនរបស់យើង ក៏ប្រកបដោយផលដែរ ។

ព្រះសុវណ្ណកុមារ បង្គាប់មនុស្ស ឱ្យយកកែវមានទឹមសារសព្វគ្រប់ប្រការ ហើយទើបទ្រង់ស្តេចយាត្រាត្រឡប់ទៅជាមួយមហាជន ក្រាបថ្វាយបង្គំព្រះវរមាតាបិតាបូជាកែវមានទឹមសារទាំងអស់ នឹងត្រឹងប្រជាប់ប្រជាទាំងឡាយ ។ គ្រានោះ ព្រះពជានឹងព្រះនាងទេវីទ្រង់ទតឃើញកែវមានទឹមសារដែលទ្រង់មិនធ្លាប់ឃើញអំពីដើម ក៏មានព្រះពជហ្ឫទ័យរីករាយ· ចាប់បបោសអង្អែលព្រះសុវណ្ណកុមារ ផ្តេកលើព្រះឧរ ទ្រង់គ្រាស់សរសើរបុណ្យសព្វគ្រប់ប្រការ ។

ព្រះពជាទ្រង់ទទួលរតនវត្ថុទាំងនោះហើយ ទ្រង់បញ្ជូនព្រះសុវណ្ណកុមារឱ្យទៅដំរីមង្គលមានសំបុរសសុទ្ធ មានពួកពលសេកលយោធាទាំង ๔ ក្រុម ហែហមអមព្រះអង្គទៅមុខ, ទើបព្រះអង្គទ្រង់ស្តេចទៅតាមក្រោយ, កាលទ្រង់ទតឃើញសិរីសម្បត្តិរបស់ព្រះសុវណ្ណកុមារហើយ

ក៏ពេញ្រពះរាជហ្ហូទ័យពន់ពេកណាស់ ។ ត្រានោះ ពួកទេវតាយក
រតនៈសួយសារអាករអំពីហានតាវតឹង្ស មកបំពេញកន្ទេងមានជង្រុកជា
ដើម ឲ្យពេញតតទ្ទះកន្ទះអ្វីទ្បើយ ទើបនាំគ្នាត្រឲ្យប់ទៅវិញ ។ នតរ
នោះ ដែលមានជំរីតជេនួនរេនួតជសារ ក៏ហាក់ជួបជានតរ្រះសហស្ស-
ន័យតន្ទ្រាធិរាជ ដែលអាចសម្រេចកិច្ចត្រប់យ៉ាង ដោយសារសំណាង
តេជានុភាពព្រះបរមពោធិសត្ត ។

សួរថាចុះហេតុអ្វី ចានជាព្រិះបរមពោធិសត្ត ចានរតនៈសួយសារ
អាករត្រប់យ៉ាងអំពីសមុទ្រជួច្នេះ ។ ធ្វើយថា ក្នុងកាលកន្ទងទៅហើយ
ព្រះបរមពោធិសត្ត កើតជាបុត្រសេដ្ឋីនៅក្នុងក្រុងពារាណសី មានរូប
ធោមល្អ មានចិត្តក្ដៀវក្ដាប្រាថ្នាតែឲ្យទាន ។ ថ្ងៃមួយមានអគ្គសាវ័កព្រះ
ពុទ្ធវិបស្សី ១ អង្គ កំពុងត្រេចទៅបិណ្ឌបាត ។ បុត្រសេដ្ឋីនោះក្រឲ្យក
ឃើញតវិយាបថលោកសេតត់សេតំរម្យទម្យល្អគួរឲ្យជ្រះថ្ងា ក៏យកបាត
មកបំពេញដោយភោជនាហារ ទើបជ្ជួចទឹកស្នោទកទូលថា បពិត្រ
ព្រះករុណាដ៏ចំរើន, សូមព្រះករុណាទទួលកត្តជានិច្ចក្នុងផ្ទះខ្ញុំកុំទាន ។
ព្រះថេរៈក៏ទទួលប្ពេជ្ញាហើយក៏ទិមន្ទចេញទៅ ។ តមកថ្ងៃមួយ ព្រះ
ថេរៈធ្វើអនុមោទនាក្នុងវេលារួចកត្តកិច្ចដោយបទគាថាថា:

ន ភោធញ្ញ បញ្ញវេរំ ករុវាបំ កណាន្ត្ថិ យេ
តេ តិវិធញ្ញ សម្ឃត្ថឹ លភន្ត្ថិ ពុទ្ធសេវិតន្ត្ថិ ។

ជនទាំងឲ្យាយឯណា មិនធ្វើនូវសេចក្ដីក្រោធផង, នូវ
វេរាទាំង ៥ ផង, នូវសំដីធ្ងន់ផង, ជនទាំងឲ្យាយនោះ

រមែងបានសម្បត្តិ ៣ ប្រការ ដែលព្រះពុទ្ធដាសាស្តាទ្រង់
សេពហើយ ។

បុត្រសេដ្ឋីបានស្តាប់ដូច្នោះហើយ ក៏មានបីតិផ្សព្វផ្សាយពេញ
សព្រាង្គកាយ ទើបថ្វាយបង្គំទូលថា ល្អហើយ ។ ព្រះគុណម្ចាស់, ខ្ញុំសូម
យកលោកម្ចាស់ជាទីពឹងស្មើជីវិត, ចាប់តាំងពីថ្ងៃនេះតទៅ សូមលោក
ម្ចាស់ជាអាចារ្យប្រដៅធម៌អាថិដល់ខ្ញុំព្រះករុណា ជានិច្ចកុំឲ្យខានឡើយ ។
ព្រះថេរក៏ទេសនានិច្ចធម៌ឲ្យស្តាប់ ។ សេដ្ឋីបុត្រក៏ប្រព្រឹត្តតាមឧរាទ
ព្រះថេរតរៀងទៅ ។

កាលនោះ មានពួកឈ្ឆ្ញញសំពៅទាំង ៥០០ ប៉ើកក្តោងចេញពីនគរ
នោះ សំដៅទៅសីហឡទ្វីប ដើម្បីជួញប្រៃ ក៏ជំណាលសរសើរសិរី
សម្បត្តិព្រះសុវណ្ណកុមារ នឹងជំរីតជសាតែរាល់ ។ មាត់ ។ អ្នកសីហ-
ឡទ្វីប ក៏នាំសេចក្តីនោះទៅក្រាបបង្គំទូលព្រះបាទភដេសុររាជ ។ ព្រះ
រាជាអង្គនោះ បានទ្រង់ព្រះសវនាការព្ធដំណឹងនោះហើយ ទ្រង់ព្រះ
ពិរោធក្រេវក្រោធមហិមា ទើបត្រាស់ហៅពួកឈ្ឆ្ញញនាវាមកសួរ ។
ពួកឈ្ឆ្ញញក្រាបបង្គំទូលថា ... បពិត្រព្រះរាជសម្ការ, ព្រះរាជបុត្ររបស់
ព្រះរាជា ជាម្ចាស់ខ្ញុំព្រះអង្គទាំងឡាយព្រះនាមព្រះសុវណ្ណកុមារ មាន
ឬទ្ធិច្រើនចំរើនមានអានុភាពធំ អាចញ្ចាំញីនូវសេនាស្តេចជទៃបាន សូម្បី
ទុកជាមហាក្សត្រទាំង ១០១ ក៏មិនហ៊ានឈមព្រះភក្ត្រទៅរកព្រះអង្គដែរ
បពិត្រព្រះរាជសម្ការ ព្រះរាជបុត្រមានអានុភាពធំយ៉ាងនេះ ។ ព្រះរាជានោះ
លុះទ្រង់ព្រះសណ្ណាប់ពាក្យពាណិជហើយ ក៏រិតតែទ្រង់ព្រះពិរោធដូចជា

នាគរាជ ដែលគេប្រហារកន្ទុយដោយដំបងដែក ទើបត្រាស់ហៅយោធា
ទាំង ៤ នាក់ ដែលក្ងៀវក្ងា អាចសម្រេចកិច្ចសព្វប្រការបាន មកបង្គាប់
ថា ចូរព្រះស្តេងទៅនគរពារាណសី ជាមួយនឹងពួកពាណិជទាំងនេះ
ហើយប្រាប់ស្តេចមហាកត្តរាជថា ព្រះបាទកដេសុររាជ នៅសីហឡទ្វីប
មានអានុភាពច្រើន តេជះច្រើន ពលច្រើន ពួកស្តេចដទៃតែងបូជា
ទាំងដំរីសោតក៏មានកំឡាំងក្ងៀវក្ងា ឥតមានអ្នកណាស្មើឡើយ ហេតុ
ដូច្នោះ ចូរព្រះអង្គនាំយកដំរីសសុទ្ធ ដែលប្រកបដោយលក្ខណៈគ្រប់
ប្រការទៅ ថ្វាយព្រះរាជាជាម្ចាស់យើងនោះ, បើមិនដូច្នោះទេ មុខជា
ព្រះរាជានោះនឹងធ្វើនគរពារាណសី ឲ្យខ្ទេចខ្ទីដល់ទូវសេចក្តីទុក្ខលំបាកមិន
ខាន ។ ពួកយោធាទាំង ៤ នាក់នោះ ក៏ទទួលព្រះរាជឧន្ការ ចេញទៅ
ដល់នគរពារាណសី ជាមួយនឹងពួកឈ្មួញ ទូលព្រះបាទមហាកត្តរាជ
សព្វសេចក្តី ។ ព្រះបាទមហាកត្តរាជព្រះចៅក្រុងពារាណសី ក៏កិតកំយតក់
ស្ងុតមហិមា ម្នីម្នាត្រាស់ហៅពួកសេនាបតី ឧបរាជ បុរោហិត ព្រះរាជ-
បុត្រាមកប្រាប់ថា ស្តេចកដេសុររាជ មានពលច្រើន មានអានុភាពច្រើន
ឲ្យយោធាមកហៅខ្ញុំទៅ, តើដំណើរនេះជាគួរទៅឬមិនគួរ? ចូរអ្នករាល់គ្នា
ពិចារណាហើយប្រាប់ខ្ញុំឲ្យធាប់ ។ ។ ពួកសេវកាមាត្យទាំងនោះ គ្រាន់
តែឌ្វដូច្នោះ ក៏កិតកំយកាំងស្មារតីនៅស្ងៀមតែរៀងខ្លួន ។ ចំណែក
ខាងព្រះសុវណ្ណកុមារ ឌ្វថាព្រះវរបិតាមានទុក្ខព្រួយព្រះរាជហ្ជុទ័យដូច្នោះ
ក៏ក្រាបបង្គំទូលថា បពិត្រព្រះវរបិតា, សូមទ្រង់កុំបារម្ភឡើយ, សូម
ទ្រង់គង់ជាសុខចុះ ជានាលើខ្ញុំព្រះអង្គ នឹងទៅនាំស្តេចកដេសុររាជព្រម

ទាំងពួកពលសកលយោធាឲ្យមកក្រាបថ្វាយបង្គំព្រះបាទាព្រះអង្គបាន ។ ទើបព្រះរាជបិតាត្រាស់តបទៅវិញថា ហៃកូនពុំដា, កូនឯងក្មេងណាស់ ស្តេចភជេសុររាជនោះ មានអានុភាពនឹងតេជះច្រើន. ដែនរបស់គេសោត ក៏ធំណាស់ផង, យោធាទាហានគេសោត ក៏ក្លៀវក្លាណាស់, បាឯងអាចទៅនាំស្តេចនោះមកដូចម្តេចបាន ។ ព្រះសុវណ្ណកុមារ ក្រាបបង្គំទូលថា បពិត្រព្រះវរបិតា. សូមទ្រង់កុំមានព្រះរាជឧត្សាវដូច្នោះឡើយ! បើទុកជាស្តេចភជេសុររាជ មានពួកពលសកលយោធាក្លៀវក្លាជល់ម្ចោ៉ះក៏ដោយ, ក៏គង់ខ្ញុំព្រះអង្គត្របសង្កត់ដោយតេជះបានដែរ ។ ឯពួករាជ-អាមាត្យ បានស្តាប់ព្រះបន្ទូលព្រះសុវណ្ណកុមារដូច្នោះហើយ ក៏មានបីតិផ្សព្វផ្សាយពេញទាំងសពាង្គកាយ ថ្វាយស័ព្ទសាធុការពរដល់ព្រះរាជ-កុមារថា សាធុ សាធុ. បើព្រះអង្គទ្រង់ស្តេចទៅហើយ មុខជាបានសម្រេចការតាមប្រាថ្នាពុំខាន ។ ឯព្រះមហាក្សត្រក៏មានព្រះបន្ទូលយ៉ាងនេះថា ត្រូវហើយកូន ត្លូវបាទៅចុះ ។ ក្នុងខណៈនោះឯង ព្រះមហា-ក្សត្រ ក៏ទ្រង់ចាត់ឲ្យយកគ្រឿងកកុធភណ្ឌទាំង ៥ គឺ ស្វេតច្ឆ័ត្រ, ព្រះចាមរ, មកុដ, ព្រះខ័ន, ព្រះសុវណ្ណបាទុកា ហើយទ្រង់អភិសេកព្រះរាជកុមារ ។ ព្រាហ្មណ៍បុរោហិត បណ្ឌិត កវី អង្គុយជិតជុំវិញ យកក្អមមាសដាក់ទឹកពេញ ។ ដំកល់ទុកត្រៀបត្រា. បញ្ឈរដើមអំពៅ ដើមចេកដោតទង់ជាយទង់ជុងត្រប់ទិសទាំងបាំបី ទើបព្រះចក្រីទ្រង់ផ្ទើតំនរកែវដែលមានរស្មីក្នុងកណ្ណាលដំណាក់មាស មានឧភាសភ្លឺអស្ចារ្យ, ទើបឲ្យព្រះសុវណ្ណកុមារ ទ្រង់ត្រឿងកកុធភណ្ឌទាំង ៥ គង់ក្នុង

ដំណាក់មាសនោះ, ពួកជនចាស់ៗក្នុងនគរនោះ ថ្វាយសំពួសាធុការ
អភិសេកព្រះសុវណ្ណកុមារឲ្យសោយរាជ្យឡើង ។ ព្រះរាជកុមារ លុះ
បានការាភិសេករួចហើយ មានពួកចតុរង្គសេនាចាមរាមដង្ហែព្រះអង្គ
ចេញទៅ កាលវេលាប្រកបដោយនក្ខត្តឫក្សល្អ ។ ក្បួនទ័ពព្រះរាជាគួរ
ឲ្យសំបើមអស្ចារ្យ ត្រៀបត្រាដោយស្បែតច្ឆត្រកូស់កំអភិរម្យ ទង់ជ័យ
សំពោងព្រាងព្រាត ដូចជាផ្កាយលើអាកាស ។ ត្រាដែលព្រះរាជា
ចេញចាកព្រះនគរទៅនោះ កាលពេលប្រកបដោយនក្ខត្តឫក្សជាំជយមង្គល
មានជំនះ៧ជាន់ មានពួកពលសកលយោធាហែពីខាងមុខ ទ្រង់គង់
លើខ្នងព្រះទីនាំងគជេន្ទ្រជាមង្គល់មានសម្បុរសស្អុះ ជាព្រះរាជពាហនៈ
ដ៏ប្រសើរ អាចញាំញីទ្រូវពួកសត្រូវបក្ខាមិត្រក្នុងមណ្ឌលសីហឡទ្វីប
បាន ជាដំរីមានអវយវៈធំ ដែលគេតាក់តែងវិចិត្រដោយគ្រឿងក្រាក់
មាសខ្សែរយន៏ងកែវមណី មានពួកបណ្ដាជនបើកបាំងដោយកូសន៏ង
ស្បែតច្ឆត្រដ៏រុងរឿង មានពួកសេនាយោធាទាហានតម្រៀបជាដួរជាជាន់
ដោយពួកដោយកង ដៃកាន់ដំបង ក្បាន់ដាវ កាន់ព្រះខ័ន កាន់លំពែង
ស្នែងក្របី មានគ្រឿងន្ត្រីគ្រែ សំឡេរគាំង កេរ៉ បន្ទឹឡើងគ្រហឹងអឺងអាប់
តាន់តាប់ដោយទង់ដែលវិចិត្រដោយរូបផ្សេង ។ ព្រះសូរសំពួសំឡេងពួក
ព្រាហ្មណ៍ពិន្ធុបុរោហិតការីស្រែកថ្វាយពរជ័យ ព្រះចក្រីទ្រង់មានពួក
សេនាយោធាចោមរោមជាបរិវារ ទ្រង់ធ្វើព្រះរាជគមនាការចេញចាកក្រុង
ភាពណាសីប៉ុរីរាជធានីនោះសំដៅទៅទីសីហឡទ្វីប ។

(មានត)

កម្លាំងនៃសាមគ្គី

និទានសុភាសិតរឿងតន្ត្រកសូកវៈ

ព្រះមហា មៅ-ខាន់ ក្រុមជំនុំព្រះត្រៃបិដក រៀបរៀង

សាមគ្គី គឺសេចក្តីព្រមព្រៀងនៃជនអ្នកនៅរួបរួមគ្នាជាពួកជាសង្គម ដោយផ្សំស្ពាប់បង្គាប់បញ្ជានឹងគ្នាជាដើម របស់អ្នកដែលជាប្រធាន ស្ទុះចិត្តគ្នាដើរតាមគ្រោយដោយសេចក្តីគោរព ជាកម្លាំងអាចប្រកាសទូវាវៈរឹងប៉ឹង មាំមួន នៃពួកសង្គម ឲ្យជាទីកោតខ្លាចដល់ពួកសត្រូវនានា អាចការពារភយន្តរាយដ៏កំណាច ឧឡារិកឲ្យចាកបបដោយរៀបរយ ញុំាងសេចក្តីសុខក្សេមក្សាន្ត រុងរឿងឲ្យកើតមានឡើង ដូចរឿងតន្ត្រកសូកវៈដែលទើបនាំមកពណ៌នាតទៅនេះ ៖

កុងអតីតកាល មានជាងឈើម្នាក់ តាំងគ្រឹះបំពាននៅស្រុកមួយក្បែរទ្វារក្រុងពារាណសី ។ ថ្ងៃមួយជាងឈើនោះចូលទៅកាន់ព្រៃដើម្បីរកឈើមកធ្វើការរបស់ខ្លួន បានឃើញកូនជ្រូកមួយតូចធ្លាក់ទៅកុងអណ្តូងក៏ចាប់យកមកចិញ្ចឹមទុក ឲ្យឈ្មោះតន្ត្រកសូកវៈ ។ តន្ត្រកសូកវៈនោះបានធ្វើការជួយកម្លាំងជាងឈើជាច្រើន គឺជួយត្រមៀលឈើដោយច្រមុះជួយលាតខ្សែបន្ទាត់ដែលម្ចាស់ចង់គ្រង់ច្រមុះ ពាំគាំបិត ពន្លាក ពួរថៅ ញញួរទៅឲ្យ លុះជ្រូកនោះធំឡើងក៏មានកម្លាំងច្រើន មានខ្លួនជាត់ធំ ។ ជាងឈើបានតាំងមេត្តាចិត្តអាណិតស្រឡាញ់ទុកស្មើកូនរបស់ខ្លួន ខាង

ស្រែកយមកគិតថា បើខ្ញុកជ្រកនេះឲ្យទៅក្នុងទីនេះតទៅ មុខជាមានអ្នកណាមកបៀតបៀន ទើបនាំទៅលែងក្នុងព្រៃ ។ តច្ចកសូករៈគិតថា អាគ្នាអញមិនអាចទៅកន្លងព្រៃតែម្នាក់ឯងបានទេ ត្រូវតែស្វែងរកញាតិមិត្រមកបួរបួមគ្នា តាំងជាឡូកំបានទៅទើបបាន គិតហើយក៏ត្រាច់ដើរស្វែងរកទៅតាមព្រៃញាតិសន្ទាត កាលបានប្រទះហ្វូងជ្រូកជាច្រើនក៏មានសេចក្តីត្រេកអរ ទើបពោលថា យើងត្រាច់ដើរស្វែងរកពួកញាតិឯណាតាមព្រៃកុំគ្រាំគ្រៃថ្ងៃដំឡូយ ឥឡូវនេះយើងបានជួបប្រទះពួកញាតិទាំងនោះហើយ មើមឈើ ផ្លែឈើក៏មានច្រើន ព្រៃកុំនឹងខ្វះសុីឯក៏គួរជាទីរីករាយអាចនឹងបានសុខសម្រាន្តជាប្រាកដ យើងនឹងនៅជាមួយញាតិទាំងឡាយក្នុងទីនេះ ហើយនឹងមិនខ្វល់ខ្វាយ មិនរង្គើស មិនសោយសោក មិនគិតខ្វាចអ្វីតទៅ ។

ជ្រូកទាំងឡាយ បានឮពាក្យតច្ចកៈហើយ ទើបពោលថា ម្នាលតច្ចក:; អ្នកចូរទៅរកទីជ្រកពួនដទៃវិញទៅ ព្រោះទីនេះសត្រូវរបស់ពួកយើងមាន វាធ្លាប់មកសម្លាប់កូនជ្រូកក្នុងទីនេះសុីជានិច្ច ។

តច្ចកសូករៈសួរថា នរណាហ្ន៎ ជាសត្រូវពួកយើងក្នុងទីនេះ? នរណាមកញាំញីកំចាត់ពួកញាតិអ្នកព្រមព្រៀងគ្នា ដែលគេកំចាត់បានដោយក្រ? អ្នកចូរប្រាប់សេចក្តីដែលយើងសួរនេះមកចុះ ។

ជ្រូកទាំងឡាយឆ្លើយថា ម្នាលតច្ចក: មានស្តេចខ្លាមួយក្រឡាតាក់បង្គុំ ជាសត្វមានកម្លាំង មានចង្កឹមជាអាវុធ វាធ្លាប់មកសម្លាប់ជ្រូកក្នុងទីនេះសុីជានិច្ច ។

ឥច្ចកសូករ:ពោលថា ទោះបីពួកយើងមិនមានចង្ក្រូមពូកែមាំមួន ក៏ឥង់មានកម្ចាំងកាយបរិបូណ៌ដែរ បើប្រសិនជាស្រុះចិត្តគ្នាទាំងអស់ហើយ ក៏អាចនឹងចាប់សត្វមានចង្ក្រូមមានកម្ចាំងមួយឲ្យនៅក្នុងអំណាចបាន ។

ជ្រូកទាំងឡាយពោលថា ម្នាលឥច្ចក: អ្នកពោលរាចាចាប់ចិត្តចាប់ថ្ងើមសប្បាយត្រចៀក (អើពួកយើងសុខចិត្តឥស្ប៊ី) ក្នុងពេលច្បាំង បើអ្នកណារត់ឥេច ពួកយើងនឹងនាំគ្នាសម្ចាប់អ្នកនោះចោលក្នុងខាងក្រោយ។

ឥច្ចកសូករ.ទូន្មានជ្រូកទាំងឡាយ ឲ្យសាមគ្គីរួបរួមគ្នាជាចិត្តមួយ ហើយទើបស្ងរថា ខ្ចាមកពេលណា? ។ ជ្រូកទាំងឡាយប្រាប់ថា ថ្ងៃនេះរាមកចាប់យកជ្រូកមួយតាំងពីព្រឹកទៅហើយ ព្រឹកស្អែកទើបរាមកទៀត ។ ឥច្ចកសូករ:ជាសត្វឈ្ចាសក្នុងការច្បាំង កំណត់ដឹងទីជយកូមិថា នៅទីនេះមិនអាចនឹងយកជ័យជំនះបានទេ ព្រោះហេតុនោះ ទើបត្រាច់ដើរជ្រើសរើសរកកូមិប្រទេសបានមួយកន្ទែង ឲ្យជ្រូកទាំងឡាយរកអាហារស៊ីឲ្យផ្អែតក្នុងរវលារាត្រី ហើយនិយាយពន្យល់ថា ធម្មតាក្ឋនចម្បាំងមាន ៣ គឺ: សកដព្យូហ: (ក្ឋនទ័ពរទេះ) ១ ចក្រព្យូហ: (ក្ឋនទ័ពកង់) ១ នឹង បទុមព្យូហ: (ក្ឋនទ័ពស្រទាប់ផ្កាឈូក) ១ រួចហើយទើបតាំងក្ឋនបទុមព្យូហ: តាំងពីពេលព្រឹក គឺរៀបដាក់ហ្ឆូងជ្រូកទុកជាជាន់ ៦ ជួចត្រ៍បកឈូក ឲ្យកូនជ្រូកដែលនៅឡៅនៅត្រង់កណ្តាល, ឲ្យមេជ្រូកទាំងនោះនៅព័ទ្ធជុំវិញ ហើយចាត់ឲ្យជ្រូកញ៉ីដែលមានអាយុយ៉ាងកណ្តាល ៦ ព័ទ្ធហ៊ុមមួយជាន់ទៀត, ត្រង់ចន្ទោះ ៦ ជ្រូកញ៉ីទាំងនោះ ចាត់ឲ្យកូនជ្រូកដែលលែងឡៅដោះ នឹងជ្រូកស្ទាវ ៦ មានចង្ក្រូមតូចជ្រកនៅ

តាមចន្ទោះ ៗ ទៀត, ក្នុងចន្ទោះជ្រូកចង្ក្រូមតូច ៗ មានជ្រូកចង្ក្រូមធំ ៗ នៅ
ប្រចាំការពារ, ក្នុងចន្ទោះជ្រូកចង្ក្រូមធំ ៗ មានជ្រូកចាស់ជ្រកនៅជារយៈ ៗ
ទៀត ហើយដាក់ជ្រូកដែលមានកម្ទាំងទុកក្នុងទីផ្សេង ៗ ជាពួក ៗ មួយ
ពួក ១០ ទ្ទះ ២០ ទ្ទះ ៣០ ទ្ទះ ហើយឲ្យនាំគ្នាជីករណ្តៅសម្រាប់លាក់ទ្ទួន,
មួយរណ្តៅ ជីកជារចាំងមានសណ្ឋានដូចជាចង្អេរ មួយរណ្តៅទៀត ក្នុង
ចន្ទោះរណ្តៅទាំងពីរនេះ ឲ្យធ្វើរូបស្រដៀងតាំងដែលទ្ទួនជ្រកអាស្រ័យ
ស្រេចហើយ ក៏នាំជ្រូកអ្នកច្បាំងដែលទ្ទាំងពូកែទាំងឡាយត្រាច់ដើរដាស់
ទឹកចិត្តជ្រូកទាំងឡាយដែលចាត់ទុកក្នុងទីផ្សេង ៗ ។ កាលតច្ចកសូករ:
ចាត់ត្រៀមការច្បាំងយ៉ាងនេះ ក៏ល្មមពេលព្រះអាទិត្យបញ្ចេញរស្មីរះ
ឡើងមក ។

លំដាប់នោះ ព្យត្ឆរាជក៏ចេញចាកអាស្រមនៃជដិលកោង មកឈរ
នៅនាចង្កេះកុំ ជ្រូកទាំងឡាយប្រាប់ដល់តច្ចក:ថា លោកដ៏ចំរើន គូរៀក
របស់ពួកយើងមកហើយ ។ តច្ចក:ទើបប្រាប់ថា អ្នកទាំងឡាយកុំខ្ទាច
ឡើយ បើខ្ទាធំនោះធ្វើអាការយ៉ាងណា អ្នកទាំងឡាយគប្បីធ្វើយ៉ាងនោះ
សំដែងឲ្យដឹងថាជាប្រតិបក្សរបស់រា ។ ខណ:នោះ ខ្ទាធំរលាស់កាយ
បន្ទន់ទ្ទួនចុះបន្ទិច ហើយបន្ទោបស្សាវ: ។ ចំណែកពួកជ្រូកក៏ធ្វើ
ត្រាប់ដូច្នោះ ។ ខ្ទាធំក្រឡេកឃើញជ្រូកទាំងឡាយ ហើយក៏បន្ទឹ
សំឡេងគំរាម ។ ចំណែកពួកជ្រូកក៏បន្ទឹសំឡេងតាមខ្ទាដែរ ។
ខ្ទាធំសំឡឹងឃើញកិរិយារបស់ពួកជ្រូកដូច្នោះ ទើបគិតថា "ជ្រូកទាំង
នេះមិនដូចពីថ្ងៃមុន ៗ សោះ ថ្ងៃនេះគង់ជាសត្រូវចំពោះអញជាប្រាកដ

ឋានជាវានាំគ្នាឈរនៅជាពួក ឃើញថាមាននាយកមកជួយចាត់ការ
ថ្ងៃនេះអាត្មាអញមិនគួរចូលទៅជិតជ្រូកទាំងនេះទេ" ឥតហើយក៏ខ្ជាច
នូវសេចក្តីមរណ: ទើបត្រឡប់ទៅកាន់សំណាក់នៃជដិលកោងវិញ ។

លំដាប់នោះ ជដិលកោងឃើញខ្ជាធំមកដៃទទេ ក៏ពោលថា
ម្នាលព្យគ្ឆរាជ អ្នកក្ដាហាន ថ្ងៃនេះប្រហែលជាអ្នកលះវៀរឋាណាតិឋាត
អ្នកឲ្យអភ័យដល់សត្វទាំងឡាយស្មោះហើយឬ: ឬចង្ក្រមនឹងក្រចករបស់
អ្នកមិនមានទៅហើយ អ្នកចូលទៅដល់កណ្តាលហ្វូងជ្រូកហើយ ម្តេចក៏
ត្រឡប់មកសញ្ជប់សញ្ជឹងសុបសៅគួរឲ្យអាសូរដូច្នេះ ។

ខ្ជាធំពោលបតថា មិនមែនចង្ក្រមនឹងក្រចករបស់ខ្ញុំករុណាមិនមាន
នោះទេ ទាំងកម្ទាំងកាយក៏មានបរិបូណិព្រម ប៉ុន្តែខ្ញុំករុណាក្រឡេក
ឃើញពួកជ្រូកព្រមដោយញាតិប្រជុំនៅក្នុងទីជាមួយគ្នា ព្រោះហេតុនោះ
ឋានជាខ្ញុំករុណាមកសញ្ជប់សញ្ជឹងសុបសៅ តែម្នាក់ឯងនៅក្នុងព្រៃ,
តាមដែលធ្លាប់ឋានដឹងឃើញមកពីមុន ។ ជ្រូកទាំងនេះគ្រាន់តែក្រឡេក
ឃើញខ្ញុំករុណា ក៏ធ្លាក់ទឹកមុខនាំគ្នាឋោលខ្ជាត់ខ្ជាយទៅក្នុងទិសតូច-ធំ
រកទីជ្រកអាស្រ័យ ថ្ងៃកអីថ្ងៃនេះវាព្រមព្រៀងមូលត្រកូលជាពួកឈរនៅ
ក្នុងទីដែលខ្ញុំករុណាមិនដាយនឹងញាំញីវាឋាន វាមាននាយកបង្គាប់ការ
ព្រមព្រៀងគ្នាជាពួកក្រុម ឥង់នឹងបៀតបៀនខ្ញុំករុណាជាប្រាកដ ឋាន
ជាខ្ញុំករុណាមិនប្រាថ្នាជ្រូកទាំងនោះ ។

ជដិលកោងស្តាប់ដូច្នោះ កាលនឹងធ្វើឲ្យខ្ជាធំកើតស្សាហ៍ ទើប
ពោលថា ព្រះតន្ទ្ធតែមួយអង្គប៉ុណ្ណោះ អាចឈ្នះពួកអសុរដ៏ច្រើនឋាន

អជ្ឈុប្បាតកសត្ត (សត្ថរកស៊ីធាប) ត្រឹមតែមួយប៉ុណ្ណោះក៏អាចញ៉ាញ៉ី
សម្ងាប់សត្ថស្ងាបទាំងហ្វូងបាន, ខ្ងាធំតែមួយទៅជល់កណ្តាលហ្វូងម្រឹគក៏
អាចសម្ងាប់ម្រឹគដែលធ្ងាញ់ៗ បាន ព្រោះកម្ងាំងរបស់ខ្ងាយ៉ាងហ្នឹងឯង ។

ខ្ងាធំពោលបញ្ជាក់ថា អ្នកដែលមានញាតិព្រមព្រៀងមូលត្រកូល
គ្នា ព្រះឥន្ទ្ធមិនអាចធ្វើឲ្យនៅក្នុងអំណាចបានឡើយ អជ្ឈុប្បាតកសត្ថ
ក៏ធ្វើឲ្យនៅក្នុងអំណាចពុំបាន ទោះបីខ្ងាធំដែលជាអធិបតីនៃពួកម្រឹគ ក៏
ធ្វើឲ្យនៅក្នុងអំណាចមិនបាន ខ្ងាធំមិនអាចធ្វើសត្ថដែលមានញាតិព្រម
ព្រៀងមូលត្រកូលគ្នាឲ្យនៅក្នុងអំណាចបានឡើយ ។

ជដិលកោង កាលញុះញង់បញ្ជោរឲ្យខ្ងាកើតឧស្សាហ៍ទៀត ទើប
ពោលថា បក្សីតូចទាំងឡាយមានឈ្មោះថាកុម្ភិល ជាបក្សីត្រាច់ហើរ
ទៅជាហ្វូង រមែងរីករាយសប្បាយចិត្ត ហើរទៅឲ្យដ៏អាកាស សញ្ជាររក
អាហារជាក្រុមៗ កាលហ្វូងបក្សីទាំងនោះនៅមូលគ្នាជាពួក បើមានបក្សី
ណាមួយម្នាក់ចេញទៅក្រៅហ្វូង ខណៈនោះអជ្ឈុប្បាតកសត្ថ រមែង
ធាបយកបក្សីនោះ, យ៉ាងនេះជាផ្ទូរឧបាយរបស់ពួកខ្ងាធំ ។ កាលជដិល
កោងពោលដូច្នេះហើយ ទើបញុះញង់បញ្ជោរជាឧបាយជាស់ចិត្តតទៅថា
ម្នាលព្យគ្ឆរាជ អ្នកមិនទាន់ដឹងកម្ងាំងកំហែងរបស់អ្នកឯងទេ កុំក្រែង
ខ្ងាចឡើយ ចូរគម្រាមដោយសម្ងេង ហើយស្ទុះជម្រង់ទៅតែប៉ុណ្ណោះ
ពួកជ្រូកក៏នឹងនៅរួមគ្នាមិនបាន នឹងត្រូវខ្ងាត់ខ្ងាយជាប្រាកដ ។

ខ្ងាធំជាសត្ថមានចង្ក្រូមនឹងក្រចក ត្រូវជដិលលោភសំឡឹងចំពោះ
អាមិស ញុះញង់បញ្ជោរឲ្យកើតសេចក្តីអង់អាច ក៏ស្ទុះសំដៅទៅក្នុង

ហ្ជូង ជ្រូកដែលមានចង្ក្រូមដូចគ្នា ដោយគិតសំគាល់ថានឹងធ្វើបានដូចពីមុនៗ មក ។

ជ្រូកពំងឡាយបានឃើញគេបប្រាប់ដល់តច្ចកៈថា លោកនាយ! អាចោរចង្រៃរាមកទៀតហើយ ។ តច្ចកសូករៈលួងលោមថា "អ្នកពំងឡាយកុំខ្ជាចឡើយ" ថាហើយក៏ក្រោកឡើងឈរលើតាំងត្រង់ចន្ទោះរណ្តៅពំងពីរនោះ ចំណែកខ្ជាធំក៏សំដែងកម្ជាំងបោលសំដៅដាក់តច្ចកសូករៈ ។ ក៏ត្រឡប់ក្រោយលោតចុះក្នុងរណ្តៅខាងមុខ ។ ខ្ជាធំស្ទុះទៅដោយរហ័សក្ងៃត តែមិនទាន់ ក៏ជ្រុលទៅធ្ជាក់រណ្តៅដែលមានសណ្ឋានដូចចង្អេរ ស្រុញខ្ជួនមូលខ្ជំដូចបាច់ស្មៅ ។ តច្ចកសូករៈក៏ស្ទុះលោតផ្ទោះឡើងអំពីរណ្តៅដោយរហ័សបន្ទាន់ទនចាក់ដោយចង្ក្រូម ត្រង់ចន្ទោះក្ងៅក្រោយ ខ្ជេះកកាយទាញសញ្ញែកឲ្យរហែកធ្ជុះធ្ជាយរហូតដល់បេះដូង មាត់ខាំសាច់ខ្ជាត្រវែងចោលទៅលើមាត់រណ្តៅ ហើយស្រែកប្រាប់ឲ្យជ្រូកពំងឡាយមកស៊ីសាច់ខ្ជា ។ ជ្រូកពំងឡាយនាំគ្នាមកស៊ីហើយពោលថា លោកនាយ! លោកចាប់បានតែខ្ជាធំមួយប៉ុណ្ណោះទេនៅមានខ្ជាកំណាចមួយទៀតដែលលោកមិនទាន់ចាប់បាន ខ្ជាកំណាចនោះជានាយករបស់ហ្ជូងខ្ជា ។ តច្ចកសូករៈទើបសួរថា នាយកខ្ជានោះគឺអ្នកណា? ។ ជ្រូកពំងឡាយប្រាប់ថា គឺជដិលកោងម្នាក់ ធ្ជាប់ស៊ីសាច់ដែលខ្ជារកមកបានជានិច្ចកាល ។

តច្ចកសូករៈ ព្រមដោយជ្រូកពំងឡាយ លើកគ្នាទៅកាន់អាស្រមនៃជដិលកោង ដោយប្រញាប់ ។

ចំណែកជដិលកោងនោះ ឃើញខ្ចាបាត់យូរ ក៏ឈរទន្ទឹងមើលផ្ទូវ
សាប់តែឃើញជ្រូកបោលព្រូមកច្រើន ក៏ជ្ជាក់ចិត្តគិតថា ប្រហែលជា
ជ្រូកទាំងនេះសម្ខាប់ខ្ចាបាន ហើយតាមមកសម្ខាប់អញទៀត ទើបស្ទុះ
ម្ទីម្ទាឡើងទៅលើដើមល្ខាមួយដើម ។ តច្ចកសូករ:ក៏បង្ហាប់ឲ្យជ្រូកស្ទាវ។
ឲ្យឈ្ចូសកកាយត្រង់គល់ល្ខា ឲ្យជ្រូកញីទាំងឡាយទៅពាំនាំទឹកមក
ស្រោច ឲ្យជ្រូកដែលមានខ្ទាយធំទាំងឡាយ ទាំកកេរបុសជុំវិញដើម
ជរាបសល់នៅតែបុសកែវមួយប៉ុណ្ណោះ ។ តច្ចកសូករ: ស្រែកប្រាប់ឲ្យ
ជ្រូកទាំងឡាយថយចេញទៅ ហើយខ្ជូនឯងក៏លុតជង្គង់ចុះយកខ្ទាយ
តាស់គល់ឈើដោយកម្ខាំងដ៏ពូកែ បុសកែវក៏ជាច់ថ្ចិល ដើមល្ខាក៏រលំ
ដួលចុះមក ។ គ្រាន់តែជដិលកោងជ្ជាក់ដល់ដីភ្ខាម ហ្ខូងជ្រូកក៏ជញ្ជែង
គ្ទាទាំកកេរស៊ីសាច់ជាអាហារ ។

ទណ:នោះ ទេវតាដែលស្ថិតនៅក្នុងជងព្រៃ បានឃើញហេតុ
ការណ៍ដ៏អស្ចារ្យជូចពណ៌នាមកនេះ ទើបពោលថា ការដែលមានញាតិ
ជុំវុំគ្ទាតង់ញ្ចាំងប្រយោជន៍ឲ្យសម្រេច ទោះបីដើមឈើដែលជុះនៅក្នុង
ព្រៃក៏ជូចគ្ទា ជ្រូកទាំងឡាយព្រមព្រៀងព្ជូតដៃគ្ទាសម្ខាប់ខ្ចាធំ ក្នុងប្រក
ផ្ទូវតែមួយបាន ។

ជ្រូកទាំងឡាយ លុះសម្ខាប់ខ្ចាធំ នឹងជដិលកោងទាំងពីរបានហើយ
ក៏មានសេចក្តីសប្បាយរីករាយចិត្ត នាំគ្ទាបន្ទឹសំឡេងលាន់ព្ទគឹកកង លុះ
បានបង្ក្រាបសត្រូវស្ងប់រៀបរយហើយ ទើបប្រឹក្សាគ្ទា អភិសេកតច្ចក-

សូការ: ឲ្យជានាយកនាំគ្នាត្រាប់ដើរសៃឡរកទឹកសម្រាប់ស្រោចប្រោះព្រំ ប្រទះឃើញស័ឡសម្រាប់ដាក់ទឹករបស់ជដិលកោឡកុឡបណ្ណសាលា ក៏ យកទៅដាក់ទឹកឲ្យពេញ ធ្វើទក្ខិណាព័ត៌ អភិសេកស្រោចតច្ចកសូការ: ត្រង់គល់ឈើល្វានោះឯង ហើយទើបស្រោចទឹកអភិសេកជ្រូកញីមួយ ឲ្យជាអគ្គមហេសីនៃស្តេចតច្ចកសូការ: ។

វិធីអភិសេក ទើបនិយមប្រើអឡុយលើតាំឡធ្វើពីឈើល្វា នឹងស្រោចទឹកដោយស័ឡទក្ខិណាព័ត៌ជាប្រពៃណីមកតាំឡអំពីកាលនោះឯង ។

ចប់រឿងតច្ចកសូការ:

គុណនៃសាមគ្គី

សាមគ្គីការព្រមកាយវាចាចិត្ត	បើសណ្ឋិតមានក្នុងបក្សគណៈណា
បក្សក្រុមនោះនឹងរុងរឿងថាវរា	មានជីវ៉ាវស់ក្នុងលោកបានអង្វែង ។
បើពលរដ្ឋប្រាកដមានសាមគ្គី	យ៉ាងពេញទីរដ្ឋនឹងមានដោតគួរស្រែង
ដនបរទេសសឹងកោតឲ្យាចគោរពឯង	មិនហ៊ានក្លែងគិតតតាំងដាសត្រូវ ។
ច្នេះគួរយើងទមរ:អ្នកស្នេហ៍ជាតិ	ដួយក្រុមញាតិជាតិដងយើងឲ្យដើរផ្លូវ
ត្រូវធមិនេះឲ្យពាសពេញប្រទេសទៅ	ឲ្យមាននៅក្នុងសន្តានគ្រប់ទ្មែរអើយ !

យូរ-អ៊ុន

រឿងសៅរសោយ

(សិសោរដាតក)

ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រាស្ទឹកវិត

(តមក)

ហើយឲ្យចេញទៅនៅ ដំណាក់ក្រៅវាំងនោះណា
សុទត្តរ័ត៍កញ្ញា ក៏យាត្រាចាកវាំងដ័យ
កាលទៅនៅពឹងពាក់ ក្នុងដំណាក់ស្នាក់អាស្រ័យ
ពេលនោះស្រស់ស្រីថ្ងៃ មានព្រះទ័យក្រែផ្ទរផង់ ។

ចំណាយចាយធនធាន ធ្វើជាទានគ្នានបង្អង់
រាល់ថ្ងៃឥតបីបង់ ដោយផ្ទាល់អង្គអនង្គថ្ងៃ
ឯស្ទូមអ្នកសូមទាន សឹងអត់ឃ្ងានពន់ពេកក្រែ
មិនដែលបានអាស្រ័យ ផ្អែតមួយថ្ងៃសោះឲ្យីយហោង ។

ជំនុំជុំគ្នីគ្នា ប្រើនមហិមាជាកន្ទង
ជ្យាតចិត្តតិតប៉ុនប៉ង សូមទានផងបរិភោក្តា
ហើយពោលថាឥឲ្យវ រាល់គ្នាត្រូវទៅធាប់ក៉
ជ្យាតស្រីថ្ងៃកញ្ញា ជាធីតាមហាច្បាស់ច្បង ។

ដែលស្តេចទ្រង់បណ្តេញ បំបង់ចេញពីវាំងហោង

សឆ្នាថ្វាកន្ធង ឲ្យទានផងតែសព្វថ្ថ
ឆ្នោះកូវត្រូវគ្រប់ត្នា ទៅវន្ធាធីតាថ្ថ
សុំអស់ភ័ស្ពុទីទៃ ត្រាន់អាស្រ័យគ្រប់អាត្ម្ា" ។
ថ្ថ្ងៃនព៌ព្រះសិសៅរ៍ ដែលនិត្យនៅស្រុកនោះណា
បានស្តាប់ស័ព្ទរាចា ស្ថូមរាល់ត្នាថាឆ្នោះហ៊ីយ
ស្ពេចសោតក៏អត់ឃ្ជាន ដើរសូមទានគេជាត្រើយ
លុះដឹងដំណឹងហ៊ីយ ពុំអង់ឡ៊ើយទៅដែរណា ។
លុះទល់ដល់ដំណាក់ នាងវរល័ក្ខណ៍អគ្គកញ្ញា
អស់ស្ថូមសូមនានា ក្រាបវន្ធាគ្រប់ ៗ កាយ
រ៉ៃព្រះសិសៅរ៍ ត្រូវកំដៅក្តៅក្រហាយ
ឈរជិតស្ថូមទាំងឡាយ មិនឧនកាយថ្ជាយវន្ធា ។
យកជាយព្រះពស្ត្រម្ជាង ទទូរក្ជាងបាំងសិរសា
ជាយម្ជាងទៀតសោតណា ស្ថៀកនៅនានឹងចង្កេះ
ហេតុបុណ្យស្ពេចនឹងនាង បានសូមសាងពីមុនម្ជ៉ះ
ពុំឃ្ជាតរាតរបេះ ជាដូច្នេះច្រើនហ៊ីយនៃ ។
ភូធរឈររេរា មិនវន្ធាធីតាថ្ថ
ទ្រង់ទតរ័ត្នចរណៃ មានព្រះទ័យកៃស្នេហា
ក្សត្រីស្រីធោមយង់ ល្អអស់អង្គវង្សធាយា
ជាហេតុឲ្យក្សត្រា ទតធីតាមិនរាវក្នេក ។
ស្ពេចនឹកក្នុងចិន្ធា គន់គិតថា "អា! ល្អឯក

មើលទៅមិនសៅតែក ថ្ងៃកចំឡែកស្រីនានា
នាងនេះសមតែបាន ទៅអ្នកមានបារមីក្ខា
ឯអញនេះវិញណា សូមអាហារគេសព្វថ្ងៃ ។
បើចួនខ្ជូនពីមុន នៅមានបុណ្យលើសលន់ក្រៃ
ទើបស្រីថ្ងៃនេះនៃ តាប់ព្រះទ័យនឹងអញណា
រីឯនាងសុទត្ត ទេវីក្សត្រ័ត្នកញ្ញា
យល់យង់អង្គក្សត្រា ឈរឯកាធ្វើវាហ៊ ។
ទើបនាងធ្វៀងនេត្រា ទតកិរិយាមហាចក្រី
កាលនេត្រព្រះនឹងស្រី ចួបត្នាឱ្ងក្តីស្នេហា
កកើតឡើងយ៉ាងខ្ចាំង ឲ្យកាន់កាំងទាំងកាយា
ព្រោះនាងនឹងក្សត្រា ជ្ជាប់រួមត្នាប្រើនជាតី ។

ទើបនាងបន្ទូលស្នង ថា "អើហងមេទាស៊ី
មើលចុះស្ងួមន្ទុះរ៉ី គើហេតុអីក៏ទុសគេ
ឈរធ្មឹងនឹងជូចត្នំ មិនបង្គំសុំទានទេ
ទទូរឈរវិះរ ម្តេចទុសគេណាមេណ៉ា ។
ចូរឯងទៅថ្ងៃងបាប់ ឲ្យតាត់ធាប់យកចេញ៉ា
សំពត់ពីសិរសា ឃើញមុខាយើងឲ្យទាន" ។
កាលនោះអស់ទាស៊ី ស្តាប់សវនីយ៍ស្រីកល្យាណ
ក៏ចូលទូលក្សត្រក្សាន្ត តាមលំអាននាងក្សត្រី ។
ថា "នែ! អ្នកកំសត់ យកសំពត់ពីសិរស៊ី

ទទូរឈរធ្វើអី ចូរសែដីប្រាប់ខ្ញុំ"
ទើបស្តេចគេចសែដី ប្រាប់ទាសីតាមនីយថា
"យើងរងសែងសុរិយា ក្តៅអាត្មាខ្ញុំងក្ខាក្រៃ ។
ទើបយើងយកពស្ត្រា ជាំងសិរសាការសែងថ្ងៃ
បើនាងឲ្យអាស្រ័យ យើងអរក្រៃតតបីថ្ងៃង
តែបើមិនឲ្យទេ យើងនឹងរេរកកន្ទែង
ទៅសុំអស់គេឯង គ្រាន់ចាត់ចែងចំអែតប្រាណ ។
ដូច្នេះនាងរាល់គ្នា ចូរលីលាម្ចីម្ចាថ្ការ
ទៅទូលដល់កល្យាណ ឲ្យនាងបានជ្រាបសេចក្តី"
ពេលនោះអស់ពួកស្ទុំ ចូលបង្គំទូលក្សត្រី
តាមពាក្យព្រះចក្រី ទើបក្សត្រីថ្ងៃតិតថា ។
"អ្នកនេះមិនអ្នកខ្យត់ មិនទូតិតអត់ទ្បើយណា
គ្រកូលពូជពង្សា មិនមែនជាវាស្ត្រសោះទ្បើយ"
តិតក្ខាងនាងសែដី ស្ងរទាសីថា "ទ្រីអើយ!
នាងស្ទិទ្ធជិតតាត់ហើយ ឃើញមុខមាត់តាត់យ៉ាងណា ។
ជាមនុស្សខ្ពស់យសសក្តិ ឬជាអ្នកធ្ងាក់សក្តា
លេងស្រីលេងសុរា លេងបស្ការកីឡាភ្នាល់
ធ្វើម្តេចនឹងជឹងអេះ ថាអ្នកនេះខ្ពស់ឬទាល់
នឹកទ្បើងនឹងចង់ស្គាល់ តែរាទាល់មិនយល់មុខ" ។
ពេលនោះអស់ទាសី យល់ក្សត្រីថ្ងៃជាទុក្ខ

កល្យាណពុំបានសុខ ចង់យល់មុខស្ងួមនោះណា
ទាស៊ីមួយសោតសល់ ដែលចេះកល់យល់តម្រា
ចរចូលទៀងទូលថា "សូមកញ្ញាត្រាប្រណី ។
ធម្មតាជាតិបុរស ត្រប់ទាំងអស់ក្នុងលោកិយ
ទោះទុក្ខជ្រប់មុខក្តី កាលឃើញស្រីតែងតយតន់
សូមម្ហាស់ផ្ទាស់តែងកាយ ឲ្យធើតធាយកៃកពេកពន់
យាងយាសវិលាសលន់ ឲ្យតាត់តន់មើលកញ្ញា ។
កាលតាត់ឃើញក្សត្រី តង់ឃ្មាតខ្មីទាញពស្ត្រា
ចេញពីទីសិរសា មើលធីតាជាពុំខាន
ពេលនោះស្រស់វរមិត្ត អាចពិនិត្យឃើញពិតបាន
ទាំងមុខទាំងខ្លួនប្រាណ អាចដឹងហានបានហ្មត់ហ្មង" ។
កាលរ័ត្នវរក្សត្រី ស្ពាប់ទាស៊ីស្ពីទូលស្នង
ប្រញាប់ធាប់កន្ទង តែងអង្គផងយ"ងប្រិមប្រិយ
ហើយចេញមកលីលា យាងបាទាទៅមកខ្មី
បង្អួតព្រះចក្រី ឲ្យនរបតីឃើញកាយា ។
ចមពលយល់ស៊ីថ្ងៃ កើតព្រះទ័យកៃស្នេហា
ទើបទាញពរពស្ត្រា ពីសិរសាទតវរល័ក្ខណ៍
ក្សត្រានឹងពន្ធក ទតទៅមកទាំងពីរនាក់
សំឡឹងនឹងមិនជាក់ សំឡក់ភក្ត្រទាំង ២ ប្រាណ ។
ពេលនោះស្រស់សុទត្ត ទេវីរ័ត្នក្សត្រកល្យាណ

យល់យង់អង្គក្សត្រក្សាន្ត ល្អត្ថប្រាណពុំមានខ្ចោះ
ទតក្ខាងនាងតិតថា អ្នកនេះណាល្អតមោះ
មិនសមមិនរម្យសោះ ដើរសូមអស់ក៏ស្ពុកោក្ពា" ។
តិតឆ្នោះស្រស់ក្សត្រី ប្រើទាស៊ីទាំងពីរថា
"ចូរនាំស្ទូមនេះណា ឆាប់ ៗ ក៉ ណាទាស៊ី
ចូរនាំគាត់ចូលទៅ ឲ្យតាត់នៅរាងត្ថ្លូ"
បានស្តាប់សវនីយ៍ ទើបទាស៊ីទាំងពីរប្រាណ ។
ចូលទូលដល់ទសពល "ដ្ឋិតនិមិលស្រស់កល្យាណ
ឲ្យនាំចមក្សត្រក្សាន្ត ទៅស្នាក់ប្រាណហានឯណោះ"
ស្តាប់ស្រេចស្តេចតេចស្ទ៊ី ប្រាប់ទាស៊ីដោយចំពោះ
"ថាបើនាងមិនស្មោះ ឲ្យយើងសោះក៏មិនថី ។
តែម្តេចក៏គេចមក នាំយើងយកទៅធ្វើអី
នឹងនាំទៅធ្វើអ្វី យើងតតបីនឹងដឹងបាន"
ត្រាស់ច្នេះអស់ ៣ ត្រា ហើយរាជាលីលាថ្កាន
យាងតាមស្នំពីរប្រាណ ទៅក្នុងហានរាងត្ថ្លណា ។
លុះចូលដល់យល់ទ្វិ ព្រះចក្រីទ្រង់ចិន្តា
ថា "តទៅនេះណា យើងយើញជាបានសុខី"
ដែលទ្រង់តិតដូច្នេះ ព្រោះទ្រង់ចេះមាយាស្រី
ពេលនោះស្រស់ក្សត្រី ចាត់ចំណីដ៏ថ្ងៃថ្ងា ។
កោជន៍ជលជងទាំងអស់ សឹងមានរសឆ្ងាញ់ពីសា

ហើយប្រាប់ទាសីថា “ នាងរាល់គ្នាលីលាធាប់
ចូរនាំយកអាហារ គ្រប់ប្រការនេះប្រញាប់
ទៅឲ្យគាត់នោះធាប់ ហើយចាំចាប់មើលកិរិយា ។
ប្រើយើញហេតុកេទម្ពេច ចូរវិលគេចប្រាប់យើងវ៉ា
ទាំងសំណល់ភោក្ពា នាងរាល់គ្នាកុំពៃពាល់
យកមកតាមភាពពិត យើងពិនិត្យយើងគង់ស្គាល់
ថាគាត់ខ្ពស់ប្ដទាល់ សោះពិភាល់ធ្លល់តទៅ” ។
ស្ពាប់ក្សាងនាងទាសី នាំចំណីថ្វាយសិស្យៀរ
ពេលនោះព្រះចមចៅ ក្រោធត្រាស់ទៅទាសីថា
“ ខ្ញុនយើងកំពុងហ្នង ញើសក្អែលល្អងពេញកាយា
ស្រមេះជូច្នេះណា នឹងភោក្ពាម្ពេចរាបាន” ។
ព្ធុច្នោះអស់មេនំ វិលបង្គំចមកល្យាណ
សុទត្ថវតន៍ក្សត្រក្សាន្ត កាលនាងបានជ្រាបសេចក្ពី
ទើបរៀបត្រៀងលាបកាយ ជងទាំងឡាយថ្វាយចក្រី
ទឹកអប់សព្ទអ្ហីៗ សំពត់ថ្មីក៏ស្រីចាត់ ។
ហើយប្រើអស់ទាសី ឲ្យនាំទ្មីថ្វាយមហាក្សត្រ
ជៀស្ធជ័យថ្ងៃអរក្ពាត់ ទើបចមក្សត្ររៀបចាត់ចែង
ស្រង់ទឹកជំរះអង្គ ហើយស្ពេចទ្រង់ផ្ទិតផ្ទង់តែង
អង្គស្រេចក៏ស្ពេចស្ពែង រិលកន្ទែងសោយគ្រយា ។

(មានត)

រឿងសាមកុក

កណ្ឌទី ២១

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

តាំងសុិនស្ងរថា អ្នកនឹងគិតធ្វើយ៉ាងណា ? ។ ក្រៀតបុឹងធ្វើយថា ចូធូ
នោះរមែងមានរោគឈឺក្បាល ហ៉ៅខ្ញុំបាទទៅមើលជានិច្ច បើចូធូឈឺទៀត
រៀលាណា ខ្ញុំបាទនឹងទៅព្យាបាលប្រកបថ្នាំឲ្យផឹកជាក់ថ្នាំបំពុលបញ្ចូល
ផង បើចូធូផឹកហើយតង់នឹងស្លាប់ ការណ៍ដែលខ្ញុំបានគិតនេះឃើញថា
មិនលំបាកដល់សេនាទាហាន ។ តាំងសុិនបានឌ្ឍជូច្នោះក៏សោមនស្ស
ក្នុងចិត្តទើបធ្វើយថា អ្នកមានសេចក្តីសត្យកតញ្ញូនឹងម្ចាស់ផែនដីប្រាកដ,
រាជសម្បត្តិនេះនឹងមិនអន្តរាយទ្បើយ គុណតាប់ដ៏ប្រសើរនឹងមានដល់ខ្លួន
អ្នកទៅងមុខ ។ លុះរៀលាព្រឹក ក្រៀតបុឹងក៏លាតាំងសុិនទៅផ្ទះវិញ ។

ខណៈនោះតាំងសុិនមានសេចក្តីសប្បាយរីករាយចិត្តណាស់ ជម្ងឺឈឺ
ថ្ពាត់ទាំងប៉ុន្មានក៏រលាយបាត់សូន្យអស់ទៅ ទើបដើរចុះទៅមើលសួនផ្ការ
ក្រឡេកឃើញខេងតងជាបាវស្មិទ្ធ អង្គុយនិយាយគ្នានឹងនាងអុិន - អេង
ដែលជាកវិយាបន្ទាប់ក្នុងទីស្ងាត់ តាំងសុិនខឹងណាស់ហៅមនុស្សបំរើឲ្យ
ចាប់ខ្ជូនខេងតងបាន ហើយហូតក្រឹតិតនឹងកាប់ខេងតងឲ្យស្ងាប់ ។ កវិ-
យាធំតាំងសុិនឃើញវីកវរឡើង ក៏ចុះទៅយាត់សុំជីវិតខេងតង ● តាំងសុិន
ក៏ឲ្យវាយខេងតងយ៉ាងទម្ងន់ហើយជាក់ច្រវាក់ទុក លុះវេលាពាក់កណ្តាល
អធ្រាត្រ ខេងតងក៏កាច់សោរត់រួចទៅនៅនឹងចូធូ ! យកសេចក្តីអាថិ
កំបាំងដែលតាំងសុិនតប់តិតគ្នានឹងអ្នក៥ នាក់នោះប្រាប់ចូធូត្រប់ប្រការ ។
ចូធូបានស្តាប់ច្បាស់ក៏ឲ្យយកខ្ជូនខេងតងទៅលាក់បំពួនទុកក្នុងផ្ទះ ។ ឯ
តាំងសុិននោះលុះព្រឹកឡើងដឹងថា ខេងតងរត់បាត់តិតថា ប្រហែលវា
រត់ទៅនៅខេត្រក្រៅ មិនបាននឹងតិតឲ្យស៊ើបសួរតាមរក ។ លុះថ្ងៃ
មួយចូធូក៏តិតកលឧបាយធ្វើជាឈឺក្បាល ទើបប្រើបំរើឲ្យទៅហៅកៀត
ប៉ុងពេទ្យហ្ជូងមករក្សារោត បំរើក៏ទៅហៅកៀតប៉ុង ។ ក៏តិតថា. "អា-
សត្រូវរាជសម្បត្តិវានឹងស្ងាប់ក្នុងត្រានេះហើយ" កៀតប៉ុងចូលទៅក្នុងផ្ទះ
យកថ្នាំពិសពុលលាក់ទៅជាមួយ ។ ចូធូឃើញកៀតប៉ុងទៅដល់ ក៏តន់
មើលម្រាមដៃឃើញកំបុត ១ សមជូចពាក្យខេងតងប្រាប់ ក៏មិនបានសាក
សួរថាម្តេច ។

ចូធូនិយាយនឹងកៀតប៉ុងថា ឥឡូវយើងឈឺក្បាលខ្ទាំងណាស់ ចូរ

អ្នកប្រែកបថ្មាំតែឲ្យសោយភេគយើងចុះ យើងនឹងឲ្យបំណាច់ឆ្អាន់ ។ កៀតប៊ុនថា "លោកឈឺគ្រានេះខ្ញុំបានធ្វើប្រែកបថ្មាំតែ ១ យ៉ាងជូនលោកពីសា ភេគលោកកំនើនសោយស្រួលៗ" ហើយកៀតប៊ុនក៏យកថ្មាំដាក់កងពែងដាំឲ្យរីងបន្តិច លុះយើញចូតូងាកមុខទៅ ក៏យកថ្មាំពិសពុលនោះដាក់បញ្ចូល ហើយចាត់ចេញល្មមបានកន្លះពែងទើបលើកហុចទៅឲ្យចូតូផឹក ។ ចូតូដឹងតាំងតែកៀតប៊ុនគំនុំធ្វើដាច្រើយមិនបានខ្លួលថ្មាំនោះ ។ កៀតប៊ុនថា មហាឧបរាជពីសាថ្មាំនេះទៅចុះទាន់នៅក្តៅដើម្បីឲ្យបែកញើសខ្លះ ភេគលោកកំនើនសះជា ។ ចូតូតបថា ខ្លួនអ្នកជាភេទ្យហ្លួងរមែងដឹងទម្លាប់ទំនៀមត្រប់សព្វហើយ បើព្រះមហាក្សត្រទ្រង់ព្រះឈួន ពេទ្យថ្វាយឧសថវេលាណាត្រូវឲ្យភេទ្យនោះប្តូនាហ្នឹងភក្សាព្រះអង្គជៀបថ្មាំជាមុន, បើមាតាបិតាឈឺ ភេទ្យប្រែកបថ្មាំឲ្យផឹកត្រូវឲ្យកូនភក្សាល្បងថ្មាំជាមុន ឥឡូវខ្លួនយើងជាមហាឧបរាជ ខ្លួនអ្នកជាភេទ្យធ្លាប់រាប់អានស្និទ្ធស្នាលនឹងយើង អ្នកប្រែកបថ្មាំឲ្យយើងផឹក អ្នកត្រូវផឹកល្បងឲ្យយើងឃើញជាមុនសិន ទើបយើងផឹកជាក្រោយ ។

កៀតប៊ុនតបថា ប្រសាសន៍លោកថាដូច្នេះក៏ត្រូវណាស់ហើយ តែខ្ញុំបានយល់ថាលោកក៏ធ្លាប់ទុកចិត្តខ្ញុំបានមកពីដើម ឥឡូវលោកឈឺ ខ្ញុំបានប្រែកបថ្មាំជូនលោកពីសា លោកនឹងឲ្យខ្ញុំបានដែលមិនឈឺខ្លួលខានជាមុននោះថ្មាំនេះតិចណាស់ នឹងអស់ភេ ភេគលោកក៏មិនសះជា ។ ចូតូក៏ធ្វើព្រងើយកន្តើយមិនព្រមខ្លួលផឹក ។ កៀតប៊ុនឃើញចូតូរង្គើស

សង្សយមិនទទួលផឹកថ្នាំដូចកល់ដង ក៏សំគាល់ក្នុងចិត្តថា ចូធូដឹងដល់គំនិតដែលខ្ជូនគិតទុក ទើបចាប់ស្ទឹកត្រចៀកចូធូជាប់ហើយយកពែងលើកឡើងប្រកឲ្យចូធូផឹក ។ ចូធូយកដៃទាត់ពែងធ្លាក់ពីដៃទៅបែក កំពប់ថ្នាំទៅលើឥដ្ឋដោយអំណាចថ្នាំពិសនោះឥដ្ឋក៏បែកខ្ទេច ។ មនុស្សបំរើទាំងពួងឃើញដូច្នោះ ក៏បបួលគ្នាចូលចោមចាប់ខ្ជូនកៀតបុឹងចងជាប់ ។ ចូធូបានចំណាប់ឃើញច្បាស់ជាកៀតបុឹងជាក់ថ្នាំពិស ក៏និយាយថា "អញមិនមែនឈឺអ្វីទេ អញពិសោធឯងចង់ដឹងទេតើ ឥឡូវអញឃើញថាឯងប្រទូសរ៉ាយអញជាប្រាកដ" ទើបបង្គាប់ទាហាន ៦០ នាក់ឲ្យនាំខ្ជូនកៀតបុឹងទៅឯសួនច្បារ ហើយចងស្នឹងវាយកៀតបុឹងយ៉ាងសហ័សស្ងរពិចារ-ណាថា ខ្ជូនឯងជាពេទ្យដែលគិតការទាំងនេះ អញក៏ឃើញថាលើសគំនិតប្រាជ្ញាឯង តើនរណាប្រើឯងឲ្យធ្វើដូច្នេះ ចូរឯងធ្វើយប្រាប់ឈ្មោះឲ្យច្បាស់តាមត្រង់ អញនឹងលើកទោសឯង ។

កៀតបុឹងត្រូវវាយឈឺចាប់ជាទម្ងន់ណាស់ ក៏មិនបានខ្លាចសេចក្តីស្លាប់ស្រែកគំហកតបថា ខ្ជូនឯងធ្វើល្មើសជាខ្មាំងសត្រូវនឹងរាជសម្បត្តិបានជាអញគិតធ្វើការដូច្នេះ មិនមែននរណាមកបង្គាប់ប្រាប់ឲ្យអញធ្វើទេព្រោះហេតុថាផែនដីសព្វថ្ងៃក្តៅត្រប់ដើមស្មៅវល្ងិឈើព្រៃទាំងពួង បានជាអញគិតសម្លាប់ឯងចេញ ទោះនរណា ។ គេក៏ប្រុងតែនឹងប្រហារជីវិតឯងដូចអញដែរ តែមិនទាន់បានឧកាសនឹងធ្វើបាន ជីវិតអញនឹងស្លាប់ហើយឯងមិនត្រូវមកស្ងរធ្វើអ្វីទ្បើយ ។ ចូធូបានឮដូច្នោះក៏ខឹងណាស់

ឲ្យវាយកៀតបុឹងតាំងពីព្រឹកដល់ថ្ងៃត្រង់ ទាល់តែខ្នងនោះបែកវល្លួយហូរ ឈាមស្រោចអស់ទាំងខ្លួន កៀតបុឹងក៏មិនធ្វើយដាក់ឆូកន ។ ចូធូបាវម្ក ត្រែងកៀតបុឹងនឹងស្ទាប់សាបសូន្យរឿងវ៉ាវ ក៏ឲ្យយកខ្លួនកៀតបុឹងទៅយុំ ទុកជាមាំមួន លុះវេលាព្រឹកឡើងចូធូក៏បង្គាប់ឲ្យរៀបតុលៀងអាហារ ឲ្យអញ្ជើញនាហ្ចឹនសពុមុខមន្ត្រីតូចធំទៅដួបដុំបរិភោក្តា ។ ឯដូហុក, ដូឡាន់, តាន់អុិប, ដោហួន ៤ នាក់នេះ ក៏ឆិតព្រមគ្នាថា បើយើងមិនទៅ ចូធូនឹងសង្ស័យ នាហ្ចឹនទាំង ៤ នាក់ក៏ទៅព្រមគ្នានឹងនាហ្ចឹនទាំងពួង តែតាំងសុិននោះឲ្យដំណឹងថាឈឺទៅមិនរួច ។

ខណៈកាលនាហ្ចឹនមុខមន្ត្រីទាំងពួងកំពុងបរិភោគអាហារ ចូធូក៏ និយាយថា "អស់លោកផឹកស្រាមិនសូវរួសរាយ យើងមានមនុស្សម្នាក់ ប្ជែកនឹងឲ្យយកមកឲ្យអស់លោកមើលលេង" ថាហើយក៏ប្រើទាហាន ឲ្យយុំនាំយកខ្លួនកៀតបុឹងចេញមក ចូធូក៏និយាយនឹងនាហ្ចឹនទាំងពួងថា "មានពួកក្សត់ឆប់ឆិតគ្នានឹងអាកំណាចម្នាក់នេះ នឹងធ្វើអន្តរាយដល់ព្រះ ចៅហៀនតេហើយធ្វើប្រទូសរ៉ាយដល់យើងផង ឥឡូវទេពតាមិនបាន ចូលទៅខាងមនុស្សអាក្រក់ បណ្តាលឲ្យយើងចាប់ខ្លួនបាន យើងនឹងស្លរ ពិចារណារា ឲ្យអស់លោកចាំស្តាប់ចុះ" ចូធូក៏ឲ្យវាយកៀតបុឹងទៀត ទាល់តែសន្ទប់ ហើយឲ្យរិតរួតទាល់តែដឹងខ្លួនឡើងវិញ ។ កៀតបុឹង នៅមិនបានញញើតខាំធ្មេញញេញមុខសំឡក់ ហើយដេរចូធូជាពាក្ស អាស្រូវភាសផ្សេងៗ ហើយថា "ហេតុម្តេចឯងមិនសម្ទាប់អញទៅ ទុក

អញធ្វើអ្វីទៀត ។ ចូរឆ្លូ ពីដើមវាគប់គិតគ្នានឹងពួក ៦ នាក់ ឯក្រោយ ឯងទៅចូលរួមគំនិតទៀតទើបត្រូវជា ៧ នាក់ ដើមគំនិតនោះគឺឈ្មោះអ្វី? បានជាឯងមិនចង្អុលឲ្យច្បាស់ ។ កៀតបុឌ្ឍក៏មិនធ្វើយតបសោះ ចូរឆ្វឹងណាស់ឲ្យវាយទៀតហើយពិចារណាសួរ កៀតបុឌ្ឍវឹងតែមិនធ្វើយជាក់ដល់ម្នាក់ណា ។

ឯដូហុក, ដូឡាន់, តាំងអ៊ុប, ដោហួន, អង្គុយបរិភោគអាហារ ឃើញចូរឆ្លូឲ្យវាយពិចារណាកៀតបុឌ្ឍដូច្នោះ អ្នកទាំង ៤ ក៏មិនបានជាសុខ ឧបមាដូចជាគេអង្គុយលើចំរ៉ងបន្ទាប់លើក្តើនគុក ទាំងកំមុខក៏ស្តីតស្តាំងគ្នានឈាមសោះ ចេះតែសំឡឹងមើលមុខគ្នាទៅវិញទៅមក ។ ចូរឃើញកៀតបុឌ្ឍមិនធ្វើយជាក់ដល់គូកនដូច្នោះ ក៏បង្គាប់ឲ្យយកខ្លួនទៅជាក់គុកដូចដើម ។

នាហ្មឺនមុខមន្ត្រីទាំងឡាយនោះ លុះបរិភោគរួចហើយទាំងអស់គ្នាក៏លាចូរឆ្លូទៅ ។ ចូរឆ្លូទើបថា អ្នកទាំងពួងនឹងទៅក៏ទៅចុះ តែដូហុក, ដូឡាន់, តាំងអ៊ុប, ដោហួន ៤ នាក់នេះត្រូវឲ្យបង្គំរ៉ៃទៅសិន យើងនឹងប្រឹក្សាការពាក់ព័ន្ធ ។ នាហ្មឺនទាំង ៤ បានឮដូច្នោះ ក៏ស្តុតរន្ធត់ចិត្តបាត់ព្រលឹងពីក្នុងខ្លួន ចាំចិត្តនៅអង្គុយដោយខ្លាចអាជ្ញាចូរឆ្លូក៏សួរនាហ្មឺនទាំង ៤ នាក់ថា អ្នកប្រឹក្សាការអ្វីខ្លះនៅផ្ទះតាំងសុិន ។ នាហ្មឺនទាំង ៤ ធ្វើយថា ខ្ញុំបាទនឹងបានទៅប្រឹក្សាការអ្វីទៅផ្ទះតាំងសុិនក៏ទេ ។

(មានត)

ដំណឹងតាមឲ្យល់ក្នុងកាន្ទារៈ

លោក ផេង-ជ្រីវ សាស្ត្រាចារ្យគៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

គេឲ្យនាងពាក់កង ការ ចិញ្ចៀនប្រដាប់ដោយត្សូងពេជ្រផ្សេងៗ ។ នាងឲ្យីឲ្យាមិនចង់លះបង់ប្រដាប់អីវ៉ាន់ដែលម្តាយចែកមកឲ្យសោះ ។ ការផ្ទាស់ប្តូរជីវភាពមួយរំពេចនេះ មិនទាន់កំចាត់ចិត្តនាងចេញពីការស្នេហាចំពោះបុគ្គលជាទីស្រឲ្យាញ់នៃនាងឲ្យីយ ។

ប្រាកដមែន នាងឲ្យីឲ្យានៅជាប់ចិត្តនឹងអនុស្សាវរីយ៍ បងស្រីដែលជាស្ត្រីអន្ធចក្ខុកំសត់ ប្រាត់បង់ទៅទាំងបង្ខំ ក្នុងវ័យពេញជំទង់ដូចផ្កាកំពុងរីក ។ នាងតែងនឹកជាញឹកញយដល់ម្តាយជាទីស្រឲ្យាញ់ គឺវាសនាអកុសលធក់បំបែកនាងចេញពីអ្នកមានគុណ ប៉ុន្តែ នាងនៅមានក្តីសង្ឃឹមថា ថ្ងៃណាមួយ នាងនឹងបានជួបម្តាយជាមិនខាន កាលណាគេឈប់ច្បាំងគ្នា កាលណាសន្តិសុខត្រឲ្យប់មកកាន់ផែនដី មកតាំងសណ្ឋិតក្នុងខន្ធសន្តាននៃមនុស្សទាំងឲ្យាយវិញ ។

ជីវភាពនៃនារីទាំងឲ្យាយតែងប្រព្រឹត្តទៅដោយមិនស្លួលស្អាតបាតក៏មែនហើយ តែប្រកបដោយនិរភ័យ ។

ជួនកាល សម័យថ្ងៃរសៀល នាងឲ្យីឲ្យាបានប្រទះអ៊ីស្មាអ៊ីល, គេញញឹមដាក់គ្នា ។ លោកអៃយ៉ាដដឹងថាកូនច្បងលោក ក្នុងពេលដែលបានធ្វើដំណើរទៅប្រទេសអឺរុប បាននាំយកទំលាប់ប៉ែកខាង

សេចក្តីគួរសមចំពោះស្រី ។ ហេតុនេះ ទើបលោកអនុញ្ញាតកូនលោក ឲ្យទៅជួបនាងឡីឡា នៅក្រោមបង្ហាត្រជាក់ទៅមុខផ្ទះ ។

សេចក្តីរីករាយប្រៃក ។ តែងកើតមានជានិច្ចជល់អ្នកកំឡោះនឹងនាងក្រមុំ កាលណាគេបានប្រទះមុខគ្នាម្តង ។ ។ មុទុតាដែលកើតក្នុងជួងចិត្តរបស់គេក្នុងពេលប្រទះគ្នាលើកដំបូង ក៏ក្លាយរាងបន្តិចម្តង ។ ទៅថាចំណង់យ៉ាងមាំហើយយ៉ាងសុចរិត ។

* * *

សម័យនោះ សង្គ្រាមកាន់តែកើតខ្លាំងឡើង ។ កងទ័ពតួរគីដែលពួកអីតាលីប្រមាថមើលងាយ ត្រឲ្យប់ជាមានកំឡាំង ។ ការណ៍ដែលបច្ចាមិត្រនឹកស្មានថា ត្រាន់តែពួកទាហានល្ហាតបន្តិចបន្តួច ក៏ក្លាយទៅជាចម្បាំងមែនទែន ។

កងទាហាននៃព្រះចៅសុល្តង់ដែលផ្ទើចម្បាំង នៅសមរភូមិទ្រីប៉ូលីតែន គឺជាទាហានឥតវិន័យ គ្មានគ្រឿងអាវុធដោយត្រឹមត្រូវ ។ គ្រឿងស្លៀកពាក់ឯកសណ្ឋានសុទ្ធតែបំណះ កាំភ្លើងផ្តសផ្តាស ចំណេះវិជ្ជាមិនគ្រប់គ្រាន់ មិនបាច់និយាយពីបៀវត្សបើកមិនត្រឹមត្រូវតាមពេលវេលាផង ម្ល៉ោះហើយការណ៍នេះ បណ្តាលឲ្យពួកទាហានធ្វើការមិនយកចិត្តទុកដាក់ ប្ដដោយធ្វេសប្រហែស ។ ម្យ៉ាងទៀត មានទាហានដោយច្រើន សុទ្ធតែអ្នកជ្លាក់សក្តិ ដូចយើងបាននិយាយពីខាងលើមកស្រាប់ប៉ុន្តែទោះបីជាល្អប្ដអាក្រក់ ក៏ទាហានទាំងនោះមិនមែនឥតក្តីក្លាហានឡើយ គឺជាកងទ័ពមានលក្ខណៈដ៏ធើតក្នុងការស៊ូប្ពូរ ។ ដៀជាក់ក្នុងសាស្ត្រ

ឥហានតួរតីស្ថិស្ថាប់នឹងកន្ទែង មិនថយក្រោយមួយជំហានឡើយ កាលណាមានបទបញ្ជាចាត់ឲ្យធ្វើប្រតិបត្តិការ ។ ស្ថាប់ដោយការរាយប្រឡូកទល់នឹងពួកទ្វិល គឺជាការស្ថាប់យ៉ាងប្រពៃ ។

គេដឹងថា ក្នុងសង្គ្រាម រុស្សី - តួរគី មានមនុស្សស្ថាប់យ៉ាងច្រើនអនេក ជាកិត្តិយស ដើម្បីការពារប្រទេសជាតិ ហើយនៅមានការស្ថាប់មនុស្សដែលណាហូបេជរើសហៅមកឲ្យជួយទៀត ។

*

* *

រាល់ល្ងាច ពួកចាស់ទុំក្នុងក្រុង តែងតែមកប្រជុំគ្នានៅផ្ទះលោកអៃយ៉ាដជាអាពុកអ៊ីស្មាអ៊ីល ។ ប៉ុន្តែ តាំងពីប៉ុន្មានពេលមកហើយរស្សីមបេនអាប់ជាឡេះ ដែលទុកជាមិត្តយ៉ាងជាប់ចិត្តមួយនៃលោកអៃ-យ៉ាដ រៀះមិនមកក្នុងពេលប្រជុំ តើរស្សីមមានបើថ្នាំងថ្នាក់ចិត្តដូចម្តេច?

ពេលរសៀល កាលដែលមុក្ការនឹងអ៊ីស្មាអ៊ីលអង្គុយជក់ថ្នាំលេងក្នុងបណ្ណាល័យអាពុកគេ រង់ចាំឲ្យថ្ងៃតជាក់ មុក្ការហៅបងហើយនិយាយថា:

– "អ៊ីស្មាអ៊ីល!

– "មានការណ៍អ្វី មុក្ការ?

– "ត្រូវខ្ញុំប្រាប់បងឲ្យដឹង អំពីតំនិតរស្សីមក្នុងរឿងនាងឡីឡា ។

និយាយចេញឈ្មោះនាងនារីឡីឡា អ៊ីស្មាអ៊ីលក្រោកឡើងភ្លាម ។ គេហាក់ដូចជាខឹងញ៉ាមួយរំពេច ។

មុក្ការសួរថា:

– "អីបងដងស្រឡាញ់នាងហ្នឹង?

- "ប្រាកដមែន! អញស្រឡាញ់នាងហ្នឹង មុក្តារ?

មុក្តារឆ្លើយថា:

- "ត្រូវប្រយ័ត្ន ស្បៃមជាសំឡាញ់ផងបង ចង់ដណ្តើមនាងឡើយយកពីយើងហើយ ។ គេសន្យានឹងឲ្យផ្ទាន់ជាប្រាក់យ៉ាងច្រើនដល់តាឡិប បើគាត់នេះគិតគូរបែបណា អាចនាំនាងក្រមុំទៅប្រគល់ឲ្យគេបាន ។ កូនឈ្លូសរបស់បងនឹងនិយាយប្រាប់រឿងអស់នេះដោយសព្វគ្រប់ ក្នុងវេលាព្រឹកស្អែក បើប្រសិនគាត់មិនត្រូវទៅត្រួតមើលចំការការហូ" ។

អ៊ីស្មាអ៊ីលសួរថា:

- "តាឡិបទៀងជាដឹងឆ្ងាស់ទូវកិច្ចការដែលឯងនិយាយឬ?" ។

មុក្តារគាន់តែឆ្លើយថា:

- "តាឡិបគាត់បានស្បថចំពោះព្រះនាមព្រះហើយជាស្រេចអំពីរឿងនោះ" ។

អ៊ីស្មាអ៊ីលសម្រេចសេចក្តីថា:

- "បើដូចសំដីអូនឯងនិយាយ ការណ៍ហ្នឹងពិតមែន ស្បៃមចង់, ដណ្តើមឡើងយកជាប្រាក ។ គឺជាសេចក្តីប្រមាថ មើលងាយមួយយ៉ាងធ្ងន់របស់ស្បៃមមកលើផ្ទះយើង" ។

មុក្តារឈាមពាវ ស្រែកឡើងដោយសេចក្តីតូចចិត្តថា:

- "ខ្ញុំទៀងជាផ្តាច់ស្ពានមេត្រីចេញពីវាជាមិនខាន" ។

អ៊ីស្មាអ៊ីលជញ្ជឹងមួយសន្ទុះ ទើបនិយាយយ៉ាងស្រួលថា:

– "នែមុត្តការអូន! កុំគាល់ច្រឡោត នៅស្ងៀមសិន ចាំស្តាប់បង ។ បងមានកលល្បិចមួយ... ។ រស្មីម ក៏មិនខានសង្ស័យអ្វីនៅឡើយទេ ។ ចូរស្តាប់បង ហើយបំបិទការណ៍សំងាត់នៃសេចក្តីព្រឿងនេះទុកក្នុងចិត្តឲ្យស្ងៀម" ។

ទុកាសនោះ អ៊ីស្មាអ៊ីលថយមកអង្គុយជិតមុត្តារ ហើយពន្យល់សព្វគ្រប់ នូវមធ្យោបាយដែលគេគិតទុក ដើម្បីបំបុងធ្វើឲសដល់រស្មីមជាអាក្បត់ ។

* * *

ទុកាសនោះជាថ្ងៃបុណ្យនៅក្រុងកាស៊ី-កាកប៊ូលី ព្រោះមានមនុស្សចំនួនច្រើនទើបនឹងមកពីលាបំណន់ឯវិហារព្រះដេតពន(១) តាមទំនៀម-ទំលាប់ប្រពៃណី ។ អំពីការធ្វើដំណើរលាបំណន់នេះ អាក៏ប់អ្នកកាន់សាសនាម្នាក់ៗត្រូវធ្វើយ៉ាងតិចក៏ម្តងក្នុងមួយជីវិតខ្លួន ។ អ្នកណាដែលគេបានធ្វើដំណើរលាបំណន់រៀងពស់ឆ្នាំ អ្នកនោះជាមនុស្សសុខសប្បាយទាំងកាយនឹងចិត្ត ។

ពួកអ្នកដែលអាស្រ័យនៅក្បែរមាត់សមុទ្រ នឹងពួកបរបាចរក៍នាបណ្តាដំរែកស្រយ៉ាងឆ្ងាយ កណ្តាល សាហារ៉ា(២) តែងធ្វើដំណើរតាមនាវាទៅកាន់វិហារព្រះដេតពន ដោយចំណាយមាសជាក់បន្តិចបន្តួច

---

១ ដេតពនជាឈ្មោះព្រះវិហារមួយនាក្រុងសាវត្ថីប្រទេសឥណ្ឌៀ គេកសាងឡើងថ្វាយព្រះសម្មាសម្ពុទ្ធ ដោយឮខ្មែរនិយមរាប់អានព្រះវិហារនេះ ពួកចាមយកកន្លែងមហាម៉ែតហៅថាព្រះដេតពនដែរ តែតាមការពិត កន្លែងមហាម៉ែតហៅថា: ម៉ែត ។

២ ឈ្មោះវាលខ្សាច់ក្នុងប្រទេសអាហ្វ្រិច ។

ដែលខ្លួនបានសន្សំទុកមកជាយូរឆ្នាំ ។ បណ្ណាអ្នកជំណើរទាំងនោះ មានមនុស្សចំនួនច្រើន ដែលស្លាប់ចោលឆ្មោចហូរហែតាមសមុទ្រក្រហមនឹងលើរាលឡាច់ប្រទេសអាវ៉ាប់ ។ ទោះបីយ៉ាងដូច្នេះក៏ដោយចុះ ពួកជនទាំងនោះក៏ឥតរួញរាទ្បើយ ។

តាំងពីចំនួនជប់សតវត្សមកហើយ ការទុរ្ភិក្ស នឹងជម្លឺប៉ែសបានបំផ្លាញក្នុងមួយឆ្នាំ ៗអស់មនុស្សច្រើនណាស់ ព្រមទាំងបញ្ចូលមេរោគមកក្នុងបណ្ណាអ្នកនៅរស់ដែលត្រូវត្រឡប់មកវិញផង ម្ល៉ោះហើយរោគរាតត្បាតនេះ ចួនកាលចាប់ផ្តើមធ្វើការតាំងពីពេលមុនធ្វើដំណើរទៅទៀតក៏មាន ។

ហេតុដូច្នេះ កាលពីគ្រិស្តសករាជ ១៩០៦ នាក្រុងបេង្គាស៊ី រោគរាតត្បាតបានសំដែងវិទ្ធិឡាំងអស្ចារ្ស ក្នុងរាងប៉ុន្មានថ្ងៃសោះ រាសំឡាប់មនុស្សអស់ចំនួនប្រាំបីពាន់នាក់ ។ អ្នកជម្លឺដួលដេករណែលតាមផ្លូវ ចោលឆ្មោចរលួយស្អុយនៅទីនោះ ។ មានអ្នកខ្លះញាក់ទៃទ្រីក ដួលលើតំនរសម្រាម កំពុងរកសត្វស្លាប់ដែលគេចោលយកមកស៊ី ចួនកាលដាច់ឡល់កំពុងបរិភោគអាហារដ៏រអើមនេះ ។

ប៉ុន្តែ ក្នុងប្រទេសនោះ ជម្លឺផង ការនៀយហត់ផង ការស្លាប់ផងទាំងនេះគួរណាស់តែបន្ទយអធិមុត្តិ (ការចុះចិត្តស៊ីប់) ទាងសាសនានោះ ចេញខ្លះ នៃះមិនដូច្នោះ ហាក់ដូចជារឹតតែរុញអធិមុត្តិ នៃមនុស្សគ្រប់ក្រៀនកោះក្នុងប្រទេសឥស្លាមឲ្យឡើងដល់ទីបំផុតរាល់ឆ្នាំ ។

(មានត)

រឿងបល្ថង្ហទិព្យ សាបសិបពីររឿង

រឿងព្រេងតណ្ឌៀ

លោកសមិន ម្ចាត្យ៉ងជម: តែង

លោក វ៉ាយ-ប៊ុក ក្រមការ ប្រែជៀបជៀង

(តមក)

និទាននៃរូបទេពនិម្មិតទីប្លន

ព្រះមហាវាជភោជ: ទ្រង់មានព្រះរាជបំណងចង់ឲ្យតេអភិសេក ទ្រង់ឲ្យសោយរាជ្យជាស្តេចពេញលក្ខណ:, ទ្រង់ក៏យាងមកជិតព្រះ បល្ថ៉ង្ហទិព្យ ។ ក្នុងពេលនោះ រូបទេពនិម្មិតទីប្លនក្រាបទូលថា: "សូម មហាវាជភោជ:ទ្រង់ជ្រាប; បល្ថ៉ង្ហទិព្យនេះ ជារបស់ព្រះបាទវិក្រមទិត្យ, បើព្រះមហាក្សត្រិយ៍អង្គណា មានព្រះគុណសម្បត្តិដ៏ឧត្តម ជូចព្រះ បាទវិក្រមទិត្យ ទើបអាចគង់នៅលើបល្ថ៉ង្ហនេះបាន" ។

ព្រះអភិវាជភោជ: ទ្រង់មានបន្ទូលទៅកាន់រូបទេពនិម្មិតទីប្លនថា: "តើគុណសម្បត្តិដ៏ឧត្តមនៃព្រះបាទវិក្រមទិត្យនោះយ៉ាងណាទ្ធះ?" ។ រូបទេពនិម្មិតនោះ ក៏ក្រាបទូលថា: "សូមទ្រង់ព្រះសណ្តាប់;

ព្រះបាទវិក្រមទិត្យ ទ្រង់សោយរាជសម្បត្តិនៅទីក្រុងអវន្តី ។ នៅ ក្នុងទីក្រុងនោះ មានព្រាហ្មណ៍ម្នាក់ត្មានកូន ជាវិញ្ញូជន ចេះដឹងជ្រៅជ្រះ ក្នុងវិទ្យា ១៤ ប្រការ គឺ: វេទ, បុត, យជ្ញ, សាម, អថិវ ព្រម

ទាំងអនុវិទ្យាទាំងប្រាំមួយ គឺ[1]គម្ពីរសិក្សា (Ciksa) កល្ប; វេយ្យាការណ:, និរុក្ត: (Nirukta); ជ្យោតិគ (Yotisha), ចន្ទ, សាស្ត្រ, បូវិ-ឧត្តរ-រូបមីមំសា (Pûrva-Uttara-Rûpa-Mimamsâ) វៃសេសិកសាស្ត្រ (Vaiceshika-Castra) ន្យាយ: (Nyâya) សំខ្យា? បតនជលី, រូបន្យាយ: (Rûpanyâya) វិស្តរ-ស្ម្ចុតិសាស្ត្រ (Vistara-Smrti-Castara) បូរាណ-សាស្ត្រ នឹង សាស្ត្រ:ខាងវិធីបតិបត្តិ គឺ: វេទ:នៃវេជ្ជសាស្ត្រ, វេទខាងធ្នូសីលជ័យ, សាស្ត្រខាងគ្រូង, សាស្ត្រខាងសិល្ប: ហត្ថកម្ម[2] វិទ្យាចំពោះវត្ថុដែលចក្ខុមើលឃើញ, ឯចំណែកវិទ្យាទាំងដប់បួនយ៉ាងដែលបានពណិនាខាងលើ ជាវិទ្យាសម្រាប់វត្ថុដែលមើលមិនឃើញ, ទាំងអស់រួមជាដប់ប្រាំបីវិទ្យា ។

ការិយានៃបណ្ឌិតគ្មានកូនេះ ពោលថា: "ឧស្ទាមីអើយ,សូមលោកថ្វាយបង្គំអាទិទេពសូមឲ្យខ្ញុំមានកូនមួយនៅក្នុងឧទរ" ។ ព្រាហ្មណ៍តបទៅនាងព្រាហ្មណីថា "នាងពោលនេះល្អ ។ បើគ្មានការប្រតិបត្តិតាមត្រូវទេ គ្មានវិទ្យា; បើគ្មានគុណសម្បត្តិខាងសាសនា គ្មានបុត្ត" ។ ព្រាហ្មណ៍ លុះពោលពាក្យដូចនេះ, ក៏បានបន់ស្រន់ចំពោះអាទិទេពក្នុងត្រួសារដើម្បីនឹងផ្គាប់ចិត្តការិយា ។ ផលដែលបានមកពីការណីយកិច្ចនេះ គឺព្រាហ្មណ៍មានបុត្តម្នាក់ពីនាងព្រាហ្មណី បុត្តនោះគេឲ្យនាមថា

---

[1] គឺថាគម្ពីរទាំងប្រាំមួយឈ្មោះតែមួយថា ជ្រទន្ត (Vetsnaga) ។ [2] ពាក្យតណ្ឌ គឺ: អយុជ្រទិ (Ayur-Veda) ធនុជ្រទិ (Dhanur-Veda) ធន្ធវិសាស្ត្រ (Ganaharva) សិល្បសាស្ត្រ: ។

ទេវទត្ត ។ ព្រាហ្មណ៍ជាបិតាបានឲ្យទេវទត្តរៀនសូត្រនូវសាស្ត្រៈទាំងឡាយ ហើយក៏រៀបវិវាហមង្គលការនឹងស្ត្រីម្នាក់ ។ ព្រាហ្មណ៍នោះ កាលពិចារណានូវវជ្ជសង្សារ ក៏បានទៅកាន់ស្រះបោក្ខរណី, ចំណែកទេវទត្ត ស្ថិតនៅក្នុងគេហដ្ឋានក្នុងហានៈជាត្រហារាស ។

មានមួយថ្ងៃទេវទត្តបានទៅព្រៃ ដើម្បីនឹងទៅរកឧសមកដុតបូជាយ័ញ ។ ក្នុងពេលនោះ, មហារាជវិក្រមទិត្យទ្រង់គង់លើអស្ពរ យាងទៅបរបាញ់ក្នុងព្រៃនោះដែរ, ទ្រង់ក៏យាងទៅពាសពេញព្រៃជាមួយនឹងកងទ័ពជាព្រះរាជបរិវារ ដើម្បីនឹងតាមម្រឹគ ។ មហារាជវិក្រមទិត្យ ទ្រង់ស្រេកព្រះឧទកៈពន់ពេក ដោយទ្រង់វង្វេងនៅក្នុងព្រៃ, ទ្រង់ជួបប្រទះនឹងព្រាហ្មណ៍ទេវទត្ត ។ ព្រះមហាក្សត្រទ្រង់បានតេទៅយើញ ព្រាហ្មណ៍, ទ្រង់សំដែងនូវតារវកាពចំពោះព្រាហ្មណ៍ ហើយមានព្រះបន្ទូលថា "វនព្រាហ្មណ៍ យើងស្រេកទឹកពន់ពេក ចូរអ្នករកទឹកឲ្យយើងផឹកផង" ។

ព្រាហ្មណ៍បានស្តាប់នូវព្រះរាជឧស្ការព្រះបាទវិក្រមទិត្យ ក៏ថ្វាយនូវផ្ទៃឈើមួយ មានឧជារសធ្លាញ់ពិសា ហើយក៏ថ្វាយទាំងទឹកត្រជាក់ទៅទ្រង់ ។ ទ្រង់សោយផ្ទៃឈើនោះរួចសោយព្រះឧទកៈ ហើយទ្រង់ក៏មានព្រះកាយពលឡើងវិញ ។ ចំណែកព្រាហ្មណ៍ ក៏ទៅបង្ហាញផ្ទូវថ្វាយព្រះមហាក្សត្រ ជាផ្ទូវដែលទៅកាន់ព្រះរាជនិវេសនដ្ឋាន ហើយវិលត្រឡប់ទៅផ្ទះវិញ ។

មានថ្ងៃមួយ ព្រះមហាក្សត្រទ្រង់បានធ្វើព្រះរាជសន្ទនាការជាមួយ

ព្រះរាជទីប្រឹក្សា, ទ្រង់មានបន្ទូលប្រាប់មន្ត្រីធំ-តូច ដែលចូលទៅ
សន្ទិបាតក្នុងពេលនោះ អំពីព្រាហ្មណ៍ទេវទត្ត បានសង្ត្រោះជល់ព្រះអង្ត
ហើយក៏ទ្រង់បានសរសើរព្រាហ្មណ៍នេះចំពោះមហាជន ។ ព្រាហ្មណ៍
នេះ បានដឹងដំណឹងសព្វគ្រប់ក៏គិតក្នុងចិត្តថា "អញបានសង្ត្រោះ
ចំពោះឧត្តមបុគ្គល, សេចក្តីសង្ត្រោះនេះ ធ្វើឲ្យឧត្តមបុគ្គលនេះ មានហេតុ
ទាក់ទងនឹងអញអស់មួយជីវិត ។ អញចង់ដឹងតើកតញ្ញូរបស់មហារាជ
មានសភាពត្រឹមណាទៅ?" ។ ព្រាហ្មណ៍គិតដូចនោះហើយ, បាន
រកឃើញមធ្យោបាយមួយ បន្ទាប់មកគាត់លួចព្រះរាជបុត្រព្រះមហាក្សត្រ
នាំយកទៅលាក់បំពួនទុកក្នុងគេហដ្ឋាន ។ ព្រះរាជាទ្រង់ជ្រាប់ថា ព្រះ
រាជបុត្រទ្រង់បាត់ពីព្រះដំណាក់ ទ្រង់បានចាត់អាមាត្យសេនាទៅគ្រប់ទី
កន្ទែងដើម្បីនឹងស្វែងរកព្រះរាជបុត្រ ។ រាជអាមាត្យព្យាយាមរកយ៉ាង
ណាក៏រកព្រះរាជបុត្រមិនឃើញ ។ ព្រះមហាក្សត្រទ្រង់ព្ឱយព្រះរាជ-
ហ្ឫទ័យពន់ពេក ព្រមទាំងនាហ្មឹនសព្វមុខមន្ត្រីក៏ព្ឱយចិត្តដែរ ។

ក្នុងពេលនោះ ទេវទត្តព្រាហ្មណ៍ បានយករតនវត្ថុដែលព្រះ
រាជបុត្រទ្រង់ ប្រគល់ឲ្យទាសាយកទៅលក់ឯផ្សារ. ទាសានោះ
បានទៅដល់ពាណិជស្ថានមួយ បានយកគ្រឿងអលង្ការនោះទៅបង្ហាញ
នាយពាណិជ ។

ក្នុងមួយរំពេចនោះ, រាជអាមាត្យបានឃើញនូវទាសានៃព្រាហ្មណ៍
កាន់គ្រឿងប្រដាប់របស់ព្រះរាជបុត្រ, បានចាប់ទាសានោះ នាំយកទៅ

ថ្វាយព្រះមហាក្សត្រ ។ ទ្រង់ឈ្វៀងព្រះនេត្រទៅកាន់ទាសា មានព្រះបន្ទូលសួរថា "គ្រឿងអលង្ការនេះជារបស់កូនយើង តើអ្នកឯងយកពីណាមក? ឯណាកូនយើង? ។

ទាសានោះក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាជ្រាស, ព្រាហ្មណ៍នាមទេវទត្ត បានប្រគល់ឲ្យខ្ញុំព្រះបង្គំយកគ្រឿងអលង្ការនេះទៅលក់" ។

ព្រះមហាក្សត្រទ្រង់ជ្រាបន្ទូវដំណឹងនេះ ទ្រង់បានចាត់ពួកអាមាត្យឲ្យទៅហៅទេវទត្តព្រាហ្មណ៍មក, ទ្រង់មានបន្ទូលសួរថា: "អ្នកឯងបានប្រគល់គ្រឿងអលង្ការនេះឲ្យគេយកទៅលក់មែនឬ?" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា: "ខ្ញុំព្រះបង្គំបានឲ្យទាសាខ្ញុំបង្គំយកគ្រឿងអលង្ការនេះទៅលក់មែន សូមទ្រង់ជ្រាបក្រមល្អង់ធួលិព្រះបាទ" ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរគេទៅទៀតថា "តើអ្នកឯងយកគ្រឿងអលង្ការនេះពីណាមក" ។ ព្រាហ្មណ៍ទូលថា "ខ្ញុំព្រះបង្គំបានយកពីព្រះពាជបុត្រ" ។ ព្រះមហាក្សត្រទ្រង់សួរថា "កូនយើងនៅឯណា? ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "ព្រះពាជបុត្រទិវង្គតហើយ" ។ ព្រះមហាក្សត្រមានបន្ទូលសួរថា "ម្តេចក៏កូនយើងស្លាប់" ។ ព្រាហ្មណ៍ក្រាបទូលថា "ខ្ញុំព្រះបង្គំបានធ្វើឃាតកម្ម" ។ មហាពាជទ្រង់មានបន្ទូលថា "អ្នកឯងជាព្រាហ្មណ៍, ជាបណ្ឌិត ជាវិញ្ញូជន សុចរិតពិតត្រង់ តើហេតុអ្វី បើគ្មានរឿងសោះ ក៏អ្នកឯងហ៊ានសម្លាប់កូនយើង" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "មកអំពីលោភចិត្តនៃខ្ញុំព្រះបង្គំបានជាខ្ញុំបង្គំហ៊ានពិឃាតព្រះពាជបុត្រ" ។

ក្នុងខណៈនោះ ព្រះមហាក្សត្រទ្រង់ជានធ្នៀងព្រះនេត្រទៅព្រះរាជទីប្រឹក្សា ។ ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស មនុស្សណាដែលពិឃាតព្រះរាជវង្សានុវង្ស មនុស្សនោះត្រូវព្រះមហាក្សត្រដាក់ទណ្ឌកម្មប្រហារជីវិតបង់ ឯអ្នកនេះជានពិឃាតព្រះរាជបុត្រ, បើតាមយុត្តិធម៌ អ្នកនេះត្រូវតែគេប្រហារជីវិតបង់ដែរ ។ តែអ្នកនេះជាព្រាហ្មណ៍ត្រូវហូតហានន្តរសក្តិនេះចេញ ហើយនិរទេសចេញពីព្រះរាជអាណាចក្រព្រមទាំងអ្នកជិតខាងគាត់" ។ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះ ដល់គុណូបការៈដែលព្រាហ្មណ៍ជានបំពេញចំពោះព្រះអង្គ មិនជានយល់តាមសេចក្តីវិនិច្ឆ័យនៃព្រះរាជទីប្រឹក្សា, ទ្រង់អនុញ្ញាតទោសព្រាហ្មណ៍នោះ ហើយទ្រង់ត្រាស់បង្គាប់ឲ្យគេដោះលែងគាត់ដោយសេរី ។

ព្រាហ្មណ៍នោះ កាលឃើញព្រះទ័យសប្បុរសនៃមហារាជ ក៏មានចិត្តត្រេកអរពន់ពេក ជានវិលត្រឡប់ទៅគេហដ្ឋានខ្ជួនវិញ ហើយក៏ឲ្យព្រះរាជបុត្រព្រះជានវិក្រមទិត្សសែង់ព្រះឧទក: សោយនូវព្រះស្ងោយ ហើយ បំពាក់នូវគ្រឿងអលង្ការសព្វយ៉ាង ហើយក៏នាំព្រះរាជបុត្រ់យកទៅឯព្រះរាជក្រុមប្រឹក្សា ។ មហារាជទ្រង់ទតឃើញព្រះរាជបុត្រវិលមកវិញ ទ្រង់មានព្រះទ័យសោមនស្សពន់ពេក, ទ្រង់ឧបព្រះរាជបុត្រដាក់ផ្ទាប់ទៅនឹងព្រះឧរ: (ទ្រូង) ហើយមានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍ថា "ម្នាលព្រាហ្មណ៍ ! ហេតុម្តេចក៏អ្នកឯងធ្វើយ៉ាងដូច្នេះ យើងមិនយល់នូវតំនិតអ្នកឯងសោះឡើយ" ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា "ទូលព្រះបង្គំចង់ដឹង គុណូបការៈដែលទូលបង្គំជានបំពេញចំពោះព្រះអង្គ តើព្រះ

អង្គទ្រង់នឹងតបបែបណាទៅ? តឹមកពីទូលបង្គំចង់ជឹងនូវផលនៃកតញ្ញូ
បានជាទូលបង្គំដើរទុបាយបែបនេះ" ។

ក្នុងមួយរំពេច, ព្រះមហាក្សត្រទ្រង់បានព្រះរាជទាននូវព្រះរាជទ្រព្យជា
ច្រើនអនេកប្បការដល់ព្រាហ្មណ៍ ហើយទ្រង់សព្វព្រះរាជហ្ឫទ័យពន់ពេក
នឹងព្រាហ្មណ៍នោះ ។ រួចតមក, ព្រាហ្មណ៍ក៏វិលមកកាន់គេហដ្ឋានវិញ ។

រូបទេពនិម្មិតទីបួន, ក្រោយដែលបាននិទាននូវរឿងរ៉ាវខាងលើនេះ
បានក្រាបទូលព្រះបាទកោជៈថា "បពិត្រព្រះមហារាជកោជៈ បើទ្រង់
អាចប្រព្រឹត្តកតញ្ញូឲ្យជូចជាព្រះមហាក្សត្រវក្រមទិត្យ ជូចទូលបង្គំបាន
ក្រាបទូលអំបាញ់មញនេះ ទើបទ្រង់អាចតង់លើបល្ថ័ង្ក្ទិព្យនេះបាន" ។
ព្រះមហាក្សត្រទ្រង់ព្រះតម្រិះថា ត្មានអ្នកណាធ្វើកតញ្ញូឲ្យបានជូចព្រះបាទ
វិក្រមទិត្យទេ, ទ្រង់ក៏បង្អង់ព្រះរាជាភិសេកក្នុងពេលនោះ ។

* * *

(មានត)

ក្រោធដោយឥតហេតុមិនដាយនឹងបន្សាប

មែនពិត, នរជនណាក្រេវក្រោធដោយប្រកាន់យកហេតុណាមួយជានិមិត្ត, នរជន
នោះ កាលបើហេតុនោះរលត់ហើយ នឹងជ្រះថ្លាវិញ (គឺបាត់ខឹង) មួយរំពេច; ចុះបើ
នរជនណា ក្រេវក្រោធស្អប់ខ្ពើមដោយមិនមានហេតុ តើនរណាហ្ន៍នឹងអាចចេះមន្ត
អាគមបន្សាបឲ្យនរជននោះសាបក្រោធបាន?

កំណាត់ដើមប្រវត្តិសាស្ត្រ

គម្ពីរប្រវត្តិ ដំណើរនៃការប្រឡងចេញពីសាលាបាលីវង្សវត្តឃ្លាំង

ខែត្រឃ្លាំងប្រទេសយៀកណាមខាងត្បូង (កម្ពុជាក្រោម)

ព្រះមហា ទួត - ទឹម

អាចារ្យសាលាបាលីវង្សវត្តលង្កា រៀបរៀង

ដោយមានដីកាពីក្រសួងធម្មការលេខ ៤០១ ចុះថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ១៩៥៥ ដែលប្រគល់ការៈឲ្យសាលាបាលីជាន់ខ្ពស់ ចាត់ចែងវិធានការប្រឡងចេញនៃសិស្សសាលាបាលីវង្ស ព្រមទាំងសំបុត្រលេខ ៥៥ ចុះថ្ងៃទី ៤ កុម្ភៈ ឆ្នាំ ១៩៥៥ របស់លោកឡឹម - ឯម អធិបតីនៃពុទ្ធសាសន-បណ្ឌិត្យវង្ស សុំអនុញ្ញាតបើកឲ្យសិស្សសាលាបាលីវង្សនៅខែត្រឃ្លាំង នឹងព្រះត្រពាំង ប្រឡងចេញនៅថ្ងៃទី ១៤ មីនា ឆ្នាំ ១៩៥៥, នោះក្រសួងធម្មការបានចាត់តាំងភិក្ខុ ៤ រូបគឺៈព្រះញាណគោសល ញាណ · ឈឺន ក្រមដំនុំព្រះត្រៃបិដក, ព្រះមហាទួត - ទឹម អាចារ្យសាលាបាលីវង្សវត្តលង្កា, ព្រះវិន័យធម្មថេរ - យុ នឹងព្រះមហាថាច់ - ឯក វត្តសាកវ័ន ឲ្យទៅធ្វើជាគណកម្មការក្នុងការប្រឡងនេះ ។ ព្រះញាណគោសល ញាណ · ឈឺន នឹងព្រះមហាទួត · ទឹម ត្រូវទៅមន្តៅខាងខែត្រឃ្លាំង; ព្រះវិន័យធម្មថេរ · យុ នឹងព្រះមហាថាច់ · ឯក ត្រូវទៅមន្តៅខាងខែត្រព្រះត្រពាំង ។

នៅថ្ងៃព្រហស្សត៍ទី ១០ មីនា ឆ្នាំ ១៩៥៥ ព្រះថេរៈទាំង ៤ រូប បានធ្វើដំណើរចេញពីក្នុំពេញទៅសំណាក់នៅវត្តចន្ទរង្សី (ព្រៃនគរ) មួយរាត្រី ព្រឹកឡើងថ្ងៃសុក្រទី ១១ ព្រះញាណកោសល នឹងព្រះមហាទួត - ទឹម និមន្តទៅខេត្រឃ្ចាំង ។

ឯព្រះថេរៈពីរអង្គទៀតក៏ចេញដំណើរនិមន្តទៅខេត្រព្រះត្រពាំង ទីទៃអំពីគ្នា ។

*

* *

របៀបវារៈនៃការប្រឡង

នៅថ្ងៃចន្ទទី ១៤ មីនា ឆ្នាំ ១៩៥៥ ជាអភិលក្ខិតសម័យ បានបើកឧកាសឲ្យសិស្សប្រឡងនៅវត្តឃ្ចាំង ។ ក្រុមសិស្សនឹងគណកម្មការមេប្រយោគ ដែលមានព្រះគ្រូបញ្ញាវង្សាថាច់ - លន ចៅអធិការវត្តឃ្ចាំង ជាអធិបតី, ព្រះញាណកោសល ញាណ - ឈឹន អធិបតីរង ព្រមទាំងលោកថាច់ - ប៉ាង តំណាងអធិបតីនៃពុទ្ធសាសនបណ្ឌិត្យរង, លោកឧញ-ប្រាជ្ញ លេខាធិការ បាននិមន្តនឹងអញ្ជើញទៅជួបជុំនៅក្នុងមន្ទីរប្រឡងដើម្បីចាំទទួលលោកចៅហ្វាយខេត្រឃ្ចាំង ជាតិយៀកណាម លោកនាំយកវិញ្ញាសាមកប្រគល់ឲ្យ ។

នៅឧកាសមុនបន្តិច ព្រះញាណកោសល លោកបានថ្ងៃងសេចក្តីក្នុងនាមនៃពុទ្ធសាសនបណ្ឌិត្យ, សាលាបាលីជាន់ខ្ពស់ ជាស់គឿនក្រុមបេក្ខសមណៈ ដើម្បីទុកជាឧត្តមគតិដល់សិស្សទាំងឡាយដូចមានតទៅ៖

បេក្ខសមណៈ៖ តាំងឡាយ! ខ្ញុំមានចិត្តត្រេកអរណាស់ ដោយខ្ញុំបានទទួលអនុញ្ញាតអំពីរាជការក្រសួងធម្មការ ចាត់ឲ្យមកបំពេញបេសកកម្មខាងព្រះពុទ្ធសាសនានៅទីនេះ, មួយទៀត ដោយនឹកឃើញដល់កិច្ចព្រះពុទ្ធសាសនា នឹងដោយសេចក្តីរព្ធកបំពោះបងប្អូនរួមជាតិខ្មែរដែលនៅក្នុងដែនកូស័ងស៊ីនេះ ទើបខ្ញុំត្រូវតែស៊ូប្តូរព្យាយាមមកដោយមិនគិតដល់ការនឿយហត់ឡើយ ។

ហេតុនេះ ខ្ញុំសូមជាស់តឿនដល់លោកជាបេក្ខសមណៈ៖ គ្រប់រូបថាការប្រឡងនេះ ជាកិច្ចពិសោធបំណេះវិជ្ជានៃការសិក្សា ដែលលោកគ្រប់អង្គបានសិក្សាមកគ្រប់កាលយ៉ាងតិចត្រឹម ៣ ឆ្នាំ ក៏ត្រូវតែប្រឡងចេញពីសាលាបាលីរង បើលោកអង្គណាបានប្រឡងជាប់ថ្នាក់នេះហើយ លោកអង្គនោះឈ្មោះថា បានសិក្សាចប់កិច្ចសិក្សាថ្នាក់ដំបូង, តែលោកគ្រប់អង្គកុំភ័ន្តច្រឡំ កុំសំគាល់ថា កិច្ចសិក្សាចប់ត្រឹមនេះហើយឲ្យសោះ ព្រោះកិច្ចសិក្សានៅមានច្រើនទៅមុខទៀត ការប្រឡងជាប់បានវិញ្ញាបនបត្រសាលាបាលីរងនេះ គ្រាន់តែមានអំណាចនឹងចូលប្រឡងជាសិស្សសាលាបាលីជាន់ខ្ពស់ឯក្នុំពេញប្ដ្រាថ្នាហានន្តរជទៃ ដែលមានដំឡៃស្មើនឹងវិញ្ញាបនប័ត្រសាលាបាលីរងប៉ុណ្ណោះ, ហេតុនេះលោកត្រូវតែតាំងចិត្តបណ្ដុះឆន្ទៈបំពេញកិច្ចសិក្សាតទៅមុខទៀត កុំអាលលះបង់ឡើយ ។

នៅទីបំផុត ខ្ញុំសូមផ្តាំអស់លោកដែលបានសិក្សាចេះដឹងត្រឹមសាលាបាលីរងក្តី សាលាបាលីជាន់ខ្ពស់ក្នុងខាងមុខនេះក្តី សូមលោកតាំងចិត្ត

ប្រកបដោយកតញ្ញូកតវេទី ចំពោះអ្នកឧបត្ថម្ភក្នុងកាលដែលខ្លួនមានសេចក្តីត្រូវការ ដូច្នេះ ខ្ញុំសុំឲ្យលោកដឹងថាការបានចេះដឹងអំពីឯកន្តៃដ៏ណា បុគ្គលណា ឬសមាគមណា បានទំនុកបំរុងឲ្យលោកបានចេះដឹងដល់ថ្នាក់នេះ លុះលោកបានសម្រេចវិជ្ជាហើយ លោកត្រូវតែធ្វើអនុវត្តន៍តបគុណចំពោះបុគ្គលនោះ សមាគមនោះឲ្យបានជាក់ស្តែង ទើបឈ្មោះថាលោកជាអ្នកប្រតិបត្តិខ្ជួនឲ្យសមដល់ឋានៈជាពលសាសនា និងជាពលរដ្ឋដែលមានព្រះពុទ្ធសាសនា; ប្រសិនបើលោកសិក្សារៀនសូត្រ បានចេះដឹងហើយ។ លោកគិតតែត្រឹមយកចំណេះមកបំពេញប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាង មិនគិតដល់ប្រយោជន៍សាធារណៈ គឺប្រយោជន៍របស់សាសនានឹងប្រយោជន៍របស់ជាតិផងទេ នោះសាសនាឬជាតិនឹងឲ្យឈ្មោះលោកថាជាមនុស្សអកតញ្ញូបាន ព្រោះថាខ្លួនបានចេះដឹងទៅជាមនុស្សមានឧត្តមគតិខ្ពង់ខ្ពស់ប៉ុណ្ណេះ ក៏ដោយសារជាតិនឹងសាសនាជួយឧបត្ថម្ភឲ្យ បើយើងមិនបានយកចំណេះវិជ្ជានេះទៅបំរើជាតិ បំរើសាសនាទេ ក៏ឈ្មោះថាយើងមិនដឹងគុណហើយ។

មុននឹងបញ្ចប់ហោកបានឆ្លៀតឱកាសឲ្យស័ព្ទសាធុការពរដល់បេក្ខ-សមណៈទាំងឡាយថា សុំឲ្យបានប្រឡងជាប់ពិន្ទុគ្រប់ៗគ្នា; បេក្ខសមណៈទាំងឡាយក៏បានទទួលសាធុដោយសេចក្តីត្រេកអរគ្រប់ៗរូប។

លុះដល់ម៉ោង ៨ ខ្វះ ១៥ នាទី លោកចៅហ្វាយខែត្រឃ្លាំង បាននាំវិញ្ញាសាប្រឡងមកប្រគល់ឲ្យគណកម្មការតាមលក្ខណៈច្បាប់ ។ ពេលនោះព្រះមហាថាច់-ពេច អាចារ្យបង្រៀនសាលាចាលីវង្សវត្តឃ្លាំង បានថ្វាយសុន្ទរកថាទទួលសេចក្តីត្រេកអរចំពោះពាក្យយៀកណាមដែលបានយកចិត្តទុកដាក់ខ្វល់ខ្វាយក្នុងកិច្ចប្រឡងចាលី ដែលជាវិជ្ជាបែកខាងព្រះពុទ្ធសាសនា, លោកចៅហ្វាយខែត្រក៏បានថ្វាយសេចក្តីខ្វី ។ ទទួលអំណរគុណចំពោះកិច្ចនេះដោយស្មោះស្ម័គ្រ ។ បន្ទាប់មកព្រះញាណកោសលបានថ្វាយសេចក្តីខ្វី ។ ក្នុងនាមនៃវង្សកិបាលកម្ពុជាថា "អាត្មាភាពគ្រប់រូបមានសេចក្តីត្រេកអរណាស់ ដោយបានឯកទុតមអញ្ជើញមកជាកិត្តិយសក្នុងទុកាសជាសុភមង្គលនេះ អាត្មាភាពសូមប្រសិទ្ធីពរចំពោះវង្សកិបាលទាំងពីរ គឺវង្សកិបាលកម្ពុជា នឹងវង្សកិបាលយៀកណាម សូមឲ្យប្រកបដោយសន្តិភាពទាំងមានជោគជ័យជានិច្ចកាល ដើម្បីនឹងបានជាមេត្រីភាក់ទងគ្នារៀងរាបតទៅឯអនាគតជាយូរអង្វែង" ។ លុះដល់ម៉ោង ៨ គណៈកម្មការមេប្រយោគចាប់ផ្តើមធ្វើការប្រឡងតាមកាលបរិច្ឆេទ ដូចមានក្នុងប្រកាសជាមួយនឹងអ្នកដំណាងលោកអធិបតីវង្សខែត្រឃ្លាំង ។

របៀបការៈដែលបានធ្វើការប្រឡងអស់កាលកំណត់ ៣ ថ្ងៃដូចតទៅនេះគឺ :

ថ្ងៃទី ១ .— ពេលព្រឹកពីត្រឹមម៉ោង ៨ ទៅដល់ម៉ោង ៩ សរសេរតាមសូត្រជាភាសាខ្មែរ, ពេលល្ងាចពីម៉ោង ១៥ ទៅដល់ម៉ោង ១៧ ប្រែចាលី លោតប្រយោគ ។

ថ្ងៃទី ២.— ព្រឹកពីម៉ោង ៨ ដល់ម៉ោង ៩ អធិប្បាយតាថា, រៀលា
រសៀលពីម៉ោង ១៥ ទៅដល់ម៉ោង ១៦ - ៣០ តបប្រស្នាវិន័យ ។

ថ្ងៃទី ៣.— ព្រឹកពីម៉ោង ៨ ដល់ម៉ោង ៩ តបប្រស្នាពុទ្ធប្បវត្តិ ។

គណៈកម្មការបានពិនិត្យកែវិញ្ញាសាហើយជាស្រេចនៅក្នុងវារៈនៃ
ការប្រឡងនោះ ។ បណ្តាគ្រហស្ថជាតិខ្មែរដែលជាពុទ្ធសាសនិក
ច្រើនរូប បានចាត់ចែងចង្ហាន់ប្រគេនគណកម្មការ ព្រមទាំងបេក្ខស-
មណៈគ្រប់រូបដោយបរិបូណិគ្រប់គ្រាន់ ។ នៅថ្ងៃទី ៣ ដែលសម្រេច
ការប្រឡងហើយ រៀលាម៉ោង ១៧ ល្ងាច ក្រុមឧបាសកឧបាសិកា
ទាំងឡាយ បាននិមន្តព្រះញាណកោសលសំដែងធម៌ទេសនា នាសាលា
បុណ្យក្នុងវត្តឃ្ងាំងនោះ ។

*

* *

លទ្ធផលនៃការប្រឡង

បេក្ខសមណៈដែលបានចូលប្រឡងចំនួន ៦០ រូប លុះប្រឡងរួច
រាល់ហើយ គណកម្មការបានពិនិត្យកែហើយស្រេច ឃើញសិស្សដែល
បានទទួលលទ្ធផលនៃការប្រឡងជាប់ចំនួន ៥០ រូប ដូចមានក្នុងសេចក្តី
កត់ហេតុស្រាប់ ។

លុះដល់ថ្ងៃពុធទី ១៦ មីនា ឆ្នាំ ១៩៥៥ ក្រោយថ្ងៃប្រឡងនៅរៀលា
ម៉ោង ១៦ ដល់ម៉ោង ១៩ ព្រះញាណកោសលធ្វៀតទកាសធ្វើទស្សន-

កិច្ចដើរមើលសិស្សសាលាជាតិវ្ទេរតាំងពីថ្នាក់កុមារដ្ឋាន ដរាបដល់សិស្ស អនុវិទ្យាល័យថ្នាក់ឆ្នាំទី ១-២ ជាមួយនឹងពួកគ្រូសាលាទាំងនោះ ហើយ បានធ្វើបាឋកថារំពុកដល់សិស្សប្រមាណ ៥០០ រូប អំពីគោលធំ ៗ គឺ: ជាតិ, សាសនា, នឹងព្រះមហាក្សត្រ នឹងអំពីប្រវត្តិដែនកូស័ងស៊ីននា បច្ចុប្ប្ជន្ននេះ ដោយសេចក្តីទ្រូស ៗ បន្ទាន់ពេល, គ្រូនឹងសិស្សទាំងនោះ មានសេចក្តីរីករាយជាកិយ្យាភាពឥតឧបមាបានឡើយ ។

ថ្ងៃព្រិហស្សត៍ទី ១៧ មីនា ទើបសមណបេសក:មាននាមដូចខាងលើ បានធ្វើដំណើរចេញពីខេត្រឃ្ចាំងមកសំណាក់នៅវត្តមុនីរ៉ង្សី ខេត្រ ព្រែកបុស្សីអស់កាលមួយរាត្រី ។ នៅទីនោះមាននិស្សិតជាតិវ្ទេរដែលនៅ សំណាក់រៀនក្នុងខេត្រព្រែកបុស្សីចំនួន ២៥ នាក់ និស្សិតទាំងនោះបាន នាំគ្នាមកថ្វាយបង្គំព្រះញាណកោសល ធ្វើបដិសណ្ឋារ:ដោយសេចក្តី គោរព, លុះដល់ម៉ោង ២១ យប់ព្រះមហាឧត្តមវិជ្ជា ថាច់-ប្រាជ្ញ និមន្ត ព្រះញាណកោសលឲ្យធ្វើបាឋកថាចំពោះនិស្សិតវ្ទេរទាំងនោះ ដើម្បី រំពុកដាស់គឿនដ៏ជ្រាលជ្រៅ ឲ្យធ្វើទុកក្នុងចិត្តដល់ប្រវត្តិសាស្ត្ររបស់ ជាតិ ព្រមទាំងឲ្យរក្សាសាមគ្គីរវាងវ្ទេរនឹងវ្ទេរ ព្រះញាណកោសល លោកក៏លើកយកគោលអាវ្យធមិនៃព្រះពុទ្ធសាសនាមកធ្វើជាបង្ហោលជាទី អាងមានសេចក្តីខ្ជីៗ ដូចតទៅ ៖

និស្សិតទាំងឡាយ! នៅក្នុងបរិយាកាសដ៏ចង្អៀតនេះ អាត្មាធ្វើ ដំណើរពីក្នុំពេញមកបំពេញបេសកកម្មផ្នែកខាងព្រះពុទ្ធសាសនា បាន

ឆ្ងៀតចែកឧកាស ដើម្បីជួបសន្ធនាប្រស្រ័យរវាងប្រជាជនជាតិខ្មែរ អ្នក
ស្រុកអាយ អាត្មាភាពមានសេចក្តីត្រេកអរណាស់ ។ និស្សិតទាំង
ឡាយ! អាត្មាសូមផ្តាំនឹងអស់អ្នកត្រប់ត្នាថា: ជាតិខ្មែរយើងរស់នៅ
ក្នុងបំណោមសាកលលោកនឹងគេបាន ដោយអាស្រ័យនឹងព្រះពុទ្ធសា-
សនា ។ ជាគោលមួយមានជំហររឹងប៉ុងល្អ សម្រាប់ទប់ទល់ខ្មែរ ទ្រទ្រង់
ខ្មែរឲ្យមានកិត្តិយសនៅក្នុងសាកលលោក សម្ងាញ់រួមលោកទាំងឡាយ
គេអាចស្គាល់ខ្មែរប្រាកដណាស់ថា ខ្មែរជាប្រជាជាតិមួយរស់នៅក្នុងបំ-
ណោមអាស៊ីបូព៌ មានព្រះពុទ្ធសាសនា មានព្រះមហាក្សត្រជាប្រមុខ
មានរដ្ឋាភិបាលត្រប់ត្រងរដ្ឋតាមរបបប្រជាធិបតេយ្យ ដូចប្រទេសទាំង
ឡាយខ្ទះក្នុងលោកសព្វថ្ងៃនេះដែរ ឯខ្មែរកម្ពុជាក្រោមបែកខ្មែកពីកម្ពុជា
ជាបច្ចុប្បន្ននេះជាយូរអង្វែងហើយ ដោយមានរដ្ឋាភិបាលផ្សេងពីគ្នា គឺ
១ រដ្ឋាភិបាលកម្ពុជា, ១ រដ្ឋាភិបាលយៀកណាមខាងត្បូង ។ សូម្បី
បែករដ្ឋាភិបាលដូច្នោះក៏ដោយ ក៏គង់ខ្មែរកម្ពុជាក្រោមទាំងនោះចេះ
រក្សាដំឡៃរបស់ជាតិដដែល គឺនៅប្រើភាសា, ប្រើអក្សរសាស្ត្រសម្រាប់
ជាតិ, រក្សាទំនឹមទំនៀម, សណ្ឋាប់ធ្នាប់, របរទទួលទាន, សំលៀក
បំពាក់ នឹងសាងវត្តអារាមតាមបវេណីខ្មែរពេញលេញឥតលះបង់ឡើយ ។
មិនតែប៉ុណ្ណោះគេស្គាល់ដល់ប្រវត្តិសាស្ត្ររបស់ខ្មែរតាំងពីបុរាណកាលមក
គេស្គាល់ថាខ្មែរសម័យបុរាណមានអាណាចក្រធំទូលាយណាស់ គេតែង
ហៅថា "មហានគរ". មានទំហំនឹងព្រំប្រទល់ដូចនិស្សិតទាំងឡាយ

បានរៀនចេះដឹងតាមផែនទីកូមិសាស្ត្រសព្វគ្រប់ស្រាប់ ។ នៅក្នុងសត-
វត្សទី ៦៥ នៃ ព. ស. ប្រទេសខ្មែរយើងត្រូវអាប់ស្មើបាត់ពន្ធឹ លោកទាំង
មូលស្ទើរតែក្លេចឈ្មោះអស់ហើយ ត្មានន្ទរណាមួយនឹកដល់ប្រទេសខ្មែរ
ទេ ព្រោះអំណាចអាណានិគមនិយមមករាវាំង បិទសិទ្ធិ សេរីភាពខ្មែរ
អស់ ខ្មែរគ្រាន់តែរស់នៅដោយការដកដង្ហើមចេញចូលប៉ុណ្ណោះ ត្រូវ
ត្មានឹងសុភាសិតថា " ស្លាប់ដូចពស់ រស់ដូចកង្កែប " ឥឡូវនេះ ដោយ
សេចក្តីព្រមព្រៀងត្មានរបស់ប្រជាជនជាតិខ្មែរ ដែលមានព្រះមហាក្សត្រ
ព្រះបាទសីហនុវ៉ន្មនជាប្រមុខ បានខំប្រឹងទាមទារឯករាជ្យបាន ទើប
សាកលលោកពោលសរសើរស្ទើរតែគ្រប់ប្រទេស ដោយគេនឹកស្មានខុសថា " ខ្មែរដើបមុខពុំរួចទេ " ស្រាប់តែខ្មែរផុះផ្លាទ្បើងវិញបាន
ទើបគេភ្ញាក់ខ្លួនគ្រប់ត្មាថា ឧ! ខ្មែរនៅដឹងខ្លួនដែរទេតើ ស្មានថាខ្មែរ
ស្លាប់បាត់ទៅហើយ ។

និស្សិតទាំងឡាយ! ពេលនេះប្រទេសខ្មែរបានឯករាជ្យហើយ
ដោតរាសនារបស់ប្រទេសបានផ្ទើសេចក្តីសង្ឃឹមលើនិស្សិតគ្រប់រូប សូម
និស្សិតគ្រប់រូបតាំងស្មារតីឲ្យមាំកុំប្រមាទឲ្យសោះ ខំរៀនសូត្រឲ្យបាន
ចេះដឹងគ្រប់ៗ ប្រាណ ហើយត្រូវអធិដ្ឋានក្នុងចិត្តថា នឹងធ្វើការបំរើជាតិ,
សាសនា, នឹងព្រះមហាក្សត្រតទៅ ។

ថ្ងៃសុក្រទី ១៨ មីនា ឆ្នាំ ១៩៥៥ ព្រះញាណកោសលនឹងសហ-
ការីរបស់លោក បានធ្វើដំណើរចេញពីវត្តមុនីរង្សីសំដៅទៅកំពង់ស្ពានជា

អាណាខេត្តត្រៃកបុស្ស៊ សំណាក់នៅក្នុងទីនោះអស់ ៦ រាត្រី, ឧកាសនោះ ប្រជាជនជាតិវ្ទ្ធរទាំងឡាយ បានយើញលោកនិមន្តទៅដល់ ក៏មានសេចក្តីត្រេកអរ បាននិមន្តសំដែងធម៌ទេសនាក្នុងយប់ទី ២, លុះព្រឹកឡើងថ្ងៃ ២០ មីនា ឆ្នាំជដែល ទើបធ្វើដំណើរចេញពីទីនោះឆ្ពោះទៅកាន់ខេត្រព្រះត្រពាំង ហើយសំណាក់នៅក្នុងខេត្រនោះអស់ថិរវេលា ៣ រាត្រីទៀត ដោយរង់ចាំពិនិត្យបញ្ជីនឹងសេចក្តីកត់ហេតុ នៃការប្រឡងនៅខេត្រព្រះត្រពាំង លុះរួចរាល់ហើយ ក៏ត្រឡប់មកកាន់រាជធានីវិញនៅថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៥៥ ដោយសេរីឥតមានមោះមៃអ្វីឡើយ ។

លក្ខណៈមនុស្សអន់

- ១ – ដំបូលផ្ទះឆ្លាយជាងដំបូលផ្សារ,
- ២ – គូថកវិយាជិតជាងម្ពាយឥពុក ។

ត្រង់ទី ១ សំដៅយកអ្នកដែលធ្វើដំណើរចេញពីផ្ទះ ទៅកាន់ទីដទៃដោយកិច្ចការណាមួយ, លុះដល់ត្រឡប់មកផ្ទះវិញ មិនត្រង់មករកផ្ទះទេ ត្រឡប់ដាចូលទៅស៊ីផឹកចាយវាយហ៊ីហាងផ្សារសិន រួចទើបមកផ្ទះ ។

ត្រង់ទី ២ សំដៅយកអ្នកដែលស្វះស្វែងរកទ្រព្យធនចានមកហើយ មិនគិតរំលែកទ្រព្យធននោះបូជាតបគុណមាតាបិតាឡើយ ដោយមិនធ្ងន់ចិត្ត, ធ្ងន់ចិត្តគិតឡាំងតែប្រពន្ធនឹងកូន ម្ហ៉ោះហើយក៏យកទ្រព្យធននោះទៅសង្ត្រោះចំពោះប្រពន្ធនឹងកូនតែប៉ុណ្ណោះ ។

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់គ្រុសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៤៧៦ ចុះថ្ងៃសុក្រ ៣ រោចខែបុស្ស ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូម៉ុក-កុយ នាមធាយ ព្រហ្មត្ថេរ កើតឆ្នាំ-ថោះ អាយុ ២៤ វស្សា ៣ ជាចៅអធិការវត្តពោធិព្រឹក្ស ឃុំស្វាយជ្រុះ ស្រុកស្ទឹង ខែត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៤៧៨ ចុះថ្ងៃសុក្រ ៤ កើតខែបុស្ស ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ សុខ-ទី នាមធាយ ឧត្តរត្ថេរ កើតឆ្នាំ-មមី អាយុ ៥៧ វស្សា ៣៧ ជាចៅអធិការវត្តជួងកែវមណី ឃុំត្រពាំងសាប ស្រុកចាទី ខែត្តតាកែវ ។

សញ្ញាប័ត្រលេខ ៤៧៩ ចុះថ្ងៃព្រហស្បត៍ ១ កើតខែមាឃ ឆ្នាំឆ្លូវ ឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ អ៊ុច-អ៊ុយ នាមធាយ ឥន្ទ្រវង្សបញ្ញា កើតឆ្នាំថោះ អាយុ ៣៦ វស្សា ១៥ ជាចៅអធិការ វត្តបន្ទាយក្រាវ ឃុំកណ្តឹង-ស្រុក-ខែត្តដូងែល ។

សញ្ញាប័ត្រលេខ ៤៨០ ចុះថ្ងៃចន្ទ ១១ រោចខែមាឃ ឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ រស់-ម៉ែន នាមធាយ សុវណ្ណបញ្ញា កើតឆ្នាំកុរ អាយុ ៦៤ វស្សា ៨ ជាចៅអធិការ វត្តទ្រព្យគរ ឃុំត្រពាំងសាប ស្រុក-ខែត្តដូងែល ។

សញ្ញាប័ត្រលេខ ៩៨១ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ឃួន-ប្រាង នាមធាយា មង្គលត្ទេរ កើតឆ្នាំរកា អាយុ ៣០ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្ត ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៨៧ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ មៅ-មាំ នាមធាយាវិន័យធម្មបញ្ញាកេសរ កើតឆ្នាំខាល អាយុ ៦៣ វស្សា ៤១ ជាគ្រូសូត្រស្តាំ វត្តស្វែង ឃុំជ្រៃវ្ទ ស្រុក ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៨៨ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ថៅ-ឡេង នាមធាយាឥន្ទកេសរបញ្ញា កើតឆ្នាំរកា អាយុ ៤១ វស្សា ៤០ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៨៩ ចុះថ្ងៃសុក្រ ៧ កើតខែចេត្រ ឆ្នាំធ្ងូវឯក ស័ក ព.ស. ២៤៩២ តាំងលោកគ្រូ សៅ-ស៊ុន នាមធាយា សុវណ្ណត្ទេរ កើតឆ្នាំម្សាញ់ អាយុ ៤៦ វស្សា ២៣ ជាចៅអធិការ វត្តប្រាសាទ ឃុំចំនួស ស្រុកសូទ្រនិគម ខេត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៩៩០ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ពុត-អ៊ុយ នាមធាយា ពុទ្ធសរោ កើតឆ្នាំខាល អាយុ ៦១ វស្សា ៣៩ ជាចៅអធិការ វត្តតគីរ ឃុំកន្ទ្ធាំង ស្រុក ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៩១ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ជួង-ប៉ាត់ នាមធាយា បុណ្ណសិរី កើតឆ្នាំជូត អាយុ ៣៨ វស្សា ១២ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក ខេត្រដដែល ។

(មានត)

ពន្ធលសុទិយា

ទស្សនាវិជ្ជី ផ្សាយជំណឹងទាងសាសនា នឹងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែមិថុនា ឈេ១៦

ព.ស.២៤៩៨ – គ.ស. ១៩៥៥

ក.ជ ៤៤ - ៦ - ///



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

		ទំព័រ
ផ្នែកសាសនា		
—វិចារណកថា	លោកប៊ូ-ប៊ូ	៣២៣
—អត្ថានុរក្ខកថា	ព្រះអាចារ្យ ផេង-សុន្ធរ	៣៣១
—រឿងមាណពអ្នកឈ្លាសក្នុងស្នាមដើង ...	ឃុនសិរីមេធី ស្រី-អ៊ូ	៣៣៩
—បញ្ញាសជាតក ភាគទី ៣ (តមក)	បណ្ឌិតមហា ឈឹម -ស៊ុម	៣៥៥
ផ្នែកអក្សរសាស្ត្រ		
—រឿងសៅរ៍សោយ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង—ប៊ម ...	៣៦២
—រឿងសាមកុក (តមក)	ឧកញ៉ា នូ- ក្រន	៣៦៨
—ដំណឹងតាមឭរល់ក្នុងកន្លារ: (តមក) ...	លោក ផេង-ជ្រឿ	៣៧៧
—រឿងបល្ល័ង្កទិព្យ (តមក)	លោក ភ័ឃ-ប៊ុក	៣៨៣
កំណត់ទីដែលប្រវត្តិការណ៍		
—បុណ្យឆ្លងព្រះវិហារនឹងសាលាបឋមសិក្សា នៅវត្តសិរីបទុម (វត្តអន្លង់ស) ស្រុកកងមាស កំពង់ចាម	លោក ចាប—ពិន	៣៩១

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ២១០រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:		Page
— Editorial	*Vén.* NOU-SOK	323
— Attanurakkhakatha	*Vén.* PHENG-SON	331
— Padakusalajataka	M. SREY-OU	339
— Pannasajataka- vol.3 (suite) .	M. CHHIM-SOUM	355

PARTIE LITTERAIRE:		
— Le «SAU SOY» ou l'influence saturnienne (suite)	*Vén.* PEUNG-PAM	362
— Histoire de samkok (suite) . .	*Oknha* NCU-KAN	368
— Le souffle du désert (suite) . .	M. PHENG-CHRIV	377
— Les trente deux récits du Trône (suite)	M. RAY-BUC	383

NOTES ET CHRONIQUES:		
— Inauguration du temple et de l'Ecole Primaire à Vat Siri-paduma	M. CHAP-PIN	391

Prix d'abonnement annuel (comprenant 12 numéros) 210.00

វិចារណាកថា

សាសនាទុកជាឫាំប្រចាំជីវិត

សាសនាគឺពាក្យប្រៀនប្រដៅ ដែលជាគោលរបស់ចិត្ត អាចគ្រប់គ្រងចិត្តរបស់អ្នករាប់អានកាន់តាមឲ្យជ្រះថ្លា ឲ្យវៀរចាកវត្ថុដែលគួរវៀរ ឲ្យធ្វើវត្ថុដែលគួរធ្វើ ឲ្យសម្រេចការគ្រប់គ្រងខ្លួនដោយខ្លួនឯង ឲ្យដឹងខុសត្រូវអាក្រក់ល្អដោយខ្លួនឯង ។

សាសនាជារបស់ចាំបាច់យ៉ាងវិសេស មានជម្លៃលើសលុប ដែលមនុស្សគ្រប់ហាន: ត្រូវមានត្រូវរាប់អានប្រចាំចិត្តខានពុំបាន ព្រោះសាសនាជាអណ្ណូងទីកើតនៃសីលធម៌ ជាគ្រឿងនាំសេចក្តីសុខមកឲ្យអ្នកកាន់តាម ដូចដំណាក់ទឹកភ្លៀងដែលធ្លាក់ចុះមក នាំយកទាំងសេចក្តីរីករាយមកផង ។ សាសនាជាប្រទីបត្រៃលបំភ្លឺចិត្តមនុស្ស ឲ្យជីវភាពមនុស្សមានដំណើរល្អ ឲ្យយោគយល់ចិត្តថ្លើមមនុស្សផងគ្នា, មិនឲ្យប្រៀតប្រៀនគ្នាដោយផ្លូវត្រង់នឹងផ្លូវអម ។ សាសនាជាគ្រឿងគ្រប់គ្រងមនុស្សបានទាំងផ្លូវកាយ ផ្លូវចិត្ត ទាំងទីកំបាំងទីរាល យ៉ាងជិតស្ទិទ្ធល្អជាងច្បាប់គ្រប់គ្រងមនុស្សដែលបានត្រឹមតែរាងកាយម្យ៉ាង ចំណែកចិត្តគ្រប់គ្រងមិនបាន, ច្បាប់ជាក់ទោសមនុស្សអ្នកប្រព្រឹត្តល្មើសបានតែក្នុងពេលដែលចាប់កំហុសបាន ដោយមានសាក្សី ឬមានឯកសារជាកស្តុតាង; តែបើមនុស្សអ្នកប្រព្រឹត្តល្មើសនោះលបធ្វើក្នុងទីកំបាំង ចាប់មិនបានទេ ព្រោះគ្មានសាក្សីគ្មានឯកសារជាឡាក់ហាន ។ ឯមនុស្សអ្នករាប់អាន

សាសនា មានសាសនាគ្រឿងប្រចាំចិត្ត តែងមានចិត្តអៀនខ្មាសមិនហ៊ានធ្វើអំពើអាក្រក់ សូម្បីក្នុងទីកំបាំងដែលគ្មានអ្នកណាដឹងឃើញឡើយ ។ មនុស្សគ្រប់រូប គ្រប់កេរ គ្រប់វ័យ សុទ្ធតែត្រូវការសេចក្តីសុខស្ងប់ដូចគ្នា គ្មានអ្នកណាបដិសេធថា មិនត្រូវការនោះទេ ។ ឯសេចក្តីសុខស្ងប់គ្រប់យ៉ាងនោះឯង កំដាផលកើតមកអំពីគោលធម៌នៃសាសនា ។

ធម្មតាចិត្តមនុស្ស រមែងអន្ទះអន្ទែងសុះសាយទៅតាន់អារម្មណ៍ផ្សេងៗ ដែលចូលមកប្រលោមឲ្យស្រឡាញ់ខ្លះ មកញុះញង់ឲ្យស្អប់ខ្ពើមខ្លះ មកលួងឲ្យភ្ញាំងភ្ញាត់ញាប់ញ័រខ្លះ មិនឲ្យនៅនឹងនួនបាន បើគ្មានបង្គោលឲ្យចិត្តប្រកាន់យកជាបង្អែក ចិត្តរមែងមិននឹងធឹងនៅបានទេ តែងតែអណ្តែតអណ្តូងទៅរកសេចក្តីក្តៅក្រហាយ ដូចស្មារដែលចូលចិត្តលោតចុះលោតឡើង បើមិនចងខ្សែនឹងបង្គោលបណ្តោយឲ្យទៅតាមចំនើង អាចនឹងធ្វើឲ្យវិនាសច្រើនស្ថាន ។ ចិត្តរបស់មនុស្សរមែងត្រូវរៃបត្តិដោយអំណាចសេចក្តីលោភ, ក្រោធ, វង្វេង, ឥច្ឆា, ឫស្សា ព្រមទាំងឲ្យទោសគឺសេចក្តីវិនាស អាក្រក់ ខ្លាំងជាងសេះដែលខូច ឬជាងដំរីចុះប្រែងទៅទៀត ។ ដោយហេតុនេះមនុស្សយើង តវមានគោលគឺសាសនាជាបង្អែកជាគ្រឿងអប់រំចិត្ត ដើម្បីឲ្យប្រណីតបញ្ចុះលះបង់សេចក្តីរៃបត្តិអាក្រក់នោះចោលចេញ ។ មនុស្សដែលមានសាសនាជាគោលហ្វឹកហាត់ចិត្តរមែងគ្មានសេចក្តីរៃបត្តិ មានតែសេចក្តីត្រជាក់ចិត្ត ឥតកិលេសដុតពោលឲ្យធ្វើសេចក្តីអាក្រក់ ដែលជាហេតុឲ្យក្តៅក្រហាយឲ្យវិនាសដល់ខ្លួនឯងនិងអ្នកដទៃទេ ។ ចំណែកមនុស្សដែលគ្មានសាសនាឈ្មោះថា គ្មានគោល

ឆ្នានបង្អែក ចិត្តមនុស្សដែលឆ្នានបង្អែក រមែងត្រូវវិបត្តិនឹងត្រូវក្រសែ
កិលេសនាំទៅតាមយថាកម្ម ដូចជាទូកដែលឆ្នានបង្គ្រាលចង រមែងត្រូវ
ទ្រៀតនឹងទ្យល់បក់ឲ្យរសាត់ទៅរកទីបំផុតឆ្នាន អាចបណ្តាលឲ្យអន្តរាយ
លិចលង់ក្នុងពេលណាមួយ ឬដូចរថយន្ត ដែលឆ្នានហ្រាំងជាគ្រឿង
ទប់កង់ អាចនឹងជ្រុលទៅបុករថយន្តដូចគ្នា ឬមនុស្ស ឲ្យទូចឲ្យមាន
របួស ឬឲ្យអន្តរាយដល់ជីវិតបាន ។

ម្យ៉ាងទៀត សាសនាទុកដូចជាគ្រឿងអលង្ការដ៏មានតម្លៃ សម្រាប់
តាក់តែងចិត្តរបស់មនុស្សឲ្យល្អ ឬក៏ដូចជាសម្ងៀកបំពាក់ សម្រាប់បិទ
បាំងរាងកាយ ឲ្យសុខសប្បាយ ឲ្យកក់ក្តៅ អាចការពារក្តៅត្រជាក់
បានតាមត្រូវការ, មនុស្សដែលឆ្នានគ្រឿងអលង្ការនឹងសំលៀកបំពាក់
សូម្បីបន្តិចបន្ទួចសម្រាប់បិទបាំងរាងកាយ រមែងជាទីគួរអៀនខ្មាសនឹង
គួរខ្ពើមរបស់អ្នកដែលបានជួបបានឃើញ កាលត្រូវសេចក្តីក្តៅរងាមក
ប៉ះពាល់ ក៏រមែងមានទុក្ខវេទនាទ្ងៃឡើងទៀត, ឆ្នានសុខស្រួលឡើយ,
ចំណែកមនុស្សអ្នកមានសំលៀកបំពាក់ នឹងគ្រឿងអលង្ការតាក់តែងរូប-
កាយ រមែងសមរម្យល្អគួរទស្សនា សូម្បីក្តៅត្រជាក់មកប៉ះពាល់ខ្ងាំង
យ៉ាងណា ក៏គ្រឿងសំលៀកបំពាក់នោះអាចជួយការពារឲ្យបានសុខ
ស្រួល ។ មនុស្សឆ្នានសាសនាជាគ្រឿងប្រដាប់ចិត្ត មិនផ្សងគ្នាពី
មនុស្សដែលអាក្រាតកាយនៅតែខ្លួនទទេនោះឡើយ, ហើយចិត្តមនុស្ស
បែបនោះ រមែងមិនល្អ មិនមានសេចក្តីសុខស្ងប់, កាលបើកិលេសា-
សវៈចូលញ៉ាំញីក៏រិតតែមួម៉ៅក្តៅក្រហាយខ្ងាំងឡើងទៀត ។ មនុស្ស

អ្នកមានសាសនាប្រចាំចិត្ត រមែងមានចិត្តល្អបរិសុទ្ធ មានចិត្តត្រជាក់ត្រជំ
នៅជាសុខ សូម្បីកិលេសចូលមកញ្ចាំញ្ចីខ្ទាំងយ៉ាងណា ក៏សាសនា
អាចជួយការពារមិនឲ្យក្តៅក្រហាយបាន ។

ដោយហេតុនេះ មនុស្សអ្នកយល់ត្រូវតាមគន្ធងធម៌មិនវិបល្ជាស
ចាកហេតុផល ទើបគេនាំគ្នានិយមកាន់សាសនា ដើម្បីទុកជាអលង្ការ
នឹងជាគោលចិត្ត មិនបណ្តោយចិត្តរបស់គេឲ្យអណ្តែតទៅតាមក្រសែនៃ
សេចក្តីអាក្រក់ដែលចូលមកប្រលោមលោមលួងឲ្យភ្ងេចខ្ជួន, ហើយចិត្ត
របស់ជនដែលមានសាសនាជាបង្អែក រមែងចំរើនដោយសេចក្តីល្អ គ្មាន
សេចក្តីថោកទាបទេ ដូចដើមឈើដែលដុះល្អមាំមួនរឹងបុឹងឡើង ក៏ព្រោះ
មានបុសកែវជាកម្ទាំង ។ សាសនាអាចផ្ទើអំណោយសន្តិសុខនឹង
ប្រយោជន៍ដល់មនុស្សត្រប់សញ្ជាតិ ត្រប់វណ្ណ: ឲ្យតែអ្នកណាប្រតិបត្តិ
តាមគោលធម៌ក្នុងសាសនា អ្នកនោះក៏បានសេចក្តីត្រជាក់សុខស្ងួលនឹង
ប្មានទទួលប្រយោជន៍តាមសមគួរដល់ការប្រតិបត្តិទួទៅត្រប់គ្នា. ដូច
អាកាសដ៏បរិសុទ្ធ អ្នកណាបានស្ងូបចូល អ្នកនោះក៏មានសុខភាព
ស្ងួល ។ ហេតុនេះសាសនាទើបមាននៅជាគូនឹងលោក ធ្វើឲ្យលោក
មានសន្តិសុខ, ជាគូនឹងប្រទេសជាតិ ធ្វើឲ្យប្រទេសជាតិបានចំរើនរុងរឿង,
ជាគូនឹងពួកមនុស្ស ធ្វើឲ្យពួកមនុស្សស្រឡាញ់រាប់អានគ្នា យល់ចិត្ត
ថ្ងើមគ្នា, ជាគូនឹងពួកគណ: ធ្វើឲ្យពួកគណ:មានសាមគ្គីគ្នាជានិច្ច,
ដូចជួងព្រះអាទិត្យព្រះចន្ទមាននៅជាគូនឹងអាកាសផែនដី ព្រមទាំងលោក
ទានពុំបាន ។

បើសាសនា មានទៅជាគូទឹងលោកអាចធ្វើអំណាយសន្តិភាពដល់លោកជាអនេកប្បការយ៉ាងនេះ, ចុះហេតុដូចម្តេចក៏មានជនខ្វះយល់ខុសថា សាសនាជាថ្នាំដែលញៀនហើយឲ្យទោសផង? តាមសេចក្តីពិត បើពោលតាមហេតុផល ក៏គង់ឃើញថា សាសនាមិនមែនជាថ្នាំដែលញៀនហើយឲ្យទោសសោះឡើយ, ប្រសិនបើប្រៀបសាសនាទៅនឹងថ្នាំ ក៏ជាថ្នាំដែលគួរសេព មិនមែនជាថ្នាំដែលញៀនហើយឲ្យទោសទេ ។ ដោយមានហេតុផលដូច្នេះ ទើបគួរញែកថ្នាំជា ២ យ៉ាងគឺ ថ្នាំគួរសេព ១ ថ្នាំមិនគួរសេព ១ ។ ថ្នាំគួរសេព គឺថ្នាំដែលចាំបាច់ដល់ជីវិតពិតៗ ខានមិនបាន រៀរចាកមិនកើត, ក្នុងវេលាមានឈឺថ្នាត់ដូចជាគ្រុន, ឈឺក្បាល, ក្តៅខ្លួន, ឬរំណោគ (របេង) យើងត្រូវបរិភោគថ្នាំ ដូចជាអាស្ពីរីន, គីនីន ឬថ្នាំចាក់ជាដើម ដើម្បីបំបាត់រោគទាំងនោះឲ្យជាសះស្បើយទៅ ។ ថ្នាំបែបនេះជាថ្នាំចាំបាច់ពិតប្រាកដដែលយើងត្រូវសេព ។ បុគ្គលណាមានរោគហើយមិនបរិភោគថ្នាំកែរោគ បណ្តោយឲ្យប្រព្រឹត្តទៅតាមយថាកម្ម រោគក៏មិនសះស្បើយ បុគ្គលនោះក៏ត្រូវរងទុក្ខវេទនាយ៉ាងខ្លាំងគ្មានសេចក្តីសុខស្រួលទេ ក្នុងទីបំផុតអាចនឹងដល់នូវសេចក្តីស្លាប់បាន ។ បុគ្គលណាមានរោគហើយបានបរិភោគថ្នាំកែរោគ បុគ្គលនោះ មិនបានឈ្មោះថា បរិភោគថ្នាំដែលញៀនទេ បានឈ្មោះថាជាអ្នកបរិភោគថ្នាំដែលគួរបរិភោគ ហើយបានសេចក្តីសរសើរថាជាអ្នកចេះថែរក្សាខ្លួនផង ។

ចំណែកវត្ថុដែលមិនមែនជាថ្នាំចាំបាច់ដល់ជីវិតមនុស្ស ដូចជា
ប៉ារ កញ្ឆា សុរា ឧទាហរណ៍ជាដើម ទោះបីមិនសេពក៏មិនស្លាប់ក្រហាយ
ថែមទាំងអាចដម្កល់ជីវិតឲ្យរស់នៅបានតាមប្រក្រតី, តែមនុស្សខ្លះផ្តើម
ហាត់សេពសុរា កញ្ឆា ប៉ារ ឬអាកៀន ដែលជារបស់មិនចាំបាច់នោះ
ធ្វើឲ្យញៀនជាប់ តើជាការចាំបាច់ឡើង ម្ល៉ោះហើយអត់មិនបាន ក៏
ត្រូវការសេពរឿយៗទៅ ។ វត្ថុថែមនេះអាចកើតជាទោស ព្រោះធ្វើ
អ្នកសេពឲ្យញៀនជាប់ទាំងឲ្យរសាប់រសល់ត្រលប់ត្រលាយ ក្នុងពេលមិនបាន
សេព តែកាលបានសេពក៏បន្ទោបង់សេចក្តីសៅប់រសល់បានតែមួយខណៈ
រួចកើតសេចក្តីរសាប់រសល់ខ្លាំង ជាហេតុធ្វើឲ្យសេពតទៅខ្លាំងរកទីបំ-
ផុតគ្មាន ហើយជាហេតុឲ្យអ្នកផងតិះដៀលថា មិនសមបើទៅហាត់ខ្លួន
ឲ្យជាប់ចំពាក់ ដោយវត្ថុមិនមែនជារបស់ចាំបាច់នោះឡើយ ។ ចំណែក
ផ្លូវសាសនា ដែលពោលថាជាឧសថគួរសេពនោះ ក៏ព្រោះថាមនុស្ស
ក្នុងលោកនេះ បើមិនសេពថ្នាំគឺសាសនា គ្មានសាសនាប្រចាំចិត្តទេ
ក៏គ្មានហិរិឧត្តប្បៈ គឺគ្មានសេចក្តីអៀនខ្មាសក្នុងចិត្ត ឥតគ្មាន សេចក្តីកោត
ក្រែងចំពោះសេចក្តីអាក្រក់គ្រប់យ៉ាងឡើយ លោកក៏មិនត្រជាក់ត្រជុំ
សុខស្រួល ឥតមិនយល់ចិត្តថ្លើមគ្នាឥតគ្នា មានតែការបៀតបៀនបំផ្ទិច
បំផ្លាញគ្នាទៅវិញទៅមក ដោយគ្មានមេត្តាករុណា ប្រហែលគ្នាឥត
សត្វត្រៃដែលកាចសាហាវ មិនមានសេចក្តីអៀនខ្មាស ហ៊ានធ្វើ
សេចក្តីអាក្រក់ពាំងក្នុងទីកលពាំងក្នុងទីកំបាំង ដោយឥតញញើតដល់
បាបកម្មឡើយ, លោកនឹងមានសភាពដែលគួរឲ្យតក់ស្លុតហួសប្រមាណ

ដូចជាបានពួកេវវសញ្ញា (សាវ៉ែន) ប្រាប់មហន្តរាយតាមផ្ទូវអាកាស ឬដូចជាមនុស្សមានរោគហើយមិនបរិភោគថ្នាំកែរោគ រោគនោះក៏នៅរាំរ៉ែ ក្នុងខ្លួនជានិច្ច, លុះតែបានបរិភោគថ្នាំដែលគួរបរិភោគទៅកាលណា ទើប រោគនោះជាសះស្បើយទៅបាន ។

សាសនាអាចធ្វើមនុស្សឲ្យចេះរក្សាសេចក្តីស្ងប់រៀបរយបានល្អ ឲ្យ ចេះយល់ចិត្តថ្វើមគ្នា ជួយអើពើក្នុងកិច្ចការដល់គ្នានឹងគ្នា ឲ្យចេះយក ចិត្តទុកជាកចំពោះគ្នីគ្នា ឲ្យដឹងគុណូបការៈរបស់អ្នកមានគុណ ហើយ គបស្នងសងគុណលោក តាមកម្ងាំងដែលអាចធ្វើបាន ទោះមានឧកាស ល្មមនឹងប្រព្រឹត្តអំពើអាក្រក់បានក៏មិនធ្វើ ព្រោះមានសាសនាប្រចាំចិត្ត ធ្វើឲ្យចេះអៀនខ្មាសចំពោះអំពើអាក្រក់នោះ ។ ដោយន័យនេះទើប ឃើញថាសាសនាបើប្រៀបធៀបទៅនឹងថ្នាំ គឺជាថ្នាំគួរសេពពិតប្រាកដ ព្រោះកាលណាសេពហើយ តែងធ្វើអ្នកសេពឲ្យមានសេចក្តីសុខយ៉ាង ត្រជាក់ត្រជំ រំលត់ទុក្ខវេទនាត្រប់យ៉ាងឲ្យអស់ទៅបាន ដូចជាថ្នាំកែរោគ ដែរ, តែសាសនាមិនមែនជាថ្នាំញៀនជាប់ដូចជាមនុស្សចំពូកខ្ជះយល់ ខុសនោះទេ ព្រោះវត្ថុដែលញៀនជាប់នោះមិនមែនជារបស់ចាំបាច់ដល់ ជីវិតមនុស្សទ្បើយ តែមនុស្សទេតើដែលទៅហាត់សេពឲ្យជាប់ខ្ជួនឯង រហូតដល់កើតជារបស់ចាំបាច់ទ្បើង, ចំណែកសាសនាជាថ្នាំចាំបាច់ ដល់ជីវិតមនុស្សពិត ។ បើមនុស្សគ្មានសាសនានៅប្រចាំក្នុងចិត្តទេ ក៏បាន ឈ្មោះថា ជាមនុស្សតែពាក់កណ្តាលប៉ុណ្ណោះ ព្រោះចិត្តមិនខ្ពស់ជាង សត្វតិរច្ឆានទ្បើយ ហើយជាមនុស្ស គ្រាន់តែមានកមានក្សាលដូចមនុស្ស

តែមិនដឹងឧបការគុណអ្នកណាឡើយ, ដោយហោចទៅ សូម្បីមាតាបិតាបង្កើតខ្លួន ក៏ថាគ្មានឧបការគុណដែរ ។ ចំណែកសាសនាទូន្មានចិត្តមនុស្សឲ្យដឹងគុណអ្នកមានគុណ ដែលហៅថាកតញ្ញូ ហើយឲ្យតបស្នងសងគុណលោកដែលហៅថាកតវេទី ។ សាសនាមាននាទី ជួយលើកជំកើងមនុស្សកាត ឲ្យមានលក្ខណៈពេញជាមនុស្សមែនទែនឲ្យមានសេចក្តីថ្លៃថ្នូរ ឲ្យមានចិត្តខ្ពស់ជាងសត្វតិរច្ឆាន ។

ហេតុជូច្នេះ មនុស្សក្នុងលោកគ្រប់រូប ទើបគួរសេពសាសនា គឺគួរមានសាសនាប្រចាំនៅក្នុងចិត្ត ។

ព្រះមហា ឌូរ - សុ ១

ត្រូវចងស្ពានមេត្រីនឹងអ្នកមានត្រកូលស្មើគ្នា

មនុស្សពីរនាក់ណា មានទ្រព្យសម្បត្តិប៉ុនគ្នា មានត្រកូលប៉ុនគ្នា មនុស្សពីរនាក់នោះ ត្រូវចងមេត្រីនឹងគ្នា ត្រូវធ្វើវិវាហៈជាមួយគ្នា តែឯមនុស្សម្នាក់ខ្សោយម្នាក់ទៀតខ្លាំង គេមិនត្រូវធ្វើគឺមិនត្រូវចងស្ពានមេត្រីទេ ។

ម្រឹគត្រូវគប់មួយអន្ទើដោយម្រឹគទាំងឡាយ គោដោយគោទាំងឡាយ សេះដោយសេះទាំងឡាយ មនុស្សល្ងង់ដោយមនុស្សល្ងង់ទាំងឡាយ អ្នកប្រាជ្ញដោយអ្នកប្រាជ្ញទាំងឡាយ, ការចងគ្នាជាសំឡាញ់បានចំពោះតែមនុស្សណា បើស្អប្អជូចគ្នា ឬបើអាក្រក់ អាក្រក់ជូចគ្នាទេ ។

ផ្នែកសាសនា

អត្ថានុរក្ខកាថា

ព្រះអាចារ្យ ផេង-សុផ្ឌ៍ វត្ថកែវព្រះភ្លើង ភ្នំពេញ

រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម្មិ និងព្រះអរិយសង្ឃ ដោយគោរព) ។

រៀលានេះ អាត្មាភាពសូមសំដែងអំពីសុភាសិត ១ កន្ធែង ដែលព្រះបរមលោកនាថទ្រង់សំដែងមានក្នុងគម្ពីរធម្មបទដ្ឋកថា ជាធម្មស្សវនាការដល់ពុទ្ធបរិស័ទ្យទាំងឡាយ ដូចតទៅនេះ

មុននឹងលើកយកពុទ្ធភាសិតនោះមកសំដែង សូមនាំយកបុគ្គលាធិដ្ឋានមកសំដែងជាទាងដើមសិន ដើម្បីនឹងអធិប្បាយជំរាលទៅរកពុទ្ធភាសិត ដែលប្រុងនឹងយកមកសំដែងក្នុងឧកាសនេះ ។

សេចក្តីដំណាលថា កាលព្រះបរមសាស្តាទ្រង់គង់នៅក្នុងវត្តដេតពន, កាលនោះ មានភិក្ខុទាំងឡាយជាច្រើនរូប បានទៅនៅចាំវស្សាក្នុងបច្ចន្តប្បទេស ភិក្ខុទាំងនោះបាននៅជាសុខស្ប្រួល ក្នុងខែជាដំបូង, តែលុះដល់ខែជាបន្ទាប់មក មានពួកចោរចូលមកប្លន់ស្រុកសម្រាប់គោចររបស់ភិក្ខុទាំងនោះ ហើយចាប់យកអ្នកស្រុកធ្វើជាឈ្លើយដោយច្រើន លំជាប់តមក ពួកអ្នកនគរទាំងឡាយក៏រវល់តែនឹងប្រុងប្រៀបរៀបចំការពារនគរ

មិនបានឧបត្ថម្ភជល់ភិក្ខុតាំងឡាយ ៗ ក៏នៅដោយលំបាក, លុះចេញវស្សាហើយ ក៏នាំគ្នាចូលទៅបង្គំគាល់ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ស្ងរសុខទុក្ខនៃភិក្ខុតាំងឡាយនោះ តាមទម្លាប់នៃបដិសណ្ឋារៈបស់ព្រះអង្គ ៗ ភិក្ខុតាំងឡាយ ក៏ក្រាបទូលតាមហេតុនោះដោយសព្វគ្រប់, លុះទ្រង់ព្រះសណ្ឋាប់ហើយ ទ្រង់ត្រាស់អនុលោមតាមពាក្យភិក្ខុតាំងឡាយថា "ម្នាលភិក្ខុតាំងឡាយ! ការនៅជាសុខស្ងួលអស់កាលជានិច្ច គេរកបានដោយកម្រណាស់, ហេតុនេះពួកមនុស្សដែលប្រុងប្រយ័ត្នបាត់ពិធីថ្វៃក្សាការពារនគរយ៉ាងណាមិញ អ្នកតាំងឡាយក៏ត្រូវប្រុងប្រៀបរៀបចំថ្វៃក្សាខ្លួនយ៉ាងនោះដែរ" រួចទ្រង់សំដែងពុទ្ធភាសិតនេះថា

នគរំ យថា បច្ចន្តំ ភុត្តំ សន្ធរពាហិរំ
ឯរំ គោបេថ អត្តានំ ខណោ មា ឧ ឧបច្ចគា
ខណាតីតា ហិ សោបន្តិ និរយម្ហិ សមប្បិតា

"(ម្នាលភិក្ខុតាំងឡាយ) ពួកមហាជនគេប្រុងរក្សាការពារនគរដែលតាំងនៅក្នុងទីបំជុនៃដែនតាំងខាងក្នុងតាំងខាងក្រៅ យ៉ាងណាមិញ; អ្នកតាំងឡាយ ក៏ត្រូវប្រុងថ្វៃក្សាខ្លួន យ៉ាងនោះដែរ, ខណៈកុំកន្ធងនូវអ្នកតាំងឡាយឡើយ ព្រោះថា សត្វតាំងឡាយ ដែលបណ្ឋាយឲ្យ ខណៈកន្ធងហួសទៅហើយ រមែងសោយសោកពេញណែនក្នុងនរក" ៗ

ព្រះពុទ្ធភាសិតខាងលើនេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះតែនឹងពួកភិក្ខុក៏ពិតមែនហើយ តែតាមព្រះពុទ្ធបំណងមិនមែនជូច្នោះទេ គឺព្រះពុទ្ធ-

ការសិតនេះជាសាជារណ:ទ្ធទៅដល់បរិស័ទ្យទាំងឡាយ ឥតរើសមុខ ។ ឯសេចក្តីសំខាន់ក្នុងដ្ឋៃនៃគាថានេះ ចែកជា ៣ ផ្នែក គឺ:

១_ ត្រូវថែរក្សាខ្លួន ឲ្យដូចជាពួកមហាជនប្រុងប្រយ័ត្នរក្សាការពារនគរ ។

២_ ខណ: កុំប្រព្រឹត្តកន្លងនូវអ្នកទាំងឡាយ ។

៣_ បើសត្វទាំងឡាយ បណ្ឌោយឲ្យខណ:កន្លងហ្លសទៅ រមែងសោយសោកពេញណែនក្នុងនគរ ។

ទី ១- ត្រង់ថា "ត្រូវថែរក្សាខ្លួន ឲ្យដូចជាពួកមហាជនប្រុងប្រយ័ត្នរក្សាការពារនគរ" នោះ បានសេចក្តីថា ត្រូវដំកល់សតិ (រពុក) នឹងពិនិត្យការពារចំពោះទ្វារទាំង ៦ គឺ: ចក្ខុទ្វារ ១, សោតទ្វារ ១, ឃានទ្វារ ១, ជិវ្ហាទ្វារ ១, កាយទ្វារ ១, មនោទ្វារ ១. ព្រោះសពាង្គកាយរបស់សព្វសត្វទាំងឡាយ ប្រៀបដូចនគរមានទ្វារ ៦ គឺ មានចក្ខុទ្វារជាដើមនោះឯង, មានព្រះមហាក្សត្រមួយព្រះអង្គសោយរាជ្យក្នុងនគរនោះ ពោលគឺព្រះបាទចិត្តរាជ, ឯអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ប្រៀបដូចជាអាគន្ពុក: (អ្នកដំណើរ) តែងសញ្ជរចូលមកក្នុងនគរគឺរាងកាយ តាមទ្វារទាំងឡាយមានចក្ខុទ្វារជាដើម, សតិប្រៀបដូចជាទ្វារបាល (អ្នកយាមទ្វារ) សម្រាប់ត្រួតពិនិត្យនូវរូបារម្មណ៍ជាដើម ដែលតែងត្រាប់ចូលមកតាមចក្ខុទ្វារជាដើមនោះឲ្យដឹងថាល្អ ឬ អាក្រក់, បើដឹងថាអាក្រក់ ក៏បដិសេធចេញ ឬ រាវាំងមិនឲ្យចូលក្នុងព្រះនគរនោះ, បើដឹង

ថាល្អ កំបណ្តោយឲ្យចូល ឬ កំនាំពតិមាននេះមកថ្វាយព្រះបាទចិត្តភជ
ឲ្យទ្រង់ជ្រាបជាមុន, បើទ្រង់អនុញ្ញាតឲ្យចូល កំចូល បើមិនទ្រង់អនុញ្ញាត
ទេ កំអាក់ខាន; ព្រោះអារម្មណ៍ទាំងនោះ តែងធ្វើឲ្យព្រះបាទចិត្តភជ
បានសុខកំមាន ទុក្ខកំមាន, ចំរើនកំមាន វិនាសកំមាន, ដោយអំណាច
នៃបុព្វារម្មណ៍លោកចែកជា ២ យ៉ាង គឺ: រូបនាំមកនូវសុខ ១, រូបនាំមក
នូវទុក្ខ ១, សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍, ផោដ្ឋព្វារម្មណ៍,
ធម្មារម្មណ៍ កំសុទ្ធតែចែក ២ យ៉ាងដូចគ្នាដែរ ។ ហេតុដូច្នេះ បើ
បុគ្គលបានប្រទះនូវអារម្មណ៍ទាំងឡាយ មានបុព្វារម្មណ៍ជាដើមណាមួយ
ដែលជាសុខ ចំរើននោះ គប្បីដំកល់សតិការពារ-ចប់សោមនស្ស ឬ
បដិឃចិត្ត ដែលជាហេតុនាំឲ្យកើតតណ្ហាចំពោះអារម្មណ៍នោះ, បើបាន
ប្រទះនូវអារម្មណ៍ដែលជាទុក្ខ ទោស ឬ នាំឲ្យវិនាស គប្បីដំកល់សតិ
ញុំាងមេត្តាចិត្តឲ្យកើតឡើង, កុំគប្បីមានបដិឃៈ ឬ ព្យាបាទចិត្តចំពោះ
អារម្មណ៍នោះឡើយ ។

បុគ្គលណាមួយ បានដំកល់សតិសង្កឹមចក្ខុទ្វារជាដើម ការពារ
នូវអារម្មណ៍ទាំងពីរប្រការ ដូចន័យដែលអធិប្បាយមកនេះហើយ សន្តក
ថាជាអ្នកបានរក្សាការពារខ្លួនដោយប្រពៃ, អាចនឹងបាននូវសុខភាព
នឹងវឌ្ឍនភាពក្នុងលោកនេះ នឹងលោកខាងមុខ ពុំលែងឡើយ ។

ពី ២ ត្រង់ថា "ខណៈកុំប្រព្រឹត្តកន្លងនូវអ្នកចាំងឡាយ" នេះជា
ពាក្យ គឺ ព្រះសម្ពុទ្ធទ្រង់ត្រាស់ជាសំពុតពុទ្ធបរិស័ទ្យចាំងឡាយ កុំឲ្យ
ស្ថិតនៅក្នុងបមាទធម៌ ព្រោះបមាទធម៌នេះ ចូលជ្រកជោកជាំក្នុង

សន្ដានៃបុគ្គលណាហើយ បុគ្គលនោះនឹងកាន់មិនបានគុណសម្បត្តិ សមត្ថភាព ឬ កំបណ្ដាយឲ្យខណៈនោះកន្លងហួសទៅពុំបាន ។ ឯខណៈនោះលោកចែកចេញជា ៤ យ៉ាង គឺ :

១- ពុទ្ធុប្បាទក្ខណោ ខណៈដែលព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោកម្ដង ។ ចាត់ជាខណៈ ដែលសត្វសត្វទាំងឡាយ ត្រូវបានទូរមហគ្គតគុណដ៏អស្ចារ្យ មានសោតាបន្នភាពជាដើម តាមឧបនិស្ស័យរៀង ។ ឮថា ពុំនោះសោតនឹងបានទូរទិដ្ឋធម្មិកផល ដូចយ៉ាងបុគ្គលបុរសជាដើម, ព្រោះព្រះសត្វញ្ញូពុទ្ធទ្រង់ជាឧយ្យានិកបុគ្គល តែងហ៊ឹកហ៊ឺនយឺតយោងពុទ្ធវៃនេយ្យសត្វ ដែលមានឧបនិស្ស័យល្មមព្រះអង្គទ្រោសបាន ឲ្យយល់ច្បាស់ក្នុងឧបាយនៃការសន្សំប្រយោជន៍ក្នុងលោកនេះនឹងបរលោក ដកបដល់សត្វអាចញ៉ាំងកិលេសនឹងតណ្ហាឲ្យរីងស្ងួតហើយរំលត់ខាន់ចូលទៅកាន់អមតនិព្វានជាបរិយោសាន ។

២- មជ្ឈិមប្បទេសេ ឧប្បត្តិក្ខណោ ខណៈដែលសត្វបានកើតក្នុងមជ្ឈិមប្រទេស ជាខណៈដ៏អស្ចារ្យ គួរសត្វថ្នាក់ថ្នមទៅកើត ព្រោះប្រទេសនោះជាទីកើតនៃរតនៈ ៧ ប្រការ មានព្រះចក្រពត្តិរាជជាដើម, ឧត្តមព្រះពុទ្ធមាតាពុទ្ធបិតាជាដើម ។ កាលបើព្រះពុទ្ធបានត្រាស់ហើយ ពួកមហាជនទាំងឡាយក្នុងមជ្ឈិមប្បទេសនោះ ច្រើនតែជាអ្នកស្ថិតនៅក្នុងអរិយធម៌ដ៏ប្រសើរមានទិដ្ឋិសីលជាដើមដោយបរិបូណ៌ ជាសត្វមានឧបនិស្ស័យ ល្មមឈោងចាប់យកទូរឧត្តមភាព ឧត្តមភាពបាន ។

៣_ សម្មាទិដ្ឋិយា បដិលទ្ធក្ខណោ ខណៈដែលសត្វ
បានបំពោះនូវសម្មាទិដ្ឋិ គឺវារៈនៃបញ្ញាចេតសិកយល់ត្រូវថា ទុក្ខតាំង
១២ កង់ជាទុក្ខមែន, តណ្ហាជាហេតុនាំឲ្យកើតទុក្ខ, ការបន្សាត់បង់នូវ
តណ្ហាបាន ជាឧបាយនាំឲ្យរលត់ទុក្ខ, ការប្រតិបត្តិតាមអដ្ឋង្គិកមគ្គតាំង
៨ ប្រការ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ពុំនោះសោត យល់បំពោះ
ហេតុនឹងផលក្នុងកាលតាំង ៣ គឺ: បច្ចុប្បន្ន, អតីត· អនាគត, តាំងអាច
ប្រកបកិច្ចសព្វយ៉ាង ដើម្បីញ្ញុំងភាពនៃខ្លួនឲ្យឡើងកាន់វឌ្ឍនធម៌បាន ។

៤_ ធន្នមាយតនាតំ អជកល្លក្ខណោ ខណៈដែលសត្វ
មានអាយតនៈ មិនខ្វះខាត គឺមាន ត្រចៀក, ត្រចៀក, ច្រមុះ, អណ្តាត,
កាយ, ចិត្ត, ពេញបរិបូណិជាបុរិសភាព ឥត្ថីភាព, ចាត់ថាជាខណៈ
របស់សត្វមានភ័ព្វដ៏ប្រសើរ, ព្រោះថាសត្វតាំងឡាយ បើមានអាយតនៈ
ណាមួយខ្វះខាតហើយ មិនអាចប្រកបកិច្ចសព្វយ៉ាងឲ្យកើតឡើងដោយ
ពេញបរិបូណិបានឡើយ ។ ហេតុនេះ សត្វដែលមានអាយតនៈពេញ
បរិបូណិ ចាត់ថាជាសត្វមានភ័ព្វដ៏ប្រសើរនោះ មិនគួរផ្ទេសបណ្តោយឲ្យ
ខកខានសិក្សាបំណេះវិជ្ជាមានអក្សរសាស្ត្រ, អារ្យសាស្ត្រជាដើម នឹង
មិនគួរខកខានបំពេញកុសលផ្សង ៗ ដែលជានាថការណីយកិច្ច ក្នុង
បច្ចុប្បន្នសម័យនឹងកាលជាអនាគតឡើយ ។

ទី ៣ ត្រង់ថា "បើសត្វតាំងឡាយ បណ្តោយឲ្យខណៈកន្ទងហួស
ហើយរមែងសោយសោកពេញណែនក្នុងនរក" នោះ សព្ទថា "នរក"

ប្រែថា "ទីនាំបេញនូវសេចក្តីសុខ" គឺថាសោយសុទ្ធតែទុក្ខ, ឬប្រែថា "រណ្តៅ" បើចែកតាមឈ្មោះមាន ៨ គឺ: សញ្ជីវ: ១, កាលសុត: ១, សង្ឃាដ: ១, រោរវ: ១, មហារោរវ: ១, តាប: ១, មហាតាប: ១, អវីចិ ១, ។ តែក្នុងទកាសនេះ សូមអធិប្បាយតាមទេវទូតសូត្រ ដែលព្រះ បរមត្រូទ្រង់សំដែងអំពីអវីចិនរក នឹងនរកជាបន្ទាប់ ។ ។ អវិចិ សព្ទ នេះប្រែថា "ឆ្នានចន្ទោះ" សំដៅឆ្នានចន្ទោះពីរយ៉ាងគឺ ឆ្នានចន្ទោះ សត្ត គឺថាក្នុងអវីចិនរកទាំងមូលពេញណែន ដោយសត្វនរកឥតមាន ទីចន្ទោះ ១ ឆ្នានចន្ទោះក្រៃង គឺថាក្នុងនរកនោះមានអណ្តាតក្រៃងធាប ធេះជានិច្ចឥតទីចន្ទោះ ១, អវីចិនរក មានសណ្ឋានជូចជាហឹប, មាន ទ្វារ ៤ តាមលំជាប់ទិស, កំពស់ជញ្ជាំងឡើង ៩ យោជន៍, ទំហំជុំវិញ ទាំងអស់ ១០០ យោជន៍, សត្វដែលកើតក្នុងនរកនោះ សោយទុក្ខ ដោយអណ្តាតក្រៃងដ៏សន្ធោសន្ធៅធាបធេះជានិច្ចឥតមានពេលស្រាក ។ បន្ទាប់អំពីអវីចិនរកទៅ មានគូថនរក មួយរណ្តៅទ្រៅត ក្នុងនរកនោះ ពេញណែនដោយលាមកទាំងអស់ សត្វដែលកើតក្នុងនរកនោះមាន លាមកជាអាហារ: មានដង្ក្រូវប៉ុន ៗ អណ្តើក តែងឡៅ ឬ ជញ្ជក់យករស ជាតិក្នុងខ្លួនសត្វនរកនោះ សត្វក្នុងនរកនោះដែលកើតស្ទាប់ ៗ ដោយ អំណាចដង្ក្រូវឡៅ ឬជញ្ជក់នោះឯង ។ បន្ទាប់អំពីគូថនរកនោះទៅ មាន កុក្កឡនរក មួយរណ្តៅទ្រៅត ក្នុងនរកនោះពេញណែនដោយផែះក្តៅ ទាំងអស់ សត្វតែងសោយទុក្ខដោយអំណាចផែះក្តៅនោះ ។ បន្ទាប់ អំពីកុក្កឡនរកនោះទៅ មានសិម្ពលីនរក (រការដែក) ដើមរការដែក

នោះមានបន្ទាស្រួចៗ ប្រវែង ១៦ អង្គុលី មានក្លីងធេះប្រាលផ្អៅឥត
ចន្ទោះ, ពួកនិរយបាលតែងវាយបង្ខំសត្វណាដែលមានទោសឲ្យឡើង
ដើមរការដែកនេះ ដោយឥតត្រាប្រណី ។ បន្ទាប់អំពីសិម្ពលីនរកនោះ
ទៅ មានត្រៃសសិត មួយទៀត សត្វសោយទុក្ខក្នុងនរកនោះដោយ
អំណាចខ្យល់បក់ស្ទឹកសសិតមកប៉ះលះដាច់សាច់អង្កន់ៗ ជួចគេអង្កន់ត្រី ។
បន្ទាប់អំពីត្រៃសសិតនោះទៅមានស្ទឹងទឹកក្រុត ១ ទៀត សត្វក្នុងនរកនោះ
ខ្ទះក៏អត់អាហារ ១ ពុទ្ធន្តរ ឬ ២ ពុទ្ធន្តរមកហើយ មានកាលម្តងៗ ពួក
និរយបាលយកសន្ទូចមក់ស្ទូច សត្វនរកក៏ស្ទុះទៅត្រចាក់ដោយស្នាន
ថាជាចំណី, និរយបាលវាត់សន្ទូចឡើងយកមកលើគោកហើយស្សរថា:
"ឯងឃ្ទានអ្វី?" ។ — "ខ្ញុំឃ្ទានអាហារណាស់!"; ។ និរយបាលក៏យកដុំ
ដែកដែលក្លីងកំពុងធេះប្រាលផ្អៅ បញ្ចុកក្នុងមាត់សត្វនរកនោះ, ហើយ
ក៏ស្សរទៀតថា "ឯងត្រូវការអ្វីទៀត?" ។ — "ឲ! លោកអើយ ខ្ញុំស្រេក
ទឹកណាស់!" ។ និរយបាលក៏ដងទឹកទង់ដែងដែលកំពុងពុះ មកច្រិកក្នុង
មាត់សត្វនរកនោះ ម្ទៅះហើយក៏សោយទុក្ខវេទនារកពណិនាពុំបាន ។

បើបុគ្គលបានដឹងច្បាស់តាមន័យដែលបានអធិប្បាយមកនេះ ហើយ
ត្សរប្រុងប្រយ័ត្នចាត់ពិធីថែរក្សាការពារខ្លួន កុំឲ្យខណៈកន្ទងហួសទៅ
ដោយមិនបានប្រកបកិច្ចមានការបំពេញកុសលជាដើម ដរាបដល់ធ្លាក់ខ្លួន
ទៅកាន់ហ៊ីនភាព ក្នុងលោកនេះ នឹងបរលោកដោយបមាទធមិឡើយ ។

អាត្មាភាពសំដែងធមិនេះល្មមដល់វេលានឹងបញ្ចប់ហើយ, សូម
សង្ខេបកថា ដោយនូវប្រការអម្បាលណោះ ឯង ។

ឧឬងមាណាពអ្នកឈ្វាសក្នុងស្នាមដើង

បទកុសលជាតក ក្នុងជាតកដ្ឋកថា ឧរកនិបាត

យុនសិរីមេធី ស្រី-អ្ងូ ប្រែ

កាលព្រះបរមគ្រូទ្រង់គង់ក្នុងវត្តៈជតពន ជិតក្រុងសាវត្ថី ទ្រង់សំដែងប្រាឌ្ឌកុមារម្នាក់ដែលជាកូនកុដុម្ពីក៍ នៅក្នុងក្រុងសាវត្ថីថា:

កុមារនោះមានអាយុ ៧ ឆ្នាំគត់ អាចស្គាល់ស្នាមដើងពិតប្រាកដមិនដែលមានកំន្ត្រចឡំសោះ ។ ពេលមួយបិតាចង់ល្បងមើលជំរិះកូនក៏លបដើរទៅលេងផ្ទះញាតិ មិនឲ្យកុមារនោះដឹងខ្លួនឡើយ ។ លុះយូរបន្តិច កុមារនោះរកមើលបិតាមិនឃើញ ក៏ឈ្វាកមើលស្នាមដើងហើយតាមរកបិតាទៅទាន់ឯផ្ទះញាតិ ។ បិតាសួរ: នែកូន ហេតុដូចម្តេច ក៏អ្នកដើររកយើងឃើញ ។ កូនឆ្វើយ: ខ្ញុំស្គាល់ស្នាមដើង ។ សម៍យថ្ងៃមួយ បិតាចេញដើរបំបាត់ដើងយ"ងឆ្ងាយ គឺដើរចូលទៅក្នុងផ្ទះអ្នកស្មិទ្ធស្នាលហែ។ទៅ ហើយគេចចេញទៅទាងដើងព្រះនគរបត់ចូលមកអង្គុយស្តាប់ធមិព្រះសាស្តាក្នុងវត្តជេតពន ។ គ្រានោះកុមារសួររកបិតា, អ្នកផងប្រាប់ថា យើងមិនដឹងទេ កុមារដាករកមើលស្នាមដើងហើយដើរតាមហែ។ទៅទាន់បិតា កំពុងអង្គុយស្តាប់ធមិ ។ បិតាសួរហេតុអ្វីក៏អ្នកដឹងថាយើងមកក្នុងទីនេះ ។ កុមារឆ្វើយ: ខ្ញុំស្គាល់ស្នាមដើង ។ បិតាស្ងើចនឹងកូន ហើយសរសើរថា កូននេះតូចប៉ុណ្ណោះទេ ក៏ចេះអ្វីម្ទេ"ះ ។

ពេលនោះ ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្បែរនោះ បានជ្រាបសព្វ
ដំណើរ ហើយទ្រង់មានព្រះពុទ្ធដីកាថា ម្នាលឧបាសក ការស្គាល់
ស្នាមដើងនៅលើផែនដីនេះ មិនទាន់ជាអស្ចារ្យប៉ុន្មានទេ កាលបុរាណ-
បណ្ឌិតជាន់ដើម គេអាចស្គាល់ស្នាមដើងព្វដ៏អាកាសបាន ហើយទ្រង់នាំ
អតីតនិទានថា ។

ក្នុងកាលកន្ទងទៅហើយ អគ្គមហេសីរបស់ព្រះបាទព្រហ្មទត្ត ក្នុងក្រុង
ពារាណសី ប្រព្រឹត្តកន្ទងព្រះទ័យព្រះរាជស្វាមី ទៅខ្ជិចនឹងបុរសម្នាក់ ។
ព្រះរាជាមានព្រះទ័យរន្ធ្ត៍សទ្រង់ចាប់ពិរុទ្ធស្ងរបញ្ជាក់ ។ អគ្គមហេសី
នោះស្បថថ្វាយព្រះរាជាថា "បើខ្ញុំម្ចាស់ប្រព្រឹត្តកន្ទងព្រះទ័យព្រះអង្គមែន
ដល់ខ្ញុំម្ចាស់ស្ទាប់ទៅ សូមឲ្យទៅកើតជាយក្ខិនី មានមុខជាសេះចុះ" ។
លុះអគ្គមហេសីនោះធ្វើមរណកាល ក៏ទៅកើតជាយក្ខិនី មានមុខជាសេះ
មែន, តែងនៅអាស្រ័យក្នុងគុហាមួយ ចាំចាប់ពួកមនុស្សដែលដើរ
ដោយជងព្រៃមកបរិភោគ ។

មានសេចក្តីដំណាលថា យក្ខិនីនោះបានអំណាចពីស្តេចវេស្សវ័ណ
កំណត់ទីទទឹងចម្ងាយ ៣០ យោជន៍ បណ្តោយ ៥០ យោជន៍ ។ ថ្ងៃមួយ
មានព្រាហ្មណ៍មានទ្រព្យសម្បត្តិច្រើន នាំពួកបរិវារដើរទៅត្រង់ទីនោះ ។
យក្ខិនីក្រទ្យកឃើញ ក៏ស្ទុះដេញចាប់ព្រាហ្មណ៍នោះបាន, ឯពួកបរិវារ
នាំគ្នារត់រួចអស់ ។

យក្ខិនីក៏ព្រនាក់ព្រាហ្មណ៍នោះលើខ្នង យកទៅទីកន្ទែងរបស់ខ្លួន ។
ដោយអំណាចកិលេសបណ្តាលទ្បើង ក៏ស្រឡាញ់ព្រាហ្មណ៍នោះត្រឡប់

ជាមិនបរិភោគ ហៃជាយកធ្វើជាប្តីរួមសង្វាសជាមួយគ្នាវិញ ។ តាំងពីពេលនោះមក យក្ខិនីចាប់បានមនុស្សឯទៀត យកទាំងសំពត់នឹងអង្ករជាដើម មកចិញ្ចឹមប្តី ។ នាងយក្ខិនីពេលដែលចេញទៅរកអាហារ តែងក៏យខ្ចាចប្តីរត់ចោល ក៏យកថ្មមកខ្ទប់គុហាទើបចេញទៅ ។ កាលព្រាហ្មណ៍នឹងយក្ខិនីនៅរួមសង្វាសជាមួយគ្នា ព្រះពោធិសត្វក៏ចុះមកចាប់បដិសន្ធិក្នុងផ្ទៃយក្ខិនីនោះ លុះគ្រប់ ១០ ខែប្រសូតចេញមក ។ យក្ខិនីស្រឡាញ់កូននោះខ្ចាំងណាស់ ឲ្យកូននៅតែក្នុងគុហា មិនឲ្យដើរទៅទីណាឡើយ ។ លុះកូននោះធំដឹងក្តីសព្វគ្រប់ ស្ទូរបិតាថា បពិត្របិតា ហេតុដូចម្តេចបានជា មុខអ្នកម្តាយដោយឡែក មុខលោកឪពុកដោយឡែក មិនប្រហែលគ្នាសោះ ។ បិតាប្រាប់ថា នែកូន ម្តាយបាឯងជាយក្ខិនី តែងស៊ីសាច់មនុស្ស បាឯងនឹងយើងជាមនុស្ស ។ កូននិយាយថា បើដូច្នោះយើងនឹងនៅក្នុងទីនេះធ្វើអ្វី! សូមអញ្ជើញទៅឯស្រុកមនុស្សវិញ ។ បិតានិយាយថា កូន! បើយើងរត់ទៅ មុខជាម្តាយបាឯងសម្ងាប់យើងទាំងពីរនាក់មិនខានទេ ។ កូនធ្វើយថា បពិត្របិតា សូមបិតាកុំខ្ចាច ខ្ញុំជានានាំបិតាទៅឲ្យដល់ស្រុកមនុស្ស ។

សម៉ាយមួយ កូននោះដឹងថា យក្ខិនីចេញទៅរកអាហារហើយក៏ប្រាងថ្មបើកទ្វារនាំបិតាចេញមកលេងខាងក្រៅ ដល់យក្ខិនីត្រឡប់មកវិញឃើញទ្វាររបើកទើបស្ទូរថា នរណាបើកទ្វារ ។ កូនធ្វើយតបថា អ្នកម្តាយ! ខ្ញុំមិនដឹងអង្គុយក្នុងទីងងឹតទេ បានជាខ្ញុំបើកទ្វារចេញមក ។ យក្ខិនីមិនមានស្តីបន្ទោសអ្វីឡើយ ដោយអំណាចស្រឡាញ់កូន ។ លុះ

យូរបន្តិចមក កូននោះក៏នាំបិតារត់ចេញមកស្រុកមនុស្ស ។ យក្ខិនីវិលមក
វិញមិនឃើញកូននឹងប្តី ក៏ស្ទុះទៅតាមទាន់និយាយថា បពិត្រអ្នកជា
ប្តី ថ្ងៃក៏អ្នករត់ចោលខ្ញុំ អ្នកចង់បានអ្វី? ។ ព្រាហ្មណ៍ឆ្លើយថា ម្នាល
ប្អូនស្រី នាងកុំខឹងនឹងបង កូននាងនាំបងរត់មកទេតើ ។ យក្ខិនីក៏មិន
ប្រកាន់ទោសអ្វីឡើយ រួចនាំមកកន្ទេងរបស់ខ្លួនវិញ ។ ព្រាហ្មណ៍
នឹងកូននាំគ្នារត់យ៉ាងនេះអស់ ៣ លើក ។ យក្ខិនីចេះតែតាមទាន់យកមក
វិញ ។ ពេលមួយ កូននោះគិតរកឧបាយនឹងរត់ឲ្យរួច ទើបទៅអង្គុយឧប
ម្ពាយហើយសួរថា បពិត្រអ្នកម្ពាយ សូមអ្នកម្ពាយប្រាប់ទីព្រំប្រទល់ត្រឹម
ណា ដែលអ្នកម្ពាយផ្សាយអំណាចទៅបាន ទីត្រឹមនោះហើយដែលជា
ក្រៀមតិកត្រូវបានកូន សូមប្រាប់ខ្ញុំឲ្យដឹងផង ។ យក្ខិនីប្រាប់ទីព្រំ
ប្រទល់មានគ្នំនឹងស្ទឹងជាដើមត្រប់ទិសថា ទទឹងចម្ងាយ ៣០ យោជន៍
បណ្តោយ ៥០ យោជន៍ កូនឯងចូរចំណាំទីប៉ុណ្ណេះទុកចុះ ។ លុះកន្ទង
មកពីរបីថ្ងៃ យក្ខិនីចេញទៅស្វែងរកអាហារ កូនក៏បញ្ជិះបិតាលើកខ្លួន
រត់ចេញទៅដល់ឆ្នេរស្ទឹងប្រទល់ដែន ។ ឯយក្ខិនីត្រឲ្យប់មកវិញមិន
ឃើញប្តីនឹងកូន ស្ទុះរត់ដេញតាមឃើញកូនកំពុងចាប់ដឹកដៃបិតាចុះទៅ
ក្នុងស្ទឹង ។ យក្ខិនីដឹងថា ផុតដែនរបស់ខ្លួនហើយ ក៏ឈរនិយាយអង្វរ
ប្តីនឹងកូនថា នែកូនប្រុស អ្នកចូរនាំបិតាមកវិញ បពិត្រប្តី ខ្ញុំប្រតិបត្តិ
ខុសឆ្គងដូចម្តេច សូមអ្នកអត់ទោស សូមអញ្ជើញមកវិញ ។ លំដាប់
នោះ ព្រាហ្មណ៍ចេះតែដើរទៅខាងនាយ មិនត្រឲ្យប់មកវិញសោះ ។
យក្ខិនីនិយាយទៅរកកូនថា ម្នាលកូនស្ទួន អ្នកកុំធ្វើយ៉ាងហ្នឹង ចូរកូនអ្នក

វិលមកវិញ ។ កូនប្រកែកថា ឱ្យជាមនុស្ស អ្នកម្តាយជាយក្ខិនីស៊ីតែសាច់មនុស្ស ឱ្យមិនហ៊ាននៅជាមួយទេ ។ យក្ខិនីអស់សេចក្តីសង្ស្យមហើយ តែនឹកអាណិតកូនឱ្យាំងណាស់ ទើបនិយាយប្រាប់កូនថា កូនអើយ ! ការចិញ្ចឹមជីវិតក្នុងមនុស្សលោកនេះលំបាកណាស់ ក្រណាស់ បើមិនចេះសិល្បវិជ្ជាអ្វីហើយ មិនងាយនឹងចិញ្ចឹមជីវិតបានស្រួលទេ ម្តាយចេះវិជ្ជាមួយឈ្មោះចិន្តាមណី (១) វិជ្ជានេះមានអានុភាព អាចស្គាល់ស្នាមជើងចោរ ដែលលួចទ្រព្យតេចំនួន ១២ ធ្នាំហើយ គង់តាមរកឃើញ ចាប់បានទាំងចោរមកផង ហេតុនេះ កូនឯងចូររៀនមន្តនេះចុះ ត្រាន់នឹងចិញ្ចឹមជីវិត ។ កូនក៏ឈរសំពះម្តាយក្នុងស្ងឹងប្រឹងរៀនមន្តនោះដរាបទល់ចប់ ទើបនិយាយថា សូមអ្នកម្តាយអញ្ជើញទៅវិញចុះ ។ យក្ខិនីធ្វើយតបដោយពាក្យជាគាថា ថា:

ឯហិ បុត្ត និវត្តស្សុ មា អនាថំ កណាហិ មេ
អជ្ជ បុត្តំ អបស្សន្តី យក្ខិនី មរណំ គតា ។

ហៃកូនប្រុសពន្ធក ចូរវិលមកធាប់ ៗ ក៉
អ្នកកុំឲ្យមាតា អនាថាណាមាសថ្ងៃ
កាលបើមិនឃើញបា ឲ្ងនមាតានឹងក្សីណក្ស៉យ
ស្ងាប់ក្នុងវេលាថ្ងៃ នេះពុំខានទេកូនអើយ ។

យក្ខិនីបែកទ្រូងស្ងាប់ក្នុងទីនោះ ; កូនដឹងថាមាតាស្ងាប់ហើយ ទើប

---

១ - វិជ្ជាដូចជាកែវមណី អាចសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាងតាមចិត្តនឹកបាន ។

នាំបិតាទៅលើកសពបូជានាធ្នេរស្ងឹង រួចនាំបិតាទៅក្រុងពារាណសី ។ ចូលទៅឈរក្បែរទ្វារប្រាសាទស្តេចហើយឲ្យគេទៅក្រាបទូលថា មានមាណពម្នាក់ ជាអ្នកឈ្វាសស្គាល់ទ្វរស្នាមជើង ឥឡូវនេះនៅឈរក្បែរទ្វារប្រាសាទ ។ ព្រះរាជាទ្រង់មានព្រះរាជឧត្តារថា បើដូច្នោះ ត្រូវឲ្យវាចូលមក ។ មាណពក៏ចូលទៅតាល់ព្រះរាជា, ព្រះរាជាទ្រង់សួរថា នែមាណព អ្នកឯងចេះមន្តវិជ្ជាពិតមែនឬ ។ – ព្រះករុណាថ្ងៃវិសេស ទូលព្រះបង្គំជាខ្ញុំចេះមន្ត អាចស្គាល់ស្នាមជើងចោរ ដែលលួចទ្រព្យគេចំនួន ១២ ធ្នាំហើយ គង់តាមរកឃើញ ចាប់បានទាំងចោរមកផង ។ – អើ បើដូច្នោះ មាណពឯងត្រូវនៅបំរើយើង ១ នឹងឲ្យមួយពាន់កហាបណ: រាល់ៗថ្ងៃ ។ – ព្រះករុណាថ្ងៃវិសេស - ថ្ងៃមួយបុរោហិតក្រាបទូលថា បពិត្រមហារាជ ព្រះអង្គមិនទាន់ជ្រាបមន្តវិជ្ជារបស់មាណពនេះសោះ ដឹងជាចេះមែនឬមិនចេះទេ សូមព្រះអង្គល្បងមើលសិន ។ ព្រះរាជាយល់តាមបុរោហិត ទើបយាងទៅជាមួយនឹងបុរោហិត ទៅយកកែវព្រះរាជទ្រព្យក្នុងប្រាសាទ ហើយយាងធ្វៀលធ្វាត់កាត់ព្រះរាជនិវេសន៍ ៣ លើក ទើបពាក់បង្អោងឡើងកំពែងចូលទៅក្នុងព្រះទីនាំងវិនិច្ឆ័យគង់បន្ទិច យាងចុះទៅប្រទក្សិណសែក្នុងព្រះរាជបុរី ៣ ជុំ ដើម្បីនឹងបំបាត់ជាន ទើបយាងចុះទៅលាក់កែវព្រះរាជទ្រព្យក្នុងសែះ ទ្រង់ឡើងមកគង់ក្នុងប្រាសាទវិញ ។ លុះព្រឹកឡើងកើតជ្ជួំលច្របល់ថា យប់មិញ ចោរលួចយកកែវព្រះរាជទ្រព្យអំពីប្រាសាទបាត់ហើយ ។ ព្រះរាជាធ្វើហាក់ជាមិនជ្រាប ទ្រង់ត្រាស់ហៅមាណពមកថា អ្នកឯងរកឃើញ

ឬទេ ។ – ក្រាបទូលរកឃើញ ប៉ុនអម្បាលចោរលួចដល់ ១៦ ឆ្នាំហើយ ទូលព្រះបន្ទំជាខ្ញុំគន់រកឃើញ ។ – បើដូច្នោះអ្នកឯងទៅយកមក ។ មាណពចេញទៅឈរនៅមុខព្រះលានលើកដៃសំពះនឹកគុណម្តាយ តាំងរាយមន្ត នឹកសញ្ញឹងបន្ទិច ទើបក្រាបទូលថា បពិត្រមហារាជ នេះពិតជាចោរពីរនាក់ ដើរចូលទៅក្នុងប្រាសាទ ចេញពីនោះមកចុះដើរធ្វៀលធ្វាត់ក្នុងព្រះរាជនិវេសន៍ ៣ លើក រួចពាក់បន្ទោងឡើងកំពែងចូលទៅក្នុងព្រះទីនាំងវិនិច្ឆឹយ ទើបចុះទៅប្រទក្សិណស្រះ ៣ ជុំ យកកែវព្រះរាជ-ទ្រព្យទៅលាក់ក្នុងស្រះនោះ ។ ក្រាបទូលដូច្នេះហើយ ក៏ចុះទៅយកកែវព្រះរាជទ្រព្យមកថ្វាយព្រះរាជា ក្រាបទូលថា បពិត្រមហារាជ ចោរពីរនាក់នេះ សុទ្ធតែមានកេរ្តឹ៍ឈ្មោះល្បីល្បាញ ឥឡូវនេះ ឡើងមកអង្គុយក្នុងព្រះរាជនិវេសន៍នេះ ។ មហាជនត្រេកអរីកកាយទះដៃឈូធរ លើកទង់ជ័យព្រោងព្រាត ។ ព្រះរាជាទ្រង់ត្រាស់ថា អើ បើអ្នកឯងរកកែវព្រះរាជទ្រព្យឃើញហើយ ត្រូវចាប់ចោរមកឲ្យយើងទៀត ។ – បពិត្រមហា-រាជ ចោរនៅក្បែរហ្នឹង មិនមែននៅឆ្ងាយទេ ។ – បើដូច្នោះ ឯងត្រូវចាប់មកបង្ហាញយើង ។ – បពិត្រព្រះម្ចាស់ផែនដី ព្រះអង្គឃើញកែវព្រះរាជទ្រព្យហើយតើ សូមព្រះអង្គកុំចង់ចានចោរទៀត ។ – នែមាណពយើងឲ្យមួយពាន់កហាបណៈរាល់ ។ ថ្ងៃដល់អ្នកឯង ត្រូវតែអ្នកឯងចាប់ចោរមកឲ្យយើង ។ – បពិត្រមហារាជ ទូលព្រះបន្ទំជាខ្ញុំមិនហ៊ានថ្វាយឈ្មោះចោរដល់ព្រះអង្គទេ ប៉ុន្តែសូមនាំរឿងមួយមកថ្វាយព្រះអង្គ ។ គង់ជ្រាបបាន ទើបនាំអតីតនិទានថា:

បពិត្រមហារាជ ក្នុងកាលដែលកន្ធងទៅហើយ មានអ្នករបាំម្នាក់ ឈ្មោះបាដលី តែងនៅអាស្រ័យក្នុងស្រុកតូចមួយប្របធ្នេរស្ទឹងជិតក្រុងពារាណសី ។ ថ្ងៃមួយអ្នករបាំនោះ នាំប្រពន្ធទៅលេងមហោស្រពឯក្រុងពារាណសី បានរង្វាន់យ៉ាងច្រើន, ដល់ពេលឈប់លេង នាំប្រ-ពន្ធចេញមក ក៏ទិញស្រានឹងបាយយកទៅផ្ទះរបស់ខ្លួន លុះដល់ធ្នេរស្ទឹងយើញទឹកហូរថ្នី ។ ឈប់អង្គុយបរិកោគបាយផឹកស្រា ស្រវឹងមិនដឹងខ្លួន ក៏យកចាបុីមកចងក ដឹកដៃប្រពន្ធធ្ងងស្ទឹង ទឹកហូរចូលតាមរន្ធចាបុី ពន្ធិចអ្នករបាំនោះក្នុងស្ទឹង ។ ប្រពន្ធដឹងថា ប្តីលង់ទឹកហើយក៏លែងដៃប្តី ស្ទុះមកលើគោក ប្តីមុជដើប ។ ទឹកចូលពេញពោះ ប្រពន្ធស្រែកសុំចម្រៀងប្តីថា បពិត្រអ្នកប្តីអើយ សូមអ្នកប្រាប់ចម្រៀងប្អូនបានមួយបទគ្រាន់នឹងចិញ្ចឹមជីវិត ។ ប្តីធ្វើយថា ហៃប្អូនស្រី បងនឹងឲ្យចម្រៀងជូចម្តេចកើតបើទឹកកំពុងតែចូលមាត់ មនុស្សយើងរស់នឹងទឹក ឥឡូវនេះទឹកសម្ងាប់ហើយ ក៏យទៅជាកើតមកអំពីរបស់ដែលជាទីពឹង ។ បពិត្រមហារាជ ទឹកជាទីពឹងរបស់មហាជន ក៏យបែរជាកើតមកអំពីទឹកជាទីពឹងនោះ យ៉ាងណា ស្តេចទាំងឡាយជាទីពឹងរបស់មហាជន ក៏យបែរជាកើតមកអំពីស្តេចទាំងឡាយ ក៏យ៉ាងនោះដែរ ក៏យនោះគ្មានន្ទរណាការពារបានឡើយ ព្រះអង្គជាបណ្ឌិតស្រាប់ហើយ សូមទ្រង់ជ្រាបចុះ ។ – យើងមិនយល់ទេ អ្នកឯងត្រូវចាប់ចោរមកឲ្យយើង ។ – បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់រឿងមួយទៀតចុះ ។ មាណពក៏ដំណាលរឿងមួយទៀតថា:

ក្នុងកាលពីដើមមានស្ងួនឆ្នាំងម្នាក់ នៅក្នុងស្រុកជិតក្រុងពារាណសី
នេះ បានជីករណ្តៅមួយយ៉ាងធំក្បែរញកក្នុំ ថ្ងៃមួយស្ងួនឆ្នាំងនោះកំពុង
តែកើបជីយកទៅធ្វើកាជន៍ ស្រាប់តែក្ងៀងធ្ងាក់មកយ៉ាងខ្ទាំង ទឹកពេញ
រណ្តៅ ជីបាក់ធ្ងាក់មកត្រូវបែកក្បាលយំទួញថា

ជនទាំងឡាយសាបព្រោះពូជលើផែនដី ពួកសត្វតែង
អាស្រ័យនឹងផែនដី ឥឡូវនេះ ផែនដីបំបែកក្បាលអាត្មាអញ
ក៏យទៅជាកើតមកអំពីរបស់ដែលជាទីពឹងវិញ ។

បពិត្រមហារាជ ផែនដីជាទីពឹងពំនាក់របស់មនុស្ស ត្រឡប់ជា
បំបែកក្បាលស្ងួនឆ្នាំងវិញ យ៉ាងណា ធម្មតាស្តេចក៏ជាទីពឹងពំនាក់របស់
មនុស្សលោកទាំងមូល ត្រឡប់ទៅជាធ្វើចោរកម្មយ៉ាងនោះដែរ នរណា
នឹងការពារបាន បពិត្រព្រះសម្មតិទេព ព្រះអង្គល្មមជ្រាបថាឈ្មោះ
ណាជាចោរហើយ ។ - នែមាណព អ្នកឯងត្រូវចាប់ដឹកដៃមកឲ្យ
យើង ។ មាណពមិនហ៊ាន ក្រាបទូលថា "ព្រះអង្គនេះឯងជាចោរ"
ដូច្នេះទេ ដោយអំណាចសេចក្តីគោរព ទើបនាំទាហរណ៍មួយទៀតថា

បពិត្រព្រះសម្មតិទេព ក្នុងកាលមុន មានបុរសម្នាក់នៅក្នុងនគរ
នេះ បុរសនោះយើញក្ងើងធេះផ្ទះ ស្ទុះចូលទៅជញ្ជូនយកទ្រព្យក្នុងផ្ទះ
ស្រាប់តែទ្វារផ្ទះបិទជិត ផ្សែងហុយងងឹតស្ទុប រកផ្ទូវចេញមកវិញមិន
រួច ក្ងើងធេះរោលរលាកនៅក្នុងផ្ទះ ស្រែកទ្រហោយំថា

អ្នកផងតែងចំអិនអាហារនឹងក្ងើង កំដៅរបស់ដែលត្រជាក់ឲ្យក្តៅ

នឹងក្ងើង ក្ងើងឡៅជាធេះខ្ជូនអាត្មាអញ ក៏យឡៅជាកើតមក
អំពីរបស់ដែលជាទីពឹង ។

បពិត្រមហារាជ មនុស្សម្នាក់ទុកជូចជាក្ងើងជាទីពឹងរបស់មហាជន
ឡៅជាលួចទ្រព្យគេវិញ សូមព្រះអង្គកុំស្ជររកចោរឡើយ ។ – នែមាណព
អ្នកឯងកុំរាសរាងត្រូវតែចាប់ចោរមក ។ មាណពនាំទ្ទាហរណ៍មួយទ្រៀតថា

បពិត្រព្រះសម្មតិទេព ក្នុងកាលមុន មានបុរសម្នាក់ទទួលព្រះរាជ-
ទានច្រើនហួស ឡៅជាហល់ចាក់ចោស់បានសេចក្តីទុក្ខលំបាកស្រែក
ត្អូញថា:

ជនទាំងឡាយតែងញ្ចុំងអត្តភាពឲ្យរស់ ដោយសារបាយ
ឥឡូវនេះ បាយនោះ ឡៅជាសម្ងាប់អាត្មាអញ ក៏យឡៅ
ជាកើតមក អំពីរបស់ដែលជាទីពឹង ។

បពិត្រព្រះនរិន្ទ បុគ្គលម្នាក់ជាទីពឹងរបស់មនុស្សលោក ជូចជាបាយ
ដែរ ហ្ងៃឡៅជាលួចទ្រព្យគេវិញ សូមព្រះអង្គទ្រង់ជ្រាបចុះ ។ – នែមាណព
អ្នកឯងត្រូវចាប់ចោរមកឲ្យយើង ។ មាណពនាំរឿងមួយមកទ្រៀតថា

បពិត្រព្រះសម្មតិទេព ក្នុងកាលពីដើម មានឈើមួយដើមដ៏ធំ
ចរិបូណិដ្ៅាយមែកនឹងស្ងឹក ជុះនៅក្នុងវ្រៃហិមពាន្តជាទីអាស្រ័យនៃ
សត្វស្វាបច្រើនពាន់ មែកឈើនោះសង្ហួតគ្នាចេញផ្សែងធេះជាក្ងើងធ្ងាក់
កំទេចមក បក្សីមួយជាធំជាងគេ ឃើញក្ងើងនោះក៏និយាយថា

បក្សីទាំងឡាយអាស្រ័យនឹងដើមឈើណា ដើមឈើនោះ
ឡៅជាបញ្ចេញក្ងើង ម្នាលគ្នាយើងទាំងឡាយ អ្នកទាំង

ឡាយចូរគប់រក ខ្លួនដ៏ឧត្តមឡាយចុះ កុំយកទៅជាកើត
មកអំពីរបស់ដែលជាទីពឹង ។

បពិត្រព្រះសម្មតិទេព ដើមឈើជាទីពឹងរបស់ពួកបក្សី យ៉ាងណា
ស្តេចជាទីពឹងរបស់ប្រជាជនយ៉ាងនោះដែរ កាលបើស្តេចធ្វើទោសហើយ
នរណានឹងការពារបាន សូមព្រះអង្គជ្រាបចុះ ។ – នែមាណព អ្នកឯង
ត្រូវចាប់ចោរមក ។ មាណពនាំរឿងមួយមកទៀតថា

បពិត្រមហាភជ ក្នុងកាសិកគ្រាមនេះ មានត្រកូលម្នាក់មានកូន
ប្រុសតែមួយ លុះបិតាស្លាប់ទៅ មាតាក៏រៀបចំឲ្យមានប្រពន្ធ នាងនោះ
មុនដំបូងចេះផ្គត់ផ្គង់ម្តាយក្មេកដោយមាំមួន ដល់ពេលក្រោយមកបែរទៅ
ជាញុះញង់ពោលទោសម្តាយក្មេកថ្កោលទ្រើងថា ខ្ញុំមិនចង់ឮមម្តាយអ្នកឯង
ទេ អ្នកត្រូវសម្លាប់គាត់ចោលទៅ ។ ប្តីឆ្លើយថា ការសម្លាប់មនុស្ស
ក្រណាស់ យើងនឹងសម្លាប់ដូចម្តេចកើត ។ – នែអ្នកប្តី ដល់គាត់
សម្លាប់លក់ យើងសែនគាត់ចាំងក្រៃទៅលាក់ក្នុងស្នូងខាងលិចផ្ទះឲ្យ
ក្រពើវាំងស៊ីអស់ទៅ ។ – អើស្រួលហើយ ចុះម្តាយនាងឯងសម្លាប់
ត្រង់ណា ។ – គាត់សម្លាប់ជិតម្តាយអ្នកឯងដែរ ។ – បើដូច្នោះនាងឯង
យកខ្សែទៅចងវែគដែលម្តាយអញសម្លាប់ឲ្យហើយទៅ សឹមមកថ្កោលប់
អញ ។ ប្រពន្ធចងរួចហើយមកថ្កោលប្តី។ ឆ្លើយថា ចាំពួកមនុស្ស
ដេកលក់សិន ហើយធ្វើជានាំប្រពន្ធដេក លុះប្រពន្ធដេកលក់ លបទៅ
ស្រាយខ្សែពីវែគម្តាយរបស់ខ្លួន ទៅចងវែគរបស់ម្តាយខាងប្រពន្ធវិញ
ហើយមកជាស់ប្រពន្ធឲ្យទៅជួយសែងវែគ ប្រពន្ធក្រោកឡើងជួយសែង

ត្រែគេទំលាក់ក្នុងស្ទឹងខាងក្រោយផ្ទះ ក្រពើស៊ីយាយនោះអស់ ។ លុះព្រឹកឡើងប្រពន្ធដឹងថា ប្តីផ្ទាស់ប្តូរត្រែដូច្នោះ ទៅនិយាយនឹងប្តីថា ឥឡូវនេះអ្នកសម្ងាប់ម្តាយខ្ញុំហើយ ត្រូវអ្នកសម្ងាប់ម្តាយអ្នកឯងទៀត ។ ប្តីធ្វើយថា អើម្តងនេះ យើងត្រូវសែងទាំងត្រែទៅដុតចោលឯព្រៃស្មសានទើបស្រួល ។ លុះម្តាយដេកលក់ នាំគ្នាប្តីប្រពន្ធសែងម្តាយទៅដល់ព្រៃស្មសាន ប្តីស្ទូរថា ឯងបានយកក្ងើងមកដែរឬ ។ – ខ្ញុំមិនបានយកមកទេ ។ បើដូច្នោះឯងទៅយកមក អញនៅចាំ ។ – ខ្ញុំមិនហ៊ានទៅទេ ខ្លាចខ្មោច ។ – ឯងនៅចាំចុះ អញទៅយក ។ – ខ្ញុំមិនហ៊ាននៅទេ យប់ស្ងាត់ឈឹងយ៉ាងនេះ ។ ប្តីប្រពន្ធបណ្តើរគ្នាទៅយកក្ងើងឯផ្ទះ លុះចេញទៅផុត ម្តាយត្រូវខ្យល់ត្រជាក់ៗ ក៏ក្រាក់ដឹងខ្លួនថាកូនយកអាគ្មាអញមកដុតទេតើ ទើបស្ទុះក្រោកឡើងចេញមក ឃើញសាកសពមួយ ក៏យកទៅរុំនឹងសំពត់ផ្តេកលើត្រែរបស់ខ្លួនហើយរត់ចេញទៅចូលក្នុងគុហាមួយ ដែលជាកន្ទែងពួកចោរធ្លាប់តែលួចទ្រព្យគេ យកមកលាក់ ។ ប្តីប្រពន្ធយកក្ងើងមកដុតសាកសពនោះ ស្មានថាម្តាយរបស់ខ្លួន រួចត្រឡប់មកផ្ទះវិញ ។ លំជាប់នោះ ចោរដីរទៅយកបង្ហូចទ្រព្យដែលខ្លួនលាក់ក្នុងគុហា ស្រាប់តែឃើញយាយចាស់ នឹកស្មានថា យក្ខិនីឬខ្មោចបិសាច មកហួងហែងទ្រព្យរបស់ខ្លួន ក៏ត្រឡប់ទៅហៅពេទ្យអ្នកចេះចាប់ខ្មោចមក ។ លុះពេទ្យមកដល់តាំងប្រសិទ្ធីមន្ត-វិជ្ជាដើរចូលទៅ ។ យាយចាស់និយាយថា ខ្ញុំមិនមែនជាយក្ខិនី ឬជាខ្មោចបិសាចអ្វីទេ ។ – ចុះធ្វើដូចម្តេចឲ្យយើងជឿផង ។ – អ្នកឯង

លៀនអណ្ណាតដាក់លើអណ្ណាតខ្ចឹមក មុខជាទឹងស្ពាល់ហើយ ។ ពេទ្យ
លៀនអណ្ណាតចេញមក, យាយចាស់ខាំជាប់ ជាប់អណ្ណាតធ្លាក់មក;
ពេទ្យស្រែកថា យីយក្ខិនីៗ; ចោរហើយនឹងពេទ្យក៏រត់ទៅផ្ទះវិញអស់ ។
លុះព្រឹកឡើង យាយចាស់ស្រាំយយកសំពត់សាច់ល្អិតមកស្ងៀក រួច
ទូលបង្វេចទ្រព្យមកផ្ទះរបស់ខ្លួន ។ ក្ងនប្រសាស្រីឃើញដូច្នោះក៏សួរថា
បពិត្រអ្នកម្ពាយ អ្នកបានទ្រព្យទាំងនេះមកអំពីណា ។ ម្ពាយក្មេកប្រាប់ថា
ធម្មតាមនុស្សដែលគេយកទៅដុតក្នុងព្រៃស្មសាន តែងតែបានទ្រព្យ
យ៉ាងហ្នឹង ។ នាងនោះ ហេតុតែចង់បានទ្រព្យក៏ទៅប្រាប់ប្ពីឲ្យយកខ្លួន
ទៅដុតក្នុងព្រៃស្មសាន ។ ប្ពីយកប្រពន្ធទៅដុតមែន ហើយឈរថ្ពាល
មើលផ្ទូរប្រពន្ធ ដល់មិនឃើញសោះ ទើបងាកទៅសួរម្ពាយថា បពិត្រ
អ្នកម្ពាយ ថ្មើរណោះហើយ ហេតុអ្វីក៏មិនឃើញប្រពន្ធខ្ចុំទូលទ្រព្យមកផ្ទះ ។
ម្ពាយស្ពីបន្ទោសថា "អាចង្រៃ អាឯងជាបុរសលាមក ធម្មតាមនុស្សដែល
ស្លាប់ហើយមិនដែលរស់មកវិញទេ កុំលង់ពេក" រួចពោលគាថាមួយថា:

> អាត្មាអញ៉ាមានសេចក្ពីត្រេកអរ បាននាំមកនូវស្រីដែល
> ប្រោះព្រំដោយខ្ចឹមចន្ទន៍ ពាក់ពាតដោយផ្ការកម្រង ស្រីនោះ
> ទៅជាបណ្ណោញអាត្មាអញឲ្យចេញអំពីផ្ទះ ក៉យទៅជាកើត
> មកអំពីរបស់ដែលជាទីពឹង ។

បពិត្រមហារាជ ស្តេចជាទីពឹងរបស់ប្រជារាស្ត្រ ដូចជាកូនប្រសា
ស្រីជាទីពឹងរបស់ម្ពាយក្មេកដែរ សូមព្រះអង្គជ្រាបរឿងនេះចុះ ។ – នៃ

មាណព រឿងនេះកំបាំងណាស់ យើងមិនយល់ទេ ត្រូវតែចាប់ចោរ
មកឲ្យយើង ។ មាណពនាំនិទានមួយមកទៀតថា

បពិត្រព្រះសម្មតិទេព កាលពីដើមកុងនគរនេះ មានបុរសម្នាក់
ត្មានកូនសោះ ទំបន់សែន់បានកូនប្រុសម្នាក់ សែឡាញ់ថ្នាក់ថ្នម បីបម
រក្សា រៀបចំឲ្យមានប្រពន្ធ លុះដល់ខ្ជួនចាស់ធ្វើការងារមិនកើត កូន
សំឡាញ់នោះបណ្តេញចេញអំពីផ្ទះ ទៅជាមនុស្សតេលតោល ឥតទីពឹង
ដើរសុំទានគេ ចិញ្ចឹមជីវិតបាន ដោយត្រជាបត្រដួសត្អូញត្អែរថា

អាត្មាអញវីកវាយនឹងកូន ប្រាថ្នាសេចក្តីចំរើនដល់កូន
កូននោះទៅជាបណ្តេញអាត្មាអញឲ្យចេញអំពីផ្ទះ ភ័យទៅ
ជាកើតមកអំពីរបស់ដែលជាទីពឹងវិញ ។

បពិត្រមហារាជ កូនដែលធំឡើងត្រូវតែថែរក្សាបិតាដែលចាស់
ជរាយ៉ាងណា ស្តេចត្រូវតែថែរក្សាជនបទតាំងមូល យ៉ាងនោះដែរ សូម
ព្រះអង្គជ្រាបថា ជនឯណោះជាចោរ ដោយហេតុនេះចុះ ។ ព្រះរាជា
ទ្រង់មិនយល់ហេតុនោះ ទ្រង់ចាប់ថ្នាក់ថា អ្នកឯងជាចោរទេដឹង បានជា
មិនរកចោរឲ្យយើង ចេះតែបណ្តោះបណ្តែវេះរាងយ៉ាងនេះ ។ – បពិត្រ
ព្រះនរិន្ទ ព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំ ចាប់ចោរពិតប្រាកដមែនឬ ។ –
អើប្រាកដមែន ។ – បើដូច្នោះឲ្យទូលព្រះបង្គំជាខ្ញុំប្រកាសកុងកណ្តាល
បរិស័ទសិនថាឈ្មោះនេះមួយ ។ ជាចោរឬ? ។ – អើប្រកាសចុះ ។
មាណពហៅពួកអ្នកជនបទនឹងអ្នកនិគមឲ្យមកប្រជុំគ្នាហើយប្រកាសថា

អ្នកទាំងឡាយចូរចាំស្តាប់ពាក្យរបស់ខ្ញុំចុះ ឥឡូវនេះ ទឹកត្រូវ
ក្ងើងធេះវិញហើយ សេចក្តីក្សេមក្សាន្តជ្ងាប់តែបានមកអំពី
ស្តេច ឥឡូវនេះ ក៏យត្រឡប់ជាកើតមកអំពីស្តេចវិញ ស្តេច
នឹងបុរោហិតតែងបូន់ពួកកស្ត្រ អ្នកកល់ត្នាត្មានស្តេច ត្រប់ត្រង
ទេ ត្រូវប្រុងប្រយ័ត្នទ្រព្យសម្បត្តិរៀងកល់ខ្លួនទៅចុះ ។

ត្រានោះ ពួកមហាជនបានស្តាប់ជាក់ច្បាស់ហើយ ក៏ក្រោកស្ទុះ
ទៅស្រវាចាប់ដំបង ៤ ជ្រុងតែកល់ដៃ ហើយទៅវាយសំពងស្តេចនឹង
បុរោហិតទាល់តែទីវង្គតស្ទាប់ក្នុងកជបុរី ហើយអភិសេកមាណពឲ្យ
សោយរាជ្យជាស្តេចក្នុងពេលនោះឡើង ។

ឯស្តេចនឹងបុរោហិត ដែលបានទទួលទោសយ៉ាងធ្ងន់ដល់អស់ជីវិត
នោះ មកអំពីទោសអទិន្នាទាន ។ ការលួចលាក់នេះ កុំបាច់និយាយ
ឡើយដល់ទៅលួចទ្រព្យសម្បត្តិអ្នកដទៃ ទើបមានទោសនោះ សូម្បី
លួចលាក់ទ្រព្យសម្បត្តិរបស់ខ្លួន គង់មានទោសយ៉ាងធ្ងន់ដល់អស់ជីវិត
ដែរ ដូចយ៉ាងស្តេចនឹងបុរោហិតនេះ ព្រោះតែលួចលាក់ទ្រព្យរបស់ខ្លួន
បានជាពួកកស្ត្រវាយស្ទាប់ ។

ឯអត្តមហេសីដែលក្ងាយខ្លួនទៅកើតជាយក្ខិនី ហើយស្ទាប់អនាថា
នោះ ព្រោះទោសនៃការប្រព្រឹត្តិមិច្ឆាចារ ហើយពោលកុហកព្រះរាជា ។

ឯអ្នករបាំឈ្មោះបាដលីដែលលង់ទឹកស្ទាប់ ព្រោះទោសនៃការធឹក
សុរា ។

ឯកូនប្រសាស្រីដែលត្រូវប្តីដុតចោលក្នុងព្រៃស្មសាននោះ ព្រោះ
គោសនៃបាណាតិបាត (ដុតសត្វតាំងរស់) ក្នុងកាលមុន ។

ចំណែកខាងមាណព ដែលបានឡើងតង់លើបល្ថ័ង្ក ក្រាមស្វេត-
ច្ជ័ត្រទទួលរាជសម្បត្តិ ព្រាទីនោះ មកអំពីគុណសម្បត្តិគឺចំណេះដែល
ចេះពិតប្រាកដ ។

ចំណេះអ្វីមួយដែលគេចេះពិតប្រាកដហើយ អាចនឹងលើកស្ទួយ
មនុស្សជាន់តាបឲ្យឡើងកាន់ទីខ្ពស់បាន អាចនាំឲ្យបានសេចក្តីចំរើន
រុងរឿងគ្រប់យ៉ាងគៅបាន ។

ចំណេះណាមួយដែលចេះមិនពិតប្រាកដហើយ អាចនាំឲ្យថោក
តាបសាបសូន្យមិនខានឡើយ ។

ចប់បទកុសលជាតក

ទ្រព្យសម្បត្តិបានដោយការរិបជាន់គេពុំប្រសើរ

សម្រាប់មនុស្សតាំងឡាយ ការនៅព្រៃប្រសើរ, ការដើរ
សូមទានគេប្រសើរ, ការធ្វើឈ្ទូលរែកពុនចិញ្ចឹមជីវិតប្រសើរ,
ការឈឺចាប់ប្រសើរ, ឯទ្រព្យសម្បត្តិដែលបានមកដោយធ្វើជា
អធិការ (ធ្វើជាធំលើគេ សង្កត់គេ) មិនប្រសើរឡើយ ។

ចញ្ចតន្ត្រះ

បញ្ញាសជាតក

ភាគទី ៣

បណ្ឌិតមហា ឈឹម-សុម សាស្ត្រាចារ្ស

នៅសាលាបាលីដាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦ ត.ស. ១៩៤៣

(តមក)

មហាសុរសេនជាតក ទី ១៤

លោកអាចារ្ស ម្រៀ-ធន្ធ រត្តលង្កា

ប្រែពីបាលី

(តកម)

អាមាត្យក្រាបទៀបព្រះបាទានៃមហាសត្ត សោកខ្សឹកខ្សួលអួលទៅ អាលំយព្រះរាជាឥតទបមា ក្សត់ព្រះលោហិតជាក់លើសិរសាហើយ ត្រឲ្យប់ទៅឯនគរ យកសេចក្តីក្រាបបង្គំទូលនាងទេវី នឹងប្រាប់ជល់ពួកមហាជនទាំងអស់ ។ ពួកអ្នកនគរមានអាមាត្យជាប្រធាន នឹងអស់ស្រីស្នំទាំងប៉ុន្មាន និមិត្តតែបានព្ទពាក្យនោះហើយ ក៏ត្រាំមិនបាន នាំគ្នាស្រែកយ៉ាងខ្ទាំង ហើយចេញបាកនគរចរចូលទៅទទ្យាន ក្សត់ព្រះលោហិតនៃមហាសត្ត ហើយលើកដៃឡើងទ្រហោយំទាល់តែសន្ទប់បាត់ស្មារតី ។ ឯនាងទេវីព្រះនាមវិជ្ជុលតា ទ្រង់ត្រកងមហាសត្ត យកក្ខួងសក់ជូតព្រះលោហិតយំនឿលទៅមក ហាក់ជូចជាធ្ពួតលីលាសន្ទប់បាត់ស្មារតី ។ កាលនោះ ជនទាំងឡាយ យកទឹកត្រជាក់ទៅស្រប់ព្រះកក្ត្រព្រះនាងបានក្រាក់ជកជង្ហើមរួច យកព្រះហស្តទាំង ២ គក់ព្រះទរ ទ្រង់

ព្រះកន្យែងកាប់រៀបថា "ម្នាលព្រះស្វាមីម្ចាស់ថ្លៃប្អូនអើយ, ខ្ញុំនឹងជាស្រីកំព្រាហើយ តាំងពីថ្ងៃនេះទៅ, ខ្ញុំម្ចាស់ជាស្រីមេម៉ាយ សមនឹងមានតែសេចក្តីទុក្ខក្តៅក្រហាយជាមិនខាន", នាងកាប់រៀបសព្វគ្រប់ហើយ នៅតែអត់សង្កត់មិនបាន កំប្រះក្បាណាសោយសោកស្ទុះស្ទប់ស្រែកប់ស្រែនោនក្រៀមក្រំហាក់ទំនឹងស្លួតនាះប្លែកម៉ិញ ។

តស្មឹ ខណៈ ក្បិណានោះសម្តេចសក្កទេវរាជ ទ្រង់គ្រឿងអលង្ការដ៏រុងរឿងថ្កើងឆាបវរ មកឋដ៏អាកាស ហាក់ព្រះសុរិយារុងរឿងរះគ្រប់ចាំងវស្មី បង្ហាញព្រះអង្គឲ្យប្រជុំជនឃ្លាសស្រឡះបានឃើញហើយ ត្រាស់ហៅនាងទេវីថា ម្នាលនាងទេវី នាងកុំទ្រង់ព្រះកន្យែងសោយសោកឡើយ យើងនឹងឲ្យជីវិតដល់ស្វាមីរបស់នាងឥឡូវនេះឯង ។ ហេតុតែអានុភាពនៃព្រះឥន្ទ្រ ទើងតេជគុណបុណ្យ ព្រះមហាសត្ត ព្រះអង្គក៏កើតមានព្រះសិរីសោភ្លើងមួយរំពេចក្នុងវិថ្ងៃនោះឯង ។ ពួកមនុស្សម្នាមហាជនបានឃើញហេតុអស្ចារ្យដូច្នោះ ក៏នាំគ្នាថ្វាយស័ព្ទសាធុការលើកទើងជាយថាំងពាន់ថ្វាយបូជាព្រះមហាសត្ត ។ ព្រះទេវីបានយល់ស្វាមីនាងជាឡើងដូច្នោះ ក៏ព្រឺព្រួចសោមនស្សលាន់ព្រះឧស្ឋថា យើងត្រូវតែធ្វើបាន។ ។ កាលនោះ សក្កទេវរាជស្ថិតឋដ៏អាកាសត្រាស់ថ្វាយព្រះពរស័ព្ទសាធុការថា "សាធុ! អ្នកសប្បុរសអើយ, អ្នកហ្មឺងហើយជាទីពឹងនៃសត្វលោក, អ្នកបំពេញមហាបរិច្ចាគចាំង ៥ គឺ បរិច្ចាគសរីរាវយវៈ ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគជីវិត ១ បរិច្ចាគកូន ១ បរិច្ចាគប្រពន្ធ ១ យ៉ាងនេះហើយគង់ទំនឹងបានជាព្រះពុទ្ធច្បាកជាមិនខាន" ព្រះឥន្ទ្រ

ត្រាស់យ៉ាងនេះស្រេចហើយក៏បាត់ពីកន្លែងនោះទៅ ។ ចាប់តាំងពីថ្ងៃនោះមក ព្រះមហាសុរសេនតែងតែធ្វើបុណ្យ មានឲ្យទានជាដើមរៀងរាល់វេលា លុះអស់ព្រះជន្មាយុកាលណា ស្តេចទៅឧប្បត្តិកន្លែងពិភពតុសិត ។ ព្រោះហេតុនោះសម្តេចព្រះដ៏មានជាគ្រែន់ត្រាស់ថា:

បត្តំ ទត្វាន យេ ធីរា មហាពលបរក្កមា
អវេរា តិទ្ធិសម្បន្នា មហាតេជា ជនប្បិយា
អនន្តរបរិវារា តេ សព្វភោគេហិ មណ្ឌិតា
សត្តរតនសម្បន្នា បក្កន្តិ មហិទ្ធិកា ។ល។

ជនទាំងឡាយឯណាជាអ្នកច្រើនបាជ ឲ្យទានឲ្យបាត្រជាទាន, ជនទាំងឡាយនោះ ជាអ្នកមានកំលាំងនឹងសេចក្តីព្យាយាមច្រើន ឥតមានខ្សោយខ្សាវ បរិបូណ៌ដោយឫទ្ធិ មានតេជះច្រើន ជាទីស្រឡាញ់នៃជន មានបរិវារមិនអស់ ប្រដាប់ដោយភោគសម្បត្តិត្រប់យ៉ាង បានជាស្តេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ប្រការ មានមហិទ្ធិឫទ្ធិបរិបូណ៌ ដោយសម្បត្តិជាកាមាវចរ រូបាវចរនឹងអរូបាវចរ សោយសេចក្តីសុខជាលោកិយ, បើកើតក្នុងពុទ្ធុប្បាទ ទីបំផុតបានជាអ្នកច្រើនបាជណែនាំបង្ហាញប្រយោជន៍ដល់សត្វក្នុងលោកទាំងមូល ជាម្ចាស់សព្វសត្វទាំងឡាយ, លុះចំណែរទៅឯក្រៃក ទីបំផុតបានត្រាស់ជាព្រះពុទ្ធ ។

ជនទាំងឡាយឯណា បានឲ្យសង្ឃាដី, ជនទាំងឡាយនោះ

ជាអ្នកញ្ញាំញ៉ីមារសេនា ទុកជាប្រទះនឹងផ្ទរវន្ទុះខ្ទាំងយ៉ាងណា ក៏មិនរំជួយរោមឡើយ មិនមានភ័យព្រឺស្បែកព្រឺរោមឡើយ, ឋានសោយសេចក្តីសុខជាកាមភូមិ. លុះចំណេរទៅឯក្នែក នឹងឋានត្រាស់ជាព្រះពុទ្ធ ។

អ្នកឲ្យចីវរជាទាន នឹងឈ្នះសង្ត្រាម ឋានជាឥស្សរកំពូលនៃជនទាំងអស់ លុះដល់កាលខាងក្រោយ នឹងឋានត្រាស់ជាព្រះពុទ្ធ ។

អ្នកឲ្យស្បង់ជាទាន នឹងឋានធ្វៀរធ្វាសចេះវិន័យ ឈ្នះមារគ្រប់ប្រការជានិច្ច, លុះចំណេរទៅឯក្នែក នឹងឋានត្រាស់ជាព្រះពុទ្ធ ។

អ្នកឲ្យវត្ថពន្ធជាទាន រមែងឋានជាអ្នកស្អាត បរិសុទ្ធក្នុងភពទាំងឡាយជាធំក្នុងទីសព្វកន្លែង, លុះពេលខាងក្រោយ នឹងឋានត្រាស់ជាព្រះពុទ្ធ ។

អ្នកដែលបរិសុទ្ធផុតពៀរវេរា បរិបូណិដោយលក្ខណ៍ មានអាយុវែង មានសេចក្តីសុខ ទាំងនេះជាផលនៃកាំបិតកោរ ។

ជនទាំងឡាយឯណា កើតក្នុងកាលគួរ មានប្រាជ្ញាមុះមុតចេះដឹងអាថិសេចក្តីសព្វគ្រប់ អង់អាច មានជ័យជំនះឈ្នះរាទទាំងពួង, ជនទាំងឡាយនោះលុះដល់ពេលខាងក្រោយ នឹងឋានត្រាស់ជាព្រះពុទ្ធ ។

ជនគំនឡាយឯណា ឲ្យអញ្ជុលជាទានដោយសទ្ធា ជន
គំនឡាយនោះនឹងមានអាយុវែង មានប្រាជ្ញាថ្ថាស្អាត ជា
ពហុស្សូតទ្រទ្រង់ធម៌ មានរូបល្អប្រាកដក្នុងលោក ។

ជនគំនឡាយឯណា ឲ្យសំពត់ដម្រងទឹកដល់កិក្ខុ ជន
គំនឡាយនោះលុះកើតក្នុងជាតិគំនញ្ជង រមែងធ្វៀវធ្ងាស
ប្រាសចាកពៀរវេរា ត្រេកត្រអាលក្នុងហានស្ជតិ មានរូបល្អ
មានសម្ឡុរល្អ មានអាយុវែង មានឥន្ទ្រិយមិនលំបាក ។

ជនគំនឡាយឯណា បានឲ្យធត្រជាទានក្នុងពេលក្តៅ
គោះធត្រមាសក្តី ធត្រស្ងាបក្លោកក្តី ធត្រសំពត់ក្តី ធត្រកែវ
ក្តី, ជនគំនឡាយនោះរមែងបានទ្ធវញ្ជកបក្ខដ៏ប្រសើរជានិច្ច ។
អ្នកឲ្យធត្រជាទានក្នុងពេលក្តៅនោះ រមែងបានគ្រឿងកកុធ-
កណ្ឌ ៥ យ៉ាងគឺ: ស្វេតច្ឆត្រ ១ ចាមរ ១ ម្ជុដ ១ ព្រះខាន់ ១
សុពណ៌បាទុក ១ ។

អ្នកមានសទ្ធាបរិសុទ្ធ បានប្រគេនរបស់ប្រកបដោយអង្គ ៨
ជាទ្រព្យប្រសើរដល់កិក្ខុគំនឡាយ គឺវិត្រចីវរ ១ បាត្រ ១
កាំបិតកោរ ១ អញ្ជុល ១ វត្ថពន្ធ ១ ដម្រងទឹក ១ អ្នក
នោះនឹងមានបរិវារៈប់មិនអស់ មានសំក្តិយសទ្ពស់អនេក ។

អ្នកឲ្យកម្រាលស្បែកជាទាន នឹងបានជាស្តេចចក្រពត្តិ
មានបុទ្ធិប្រើន មនុស្សក្នុងលោកគំនអស់តែងស្រឡាញ់ចូល
ចិត្ត. រមែងវៀរចាកកពមានរូបកពជាដើម ។

អ្នកឲ្យចីវរជាទាន នឹងបានសម្បត្តិច្រើន មានបុទ្ធិច្រើន
បរិបូណិដោយកំលាំងច្រើន, លុះចំណេរទៅឯក្នែក នឹង
បានដល់នូវព្រះនិព្វានជាឋានរលត់ទុក្ខ ។

នរៈនារី ដែលបានឲ្យគ្រឿងបរិក្ខារគ្រប់ប្រដាប់ នឹងបាន
សម្បត្តិទិព្ធ យសទិព្ធ ខ្ញុំប្រុសខ្ញុំស្រីរាប់មិនបាន សោយ
សេចក្តីសុខក្នុងកាមលោក ដល់នូវសេចក្តីសុខក្នុងរូបលោក
អរូបលោក, លុះចំណេរទៅឯក្នែក នឹងបានដល់នូវ
ព្រះនិព្វាន ។

ភិក្ខុដែលប្រាថ្នាលោកុត្តរធម៌ ៩ យ៉ាង ត្បូរបំពេញបារមី-
៣០ ប្រការ ឲ្យគ្រប់ទាំងអស់ ដោយយល់ឃើញថា ទាន
បារមីជាបុសគល់, ព្រះពុទ្ធគ្រប់អង្គទ្រង់សរសើរជានិច្ច អ្នក
ដែលមានបារមីគ្រប់គ្រាន់ហើយ រមែងដល់នូវព្រះនិព្វាន
ជាប្រាកដ ។ លុះដល់ព្រះអរិយមេត្តយ្យ មកឧប្បត្តិក្នុង
ជម្ពូទ្វីប ជនដែលបានឲ្យទាននោះ នឹងបានជាឯហិភិក្ខុក្នុង
សំណាក់ព្រះអង្គ ប្រដាប់ដោយបាត្រ នឹងចីវរ ជាពុទ្ធបុត្រ
មានបញ្ញាច្រើន សម្រេចដូចសេចក្តីប្រាថ្នា; ទាំងនេះក៏ព្រោះ
ឲ្យទានគ្រឿងអដ្ឋបរិក្ខារ រមែងបានសំពូសាធុការពរអំពី
ទេវតាទាំងឡាយ ដោយអានុភាពនៃគ្រឿងបរិក្ខារ; ព្រោះ
ហេតុនោះ បណ្ឌិតអ្នកមានប្រាជ្ញាច្រើន កាលបើបានជ្រាប

ថាឲ្យទានគ្រឿងបរិក្ខារមានផលច្រើនយ៉ាងនេះហើយ គប្បីឲ្យទានក្នុងកាលដែលមានសាសនាព្រះសម្មាសម្ពុទ្ធ ។

ព្រះបរមគ្រូជាម្ចាស់ កាលត្រាស់សំដែងព្រះធម្មទេសនាចប់សេចហើយ ក៏ទ្រង់ប្រជុំជាតកថា នាងវិជ្ជុលតាទេវី ពីកាលនោះ ឥឡូវនេះបានមកជាមាតានៃរាហុលកុមារ នាមនាងយសោធរា, ឯរាជទ្រសណ្ឆោះវរជោតិកុមារ បានមកជារាហុល, សុចិអាមាត្យបានជាអានន្ទពុទ្ធុបដ្ឋាក, ព្រះមមរិន្ទ្ធាធិរាជ បានជាភិក្ខុណ្ឆោះអនុរុទ្ធ មានចក្ខុទិព្វដ៏ឧត្តម, ព្រះបាទមហាសុរសេនរាជ ដែលមានព្រះទ័យត្រេកអរចំពោះទាន គឺអង្គព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ។ អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ មហាសុរសេនរាជជាតក ទី ១៤ ។



ផ្នែកអក្សរសាស្ត្រ

រឿងសៅវ៍សោយ

(សិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ជលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រាស្លឹកវិត

(តមក)

ទើបហោរគន់គូរ ដោយនូវគំនូរ ពុំយូរលង់ឡើយ បូកលេខសាយ សព្វ ត្រាន់ត្រប់ចប់ហើយ ពុំអែមង់ឡើយ ក្រាបហើយទូលថា ។

"បពិត្រនរបតី រីរ៉ត៍ក្សត្រី ចមស្រីធាយា បើតាមដំរាយ ទំនាយ ទាយថា នឹងមានកស្តា នៅនាធាប់ហើយ ។ ឯព្រះកស្តា ទំនាយ ទាយថា នៅនាបង្ហើយ ចូលមកនៅក្នុងទីក្រុងនេះហើយ ត្មានផៅនៅ ឡើយ ពិតហើយជាខ្សត់ ។ សព្វថ្ងៃអត់ឃ្មាន ធ្វើស្មូមសូមទាន ត្មានហានកំណត់ ជ្រកដោយរានផ្សារ តាមការក្រខ្សត់ ក្រោយទើបប្រាកដ កំណត់ចេស្តា" ។

ស្តេចស្តាប់ហើយនៃ ទ្រង់តូចព្រះទ័យ ពេកក្រៃណាស់ណា ទើប ទ្រង់រំពឹង ជញ្ជឹងគិតថា អះ! នេះម្តេចរ៉ ទើបជាយ៉ាងហ្នឹង!' ។ នឹកឡើង រឹងព្រួយ មានកូនតែមួយ ជាត្រួយព្រលឹង ខំតែថ្ងៃ លុះធំបុណ្ណឹង ព្រោះនឹករំពឹង ពំនឹងរាសនា ។ នឹកថាដល់ធំ មានគូផ្ទូផ្ទំ ស្ងួនសមសក្តា

នឹងបែងរំលែក ចាត់ចែករដ្ឋា ឲ្យត្រងសីមា ជាពាក់កណ្តាល ។ នេះម្តេច
ជូច្នេះ អក់ពូអីម្ចេ៉ះ ពុំចេះស្រកស្រាល បើគុកឲ្យនៅ តៈទៅយូរកាល
នាំឆ្នាសអម្បាល ញាតិពង្សវង្សា ។ ជម្រិះច្នេះសោត ព្រះអង្គទ្រង់
ក្រោធ ច្រឡោតណាស់ណា ទ្រង់បញ្ជាចេញ ឲ្យដេញធីតា ចាកពី
សីមា រដ្ឋាភជហាន ។ រីឯមហេសី សុទ្ធិវតី ប្រិមប្រិយកល្យាណ
ជ្រាបថាស្តេចក្រោធ ពិភេធពុំក្សាន្ត នាងទប់ពុំបាន ប្រះប្រាណ
សោកា ។ ទ្រង់ព្រះកន្សែង សោកយំចំបែង ថ្វាថ្ងៃងឡេញថា "ឧកូន
មាសស្ថូន ឆ្ងឹមឆ្ងួនមាតា ហេតុកម្មវាសនា ធីតាឯងហើយ ។ នេះគឺ
អំពើ ដែលនាងសាងធ្វើ ទេតើជាត្រើយ តាមស្នងសងផល អំពល់
ពុំស្បើយ ពុំយ្ងាតបាត់ឡើយ ទើបព្រាត់បុរី ។ ឧ! មាសស្នេហា
ព្រះវរបិតា ពុំត្រាប្រណី ពីដើមព្រះអង្គ ស្តេចទ្រង់ប៉ែតី ឥឡូវចក្រី
ឥតបីមេត្តា ។ ស្តេចពុំអាណិត ធ្វើតាមព្រាហ្មណ៍ព្រឹទ្ធ ជំនិតហោរា
ភចេះតែទាយ ទំនាយមុសា ស្តេចពុំចិន្តា សង្ការតិចឡើយ" ។ នាង
សោយសោកា អួលអន់ឧភ ទុក្ខាឥតស្បើយ ញ៉ូរអង្គចំប្រប់ សន្ធប់ជា
ត្រើយ លុះយូរតិចហើយ ទើបស្បើយឡើងឆ្នី ។ កាលបើស្រាក
ស្រាន្ត នាងយាងទៅថ្ការ ធ្លោះហានស្ងាមី អង្ងរព្រះអង្គ ឲ្យទ្រង់
ប្រណី អាណិតបុត្រី ស្រស់ស្រីកល្យាណ ។ "បពិត្រវរវង្ស
សូមទានព្រះអង្គ ស្តេចទ្រង់ប្រោសប្រាណ ឆ្ងំនឹងព្រះបង គ្រប់គ្រង
រដ្ឋហាន មានកូនកល្យាណ ១ប្រាណទៃន ។ ពុំគួរចក្រា ស្តេច
ជឿហោរា ប្ចស្យាចង្រៃ ហើយបណ្តេញកូន ឆ្ងឹមឆ្ងួនហប្ចទ៉ីយ ចេញ

ចាកវៀងជ័យ ឥតបីអាណិត ។ ទំនាយនេះណា ខ្ញុំម្ចាស់យើញថា ជាការពុំពិត បើមែនដូច្នោះ ក៏ព្រោះកម្មពិត ដែលពីអតីត(១) ខ្លួនគិត ខាងចាប ។ មួយទៀតជាតំស្រែ គោះមានស្វាមី ជាប្តីថោកទាប ក៏ស្រែចតែកម្ម ប្រចាំអត្តភាព ចាំនឹងស៊ប់ទាប តាមភាពវាសនា ។ បពិត្រវរេន្ទ្រ ចេះសូមព្រះអង្គ ស្តេចទ្រង់មេត្តា កុំបណ្តេញកូន ខ្ញុំមខ្លួនធីតា ចេញផុតរដ្ឋា ឡើយណាចក្រី ។ សូមទានព្រះទៅ ឲ្យសាងលំនៅ នាក្រៅបុរី ហើយឲ្យវាទៅ ជ្រកនៅនោះឯ គោះម្តេចៗ ក្តី ពាសីផងវា” ។

ព្រះចាខចក្រី ស្តាប់សំដីមហេសី មានក្តីមេត្តា ទើបគ្រាន់តែ ត្រាស់ ដេញព្រះធីតា ចេញពីសីមា ទៅនៅក្រៅកំផែង ។ មហេសី ស្តាប់ច្បាស់ ក្រាបលាវហ៍ស រលេះរលាំង ទៅរកកូនស្រី ក្សត្រី គាន់គាំង ឧបកូនហើយគាំង សោកាថ្លាថ្ងែង ។

បទព្រហ្មគីត (២)

កាលណោះព្រះមាតា សោយសោកាមហាចំមែង
នាងទួញទំនួញថ្ងែង សោកកណ្តែងវែងប្រមាណ
“ឱ! កូនសួនដ៏ពាំ ឥតនរណាជាតិរុក្ខា
គ្រាប់ចរកង៏ស្នាន ព្រាត់ពីឋានដ៏ក្សត្តេ ។

---

១ អានថា អៈទិត ។ ២ បទនេះ មួយឃ្លាមាន ១១ ពាក្យ, ៤ ឃ្លាត្រូវដាក់ ១ខ្នុសញ្ញា ១ ។ បទព្រហ្មគីតនេះ ត្រូវគ្នានឹងបទឥន្ទវជិរឆន្ទ ឬ បទយាតីខាងថាលី ដូច យោសន្ធិសិនេ្ទ ឬ យាតីធរូតានិ ។ ដូច្នេះ តាមត្រូវ ក្នុងឃ្លាមួយៗ មិនត្រូវកាត់ដា ២ កំណាត់ ដូចដែលធ្លាប់ឃើញមកនោះទេ ។

ឧ! បុត្រវិស្សុតស្ងួន　　មាសឯមឯនន្ងួនធោមធ្វៅ
ព្រាត់ធ្វាយពីម្ពាយទៅ　　ឲ្យម្ពាយនៅសៅឯកា
កាលកូនស្ងួននៅឡើយ　　ម្ពាយបានស្ស៊ីយល្ហើយឧកា
ឥឡូវព្រះបូវណា　　ពុំមេត្តាត្រាប្រណី ។
មិនសមព្រះបមពង្ស　　ស្តេចពុំទ្រង់ប្រោសបុត្រី
អាក្រក់ល្អម្តេចក្តី　　កម្មកូនស្រីស្រេចហើយណា
ហេតុម្តេចស្តេចក្ងេចគិត　　ពុំអាណិតចិត្តធីតា
ទោះអាប់យ៉ាប់ម្តេចម្ពា　　ពុំគួរណាដាច់ព្រះទ័យ ។
ឧ! កូនៗ មាសម៉ុម　　នាងធ្វាប់ផ្ទំៗ សព្វថ្ងៃ
លើត្រែៗ មាសម័យ　　ឥឡូវថ្ងៃៗ ព្រាត់ធ្វាយ
ទៅនៅក្រៅស៊ីមា　　តែឯកាណា មាសម្ពាយ
គេងលើទីទាំងឡាយ　　ដែលគួរណាយអនាថា ។
នាងធ្វាប់តែចាប់សោយ　　នូវព្រះស្វាយធ្វាញ់ពីសា
ក្នុងចានសុវណ្ណា　　ដ៏ថ្ងៃថ្ងាដាប្រក្រតី
តទៅត្រូវកោក្ពា　　តែផលាដាបំណី
រាល់ពេលរាល់រាត្រី　　ពុំគួរអ្វីស្រីរងកម្ម ។
ធ្វាប់គង់ក្នុងប្រាងប្រា-　　សាទស្អាតថ្ងាដាប្រចាំ
គំនាល់គាល់ធ្វេងស្ពាំ　　ចាំបំរើដាធម្មតា
ពេលនេះស្រស់ពាលពៅ　　ត្រូវទៅនៅក្នុងគេហា
កណ្ណាងឯងឯកា　　គ្មានន្រណាដាពីរប្រាណ ។

នរណានឹងអាណិត　　មកជាមិត្តស្មិទ្ធជិតហាន
នរណានឹងស្មោះស្មាន　　នាំកល្យាណសោយកោជន
កូនអើយពីបុព្វេ　　ប្រហែលមេសាងកម្មផ្ទន់
ទើបពៅត្រូវមកធន់　　ទុក្ខទូរន់ផ្ទន់ឥតបី ។
មុនកូវពៅធ្លាប់ចរ　　ដោយព្រះវមាសណាស្រី
តទៅពៅពីស៊ី　　ត្រូវឃ្មាតឱ្ងដោយបាទា
នាងធ្លាយពីម្តាយទៅ　　ឲ្យម្តាយនៅសៅកំព្រា
រងទុក្ខរងវេទនា　　ស្លាប់ទៅជារាតឃ្យី" ។
　កាលដែលព្រះជាយា　　សោកពណិនាជាសេចក្តី
ធីតាថ្លាពីស៊ី　　នាងឥតបីនឹងទប់បាន
ទឹកនេត្រហូរហៀរធ្លាក់　　ស្រោចព្រះកត្ត្រអ្នកកល្យាណ
នាងសោកអាមោកថ្ពាន　　ទ្ធញ្ញប្រះប្រាណពុំមានស្ឈីយ ។
ឧបបាទព្រះមាតា　　ទ្ធញ្ញទូលថាព្រះមេអើយ
នេះគឺកម្មកូនហើយ　　ពុំបាត់ទ្ឈីយតាមមកស្នង
ទើបកូនត្រូវព្រាត់ប្រាស　　ឃ្លាតនិវាសពេលនេះម្តង
ចាកទៅដោយសៅហ្មង　　ខុសបំណងផងមាតា ។
ព្រះមែខំថែធ្ងន　　ឲ្យកូនស្ទួនបានសុខា
តាំងពីទារិកា　　លុះដល់ត្រាធំប៉ុណ្ណឹង
សូមទ្រង់កុំសោកា　　តាំងចិន្តាក្លាវឹងបុឹង
នឹកថាចិញ្ចឹមហ្នឹង　　ដោយរំពឹងយកតែបុណ្យ ។

ពោះបីឱ្យអម្ចាស់ ជានក្រឡាស់មកតបគុណ
ឬក៏ទកស្ពកស្ពុន សូមព្រះគុណប្រោសផង៉
សូមទ្រង់កុំទុក្ខឡើយ កូនលាហើយ ! ណាម៉ែណា+ !
ពោះសុទទុក្ខម្ពេចម្ពា តាមយថាកម្មបុព្វេ" ។
ត្រាស់ចប់ជ្រប់កក្ត្រា លើជាតានៃព្រះមេ
ពេលនោះក្សត្រតាំងទ្វេ មិនអត់ទេតាំងកន្សែង
នាងនាថនឹងមាតា សោយសោកាមហាកណ្តែង
យោបំយំចំបែង សោកថ្ថាថ្ថែងរែងប្រមាណ ។
លុះលន់ទន់សន្ធប់ ក្រាបស្ទ្រមស្ទប់សព្ទ ។ ជ្រាណ
យូរសល់ទើបកល្យាណ តាំង ៦ ជ្រាណជានស្មារតី
ពេលនោះព្រះមាតា មានបញ្ញាសវនីយ៍
ត្រាស់ប្រើក្រុមវឌ្ឍកី(1) ឲ្យឃ្មាតឱ្មីសាងដំណាក់ ។
មួយឱ្មងនៅក្រៅក្រុង ទុកបំរុងអនង្គល៍ក្ខណ៍
ត្រាន់នឹងនៅពឹងពាក់ ជានសំណាក់ស្មាក់អាស៍យ
ហើយចាត់អស់បរិវារ នឹងបរិក្ខារជាប្រើនក្រៃ
មាសពេជ្រកែរចរណៃ អាវសាវស្សឲ្យធីតា ។ (មានត)

---

1 វឌ្ឍកី ប្រែថា ជាង, ជាងឈើ ។

ជឿងសាមកុក

កណ្ឌទី ២១

ឧកញ៉ាវិបុលរាជសេនា ន្ធ-កន ប្រែជៀបជៀង

(តមក)

ជឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ឯទីប្រឹក្សាទាំងពួងក៏និយាយនឹងឡៅពៀវថា យីអេងពោលទ្រតោះ
មើលងាយលោកខ្ចាំងណាស់ ហេតុម្តេចបានជាលោកមិនសម្ចាប់ចេញ។ ។
ឡៅពៀវតបថាយើងជឹងដំណឹងថា យីអេងនេះមានជំរេះប្រាជ្ញា វៃជា
មនុស្សគ្មានអធ្យាស្រ័យសោះ, កាលនៅក្នុងស្រុកហ្ចូតោនោះ ក៏បាន
ពោលទ្រតោះមើលងាយចូធូជាប្រើនលើក ចូធូ៧ស្សាហ៍ត្រាំអត់សង្កត់ចិត្ត
មិនបានសម្ចាប់យីអេង ព្រោះវអែងខ្ចាចមនុស្សទាំងពួង នឹងតរហានិន្ទា
ប្រការ ១ ទៀតបើមានអ្នកឯណាចូលមកយកអាសាធ្វើការជាមួយផង ក៏
វមែងស្ទើរចិត្តជ្ឋិតយើញសម្ចាប់មនុស្សល្អ បានជាចូធូក្ងែងប្រើយីអេងមក
បញ្ចុះបញ្ចូលយើង ប្រាថ្នាដើម្បីនឹងខ្ចីដៃយើងឲ្យសម្ចាប់យីអេងចេញ នឹង

ឲ្យសេចក្តីគាក្រក់នោះធ្លាក់មកលើយើង ។ ត្រូវក្លែងឲ្យយីអេងឡេបញ្ចុះ
បញ្ចូលហងច ព្រោះហងចចិត្តស្រាលរហ័សគ្មានអ្វីទប់ បើយីអេងឡេ
និយាយទ្រំគោះបោះបោកឲ្យហងចប្រការម្តេច ហងចក៏នឹងសម្ងាប់យីអេង
មិនខាន បើដំណឹងនេះដឹងឡេជល់ចូធូរៀលាណា យើញថាចូធូនឹងកោត
ខ្ជាចគំនិតយើងថា យើងដឹងជល់គំនិតចូធូ ។

ទីប្រឹក្សាតំងពួងក៏សរសើរឡៀពៀវថា មានប្រាជ្ញាឈ្លាសវៃស្រ-
ដីថា លោកគិតនេះត្រូវល្អណាស់ ។ ឧណៈនោះ មានបំរើអ្ជីនសៀវកាន់
សំបុត្រមកឲ្យឡៀពៀវ សេចក្តីថា "ឲ្យឡៀពៀវជួយគិតការទំនុកបំរុង
ផែនដី" ។ ឡៀពៀវក៏ប្រឹក្សានឹងសេនាតាហានតំងពួងថា ចូធូនឹង
អ្ជីនសៀវជាសត្រូវនឹងគ្នា ឥឡូវចូធូនឹងអ្ជីនសៀវឲ្យមកបញ្ចុះបញ្ចូលយើង
តំងសងខាង តើអ្នកតំងពួងនឹងយល់យើញប្រការម្តេច? ។

ហាន់សុងធ្វើយថា ចូធូនឹងអ្ជីនសៀវគ្រានេះជាគោសតាស់ធ្វើ
សង្គ្រាមនឹងគ្នា បើលោកមិនចូលឡេខាងណា នឹងគិតឲ្យជាប្រយោជន៍
ចូរមើលកលការ បើយើញខាងណាក្លាត់ចំណាប់ត្រូវលោកលើកកងទ័ព
ឡេព្ជតរាយខាងណោះយកស្រុកឲ្យបាន តែឱ្យាទខ្ជាចក្រែងនៅ ១ ១ ថា
ចូធូនោះមានសតិបញ្ញាច្រើនណាស់ ឈ្លាសយល់តំងក្ស្ជនពិជ័យសង្គ្រាម
ស្ជាញស្ជាត់ជាងអ្ជីនសៀវ ហើយចេះចិញ្ចឹមរក្សាមនុស្សល្អមានលក្ខណៈ
តាមវិជ្ជានឹងថ្វីដៃមនុស្សតំងពួងក្នុងផែនដី ក៏ចុះចូលឡេនៅនឹងចូធូជា
ច្រើនមិនជាប់សោះ ឱ្យាទយល់យើញថា ចូធូនោះ នឹងធ្វើការសឹក
សង្គ្រាមគង់មានជ័យជំនះអ្ជីនសៀវមិនខាន បើចូធូបានស្រុកគីជីវហើយ

មុខជាលើកកងទ័ពទៅវាយយកស្រុកធំ ៗ ខាងទិសឯកើតរហូតដល់ស្រុក
កាំងតាំង ទោះយ៉ាងណាក៏គទល់នឹងចូធូមិនបាន សូមឲ្យលោកស្ម័ត្ត
រាប់អានចូលទៅខាងចូធូចុះ មុខជាចូធូនឹងទំនុកបំរុងលោកជាប្រក្រតី
តទៅ ។

ឡៅពៀវធ្វើយថា បើដូច្នោះចូរអ្នកចេញទៅសើបស័ព្ទស្តាប់ការណ៍
ក្នុងក្រុងហ្ចូតោចុះ បើដឹងការណ៍យ៉ាងណាហើយ ចូរអ្នកវិលត្រឲ្យប់មក
ប្រាប់យើង ៗ នឹងបានត្រិះរិះគិតការណ៍នេះតទៅទៀត ។ ហាន់សុងជំរាប
ថាដែលលោកនឹងប្រើឲ្យទៅយ៉ាងម្តេច ខ្ញុំបាទមិនទទឹងនឹងប្រសាសន៍ទេ
ខ្ជាចតែព្រះចៅហ្រានតេនឹងជប់លៀង ឲ្យខ្ញុំធ្វើនាហ្ចឹនខាងក្នុង នឹងមិនបាន
ត្រឲ្យប់មកជាគឿនស្ថាប់រស់ជាមួយនឹងលោក មុខជាលោកមានសេចក្តី
សង្ស័យនឹងខ្ញុំបាទ ។ ឡៅពៀវតបថា ដែលអ្នកនិយាយដូច្នេះគួរ
ហើយ តែថាទោះបីយើងនឹងនៅឆ្ងាយពីគ្នាយ៉ាងណា ក៏ត្រូវឲ្យមានចិត្ត
ស្រឡាញ់គ្នាយ៉ាងជិតស្និទ្ធដូចជីវិត ១, ដែលអ្នកនឹងទៅនោះ បើបានដឹង
កិច្ចរាជការអ្វី ៗ ខ្លួនមិនបានមក ក៏ត្រូវផ្ញើសំដីដោយសំបុត្រលិខិតមកដល់
យើងឲ្យដឹង ដើម្បីនឹងបានគិតការតទៅ ។

ហាន់សុងក៏លាឡៅពៀវចូលទៅស្រុកក្រុង លុះដល់ហើយក៏ចូល
ទៅតំនាប់ចូធូ ៗ ឃើញហាន់សុង ទៅដល់ក៏ទទួលដោយអំណរគួរសម
ណាស់ សាកសួរសុខទុក្ខយ៉ាងស្និទ្ធស្នាល ហើយតាំងឲ្យធ្វើជានាហ្ចឹន
ខ្ញុំរាជការក្នុងព្រះចៅហ្រានតេ ហើយឲ្យស្រុកឡេងឡេងឡើងស្តាប់បង្គាប់
ហាន់សុង ។ ស៊ុនហុកទើបចូលមកទ្យិបសួរចូធូថា ខ្ញុំបាទឃើញថា

ឡៅពៀវប្រែហាន់សុង៑ឲ្យមកស៊ើបស្តាប់ការជាសម្ងាត់ ខ្ញុំហាន់សុង៑មិនទាន់មានគុណបំណាច់អ្វីនឹងលោកសោះ ហេតុម្តេចបានជាលោកតាំង ហាន់សុង៑ឲ្យធ្វើនាហ្នឹងបានខៃត្បែងឡែងឡើងស្តាប់បង្គាប់ ប្រការ១ យើអេង៑ដែលឡៅបញ្ចុះបញ្ចូលឡៅពៀវនោះ ក៏នៅមិនទាន់បានសេចក្តីអ្វីមកដល់លោក។ ក៏មិនបានសួរការណ៍នេះដល់ហាន់សុង៑សោះ ។

ចូធូតបថា "យើអេង៑នោះអាក្រក់ដូចជាតិប្រមាថមើលងាយយើង៑ជាច្រើន យើង៑មានចិត្តខឹង៑ក្តៅនៅជាប់ បើនឹង៑សម្លាប់វាចេញមនុស្សទាំងពួងនឹង៑គេហាន់ខ្លាថា យើង៑មានវាសនាធ្វើធំតំហែង៑អ្នកតូច បានជាយើង៑ប្រែឲ្យឡៅបញ្ចុះបញ្ចូលឡៅពៀវ ប្រាថ្នានឹង៑ខ្លីដៃឡៅពៀវឲ្យសម្លាប់យើអេង៑ចេញ ដែលនឹង៑សួរដំណឹង៑នោះ ក៏មិនជាការប្រយោជន៍អ្វី" ហើយចូធូក៏បង្គាប់ហាន់សុង៑ឲ្យវិលទៅស្រុកគេង៑ដីវិញ ឲ្យបញ្ចុះបញ្ចូលឡៅពៀវមកចូលធ្វើពជការនឹង៑យើង៑ឲ្យបាន ។

ហាន់សុង៑ទទួលពាក្យចូធូ ហើយក៏លាត្រឡប់ទៅស្រុកគេង៑ដីវ លុះទៅដល់ហើយក៏អធិប្បាយរឿង៑ដែលចូធូនិយាយ ទឹង៑តាំង៑ខ្ញុំឲ្យធ្វើនាហ្នឹងនោះឲ្យឡៅពៀវស្តាប់គ្រប់ប្រការ ហើយថា ចូធូនោះមានចិត្តចូរច្រូលយួរស្រពយកបំអានមនុស្សទាំងពួង គួរណាស់លោកនឹង៑ចូលទៅធ្វើពជការជាមួយផង សូមឲ្យលោកចាត់យកបុត្រលោកចូលទៅថ្វាយជាខ្ញុំព្រះចៅហៀនតេ នឹង៑បានធ្វើពជការជានាហ្នឹងតទៅ ។ ឡៅពៀវបានឮដូច្នេះក៏ខឹង៑ណាស់និយាយថា "ខ្ញុំមិនយកសេចក្តីអាថ៌កំបាំង៑របស់យើង៑ទៅប្រាប់ចូធូហើយឬ? បានជាចូធូតាំង៑ឲ្យខ្ញុំធ្វើជានាហ្នឹង,

ដែលខ្ជនគិតធ្វើការយ៉ាងនេះ ក៏យើញថាទូរយសនឹងយើង" ហើយ
បង្គាប់ឲ្យចាប់ខ្ជនហាន់សុងទៅសម្ងាប់ ។ ហាន់សុងធ្វើយថា ខ្ញុំបាន
នឹងគិតប្រទូសរ៉ាយចំពោះលោកក៏ទេ នឹងបានលះបង់ចោលលោកក៏ទេ
ហេតុម្តេចលោកត្រឡប់លះបង់ចោលខ្ញុំបាទវិញ ។

កេងលៀងបានញ្ជូជ្នោះ ក៏និយាយនឹងឡៅពៀវថា កាលលោក
ប្រើហាន់សុងឲ្យទៅនោះ ហាន់សុងក៏បានធ្វើយដំរាបលោកទុកថា ដែល
លោកឲ្យចូលទៅស្រុកក្រុងក្រែងលោកនៅមានសេចក្តីសង្ស័យ លោក
ក៏បានថាមិនមានសង្ស័យអ្វីទេ បានជាហាន់សុងទៅ ឥឡូវហាន់សុង
ត្រឡប់មកវិញ ជូនដំណឹងកិច្ចរាជការឲ្យលោកជ្រាបតាមពិត, ដែល
លោកមកប្រើឲ្យគេសម្ងាប់ហាន់សុងចេញ មិនស្ងរសោះ ។ ឡៅពៀវ
យល់ថាខ្ជនគិតខុសក៏ព្រមលើកទោសហាន់សុង ។ ខណៈនោះទទួលបំរើ
សេះមកប្រាប់ឡៅពៀវថា យីអេងដែលទៅនិយាយបញ្ចុះបញ្ចូលហងច
ចៅហ្វាយស្រុកកាំងហែនោះ ហងចរៀបតុលៀងអាហារឲ្យយីអេងបរិ-
ភោគតាមទំនៀម លុះសេពសុរាស្រវឹងផងគ្នា ហងចក៏ស្ងរយីអេងថា ក្នុង
ក្រុងហ្ចូតោនោះ អ្នកបានយើញនាហ្ចឹនណាមានសតិបញ្ញាជ្រៅទូលាយ
ខ្ងះ យីអេងប្រាប់ថា ខុងយ៉ុងនឹងអៀវពីវ ២ នាក់នេះ សុទ្ធតែមានដំរេះ
ចេះគិតគូរត្រាន់បើ ក្រៅពីនេះមិនយើញមាននរណាសោះ ហងចថា
ដំរេះខុងយ៉ុងនឹងអៀវពីវហើយនឹងដំរេះយើងនេះ អ្នកឯងយើញជាយ៉ាង
ម្តេចពីគ្នាខ្ងះ? យីអេងថា ដំរេះអ្នកឯងនេះ៖ បមាដូចជាដុំថ្ងនៅក្នុងខ្ជម
ទេពារ៉ក្ស ទោះនឹងមានគេមកសែនព្រនថាប្រការម្តេច ដុំថ្ងនោះក៏មិន

ចេះធ្វើយតនឹងអ្នកដែលបួងសួងនោះទ្បើយ ។ បមាដូចជាសំពះដុំឈើ ១ កំណាត់ ហងចបានញ្ចដូច្នោះក៏ទឹងទ្ចាំងណាស់ ហូតក្រប៉ីចេញហើយ ក៏លើកទ្បើងកាប់យីអេង ។ ដេរប្រទេចហងចតាល់តែដាច់ទ្យល់ស្ទាប់ ។ ទ្បៅពៀវបានស្ទាប់ដូច្នោះក៏មានចិត្តអាណិតយីអេងណាស់ ប្រើមនុស្ស ឲ្យទៅរៀបសង្ការសពកប់យីអេង ទុកនៅតំបន់អើងប្ចីជីវ ឯទ្បៅពៀវ នោះក៏មិនបានគិតនឹងចូលទៅទាងចូធូទេ ។

កាលចូធូញ្ចដំណឹងថាយីអេងស្ទាប់ ក៏អស់សំណើចហើយនិយាយថា យីអេងនេះជាមនុស្សអាក្រក់ណាស់ មាត់របស់រាជាអាវុធសម្ទាប់ទ្ចូនរាទៅ ឯង ។ ទណ:នោះចូធូនៅចាំស្ទាប់ដំណឹងទ្បៅពៀវ តែមិនបានដំណឹង ប្រការម្តេចសោះ ទេបប្រមូលសេនាតាហានតាំងពួងនឹងលើកទ័ពទៅ រាយយកស្រុក កងជីវ ។ ស៊ុនហុកក៏ហាមយាត់ចូធូថា អ្ជិនសៀវមាន កំឡាំងច្រើនណាស់តាំងទ្បៅពីក៏ប្រែគំនិតចិត្តចេញពីលោកទៅផង មុទ ជាចូលគំនិតគ្នានឹងអ្ជិនសៀវ ត្រូវតែគិតបង្ក្រាបអ្ជិនសៀវនឹងទ្បៅពីឲ្យ រៀបតាបចេញសិន សឹមលើកទ័ពទៅប្រាបប្រាមទ្បៅពៀវនឹងបាន ដោយងាយ ។ ចូធូយល់ឃើញត្រូវ ក៏គិតថានឹងលើកកងទ័ពទៅច្បាំង នឹងអ្ជិនសៀវ, ទ្បៅពី, តែសេចក្តីនេះចូធូមិនតាន់ប្រឹក្សានឹងអ្នកឯណា ក៏បង្អង់នៅស្ទៀម ។ លុះព្រះចៅហៀនតេស្ទេចទៅគង់ក្នុងស្រុកហ្ចូតោ បាន ៥ ព្រះវស្សាហើយ ទណ:នោះជាទេសកាលទៃមាយចូលធ្នាំចិន ចូធូ នឹងនាហ្ចឺនមុទមន្ត្រីទ្ចុំរាជការតាំងឡាយ តាក់តែងផូបទៀនមានផ្ការឈើ នឹងគ្រឿងប្រដាប់ចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេតាមទំនៀម ។

តាំងសុំនទឹងមន្ត្រីតាំងពួង យើញចូឆ្លូផ្ទៃបុកតាមិនកោតខ្លាចមិនចង់ថ្វាយ
បង្គំព្រះចៅហៀនតេ នាហ្នឹងដែលមានចិត្តសុចរិតទៀងត្រង់ទឹងផែនដី
កំនាំគ្នាខឹងក្តៅទឹងចូឆ្លូជាច្រើន លុះព្រះចៅហៀនតេស្តេចយាងចូល
ហើយ ចូឆ្លូទឹងបណ្តាខ្ញុំពជការតូចធំកំនាំគ្នាត្រឡប់ទៅផ្ទះ ។ ឯតាំង-
សុំននោះ តាំងពីក្រោយទៀតពីលើកទ័ពចេញទៅ តាំងមាំថេងក៏លើក
ទ័ពចេញទៅក្រុងសេលៀងៈទៀត តាំងសុំនទឹងជូហុក, ជូឡាន់, តាំងអ៊ុច,
ដោ៉ហួនលបគិតគ្នាពល់ៗថ្ងៃដើម្បីទឹងរំលាយបំផ្លាញចូឆ្លូ តែមិនសមតាម
សេចក្តីប្រាថ្នា តាំងអស់គ្នាក៏មានបរិវិតក្តក្តុក្តួគោមនស្សមិនដេក មិនស៊ី
ឲ្យសប្បាយ, តាំងសុំននោះក៏បណ្តាលដម្ងីក្តៅក្រហាយដេកឈឺក្នុងផ្ទះ ។

ព្រះចៅហៀនតេទ្រង់ជ្រាបថា តាំងសុំនមានជម្ងឺឈឺ ក៏ត្រាស់ប្រៃ
ភៀតបុំងជាវេទ្យហួងឲ្យទៅព្យាបាលអាការរោគតាំងសុំន ភៀតបុំងក៏
ទៅព្យាបាលតាំងពេលយប់ពេលថ្ងៃ យើញតាំងសុំនដេកដកដង្ហើមធំ
រឿយ ។ ក៏ដឹងថាមិនមែនជម្ងឺធម្មតាគឺរោគឈឺចិត្ត ភៀតបុំងមិនអាចសួរ
សាកប្រការម្តេចបាន លុះព្រឹកឡើងថ្ងៃ ១ នោះ ភៀតបុំងក៏និយាយទឹងតាំង
សុំនថា ថ្ងៃនេះខ្ញុំបាទសូមលាលោកទៅ ស្អែកសឹមត្រឡប់មកវិញ ។
តាំងសុំនក៏និយាយឃាត់ថា ថ្ងៃនេះអ្នកកុំអាលទៅឡើយ នៅដេកទឹង
យើងមួយយប់សិន តាំងសុំនក៏ឲ្យរៀបតុៈលៀងអាហារ ហើយអញ្ជើញ
ភៀតបុំងមកផឹកស្រាជាមួយគ្នា ។ តាំងសុំនបរិភោគកាលណា ក៏គិត
ដល់សេចក្តីដែលគិតពុកនោះឲ្យព្រួយរំខានពន់ប្រមាណណាស់ ធ្វេស
ស្មារតីទំរេតខ្លួនលក់លើកៅអីតាំងទៅ យល់សប្តិឃើញថា « ជូហុក,

ជូឡាន់, តាំងអ៊ុប, ដ៉ោហ្ជន ៤ នាក់នេះ នាំគ្នាមកកតាំងស៊ុនឯផ្ទះហើយ
ប្រាប់ថា ឥឡូវអ្ជនសៀវនឹងឡៅពីលើកតាហាន ១០ ម៉ឺនចូលមកពីទាង
ទិសឯត្ស្យង មា៉ថែងនឹងហាន់ស៊ុយលើកតាហាន ៧២ ម៉ឺនចូលមកពីទិសឯ
ជើង នឹងមកឈយយកស្រុកហ្ជូតោ ឯចូធ្ជូក៏លើកតាហានចេញទៅត
ទល់ទាងក្រៅកំពែងស្រុកតាំង ៦ តំបន់ ក្នុងស្រុកនោះនៅតែចូធ្ជូនឹងកូន
តាហានប្រមាណ ៩-១០ នាក់ តាំងស៊ុននឹងមន្ត្រី ៤ នាយក៏ពាក់ក្រិស
ជិះសេះកាន់អាវុធត្រប់ដៃ ហើយលើកតាហានទៅជល់មុទផ្ទះនោះ ឃើញ
ចូធ្ជូកំពុងអង្គុយជឹកស្រា តាំងស៊ុនក៏បរសេះជម្រង់ចូលទៅយកក្រប៉ីកាប់
ក្បាលចូធ្ជូជាច់ជ្ជាក់ពីលើស្មាស្ជាប់ ហើយតាំងស៊ុនជេរចូធ្ជូថាអាក្សត់"
ទណ:នោះតាំងស៊ុនក៏មានចិត្តត្រេកអរសប្បាយ ក្រាក់ជឹងទ្ជូនហើយក៏
នៅជេរចូធ្ជូមិនឈប់មាត់ ។

កៀតប៊ុងបានឃើញតាំងស៊ុនមមើជេរចូធ្ជូជ្ជាះ ក៏ជឹងថា តាំងស៊ុន
មានចិត្តស្អប់ចូធ្ជូ ប្រុងនឹងប្រទូសក៉យចូធ្ជូ កៀតប៊ុងក៏ជជីកស្ជរតាំងស៊ុនថា
លោកប្រុងនឹងធ្ជើអន្តរាយមហាទបរាជប្ជ ! ទ្ជុំនឹងនាំយកសេចក្តីនេះទៅ
ប្តឹងឲ្យមហាទបរាជជ្រាប ។ តាំងស៊ុនបានឡកៀតប៊ុងថាជ្ជាះ ក៏ក៉យ
ស្ជុតស្មាវតីមិនធ្ជើយតបថាអ្ជីសោះ ។ កៀតប៊ុងឃើញតាំងស៊ុនក៉យទ្ជាច
ជ្ជាះក៏និយាយថា លោកកុំក៉យទ្ជាច ទ្ជុំបាទថាជ្ជាះព្រោះចង់ពិសោធ
ចិត្តលោកទេ សព្ជាថ្ជៃនេះទ្ជុំបាទគ្រាន់តែធ្ជើពេទ្យ តែជ្ជងចិត្តគិតនឹងតប
ស្នងគុណព្រះចៅហ្ជានេតជាជរាប ដែលទ្ជុំបាទមកនៅព្យាបាលរោគ
លោកយ្ជូរថ្ជៃ ហើយមិនបានជឹងប្រាកដថា រោគលោកនោះកើតអំពីអ្ជី

ឃើញលោកចេះតែដដកដ្ហើមធំរឿយ ៗ ខ្ញុំបាទក៏មិនអាចហានសួរ ឥឡូវខ្ញុំ
បាទបានឃើញលោកមមើដេរចូធូ ក៏ត្រូវត្នានឹងដកដដ្ហើមធំ ឯការដែល
លោកតិតទុកប្រការម្តេចនោះ ចូរលោកកុំលាក់ឡើយប្រាប់ខ្ញុំបាទឲ្យ
ត្រង់មកចុះ បើល្មមខ្ញុំបាទនឹងទទួលធ្វើបាន ខ្ញុំបាទក៏ទទួលយកអាសា ។

តាំងសុិនបានញ្ជកៀតបុឹងនិយាយដូច្នោះក៏យំហើយថា យើងបារម្ភ
តែចិត្តអ្នកនឹងមិនដូចមាត់និយាយ ការដែលយើងតិតទុកនឹងទូចអសារ
ឥៅ ។ កៀតបុឹងធ្វើយថា "បើលោកសង្ស័យខ្ញុំបាទនឹងធ្វើឲ្យជាបន្ទាល់
ច្បាស់" និយាយហើយកៀតបុឹងក៏យកក្រប៊ីកាត់ម្រាមដៃ ឲ្យលោហិត
ហូរចេញមកជាក់លាយនឹងស្រាក្នុងពែង ហើយលើកឡើងស្បថសច្ចាថា
"ខ្ញុំបាទមានចិត្តសុចរិតត្រង់នឹងផ្ទែនដី បើមានសេចក្តីរៀចក្នែងបញ្ជោត
លោក ក៏សូមឲ្យជីវិតខ្ញុំបាទអន្តរាយដោយអាវុធផ្សេង ៗ ចុះ" លុះសច្ចា
ហើយកៀតបុឹងក៏ធឹកអស់ឥៅ ។ តាំងសុិនបានឃើញកៀតបុឹងស្បថសច្ចា
ជាទីអស្ចារ្យដូច្នោះក៏ស់សង្ស័យ ទើបយកឡាយព្រះហស្តមកបង្ហាញឲ្យ
កៀតបុឹងមើល ហើយថា "ដែលយើងរួមតំនិតតិតត្នានឹងកចាត់ចូធូចេញ
នោះ ៧ នាក់ទាំងខ្លួនយើង ឥឡូវឡៅពីនឹងម៉ាថេងក៏ចេញពីស្រុកក្រុង
អស់ឥៅហើយ នៅតែយើងនឹងមន្ត្រីមានឈ្មោះ ៤ នាក់បានជាតិតការ
មិនផ្ទុះធ្លាយ យើងក៏ឥៅជាឈឺព្រោះហេតុនេះ ។ កៀតបុឹងឃើញ
ឡាយព្រះហស្តព្រះចៅហៀនតេ ហើយស្តាប់ពាក្យតាំងសុិននិយាយ
ដូច្នោះ ក៏ធ្វើយតបថា ការដែលនឹងតិតធ្វើអន្តរាយ ចូធូនោះ ទុកជាកិច្ច
ធុរៈលើខ្លួនខ្ញុំបាទចុះនឹងទទួលយកអាសា ។ (មានត)

ដំណឹងតាមឲ្យល់ក្នុងកាន្តារ:

លោកផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីកាសាបារាំងមកជាកាសាខ្មែរ

(តមក)

ខណៈនោះ អ៊ីស្មាអ៊ីលចូលទៅជិតនាងនារីឡីឡា ហើយនិយាយប្រាប់ដោយសុន្ទរវាចាប្រកបដោយមុទុចិត្តថា:

– "បើអូនយ្ងាន ចូរទារវត្ថុដែលពេញចិត្តពីលោកតានេះ ។ ផ្ទៃឈើក្នុងសួន សម្រាប់បំបាត់ការស្រេករបស់អូន, បន្ទៃក្នុងចំការ សម្រាប់បំបាត់ការយ្ងានរបស់អូន, រឿងព្រេងរបស់តាឡិប សម្រាប់ធ្វើឲ្យអូនរីករាយបាត់អផ្សុក, នែឡីឡាមាសបង! ចូរអូនគេងជាសុខ ចូរមានក្តីទុកចិត្តលើរូបបងជាសំឡាញ់ចុះ" ។

នាងឡីឡាស្ទុះទៅចាប់ដៃអ៊ីស្មាអ៊ីលហើយថើបដោយកតញ្ញូ លុះនាងដើបមុខឡើង អ្នកកំឡោះឃើញជលនេត្ររលងរលោងក្នុងក្នែកទាំងពីររបស់នាង ។

អ៊ីស្មាអ៊ីលខ្ចល់ក្នុងចិត្តពេក ទើបស្ទរភ្ទាមថា:

– "អូនមានទុក្ខដូចម្តេច?" ។

នាងឡីឡាយំអណ្តឹតអណ្តក ហើយនិយាយប្រាប់ពីដំណើរបងស្រីដែលនៅតែម្នាក់ឯងក្នុងវាលខ្សាច់ ។

– "ឧព្រះគុណម្ចាស់ថ្ថៃ! ខ្ញុំសូមអង្វរលោក សូមលោកមេត្តាជួយស្រង់ជីវិតបង្ស្រីខ្ញុំផង!" ។

អ៊ីស្មាអ៊ីលប្រាប់ថា:

– 'បង្សមសន្យាថានឹងទៅរក ពេលស្អែកពីព្រលឹម ។ យប់នេះហួសហើយមើលអ៊ីមិនឃើញទេ កណ្ណាលផ្ទូរខ្យាច់ ។ តែបង្ងនឹងចេញទៅរកមុនព្រះអរុណរះបញ្ចាំងរស្មីមកលើព្រះធរណី ។ នៃឡីឡាមាសព្រលឹងបង! ចូរអូនស្ងៀមចុះ សូមព្រះអាឡស់ជួយរក្សាខ្លួនអូននឹងជនទាំងប៉ុន្មានដែលអូនតាប់ចិត្ត" ។

អ៊ីស្មាអ៊ីលឈប់បង្អង់នៅក្បែនោះយូរបន្តិច ដោយគេចង់ដឹង តើតាឡិបលាក់នាងទុកត្រង់ណា ។

តាឡិបមានឡាំងសម្រាប់ដាក់ស្មៅសេះមួយនៅសល់ទំនេរ ។ ក្នុងឡាំងនោះគាត់ដាក់ផ្ទយរបស់គាត់ ។ បើប្រសិនជាខ្ចាចក្រែងចូលទៅក្នុង ហើយរាហប់ត្មានខ្យល់អាកាស ដែលនាំបណ្ណាលឲ្យជកដង្ហើមមិនស្រួល គង់នៅមានអានសេះ តែបសេះជាច្រើនដែលអាចដាក់បង្ករបំបាំងបានដោយត្រឹមត្រូវ ។

កាលណាកិច្ចការរៀបចំស្រេចអស់ហើយ កាលណាអ៊ីស្មាអ៊ីលដឹងប្រាកដថាឡីឡាមិនមានអន្តរាយហើយ គេឲ្យរាត្រីសុវត្ថិដល់នាងក្រមុំអរគុណដល់តាឡិប ទើបគេដើរសំដៅកន្ទីងសូត្រធមិដែលគេតាក់តែងក្នុងទីគួរសមមួយដោយឡែកក្នុងផ្ទះ សំរាប់អរគុណដល់ព្រះអាឡស់ ។ រួចពីនោះមក គេទៅគេងលើត្រែពូកមួយ ក្នុងចិត្តនឹកមិនភ្ងេច បំរុងនឹង

ចេញទៅក្នុងវាលខ្សាច់ពេលសងាកើត ហើយក៏ដេកលក់ទៅច្របូកច្របាយ
ចិត្តសប្បាយរីករាយមានសេចក្តីសង្ឃឹមខុសជាមុន ។

*
* *

ស្អែកឡើងពេលថ្ងៃរះ នាងឡឺឡាមិនបានឮសូរដើងសេដែល
អ៊ីស្មាអ៊ីលដំរះសេះទៅវាលខ្សាច់ទេ ។ នាងដេកលក់ស៊ប់ឥតយល់សុបិ
ព្រោះអស់កម្លាំងខ្លាំងពេក ។ កាលនាងភ្ញាក់ឡើងជ្រុលថ្ងៃបន្តិច នាង
ឮសូរសំដីនិយាយ ហើយស្គាល់ច្បាស់ដូចជាសំឡេងមាត់អ៊ីស្មាអ៊ីល ។
នាងពត់ខ្លួនច្រណា ចេញពីក្នុងឡាំង ឥតមានព្រួយបារម្ភអ្វីទេ ។
នាងស្រាប់តែឃើញតាចាស់ម្នាក់មានឈុតធំ ដួតឆ្ងាត ស្លៀកពុំសំពត់លំអ
ដោយគ្រឿងប៉ាក់ដ៏មានតម្លៃ ស្ថិតនៅចំពីមុខ ។ នាងទប់ដឹកស្រឡាំង
កាំង ។ តាចាស់សំឡឹងនាងមួយស្របក់ រួចបែរទៅរកតាឡាបដែល
អង្គុយនៅក្បែរមួយស្លៀមស្ងាត់មិនកំរើក ហើយសួរដោយពាក្យច្រឹត
ច្រៀងថា:

— "ស្ត្រីនេះជាអ្វី?" ។

តែមុនដែលតាឡាបនឹងឆ្លើយ ឮសូរដើងសេរកឯខ្ទមា រួចអ៊ីស្មា
អ៊ីលមកដល់មាត់ក្រាល ។ អ៊ីស្មាអ៊ីលឈប់ដឹក កាលដែលបានឃើញ
អាពុក គេមានទឹកមុខស្រពោនយ៉ាងខ្លាំង ។ គ្រាន់តែឃើញអ៊ីស្មាអ៊ីល
មកដល់ នាងឡឺឡាគ្មានគិតអ្នកណា ក៏ស្ទុះភ្លែតទៅរក ហើយសួរ
គាំងព្រួយថា:

— "ម៉េចទៅអ្នកបង ចានឃើញបងស្រីខ្ញុំឬទេ?" ។

អ៊ីស្មាអ៊ីលឆ្លើយត្រឹមតែថា:

— "បំណងផងព្រះអាឡស់ មិនងាយជនណាអាចជ្រៀតចូលបានឡើយ ។ ត្រូវតែអត់ធ្មត់នៅចំពោះមុខនៃការស្ទង់គ្រប់ដំណាក់ការបស់ព្រះអង្គចុះ ។ ចំថ្ងៃរសៀលបងនឹងប្រែមនុស្សទៅឯណាលឱ្យបាត់ឆ្ងើផ្ងរមួយឱ្យគួរដល់តុណាភាពនឹងរូបសម្បត្តិរបស់បងកំសត់នៃអូន!

នាងឡីឡាមុខឡើងស្វេកស្វាំង ។ នាងនិយាយមិនរួច ត្រៀបលើដៃអ៊ីស្មាអ៊ីល ហើយយំដូចកូនក្មេង ។

ខណៈនោះ អ៊ីស្មាអ៊ីល បែរទៅរកអាពុក ហើយដាក់បថា:

— "នាងនេះឈ្មោះឡីឡា ម្តាយនាងជាបងជាឈ្វីយនៃពួកតាហានគ្លរគី បងស្រីនាងស្លាប់ទៅកណ្តាលវាលឱ្យាបាត់" ។

លោកអៃយ៉ាជសំឡឹងមើលទៅកូនរបស់លោកម្តង សំឡឹងទៅនាងក្រមុំអាក៉ាប់ម្តង ។

នាងឡីឡាកំសត់ចេះតែអណ្តឺតអណ្តក ។ លោកអៃយ៉ាជនឹកដល់ឱ្យាបាត់ព្រះអាឡស់ដែលបង្គាប់ថា ត្រូវឱ្យធ្វើជាអ្នកចិត្តល្អសប្បុរស មានមេត្តា ។ លោកលើកដៃក្តឹផ្ងែកៗដោយត្អូងមរកតនឹងត្អូងខ្ចីម ម៉ក្ឱ្យតពុកចង្កាវែងអន្ទាយដូចប្រាក់ ។ លោកមានប្រសាសន៍ថា:

"អ៊ីស្មាអ៊ីល ឯងរើសនាងនារីនេះមកទុកក្នុងផ្ទះអាពុកម្តាយល្អហើយ ប៉ុន្តែឯងទុកគ្មាឱ្យទៅកន្លែងនេះ មិនសមរម្យទេ ។ ចាប់ពីពេលនេះទៅ

ត្រូវឲ្យនាងទៅនៅលើផ្ទះយើងជាមួយនឹងប្អូនស្រីឯង ហើយឲ្យស៊ីបាយ
ទឹកតុជាមួយគ្នាផង ។ សូមឲ្យការស្មំគ្រផងព្រះអាឡស់សម្រេច ហើយ
សូមឲ្យគេគោរពសំដីរបស់ព្រះអង្គជានិច្ចកាល!" ។

រាចារបស់លោកអៃយ៉ាដទាំងប៉ុណ្ណោះនេះ សុទ្ធតែជាសំដីដែលចេញ
មកពីដួងចិត្តដ៏មានមេត្តា ជ្ឈិតលោកជាមនុស្សដ៏បរិសុទ្ធ ជាអ្នកជួយ
សង្រ្គោះដោយសុចរិតស្មោះត្រង់ ។

វគ្គទី ៦

រស្សីម បេន អាប់ដាឡះ

គោះបីជាសម័យមានទុក្ខ ដោយស្រុកកើតចំបាំងរាំងដល ក៏ជីវភាព
ក្នុងផ្ទះលោកអៃយ៉ាដនៅប្រព្រឹត្តទៅស្រួលគួរសមល្មម នៅជាសុខ
សប្បាយដល់នាងឡីឡា ។

ក្នុងគេហស្ថានលោកអៃយ៉ាដ មានក្រុមស្រីៗសម្រាប់មនុស្សថ្នាក់
សង្គមជាន់ខ្ពស់ នឹងប៉ែកឯកសិទ្ធិនៃសង្គម ។ លោកនៅមានករិយាទីពីរ
នឹងស្ត្រីទ្ទះជាបរិវារ ។ នៅក្នុងផ្ទះមួយទៀតមានសុទ្ធតែធីតារបស់លោក
នឹងធីតារបស់ប្អូនលោកដែលអនិច្ចកម្មចោល ហើយលោកទទួលយក
មកចិញ្ចឹម ។

នាងឡីឡាគេទទួលឲ្យនៅក្នុងចំណោមនារីទាំងនោះ ។ ពួកស្ត្រី
ជាដីជូនមួយនឹងអ៊ីស្មាអ៊ីល ពេញចិត្តនឹងនាងឡីឡាជាពន់ពេក ដោយ
នាងនេះសូតមានប្រាជ្ញានឹងរូបសម្បត្តិបរិបូណ៌ ។ ក្រុមស្រីក្រមុំទាំងអស់

នេះសុទ្ធតែនៅក្មេង។ អាយុរវាង៨ដប់ជុំចាំមួយឬក្នុងមួយឆ្នាំប៉ុណ្ណោះ ។ ក្នុងរយៈអាយុប៉ុណ្ណោះ តរុណភាពនឹងរូបសម្បត្តិនៃស្ត្រី បណ្តាលមិនឲ្យចេះច្បែណាឈ្មោះនឹងគ្នាឡើយ រឿងទុក្ខវេទនារបស់នាងកំសត់ឡើយ ទៅកកាយទាញកុណាត្តិចេញពីដួងវិញ្ញាណនៃពួកយុវតីទាំងនោះ ។ ឥឡូវនេះ គឺជាពេលសុខកាយសប្បាយចិត្តនៃនាងឡើយ ដែលខើបនឹងសោយអនិដ្ឋារម្មណ៍ គឺការអនិច្ចកម្មនៃបងស្រីនាង ។

នាងចរាចរការនេះ ដែលពីដើមធ្លាប់តែនៅហាលថ្ងៃ ហាលខ្យល់ក្នុងជំរុំដ៏គ្រោតគ្រាត មិនដែលនឹកគិតដល់រូបសម្បត្តិម្តង ទ្រុតទុតតាមតែប្រទះ ក្នុងជ្រោះ ក្នុងត្រពាំង ឥឡូវនាងបានស្គាល់គ្រឿងតែងកាយពួកស្រី។ ។ នាងបានស្គាល់ការរួតយ៉ាងសុខុមក្នុងអាង គឺបួលគ្រាំពប់មើងក្នុងអាងពេញដោយទឹកដ៏ត្រជាក់ អប់ផ្កាកូឡាប ។ ស្នានបែបនេះ លុះក្រោកឡើងចេញ នាំឲ្យរូបកាយទន់ល្អន់ គំនិតថ្លា បណ្តាឲ្យឈាមដ៏វរត់ក្នុងសរសៃតូចធំយ៉ាងប្រពៃ ។ សេក់ខៀតកំមានស្ត្រីបំរើយ៉ាងចំណាប់ក្នុងការផងសក់ ប្លង់ គាប គាស់ ឲ្យត្រឹមត្រូវ ។ នាងបានស្គាល់គ្រឿងលាបខៀត គឺមេម្សៅក្រអូបអប់ផ្កាម្ទិះ ផ្កាកូឡាប មានមេម្សៅម្យ៉ាងសម្រាប់រំលីងភេមក្លៀក ភេមស្ពន មានមេម្សៅសម្រាប់ពត់ចិញ្ចើមសម្រាប់តម្រង់ព្រួយក្បែក មានប្រេងសម្រាប់លាបសក់ឲ្យខ្មៅរលើប ។ សំលៀកបំពាក់ខៀតសោតក៏សុទ្ធតែសូត្រនឹងវែង, កាលពីមុន នាងស្លៀកពាក់តែសំពត់សាច់គ្រឹម ។

(មានត)

រឿងបល្ស័ង្ក្ពិត្យ សាមសិបពីររឿង

រឿងព្រេងឥណ្ឌៀ

លោកសមិន ម្ចាត់សងដម: តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

និទាននៃរូបទេពនិម្មិតទីពីរ

មានកាលមួយថ្ងៃ ព្រះអភិរាជកោជ: ទ្រង់បានសម្រេចក្នុងព្រះទ័យថា នឹងចាត់ឲ្យគេធ្វើរាជាភិសេកទ្រង់ពេញច្បាប់ ទ្រង់ក៏ចូលទៅជិតព្រះប័ល្ស្ងក្ពិត្យព្រមដោយរាជបរិវារ ។ ក្នុងពេលនោះ រូបទេពនិម្មិតទីពីរដែលស្ថិតនៅនឹងព្រះបល្ស័ង្ក្ពិត្យ ពោលថា "សូមព្រះមហាក្សត្រិយ៍ទ្រង់ជ្រាប ព្រះមហាក្សត្រិយ៍អង្គណា អាចគង់នៅលើបល្ស័ង្ក្ពិត្យនេះបាន លុះតែព្រះមហាក្សត្រិយ៍អង្គនោះ មានព្រះរាជបរិយាសមរម្យអស្ចារ្យស្មើនឹងព្រះបាទវិក្រមទិត្យ" ។ ព្រះមហាក្សត្រិយ៍ទ្រង់សួរទៅរូបទេពនិម្មិតទីពីរវិញថា "កិត្យានុកាពនៃព្រះបាទវិក្រមទិត្យនោះយ៉ាងណាទៅ?" ។ រូបទេពនិម្មិតនោះ ក្រាបទូលព្រះមហាក្សត្រិយ៍ថា "សូមទ្រង់ព្រះសណ្ឋាប់, ទូលបង្គំនឹងក្រាបទូលទ្រង់ក្នុងកាលឥឡូវនេះ ៖

អភិរាជវិក្រមទិត្យ ទ្រង់សោយរាជសម្បត្តិនៅប្រទេសអវន្តី; ថ្ងៃមួយទ្រង់បានចាត់ពួកអាមាត្យនៅគ្រប់ទីតំបន់ឲ្យស្វែងរកអច្ចរិយរត្ន ដែលមាននៅតាមភូមិភាគក្នុងប្រទេស ។ ពួកអាមាត្យក៏បានទៅពិនិត្យភូមិ

ភាគទាំងនោះហើយត្រឡប់មកទូលព្រះមហាក្សត្រិយ៍វិញថា "សូមព្រះអង្គទ្រង់ជ្រាប នៅគិរីចិត្រកូត (Citrakuta) មានវត្តមួយនៅក្បែរនោះមានដើមផ្ការតប់យ"ង ហើយមានទន្ទេមួយហូរចំពីមុខវត្ត, បើមានបុគ្គលណាដែលមានចិត្តបរិសុទ្ធចុះទៅមុជទឹកក្នុងទន្ទេនោះ រូបបុគ្គលនោះសដូចទឹកដោះគោ, បើបុគ្គលពាលទុច្ចរិត ចុះទៅមុជវិញ ទឹកនោះអាចធ្វើរូបបុគ្គលនោះឲ្យខ្មៅដូចទឹកខ្មៅ(1); នៅទីនោះមានយោគី(2) ម្នាក់សូត្រធម៌ជានិរន្តរ៍ តែងធ្វើកម្មដ្ឋាន, ធ្វើអាមិសបូជានឹងធម្មបូជាជានិច្ច តែនាងទេវធីតាមិនសូវពេញចិត្តនឹងព្រះយោគីនោះសោះ" ។

ព្រះបាទវិក្រមទិត្យ ទ្រង់ព្រះសណ្ឋាប់នូវសេចក្តីរាយការណ៍នោះ ទ្រង់ក៏ស្តេចទៅកាន់ទីនោះ ទ្រង់ស្រង់ព្រះទកៈនៅទន្ទេ ហើយទ្រង់ក៏យល់ជាក់ច្បាស់ថាទន្ទេនោះ មានទឹកបរិសុទ្ធស្អាតឥតមន្ទិលមែន, ហើយទ្រង់សំដែងព្រះរាជកិរិយាគោរពចំពោះព្រះអាទិទេព រួចទ្រង់ក៏យាងតម្រង់ទៅរកយោគីនោះ ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះដម្រាស់សួរប្រស្នានេះនឹងយោគីនោះថា: "យោគី! តើពីកាលណាមក ដែលអ្នកធ្វើអត្តកិលមដ្ឋានុយោគនេះ (Mortification) ។ ព្រះយោគីក្រាបទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស! ទូលបង្គំធ្វើតាំងពីខែពិសាខ, ដេស្ត, ឥសាធ, ស្រាពណ៍, កត្របទ, អស្សុជ, កត្តិក, មិគសិរ, បុស្ស, មាឃ,

---

1 ទឹកខ្មៅប្រហែលជាល់អងភ្លើង ។ 2 យោគី ពួករុក្ខមូលបានធ្វើសមាធិចិត្តដល់ឈានចិត្ត ។

ជល្ពុន, ចេត្រ, គឺថាវៃប្រមូលរូបរួមហៅថាធ្នាំ, ធ្នាំនោះមួយរយធ្នាំ
ហើយទូលបង្គំបានប្រព្រឹត្តធ្វើអត្តកិលមង្ខានយោគ គឺធ្វើខ្ជូនឲ្យលំបាក,
ទូលបង្គំមិនទាន់បានឃើញនូវទេវធីតាអង្គណាមកប្រោសសោះ ។ ព្រះ
មហាក្សត្រិយ៍លុះទ្រង់ព្រះសណ្តាប់នូវសព្ទរាចានៃតាបស ទើបទ្រង់ព្រះ
តម្រិះថា "អញបានថ្នមរូបកាយរបស់អញជានិរន្តរ៍, សេចក្តីស្ទាប់គង់នឹង
មានមកជាប្រាកដដល់អញមិនខាន, បើអញលះបង់ជីវិតដើម្បីនឹងធ្វើ
ប្រយោជន៍ជាសារជាណ:, មរណភាពនេះ ហៅថាមរណភាពវិសេស" ។
ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទ្រង់ក៏ប្រកាសក្នុងព្រះ
រាជហ្ជុទ័យ ដោយទ្រង់ព្រះវិតក្កទៅកាន់នាងទេវធីតានោះ ហើយក៏
ទ្រង់ចាប់ព្រះខ័នថ្ទា ទ្រង់រៀបនឹងកាត់ព្រះសិរ ស្រាប់តែនាងទេវធីតា
មកដល់ស្ទុះទៅចាប់ព្រះហស្តព្រះអង្គ ហើយក្រាបទូលថា "សូមទ្រង់
កុំកាត់ព្រះសិរ, យើងសប្បាយចិត្តនឹងទ្រង់ណាស់, ចូរទ្រង់សូមមក
យើង, ចូរមានព្រះរាជឧស្ការតាមព្រះរាជបំណងចុះ" ។ ព្រះមហា-
ក្សត្រិយ៍ទ្រង់តបទៅនាងទេវធីតាវិញថា "នាងទេវធីតា! យោគីនេះ
បានព្យាយាមធ្វើបាបរូបកាយមកអស់កាលយូរ; នាងមិនបានអនុគ្រោះ
ចំពោះយោគីនេះ, ឯចំណែកយើង នាងចូលមកប្រោសប្រាណ ម្តេច
ក៏យ៉ាងដូចនេះ?" ។ ព្រះនាងទេវីក្រាបទូលព្រះមហាក្សត្រិយ៍ថា "ឧ
មហារាជវិក្រមទិត្យ ដូចជាសមាធិធម៌ចំពោះទៅកាន់មន្ត្រស្រះពិសិដ្ឋ,
នាងទេវធីតាត្រូពេទ្យ, ត្រូនេះជាការណីយកិច្ចពិតមែន ខ្ញុំម្ចាស់មិនដែល
យល់នូវយោគីនេះ នឹកនាយកខ្ញុំម្ចាស់ជាអារម្មណ៍នៃសមាធិកម្មដ្ឋានណា

មួយទ្បើយ" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ណាប់នូវព្រះវាចានៃ
ព្រះនាងទេវធីតានេះ ទ្រង់ព្រះតម្រិះថា "នាងទេវធីតានេះ មកស្ថិត
ក្នុងជីវភាពនេះដោយដុំឈើ ឬ ដុំថ្ម; ជីវភាពនេះមកពីការប្រព្រឹត្តិ,
ប្រតិបត្តិ(១)" ។ ព្រះមហាក្សត្រិយ៍ដោយទ្រង់មានព្រះវាជបំណងចង់
ធ្វើការប្រយោជន៍ជាទៃ, ទើបពោលទៅកាន់នាងទេវធីតាថា "ឧនាង
ទេវធីតាអើយ, បើព្រះនាងសប្បាយចិត្តនឹងយើង, ហើយដោយហេតុ
ថាយោគីនេះខំប្រព្រឹត្តធ្វើទុក្ខធ្វើបាបខ្ជូនតាត់អស់កាលយូរ ថែមទាំងមិន
បានសម្រេចផលដ៏ល្អទៀត, សូមព្រះនាងអនុញ្ញាតឲ្យយោគីនេះ ជ្រើស
រើសនូវពាក្យស្មូមដែលព្រះនាងបានបើកឧកាសឲ្យយើងពីមុន" ។ នាង
ទេវធីតាក៏យល់ព្រមឲ្យយោគីនោះសូមអ្វីតាមប្រាថ្នា ។ ព្រះបាទ
វិក្រមទិត្យក្រោយដែលបានប្រគល់នូវពាក្យប្តេជ្ញានោះទៅយោគី ក៏ទ្រង់
រិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ។

រូបទេពនិម្មិតទិពីរបន្ទែមសេចក្តីថា: បពិត្រព្រះបាទភោជ:! ទូល
បង្គ បានក្រាបទូលទ្រង់ថា ព្រះបាទវិក្រមទិត្យ ទ្រង់មានព្រះគុណ-
សម្បត្តិពីរយ៉ាងគឺ សប្បុរិសធម៌ ១, រីរធម៌ ១, បើគុណសម្បត្តិទាំងពីរ
យ៉ាងនេះមាននៅក្នុងព្រះទ័យ ទ្រង់ ។ អាចគង់នៅលើបល្ល័ង្ក ទិព្យនេះបាន ។

---

១ នៅទីនេះ គឺជាការពិចារណាដោយសុទុមហើយល់ចាកនឹងយល់ពន់ពេក; គេបានញែក
ជាបីយ៉ាងគឺ: ភាវិនា, សិទ្ធិ, ភាវិ:; ប្រតិបត្តិធម៌មកពីភាវិនា ហើយភាវិ:មកពីប្រតិបត្តិធម៌ ។
វិត្ថុអ្វីរស់នៅបាន (ឬមាន) ព្រោះផលនៃភាវិនា ។ ប្រហែលជាមានបំណងចង់បន្ទំពាក្យភាវិ:
នឹងភាវិនា ។ បើតាមអ្នកបកប្រែ ភាវិ-ភាព ប្រែថា បែប, បទ, លំនាំ; ភាវិនា ប្រែថា
ការបំរើន ។

ឥទ្ធានអនៃរូបទេពនិម្មិតទីបី

ព្រះអភិភជគោជៈ ទ្រង់ប្តេជ្ញាកន្ត ព្រះទ័យថា ឥឡូវនេះគេអភិសេក ទ្រង់ឲ្យសោយរាជ្យជាស្តេចពេញច្បាប់ ហើយទ្រង់ក៏ស្តេចយាងចូលទៅដំកល់ក្នុងឥទ្ធិនោះ ។ លុះតែរូបទេពនិម្មិតទីបីពោលថា "ឱ! ព្រះអភិភជគោជៈ, សូមទ្រង់ព្រះសណ្តាប់ចូលបង្គំ; ព្រះមហាក្សត្រិយ៍អង្គណាអាចគង់នៅលើបល្ល័ង្កឥទ្ធិនេះបាន, លុះតែតាតែព្រះមហាក្សត្រិយ៍អង្គនោះ មានព្រះគុណសម្បត្តិដ៏ឧត្តមដូចព្រះមហាក្សត្រិយ៍វិក្រមទិត្យ" ។ ព្រះអភិភជគោជៈទ្រង់មានព្រះបន្ទូលសួរទៅរូបទេពនិម្មិតទីបីថា: "តើព្រះគុណសម្បត្តិដ៏ឧត្តមនៃមហាភជវិក្រមទិត្យមានអ្វីខ្លះ?" ។ រូបទេពនិម្មិតទីបីទូលថា: "ព្រះគុណសម្បត្តិដ៏ឧត្តមនៃមហាវិក្រមទិត្យគឺ ១ឱ្ជី, កាចំពោះខ្លួន, ចិត្តនឹងខ្លួន, ពលកាយ, ជ្ញាជ្ញ, វីរកាយ, នេះជាគុណសម្បត្តិប្រាំមួយយ៉ាង ដែលមាននៅលើបុគ្គលណា អាចធ្វើបុគ្គលនោះឲ្យព្រះអាទិទេពខ្លាចបាន ។ គុណសម្បត្តិទាំងប្រាំមួយយ៉ាងនេះ មានចំពោះមហាភជវិក្រមទិត្យ ។

មានកាលមួយថ្ងៃ, ព្រះមហាភជទ្រង់ព្រះតម្រិះថា "កោគទ្យឥឡូវតែពត៌ បើកាលណាវាមកដល់ តើវាមកពីណា? កាលណាវាទៅវិញ តើទៅឯណា? បញ្ហានេះ អញមិនអាចធ្វើយដោយខ្លួនអញបានទេ ។ ឥឡូវអញមានជោគជ័យជាច្រើន, តែដល់អនាគតតើយ៉ាងណាទៅ? អញក៏មិនអាចដឹងដល់" ។ លុះទ្រង់ព្រះតម្រិះយ៉ាងនេះ, ទ្រង់ក៏មាន

ព្រះរាជបំណងចង់ធ្វើអាមិសបូជាចំពោះព្រាហ្មណ៍, អ្នកក្រ, ស្ត្រី, ក្មេង, ចំពោះអ្នកណាដែលគ្មានគេឧបត្ថម្ភ, អ្នកណាដែលខ្សត់ខ្សោយ ហើយព្រះអង្គយកពន្ធអាករ ពីអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ តែបន្ទិចបន្ទួច(១) ។ ដើម្បីឲ្យពួកអាទិទេព ទ្រង់សព្វព្រះហ្ឫទ័យនឹងព្រះអង្គ ។ ទ្រង់តែងតាំងពួកព្រាហ្មណ៍ជាអ្នកវិញ្ញូជនចេះដឹងក្នុងវេទ, ប្រតិបត្តិធម៌ សព្វយ៉ាង, ពលីកម្ម, សូត្រធម៌, ហោម(២), ពលី(៣), លទ្ធិ ។ ចំពោះកិច្ចការខាងអាទិទេ គង្គា, ទ្រង់បានត្រាស់បង្គាប់ឲ្យព្រាហ្មណ៍ម្នាក់ទៅមាត់សមុទ្រ ។ ព្រាហ្មណ៍ទៅដល់ទីនោះធ្វើអញ្ជលីកម្មហើយ សូត្រធម៌ផ្សាយទៅរកសមុទ្រ ។ ខណៈនោះ ព្រះឈទកទេវតា (ទេវតាទឹក) បង្ហាញខ្លួនហើយពោលថា: "ព្រាហ្មណ៍! ខ្ញុំពេញចិត្តអនុគ្រោះព្រះបាទវិក្រមទិត្យ ដោយហេតុមហារាជនេះ ប៊ុនប្រសប់គ្រប់យ៉ាង; ពិតមែនតែទ្រង់គង់នៅធ្លាយ ខ្ញុំនៅតែស្រឡាញ់ទ្រង់ដរាប ។ ចូរព្រាហ្មណ៍យករតនវត្ថុបួនយ៉ាងទៅថ្វាយព្រះបាទវិក្រមទិត្យ ហើយអ្នកក្រាបទូលព្រះអង្គឲ្យទ្រង់ជ្រាបពីគុណសម្បត្តិ នៃរតនវត្ថុទាំងនេះ ។ អានុភាពនៃរតនវត្ថុទីមួយ ជាអស្ចារ្យពន់ពេក ព្រោះអាចធ្វើឲ្យព្រះស្លាយ ដែលគ្រាន់តែទ្រង់ព្រះតម្រិះ ក៏មកដល់មួយរំពេច; រតនវត្ថុទីពីរ

---

១ ឧត្តមធតិរបស់ព្រះមហាក្សត្រិយ៍, តាមប្រពៃណីនៃពួកបូពាំដន តឹត្រូវព្រះរាជទាន ទៅអ្នកទាំងអស់ឆ្នាដាច្រើន ហើយមិនត្រូវយកពីអ្នកណាមកវិញសោះឡើយ ។ ២ មហាយញ្ញៈ ពលិកម្មចំពោះអាទិទេពសំខាន់ ។ ៣ ពលីកម្មៈ ចំពោះអាទិទេពតូចទាប តឹបូជាយញ្ញៈតូច ។

បើទ្រង់ចង់បានភោគទ្រព្យអ្វី ក៏បានដូចព្រះបំណង; រតនវត្ថុទីបី បើទ្រង់ព្រះតម្រិះចង់បានកងទ័ពមួយមានរថ, ដំរី, ទ័ពសេះ, ទ័ពថ្មើរជើង ក៏បានភ្លាម; រតនវត្ថុទីបួន បើទ្រង់ចង់បានគ្រឿងអលង្ការអ្វីក៏បានតាមព្រះរាជបំណង" ។

ព្រាហ្មណ៍នោះ ក៏យករតនវត្ថុទាំងបួនវិលត្រឡប់ទៅកាន់ព្រះរាជ-ធានីវិញ ហើយក៏យករតនវត្ថុទាំងនោះទៅថ្វាយព្រះមហាក្សត្រិយ៍; ហើយក្រាបទូលអំពីគុណសម្បត្តិនៃរតនវត្ថុទាំងនោះ ។ ព្រះមហា-ក្សត្រិយ៍មានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍ថា: "បណ្ណារតនវត្ថុទាំងបួន ឲ្យអ្នកជ្រើសរើសយករតនវត្ថុណាមួយ ទុកជាសិរីវត្ថុរបស់ខ្ជូនចុះ" ។ ព្រាហ្មណ៍ក្រាបទូលព្រះមហាក្សត្រិយ៍ថា. ទូលព្រះបង្គំ មានបុត្តមួយ, កូនប្រសាស្រីមួយ, ភរិយាមួយ, ទូលបង្គំចង់ពិសោធមើលអ្នកទាំងបីនោះ បើអ្នកទាំងបីយករតនវត្ថុណា ទូលបង្គំក៏យករតនវត្ថុនោះ" ។ ដល់ក្រាបទូលព្រះមហាក្សត្រិយ៍ឲ្យជ្រាបសព្វគ្រប់ប្រការ ព្រាហ្មណ៍ក៏វិលត្រឡប់ទៅកាន់គេហដ្ឋានវិញ ហើយក៏ដំណាលរឿងរ៉ាវនោះ ប្រាប់ភរិយា, បុត្តនឹងកូនប្រសាស្រី ។ បុត្តពោលថា: "ឆួរតែយករតន-វត្ថុ ដែលមានដំរី សេះ" ។ ភរិយាពោលថា: "ឆួរយករតនវត្ថុដែលមានម្ហូបអាហារ" ។ កូនប្រសាស្រីពោលថា: "ឆួរយករតនវត្ថុដែលមានគ្រឿង មាស-ប្រាក់" ។ ព្រាហ្មណ៍ពោលថា: "រតនវត្ថុណាដែលមានភោគទ្រព្យប្រើន គឺជារតនវត្ថុដែលអញឆួរយក" ។ បុគ្គលទាំងបួនមានយោបល់មិនត្រូវគ្នាសោះ ។ ព្រាហ្មណ៍ក៏វិលត្រឡប់ទៅ

គាល់ព្រះមហាក្សត្រិយ៍វិញ ហើយក្រាបបង្គំទូលអំពីរឿងរ៉ាវខាងលើ
នេះ ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ឋាប់នូវសុនូរកថាព្រាហ្មណ៍
ទ្រង់ក៏ប្រោសព្រះរាជទាននូវរតនវត្ថុតាំងជួនមកព្រាហ្មណ៍ ដើម្បីនឹងឲ្យ
អ្នកតាំងជួនសប្បាយចិត្ត ។ ព្រាហ្មណ៍នោះ ក៏វិលត្រឡប់មកកាន់
គេហដ្ឋានវិញ ដោយចិត្តរីករាយពន់ពេក ។

រូបទេពនិម្មិតទីបី ក្រាបទូលថា: "សូមព្រះមហាក្សត្រិយ៍ភោជ:
ទ្រង់ជ្រាប: ទូលបង្គំបានក្រាបទូលទ្រង់អំពីឧត្តមភាពនៃមហារាជវិក្រម-
ទិត្យយ៉ាងនេះឯង ។ បើទ្រង់មានព្រះចរិយាជ៏ឧត្តមបែបនេះ ទើប
ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្យនេះបាន ។ (មានត)

* * *

អ្នកធ្វើល្អបានអាក្រក់ អ្នកធ្វើអាក្រក់បានល្អ

សេចក្តីល្អនៃបរិវារដែលមានសភាពជាអ្នកស្រឡាញ់ស្មោះត្រង់
ពិតៗ ខំប្រឹងធ្វើឲ្យ ជួនកាលត្រឡប់ទៅជាទោសអាក្រក់គួរស្អប
ខ្ពើមទៅវិញ, ឯទោសអាក្រក់ប្រត្យ័ក្សលាំងៗ ដែលជនជទៃគេធ្វើ
ឲ្យ ត្រឡប់ទៅជាគុណនាំឲ្យជាទីស្រឡាញ់ពេញចិត្ត, ក៏រឯព្រះ
ទ័យនៃព្រះរាជាដែលប្រែប្រួលមិននឹងនៅក្នុងភាពតែមួយយ៉ាងនេះ
បុគ្គលពិបាកនឹងប្រកាន់កំណត់សំគាល់ណាស់ ជូច្នេះ សេរាជមិគី
សភាពខ្ចុំបំរើម្ចាស់ផែនដីនេះ មានសភាពសាំញ្ញាំស្មុកស្មាញគ្រៃ-
លែងណាស់ សូម្បីតែព្រះយោគីក៏មិនងាយនឹងបំពេញឲ្យបរិបូណិ
បានឡើយ ។

កំណាត់ឯកប្រវត្តិសាស្ត្រ

បុណ្យឆ្លងព្រះវិហារ និង សាលាបឋមសិក្សា

នៅវត្តសិរីបទុម ឃុំអង្គរជាន ស្រុកកងមាស ខេត្តកំពង់ចាម

លោក បាប-ពិន រៀបរៀង

នៅតាមផ្នែកខ្វេមគង្គ (ខ្វេធំ) មានវត្តមួយឈ្មោះ "វត្តសិរីបទុម" ហៅតាមនាមភូមិថា "វត្តអន្ទង់ស" ព្រោះជាប្រធាននៃភូមិនេះ ក្នុងឃុំអង្គរជាន ស្រុកកងមាស (កំពង់ចាម) ជាវត្តប្រកបដោយសប្បាយ ៤ យ៉ាង គឺសប្បាយដោយទីសេនាសនៈ ដោយធម៌និយ ដោយបុគ្គលិក-មានសាមគ្គីធម៌ ដោយអាហារគោជន, មានសាលាចាលីវង, សាលាបឋមសិក្សា ៤ ថ្នាក់ គឺថ្នាក់កុមារដ្ឋាន-បឋមដ្ឋាន-អាទិកដ្ឋាន-មធ្យម-ដ្ឋានទី ១ ជាវត្តចំរើនទាំងផ្លូវធម៌ទំងផ្លូវលោក ទំងចំរើនទាំងគន្ថធុរៈ ទាំងវិបស្សនាធុរៈ ដោយគេបែងចែកទីវត្តជា ៣ ភាគ គឺ ២ ភាគខាងមុខជាលំនៅព្រះសង្ឃសិក្សាព្រះបរិយត្តិធម៌, ១ ភាគខាងក្រោយ ដែលមានជម្រំដើមគគីរជារបងខ័ណ្ឌដោយឡែក ជាលំនៅគ្រហស្ថអ្នកស្ងប់គ្រៃនៅក្នុងតូបតូច ។ ក្បែរជិតគរុខោសថសីល អគារកសីល ទំងស្នាងស្មាធ៌ភាវនា ដោយមានសាលាមួយខ្នង នៅចំកណ្តាលជាធម្មសភាសម្រាប់អាចារ្យបង្ហាត់សមថវិបស្សនាតាមគម្ពីរវិសុទ្ធិមគ្គ ។

នៅថ្ងៃ ១៥ កើត ខែ ភេចទំង ២ ភេចខែផល្គុន ឆ្នាំមមីឆស័ក ព.ស. ២៤៧៧ ត្រូវទំងថ្ងៃទី ៨ ទី ៩ ទី ១០ មីនា ១៩៣៤, វត្តនេះមានកិច្ចធ្វើ

បុណ្យសម្ពោធ (ធ្ងង) ព្រះវិហារដែលសង់ដោយបេតុងអារមែ តាមរបៀបទាន់សម័យនឹងសម្ពោធសាលាបឋមសិក្សា ។

ដោយទីវត្តនោះធំទូលាយមានទេសភាពស្អាតបាតល្អ មានដើមឈើធំតូចម្ចប់ត្រឈឹងត្រឃៃជាជួរ ។ រៀងរាយតាមមុខកុដិសាលាទាំងពួងហើយក្រោមដើមឈើទាំងនោះ មានក្រាលផ្ទាំងស៊ីម៉ង់ត៍ជាផ្ទូវដើររាបទាបល្អ ក៏ជាទីមានលំអគួរចាប់អារម្មណ៍ដល់បណ្តាជនអ្នកទស្សនា ។

បុណ្យនោះមានរបៀបដូចរៀបរាប់តទៅនេះ ៖

• បាសកបំណុះវត្តនេះ តាមធម្មតាគេព្រមព្រៀងចែកគ្នាជា ៤ ក្រុមតាមសង្កាត់នៃភូមិដើងវត្ត គឺ

– សង្កាត់ខាងកើតវត្ត ជាក្រុមទី ១;

– សង្កាត់ខាងត្បូងឈៀងខាងកើត ជាក្រុមទី ២;

– សង្កាត់ខាងត្បូងឈៀងខាងលិច ជាក្រុមទី ៣;

– សង្កាត់ខាងលិចវត្ត ជាក្រុមទី ៤ ។,

ក្រុមនីមួយ ។ គេតាំងអ្នកមានធនធាន នឹង មានសមត្ថភាពម្នាក់ជាប្រធាន ហើយមានសមាជិកជាច្រើននាក់ សម្រាប់ប្រឹក្សាការបុណ្យទាន, ជាក្រុមនៅក្រោមអធិបតីភាពនៃគណៈកម្មការវត្ត, រវលាធ្វើបុណ្យនេះ គេធ្វើរោងធំ ៤ សម្រាប់ទទួលព្រះសង្ឆ នឹង ត្រហស្ថ មានរបៀបដូច្នេះ:

- ក្រុមទី ១ ធ្វើនៅជ្រុងខាងដើងឈៀងពាយ័ព្យព្រះវិហារ;

- ក្រុមទី ២ ជ្រុងខាងត្បូងឈៀងនិរតីព្រះវិហារ;

- ក្រុមទី ៣ ជ្រុងខាងត្បូងឈៀងអគ្នេយ៍ព្រះវិហារ;

- ក្រុមទី ๔ ជុំជិតភាគខាងជើងឈៀងឆ្ងៀសានព្រះវិហារ ។

ពេធ៌តាំង ๔ នោះ សុទ្ធតែរចនាដោយស្នឹកក្រុងជាតិ ទន់ជាតិ ទន់សាសនា ព្រះពុទ្ធរូបព្រះបដអគ្គធំ ។ ទឹងបង្ហើងគោមតែវយ៉ាងល្អ ។ គួរជ្រះថ្លា ។ នៅគ្រប់មុខពេធ៌ធំ ។ សុទ្ធតែមានពេធ៌តាំងតូចមួយ ។ មានតុកៅអីទឹងស្នៀនប្រចាំការ សម្រាប់ទទួលកត់ត្រាច្រាក់ចំណូល ។

មានពេធ៌តាំងធំជាងគេមួយទៀត នៅកណ្តាលវត្តចំមុខកុដិលោកចៅអធិការ ជារបស់ព្រះសង្ឃសម្រាប់ប្រជុំការធំ ។, ពេធ៌នេះគេរចនាដោយព្រះពុទ្ធរូបព្រះបដផ្ទាំងធំ ។ រឿងពុទ្ធប្រវត្តិ ទឹងគ្រឿងសក្ការបូជាយ៉ាង ។ ឡាវគួរជ្រះថ្លា ។

នៅគ្រប់ពេធ៌តាំងតូចតាំងធំ សុទ្ធតែមានលំអដោយបដាច្រៃនផ្ទាំងចារគុកពុទ្ធកាសិត ទឹងខេមរសុកាសិត ជាដំបូន្មានផ្សេង ។ ។

ដោយអំណាចគ្រឿងចក្រមេក្លើង មានខ្សែវែងអំពូលច្រៃនព័ណ៌ដែលពួកវិស្វករបានដាក់អំពូលក្លើងតាមសំយាបជុំវិញព្រះវិហារ ទឹងប្រទាក់ទៅគ្រប់ពេធ៌បុណ្យគ្មានសល់មួយអុជបំភ្លឺពាល់យប់, បរិយាកាសបុណ្យនេះក៏ភ្លឺរស្មីយដូចថ្ងៃ ។

បុណ្យនេះគេធ្វើ ៣ ថ្ងៃ ៣ យប់ គេនិមន្តព្រះសង្ឃពីវត្តផ្សេង ជាង ๔๐ វត្តមកជាបដិគ្គាហក ។ ដើម្បីឲ្យទានបានពេញជាសង្ឃទាន, ព្រះសង្ឃទាំងនោះ ។ ជាសកទាំង ๔ ក្រុមគេចាប់ស្លាកបានលោកអង្គណាគេនិមន្តលោកអង្គនោះទៅធាន់យាគូ ចង្ហាន់ ទឹងកេសជ្ជៈនៅពេធ៌គេ ។ ម៉ោង ๗ ព្រឹកពាល់ថ្ងៃ គេប្រគេនយាគូ, ម៉ោង ๑๑ ប្រគេនកត្តា, ម៉ោង ๓

រសៀលប្រគេនកេសជ្ជ:, ម៉ោង ៨ ល្ងាចរាល់រាត្រីគេជួបជុំគ្នាស្តាប់ព្រះបរិត្ត
នឹងធម៌ទេសនាក្នុងព្រះវិហារ ។ ការសូត្រព្រះបរិត្តក្តី ការសំដែងធម៌ក្តី
សុទ្ធតែប្រើទគ្ឆាសនស័ព្ទតាំងអស់ ។ រាត្រីទី ១ មានការសំដែងធម៌ ៣
លើក, លើកទី ១ ព្រះមុនីកោសល សោម - ឈុន អធិបតីរងក្រុមជំនុំព្រះ
ត្រៃបិដក, លើកទី ២ ព្រះធម្មិស្សរោ ឯក - ញឹម អតីតវិន័យធរអនុគណ
ស្រុកសូទ្រនិគម (សៀមរាប), លើកទី ៣ ព្រះសាសនមុនី មាស - កង
ចៅអធិការវត្តពិភទ្ធរង្សី ភ្នំពេញ ។ រាត្រីទី ២ សម្តេចព្រះមហាសុមេធា-
ធិបតីសង្ឆនាយកគណៈមហានិកាយ ។ ពីររាត្រីខាងដើម ជារាត្រីធម៌
ទេសនាសុទ្ធ ឥតមានល្បែងល្ឆាំលាយឡំទេ សូម្បីតែមានចាក់ថាស
ម៉ាស៊ីនខ្ទះដោយទគ្ឆាសនស័ព្ទ ក៏ប្រើតែថាសក្ទេងពិណពាទ្យនៅ
ពេលចប់ធម៌មួយលើកៗ ប៉ុណ្ណោះ ។ ដល់រាត្រីទី ៣ ក្រោយបំផុតនៃ
កិច្ចបុណ្យ ទើបជារាត្រីសមោសរសុទ្ធ ដោយមានក្រុមចម្រៀងអាយ៉ៃ
ពីភ្នំពេញទៅលេងកំសាន្តចិត្តញ្ញកយុរជន ។

លោកចៅអធិការ នឹងទបាសកចំណុះវត្ត បានព្រមព្រៀងគ្នាផ្ទុក
ផ្តាក់ឲ្យខ្ញុំ (ចាប - ពិន នាយការិយាល័យនៃក្រុមជំនុំទំនៀមទម្ទាប់ខ្មែរ
នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ) ជាអ្នកចាត់របៀបបុណ្យនេះ ព្រោះ
ស្រុកនេះជាមាតុភូមិរបស់ខ្ញុំ ។

របៀបបុណ្យនេះ មានកិច្ចទទួលសម្តេចព្រះមហាសុមេធាធិបតី
សង្ឆនាយក ជាកិច្ចដ៏ទទ្បាវិក ដូចរៀបរាប់តទៅនេះ :

ដោយសម្តេចបានណាត់រៀបថា នឹងនិមន្តមកដល់វត្តអន្ទង់សនៅ
ម៉ោងជាង ១១ ព្រឹកនៃថ្ងៃទី ៩ មីនា ១៩៥៥, ការចាត់រៀបទទួលក៏បាន
ផ្តើមធ្វើឡើងតាំងពីមុនម៉ោង ១១ ដោយរបៀបដូច្នេះ គឺ

ពីត្រឹមទ្វាររបងវត្តភាគខាងត្បូង ទៅលើនឹងជណ្តើរមុខព្រះវិហារ
ចម្ងាយជិតរយម៉ែត្រ មានពុទ្ធបរិស័ទឈរជាពីរជួរអមផ្លូវរថយន្តសម្តេច ។
ជួរខាងកើតបែរមុខទៅលិច : ពួកសិស្សសាហបថមសិក្សាច្រើនរយនាក់
ប្រុស។ ខាងត្បូង ស្រី។ ខាងជើង ដៃកាន់ទង់ជាតិ ទង់សាសនា ។ ជួរ
ខាងលិចបែរមុខទៅកើត : ខាងត្បូង កិកុ សាមណេរ, ខាងជើង ឧបាសក
ឧបាសិកាអ្នកការសក់ស្លៀកសពាក់សឈរជួរមុខ, អ្នកស្លៀកពាក់ព័ណ៌
ផ្សេងៗ ឈរជួរក្រោយ យ៉ាងណែនណាន់តាន់តាប់ ។ ម៉ោង ១១
កន្លះ សម្តេចមកដល់ ។ កាលរថយន្តចូលដល់ទ្វារវត្ត ទាំងបព្វជិត
ទាំងគហស្ថ លើកហត្ថប្រណម្យដោយស្ងប់រៀបរយ, លុះរថយន្តបើក
សន្សឹមៗ ចូលទៅ ខ្ញុំឈរលើវេទិកានៅយ៉ាងមុខព្រះវិហារ ប្រកាស
ដោយឧគ្ឃោសនស័ព្ទថា "ជយោ! ព្រះពុទ្ធសាសនា, ជយោ!
សម្តេចព្រះមហាសុមេធាធិបតី, ជយោ! សម្តេចព្រះសង្ឃនាយក;
(ផ្លូវ។) ត្រាតែរថយន្តដល់ដើងជណ្តើរព្រះវិហារទើបឈប់ ។ កាល
សម្តេចនិមន្តចុះពីរថយន្តឡើងតាមជណ្តើរព្រះវិហារ, កុមារី ៦ នាក់
ឈរអមក្បាលជណ្តើរ ដៃកាន់ពានផ្កាដើរចាចបុប្ផជាតលើកម្រាលព័ណ៌
ក្រហមផ្លៅ នាំផ្លូវសម្តេចតម្រង់ទៅកើយខាងមុខព្រះវិហារ និមន្ត
សម្តេចឡើងគង់លើវេទិកា, កាលសម្តេចឡើងគង់ហើយមានថេរ-

ដីកាថា "អាត្មាមានអំណរយ៉ាងជ្រាលជ្រៅចំពោះបដិសន្ទារកិច្ចដែលអស់លោក-អ្នកបានធ្វើចំពោះអាត្មានេះ, សូមឲ្យលោក អ្នកបានប្រកបដោយអាយុ វណ្ណ: សុខ: ពល: ព្រមទាំងសិរីសួស្តីគ្រប់យ៉ាង; ដោយពេលនេះខ្ញីពេក អាត្មាសូមធ្វើតសំណេះសំណាលបន្ទិចចំពោះតែពួកកុមារាកុមារី ដោយយើញថាក្មេងតូច ៗ មានពេលមកប្រជុំជួបេះតិចណាស់ ពេលរត់លេងប្រើន ៗ អ្នកនាងទាំងឡាយ! អាត្មាមានអំណរណាស់ដែលអ្នកនាងបាននាំគ្នាមកសិក្សាវិជ្ជាអក្សរសាស្ត្រនេះ ចូរអ្នកនាងខំយកចិត្តទុកដាក់រៀនសូត្រឲ្យចេះដឹងទាំងផ្ទូវលោកផ្ទូវធម៌យ៉ាងមាំមួនទាន់ខ្ជួននៅក្មេង ដើម្បីយកវិជ្ជានេះទៅប្រកបជីវភាពនៅវេលាខ្ជួនធំឡើង ឲ្យបានចម្រើនខ្ជួននឹងប្រទេសជាតិ, សព្វថ្ងៃនេះប្រទេសកម្ពុជាបានឯករាជ្យពេញទីហើយ ត្រូវការអ្នកមានចំណេះវិជ្ជាណាស់ ព្រោះចំណេះវិជ្ជានេះហើយដែលអាចញ្ចាំងអនាគតនៃប្រទេសជាតិឲ្យរុងរឿងតទៅ" ៗ

កាលចប់ថេរដីកាសម្តេច, ពួកកុមារាកុមារីទាំងនោះបានប្រៀងប្រគេនពរដោយទំនុក ថា:

ខ្ញុំករុណា ទាំងឡាយលើកដៃប្រណម្យ
ឧនថ្វាយបង្គំសម្តេចអគ្គមហាបណ្ឌិត
ដែលគេស្រប់ស្រែងពេកពិត
ប្រគេនពរប្រសិទ្ធ, ជាមហាបណ្ឌិតនៃកម្ពុជា (ផ្ទួន) ៗ

សូមអានុភាពនៃត្រៃរតនា
ដ៏ខ្ជាំងក្លាទ្រទ្រង់ឲ្យបានត្រកាល

ទាំងទេពកុងចក្រវាឡ

សូមជួយអកិបាល, ឲ្យសព្វៗកាលកុំមើលបណ្ដាំ (ផ្ទួន) ។

សូមសម្តេចមានព្រះជន្មយូរឆ្នាំ

ដើម្បីឧបត្ថម្ភព្រះពុទ្ធសាសនា

ជាម្ចប់នៃជាតិទេមក

ឲ្យរុងរឿងអស្ចារ្យ នឹងមហាក្សត្រាគ្រប់គ្រងផែនដី (ផ្ទួន) ។

សាមគ្គីសមគ្គាជាប្រពៃ

ទ្វៃរទាំងប្រុសស្រីត្រូវតែចងចាំទុក

ប្រទេសជាតិនឹងបានសុខ

បានចំរើនទៅមុខ, យើងត្រូវចាំទុកនូវធមិសាមគ្គី (ផ្ទួន) ។

បន្ទាប់ពីនេះនិមន្តសម្តេចទៅធាន់ ។ រៀលាម៉ោង ៨ យប់ថ្ងៃនោះ ក្រោយពេលសូត្រព្រះបរិត្ត និមន្តសម្តេចឡើងគង់លើធម្មាសនៈត្រង់យ៉ ខាងមុខព្រះវិហារសំដែង ធមិទេសនា មុននឹងសំដែង ឱ្យបានថ្ងៃង សុន្ទរកថា មានសេចក្តីដូចតទៅនេះ :

– សូមឧកាសសម្តេច,

– ព្រះករុណាគ្រប់ព្រះអង្គ,

– អស់លោក-អ្នកសប្បុរសទាំងឡាយ,

ដើម្បីថ្ងៃងប្រវត្តិវត្តនេះ នឹងពិធីបុណ្យនេះ ដូចតទៅ:

វត្តនេះ ផ្តើមសាងឡើងក្នុងរវាង ព.ស. ២៤៩០ ឡាយ គិតមកដល់ឆ្នាំនេះ ប្រមាណជា ៤០ ឡាយឆ្នាំ, នាមដែលត្រាទុកក្នុងផ្ទូវការថា

"វត្តសិរីបទុម" ប្រែថា "វត្តមានឈូកដ៏មានសិរី" ដោយសន្ទត
តាមទីវត្តនេះភាគខាងជើង ដែលមានព្រែកមានទឹកខ្ជូបប្រាំងវស្សា មាន
ឈូកជុះពាសពេញ មានផ្ការផ្ទៃជានិច្ច, នាមក្រោផ្ទូវការថា "វត្តអន្ទង់ស"
តាមឈ្មោះទីកន្ទែងនេះ ព្រោះមុនពេលសាងវត្តនេះ នៅមាត់ព្រែកជ្រុង
ឦសានវត្ត មានឈើធំមួយដើមជាឈើអ្នកស្រុកតែងបូជា, មានជំណាល
ថា យប់មួយនោះ ជនម្នាក់យល់សប្តិឃើញតាចាស់ម្នាក់ប្រាប់ថា "បើ
ចង់បានអន្ទង់ស ចូរទៅយកនៅព្រែកក្បែរដើមឈើនោះចុះ" ព្រឹកឡើង
ជននោះទៅនេសាទក្នុងទីនោះក៏បានអន្ទង់មួយមានសម្បុរសមែន, ក្រោយ
ពីនោះមកអ្នកស្រុកនាំគ្នាហៅទីនោះថា "អន្ទង់ស ៗ" រហូតដល់សព្វ
ថ្ងៃ ៗ កាលមិនទាន់មានរឿងទាក់ទងដោយអន្ទង់ស ភូមិជើងវត្តនេះដោយ
ហេតុមានដើមរកាមួយដើមធំកំបុតចុង គេហៅថា "ភូមិរកាកំបុត" ប៉ុន្តែ
ដោយឈ្មោះនេះជាទំនាស់នឹងជាតិចាមដែលនៅក្នុងភូមិនោះផង ដោយ
ទីនោះមានដើមពោធ៏ធំមួយដើមស្រុំតទៅក្នុងទន្ទេធំផង អ្នកស្រុកក៏ផ្ទាស់
ឈ្មោះរកាកំបុត ទៅជាភូមិពោធ៏ស្រុតវិញ, ហើយដោយពាក្យថាពោធ៏
ស្រុតជាទំនាស់នឹងអធ្យាស្រ័យខ្មែរ ក៏ត្រឡប់ជាបាត់ឈ្មោះនោះទៅ
កើតឈ្មោះថា "អន្ទង់ស" ឡើងជាឈ្មោះភូមិជើងវត្តនេះទាំងមូល តាម
ប្រផ្នូលជូចពោលខាងដើម តាំងពីពេលសាងវត្តនេះរហូតដល់សព្វថ្ងៃ ៗ

វត្តនេះ តាំងពីផ្តើមសាង រវាងពី ព.ស. ២៤៥០ ឆ្នាយ មកដល់
ព.ស. ២៤៩៧ នេះមានចៅអធិការ ៣ រូប គឺ

- ចៅអធិការទី ១ ព្រះនាម សូរ-គឺម ដែលលោកត្រូបណ្ឌិតឯក

នឹងលោកគក្តីវិជ្ជាសុខ ជាអ្នកផ្តើមសាងវត្តនេះបាននិមន្តពីវត្តអូរឲ្យាប់ស្រុក
ស្រីសុន្ធរមក ។ លោកគ្រូអង្គនេះបានផ្តើមសាងព្រះវិហារនេះដោយ
គ្រឿងឈើជញ្ជាំងប្រទាំ នឹងកុដិសាលាខ្ទះ ហើយលោកសុគតទៅ ;

- ចៅអធិការទី ២ ព្រះនាម អ៊ុក-នឹម លោកបានសាងកុដិសាលា
បន្ទៃមជាច្រើន ជាមួយខ្ទុំព្រះករុណាខ្ទុំបាទ (ចាប-ពិន) កាលនៅជា
បព្ទជិត ដែលបានសាងសាលាបាលីរងមួយខ្នង មានជាន់ពីរដោយឥដ្ឋ
បានជួយបង្ហើយសាលាបឋមសិក្សាមួយខ្នង មានជាន់មួយដោយឥដ្ឋ បាន
ក្រាលឥដ្ឋពណិព្រះវិហារនេះ ។ ល ។ នឹងជាមួយព្រះធម្មិស្សរោ ឯក-ញឹម
ដែលបានសាងកុដិមួយខ្នង នឹងទីផ្ទើសមាធិ ហើយលោកគ្រូ អ៊ុក នឹម
ចាកសិក្ខាបទទៅ ;

- ចៅអធិការទី ៣ ព្រះនាម សម្រិទ្ធី ជាចៅអធិការបច្ចុប្បន្ន
បានសាងជញ្ជាំងព្រះវិហារជាថ្មី មានយ៉ ៤ ទិស នឹងខឿនព្រះវិហារ
ដោយឥដ្ឋនឹងបេតុងអារម៉ៃ ដោយចែកមុខឲ្យទបាសកអ្នកមានសទ្ធាម្នាក់ៗ
ផ្ទើតាមល្ទែងតាមជ្ជាំង ព្រមទាំងគូរគំនូររឿងពុទ្ធប្រវត្តិយ៉ាងល្អ សឹងមាន
ចាវិកឈ្មោះអ្នកសាងគ្រប់គ្នាក្នុងទីនោះៗ ស្រាប់ ព្រមទាំងបានសាងសាលា
ធម្មសភា សាលាបឋមសិក្សាដោយគ្រឿងឈើ ។ ល ។ ដែលសារុប
ផ្ទើបុណ្យសម្ពោធក្នុងវេលានេះ ។

ករណីយកិច្ចដែលលោកចៅអធិការទី ៣ បានផ្ទើឲ្យវត្តនេះបានចម្រើន
មានច្រើនបែប, បែបដែលប្ទែកពីវត្តធម្មតា គឺលោកបានផ្ទើរបងវត្ត
ដោយដាំដើមយុទ្ធថ្ការ មានបន្ទាចាក់ស្រែះជិតស្ទិទ្ធជុំវិញវត្ត មានទ្វារ

ចាក់ស្រាវ សម្ស៊ីតែភិក្ខុ សាមណេរ ឬ ឧបាសកដើងវត្ត តែហ្លួសពេល
ម៉ោងមិនអាចបេញចូលរហេតរហូតបាន ។ ល ។

ឧបាសកដើងវត្តជ្រះថ្លា ចំពោះការណីយកិច្ចរបស់ហេកចៅអធិការ
នេះ បានចំណាយធនធានកសាងវត្ត នេះតាមកម្លាំងសទ្ធារៀងខ្លួន
ហើយបានធ្វើបុណ្យសម្ពោធនេះជាការបន្ទែមបុណ្យឡើងទៀត ។

បុណ្យនេះ ដោយសារសម្តេចនឹងព្រះករុណាគ្រប់អង្ត ព្រមទាំង
អស់លោក អ្នកសប្ប្យុរសនៅស្រុកជិតឆ្ងាយបាននិមន្ត បានអញ្ជើញមក
ជាអធិបតី មកជួយអនុមោទនាផង ក៏បានជាបុណ្យឧឡារិកអធិកអធំគួរ
ជ្រះថ្លាកៃពេក ។

ក្នុងនាមឧបាសកដើងវត្តនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រគេន
សូមជូនពរស័ព្ទសាធុការ ចំពោះសម្តេច, ព្រះករុណាគ្រប់អង្ត នឹង
អស់លោក-អ្នកសប្ប្យុរស សូមឲ្យបានប្រកបដោយអាយុ វណ្ណ: សុខ:
ពល: នឹងសិរីសួស្តីជ័យមង្គលគ្រប់ប្រការ សព្វទិវារាត្រីកុំបីមាន
ចន្ទោះឡើយ !

បន្ទាប់ពីសុន្ទរកថា ខ្ញុំអារាធនាសម្តេចសំដែងធម៌សមគួរតាមកាល
វេលា ។ រាត្រីនោះក៏មានបរិយាកាសរីករាយយ៉ាងកៃលែង ។

ព្រឹកឡើងថ្ងៃ ២ រោច ផល្គុន (១០ មីនា ១៩៥៥) និមន្ត
ព្រះសង្ឆជារឆ្ងង ជាកិច្ចបង្ហើយបុណ្យត្រឹមប៉ុណ្ណេះ ។